សាកលវិទ្យាល័យភូមិន្ទកសិកម្ម
មហាវិទ្យាល័យ សេដ្ឋកិច្ចកសិកម្ម និង អភិវឌ្ឍន៍ជនបទ

# ធនាគារកណ្ដាល និង គោលនយោបាយរូបិយវត្ថុ

# THE CENTRAL BANK AND MONETARY POLICY




បណ្ឌិត សឹន សុទ្ធ
សាស្ត្រាចារ្យរងបណ្ឌិត ឆាយ គន្ធា

ឧបត្ថម្ភដោយ

CAMBODIA

២០២១

សាកលវិទ្យាល័យភូមិន្ទកសិកម្ម
មហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និង អភិវឌ្ឍន៍ជនបទ

# ធនាគារកណ្តាល និង គោលនយោបាយរូបិយវត្ថុ
# The Central Bank and Monetary Policy

បណ្ឌិត សឹន សុទ្ធ
សាស្ត្រាចារ្យរងបណ្ឌិត ឆាយ គន្ធា

២០២១

# រក្សាសិទ្ធ

© ឆ្នាំ ២០២១
**រក្សាសិទ្ធគ្រប់យ៉ាង**
គ្មានផ្នែកណាមួយនៃសៀវភៅនេះ អាចត្រូវបានថតចម្លង និងផលិតឡើងវិញ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នកនិពន្ធ និងសាកលវិទ្យាល័យភូមិន្ទកសិកម្ម។

បោះពុម្ពលើកទី១ ដោយមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំយុវជន និងកីឡា នៅព្រះរាជាណាចក្រកម្ពុជា

**ទំនាក់ទំនងព័ត៌មាន:**

អ្នកនិពន្ធ៖ បណ្ឌិត សឺន សុទ្ធ
ទូរស័ព្ទ៖ (+៨៥៥) ១២ ៧៨៨ ៩៧៧/(+៨៥៥) ៩៨ ៧៨៨ ៩៧៧
អ៊ីមែល៖ sonvisoth@gmail.com/webpage៖ economicstreet

©. 2021, Son Soth, Ph.D. All rights reserved. No part of this publication may be reproduced, stored in a retrieval system, or transmitted by any process without the prior written permission from the author and the Royal University of Agriculture.

First Edition
Printed by the Research Creativity and Innovation Fund (RCI Fund) of Ministry of Education, Youth and Sport, the Kingdom of Cambodia

Enquiries about the book:

Author: Dr. Son soth
Mobile phone: +855 98 788 977 / +855 12 788 977
Email: sonvisoth@gmail.com/webpage: economicstreet

# មុខកថា

ដំណើរអភិវឌ្ឍនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងយុគសម័យទំនើបនេះ ជាមេរៀនដ៏ជោគជ័យបំផុតមួយ ដែលចាប់ឫសគល់ចេញពីការបញ្ចប់របបប្រល័យពូជសាសន៍ ការបញ្ចប់សង្គ្រាម ការផ្សះផ្សាជាតិ ការកសាងមូលដ្ឋានរឹងមាំនៃសន្តិភាពនិងស្ថេរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច។ នៅក្រោយពេលដែលសន្តិភាពត្រូវបានកើតឡើងដោយបរិបូរណ៍នៅឆ្នាំ១៩៩៨ កម្ពុជាទទួលកំណើនសេដ្ឋកិច្ចខ្ពស់ គឺប្រមាណ៨% ក្នុងមួយឆ្នាំ។ លើសពីនេះទៀត អត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយពីប្រមាណ៥៣% នៅឆ្នាំ២០០៤ មកនៅទាបជាង១០% នៅឆ្នាំ២០១៩។ ដំណើរនៃការអភិវឌ្ឍជាតិជាសកម្មភាពដែលបន្តទៅមុខជាប់ជានិច្ច ហើយគោលនយោបាយថ្មីៗដែលមានលក្ខណៈអន្តរវិស័យគ្រប់ដណ្តប់ក៏កំពុងលេចរូបរាងឡើង ដើម្បីតម្រង់ទិសកម្ពុជាឆ្ពោះទៅកាន់ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងឈានឡើងជាប្រទេសមានប្រាក់ចំណូលខ្ពស់ នៅឆ្នាំ២០៥០។ ការប្រែប្រួលឆាប់រហ័សនៃនិម្មាបនកម្មពិភពលោកនិងតំបន់ រួមទាំងទំនាក់ទំនងភូមិសាស្ត្រនយោបាយ បានផ្តល់កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា ដែលត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងបន្តពង្រឹងនិងអភិវឌ្ឍវិស័យអប់រំឆ្ពោះទៅរកការស្រាវជ្រាវនិងនវានុវត្តន៍ ដើម្បីពង្រឹងសមត្ថភាពនិងជំនាញរបស់ធនធានមនុស្សនៅកម្ពុជា ឱ្យស្របទៅនឹងបរិបទថ្មីនៃការអភិវឌ្ឍ ជាពិសេសការពង្រឹងសហគ្រិនភាពក្នុងការរៀបចំម៉ូដែលធុរកិច្ចថ្មីៗ។ ដើម្បីចាប់យកកាលានុវត្តភាពពីបដិវត្តន៍ឧស្សាហកម្មទី៤ និងសេដ្ឋកិច្ចឌីជីថលដែលកំពុងផុសផុលឡើង ប្រព័ន្ធអេកូឡូស៊ីដែលបង្កលក្ខណៈអំណោយផលដល់ការបង្កើតថ្មី នវានុវត្តន៍ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ត្រូវតែមានការកែលម្អ។

បណ្តាប្រទេសនៅទ្វីបអាស៊ីកំពុងនាំមុខក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ដោយមានភាគហ៊ុនប្រមាណ៤៤% នៃការវិនិយោគទាំងមូលរបស់ពិភពលោក។ ប្រទេសចិនកំពុងបន្តកសាងហេដ្ឋារចនាសម្ព័ន្ធនៃការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ក៏ដូចជាសមត្ថភាពមនុស្ស។ ផ្ទុយទៅវិញ ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក កំពុងស្ថិតនៅឆ្ងាយពីការវិនិយោគនេះ ហើយជាលទ្ធផល ប្រទេសទាំងនោះក៏ពុំមានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ដែរ។ ទុនវិនិយោគសរុបលើការស្រាវជ្រាវនិងអភិវឌ្ឍរបស់ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក មានប្រមាណ៥%នៃការវិនិយោគទាំងមូលរបស់ពិភពលោក ក្នុងពេលដែលតំបន់ទាំង២នេះមានប្រជាជនប្រមាណ២០%នៃប្រជាជនពិភពលោក។ ប្រទេសចំនួន៦ដែលមានលំដាប់ខ្ពស់ជាងគេនៅក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ រួមមានសហរដ្ឋអាមេរិក ចិន ជប៉ុន អាល្លឺម៉ង់ ឥណ្ឌា និងកូរ៉េខាងត្បូង ដែលស្មើនឹងប្រមាណ៧០%នៃទុនវិនិយោគសរុបរបស់ពិភពលោក។

តើចំណេះដឹង ផលិតផល និងសេវាកម្មថ្មីទាំងនេះកើតឡើងពីអ្វី? ហើយកើតឡើងដោយរបៀបណា? ព្រះរាជាណាចក្រកម្ពុជាកំពុងតែកសាងមូលដ្ឋានសម្រាប់ការត្រៀមខ្លួនទទួល និងប្រកួតប្រជែងក្នុងយុគសម័យបដិវត្តឧស្សាហកម្មទី៤ នៅក្នុងសេដ្ឋកិច្ចដែលផ្អែកលើពុទ្ធិ ហើយដែលប្រការនេះ

ចាំបាច់តម្រូវឱ្យពលរដ្ឋកម្ពុជា ត្រូវក្លាយខ្លួនជាពលរដ្ឋឌីជីថល ពលរដ្ឋសកល និងពលរដ្ឋដែលប្រកបដោយការទទួលខុសត្រូវ ដែលមានសមត្ថភាពក្នុងការផលិត ចែកចាយ និងប្រើប្រាស់ពុទ្ធិដើម្បីទទួលមនុញ្ញផល និងរួមចំណែកក្នុងកំណើន។ ធនាគារពិភពលោកបានធ្វើការកត់សម្គាល់តាំងពីឆ្នាំ ២០០២នូវបម្លាស់ប្តូរនៃមូលដ្ឋានសេដ្ឋកិច្ច ពីសេដ្ឋកិច្ចដែលពឹងផ្អែកលើកម្លាំងពលកម្ម និងធនធានអតិកម្ម (Labour and Resource Based Economy) ទៅកាន់សេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិ (Knowledge Based-Economy) ដែលក្នុងន័យនេះ ពុទ្ធិគឺជាគន្លឹះនៃការអភិវឌ្ឍ។ អាស្រ័យហេតុនេះ នៅលើគន្លងដែលកម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅកាន់សេដ្ឋកិច្ចឌីជីថល សង្គមកម្ពុជាត្រូវតែមានសមត្ថភាពក្នុងការផលិត ជ្រើសរើស បន្សាំ បង្កើតមុខរបរ និងប្រើប្រាស់ពុទ្ធិ ដើម្បីរក្សានិរន្តរភាពនៃកំណើន និងកែលម្អជីវភាពរស់នៅ។ សមត្ថភាពទាំងនេះ អាចកើតឡើងនៅពេលពលរដ្ឋកម្ពុជាមានឱកាសក្នុងការទទួលបានបទពិសោធន៍ពីការស្រាវជ្រាវ ការបណ្តុះគំនិតច្នៃប្រឌិត និងការស្វែងរកនវានុវត្តន៍។

កំណែទម្រង់វិស័យអប់រំ គឺជាការត្រួសត្រាយមាគ៌ាសម្រាប់ដំណើរឆ្ពោះទៅកាន់សង្គមប្រកបដោយពុទ្ធិ និងប្រជាពលរដ្ឋប្រកបដោយភាពរស់រវើក។ តាមរយៈមូលដ្ឋានអប់រំ សង្គមប្រកបដោយពុទ្ធិនឹងប្រមូលផ្តុំ បង្កើត និងចែករំលែក ទៅកាន់សមាជិកក្នុងសង្គមនូវសម្បទាអប់រំ ពិសេសគឺពុទ្ធិសម្បទាក្នុងបុព្វហេតុនៃមនុស្សជាតិនិងឧត្តមប្រយោជន៍នៃប្រទេស។ សង្គមប្រកបដោយពុទ្ធិ គឺពុំគ្រាន់តែជាសង្គមដែលសម្បូរព័ត៌មានប៉ុណ្ណោះទេ តែជាសង្គមដែលប្រជាពលរដ្ឋអាចធ្វើបរិវត្តកម្មពីព័ត៌មានទៅជាមូលធនប្រកបដោយប្រសិទ្ធភាព។ ការរីកចម្រើនទៅមុខជាលំដាប់នៃបច្ចេកវិទ្យានិងតំណភ្ជាប់ បានពង្រីកព្រំដែននៃការចូលទៅកាន់ និងការទទួលបានព័ត៌មានជាសកល ហើយដែលក្នុងន័យនេះ ការអប់រំនឹងបន្តវិវត្តទៅមុខនិងមានការផ្លាស់ប្តូរ។ សង្គមមួយដែលមានអំណាន និងរាប់ជាបុរេលក្ខខណ្ឌនៃជីវភាពប្រចាំថ្ងៃនៃប្រជាពលរដ្ឋ ពេលនោះបំណិននៃអំណាន និពន្ធ និងការគណនាលេខនព្វន្ត គឺជាចលករនៃការរៀនរបស់សិស្ស។ ធាតុដ៏ចម្បងមួយដែលស្ថិតនៅក្នុងការកសាងសង្គមដែលប្រកបដោយពុទ្ធិគឺសៀវភៅសិក្សា ហើយការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សាជាប្រចាំ គឺជានវានុវត្តន៍នៃវិស័យអប់រំដែលនាំទៅរកការសិក្សាពេញមួយជីវិត ការអភិវឌ្ឍសម្បទាអប់រំ និងការចែករំលែកចំណេះដឹង។ មូលដ្ឋានអប់រំ ជាពិសេសគឺគ្រឹះស្ថានឧត្តមសិក្សាត្រូវមានតួនាទីដែលប្រកបដោយការឆ្លើយតប ចំពោះតម្រូវការខាងលើនេះ។ សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំត្រូវបន្តសិក្សាជាប់ជានិច្ច តាមរយៈការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ហើយដែលសៀវភៅសិក្សាទាំងនេះនឹងក្លាយជាស្ពាននៃទំនាក់ទំនងរវាងនវានុវត្តន៍នៃបច្ចេកវិទ្យា និងការរៀននិងបង្រៀននៅក្នុងថ្នាក់រៀន។

សង្គមដែលប្រកបពុទ្ធិ ក៏ជាសង្គមដែលបណ្តុះឱ្យមានរចនាសម្ព័ន្ធទន់នៃសេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិដែរ។ ឧទាហរណ៍ជាក់ស្តែងនៃបែបផែននេះរួមមាន Silicon Valley នៃសហរដ្ឋអាមេរិក សួនឧស្សាហកម្មវិស្វកម្មអាកាសយានយន្តនិងយានយន្តនៅទីក្រុង Munich ប្រទេសអាល្លឺម៉ង់ តំបន់ជីវបច្ចេកវិទ្យានៅក្រុង Hyderabad ប្រទេសឥណ្ឌា តំបន់ផលិតគ្រឿងអេឡិចត្រូនិកនិងសារគមនាគមន៍ឌីជីថលនៅទីក្រុង Seoul ប្រទេសកូរេខាងត្បូង ក៏ដូចជាសួនឧស្សាហកម្មថាមពល និងឥន្ធនគីមីសាស្ត្រនៃប្រទេសប្រេស៊ីល ហើយក៏នៅមានទីក្រុងនៃប្រទេសជាច្រើនទៀតនៅលើពិភពលោក។ លក្ខណៈសម្បត្តិ

នៃទីក្រុងទាំងនេះគឺការប្រើប្រាស់និន្នាការនៃការអភិវឌ្ឍដែលជំរុញ និងតម្រង់ទិសដោយចំណេះដឹង ហើយដែលចំណេះដឹងទាំងនោះកើតចេញជាចំបូងពីការវិនិយោគទៅលើគ្រឹះស្ថានឧត្តមសិក្សា ស្ថាប័នស្រាវជ្រាវ មជ្ឈមណ្ឌលឧត្តមភាពនៃជំនាញជាន់ខ្ពស់ ការប្រកួតប្រជែងដោយគុណាធិបតេយ្យ និងជាពិសេសគឺការបណ្ដុះវប្បធម៌អំណាននិងនិពន្ធសៀវភៅ។ ល្បឿននៃការរីកចម្រើនផ្នែកពុទ្ធិ និងបច្ចេកវិទ្យាកំពុងមានសន្ទុះលឿនជាងអ្វីដែលសិស្ស និងនិស្សិតអាចទទួលបានពីគ្រូនៅគ្រឹះស្ថានសិក្សា ដែលធ្វើឱ្យគោលដៅនៃការអប់រំនៅពេលបច្ចុប្បន្ននេះ មានការប្រឈមខ្លាំងជាងពេលណាទាំងអស់។ ឧទាហរណ៍ ក្នុងមួយឆ្នាំ មានសៀវភៅជាង២,២លានចំណងជើង ត្រូវបានសរសេរនិងបោះពុម្ព ដែលក្នុងនោះប្រទេសចិនមាន៤៤០ពាន់ ចំណែកឯសហរដ្ឋអាមេរិកមាន៣០៥ពាន់ និងប្រទេសរុស្ស៊ីមាន១២០ពាន់ចំណងជើង។

ខណៈពេលដែលបច្ចេកវិទ្យាកំពុងរីកចម្រើនជារៀងរាល់ថ្ងៃ មធ្យោបាយសម្រាប់អំណានក៏មានច្រើនជម្រើសសម្រាប់សិស្ស-និស្សិត និងសាធារណៈជន រួមមានការអានសៀវភៅ ការអានលើឧបករណ៍អេឡិចត្រូនិក ការអានដោយប្រើទូរសព្ទឆ្លាត និងការអានលើកុំព្យូទ័រ ដែលសុទ្ធសឹងជាមធ្យោបាយសំខាន់ៗដែលនាំអ្នកអានទាំងឡាយឱ្យសម្រេចគោលបំណងអានរបស់ខ្លួន។ម្យ៉ាងវិញទៀត អំណានដោយប្រើមធ្យោបាយបច្ចេកវិទ្យាទំនើប ចំណាយពេលតិច ងាយស្រួលអាន និងជួយដល់បរិស្ថានមួយកម្រិតទៀត។ នាពេលបច្ចុប្បន្ន សិស្ស-និស្សិត និងសាធារណៈជនកម្ពុជាដែលស្រឡាញ់អំណានកំពុងតែប្រើប្រាស់មធ្យោបាយអំណានទាំងនេះ។ បើយើងក្រឡេកមើលទៅប្រទេសជឿនលឿន ទោះបីជាបច្ចេកវិទ្យារីកចម្រើនខ្លាំងយ៉ាងណា អំណានតាមរយៈសៀវភៅនៅតែមានសន្ទុះដដែល។ ម្យ៉ាងវិញទៀត បច្ចេកវិទ្យាអានបែបទំនើបតាមរយៈឧបករណ៍ទំនើប អាស្រ័យលើលទ្ធភាពនៃធនធានអប់រំឌីជីថល និងមាតិកាឌីជីថលគ្រប់គ្រាន់ដែលបានផលិត និងបង្ហោះចែកចាយសម្រាប់អំណាន។

ក្នុងបរិបទកម្ពុជា ជាពិសេសក្នុងបរិការណ៍នៃការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញឱ្យមានបរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្តែមនៃការអប់រំ ជាពិសេសការអប់រំតាមប្រព័ន្ធអេឡិចត្រូនិកនិងការអប់រំពីចម្ងាយ ដើម្បីលើកកម្ពស់អំណាន តាមរយៈការផលិតមាតិកាឌីជីថលដែលមានភាពចំរុះ ការកសាងសមត្ថភាពផ្នែកតំណភ្ជាប់និងវេទិកាឌីជីថល ការពង្រីកវិសាលភាពនៃមជ្ឈមណ្ឌលទិន្នន័យ និងការលើកកម្ពស់គុណភាពនៃការផលិតធនធានអប់រំឌីជីថល គួបផ្សំជាមួយការចែកសន្លឹកកិច្ចការឱ្យសិស្សយកទៅរៀននៅផ្ទះ និងការចុះទៅជួបជាមួយសិស្សជាបណ្ដុំនៅតាមសហគមន៍។ ក្នុងន័យលើកកម្ពស់អំណាន និងភាពសម្បូរបែបនៃធនធានសៀវភៅសិក្សា ឱ្យកាន់តែមានប្រសិទ្ធភាពនិងភាពសក្តិសិទ្ធិ និងផ្តល់ឱកាសអំណានកាន់តែច្រើនថែមទៀតដល់សិស្សានុសិស្ស និស្សិត និងសាធារណៈជន ក្រសួងអប់រំ យុវជន និងកីឡាលើកទឹកចិត្តនូវចំណុចមួយចំនួនដូចខាងក្រោម៖

១. សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំ សូមបន្តនិងបង្កើនការបោះពុម្ពស្នាដៃបន្ថែមទៀត ដើម្បីធ្វើឱ្យធនធានសម្រាប់អំណានកាន់តែសម្បូរបែប ជាពិសេសធនធានអំណានជាខេមរភាសា

២. គ្រឹះស្ថានឧត្តមសិក្សា សូមផ្ដល់លទ្ធភាពគ្រប់បែបយ៉ាង ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និងនិស្សិតគ្រប់កម្រិតសិក្សាអាចចូលរួមអាន និងសិក្សាស្រាវជ្រាវតាមគ្រប់លទ្ធភាពជាមួយធនធានអំណាន ជាពិសេសការរៀបចំឱ្យមានពេលវេលាសម្រាប់សហសិក្សា និងអំណានក្នុងបណ្ណាល័យ

៣. សាស្ត្រាចារ្យតាមមុខវិជ្ជា និងអ្នកស្រាវជ្រាវតាមជំនាញឬវិស័យ ត្រូវរៀបចំដំណើរការរៀនបង្រៀន និងស្រាវជ្រាវដែលមានដាក់បញ្ចូលកិច្ចការស្វ័យសិក្សា សហសិក្សា ឬការស្រាវជ្រាវបណ្ណាល័យដែលតម្រូវឱ្យនិស្សិត ត្រូវអាននិងស្រាវជ្រាវជាមួយធនធានអំណាន

៤. គ្រឹះស្ថានឧត្តមសិក្សា និងមជ្ឈមណ្ឌលស្រាវជ្រាវ ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការបង្កើតបណ្ណាល័យ មជ្ឈមណ្ឌលរក្សាឯកសារ ឬមជ្ឈមណ្ឌលអប់រំឌីជីថលជាដើម ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់និងនិស្សិតគ្រប់កម្រិតសិក្សាអាចទទួលបាន និងស្វែងរកប្រភពសម្រាប់អំណានកាន់តែសម្បូរបែប និងមានភាពបត់បែន ឆ្លើយតបតាមតម្រូវការអ្នកអាន

៥. និស្សិតគ្រប់កម្រិតសិក្សាត្រូវខិតខំនិងចំណាយពេលវេលាដើម្បីអាន និងចាត់ទុកវប្បធម៌និងអកប្បកិរិយាអំណានជាផ្នែកមួយ នៃពេលវេលានិងភាពស៊ីវិល័យនៃជីវិតប្រចាំថ្ងៃ

៦. បងប្អូនជនរួមជាតិ ដែលជាមាតាបិតា ឬអ្នកអាណាព្យាបាល សូមជួយជំរុញនិងបង្កលក្ខណៈកាន់តែច្រើនថែមទៀត ជាពិសេសការលែលកចំណាយនៅក្នុងគ្រួសារសម្រាប់ការទិញសម្ភារៈសិក្សា សៀវភៅអាន និងឧបករណ៍សម្រាប់អំណានដល់កូនៗ ដែលចាត់ទុកជាការវិនិយោគមួយដ៏សំខាន់ សម្រាប់ បង្កើនចំណេះដឹង និងអនាគតរបស់ពួកគេ។

ដោយមានការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលហៅកាត់ថា "មូលនិធិ ស.គ.ន." និងហៅជាភាសាអង់គ្លេសថា The Research Creativity and Innovation Fund ដែលហៅកាត់ជាភាសាអង់គ្លេសថា "RCI Fund"។ គោលដៅចម្បងនៃមូលនិធិនេះ គឺរួមចំណែកលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្ត ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ យុវជន និងកីឡា ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងសាកលភាវូបនីយកម្ម។ មូលនិធិ ស.គ.ន. បានសម្រេចកំណត់ប្រធានបទ ជាអាទិភាពសម្រាប់ការគាំទ្រដោយមូលនិធិចំនួន៣ រួមមានឌីជីថលនីយកម្មសម្រាប់បដិវត្តឧស្សាហកម្ម៤.០ (Digitalization for IR.4.0) ការស្រាវជ្រាវអនុវត្តលើវិស័យកសិកម្ម (Applied Agricultural Research) និងការស្រាវជ្រាវគរុកោសល្យសតវត្សទី២១ (21st Century Pedagogy Research)។

ដោយមានការធ្វើអាទិភាពូបនីយកម្មទៅលើទិសដៅ នៃការប្រើប្រាស់ថវិកាមូលនិធិសម្រាប់ឆ្នាំ ២០២០ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា បានផ្ដល់ការគាំទ្រដល់ការ **រៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សា (Text book) ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា**។ គោលបំណងនៃការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា គឺដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រីកសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូនដល់និស្សិត

ដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ លើសពីនេះទៀត ការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា មានគោលដៅដូចខាងក្រោម ៖

១. ឆ្លើយតបជាបន្ទាន់ចំពោះការខ្វះខាតធនធានសិក្សា ដែលជាតម្រូវការសិក្សារបស់និស្សិតនៅកម្រិតឧត្តមសិក្សា

២. លើកកម្ពស់ទំនើបកាវូបនីយកម្ម និងឧត្តមានុវត្តន៍នៃការរៀននិងបង្រៀន និងការស្រាវជ្រាវនៅលើមុខវិជ្ជា កម្មវិធីសិក្សា ឬមុខជំនាញជាក់លាក់

៣. បង្កើនភាពស៊ីជម្រៅក្នុងការកសាងវិជ្ជាជីវៈនិងបទពិសោធន៍សម្រាប់ឋានៈសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ

៤. រួមចំណែកដល់ការកសាងភាពជាសហគមន៍វិជ្ជាជីវៈ ការចែករំលែកបទពិសោធន៍ និងវប្បធម៌នៃការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា បានវាយតម្លៃខ្ពស់ចំពោះការបោះជំហានប្រកបដោយមនសិការវិជ្ជាជីវៈនៃគ្រឹះស្ថានឧត្តមសិក្សា និងបុគ្គលិកអប់រំទាំងអស់ ក្នុងការរៀបចំ រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រឹងសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូននិស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សាជាផ្នែកមួយនៃការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានឧត្តមសិក្សា និងជាធនធានសិក្សាដែលជាមូលដ្ឋានមួយដ៏សំខាន់ ក្នុងការគាំទ្រដល់ការបង្រៀន និងរៀន ហើយត្រូវមានបរិមាណគ្រប់គ្រាន់ ឆ្លើយតបទៅនឹងកម្មវិធីអប់រំ និងតម្រូវការសិក្សាស្រាវជ្រាវ។ ជាគោលការណ៍ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ត្រូវមានសៀវភៅសិក្សាដែលប្រើជាគោលសម្រាប់មុខវិជ្ជានីមួយៗ។ ចំនួនសៀវភៅសិក្សាដែលគ្រប់គ្រាន់សម្រាប់ការស្រាវជ្រាវ និងការសិក្សារបស់និស្សិត ត្រូវមានយ៉ាងតិចមួយចំណងជើងក្នុងមួយមុខវិជ្ជា ហើយត្រូវតម្កល់យ៉ាងតិច២ច្បាប់នៅក្នុងបណ្ណាល័យ ឬអាចរកបានតាមប្រព័ន្ធអេឡិចត្រូនិក។ ក្រសួងអប់រំ យុវជន និងកីឡា លើកទឹកចិត្តបន្ថែមទៀតជូនដល់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលបានស្នើសុំថវិកាមូលនិធិ ស.ត.ន រួច សូមចូលរួមបន្ថែមទៀតដើម្បីបង្កើនចំនួនចំណងជើងសៀវភៅ។ ចំណែកគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលពុំទាន់បានដាក់ពាក្យស្នើសុំថវិកាមូលនិធិ ដើម្បីរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា សូមស្រវាន់ចូលរួមដើម្បីជាគុណប្រយោជន៍ដល់តម្រូវការដ៏ទទូចនិងថ្លៃថ្លានៃនិស្សិតកម្ពុជាក្នុងការសិក្សា និងស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។

## សេចក្តីបញ្ជាក់
## នៃមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

សៀវភៅសិក្សានេះជាលទ្ធផលនៃការស្នើសុំអនុវត្តថវិកាមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ក្នុងគម្រោង**រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។** សៀវភៅសិក្សានេះ ត្រូវបានរៀបរៀង និពន្ធ ឬកែលម្អដោយមានការធានាអះអាងថាជាស្នាដៃរបស់អ្នកនិពន្ធផ្ទាល់ និងបានឆ្លងកាត់ត្រួតពិនិត្យ ផ្តល់យោបល់ និងវាយតម្លៃដោយក្រុមប្រឹក្សាអប់រំ ក្រុមប្រឹក្សាស្រាវជ្រាវ ឬក្រុមប្រឹក្សាដែលមានតម្លៃស្មើនៃគ្រឹះស្ថានឧត្តមសិក្សា និងតាមរយៈកិច្ចសន្យាដែលបានធ្វើឡើង និងដែលបានតម្កល់ទុកនៅមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍។ រាល់ខ្លឹមសារ ការបកស្រាយ ឬរូបភាព ដែលមាននៅក្នុងសៀវភៅនេះ គឺជាជំហរនិងទស្សនៈផ្ទាល់របស់អ្នកនិពន្ធ ហើយពុំឆ្លុះបញ្ចាំង ឬជាតំណាងដល់មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំ យុវជន និងកីឡាឡើយ។

# ឧទ្ទិសកថា

កូនសូមឧទ្ទិសនូវអំណរអរគុណយ៉ាងជ្រាលជ្រៅផងដែរ ចំពោះវិញ្ញាណក្ខន្ធ លោកឪពុក **ស៊ីន ណៃរ** ដែលបានផ្ដល់កំណើតឱ្យរូបកូន និងសតិបញ្ញា ភ្លឺថ្លា ឈ្លាសវៃ ដែលបានបីបាច់ថែរក្សារូបកូនកន្លងមក ជាពិសេសជាងនេះទៅទៀត ព្រមទាំងដីដូនជីតា បុព្វបុរសខ្មែរ អ្នកស្នេហាជាតិ ដែលបានបាត់បង់ជីវិត ដើម្បីបុព្វហេតុជាតិមាតុភូមិ និងអស់លោកអ្នកប្រាជ្ញ បណ្ឌិត កវី បញ្ញវន្ត អ្នកនិពន្ធខ្មែរ ដែលបានបន្សល់ទុកនូវស្នាដៃ និងបទពិសោធន៍ល្អៗជាច្រើនឥតគណនាដល់កូនខ្មែរជំនាន់ក្រោយបានសម្រាប់សិក្សាស្រាវជ្រាវ។

ខ្ញុំសូមបួងសួងឱ្យវិញ្ញាណក្ខន្ធអស់លោកទាំងអស់បានទៅកើតនៅក្នុងសុគតិភពដែលជួបប្រទះតែនឹងសេចក្ដីសុខ សេចក្ដីចម្រើន និងមានចំណេះវិជ្ជាខ្ពង់ខ្ពស់គ្រប់ៗជាតិ។

# សេចក្ដីថ្លែងអំណរគុណ

សៀវភៅ "ធនាគារកណ្ដាល និង គោលនយោបាយរូបិយវត្ថុ" នេះអាចប្រសូត្រចេញបានក៏ដោយសារតែមានការចូលរួម និងការផ្ដល់វិភាគទានយ៉ាងធំធេងពីបណ្ដាអ្នកវិទ្យាសាស្ត្រ និងឥស្សរជនដែលមានបទពិសោធន៍នៅក្នុងផ្នែកស្រាវជ្រាវកសិកម្មជាច្រើនរូប។

ខ្ញុំសូមថ្លែងអំណរគុណជាអនេកប្បការដល់ការពិនិត្យ និងផ្ដល់ជាមតិល្អៗក្នុងការរៀបចំសៀវភៅនេះដោយៈ

- ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ង៉ោ ប៊ុនថាន** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ក៏ដូចជាអង្គភាពសាមី( សាកលវិទ្យាល័យភូមិន្ទកសិកម្ម )
- ឯកឧត្តម **សាន វឌ្ឍនា** អនុរដ្ឋលេខាធិការនៃក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍
- សាស្ត្រាចារ្យរងបណ្ឌិត **ហួច ថាវរៈ** សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យភូមិន្ទសិកម្មកម្ម
- គណៈកម្មការត្រួតពិនិត្យមហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ និងគណៈកម្មការត្រួតពិនិត្យសាកលវិទ្យាល័យភូមិន្ទកសិកម្ម ដែលបានជួយជ្រោមជ្រែងក្នុងការស្រាវជ្រាវ
- គណៈកម្មការត្រួតពិនិត្យៈ លោកបណ្ឌិត ឆាំង ហ៊ុយ លោកបណ្ឌិត ម៉ក់ ពុទ្ធី លោកបណ្ឌិត លាប ប៉ូឡូ លោកបណ្ឌិត ហែម ឡាច លោកបណ្ឌិត វង្ស ឱណា លោក អេង លេង លោកស្រី ឆាយ ស្រីល័ក្ខ លោកស្រី ហ៊ូ ផល្លា និងលោកស្រី ឆាយ ស្រីមុំ
- អ្នកផ្ដល់យោបល់ ក៏ដូចជាអ្នកផ្ដល់ឯកសារយោងទាំងភាសាជាតិ និងភាសាបរទេសនានា
- ក្រុមគ្រួសារជាទីស្រលាញ់របស់ខ្ញុំ ព្រមទាំងមិត្តភក្តិដែលបានជួយជ្រោមជ្រែងទាំងអស់

ដែលបានជួយផ្ទៀងផ្ទាត់អក្ខរាវិរុទ្ធ និងឃ្លាប្រយោគ ការវាយអត្ថបទ ការរចនារូបភាព ដ្យាក្រាម និងក្រាហ្វិចមួយចំនួនតាមកម្មវិធីកុំព្យូទ័រសម្រាប់ជាឧទាហរណ៍នៅក្នុងការគណនា និងវិភាគទិន្នន័យនៅក្នុងវិធីសាស្ត្ររៀបចំការពិសោធន៍ផ្សេងៗ។

# អារម្ភកថា

បញ្ហាសេដ្ឋកិច្ចគឺជាចំណោទបញ្ហា "**សង្គមជាតិគឺសង្គមសេដ្ឋកិច្ច**" សៀវភៅនេះបានរៀបរៀងឡើងដោយសម្ផិតសម្ផាងលើបញ្ហាសេដ្ឋកិច្ច សំដៅលើទិដ្ឋភាពទ្រឹស្តីធនាគារកណ្តាល និងគោលនយោបាយរូបិយវត្ថុ ដោយផ្តើមចេញពីការវិភាគលើទ្រឹស្តីរូបិយវត្ថុទំនើបជាពិសេស។ ហេតុផលនៃការរៀបរៀងសៀវភៅនេះ ដោយសារតែអ្នករៀបរៀងបានយល់ឃើញថាប្រទេសកម្ពុជាបន្ទាប់ពីសង្គ្រាមស៊ីវិលអស់ជាច្រើនទសវត្សរ៍កន្លងមក ការចងក្រងសៀវភៅជាខេមរភាសាសម្រាប់អ្នកសិក្សាស្រាវជ្រាវមុខជំនាញសេដ្ឋកិច្ចនៅមានកម្រិត។ ហេតុនេះ អ្នករៀបរៀងនិពន្ធសៀវភៅនេះ បានខិតខំជ្រើសរើសសម្រិតសម្រាំងចងក្រងសៀវភៅជាខេមរភាសា ដោយបានដកស្រង់ចេញពីសៀវភៅ អត្ថបទ ខ្លឹមសារទ្រឹស្តី និងឯកសារភាសាបរទេសដ៏មានគុណតម្លៃខ្ពស់មកប្រែសម្រួលជាខេមរភាសាសម្រាប់អ្នកសិក្សាស្រាវជ្រាវដែលនិយមភាសាខ្មែរ។ ការរៀបរៀងស្នាដៃនេះគឺទាមទារពេលវេលា កម្លាំងកាយ កម្លាំងចិត្ត ប្រាជ្ញា ស្មារតីជាច្រើន ដើម្បីឱ្យស្នាដៃនេះ ចេលចេញជារូបរាងបាន។

ទន្ទឹមនឹងនេះ អ្នករៀបរៀងនិពន្ធសៀវភៅនេះ សុំការអធ្យាស្រ័យពីមិត្តអ្នកអានទាំងអស់នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនាក្នុងស្នាដៃនេះ ដូចជាកំហុសឆ្គងខាងអក្ខរាវិរុទ្ធ ដោយសារការពិនិត្យមិនបានគ្រប់ជ្រុងជ្រោយជាដើម។ ទន្ទឹមនឹងនេះ សូមថ្លែងអំណរគុណនូវការផ្តល់មតិកែម្អដើម្បីឱ្យស្នាដៃនេះកាន់តែមានគុណភាព ដើម្បីជាប្រយោជន៍ជាតិ និងសង្គមកម្ពុជារបស់យើងទាំងអស់គ្នា។

សៀវភៅនេះទៀតសោត គឺផ្តោតជាសំខាន់លើ "ធនាគារកណ្តាល និងគោលនយោបាយរូបិយវត្ថុ" វិភាគលើគោលនយោបាយរបស់ធនាគារកណ្តាលដែលប្រើនូវឧបករណ៍គោលនយោបាយរូបិយវត្ថុ ដើម្បីឆ្លុះបញ្ចាំងពីគោលនយោបាយសេដ្ឋកិច្ចឱ្យមានស្ថិរភាពថ្លៃ កម្រិតនិកម្មភាពអតិបរមា និងកំណើនសេដ្ឋកិច្ចរយៈពេលវែង។

សូមឱ្យស្នាដៃនេះ បានជាជំនួយស្មារតីសម្រាប់លោកអ្នកអាន។

ថ្ងៃ.................... ខែ.............. ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦

រាជធានីភ្នំពេញ ថ្ងៃទី...... ខែ......... ឆ្នាំ២០២០

**អ្នកនិពន្ធ**

**បណ្ឌិត សឹន សុទ្ធ**

**អ្នកនិពន្ធ**

នាម និងគោត្តនាម ៖ បណ្ឌិត សឺន សុទ្ធ
អាសយដ្ឋាន ៖ ភូមិស្វាយឧត្តម សង្កាត់ពន្លាំង ខណ្ឌព្រែកព្នៅ ភ្នំពេញ
ទីកន្លែងកំណើត ៖ ភូមិថាំងម៉ែ ឃុំប៉ៃលិន ស្រុករតនៈមណ្ឌល បាត់ដំបង
ស្ថាប័នការងារ ៖ អគ្គនាយកដ្ឋានពន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ឯកទេស ឬមុខជំនាញ ៖ សវនករពន្ធដារ



ប្រវត្តិការសិក្សា៖

- ២០២០-២០២២៖ កំពុងសិក្សាបន្តថ្នាក់ស្រាវជ្រាវក្រោយបណ្ឌិត
- ២០១៦-២០២០៖ បញ្ចប់ថ្នាក់បណ្ឌិតសេដ្ឋកិច្ច
- ២០០៣-២០០៥៖ បញ្ចប់ថ្នាក់អនុបណ្ឌិត
- ១៩៩៦-១៩៩៨៖ បញ្ចប់ថ្នាក់បរិញ្ញាប័ត្រ
- ១៩៩៣-១៩៩៦៖ បញ្ចប់ថ្នាក់បរិញ្ញាប័ត្ររង
- ១៩៩២-១៩៩៣៖ សិក្សាថ្នាក់ត្រៀមមហាវិទ្យាល័យ
- ១៩៨៩-១៩៩២៖ ទទួលសញ្ញាប័ត្រទុតិយភូមិ

បទពិសោធន៍ការងារ៖

- ១៩៩៨-២០០០៖ បម្រើការងារនៅនាយកដ្ឋានវិភាគ និងព្យាករណ៍សេដ្ឋកិច្ចនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ២០០០-២០១៤៖ បម្រើការងារនៅនាយកដ្ឋានសវនកម្មសហគ្រាសនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ២០១៤-២០១៦៖ បម្រើការងារនៅសាខាពន្ធដារខណ្ឌ ឬស្សីកែវនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ២០១៦-២០២១៖ បម្រើការនៅសាខាពន្ធដារខណ្ឌដូនពេញនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

បទពិសោធន៍បង្រៀនពីឆ្នាំ ២០០៩-២០២១៖

- សាលាជាតិពន្ធដារ
- សាកលវិទ្យាល័យខេមរៈ
- សាកលវិទ្យាល័យភូមិន្ទកសិកម្ម
- សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច (សាខាកំពង់ចាម)
- សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច (ទីតាំងគោលបាត់ដំបង)
- សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច (សាខាបន្ទាយមានជ័យ)
- សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច (សាខាព្រះសីហនុ)

## អ្នកនិពន្ធ

នាម និងគោត្តនាម ៖ សាស្ត្រាចារ្យរង បណ្ឌិត ឆាយ គង្គា



( Assoc. Prof. CHHAY Kongkea, Ph.D. )

**អាស័យដ្ឋាន** ៖ ផ្ទះលេខ ២១១ ផ្លូវ ១១ ភូមិសំបួរ សង្កាត់ដង្កោ
ខណ្ឌដង្កោ រាជធានីភ្នំពេញ

**ស្ថាប័នការងារ** ៖ មហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ
សាកលវិទ្យាល័យភូមិន្ទកសិកម្ម

**ឯកទេស ឬមុខជំនាញ** ៖ បណ្ឌិតវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញសេដ្ឋកិច្ចកសិកម្ម

**ប្រវត្តិការសិក្សា៖**

- 2003 - 2006៖ Ph.D. Degree in Economics, Major in Agricultural Economics
  Chonnam National University, Gwangju City, South Korea.
- 2001 - 2003៖ Master's Degree in Economics, Major in Agricultural Economics Chonnam National University, Gwangju City, South Korea.
- 1993 - 1998៖ Bachelor's Degree in Economics, Major in EnterpriseManagement Facultural of Law and Economics, Phnom Penh, Cambodia [Present: Royal university of Law and Economics (RULE)]
- 1993 - 1996៖ Diplôme de Baccalauréat en sciences économiques, Faculté de droit et des sciences économiques, Royaume du Cambodge.
- 1992 - 1993៖ Certificate of Preparatory Class, Institute of Economic Sciences.
- 1990 - 1992៖ Diplima Up-Grading of Psychogical Pedagogy, Major in Mathematic Battambang Psychogical Pedagogy School, Battamabng Province. (Present: National University of Management), Cambodia.
- 1990 - 1992៖ Diplima of Sinor Hight School, Battambang Secondary School,
  Battambang Province, Kingdom of Cambodia.

**បទពិសោធន៍ការងារ៖**

- ២០០៧ - បច្ចុប្បន្ន៖ ព្រឹទ្ធបុរសរង (Vice Dean) មហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ព្រះរាជាណាចក្រកម្ពុជា
- ២០១២ - បច្ចុប្បន្ន៖ សាស្ត្រាចារ្យរង(Associate Professor)តាមអនុក្រឹត្យលេខ៥៤៤ អនក្រ.តក ស្តីពីការតែងតាំងឋានៈជាសាស្ត្រាចារ្យរងជូនមន្ត្រីរាជការ និងគ្រូបង្រៀនថ្នាក់ឧត្តមក្នុងវិស័យកសិកម្មរបស់រាជរដ្ឋាភិបាលកម្ពុជាចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១២
- 1998 - បច្ចុប្បន្ន៖ គ្រូបង្រៀនតាមសាកលវិទ្យាល័យនានា៖NUM, BBU, NIB, HRU, UME,

## មាតិកា

បុព្វកថា និងសេចក្តីបញ្ជាក់នៃមូលនិធិ

**ទំព័រ**


សេចក្ដីថ្លែងអំណរគុណ.....i
ក្រោសិទ្ធ.....ii
អារម្ភកថា.....x
អ្នកនិពន្ធ.....iv
មាតិកា.....v
អក្សរកាត់អង់គ្លេស.....xiv
បញ្ជីគំនូសតាង និងក្រាហ្វិក.....xvi


**ជំពូកទី១៖ សេដ្ឋកិច្ចរូបិយវត្ថុ** (MONETARY ECONOMICS)


១.១- សេដ្ឋកិច្ចរូបិយវត្ថុ (Monetary economics).....១

១.១.១- តើសេដ្ឋកិច្ចរូបិយវត្ថុជាអ្វី? (What is Monetary economics?).....១

១.១.២- មីក្រូសេដ្ឋកិច្ចជាផ្នែកមួយនៃសេដ្ឋកិច្ចរូបិយវត្ថុ (Microeconomics part of monetary economics).....២

១.១.៣- ម៉ាក្រូសេដ្ឋកិច្ចជាផ្នែកមួយនៃសេដ្ឋកិច្ចរូបិយវត្ថុ (Macroeconomics part of monetary economics: money in the macroeconomy).....៣

១.២- តើរូបិយវត្ថុគឺជាអ្វី? (What is money)?.....៣

១.២.១- មុខងាររូបិយវត្ថុ (Functions of money).....៣

១.២.២- លក្ខណៈពិសេសនៃរូបិយវត្ថុ (Feature of money).....៥

១.២.៣- ការកំណត់ប្រភេទរូបិយវត្ថុ (Determined of money).....៦

១.៣- ការផ្គត់ផ្គងរូបិយវត្ថុ និងស្តុករូបិយវត្ថុ (Money supply & money stock).....៧

១.៣.១- ការផ្គត់ផ្គង់រូបិយវត្ថុ (Money supply).....៨

១.៣.១.១- តើអ្វីជាការផ្គត់ផ្គង់រូបិយវត្ថុ? (What Is the Money Supply)?..៨

១.៣.១.២- ហេតុអ្វីការផ្គត់ផ្គង់ប្រាក់មានសារសំខាន់? (Why Is the Money Supply Important)?.....៨

១.៣.១.៣- តើអ្វីដែលកំណត់ការផ្គត់ផ្គង់រូបិយវត្ថុ? (What Determines the Money Supply)?.....៩

១.៣.១.៤- ការប្រែប្រួលទុនបម្រុងធនាគារសហព័ន្ធ (Changing Federal Reserve).....១២

១.៤- អតិផរណា (Inflation).....១៤

១.៤.១- វង្វាស់អតិផរណា (Measuring Inflation).....១៥

១.៤.២- មូលហេតុនៃអតិផរណា (Causes of Inflation).....១៦

១.៤.៣- ផលវិបាកនៃអតិផរណា (Consequences of Inflation).....១៩

១.៤.៤- អតិផរណាដែលមិនអាចគ្រប់គ្រងបាន (Unanticipated Inflation) ......២០
១.៥- ភាពខុសគ្នារវាងតម្លៃរូបិយវត្ថុមានតែនាម និងតម្លៃរូបិយវត្ថុពិត
(Nominal vs. real value of money) ......................................................២២
១.៦- តើការបង្កើតរូបិយវត្ថុគឺជាអ្វី? (What is money creation)? ........................២២
១.៦.១- ឥឡូវយើងសូមក្រឡេកមើលយន្តការផ្សេងៗគ្នាដែលនាំឱ្យមានការបង្កើតប្រាក់
(Let us now look at the different mechanisms leading) .......... ២៣
១.៦.២- ការបង្កើតរូបិយវត្ថុតាមរយៈបំណុល (Money creation through debt) ២៤
១.៦.៣- ឧបករណ៍មានសម្រាប់ធនាគារកណ្តាល ដើម្បីគ្រប់គ្រងការបង្កើតរូបិយវត្ថុ៖
(Tools for central bank to manage currency) ..........................២៥
១.៦.៤- ប្រតិបត្តិការទីផ្សារបើកចំហ (Open market operation-OMO)............២៦
១.៧- ទីផ្សាររូបិយវត្ថុ និងមូលបត្របំណុលក្នុងម៉ាក្រូសេដ្ឋកិច្ច
(Money and bond markets in monetary macroeconomics)..................២៦
១.៧.១- ការវិវឌ្ឍន៍រូបិយវត្ថុ និងរូបិយវត្ថុប្រហាក់ប្រហែល ចាប់តាំងពី១៩៤៥
(Evolution of money and near-monies since 1945) .................២៩
១.៧.២- នវានុវត្តន៍ផ្នែកហិរញ្ញវត្ថុ (Financial innovations) ...........................៣០
១.៧.៣- ការវិវឌ្ឍន៍ទ្រឹស្តីរូបិយវត្ថុ (Theoretical developments of money) .... ៣២
១.៧.៤- មូលដ្ឋានរូបិយវត្ថុ និងតួគុណរូបិយវត្ថុ
(Monetary base and monetary base multiplier) ...................... ៣៣
១.៨- ភាពខុសគ្នារវាងអត្រាការប្រាក់ និងការផ្គត់ផ្គង់រូបិយវត្ថុ
(Interest rates versus money supply)..................................................៣៤
១.៨.១- តួនាទីធនាគារក្នុងនាមជាអន្តរការីហិរញ្ញវត្ថុ
(Role of banks as financial intermediaries) .............................៣៥
១.៨.២- ភាពផុយស្រួយនៃប្រព័ន្ធហិរញ្ញវត្ថុ (Fragility of the financial system)៣៥
១.៩- ភាពខុសគ្នានៃការវិភាគសេដ្ឋកិច្ច
(Different modes of analysis of economy)............................................៣៦
១.១០- គំរូម៉ូដែលក្លាស៊ីក (The classical paradigm)......................................... ៣៧
១.១០.១- ទស្សនៈរបស់សេដ្ឋវិទូក្លាស៊ីក(Traditional classical idea) ............. ៣៧
១.១០.២- ទ្រឹស្តីតម្រូវការសរុបនៃសេដ្ឋកិច្ចក្លាស៊ីក
(Theory of Aggregate Demand in the Traditional Classical) ...៣៨
១.១០.៣- គំរូទ្រឹស្តីនេអូក្លាស៊ីក(Neoclassical model) ................................៣៩
១.១០.៤- វិធីសាស្ត្រនៃរូបិយវត្ថុនិយមនាទសវត្សរ៍ ១៩៧០
(Monetary methods of the 1970s)........................................ ៤០

១.១១- គោលនយោបាយរូបិយវត្ថុ (Monetary policy) ........................................ ៤០
១.១២- ទ្រឹស្តីគោលនយោបាយរូបិយវត្ថុ និងគោលនយោបាយសារពើពន្ធ
(Definitions of monetary and fiscal policies) .................................... ៤១

**ជំពូកទី២៖ សារសំខាន់នៃធនាគារកណ្តាល**

២.១- ប្រវត្តិសង្ខេបនៃធនាគារកណ្តាល (Briefly history of central bank)................៤៣
២.២- រចនាសម្ព័ន្ធធនាគារសហព័ន្ធ (Federal Bank Structure) ............................៤៣
២.៣- ប្រវត្តិសង្ខេបធនាគារជាតិនៃកម្ពុជា (Briefly history of NBC) ........................ ៤៥
២.៣.១- ប្រវត្តិសង្ខេបពីឆ្នាំ ១៩៥៤ - ១៩៧៥ (Brief history from 1954 - 1975)៤៥
២.៣.២- រចនាសម្ព័ន្ធគ្រប់គ្រងធនាគារកណ្តាល (Organization of CB)............ ៤៨
២.៣.៣- ធនាគារិក (Baker)...................................................................... ៥១
២.៣.៤- តួនាទីសំខាន់របស់ធនាគារកណ្តាល (The role of Central bank
Operation)........................................................................................៥៣
២.៤- គ្រឹះស្ថានធនាគារកណ្តាល៖ ប្រព័ន្ធហិរញ្ញវត្ថុ
(central bank: the financial system) ..................................................... ៥៥
២.៤.១- ប្រព័ន្ធហិរញ្ញវត្ថុ (Financial system) .............................................. ៥៦
២.៤.២- សមាសធាតុនៃប្រព័ន្ធហិរញ្ញវត្ថុ (Element of financial system) .......... ៥៨
២.៥- ធនាគារកណ្តាល៖ ស្ថិរភាពហិរញ្ញវត្ថុ
(Central banking: financial stability) ..................................................... ៥៩
២.៥.១- កម្មវត្ថុនៃស្ថិរភាពហិរញ្ញវត្ថុ (Objective of financial stability)............... ៥៩
២.៥.២- តើអ្វីជាស្ថិរភាពហិរញ្ញវត្ថុ? (Why financial stability?)...................... ៦១
២.៥.៣- តើអ្វីជាតម្លៃខាងក្នុង និងខាងក្រៅរូបិយវត្ថុ?
(What are the internal and external values of the currency?)... ៦១
២.៥.៣.១- តម្លៃខាងក្នុងរបស់រូបិយវត្ថុ (Internal value of the
currency) ................................................................. ៦១
២.៥.៣.២- តម្លៃខាងក្រៅរបស់រូបិយវត្ថុ (External value of currency) ៦២
២.៥.៣.៣- របបនៃអត្រាប្តូរប្រាក់ (Exchange rate regime)............... ៦២
២.៥.៣.៤- ឥទ្ធិពលនៃការប្រែប្រួលអត្រាប្តូរប្រាក់
(Influence of exchange rate)...................................៦២
២.៥.៣.៥- ទីផ្សារប្តូរប្រាក់បរទេស (fluctuations foreign exchange
market) ....................................................................៦៣
២.៥.៤- តើស្ថិរភាពហិរញ្ញវត្ថុសម្រេចបានដោយរបៀបណាក្នុងប្រទេសមួយ?
(How is financial stability achieved domestically)? ...................៦៣

២.៥.៥- ការចាប់អារម្មណ៍ជាសកល (Worldwide focus) ............................... ៦៤
២.៦- តារាងតុល្យការរបស់ធនាគារកណ្តាល
(Balance sheet of central bank) ................................................... ៦៦
២.៦.១- គណនីបំពុល (Liabilities) ....................................................... ៦៨
២.៦.១.១- ក្រដាសប្រាក់ និងកាស (Notes and Coins) ..................... ៦៨
២.៦.២.២- ប្រាក់បញ្ញើរដ្ឋាភិបាល (Government deposit) ................. ៦៩
២.៦.២.៣- ប្រាក់បញ្ញើធនាគារ (Bank deposit) ................................. ៦៩
២.៦.២.៤- មូលប័ត្ររបស់ធនាគារកណ្តាល (Central bank securities) ៧២
២.៧- ការបង្កើតរូបិយវត្ថុ (Money creation) ........................................ ៧៣
២.៧.១- គណនីទ្រព្យសកម្ម (Assets) .................................................... ៧៣
២.៧.១.១- ទ្រព្យសកម្មបរទេស (Foreign Assets) ............................. ៧៣
២.៧.១.២- ការផ្តល់កម្ចីឱ្យដល់រដ្ឋាភិបាល (Loans to government)..... ៧៤
២.៧.១.៣- ការផ្តល់កម្ចីឱ្យដល់ធនាគារ (Loans to banks)................. ៧៤
២.៨- មុខងាររបស់ធនាគារកណ្តាល (Functions of central banks)......................... ៧៥
២.៨.១- សមាសធាតុនៃការផ្គត់ផ្គង់រូបិយវត្ថុ (Element of money supply)......... ៧៥
២.៨.២- គោលការណ៍នៃការបង្កើតរូបិយវត្ថុ (Principle of money creation) ...... ៧៧
២.៩- មុខងាររបស់ធនាគារកណ្តាល(Functions of central banks)........................ ៧៨
២.៩.១- គោលការណ៍រួមរបស់ធនាគារកណ្តាល (Principle of central banks) ... ៨០
២.៩.២- តួគុណប្រាក់បញ្ញើធនាគារ (Deposit Multiplier) ................................ ៨១

**ជំពូកទី៣៖ ធនាគារិកជាទីប្រឹក្សាឱ្យរដ្ឋាភិបាល**

៣.១- តើអ្វីជាធនាគារ? (What's banking?) ........................................ ៨៥
៣.១.១- ហេតុអ្វីយើងសិក្សាពីធនាគារ? (why we are study the bank)?........ ៨៥
៣.១.២- ប្រភេទនៃធនាគារ (Types of bank) ............................................ ៨៧
៣.១.៣- តួនាទីរបស់ធនាគារ (The role of bank) ...................................... ៨៨
៣.២- មុខងារនៃប្រាក់បញ្ញើ (Function of deposit)...................................... ៨៨
៣.២.១- ប្រភេទសេវានៃប្រាក់បញ្ញើ (Types of deposit services)..................... ៨៨
៣.២.២- ការត្រួតពិនិត្យប្រាក់បញ្ញើ (Control deposit) .................................. ៨៩
៣.២.៣- មុខងារទូទាត់ (Function of payment) ........................................ ៨៩
៣.២.៤- មុខងារឥណទាន (Function of credit) ......................................... ៨៩
៣.៣- ការគ្រប់គ្រងឥណទាន (Credit management) ..................................... ៩០
៣.៣.១- ដំណើរការឥណទាន (Credit processing) ...................................... ៩០
៣.៣.២- សេវាប្រាក់បញ្ញើអតិថិជន (Customer deposit service) ..................... ៩១

៣.៣.៣- សេវាប្រាក់កម្ចីធនាគារ ( Bank loan services ) ................................ ៩២
៣.៣.៤- សេវាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ( Microfinance institution services ) ...... ៩៣
៣.៣.៥- តួនាទីសំខាន់របស់ធនាគារក្នុងសេដ្ឋកិច្ច ( Role of bank for economics ) ៩៣
៣.៤- មុខងារចម្បងរបស់ធនាគារកណ្តាល ( Function of Central Bank ) .................. ៩៥
៣.៥- ទីផ្សារអន្តរធនាគារ ( Interbank markets ) .................................................. ៩៦
៣.៥.១- ទីផ្សារអន្តរធនាគាររវាងធនាគារ និងធនាគារកណ្តាល
( The bank-to-central bank interbank market ) ............................ ៩៨
៣.៥.២- ទីផ្សារអន្តរធនាគាររវាងធនាគារកណ្តាល និងធនាគារ
( The central bank-to-bank interbank market ) ............................ ៩៨
៣.៥.៣- ទីផ្សារអន្តរធនាគាររវាងធនាគារ និងធនាគារ
( bank-to-bank interbank market ) .............................................. ៩៩
៣.៦- ការគ្រប់គ្រងសាច់ប្រាក់ងាយស្រួលរបស់ធនាគារ
( Bank liquidity management ) ............................................................ ១០២
៣.៧- ធនាគារិករបស់រដ្ឋាភិបាល ( Banker to government ) ..................................១០៤
៣.៨- គណនីពន្ធ និងឥណទាន ( Tax and loan accounts ) ..................................១០៤
៣.៨.១- ការបង់ពន្ធ ( Tax payments ) ......................................................១០៦
៣.៨.២- បង្កាន់ដៃប័ណ្ណបំណុល ( Receipts of loan issues ) ..........................១០៨
៣.៨.៣- ទស្សនៈរបស់ធនាគារកណ្តាលពីបញ្ហា
( Problem from perspective of Central bank ) ............................១០៩
៣.៨.៤- ទស្សនៈរបស់រដ្ឋាភិបាលអំពីបញ្ហា
( Problem from perspective of government ) .............................១០៩
៣.៨.៥- ទស្សនៈរបស់ធនាគារអំពីបញ្ហា ( Problem from perspective of
banks ) ......................................................................................១១០
៣.៨.៦- ដំណោះស្រាយ ( The solution ) ....................................................១១០
៣.៨.៧- ឧបករណ៍គោលនយោបាយរូបិយវត្ថុ ( Monetary policy tool ) ........... ១១៣
៣.៩- ការគ្រប់គ្រងបំណុលសាធារណៈ ( Public debt management ) .................... ១១៣
៣.៩.១- បំណុលសាធារណៈ ( The public debt ) ........................................១១៤
៣.៩.១.១- ភាពខុសគ្នារវាងបំណុលក្នុងស្រុក និងបំណុលបរទេស
( Domestic vs. Foreign debt ) ...................................១១៤
៣.៩.១.២- រចនាសម្ព័ន្ធនៃកាលវសាន្តសងបំណុល
( Structure of maturity debt ) ....................................១១៥
៣.៩.១.៣- ទំនាក់ទំនងគោលនយោបាយរូបិយវត្ថុ

(Relationship with monetary policy) ........................ ១១៥
៣.៩.១.៤- ដំណើរការគ្រប់គ្រងបំណុល (In-progress debt Management) ........................................................ ១១៥
៣.៩.១.៥- អនុបាតផលិតផលក្នុងស្រុកសរុប និងបំណុលរដ្ឋាភិបាល (Ratio to GDP vs. GD) ............................................ ១១៦
៣.៩.២- ធនាគារកណ្ដាល និងការគ្រប់គ្រងបំណុលសាធារណៈ (CB and Public debt management) ........................................ ១១៦
៣.១០- រដ្ឋបាលនៃការគ្រប់គ្រងការផ្លាស់ប្ដូរ (Administration of exchange controls) ........................................... ១១៧

## ជំពូកទី៤៖ ប្រព័ន្ធធនាគារ និងការគ្រប់គ្រងរូបិយវត្ថុ

៤.១- តើទីផ្សាររូបិយវត្ថុជាអ្វី? (What is monetary market?) ............................... ១១៨
៤.២- តើទីផ្សារមូលធនជាអ្វី? )What is capital market?) .................................. ១១៩
៤.៣- តើអ្វីជាអន្តរការីធនាគារ? (What is a bank intermediary?) ...................... ១២១
៤.៤- ធនាគារិក និងធនាគារឯកជន (Banker to private banks) .......................... ១២៣
៤.៥- ការទូទាត់សំណងអន្តរធនាគារ (Settlement of interbank claims) ............... ១២៨
៤.៦- ការត្រួតពិនិត្យប្រព័ន្ធទូទាត់ (Supervision of payments system) ................ ១៣៤
៤.៦.១- ប្រតិបត្តិការធនាគារកណ្ដាល (Central bank transactions) ............ ១៣៤
៤.៦.២- បញ្ហាតូច ឬធំរបស់ធនាគារ (Large/small bank problem) .............. ១៣៦
៤.៦.៣- ទំនុកចិត្ត និងដំណើរការរបស់ធនាគារ (Confidence and the bank run) ............................................................................ ១៣៧
៤.៧- ការគ្រប់គ្រងរូបិយប័ណ្ណ (Currency (N&C) management) ....................... ១៣៩
៤.៨- ការត្រួតពិនិត្យប្រព័ន្ធធនាគារ (Bank supervision) ...................................... ១៤១
៤.៨.១- ហេតុផលសម្រាប់បទប្បញ្ញត្តិច្បាប់ (Rationale for regulation) ........... ១៤១
៤.៨.២- គោលបំណងនៃបទប្បញ្ញត្តិ (objectives of regulation) .................. ១៤២
៤.៩- ការគ្រប់គ្រងអត្រាប្ដូរប្រាក់ (Management of exchange rate) ..................... ១៤២
៤.១០- លក្ខណៈទូទៅនៃអត្រាប្ដូរប្រាក់ (Nature of exchange rate) ........................ ១៤៣
៤.១១- ការគ្រប់គ្រងទ្រព្យសកម្មបរទេស (Management of foreign assets) ........... ១៤៨
៤.១១.១- ហេតុអ្វីធនាគារកណ្ដាលកាន់កាប់ទ្រព្យសកម្មបរទេស (Why do central banks hold foreign assets.) ....................... ១៤៩
៤.១១.២- កម្រិតទុនបម្រុងដែលចង់បាន (The desired level of reserves) ..... ១៤៩
៤.១១.៣- ការគ្រប់គ្រងទុនបម្រុងទ្រព្យសម្បត្តិបរទេស (Foreign asset reserve management) .................................. ១៥០

៤.១១.៤- ដុល្លារអាម៉េរិកក្នុងការគ្រប់គ្រងទ្រព្យសកម្មជាទុនបម្រុង

(The USD in foreign asset reserve management)..................១៥១

៤.១២- ការអភិវឌ្ឍន៍ទីផ្សារបំណុល (Development of the debt market)...............១៥១

**ជំពូកទី៥៖ ក្របខ័ណ្ឌនៃគោលនយោបាយរូបិយវត្ថុ**

៥.១- សេចក្ដីផ្ដើម (Introduction) .................................................................. ១៥៧

៥.១.១- ការកំណត់អត្រាការប្រាក់ទីផ្សារ (Set interest rates market) ........... ១៥៧

៥.១.២- ប្រតិបត្តិការមូលដ្ឋានរបស់ធនាគារ (Principal of bank operation).....១៥៨

៥.១.៣- ការវាស់វែងរូបិយវត្ថុ (measuring money) ....................................១៥៩

៥.២- អត្តសញ្ញាណរូបិយវត្ថុ៖ ការបង្កើតរូបិយវត្ថុ

(Money identity: money creation) ...................................................... ១៦៣

៥.២.១- សេចក្ដីផ្ដើម (Introduction)....................................................... ១៦៣

៥.២.២- ឧទាហរណ៍៖ ប្រាក់កម្ចីពីធនាគារ (Loan from bank).......................១៦៥

៥.២.៣- ឧទាហរណ៍៖ ការនាំចេញ (Exports) ...........................................១៦៦

៥.២.៤- ឧទាហរណ៍៖ មូលបត្របំណុលរដ្ឋាភិបាល (government issues bonds)១៦៩

៥.២.៥- ឧទាហរណ៍៖ ក្រដាសប្រាក់របស់ធនាគារ (Example: bank notes).... ១៧១

៥.២.៦- ហាយនភាពរូបិយវត្ថុ (Money destruction) ................................. ១៧២

៥.២.៧- ប្រាក់បញ្ញើធនាគារ និងទុនបម្រុងកាតព្វកិច្ច

(Bank deposits and reserve requirement) .............................១៧៣

៥.៣- បរិបទបទប្បញ្ញត្តិច្បាប់ (Statutory environment)...................................... ១៧៤

៥.៤- កម្មវត្ថុនៃគោលនយោបាយរូបិយវត្ថុ (Objectives of monetary policy) ........... ១៧៥

៥.៤.១- ប្រតិបត្តិការទីផ្សារបើកចំហ (Open market operation-OMO)........... ១៧៧

៥.៤.២- បង្អួចអប្បហារ (Discount window)............................................ ១៧៨

៥.៤.៣- ទុនបម្រុងកាតព្វកិច្ច (Reserve requirement) .............................. ១៧៨

៥.៥- ស្ថិរភាពថ្លៃ (Price stability)............................................................... ១៧៩

៥.៥.១- សេចក្ដីផ្ដើម (Introduction) ..................................................... ១៧៩

៥.៥.២- តើស្ថិរភាពថ្លៃគឺជាអ្វី (What Is Price Stability?) ........................... ១៧៩

៥.៥.៣- តើស្ថិរភាពថ្លៃមានអត្ថប្រយោជន៍អ្វីខ្លះ?

(What's advantage of stable price?) ............................................................. ១៧៩

៥.៦- អតិផរណាផ្ដោតលើក្របខ័ណ្ឌគោលនយោបាយរូបិយវត្ថុ

(Inflation targeting monetary policy framework)..................................១៨០

៥.៧- គណនេយ្យភាព និងតម្លាភាពនៃគោលនយោបាយរូបិយវត្ថុ

(Monetary policy accountability and transparency).................................... ១៨២

៥.៨- ដែនកំណត់នៃគោលនយោបាយរូបិយវត្ថុ ( Limitations of monetary policy ) ........................................................................................ ១៨៤
៥.៩- ឧបករណ៍នៃគោលនយោបាយរូបិយវត្ថុ ( Tools of monetary policy ) .............. ១៨៥
៥.១០- ឯករាជ្យភាពរបស់ធនាគារកណ្ដាល ( Independence of central banks )........................................................................................ ១៨៨
៥.១១- ការវាស់កំណើនសេដ្ឋកិច្ច ( Measurement economy growth )................... ១៨៨
៥.១២- ការវាស់អតិផរណា ( Measurement inflation ) ........................................ ១៩០

**ជំពូកទី៦៖ គោលនយោបាយរូបិយវត្ថុ ( MONETARY POLICY )**

៦.១- សេចក្ដីផ្ដើមនៃគោលនយោបាយរូបិយវត្ថុ ( Introduction to monetary policy ) ....................................................... ១៩៥
៦.១.១- មុខងារចម្បងរបស់ធនាគារកណ្ដាល ( Main function of CB ) ............. ១៩៥
៦.១.២- តើអ្វីជាគោលនយោបាយរូបិយវត្ថុ ? ( What is monetary policy ? ) .... ១៩៦
៦.១.៣- តើអ្វីជាគោលនយោបាយសារពើពន្ធ ? ( what is fiscal policy ? ) ....... ១៩៧
៦.២- គំរូម៉ូដែលគោលនយោបាយរូបិយវត្ថុ ( Models of monetary policy ).............. ២០១
៦.២.១- គោលនយោបាយរូបិយវត្ថុ ( Monetary policy )................................ ២០១
៦.២.២- គំរូតម្រូវការទុនបម្រុងរកាតព្វកិច្ច ( Firm required reserve model ) ... ២០៤
៦.២.៣- គំរូទុនបម្រុងជាប្រាក់កម្ចី ( Firm borrowed reserves model ) .......... ២០៨
៦.២.៤- គំរូម៉ូដែលអត្រាអន្តរធនាគារ ( Interbank rate model ) ..................... ២១២
៦.២.៥- សសរស្ដម្ភនៃគោលនយោបាយរូបិយវត្ថុ ( Quoins of monetary policy ) ២១៤
៦.៣- ឥទ្ធិពលនៃគោលនយោបាយរូបិយវត្ថុ៖ អត្រាការប្រាក់ និងអតិផរណា ( Effects of monetary policy ) ........................................................................................ ២១៥
៦.៤- ឥទ្ធិពលរុញចេញនៃគោលនយោបាយរូបិយវត្ថុ ( Crowding-out effect on MP ).............................................................. ២២០
៦.៤.១- តើអ្វីជាឥទ្ធិពលរុញចេញ ? ( What is Crowding Out ? ) .................. ២២១
៦.៤.២- ការវិភាគឥទ្ធិពលរុញចេញ ( Analysis Crowding out )...................... ២២៣
៦.៤.៣- ការវាយតម្លៃទ្រឹស្ដីរុញចេញ ( Evaluating of Crowding Out Theory ) .២២៣
៦.៥- ឥទ្ធិពលនៃគោលនយោបាយសារពើពន្ធលើការនាំចេញសុទ្ធ ( Net export: Effects of fiscal Policy ) .................................................... ២២៥

សេចក្ដីសន្និដ្ឋាន ........................................................................................ ២២៨

# បណ្ណាល័យសាស្ត្រ

# បញ្ជីពាក្យសរសេរកាត់

| ពាក្យសរសេរកាត់ | | ការពន្យល់ |
|---|---|---|
| BR | : | BANK RESERVE |
| CB | : | CENTRAL BANK |
| DD | : | DOMESTIC DEMAND |
| ER | : | EXCESS RESERVE |
| LC | : | LOCAL COUNTRY |
| LS | : | LIQUIDITY SHORTAGE |
| MD | : | MARKETABLE DEBTS |
| QE | : | QUANTITATIVE EASTING |
| RA | : | REVENUE AUTHORITY |
| RP | : | RISK PREMIUM |
| RR | : | REQUIREMENT RESERVE |
| TR | : | TOTAL RESERVE |
| ACB | : | AUTOMATED CLEARING BUREAU |
| ATM | : | AUTOMATIC TELLER MACHINE |
| BLS | : | BUREAU OF LABOR STATISTICS |
| BNP | : | BANQUE NATIONALE DE PARIS |
| CBM | : | CENTRAL BANK MONEY |
| CBS | : | CENTRAL BANK SECURITIES |
| ECB | : | EUROP OF CENTRAL BANK |
| CPI | : | CONSUMER PRICE INDEX |
| GDE | : | GROSS DOMESTIC EXPENDITURE |
| GDP | : | GROSS DOMESTIC PRODUCT |
| MBS | : | MONETARYBANKING SECTOR |
| MPC | : | MONETARY POLICY COMMITTEE |
| NBC | : | NATIONAL BANK OF CAMBODIA |
| NER | : | NET EXCESS RESERVES ( NER ) |
| NER | : | NET EXCESS RESERVES ( NER ) |
| NFA | : | NET FOREIGN ASSETS |
| NLG | : | NET LOANS TO GOVERNMENT |
| NMD | : | NONE MARKETABLE DEBTS |

NPS : NATION PAYMENT SYSTEM
N&C : NOTE AND CIONS
OMO : OPEN MARKET OPERATIONS
OTC : OVER THE COUNTER MARKETS
RFR : RISK-FREE RATE
RRR : REQUIRED RATE OF RETURN
HICP : HARMONISED INDEX OF CONSUMER PRICES
BNCI : BANQUE NATIONALE POUR LE COMMERCE ET I'INDUSTRIE
LOLR : LENDER OF LAST RESORT
LTDM : LONG-TERM DEBT MARKET
LT-MD : MARKETABLE DEBT
NBPS : NON-BANK PRIVATE SECTOR
RTGS : REAL TIME GROSS SETTLEMENT
STDM : SHORT-TERM DEBT MARKET
ST-MD : ST MARKETABLE DEBT
TLAS : TAX AND LOAN ACCOUNTS
BSSOC : BALANCE SHEET SOURCE OF CHANGE
CAMELS : CAPITAL, ASSETS, MANAGEMENT, EARNINGS, LIQUIDITY, SENSITIVITY TO MARKET RISK

## បញ្ជីគំនូសតាង និងក្រាហ្វិក


គំនូសតាងទី ១៖ រចនាសម្ព័ន្ធធនាគារសហព័ន្ធសហរដ្ឋ (Federal bank structure)....... ៤៤
គំនូសតាងទី ២៖ ប្រព័ន្ធហិរញ្ញវត្ថុ (financial system)........................................... ៥៧
គំនូសតាងទី ៣៖ សមាសធាតុនៃប្រព័ន្ធហិរញ្ញវត្ថុ (Element of financial system) ....... ៥៩
គំនូសតាងទី ៤៖ តើអ្វីជារូបិយវត្ថុ? (what is money?) ........................................ ៦៩
គំនូសតាងទី ៥៖ កម្រិតមធ្យមភាគរបស់ធនាគារ (Bank margin) ............................. ៧៤
គំនូសតាងទី ៦៖ទីផ្សារអន្តរធនាគារ (interbank markets) ................................. ១០២
គំនូសតាងទី ៧៖ តើអ្វីជារូបិយវត្ថុ M3? (what is money M3?) ............................ ១៦១
គំនូសតាងទី ៨៖ កម្មវត្ថុនៃគោលនយោបាយរូបិយវត្ថុ (Object of monetary policy) .. ១៧៧
គំនូសតាងទី ៩៖ គោលនយោបាយរូបិយវត្ថុ (Monetary policy) ............................ ១៨៧
គំនូសតាងទី ១០៖ គោលនយោបាយរបស់រដ្ឋាភិបាល (Government policy)............ ២០០
គំនូសតាងទី ១១៖ គោលនយោបាយរូបិយវត្ថុ (Monetary policy) ........................ ២០៣
គំនូសតាងទី ១២៖ យន្តការបញ្ជូនគោលនយោបាយរូបិយវត្ថុ (MPTM)..................... ២១៧
គំនូសតាងទី ១៣៖ ឥទ្ធិពលរុញចេញ (Crowding-out effect) .............................. ២២២

ក្រាហ្វិកទី ១៖ ការផ្គត់ផ្គង់ និងតម្រូវការរបស់កម្ចីធនាគារ (Supply & bank's demand). ៥៥
ក្រាហ្វិកទី ២៖ ឥទ្ធិពលកម្រិតអត្រារបស់ KIR..................................................... ៩៧
ក្រាហ្វិកទី ៣៖ ការផ្លាស់ប្តូរប្រាក់បញ្ញើរបស់រដ្ឋាភិបាលជាមួយធនាគារកណ្តាល
(Exchange of government deposits with the central bank)......១០៥
ក្រាហ្វិកទី ៤៖ ហានិភ័យ (Risk) .........................................................................១៥០
ក្រាហ្វិកទី ៥៖ M3 & LNBPS...........................................................................១៦៥
ក្រាហ្វិកទី ៦៖ ស្ថិរភាពរូបិយវត្ថុ (ធនាគារផ្តល់កម្ចី) (Monetary stability) ................ ២០៦
ក្រាហ្វិកទី ៧៖ តម្រូវការ និងការផ្គត់ផ្គង់ប្រាក់កម្ចី (Demand and supply of loan) .... ២០៨
ក្រាហ្វិកទី ៨៖ KIR & PR.............................................................................. ២០៩
ក្រាហ្វិកទី ៩៖ ឥទ្ធិពលរុញចេញ (Crowding-out effect)....................................... ២២១
ក្រាហ្វិកទី ១០៖ វិភាគឥទ្ធិពលរុញចេញ (Analysis of crowding-out effect)............២២៣

# ជំពូកទី ១

# សេដ្ឋកិច្ចរូបិយវត្ថុ

MONETARY ECONOMICS

## ១.១- សេដ្ឋកិច្ចរូបិយវត្ថុ (Monetary economics)

### ១.១.១- តើសេដ្ឋកិច្ចរូបិយវត្ថុជាអ្វី? (What is monetary economics?)

សេដ្ឋកិច្ចរូបិយវត្ថុ គឺផ្តោតសំខាន់ទៅលើទីផ្សាររូបិយវត្ថុ និងទីផ្សារហិរញ្ញវត្ថុ។ សម្រាប់ខ្លឹមសាររូបិយវត្ថុមានន័យថាអ្វីៗដែលគេបានទទួលស្គាល់ជាមធ្យោបាយទូទាត់សំណង និងជាមធ្យោបាយដោះដូរនៅក្នុងសេដ្ឋកិច្ច។ មធ្យោបាយដោះដូរ គឺអ្វីទាំងឡាយណាដែលត្រូវបានគេទទួលស្គាល់យ៉ាងទូលំទូលាយនៅក្នុងសង្គមជាតិមួយជាមធ្យោបាយដោះដូរទំនិញ និងសេវាកម្ម។ ប្រភពដើមនៃរូបិយវត្ថុមានប្រវត្តិតាំងពីយូរលង់ណាស់មកហើយ។ កាលពីដើមមករូបិយវត្ថុ គឺធ្វើពីលោហៈធាតុមានតម្លៃដូចជាមាស ប្រាក់ ស្ពាន់ជាដើម ដោយសារវាជាប់ទាក់ទិនទៅនឹងតួនាទីជាមធ្យោបាយដោះដូរ។ ក្រោយមកទៀត បានធ្វើបដិវត្តដោយបានដាក់ជំនួសឱ្យប្រើប្រាស់រូបិយវត្ថុជាប្រដាសប្រាក់វិញ ដែលមានការធានាដោយមាស(GOLD)។ បន្ទាប់មកទៀត ធនាគារបានយល់ឃើញថាវាមិនចាំបាច់មានមាសទេក្នុងការបោះផ្សាយក្រដាសប្រាក់នោះ ក៏គេអាចបោះពុម្ពផ្សាយក្រដាសប្រាក់បានច្រើនជងថែមទៀត បើធៀបនឹងតម្លៃមាសដែលគេមាន។ បន្ទាប់ពីការបោះផ្សាយក្រដាសប្រាក់ដោយធនាគារឯកជនត្រូវបានគេហាមឃាត់មកហើយធនាគារកណ្តាលបានទទួលខុសត្រូវត្រួតពិនិត្យលើបញ្ហានេះវិញ។ មានតែធនាគារកណ្តាលតែប៉ុណ្ណោះ ទើបមានសិទ្ធិបោះផ្សាយក្រដាសប្រាក់ច្រើនជាងមាសដែលពួកគេមាន។ នៅក្នុងចន្លោះពេលសង្គ្រាមលោកលើកទី២ បណ្តាប្រទេសជាច្រើន បានបោះបង់ចោលនូវស្តង់ដារមាស ហើយត្រឡប់មកយកក្រដាសប្រាក់ដែលពួកគេអាចដូរជាមាសបាន។

សេដ្ឋកិច្ចរូបិយវត្ថុ រួមមានសមាសធាតុពីរសំខាន់ គឺមីក្រូសេដ្ឋកិច្ច និងម៉ាក្រូសេដ្ឋកិច្ចនៅក្នុងក្របខ័ណ្ឌសេដ្ឋកិច្ច។ នេះចំណោទបញ្ហានៃមីក្រូសេដ្ឋកិច្ចទាក់ទងនឹងទ្រឹស្តីរូបិយវត្ថុដ៏ត្រឹមត្រូវមួយនៃតម្រូវការរូបិយវត្ថុ និងការផ្គត់ផ្គង់រូបិយវត្ថុ។ ចំណោទបញ្ហានៃម៉ាក្រូសេដ្ឋកិច្ចទាក់ទងនឹងការបង្កើតនូវគោលនយោបាយរូបិយវត្ថុ និងផលប៉ះពាល់របស់វាមកលើសេដ្ឋកិច្ច។ ទ្រព្យសកម្មហិរញ្ញវត្ថុ ក៏អាចបម្រើជាមធ្យោបាយទូទាត់ជំនួសឱ្យតួនាទីរូបិយវត្ថុបានដែលមានការផ្លាស់ប្តូរគ្រប់ពេលវេលា។ ជាភាពត្រឹមត្រូវនៃនិយមន័យរបស់ "រូបិយវត្ថុ" ត្រូវបានបន្តមានការប្រែប្រួលខ្លឹមសារជានិច្ចកាល។

ការវិភាគសេដ្ឋកិច្ចរយៈពេលខ្លីលើសេដ្ឋកិច្ចរូបិយវត្ថុ គឺផ្នែកមួយដ៏សំខាន់នៃម៉ាក្រូសេដ្ឋកិច្ចដែលជាទ្រឹស្តីគំរូសំខាន់ៗម៉ាក្រូសេដ្ឋកិច្ច ដូចជាទ្រឹស្តីគំរូរបស់ក្លាស៊ីកនិយម និងទ្រឹស្តីគំរូរបស់កេនស៍និយម។ ចំពោះការសិក្សាសេដ្ឋកិច្ចលើទ្រឹស្តីគំរូទាំងនោះ បានបកស្រាយពន្យល់លើទ្រឹស្តីលំនឹងសមតានិកម្មភាពពេញលេញ (full employment) ខណៈពេលដែលផ្តោតជាសំខាន់លើគម្លាតរបស់ទីផ្សារដែលឃ្លាតឆ្ងាយពីចំនុចលំនឹងសមតា។

សេដ្ឋកិច្ចរូបិយវត្ថុ គឺជាការសិក្សាលើសេដ្ឋកិច្ចនៃការផ្គត់ផ្គង់រូបិយវត្ថុ កម្រិតថ្លៃ និងអត្រាការប្រាក់ ព្រមទាំងផលប៉ះពាល់របស់វាមកលើសកម្មភាពសេដ្ឋកិច្ច។ សេដ្ឋកិច្ចរូបិយវត្ថុ គឺផ្តោតជាសំខាន់លើទីផ្សាររូបិយវត្ថុ និងទីផ្សារហិរញ្ញវត្ថុ។ ការកំណត់អត្រាការប្រាក់មានវិសាលភាពលើអង្គភាពសេដ្ឋកិច្ច និងផលប៉ះពាល់ដែលទាក់ទងនឹងបរិបទនៃម៉ាក្រូសេដ្ឋកិច្ចទាំងមូល។

ជាទូទៅ ការសិក្សាពីមូលដ្ឋានគ្រឹះគោលនយោបាយរូបិយវត្ថុដោយធនាគារកណ្តាល ឬអាជ្ញាធររូបិយវត្ថុ ការយកចិត្តទុកដាក់ចំពោះការផ្គត់ផ្គង់រូបិយវត្ថុ និងអត្រាការប្រាក់ ហើយយន្តការទាំង២នេះត្រូវបានគេប្រើប្រាស់ដើម្បីធ្វើឱ្យមានប្រសិទ្ធភាពខាងសេដ្ឋកិច្ច។[១] ស្ទើរតែទាំងស្រុងក្របខ័ណ្ឌនៃសេដ្ឋកិច្ចរូបិយវត្ថុ គឺជាមធ្យោបាយទូទាត់ក្នុងចំណោមភ្នាក់ងារសេដ្ឋកិច្ចខុសៗគ្នា មានដូចជាទីផ្សារពលកម្ម ទីផ្សារទំនិញ និងសេវា ឬទីផ្សារមូលបត្របំណុល(សញ្ញាប័ណ្ណ) ដែលសមាសធាតុទាំងនេះបង្កើតបានជារូបិយវត្ថុដែលមិនមែនជាទំនិញ។ ដូច្នេះគ្រប់ប្រតិបត្តិការសេដ្ឋកិច្ចទីផ្សារបើកចំហ ត្រូវបានប្រើប្រាស់សេដ្ឋកិច្ចរូបិយវត្ថុទំនើបដែលសុទ្ធតែពាក់ព័ន្ធនឹងរូបិយវត្ថុទាំងអស់។ ដូចនេះ មានទិដ្ឋភាពខ្លះនៃសេដ្ឋ-កិច្ចរូបិយវត្ថុ ត្រូវបានបោះបង់ចោលតួនាទីរូបិយវត្ថុផងដែរ និងប្រសិទ្ធភាពនៃការផ្តល់ជាបំណុលដែលមានវិសាលភាពលើសេដ្ឋកិច្ចរូបិយវត្ថុដែលមានលក្ខណៈទូលំទូលាយ។

យើងដឹងហើយថា សេដ្ឋកិច្ចរូបិយវត្ថុ គឺមានទាំងផ្នែកទ្រឹស្តីមីក្រូសេដ្ឋកិច្ច និងផ្នែកទ្រឹស្តីម៉ាក្រូសេដ្ឋកិច្ច។ បន្ថែមលើសពីនេះទៀត ការបង្កើតគោលនយោបាយរូបិយវត្ថុរបស់ធនាគារកណ្តាល ឬ "អាជ្ញាធររូបិយវត្ថុ" ត្រូវបានបង្កើតនូវគោលនយោបាយនេះ សម្រាប់ប្រព័ន្ធធនាគារកណ្តាលនៃប្រទេសរបស់ពួកគេ។[២] ដូចនេះ ប្រធានបទដ៏សំខាន់នេះ ត្រូវបានផ្តល់នូវសិទ្ធិផ្តាច់មុខរបស់ធនាគារកណ្តាលដែលគ្របដណ្តប់លើមីក្រូសេដ្ឋកិច្ច ឬម៉ាក្រូសេដ្ឋកិច្ចនៃសេដ្ឋកិច្ចរូបិយវត្ថុ។

### ១.១.២- មីក្រូសេដ្ឋកិច្ចជាផ្នែកមួយនៃសេដ្ឋកិច្ចរូបិយវត្ថុ (Microeconomics part of monetary economics)

មីក្រូសេដ្ឋកិច្ច គឺជាផ្នែកមួយនៃសេដ្ឋកិច្ចរូបិយវត្ថុដោយផ្តោតទៅលើការសិក្សាពីតម្រូវការរូបិយវត្ថុ និងការផ្គត់ផ្គង់រូបិយវត្ថុ រួមទាំងចំណុចលំនឹងសមតាទីផ្សារ។ ការសិក្សាអំពីសេដ្ឋកិច្ចរូបិយវត្ថុ មិនអាចគ្រប់ជ្រុងជ្រោយនោះទេ បើសិនពុំបានសិក្សាពីស្ថាប័នហិរញ្ញវត្ថុ(financial institutions)ទៀតនោះ។

ស្ថាប័នសំខាន់ៗនៃការផ្គត់ផ្គង់រូបិយវត្ថុរបស់ស្តុករូបិយវត្ថុ ដូចជាធនាគារកណ្តាល និងធនាគារពាណិជ្ជ។ ធនាគារពាណិជ្ជខ្លួនឯង គឺជាផ្នែកមួយនៃប្រព័ន្ធអន្តរការីហិរញ្ញវត្ថុដែលកាន់កាប់រូបិយវត្ថុយ៉ាងទូលំទូលាយដែលកម្រិតការផ្គត់ផ្គង់រូបិយវត្ថុ ដូចជាជំនួសឱ្យរូបិយវត្ថុដែលត្រូវបានគេស្គាល់ថាជាសាច់ប្រាក់ប្រហាក់ប្រហែល(near-monies)។

[១] *Even an economy that starts out without money soon discovers its usefulness and creates it in some form or other. The classic article by Radford (1945) provides an illustration of the evolution of money from a prisoner-of-war camp in Germany during the Second World War.*

[២] *In the United States and Canada, the control of monetary policy rests solely with the central bank, so that the centralbank alone constitutes the "monetary authority". In the United Kingdom, control over the goals of monetary policy rests with the government while its implementation rests with the Bank of England (the central bank), so that the "monetary authority" in the UK is composed of the government in the exercise of its powers over monetary policy and the central bank.*

សមាសធាតុសំខាន់ពីរនៃទ្រឹស្តីនៃមីក្រូសេដ្ឋកិច្ច គឺជាផ្នែកមួយនៃសេដ្ឋកិច្ចរូបិយវត្ថុដែលជាតម្រូវការរូបិយវត្ថុ និងការផ្គត់ផ្គង់រូបិយវត្ថុ(នឹងមានការសិក្សាលម្អិតនៅពេលបន្ទាប់)។ ធនាគារកណ្តាលមានតួនាទីបង្កើតគោលនយោបាយរូបិយវត្ថុដែលមានផ្នែកបន្ទាប់នៃសៀវភៅនេះ ។

### ១.១.៣- ម៉ាក្រូសេដ្ឋកិច្ចជាផ្នែកមួយនៃសេដ្ឋកិច្ចរូបិយវត្ថុ ( Macroeconomics part of monetary economics: money in the macroeconomy )

ក្នុងទ្រឹស្តីម៉ាក្រូសេដ្ឋកិច្ច គឺជាផ្នែកមួយនៃសេដ្ឋកិច្ចរូបិយវត្ថុដែលត្រូវបានគេដាក់បញ្ចូលទៅក្នុងទ្រឹស្តីម៉ាក្រូសេដ្ឋកិច្ចសម្រាប់សេដ្ឋកិច្ចរយៈពេលខ្លី។ សេដ្ឋកិច្ចរូបិយវត្ថុ គឺជាបាតុភូតសេដ្ឋកិច្ចដែលមានឥទ្ធិពលលើអថេរនៃម៉ាក្រូសេដ្ឋកិច្ចស្ទើរតែទាំងស្រុងសម្រាប់សេដ្ឋកិច្ចរយៈពេលខ្លី។

នៅក្នុងចំណោមអថេរម៉ាក្រូសេដ្ឋកិច្ចដែលកើតឡើងដោយការប្រែប្រួលការផ្គត់ផ្គង់រូបិយវត្ថុ និងតម្រូវការរូបិយវត្ថុ គឺជាលទ្ធផលនៃនិកម្មភាព អត្រាអនិកម្មភាព ការនាំចេញ ការនាំចូល អត្រាប្តូរប្រាក់ និងតុល្យភាពនៃជញ្ជីងទូទាត់។ ក្នុងចំណោមសំណួរសំខាន់ៗក្នុងការវិភាគទ្រឹស្តីម៉ាក្រូសេដ្ឋកិច្ច *ថាតើបម្រែបម្រួលនៃការផ្គត់ផ្គង់រូបិយវត្ថុ កម្រិតថ្លៃ អតិផរណា និងអត្រាការប្រាក់ ដែលមានផលប៉ះពាល់ដល់អថេរនៃម៉ាក្រូសេដ្ឋកិច្ច ជាពិសេសទិន្នផលជាតិសរុប និងនិកម្មភាពដែរឬទេ?*។

ភាពចាកចេញពីប្រពៃណីរូបិយវត្ថុនៅក្នុងការវិភាគសេដ្ឋកិច្ច ត្រូវបានផ្តល់ការវិភាគលើគំរូម៉ូដែលរូបិយវត្ថុពីមួយជំនាន់ទៅមួយជំនាន់។ ទាំងនេះ មានផលប៉ះពាល់ពីភាពខុសៗគ្នាចំពោះគោលនយោបាយរូបិយវត្ថុ និងផលប៉ះពាល់របស់រូបិយវត្ថុមកលើសេដ្ឋកិច្ចសម្រាប់ការវិភាគទ្រឹស្តីគំរូម៉ូដែលម៉ាក្រូសេដ្ឋកិច្ចសម្រាប់សេដ្ឋកិច្ចរយៈពេលខ្លី។ មានសៀវភៅជាច្រើនបានសរសេរពី "សេដ្ឋកិច្ចរូបិយវត្ថុ" នេះ ដោយមិនបានរាប់បញ្ចូលម៉ូដែលនៃរូបិយវត្ថុ ដែលត្រួតជាន់គ្នាឡើយ។ ប៉ុន្តែវាមានការអភិវឌ្ឍន៍ម៉ូដែលថ្មីៗយ៉ាងសំខាន់ក្នុងទ្រឹស្តីសេដ្ឋកិច្ចរូបិយវត្ថុ។ សម្រាប់ការសិក្សាវិភាគនេះ មានសរសេរនៅក្នុងសៀវភៅដែលមានចំណងជើងថា "Monetary Economics" ត្រូវបានបង្ហាញនៅក្នុងជំពូកទី ២១ ដល់ ២៣។

ការវិភាគសេដ្ឋកិច្ចរូបិយវត្ថុសេដ្ឋកិច្ចរយៈពេលវែង គឺមិនសូវមានភាពទូលំទូលាយទេ។ ខណៈពេលខ្លះទ្រឹស្តីកំណើនម៉ាក្រូសេដ្ឋកិច្ច ត្រូវបានគេរាប់បញ្ចូលទាំងរូបិយវត្ថុផងដែរ ដែលជាលទ្ធផលទ្រឹស្តីនៃកំណើនសេដ្ឋកិច្ចរូបិយវត្ថុ គឺគ្រាន់តែជាផ្នែកតូចមួយនៃសេដ្ឋកិច្ចរូបិយវត្ថុប៉ុណ្ណោះ។ មានវិធីសាស្ត្រផ្សេងៗគ្នាជាច្រើន ចំពោះការសិក្សាវិភាគទ្រឹស្តីម៉ាក្រូសេដ្ឋកិច្ចនៃគោលនយោបាយរូបិយវត្ថុ។ ទ្រឹស្តីគំរូទាំងនេះរួមបញ្ចូលទាំងគំរូម៉ូដែលរបស់ពួកក្លាស៊ីក ( classical ) ច្បាប់របស់វ៉ាល់រ៉ាសៀន ( Walrasian ) និងគំរូម៉ូដែលពួកនេអូក្លាស៊ីក ( neoclassical ) ព្រមទាំងគំរូម៉ូដែលរបស់លោកកេនស៍ បានរួមបញ្ចូលទាំងគំរូម៉ូដែលរបស់នេអូកេនស៍(ថ្មី)ផងដែរ។

## ១.២- តើរូបិយវត្ថុគឺជាអ្វី? ( What is money? )

### ១.២.១- មុខងាររូបិយវត្ថុ ( Functions of money )

រូបិយវត្ថុគឺមិនមែនជាទ្រព្យសកម្មនោះទេ។ ដោយហេតុថា "ទ្រព្យសកម្ម" បានដើរតួជារូបិយវត្ថុ

មានទំនោរប្រែប្រួលទៅតាមពេលវេលាតាមប្រទេសណាមួយក្នុងចំណោមប្រទេសភាគច្រើន។ រូបិយវត្ថុត្រូវបានគេរកឃើញដោយឯករាជ្យពីទ្រព្យសកម្ម ជាពិសេសវាអាចមានក្នុងសកម្មភាពសេដ្ឋកិច្ចនៅពេលណាមួយ។ ទ្រឹស្ដីនៃរូបិយវត្ថុ ត្រូវបានកំណត់ពីមុខងាររបស់វានៅក្នុងការអនុវត្តន៍រូបិយវត្ថុ។

សង្គមត្រូវការរូបិយវត្ថុសម្រាប់គោលបំណងជាច្រើន។ មុខងារទី១៖ សារសំខាន់នៃរូបិយវត្ថុ គឺផ្ដល់តម្លៃស្ដង់ដារ និងជាគ្រឿងដំណូរសម្រាប់ការវាយតម្លៃ និងការដោះដូរអ្វីៗនៅពេលបច្ចុប្បន្ន។ មុខងារទី២៖ ជាមុខងារអនាគតនៃរូបិយវត្ថុ គឺការផ្ទេរតម្លៃពីអំឡុងពេលមួយទៅអំឡុងពេលមួយទៀតដែលជាអំឡុងពេលអនាគត។ លក្ខណៈពិសេសនៃតួនាទីរបស់រូបិយវត្ថុ គេសង្កេតឃើញមានតួនាទីសំខាន់បួនយ៉ាងគឺ៖

- មធ្យោបាយដោះដូរ (Medium of exchange/payments)៖ ជាមធ្យោបាយដោះដូរឱ្យមានប្រសិទ្ធភាពបំផុតនោះ រូបិយវត្ថុមានលក្ខណៈមួយចំនួន វាត្រូវទទួលស្គាល់ជាស្រេចទៅហើយសម្រាប់ប្រទេសជាតិមួយ។ វាមានតម្លៃខ្ពស់បើធៀបទៅនឹងទម្ងន់របស់វា ត្រូវតែបែងចែកបានព្រោះរូបិយវត្ថុដែលមានតែតម្លៃធំវាគ្មានប្រយោជន៍ ព្រោះតែប្រតិបត្តិការដែលមានតម្លៃតិចតួច ប៉ុណ្ណោះ ទីបំផុតវាត្រូវតែមានការលំបាកក្នុងការធ្វើក្លែងក្លាយ។
- រក្សាតម្លៃ ឬស្តុកតម្លៃ (Store of value)៖ រូបិយវត្ថុ គឺជាមធ្យោបាយដ៏ងាយស្រួល ក្នុងការរក្សាអំណាចនៃការទិញ។ ដើម្បីបំពេញតួនាទីរូបិយវត្ថុត្រូវតែមានតម្លៃថេរ ការកើនឡើងនៃកម្រិតថ្លៃគឺបន្ថយនូវអំណាចនៃរូបិយវត្ថុផងដែរ។ ពេលកម្រិតថ្លៃថេរកម្លាំងរូបិយវត្ថុជាក់លាក់មួយក៏ថេរដែរ។ វាជាមធ្យោបាយនៃការជំនួសតម្លៃជាក់លាក់លើទំនិញ និងសេវាកម្ម។ ដូច្នេះវាជាឯកតាគណនី ឬជាស្តង់ដារតម្លៃ គឺជាឯកតារូបិយវត្ថុដែលគេប្រើប្រាស់ដើម្បីវាស់តម្លៃទំនិញ និងសេវាកម្មដែលពាក់ព័ន្ធនឹងទំនិញ និងសេវាកម្មដទៃទៀត។ មធ្យោបាយដទៃទៀតនៃការពិពណ៌នារូបិយវត្ថុជាឯកតាគណនី គឺត្រូវនិយាយថាជាស្តង់ដារតម្លៃដែលអនុញ្ញាតឱ្យអ្នកធ្វើប្រតិបត្តិការប្រៀបធៀបតម្លៃទំនិញ និងសេវាកម្មផ្សេងៗដែលពាក់ព័ន្ធ។
- ឯកតាគណនី (Unit of account)៖ *ថាតើរូបិយវត្ថុអាចដើរតួនាទីជាមធ្យោបាយទូទាត់បានដែរឬទេ?* បាន ឬមិនបាននោះ វាអាស្រ័យទៅលើ *ថាតើនោះយល់ព្រមផ្ទេរពីអតិថិជនមួយទៅអតិថិជនមួយទៀតបានដែរឬទេ?* តាមសំណូមពរអតិថិជននោះ។
- ស្តង់ដារនៃពន្យាពេលការទូទាត់ (Standard of deferred payments)

ក្នុងចំណោមមុខងារទាំងនេះ មធ្យោបាយទូទាត់ គឺជាមុខងារដ៏សំខាន់បំផុតនៃរូបិយវត្ថុ។ ទ្រព្យសកម្មទាំងនេះ មិនត្រូវបានអនុវត្តជាមុខងារទូទាត់ដោយផ្ទាល់ ឬដោយប្រយោលតាមរយៈរូបិយវត្ថុដូចជារូបិយវត្ថុជាមធ្យោបាយទូទាត់ឡើយ។ ជាទូទៅ ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច ចាំបាច់ត្រូវមានទ្រព្យសកម្មឱ្យបានច្រើនដែលអាចដើរតួនាទីអភិវឌ្ឍន៍នេះ។

ទ្រព្យសកម្មអនុវត្តតួនាទីទាំងនេះ មានភាពខុសប្លែកគ្នាទៅតាមកាលៈទេសៈជាមួយនឹងរូបិយវត្ថុជាមធ្យោបាយទូទាត់តែមួយ ឬមធ្យោបាយទូទាត់ដ៏ចាំបាច់ នៅដំណាក់កាលដំបូងការវិវត្តនៃសេដ្ឋកិច្ចរូបិយវត្ថុ។ រូបិយវត្ថុត្រូវបានបំពេញមុខងារជាប្រាក់បញ្ញើដែលមានតម្រូវការជាមួយការមកដល់នៃប្រព័ន្ធ

ធនាគារ។ ហើយបន្ទាប់មក មានការកើនឡើងទ្រព្យសកម្មហិរញ្ញវត្ថុនៅពេលដែលអន្តរការីហិរញ្ញវត្ថុផ្សេងទៀតត្រូវបានបង្កើតឡើង។

▪ *តើការកាន់កាប់រូបិយវត្ថុជាអ្វី?*

ការចំណាយដែលមិនទទួលបានការប្រាក់ (រូបិយវត្ថុដែលមិនទទួលបានការប្រាក់) និងប្រាក់ចំណេញពីការកាន់កាប់រូបិយវត្ថុ គឺជាទ្រព្យដែលមិនទទួលបានការប្រាក់ខ្ពស់ ឬការវិនិយោគ ឬជាការបាត់បង់ការប្រាក់ដោយសាររូបិយវត្ថុមិនបានវិនិយោគនូវទ្រព្យដែលមានជម្រើសទាំងនេះ។

### ១.២.២- លក្ខណៈពិសេសនៃរូបិយវត្ថុ ( Feature of money )

លក្ខណៈពិសេសនៃរូបិយវត្ថុ ត្រូវតែមានលក្ខណៈពិសេសជាក់លាក់។ តម្លៃនៃរូបិយវត្ថុ គឺធំជាងរូបិយវត្ថុទំនិញ ( Commodity money ) ហើយគេអាចកែរូបិយវត្ថុបានទេ ប៉ុន្តែគេអាចចម្លងវាបាន។

១. សារសំខាន់នៃការចែកចាយ

បន្ទាប់ពីរូបិយវត្ថុជាច្រើនមានតម្លៃដូចគ្នាជារបស់ប្រើប្រាស់ដែលរូបិយវត្ថុធ្វើជាគ្រឿងដំណូរ។ នៅពេលរូបិយវត្ថុជាគ្រឿងដំណូរ ឬជាការរក្សាតម្លៃ (ស្តុក) មានតម្លៃសេដ្ឋកិច្ចជាទំនិញសម្រាប់អ្នកប្រើប្រាស់ ឬជាកត្តាផលិតកម្មដែលមិនមែនជាតួនាទីរបស់រូបិយវត្ថុនោះ គេហៅរូបិយវត្ថុថាជារូបិយវត្ថុទំនិញ។

២. ការទទួលយក

រូបិយវត្ថុ គឺត្រូវតែមានតម្លៃ ដូចនេះអាចទទួលយកបានការផ្គត់ផ្គង់រូបិយវត្ថុត្រូវតែមានកំណត់ទាក់ទងនឹងតម្រូវការ និងសមត្ថភាពរបស់ប្រទេសក្នុងការបោះផ្សាយរូបិយវត្ថុ។ ការខ្លាចថាភាគីឯកជន និងមិនត្រូវបានរឹតបណ្តឹងនូវការបោះផ្សាយរូបិយវត្ថុបណ្តាលឲ្យធនាគារកណ្តាល ត្រូវតែអត្រាលើគ្រឹះស្ថានហិរញ្ញវត្ថុ។

៣. ស្ថិរភាពថ្លៃ

ស្ថិរភាពថ្លៃនៃរូបិយវត្ថុ គឺសំខាន់ផងដែរ ប្រសិនបើរូបិយវត្ថុដំណើរការរលូនទៅមុខ ជាពិសេសនៅពេលដែលរូបិយវត្ថុត្រូវបានគេកំពុងប្រើប្រាស់ជាការរក្សាតម្លៃ (ស្តុក) វាមានសារសំខាន់ណាស់ដែលថា របស់វាអត់មានការប្រែប្រួល។

រូបិយវត្ថុដែលពុំមានស្ថិរភាពអាចបង្កឲ្យមានការពិបាកនូវការប្រើប្រាស់ជាគ្រឿងដំណូរ ប្រសិនបើមនុស្សបាត់បង់ជំនឿលើរូបិយវត្ថុ ពួកគេព្យាយាមបោះចោលរូបិយវត្ថុរបស់គេឲ្យលឿនតាមលទ្ធភាពដែលអាចធ្វើទៅបាន។ កំណើនអត្រាបង្វិលរូបិយវត្ថុធ្លាក់ចុះកាន់តែលឿន។

៤. រូបិយវត្ថុស្របច្បាប់

ប្រភេទរូបិយវត្ថុជាក់លាក់ ត្រូវបានប្រកាសដោយច្បាប់ថារូបិយវត្ថុស្របច្បាប់។ គោលបំណងនៃប្រកាសរូបិយវត្ថុនេះ គឺដើម្បីបង្កើនការទទួលយកបាន។ គ្រប់រូបិយប័ណ្ណទាំងអស់ ទាំងកាស និងជា

រូបិយប័ណ្ណក្រដាស គឺជារូបិយប័ណ្ណស្របច្បាប់ក្នុងចំនួនប៉ុន្មានក៏ដោយ (ចំនួនណាមួយក៏បាន)។ បើទោះបីជាប្រាក់បញ្ញើតម្រូវការ (Demand deposit) ជារូបិយវត្ថុសំខាន់បំផុតរបស់យើង គឺរូបិយប័ណ្ណស្របច្បាប់ ឬជាមូលប្បទានប័ត្រក៏ដោយច្បាស់ណាស់ ទោះបីជាអ្វីមួយជារូបិយវត្ថុស្របច្បាប់ ឬមិនស្របច្បាប់ក៏ដោយ ក៏មិនស្ថិតនៅត្រង់ថាតើវាជារូបិយវត្ថុ ឬមិនមែនរូបិយវត្ថុអ្វីនោះទេ។ រូបិយវត្ថុមានតម្លៃដោយសារតែការប្រើប្រាស់ និងភាពកម្រារបស់វាដែលទាក់ទងគ្នា។

### ១.២.៣- ការកំណត់ប្រភេទរូបិយវត្ថុ (Determinded of money)

ជាប្រវត្តិសាស្ត្រការឱ្យនិយមន័យពី "រូបិយវត្ថុ" ត្រូវបានកំណត់ដោយបរិមាណរូបិយវត្ថុ (money quantity) នៅក្នុងសេដ្ឋកិច្ច ដូចជាផលបូកនៃគ្រប់ធាតុទាំងអស់ដែលជាប្រព័ន្ធនៃមធ្យោបាយទូទាត់នៅក្នុងសេដ្ឋកិច្ច។ ទោះយ៉ាងណាក៏ដោយសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចរូបិយវត្ថុ មានឧបករណ៍ទូទាត់ដទៃផ្សេងទៀត មិនបានបម្រើជាមធ្យោបាយទូទាត់ដោយផ្ទាល់ទេ ប៉ុន្តែវាអាចបម្លែងទៅជាមធ្យោបាយទូទាត់តាមរយៈការចំណាយថ្លៃដើមតិចតួច និងអាចជាឃ្លាំងស្តុកនៃតម្លៃក្នុងពេលដំណាលគ្នា។ ជាតុទាំងនោះ អាចជំនួសជាមធ្យោបាយទូទាត់ដោយខ្លួនឯងផ្ទាល់។ ដូច្នេះ មានវិធានការជាច្រើនបានជជែករកខុសត្រូវ និងការខ្វែងគំនិតគ្នា ថាតើត្រូវផ្តល់និយមន័យ "រូបិយវត្ថុ" ក្នុងន័យតូចចង្អៀតជាមធ្យោបាយទូទាត់ ឬបញ្ចូលជាតុទាំងនោះជំនួសឱ្យជាមធ្យោបាយទូទាត់វិញម្តង។[៣]

ដោយផ្អែកលើទ្រឹស្តីដើម្បីឆ្លើយតបនឹងសំណួរទាំងនេះ ផ្តោតទៅលើការអនុវត្តន៍ជាក់លាក់របស់៖ "រូបិយវត្ថុ" គឺជាឧបករណ៍ដែលបម្រើដោយផ្ទាល់ជាមធ្យោបាយទូទាត់។ ការអភិវឌ្ឍន៍សេដ្ឋកិច្ចហិរញ្ញវត្ថុត្រូវបានប្រើរូបិយប័ណ្ណដែលបានកាន់កាប់ដោយសាធារណជន និងប្រាក់បញ្ញើធនាគារដែលអាចពិនិត្យដោយសាធារណជនក្នុងស្ថាប័នហិរញ្ញវត្ថុភាគច្រើន ដូចជាធនាគារពាណិជ្ជកម្មជាដើម ដោយផលបូករបស់វាត្រូវបានគេកំណត់និមិត្តសញ្ញា "M1" ហៅថារូបិយវត្ថុចង្អៀត។ ការដាក់រូបិយវត្ថុដែលអាចពិនិត្យមើលបាន ឬមានតម្រូវការបាន គឺសំណួរមួយដែលការដករូបិយវត្ថុអាចធ្វើឡើងដោយមូលប្បទានប័ត្រ ឬប័ណ្ណឥណពន្ធ។ ដូច្នេះ ការផ្លាស់ប្តូររូបិយវត្ថុជំនួសឱ្យសាច់ប្រាក់ ត្រូវបានគេចាត់ទុកថាជាមធ្យោបាយនៃការទូទាត់ត្រូវបានគេហៅថា "ប្រហាក់ប្រហែលនឹងសាច់ប្រាក់ប្រហាក់ប្រហែល (near-monies)"។ សម្រាប់ចម្លើយដែលមានលក្ខណៈជាក់ស្តែង ចំពោះការឱ្យនិយមន័យស្តុករូបិយវត្ថុ (money stock) គឺមានលក្ខណៈពិសេសជាងសមិទ្ធផលខាងផ្នែកទ្រឹស្តីរបស់វា ។ វាអាចជារូបិយវត្ថុតូចចង្អៀត ឬរូបិយវត្ថុធំទូលាយ អាស្រ័យលើអ្វីដែលអាចជំនួសទៅនឹងមធ្យោបាយទូទាត់ ត្រូវបានរាប់បញ្ចូល ឬដកចេញ។

សរុបជារួមនិយមន័យ "រូបិយវត្ថុ" ត្រូវបានគេទទួលស្គាល់យ៉ាងទូលំទូលាយនៅក្នុងចំណោមអ្នកសេដ្ឋកិច្ច ដែលត្រូវបានគេស្គាល់ថាជាទ្រឹស្តីរបស់រូបិយវត្ថុនិយម គឺលោក Milton Friedman ។ បានឱ្យ

[៣] *A bill of exchange is a promissory note issued by a buyer of commodities and promises to pay a specified sum of money to the seller on a specific future date. As such, they arise in the course of trade where the buyer does not pay for the goods immediately but is extended credit for the value of the goods for a short period, often three months. This delay allows the buyer time to sell the goods, so that the proceeds can be used to pay the original seller. In the nineteenth century, bills of exchange issued by reputable firms could be traded in the financial markets or discounted (i.e. sold at a discount to cover the interest) with banks. Some of them passed from hand to hand (i.e. were sold several times).*

និយមន័យរូបិយវត្ថុ គឺជាបរិមាណរូបិយប័ណ្ណនៅក្នុងដៃរបស់សាធារណជន និងប្រាក់បញ្ញើសាធារណៈទាំងអស់នៅក្នុងធនាគារពាណិជ្ជកម្ម។ ហើយបន្ទាប់មកទៀត មានរួមបញ្ចូលប្រាក់បញ្ញើតាមតម្រូវការក៏ដូចជាប្រាក់បញ្ញើសន្សំក្នុងធនាគារពាណិជ្ជកម្មដែរ។ តាមរយៈលោក Friedman បានកំណត់ប្រភេទ "រូបិយវត្ថុ" ដោយកំណត់និមិត្តសញ្ញាប្រភេទរូបិយវត្ថុ M2 ដែលត្រូវបានគេកំណត់ថា M2+, M2++ ឬ M2A, M2B។ល។ ទោះយ៉ាងណា ឥឡូវនេះមានការប្រើប្រាស់និមិត្តសញ្ញារូបិយវត្ថុជាច្រើន ដែលជាទូទៅគេបានកំណត់និមិត្តសញ្ញាប្រភេទរូបិយវត្ថុ M3 និង M4។ ល។

លោក Milton Friedman បានកំណត់និយមន័យយ៉ាងទូលំទូលាយទៅលើប្រភេទរូបិយវត្ថុ M2 គឺផលបូករវាងប្រាក់បញ្ញើក្នុងគណនីធនាគាជាស្ថាប័នហិរញ្ញវត្ថុមានប្រាក់បញ្ញើក្នុងគណនីធនាគារ និងមុខងារស្មើរដូចគ្នា សម្រាប់អ្នកដាក់ប្រាក់បញ្ញើដែលប្រាក់បញ្ញើស្រដៀងគ្នាក្នុងគណនីធនាគារពាណិជ្ជដែរ។ ឧទាហរណ៍៖ ស្ថាប័នហិរញ្ញវត្ថុទាំងនេះ គឺសមាគមសន្សំ និងប្រាក់កម្ចី និងធនាគារសន្សំនៅសហរដ្ឋអាម៉េរិក សហជីពឥណទាន និងក្រុមហ៊ុនផ្តល់ប្រាក់កម្ចីមានទ្រព្យបញ្ចាំនៅកាណាដា និងជាស្ថាប័នហិរញ្ញវត្ថុនៅចក្រភពអង់គ្លេសជាដើម។

ការដាក់បញ្ចូលប្រាក់បញ្ញើបែបនេះទៅក្នុងរង្វាស់នៃរូបិយវត្ថុ ត្រូវបានកំណត់ដោយនិមិត្តសញ្ញាប្រភេទរូបិយវត្ថុ M3, M4 ។ល។ និងប្រភេទរូបិយវត្ថុ M2A, M2B ឬប្រភេទរូបិយវត្ថុ M2+, M2++ ។ល។ លក្ខណៈសម្គាល់និមិត្តសញ្ញាទាំងនេះមិនបានក្លាយជាស្តង់ដារនោះទេ ហើយនៅតែមានលក្ខណៈពិសេសទៅតាមបណ្តាប្រទេសនីមួយៗ។ លក្ខណៈពិសេសរបស់វា ជាមូលដ្ឋានសម្រាប់ការជ្រើសរើសក្នុងចំណោមប្រភេទរូបិយវត្ថុ។

## ១.៣- ការផ្គត់ផ្គង់រូបិយវត្ថុ និងស្តុករូបិយវត្ថុ (Money supply & money stock)

រូបិយវត្ថុ គឺជាទំនិញដែលដូចគ្នានឹងទំនិញផ្សេងទៀតដែរ ដែលមានតម្រូវការ និងការផ្គត់ផ្គង់ដោយភ្នាក់ងារសេដ្ឋកិច្ចក្នុងសេដ្ឋកិច្ច។ កត្តាកំណត់ខ្លះទៀត គឺតម្រូវការរូបិយវត្ថុ (money demand) និងការផ្គត់ផ្គង់រូបិយវត្ថុ (money supply) ដែលជាកត្តាកំណត់សំខាន់បំផុតនៃតម្រូវការរូបិយវត្ថុ គឺជាប្រាក់ចំណូលជាតិ (national income) កម្រិតថ្លៃ (price level) និងកម្រិតអត្រាការប្រាក់ (intere st rates) ខណៈពេលដែលការផ្គត់ផ្គង់រូបិយវត្ថុ គឺជាឥរិយាបថរបស់ធនាគារកណ្តាលនៃប្រទេសនីមួយៗ ដែលត្រូវបានផ្តល់អំណាចឱ្យគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុ និងដឹកនាំការផ្លាស់ប្តូរវា។ បរិមាណរូបិយវត្ថុត្រង់ចំណុចលំនឹងសមតាសម្រាប់ទីផ្សាររូបិយវត្ថុ គឺជាទីផ្សារស្តុករូបិយវត្ថុ (money stock) ហើយផ្ទុយមកវិញ ការផ្គត់ផ្គង់រូបិយវត្ថុ (money supply) ដែលមានមុខងាររូបិយវត្ថុបញ្ជាក់អំពីបរិមាណការផ្គត់ផ្គង់រូបិយវត្ថុក្នុងកម្រិតអត្រាការប្រាក់ និងប្រាក់ចំណូលផ្សេងៗទៀត។ បរិមាណសមតារូបិយវត្ថុ គឺជាបរិមាណរូបិយវត្ថុដែលបរិមាណតម្រូវការរូបិយវត្ថុ និងបរិមាណការផ្គត់ផ្គង់រូបិយវត្ថុស្មើគ្នា។ សម្រាប់ការផ្គត់ផ្គង់រូបិយវត្ថុ និងស្តុករូបិយវត្ថុ គឺមានភាពដូចគ្នាបេះបិទក្នុងករណីដែលការផ្គត់ផ្គង់រូបិយវត្ថុ ត្រូវបានរឹតបណ្តឹងយ៉ាងខ្លាំងតាមរយៈគោលការណ៍របស់ធនាគារកណ្តាល។ ករណីបែបនេះ វាឯករាជ្យលើអត្រាការប្រាក់ និងអថេរសេដ្ឋកិច្ចផ្សេងទៀត ទោះបីជាវាអាចមានឥទ្ធិពលរបស់វាក៏ដោយ។ មានហេតុផលជាច្រើនលើទ្រឹស្តីរបស់រូបិយវត្ថុ និងម៉ាក្រូសេដ្ឋកិច្ច ដែលបានបង្កើតពាក្យថា "ស្តុករូបិយ

វត្ថុ" និង "ការផ្គត់ផ្គង់រូបិយវត្ថុ" ត្រូវបានគេប្រើជាសទិសន័យនេះ។ ការគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុ ស្ថិតក្រោមអាជ្ញាធររូបិយវត្ថុ ឬធនាគារកណ្ដាល។ គោលនយោបាយរបស់ពួកគេទាក់ទងនឹងការផ្លាស់ប្ដូរការផ្គត់ផ្គង់រូបិយវត្ថុ ត្រូវបានគេស្គាល់ថាជាគោលនយោបាយរូបិយវត្ថុ។

### ១.៣.១- ការផ្គត់ផ្គង់រូបិយវត្ថុ ( Money supply )[៤]

#### ១.៣.១.១- តើអ្វីជាការផ្គត់ផ្គង់រូបិយវត្ថុ ?( What Is the Money Supply ? )

សហរដ្ឋអាម៉េរិកសម្រាប់ការផ្គត់ផ្គង់រូបិយវត្ថុ រួមមានរូបិយប័ណ្ណ (currency) ជាក្រដាសប្រាក់ និងកាស (N&C) បានចេញផ្សាយដោយធនាគារកណ្ដាលសហរដ្ឋ (Fed) និងរតនាគារសហរដ្ឋ និងមានប្រាក់បញ្ញើច្រើនប្រភេទទៀត ដែលកាន់កាប់ដោយសាធារណជននៅក្នុងធនាគារពាណិជ្ជ និងស្ថាប័នតម្កល់ប្រាក់ដទៃផ្សេងៗទៀត ដូចជាគ្រឹះស្ថានទទួលប្រាក់បញ្ញើ និងសហគមឥណទានជាដើម។

ឧទាហរណ៍៖

នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៤ ការផ្គត់ផ្គង់រូបិយវត្ថុរបស់ធនាគារកណ្ដាលសហរដ្ឋ (Fed) ត្រូវបានវាស់វែងជាផលបូករូបិយប័ណ្ណ និងគណនីប្រាក់បញ្ញើមាន ១,៣៣៣ពាន់លានដុល្លារអាម៉េរិក។ រួមមានទាំងប្រភេទប្រាក់បញ្ញើសន្សំមួយចំនួនក្នុងការផ្គត់ផ្គង់រូបិយវត្ថុមាន ៦,២៧៥ ពាន់លានដុល្លារអាម៉េរិក។ វិធានការវាស់វែងកាន់តែធំទូលំទូលាយការផ្គត់ផ្គង់រូបិយវត្ថុមាន ៩,២៧៥ ពាន់លានដុល្លារអាម៉េរិក។ វិធានការទាំងនេះ ត្រូវគ្នានឹងនិយមន័យទាំងបីយ៉ាងនៃរូបិយវត្ថុដែលធនាគារកណ្ដាលបានប្រើមានដូចជា៖

- M1 ជាវិធានតូចចង្អៀតនៃមុខងាររូបិយវត្ថុជាមធ្យោបាយដោះដូរ។
- M2 ជាវិធានទូលំទូលាយដែលឆ្លុះបញ្ចាំងពីមុខងាររូបិយវត្ថុជាឃ្លាំងនៃតម្លៃ។
- M3 នៅតែជាវិធានទូលំទូលាយដែលគ្របដណ្ដប់លើប្រភេទ ដែលចាត់ទុកជាជំនួសរូបិយវត្ថុយ៉ាងជិតស្និទ្ធ។ និយមន័យនៃរូបិយវត្ថុ គឺមានភាពខុសៗគ្នា។

អស់រយៈកាលជាច្រើនសតវត្សរ៍មក សម្រាប់រូបវន្តជាទំនិញដែលភាគច្រើនជាកាសប្រាក់ ឬកាសមាស ត្រូវបានបម្រើជារូបិយវត្ថុ។ ក្រោយមកទៀត រូបិយវត្ថុដែលជាក្រដាស និងកាស (N&C) ជាប្រាក់បញ្ញើត្រូវបានគេណែនាំឱ្យប្ដូរជារូបិយវត្ថុទំនិញវិញ។ ការបោះបង់ចោលរូបិយវត្ថុ(ក្រដាស និងកាស) ទៅជារូបិយវត្ថុទំនិញ បានចាប់ផ្ដើមពីថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧១ នៅពេលដែលប្រធានាធិបតី Richard M. Nixon ឈប់បន្តប្ដូរក្រដាសប្រាក់ដុល្លារជានឹងមាស ៣៥ ដុល្លារក្នុងមួយអោន បានធ្វើឱ្យប្រាក់របស់សហរដ្ឋអាម៉េរិក និងប្រទេសដទៃទៀតជាក្រដាសប្រាក់(fiat)។ រូបិយវត្ថុ គឺក្រដាសប្រាក់ជាតិនៃអាជ្ញាធររូបិយវត្ថុ ឬធនាគារកណ្ដាលមានអំណាចក្នុងការបោះផ្សាយដោយគ្មានឧបសគ្គផ្នែកផ្លូវច្បាប់ឡើយ។

---

[៤] *Anna J. Schwartz is an economist at the National Bureau of Economic Research in New York. She is a distinguished fellow of the American Economic Association.*

### ១.៣.១.២- ហេតុអ្វីការផ្គត់ផ្គង់ប្រាក់មានសារសំខាន់? (Why Is the Money Supply Important)?

ដោយសាររូបិយវត្ថុ ត្រូវបានប្រើក្នុងប្រតិបត្តិការសេដ្ឋកិច្ចស្ទើរតែទាំងស្រុង វាមានឥទ្ធិពលខ្លាំងទៅលើសកម្មភាពសេដ្ឋកិច្ច។ ការកើនឡើងនៃការផ្គត់ផ្គង់រូបិយវត្ថុ ធ្វើឱ្យបញ្ចុះអត្រាការប្រាក់ដែលជួយជំរុញការធ្វើវិនិយោគទុន និងតាមរយៈការដាក់ប្រាក់បញ្ញើកាន់តែច្រើន ដែលមានក្នុងដៃរបស់អ្នកប្រើប្រាស់ធ្វើឱ្យពួកគេមានអារម្មណ៍ថាពួកគេមានទ្រព្យសម្បត្តិ ដូច្នេះបានជំរុញឱ្យការចំណាយកើនឡើង។ ក្រុមហ៊ុនអាជីវកម្ម ឆ្លើយតបនឹងការកើនឡើងនៃការលក់ដោយការបញ្ជាទិញវត្ថុធាតុដើមកាន់តែច្រើន និងបង្កើនផលិតកម្ម។ ការរីករាលដាលនៃសកម្មភាពអាជីវកម្ម បង្កើននូវតម្រូវការកម្លាំងពលកម្ម (ទីផ្សារពលកម្ម) និងបង្កើនតម្រូវការទំនិញមូលធន។ ក្នុងសេដ្ឋកិច្ចមានការរីកចម្រើនតម្លៃភាគហ៊ុនរបស់ទីផ្សារភាគហ៊ុន (stock market) ហើយក្រុមហ៊ុននានាបានចេញផ្សាយភាគហ៊ុន និងប័ណ្ណបំណុល។ ប្រសិនបើការផ្គត់ផ្គង់ប្រាក់នៅតែបន្តពង្រីកតម្លៃ ការចាប់ផ្តើមកើនឡើងជាពិសេស ប្រសិនបើកំណើនទិន្នផលសរុបឈានដល់កម្រិតសមត្ថភាព។ ខណៈពេលដែលសាធារណជនចាប់ផ្តើមរំពឹងថានឹងទទួលបានប្រាក់កម្ចីអ្នកផ្តល់ប្រាក់កម្ចីទទូចឱ្យមានអត្រាការប្រាក់ខ្ពស់ ដើម្បីទូទាត់ការធ្លាក់ចុះនៃអំណាចទិញដែលរំពឹងទុកក្នុងរយៈពេលនៃប្រាក់កម្ចីរបស់ពួកគេ។ ផលប៉ះពាល់ផ្ទុយគ្នាកើតឡើងនៅពេលដែលការផ្គត់ផ្គង់ប្រាក់ធ្លាក់ចុះ ឬនៅពេលដែលអត្រាកំណើនរបស់វាធ្លាក់ចុះ។ សកម្មភាពសេដ្ឋកិច្ចធ្លាក់ចុះ ព្រមទាំងការចុះខ្សោយអតិផរណា (បន្ថយអតិផរណា) ឬបរិត្តផរណា (ថ្លៃធ្លាក់ចុះ)។

### ១.៣.១.៣- តើអ្វីដែលកំណត់ការផ្គត់ផ្គង់រូបិយវត្ថុ? (What Determines the Money Supply?)

គោលនយោបាយរបស់ធនាគារកណ្តាលសហរដ្ឋ(Fed) គឺជាកំណត់កត្តាសំខាន់ៗសម្រាប់ការផ្គត់ផ្គង់រូបិយវត្ថុ។ ធនាគារកណ្តាលសហរដ្ឋ មានឥទ្ធិពលដល់ការផ្គត់ផ្គង់រូបិយវត្ថុភាគច្រើន គឺពាក់ព័ន្ធនឹងប្រាក់បញ្ញើធនាគារ។ នេះជារបៀបដែលវាដំណើរការគោលនយោបាយរបស់វា។ សម្រាប់ធនាគារសហព័ន្ធសហរដ្ឋ តម្រូវឱ្យស្ថាប័នតម្កល់ប្រាក់ (ធនាគារពាណិជ្ជកម្ម និងស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត) ត្រូវរក្សាទុកទុនបម្រុងនៃបំណុលប្រាក់បញ្ញើដែលបានកំណត់។ ស្ថាប័នប្រាក់បញ្ញើត្រូវតែកាន់កាប់ប្រាក់បម្រុងទាំងនេះជាសាច់ប្រាក់នៅក្នុងគណនី ឬម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ (ATM) និងប្រាក់បញ្ញើធនាគារសហព័ន្ធសហរដ្ឋ។ ក្នុងការត្រួតពិនិត្យរបស់ធនាគារសហព័ន្ធសហរដ្ឋ ផ្តល់ប្រាក់កម្ចីដល់ស្ថាប័នតម្កល់ប្រាក់ និងការផ្លាស់ប្តូរបញ្ចុះតម្លៃប្រាក់បម្រុងទុករបស់ធនាគារសហព័ន្ធលើប្រាក់កម្ចីទាំងនោះ និងប្រតិបត្តិការទីផ្សារបើកចំហ (OMO)។ ធនាគារសហព័ន្ធសហរដ្ឋ ប្រើប្រាស់ប្រតិបត្តិការទីផ្សារបើកចំហ ដើម្បីបង្កើនទុនបម្រុង ឬបន្ថយទុនបម្រុង។ ការបង្កើនទុនបម្រុងធនាគារសហព័ន្ធសហរដ្ឋ ដោយទិញមូលប័ត្ររតនាគារអាមេរិក (U.S. Treasury Securities) ដែលចារឹកជាមូលប្បទានប័ត្រដែលកំណត់ដោយខ្លួនឯង។ អ្នកលក់មូលប័ត្រ បានដាក់ប្រាក់ជាមូលប្បទានប័ត្រទៅក្នុងធនាគារដែលបង្កើនប្រាក់បញ្ញើរបស់អ្នកលក់។ ជាលទ្ធផល ធនាគារដាក់ប្រាក់បញ្ញើជាមូលប្បទានប័ត្រនៅធនាគារ

សហព័ន្ធសហរដ្ឋរបស់ខ្លួន ដូច្នេះបង្កើនបានទុនបម្រុងរបស់ខ្លួន។ ផ្ទុយគ្នាមកវិញ ការកេកើតឡើងជាបន្តបន្ទាប់នៅពេលដែលធនាគារសហព័ន្ធលក់មូលប័ត្ររតនាគារៈ ប្រាក់បញ្ញើរបស់អ្នកទិញបានធ្លាក់ចុះ ហើយលទ្ធផលប្រាក់បម្រុងរបស់ធនាគារក៏ធ្លាក់ចុះ។ ប្រសិនបើ ធនាគារសហព័ន្ធសហរដ្ឋ បង្កើនប្រាក់បម្រុងរបស់ធនាគារតែមួយ អាចធ្វើឱ្យប្រាក់កម្ចីដែលជាប្រាក់បម្រុងលើសកំណត់បង្កើតបរិមាណប្រាក់បញ្ញើស្មើគ្នា។ បើទោះយ៉ាងណា ប្រព័ន្ធធនាគារអាចបង្កើនការពង្រីកប្រាក់បញ្ញើបានច្រើន។ ដោយសារធនាគារនីមួយៗផ្តល់ប្រាក់កម្ចី និងបង្កើតប្រាក់បញ្ញើធនាគារ ហើយវាបាត់បង់ប្រាក់បម្រុងនៅធនាគារផ្សេងទៀត ដែលប្រើវាដើម្បីបង្កើនប្រាក់កម្ចី ហើយបង្កើតប្រាក់បញ្ញើថ្មីរហូតដល់ប្រាក់បម្រុងលើស ត្រូវបានប្រើ។

ប្រសិនបើអនុបាតទុនបម្រុងកាតព្វកិច្ច គឺថាប្រមាណ ១០ភាគរយ បន្ទាប់មកចាប់ផ្តើមពីចំនួនទឹកប្រាក់ ១,០០០ដុល្លារ ដែលធនាគារអាចឱ្យប្រាក់កម្ចីត្រឹមតែ ៩០០ ដុល្លារ ដើម្បីរក្សាទុកជាទុនបម្រុង ១០០ដុល្លារ ធៀបនឹងប្រាក់បញ្ញើដែលបានដំឡើងក្នុងពេលដំណាលគ្នា។ នៅពេលដែលអ្នកឱ្យប្រាក់កម្ចី បានសរសេរចេញជាមូលប្បទានប័ត្រផ្ទុយពីចំនួនទឹកប្រាក់ក្នុងគណនីធនាគារ (A) សម្រាប់អ្នកទទួលប្រាក់បញ្ញើដាក់ចូលក្នុងធនាគារ(B)។ ប្រាក់បញ្ញើតាមតម្រូវការថ្មីដែលធនាគារទទួលបាននឹងបង្កើតចំនួនទឹកប្រាក់បម្រុងថ្មីស្មើគ្នា។ ឥឡូវធនាគារ (B) នឹងមានប្រាក់បម្រុងបន្ថែមទឹកប្រាក់ ៩០០ ដុល្លារ ក្នុងនោះត្រូវតែរក្សាទុកប្រាក់បម្រុងចំនួន ៩០ដុល្លារ ដូច្នេះវាអាចខ្ចីប្រាក់បានតែចំនួន ៨១០ ដុល្លារតែប៉ុណ្ណោះ។ សរុបជារួម ប្រាក់កម្ចីជាថ្មីនៃប្រព័ន្ធធនាគារដែលផ្តល់ប្រាក់កម្ចីសរុបក្នុងឧទាហរណ៍នេះមានចំនួន១០ ដងនៃចំនួនទឹកប្រាក់បម្រុងលើស ឬ$៩,០០០៖ ៩០០+៨១០+៧២៩+៦៥៦.១+៥៩០.៥ ។ល។ ក្នុងប្រព័ន្ធដែលមានតម្រូវការប្រាក់បម្រុងកាតព្វកិច្ចកើនឡើង ប្រាក់បម្រុងរបស់ធនាគារអាចគាំទ្រដល់ការពង្រីកប្រាក់បញ្ញើច្រើន ហើយការធ្លាក់ចុះនេះអាចបណ្តាលឱ្យមានការធ្លាក់ចុះនៃប្រាក់បញ្ញើច្រើន។ មេគុណតម្លៃ គឺអាស្រ័យទៅលើសមាមាត្រប្រាក់បម្រុងដែលមានតម្រូវការលើប្រាក់បញ្ញើ។ អនុបាតប្រាក់បម្រុងកាតព្វកិច្ចខ្ពស់ អាចធ្វើឱ្យតម្លៃនៃមេគុណធ្លាក់ចុះ។ អនុបាតប្រាក់បម្រុងកាតព្វកិច្ចទាបបង្កើននូវតម្លៃនៃមេគុណ។

ក្នុងឆ្នាំ ២០០៤ ធនាគារដែលមានទឹកប្រាក់បញ្ញើសរុប ៧លានដុល្លារ ត្រូវបានរួចផុតពីតម្រូវការប្រាក់បម្រុងកាតព្វកិច្ចរក្សាទុក។ អ្នកដែលមានទឹកប្រាក់លើសពី ៧លានដុល្លារ ប៉ុន្តែតិចជាង ៤៧,៦លានដុល្លារ ជាប្រាក់បញ្ញើមូលប្បទានដែលតម្រូវឱ្យរក្សាទុនបម្រុង ៣ភាគរយ ក្នុងគណនីប្រាក់បម្រុង។ រីឯអ្នកដែលមានគណនីមូលប្បទានប័ត្រដែលមានចំនួន ៤៧,៦លានដុល្លារ ឬច្រើនជាងនេះ គឺតម្រូវឱ្យរក្សាបម្រុង ១០ភាគរយ មិនតម្រូវឱ្យមានការបម្រុងទុកផ្ទុយនឹងប្រាក់បញ្ញើមានកាលកំណត់នោះទេ។ ទោះបីជាមិនមានប្រាក់បម្រុងកាតព្វកិច្ចស្របច្បាប់សម្រាប់ធនាគារក៏ដោយ ក៏ពួកគេនៅតែបន្តរក្សាសមតុល្យទូទាត់ដែលត្រូវការទុនបម្រុងជាមួយនឹងធនាគារសហព័ន្ធ ដែលមានសមត្ថភាពក្នុងការគ្រប់គ្រង បរិមាណប្រាក់បញ្ញើមិនត្រូវបានចុះខ្សោយឡើយ។ ធនាគារបន្តរក្សាប្រាក់បម្រុងដើម្បីឱ្យពួកគេអាចទូទាត់បំណុលដែលកើតឡើងពីប្រតិបត្តិការជាមួយធនាគារផ្សេងទៀត ដើម្បីទទួលបានរូបិយប័ណ្ណដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកដាក់ប្រាក់បញ្ញើ និងចៀសវាងឱនភាពដែលជាលទ្ធផលអតុល្យភាពក្នុងការទូទាត់។ សមាសធាតុរូបិយប័ណ្ណនៃការផ្គត់ផ្គង់រូបិយវត្ថុដោយប្រើនិយមន័យប្រភេទ

រូបិយវត្ថុ M2 គឺតូចជាងសមាសធាតុប្រាក់បញ្ញើ។ រូបិយប័ណ្ណរួមបញ្ចូលទាំងក្រដាសប្រាក់ និងកាសរបស់ធនាគារសហព័ន្ធផងដែរ។ ក្រុមប្រឹក្សាភិបាល បានដាក់ចេញបទបញ្ជាជាមួយនឹងការិយាល័យចារកម្ម និងគ្រឹះស្ថានបោះពុម្ពផ្សាយក្រដាសប្រាក់ និងកាសរបស់ធនាគារសហព័ន្ធសម្រាប់ធនាគារទាំងអស់។ បន្ទាប់មកបែងចែកក្រដាសប្រាក់ទៅឱ្យធនាគារបម្រុងនីមួយៗទាំងនោះ។ បច្ចុប្បន្ននេះ ក្រដាសប្រាក់ និងកាស មិនត្រូវបានសម្គាល់ដោយសារតែត្រាក្នុងស្រុកនីមួយៗទៀតទេ។ ជាទូទៅ ធនាគារសហព័ន្ធសហរដ្ឋ បានកាប់កាប់ក្រដាសប្រាក់ និងកាសនៅក្នុងគណនីរបស់ពួកគេរហូតដល់មានការលក់ទៅឱ្យធនា- គារពាណិជ្ជ ដែលបង់ឱ្យក្រុមហ៊ុនដឹកជញ្ជូនឯកជន ដើម្បីយកសាច់ប្រាក់ពីធនាគារបម្រុងក្នុងស្រុករបស់ពួកគេ។ ធនាគារដកប្រាក់ពីគណនីបម្រុងរបស់ធនាគារពាណិជ្ជក្នុងការទូទាត់ សម្រាប់តម្រូវការក្រដាសប្រាក់ និងកាសរបស់អតិថិជន។ នៅពេលដែលតម្រូវការសម្រាប់ក្រដាសប្រាក់ធ្លាក់ចុះ ធនាគារបម្រុងទទួលយកលំហូរត្រឡប់មកវិញ ក្រដាសប្រាក់ពីធនាគារពាណិជ្ជ និងផ្តល់ប្រាក់កម្ចីបម្រុងរបស់ពួកគេ។

ក្រុមហ៊ុនផលិតក្រដាសប្រាក់ និងកាសរបស់សហរដ្ឋអាមេរិក សម្រាប់ការចែកចាយដោយធនាគារសហព័ន្ធសហរដ្ឋ។ ក្រុមប្រឹក្សាភិបាលដាក់បញ្ជាទិញវត្ថុធាតុដើមរ៉ែឱ្យសមរម្យ។ ប្រព័ន្ធនេះទិញកាសតាមតម្លៃ ចំពោះមុខរបស់វាដោយបញ្ចូលក្នុងគណនីរបស់រតនាគារសហរដ្ឋនៃធនាគារបម្រុង (Fed)។ ប្រព័ន្ធធនាគារសហព័ន្ធរក្សាទុកកាសរបស់ខ្លួន ដែលក្រុមហ៊ុនដឹកជញ្ជូនជាកម្មសិទ្ធិ និងប្រតិបត្តិការ។ ធនាគារពាណិជ្ជ ទិញកាសតាមតម្លៃពីធនាគារបម្រុងដែលទទួលការទូទាត់ដោយការដកប្រាក់គណនីបម្រុងរបស់ធនាគារពាណិជ្ជ។ ធនាគារពាណិជ្ជបង់ថ្លៃចំណាយទាំងស្រុងក្នុងការដឹកជញ្ជូនក្រដាសប្រាក់ និងកាស(N&C)។ នៅក្នុងប្រព័ន្ធធនាគារសហព័ន្ធមួយចំណែកលំហូររូបិយប័ណ្ណពីធនាគារ បានកាត់បន្ថយប្រាក់បម្រុងរបស់ខ្លួន ហើយលុះត្រាធនាគារសហព័ន្ធផ្តល់នូវបរិមាណទឹកប្រាក់បន្ថែមនៃរូបិយប័ណ្ណបម្រុងគ្រប់គ្រាន់ និងប្រាក់បម្រុងទុក សម្រាប់ការដាក់ប្រាក់បញ្ញើច្រើនធ្វើឱ្យបរិមាណប្រាក់មានការថយចុះ។ រូបិយប័ណ្ណ និងប្រាក់បម្រុងធនាគារ បានបូកបញ្ចូលគ្នាស្មើគ្នានឹងមូលដ្ឋានរូបិយវត្ថុដែលពេលខ្លះត្រូវបានគេស្គាល់ថា ប្រាក់ដែលមានថាមពលខ្ពស់។ ធនាគារសហព័ន្ធ មានអំណាចគ្រប់គ្រងបញ្ហានៃសមាសធាតុទាំងពីរ តាមរយៈការកែសម្រួលសមតុល្យប្រាក់បម្រុងរបស់ធនាគារ ក្នុងរយៈពេលជាច្រើនត្រីមាស វាអាចសម្រេចបានអត្រាកំណើនប្រាក់បញ្ញើ និងការផ្គត់ផ្គង់រូបិយវត្ថុដែលចង់បាន។ ធនាគារសហព័ន្ធ អាចទូទាត់ផលប៉ះពាល់លើការផ្គត់ផ្គង់រូបិយវត្ថុដោយការផ្លាស់ប្តូរប្រាក់ បម្រុង និង/ឬរូបិយប័ណ្ណ។ ប្រសិនបើធនាគារសហព័ន្ធកំណត់ទំហំការផ្គត់ផ្គង់រូបិយវត្ថុ *ថាតើអ្វីដែលធ្វើឱ្យតម្លៃនាមករណ៍ដែលមានស្រាប់ស្មើនឹងចំនួនទឹកប្រាក់ដែលប្រជាជនចង់កាន់កាប់?* ការផ្លាស់ប្តូរអត្រាការប្រាក់ គឺជាមធ្យោបាយមួយដើម្បីធ្វើឱ្យមានការឆ្លើយឆ្លងការកើតឡើង។ ការធ្លាក់ចុះអត្រាការប្រាក់បង្កើនបរិមាណរូបិយវត្ថុដែលមនុស្សចង់កាន់កាប់ ខណៈពេលដែលការកើនឡើងអត្រាការប្រាក់ថយចុះនូវបរិមាណរូបិយវត្ថុ។ ការផ្លាស់ប្តូរកម្រិតថ្លៃ គឺវិធីមួយផ្សេងទៀតដើម្បីធ្វើឱ្យការផ្គត់ផ្គង់រូបិយវត្ថុស្មើនឹង បរិមាណទឹក ប្រាក់ដែលមានតម្រូវការ។ នៅពេលដែលមនុស្សកាន់ដុល្លារនាមករណ៍កាន់តែច្រើនជាងអ្វីដែលពួកគេចង់បាន ពួកគេចំណាយវាលឿនជាងមុនដែលជាហេតុបណ្តាលឱ្យថ្លៃរបស់វាកើនឡើង។ ការកើនឡើងថ្លៃទាំងនេះ កាត់បន្ថយអំណាចទិញរបស់រូបិយវត្ថុរហូតដល់បរិមាណ ដែលមនុស្សចង់បានស្មើនឹង

បរិមាណដែលមាន។ ផ្ទុយទៅវិញ នៅពេលមនុស្សកាន់រូបិយវត្ថុតិចជាងអ្វីដែលពួកគេចង់បាន ពួកគេចំណាយយឺតៗបណ្តាលឱ្យថ្លៃធ្លាក់ចុះ។ ជាលទ្ធផល តម្លៃបច្ចុប្បន្ននៃរូបិយវត្ថុ ដែលមានស្រាប់ស្មើនឹងបរិមាណទឹកប្រាក់ដែលមនុស្សមានបំណងកាន់កាប់ប៉ុណ្ណោះ។

### ១.៣.១.៤- ការប្រែប្រួលទុនបម្រុងធនាគារសហព័ន្ធ

(Changing Federal Reserve)

ធនាគារសហព័ន្ធសហរដ្ឋ(Fed)សម្រេចកម្រិតទុនបម្រុងដែលចង់បានទាំងការឱ្យប្រាក់កម្ចីដែលធនាគារទទួលបានបង្អួចអប្បហារ (discount window) និងទុនបម្រុងដែលមិនត្រូវផ្តល់ប្រាក់កម្ចីដែលបានផ្តល់ដោយការទិញតាមរយៈប្រតិបត្តិការទីផ្សារបើកចំហ ដែលមានការប្រែប្រួលគួរឱ្យកត់សម្គាល់។ ធនាគារកណ្តាល បានគ្រប់គ្រងបរិមាណទុនបម្រុង និងការឱ្យខ្ចីប្រាក់ដោយធនាគារជាសមាជិកមានការប្រែប្រួលអត្រាបង្អួចអប្បហារ (discount window)។ តាមទ្រឹស្តីការនៃការឱ្យប្រាក់កម្ចីធ្វើឱ្យធនាគារជាសមាជិកស្ទាក់ស្ទើរក្នុងការពង្រីកប្រាក់កម្ចី ពីព្រោះបំណងប្រាថ្នារបស់ពួកគេដើម្បីសងបំណុលរបស់ខ្លួនទៅឱ្យធនាគារសហព័ន្ធឱ្យបានឆាប់តាមដែលអាចធ្វើទៅបានត្រូវបានគេសន្មតថា រាំងស្ទះដល់ឆន្ទៈរបស់ពួកគេក្នុងការសម្រួលដល់អ្នកសុំប្រាក់កម្ចី។

ក្នុងទសវត្សរ៍ឆ្នាំ១៩២០ ខណៈពេលដែលធនាគារសហព័ន្ធ បានរកឃើញថាប្រតិបត្តិការទីផ្សារបើកចំហក៏បង្កើតទុនបម្រុងដែរ ពោលគឺជាការប្រែប្រួលទុនបម្រុងដែលគ្មានប្រាក់កម្ចីបានផ្តល់នូវវិធីសាស្ត្រដែលមានប្រសិទ្ធភាពជាងមុន ដើម្បីទូទាត់ការផ្លាស់ប្តូរដែលមិនចង់បានក្នុងការឱ្យខ្ចីប្រាក់ពីធនាគារជាសមាជិក។

ក្នុងទសវត្សរ៍ឆ្នាំ១៩៥០ ធនាគារសហព័ន្ធ បានស្វះស្វែងការគ្រប់គ្រងអ្វីដែលគេហៅថាទុនបម្រុងឥតគិតកម្រៃសេវា ឬប្រាក់បម្រុងលើសដែលដកចេញពីធនាគារជាសមាជិកផ្តល់នូវប្រាក់កម្ចី។ ធនាគារសហព័ន្ធ បានបកស្រាយថាការដំឡើងអត្រាការប្រាក់ គឺថាជាការរឹតត្បិតនយោបាយរូបិយវត្ថុ។ ការទម្លាក់អត្រាការប្រាក់ គឺជាការបន្ធូរបន្ថយនូវគោលនយោបាយរូបិយវត្ថុ។ ប៉ុន្តែអត្រាការប្រាក់ គឺចង្អុលបង្ហាញមិនល្អឥតខ្ចោះនៃគោលនយោបាយរូបិយវត្ថុនោះទេ។ ប្រសិនបើ គេរំពឹងថាគោលនយោបាយរូបិយវត្ថុងាយនឹងបង្កអតិផរណាអ្នកផ្តល់ប្រាក់កម្ចីទាមទារអត្រាការប្រាក់ខ្ពស់ជាងមុន ដើម្បីទូទាត់សងសម្រាប់អតិផរណានេះ ហើយអ្នកខ្ចីប្រាក់មានឆន្ទៈក្នុងការបង់អត្រាខ្ពស់ ពីព្រោះអតិផរណាកាត់បន្ថយថ្លៃប្រាក់ដុល្លារដែលពួកគេសងត្រឡប់មកវិញ។

ដូច្នេះការកើនឡើងអតិផរណាដែលរំពឹងទុក នឹងបង្កើននូវអត្រាការប្រាក់។ ជាឧទាហរណ៍រវាងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៩ សម្រាប់ឧបករណ៍គោលនយោបាយរូបិយវត្ថុរបស់សហរដ្ឋអាម៉េរិកមានភាព ងាយស្រួល ហើយអត្រាការប្រាក់បានកើនឡើង។ ស្រដៀងគ្នានេះ ប្រសិនបើគោលនយោបាយរូបិយវត្ថុតឹងតែងត្រូវបានគេរំពឹងទុកថានឹងកាត់បន្ថយអតិផរណាអត្រាការប្រាក់អាចនឹងធ្លាក់ចុះ។

ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨២ តាមរយៈលោក Paul Volcker ដែលជាប្រធានធនាគារសហព័ន្ធ បានព្យាយាមគ្រប់គ្រងទុនបម្រុងដែលមិនឱ្យខ្ចីប្រាក់ ដើម្បីសម្រេចគោលដៅរូបិយវត្ថុរបស់ខ្លួន។ នីតិវិធីនេះ បានបង្កើតការផ្លាស់ប្តូរយ៉ាងច្រើនទាំងកំណើនប្រាក់ និងអត្រាការប្រាក់។ ការជំរុញមិនឱ្យខ្ចីប្រាក់

បម្រុងធ្លាក់ចុះ នៅពេលគោលដៅខាងលើនាំឱ្យការខ្ចីប្រាក់បម្រុងកើនឡើង ព្រោះធនាគារសហព័ន្ធបានអនុញ្ញាតឱ្យធនាគារអាចចូលទៅកាន់បង្អួចអប្បហារ (discount window) នៅពេលដែលពួកគេស្វែងរកប្រភពប្រាក់បម្រុងនេះ។ តាំងពីពេលនោះមក ធនាគារសហព័ន្ធ បានកំណត់ជួរតូចចង្អៀតនូវអត្រាមូលនិធិរបស់ធនាគារសហព័ន្ធ ដែលអត្រាការប្រាក់កម្ចីពីធនាគារមួយទៅធនាគារមួយទៀត ជាឧបករ-ណ៍ដើម្បីសម្រេចគោលបំណងរបស់ខ្លួន។ បើទោះបីជា ធនាគារសហព័ន្ធមិនធ្វើអន្តរកម្មដោយផ្ទាល់ក្នុងទីផ្សារមូលនិធិរបស់ធនាគារសហព័ន្ធក៏ដោយ ខណៈពេលដែលធនាគារសហព័ន្ធកំណត់អត្រាមូលនិធិខ្ពស់វាធ្វើឱ្យអត្រាខ្ពស់ជាងនេះ ការកាត់បន្ថយប្រាក់បម្រុងដែលវាផ្ដល់ឱ្យប្រព័ន្ធហិរញ្ញវត្ថុទាំងមូល។ នៅពេលវាបញ្ជាក់ពីអត្រាមូលនិធិធនាគារសហព័ន្ធទាបជាង វាបង្កើតផ្ដល់នូវទុនបម្រុងកើនឡើង។ អត្រាការប្រាក់ទីផ្សារធនាគារសហព័ន្ធខុសគ្នាបន្តិចបន្តួចពីអត្រាការប្រាក់គោលដៅ (target rate)។

ប្រសិនបើគម្លាតកាន់តែខ្លាំងនោះ គឺជាសញ្ញាមួយដល់ធនាគារសហព័ន្ធថា ប្រាក់បម្រុងដែលខ្លួនបានផ្ដល់មិនសមស្របនឹងអត្រាមូលនិធិដែលខ្លួនបានប្រកាសនោះទេ។ វានឹងបង្កើន ឬកាត់បន្ថយទុនបម្រុងអាស្រ័យលើគម្លាត។ ការផ្លាស់ប្ដូរដ៏ធំធេងក្នុងគោលបំណងធនាគារសហព័ន្ធក្រោមការដឹកនាំបន្តវេនរបស់លោក Alan Greenspan បានទទួលស្គាល់ថាការទទួលខុសត្រូវដ៏សំខាន់របស់ខ្លួន គឺដើម្បីការគ្រប់គ្រងអតិផរណា។ ធនាគារកណ្ដាល បានអនុម័តគោលដៅច្បាស់លាស់សម្រាប់អតិផរណានាពេលអនាគត។ ភាពជោគជ័យក្នុងការសម្រេចគោលដៅរបស់ខ្លួនធ្វើឱ្យវាអាចទុកចិត្តបាន។ គោលដៅរបស់ធនាគារកណ្ដាល បានក្លាយជាអត្រាអតិផរណាដែលរំពឹងទុករបស់សាធារណជន។

ចាប់តាំងពីបង្កើតធនាគារសហព័ន្ធនៅឆ្នាំ ១៩១៣ រហូតមកដល់ចុងបញ្ចប់សង្គ្រាមលោកលើកទី២ ដែលការផ្គត់ផ្គង់រូបិយវត្ថុមាននិន្នាការកើនឡើងខ្ពស់ជាងការកើនឡើងកម្រិតកំណើនផលិតផលជា-តិសរុបមានតែនាម GNP(growth of nominal GNP)។ ការកើនឡើងសមាមាត្រនៃការផ្គត់ផ្គង់រូបិយវត្ថុធៀបនឹងផលិតផលជាតិសរុប (GNP) បង្ហាញពីការកើនឡើងបរិមាណរូបិយវត្ថុ ដែលជាចំណែកនៃប្រាក់ចំណូលរបស់ពួកគេដែលប្រជាជនចង់កាន់កាប់។

ចាប់តាំងពីឆ្នាំ១៩៤៦ ដល់ឆ្នាំ១៩៨០ ផលិតផលជាតិសរុបមានតែនាម (GNP) មាននិន្នាការកើនឡើងក្នុងអត្រាខ្ពស់ជាងកំណើននៃការផ្គត់ផ្គង់រូបិយវត្ថុ ដែលនេះចង់បង្ហាញថាសាធារណៈកាត់បន្ថយសមតុល្យរូបិយវត្ថុទាក់ទងនឹងប្រាក់ចំណូលរបស់ខ្លួន។ រហូតមកដល់ឆ្នាំ១៩៨៦ សម្រាប់សមតុល្យរូបិយវត្ថុបានកើនឡើងទាក់ទងនឹងប្រាក់ចំណូល។ ចាប់តាំងពីពេលនោះមក ពួកគេមានការធ្លាក់ចុះទាក់ទងនឹងប្រាក់ចំណូល។ ពួកសេដ្ឋវិទូពន្យល់អំពីចលនាទាំងនេះ ដោយសារតែការផ្លាស់ប្ដូរការរំពឹងទុកនៃកម្រិតថ្លៃ ក៏ដូចជាការផ្លាស់ប្ដូរអត្រាការប្រាក់ដែលធ្វើឱ្យរូបិយវត្ថុកាន់កាប់តែច្រើន ឬមានការថយចុះរូបិយវត្ថុ។

ប្រសិនបើកម្រិតថ្លៃត្រូវបានគេរំពឹងថានឹងធ្លាក់ចុះ ការលើកទឹកចិត្តដើម្បីរក្សាតុល្យភាពរូបិយវត្ថុមានការកើនឡើង រូបិយវត្ថុនឹងទិញកាន់តែច្រើនថែម ប្រសិនបើការរំពឹងទុកត្រូវបានគេដឹងស្រដៀងគ្នានេះដែរ ប្រសិនបើអត្រាការប្រាក់ធ្លាក់ចុះថ្លៃដើមនៃការរក្សាសមតុល្យរូបិយវត្ថុជាជាងការចំណាយ ឬការវិនិយោគធ្លាក់ចុះ។ ប្រសិនបើកម្រិតថ្លៃត្រូវបានគេរំពឹងថា នឹងកើនឡើង ឬអត្រាការប្រាក់កើនឡើងការកាន់កាប់រូបិយវត្ថុច្រើនជាងការចំណាយ ឬការវិនិយោគចំណាយកាន់តែច្រើន។

ចាប់តាំងពីឆ្នាំ១៩១៤ ការធ្លាក់ចុះនៃការផ្គត់ផ្គង់រូបិយវត្ថុប្រកបដោយចីរភាពបានកើតឡើងក្នុងអំឡុងពេលនៃវដ្តអាជីវកម្មតែ៣ប៉ុណ្ណោះ។ វដ្តនីមួយៗមានលក្ខណៈធ្ងន់ធ្ងរ ត្រូវបានវិនិច្ឆ័យដោយការធ្លាក់ចុះនៃទិន្នផលសរុប និងការកើនឡើងអនិកម្មភាពចន្លោះពីឆ្នាំៈ ១៩២០-១៩២១ ១៩២៩-១៩៣៣ និង១៩៣៧-១៩៣៨។ ភាពធ្ងន់ធ្ងរនៃការធ្លាក់ចុះនៃសេដ្ឋកិច្ចនៅក្នុងការធ្លាក់ចុះនៃវដ្តនីមួយៗទាំងនេះ ត្រូវបានគេទទួលស្គាល់ជាទូទៅ គឺជាផលវិបាកនៃការកាត់បន្ថយបរិមាណរូបិយវត្ថុ ជាពិសេសសម្រាប់ការធ្លាក់ចុះ បានចាប់ផ្តើមក្នុងឆ្នាំ១៩២៩ ខណៈពេលដែលបរិមាណរូបិយវត្ថុធ្លាក់ចុះដែលមិនធ្លាប់កើតមានពីមុនមក។ នៅសហរដ្ឋអាម៉េរិក បានជួបប្រទះនឹងអតិផរណាកម្រិតថ្លៃសំខាន់ៗចំនួនបី ចាប់តាំងពីឆ្នាំ១៩១៤ ហើយកម្រិតថ្លៃនីមួយៗ ត្រូវបាននាំមុខនឹងអមដោយការកើនឡើងនៃអត្រាកំណើននៃការផ្គត់ផ្គង់រូបិយវត្ថុពីឆ្នាំ១៩១៤-១៩២០ ១៩៣៩-១៩៤៨ និង១៩៦៧-១៩៨០។ ការបង្កើនល្បឿន កំណើនរូបិយវត្ថុដែលលើសពីកំណើនផលិតផលជាតិសរុបពិត(realGNP) បានធ្វើឱ្យមានអតិផរណាផលិតកម្មបានកើតមានឡើងយ៉ាងខ្លាំងនៅក្នុងសហរដ្ឋអាម៉េរិក និងទីកន្លែងផ្សេងទៀតលើពិភពលោក។ រហូតដល់ធនាគារសហព័ន្ធ បានអនុម័តគោលដៅអតិផរណាជាក់ស្តែងនៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ស្តីពីការផ្គត់ផ្គង់រូបិយវត្ថុ មាននិន្នាការកើនឡើងយ៉ាងឆាប់រហ័សក្នុងអំឡុងពេលការពង្រីកវដ្តអាជីវកម្ម។ ក្នុងអត្រានៃការកើនឡើងទំនងជាធ្លាក់ចុះមុនពេលដល់ចំណុចកំពូលនៃអាជីវកម្ម និងការកើនឡើងមុនពេលទឹកជំនន់វាមកដល់។ កម្រិតថ្លៃបានកើនឡើងក្នុងអំឡុងពេលការពង្រីក (expansionary) និងបានធ្លាក់ចុះក្នុងអំឡុងពេលការបង្រួម (contractionary)។ គំរូនេះបច្ចុប្បន្នមិនត្រូវបានគេសង្កេត ឃើញទេ។ អត្រាកំណើននៃរូបិយវត្ថុសរុបមានទំនោរទៅរកកម្រិតមធ្យម និងមានស្ថិរភាព បើទោះបីជាធនាគារសហព័ន្ធ ដូចជាធនាគារកណ្តាលភាគច្រើន ឥឡូវនេះមិនអើពើនឹងបរិមាណរូបិយវត្ថុសរុបក្នុងក្របខ័ណ្ឌ និងការអនុវត្តរបស់វាក៏ដោយ។ ជាលទ្ធផល អាចកើតឡើងដោយអចេតនានៃភាពជោគជ័យរបស់ខ្លួនក្នុងការគ្រប់គ្រងកម្រិតអតិផរណា គឺរូបិយវត្ថុសរុបមិនមានអំណាចព្យាករណ៍ទាក់ទងកម្រិតថ្លៃនោះ។ ប្រវត្តិសាស្ត្រនៃការផ្គត់ផ្គង់រូបិយវត្ថុ បានបង្រៀនថា ការមិនអើពើនឹងការផ្លាស់ប្តូរការផ្គត់ផ្គង់រូបិយវត្ថុនៃភាពមិនចុះសម្រុងនៃរូបិយវត្ថុ។ ពេលវេលានឹងប្រាប់ថាតើអវសាន្តនៃរូបិយវត្ថុនាពេលបច្ចុប្បន្នកំពុងស្ថិតស្ថេរ និងជាឧបសគ្គទាំងនោះ។

## ១.៤- អតិផរណា (Inflation)[៥]

សេដ្ឋវិទូប្រើពាក្យ "អតិផរណា" ដើម្បីបញ្ជាក់ពីការកើនឡើងនៃកម្រិតថ្លៃរួម ដែលបានដកស្រង់ចេញពីឯកតានៃរូបិយវត្ថុ។ ទំហំនៃកម្រិតអតិផរណា គឺជាអត្រាអតិផរណាដែលត្រូវបានគេរាយការណ៍ថាជាកំណើនភាគរយប្រចាំឆ្នាំនៃសន្ទស្សន៍យ៉ាងទូលំទូលាយតម្លៃរូបិយវត្ថុ។ ការកើនឡើងតម្លៃនៃរូបិយវត្ថុ (ដុល្លារអាម៉េរិកាំង) សម្រាប់ក្រដាសប្រាក់ ១ដុល្លារ មានអំណាចទិញតិចជាងរាល់ឆ្នាំ។ ហើយជាទូទៅកម្រិតអតិផរណាមានន័យថា ការធ្លាក់ចុះជាបន្តបន្ទាប់នៃអំណាចទិញ (purchasing power) របស់ឯកតានៃរូបិយវត្ថុ (monetary unit)។

[៥] *Lawrence H. White is the F. A. Hayek Professor of Economic History at the University of Missouri, St. Louis.*

អត្រាអតិផរណាខុសៗគ្នាពីមួយឆ្នាំទៅមួយឆ្នាំ ពីរូបិយប័ណ្ណមួយទៅរូបិយប័ណ្ណមួយទៀត។ ចាប់តាំងពីឆ្នាំ១៩៥០ មក អត្រាអតិផរណាជាប្រាក់ដុល្លារអាម៉េរិក ត្រូវបានវាស់វែងដោយការផ្លាស់ប្តូរពីខែធ្នូ ដល់ខែធ្នូ ក្នុងសន្ទស្សន៍នៃថ្លៃទំនិញប្រើប្រាស់ ចាប់ពីកម្រិតអតិផរណាទាប ០.៧ភាគរយ (១៩៥៤) រហូតដល់កម្រិតអតិផរណាខ្ពស់ ១៣.៣ភាគរយ (១៩៧៩)។ ចាប់តាំងពីឆ្នាំ១៩៩១ អត្រាអតិផរណានេះស្ថិតក្នុងរង្វង់ពី១.៦ភាគរយ ទៅដល់ ៣.៣ភាគរយ ក្នុង១ឆ្នាំ។ ចាប់តាំងពីឆ្នាំ១៩៥០ យ៉ាងហោចណាស់ក៏មានប្រទេសចំនួន១៨ បានជួបប្រទះមហាអតិផរណា (HYPERINFLATION) ដែលអត្រាអតិផរណាបានកើនឡើងខ្ពស់ជាង ៥០ភាគរយ នៅក្នុងរយៈពេល១ខែ។ ប៉ុន្មានឆ្នាំថ្មីៗនេះ ប្រទេសជប៉ុនបានជួបប្រទះនូវកម្រិតអតិផរណាអវិជ្ជមាន ឬ "បរិត្តផរណា" ប្រហែលជា ១ភាគរយ ក្នុង១ឆ្នាំ ដូចបានវាស់ដោយសន្ទស្សន៍ថ្លៃ (CPI) របស់ប្រទេសជប៉ុន។ ធនាគារកណ្តាលនៅតាមបណ្តាប្រទេសភាគច្រើន សព្វថ្ងៃមានការព្រួយបារម្ភក្នុងការរក្សាកម្រិតអតិផរណាឱ្យមានកម្រិតទាប ប៉ុន្តែវាមានវិជ្ជមាន។ អ្នកខ្លះបញ្ជាក់គោលដៅសម្រាប់អត្រាអតិផរណា ដែលជាធម្មតាមានកម្រិតអត្រាអតិផរណាពី ១ ទៅ ៣ភាគរយ។

ទោះបីជាសេដ្ឋកិច្ចស្តង់ដារប្រាក់ និងមាស ពេលខ្លះជួបប្រទះអតិផរណាក៏ដោយក៏អត្រាអតិផរ-ណាក្នុងសេដ្ឋកិច្ចបែបនេះកម្រមានលើសពី ២ភាគរយ ក្នុងមួយឆ្នាំណាស់ ហើយជាទូទៅបទពិសោធសតវត្សរ៍មកនេះ គឺកម្រិតអតិផរណាជិតដល់កម្រិតសូន្យ។ សេដ្ឋកិច្ចនៃស្តង់ដារក្រដាសប្រាក់ និងកាសដែលសេដ្ឋកិច្ចសព្វថ្ងៃនេះ បានបង្ហាញអតិផរណាច្រើនជាង។ លោក Peter Bernholz (2003, p.1) បានចង្អុលបង្ហាញថា អតិផរណាអាក្រក់បំផុតបានកើតមានឡើងនៅក្នុងសតវត្សរ៍ទី២០។ តាមបណ្តាប្រទេសដែលប្រើប្រាស់ស្តង់ដាររូបិយវត្ថុលោហៈធាតុលែងមានតទៅទៀតហើយ។ ក្នុងឆ្នាំ១៩៧១ រដ្ឋាភិបាលអាម៉េរិក បានកាត់ផ្តាច់បណ្តាញប្រាក់ដុល្លារអាម៉េរិកចុងក្រោយទៅនឹងមាស ដោយប្តេជ្ញាចិត្តការទូទាត់ប្រាក់ដុល្លារជាមាសតាមអត្រាថេរ (Fixed Rate) សម្រាប់ធនាគារកណ្តាលបរទេស ។ បើទោះជានៅតាមបណ្តាប្រទេសដែលបានចៀសផុតពីអត្រាអតិផរណាឡើងខ្ពស់ក៏ដោយក្នុងឆ្នាំ១៩៧១ ក្តី។ ប៉ុន្តែអត្រាអតិផរណាក្នុងប្រទេសភាគច្រើន គឺមានកម្រិតទាបជាង ចាប់តាំងពីឆ្នាំ១៩៨៥ បើប្រៀបធៀបនឹងឆ្នាំ ១៩៨៥-១៩៧១។

### ១.៤.១- រង្វាស់អតិផរណា (Measuring Inflation)

នៅសហរដ្ឋអាម៉េរិក អត្រាអតិផរណា ត្រូវបានវាស់វែងដោយការកើនឡើងភាគរយនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) ត្រូវបានរាយការណ៍ជាប្រចាំខែដោយការិយាល័យស្ថិតិការងារ (BLS)។ សន្ទស្សន៍តម្លៃទំនិញ ១២០ របស់ចំនួន១២០ ក្នុងរយៈពេលបច្ចុប្បន្នមានន័យថាឥឡូវត្រូវការចំណាយ ១២០ដុល្លារ ដើម្បីទិញកញ្ចប់តំណាងឱ្យទំនិញ ១០០ដុល្លារ ទិញម្តង។ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) មិនមានលក្ខណៈច្បាស់លាស់ដែលអ្នកបានប្រើកើនឡើងភាគរយក្នុងសន្ទស្សន៍នៃថ្លៃទំនិញប្រើប្រាស់គឺល្អបំផុតគ្រាន់តែជាការប៉ាន់ប្រមាណការកើនឡើងភាគរយនៃថ្លៃដើមក្នុងការរស់នៅរបស់អ្នកតែប៉ុណ្ណោះ។ បរិត្តផរណាផលិតផលក្នុងស្រុកសរុប(GDP deflator) គឺតំណាងឱ្យសេដ្ឋកិច្ចទាំងមូល ប៉ុន្តែមិនសូវពាក់ព័ន្ធអ្នកប្រើប្រាស់ធម្មតានោះទេ ពីព្រោះកញ្ចប់ទំនិញ និងសេវារបស់វារួមបញ្ចូលទាំងថ្លៃ

ទំនិញដែលមិនមែនជាសហគ្រាស (បរិក្ខារជំនួញថ្មីៗ) ដែលអតិថិជនមិនទិញ និងមិនរាប់បញ្ចូលថ្លៃទំនិញជាច្រើន និងរួមមានថ្លៃទំនិញផលិតនៅបរទេសដែលអតិថិជនបានទិញ។

### ១.៤.២- មូលហេតុនៃអតិផរណា (Causes of Inflation)

អតិផរណាកើតឡើងអំណាចទិញប្រាក់ដុល្លារធ្លាក់ចុះដល់កម្រិតការផ្គត់ផ្គង់ជាប្រាក់ដុល្លារមានការកើនឡើងលឿនជាងតម្រូវការដាក់ស្តែងដើម្បីកាន់កាប់ដុល្លារ។ វិធីសាស្ត្រស្តង់ដារក្នុងការវិភាគមានទំនាក់ទំនងរវាង (M) និងកម្រិតថ្លៃជាទូទៅ )P)៖ MV = Py ដែល V បង្ហាញពីល្បឿនប្រាក់ចំណូលគិតជាចំនួនដងក្នុង)១ឆ្នាំ ជាមធ្យមដុល្លារប្តូរទៅជាប្រតិបត្តិការសម្រាប់ទំនិញ និងសេវាកម្មចុងក្រោយ ( និងy បង្ហាញពីប្រាក់ចំណូលពិតរបស់សេដ្ឋកិច្ច)ការវាស់វែងដោយផលិតផលក្នុងស្រុកសរុប។( ដោយសារតែ V ត្រូវបានកំណត់ដោយ Py/M ជាសមាមាត្រនៃប្រាក់ចំណូលនាមករណ៍នឹងសមតុល្យរូបិយវត្ថុសមីការខាងក្រោម។ តាមទ្រឹស្តីបរិមាណនៃរូបិយវត្ថុ ទ្រឹស្តីបរិមាណរូបិយវត្ថុនៃទ្រឹស្តីកម្រិតនៃថ្លៃកំណត់ថាជាកម្រិត M ខ្ពស់ ឬទាបជាងនេះមិនបណ្តាលឱ្យមានការផ្លាស់ប្តូរអចិន្ត្រៃយ៍នៃ y ឬ V ដែលចង់បានឬក៏ផ្សេងទៀត មិនប៉ះពាល់ដល់តម្រូវការពិតក្នុងការកាន់កាប់រូបិយវត្ថុជាអចិន្ត្រៃយ៍។ សម្រាប់រយៈពេលវែង M ធំជាងមានន័យថាសមាមាត្រខ្ពស់ជាង P ។ នៅក្នុងន័យជាផ្លូវការ ការដាក់ប្រាក់ដុល្លារកាន់តែច្រើនធ្វើឱ្យលំហូរអំណាចទិញរបស់ដុល្លារនីមួយៗចុះខ្សោយ ឬថ្លៃឡើងនៅពេលដែលមានប្រាក់ដុល្លារច្រើនទៀតដេញតាមបរិមាណនៃទំនិញដូចគ្នា។ ការពិសោធន៍ដែលបានគិតអាចជួយបង្ហាញការគិតនៅពីក្រោយទ្រឹស្តីបរិមាណ ពិចារណាអំពីសេដ្ឋកិច្ចដែលថ្លៃទាំងអស់ស្ថិតនៅក្នុងលំនឹង។ ឥលូវនេះសូម សញ្ជឹងគិត រូបិយវត្ថុទ្វេដងនៃរូបិយវត្ថុដោយបង្កើនលេខទ្វេដងលើរូបិយប័ណ្ណ និងសមតុល្យគណនីធនាគារទាំងអស់រាល់កម្រិតថ្លៃត្រូវបានកើនឡើងទ្វេដងក្នុងពេលដំណាលគ្នា ដើម្បីរក្សាថ្លៃដែលទាក់ទងនឹងអំណាចទិញរបស់មនុស្សម្នាក់ៗ មា)នចំនួនទ្វេដងធ្វើឱ្យ (មានតុល្យភាពរូបិយវត្ថុដូចគ្នាដូច្នេះដើម្បីរក្សាសេដ្ឋកិច្ចឱ្យមានលំនឹងសមតា។ កម្រិតថ្លៃត្រូវតែកើនឡើងសមាមាត្រទៅនឹងបរិមាណរូបិយ វត្ថុ។ សូមសញ្ជឹងគិតថា ធនាគារសហព័ន្ធបានទម្លាក់រូបិយប័ណ្ណឱ្យបានគ្រប់គ្រាន់ ដើម្បីផ្គត់ផ្គង់រូបិយវត្ថុទ្វេដងឱ្យទូទាំងប្រទេស។ ដំណើរការដាក់ស្តែង ធនាគារសហព័ន្ធបានដាក់បញ្ចូលរូបិយវត្ថុថ្មី។ ជាទូទៅតាមរយៈការទិញមូលប័ត្របំណុលក្នុងទីផ្សារបើកចំហជាមួយបំណុលរបស់ធនាគារសហព័ន្ធ បានបង្កើតថ្មីទាំងនេះ។ ក្នុងចំណោមភាពខុសគ្នាផ្សេងទៀត ការចំណាយសម្រាប់ជុំដំបូងនៃរូបិយវត្ថុថ្មី គឺជាមូលប័ត្របំណុលដែលមិនមែនទំនិញសម្រាប់ការប្រើប្រាស់នោះទេ។ ការចំណាយសម្រាប់ជុំទី២ សញ្ញាប័ណ្ណរបស់ធនាគារជាអ្នកលក់នៅក្នុងនោះធនាគារសហព័ន្ធ បានបង្កើតទុនបម្រុងដែលទើបតែបង្កើតថ្មីនឹងទិញមូលប័ត្រ បន្ថែម ការ (ឬធ្វើកម្ចីបន្ថែម)ពង្រីកប្រាក់បញ្ញើរបស់ប្រព័ន្ធធនាគារនៅពេលពួកគេ។ សកម្មភាពរបស់ធនាគារកណ្តាល និងសកម្ម)ភាពជាបន្តបន្ទាប់របស់ធនាគារពាណិជ្ជកម្ម (ពង្រីកការផ្គត់ផ្គង់មូលនិធិដែលអាចខ្ចីបានដែលអាចបន្ថយអត្រាការប្រាក់ពិតបាន។ អ្នកខ្ចីប្រាក់ធនាគារពាណិជ្ជភា)គច្រើនក្រុមហ៊ុនអាជីវកម្ម) យ៉ាងហោចណាស់ជាបណ្តោះអាសន្ន ការឡើងថ្លៃដែលទាក់ទងនឹងទ្រព្យសកម្ម ដែលពួកគេទិញ រោងចក្រ និង)បរិក្ខារ។ សេដ្ឋវិទូជាច្រើនសន្មតថា(ផលប៉ះពាល់ទាក់ទងនឹងថ្លៃបែបនេះ គឺមានលក្ខណៈធ្វេសប្រហែស ប៉ុន្តែ AUSTRIAN SCHOOL បានចាត់ទុកថាមានតួ

នាទីសំខាន់នៅក្នុងទ្រឹស្ដីនៃវដ្តអាជីវកម្ម។ ចំពោះលទ្ធផលតែមួយគត់នៃការពង្រីករូបិយវត្ថុជាក់ស្ដែង ដែលជាការកើនឡើងចំនួនសមាមាត្រស្មើគ្នាយ៉ាងពិតប្រាកដ ក្នុងកម្រិតថ្លៃទាំងអស់ ហើយការចំណាយលើរូបិយវត្ថុថ្មីមិនត្រូវជំរុញឡើងថ្លៃខ្ពស់ជាងថ្លៃដទៃទៀត។ ពេលខ្លះស្ថានភាពនេះ ត្រូវបានពិពណ៌នាថា រូបិយវត្ថុអព្យាក្រឹត។ នៅក្នុងរយៈពេលវែង” វាសមហេតុផលក្នុងការសន្មតថា ផលប៉ះពាល់កម្រិតថ្លៃដែលទាក់ទងនឹងការបោសសម្អាតទីផ្សារភាគច្រើន ដូច្នេះការយល់ដឹងអំពីអតិផរណាដែលមានរយៈពេលមួយទសវត្សរ៍នេះ មានការចាប់អារម្មណ៍អំពីវា។ ដើម្បីយល់ដឹងពីរបៀបគោលនយោបាយរូបិយវត្ថុ អាចជំរុញឱ្យវដ្តអាជី-វកម្ម បើទោះជាយ៉ាងណាក៏ដោយការសន្មតថាអព្យាក្រឹតភាពត្រូវតែដាក់មួយឡែក។ សមីការនៃការផ្លាស់ប្ដូរអាចត្រូវបានប្រើ ដើម្បីបង្ហាញពីរបៀបដែលអត្រាអតិផរណាអាស្រ័យលើអត្រាកំណើន M, V និង y។ ទំនាក់ទំនងក្នុងចំណោមអត្រាកំណើនទាំងបួនត្រូវបានផ្ដល់ដោយ “dynamic” ឬអត្រាកំណើននៃសមីការ៖ gM + gV = gP + gy ។ អាចនិយាយបានថា៖ អត្រាកំណើនបរិមាណរូបិយវត្ថុបូកនឹង អត្រានៃកំណើនល្បឿនជុំរូបិយវត្ថុស្មើនឹងអត្រាអតិផរណា បូករួមនឹងអត្រាកំណើនប្រាក់ចំណូលពិត។ សមីការនេះ រក្សាយ៉ាងពិតប្រាកដសម្រាប់អត្រាកំណើនដែលបានរួមផ្សំគ្នាជាបន្តបន្ទាប់។ សម្រាប់អត្រាពីមួយឆ្នាំទៅមួយឆ្នាំ វាគឺជាការប៉ាន់ស្មាន។

សមីការនៃការផ្លាស់ប្ដូរបានបង្ហាញថាអតិផរណាមិនត្រឹមតែអាស្រ័យលើអត្រានៃការពង្រីករូបិយវត្ថុប៉ុណ្ណោះទេ។ ប៉ុន្តែថែមទាំងអត្រានៃកំណើនល្បឿនបង្វិល (អវិជ្ជមានលើអត្រានៃកំណើនប្រាក់ចំណូលពិត)។ តើកត្តាមួយណាក្នុងចំណោមកត្តាទាំងបីនេះ ដែលរួមចំណែកច្រើនបំផុតចំពោះអតិផរ-ណាក្នុងការអនុវត្តន៍? សេដ្ឋវិទូរូបិយវត្ថុល្បីឈ្មោះ គឺលោក MILTON FRIEDMAN (1992, p.262) បានប្រកាសថា៖ «អតិផរណាតែងតែមាននៅគ្រប់ទីកន្លែង គឺជាបាតុភូតរូបិយវត្ថុ។ អ្វីដែលគាត់ចង់និយាយគឺថាអតិផរណាដែលមាននិរន្តរភាពតែងតែមានជាប្រវត្តិសាស្ត្រ ដោយសារតែកំណើនការផ្គត់ផ្គង់រូបិយវត្ថុប្រកបដោយចីរភាពមិនមែនដោយសារការបង្កើនល្បឿនបង្វិល ឬកំណើនអវិជ្ជមានក្នុងប្រាក់ចំណូលពិតនោះទេ។ គឺមានភស្តុតាងគាំទ្រដល់ទ្រឹស្ដីរបស់លោក Friedman ដែលថាមានទិសដៅត្រង់ទៅលើ (straightforward)។ បណ្ដាប្រទេសភាគច្រើន បានត្រួតពិនិត្យមើលប្រចាំឆ្នាំប្រាក់ចំណូលដែលមិនល្អ ដោយមានការធ្លាក់ចុះច្រើនជាងកម្រិត ២ភាគរយ ឬ ៣ភាគរយ ។ កម្រិតល្បឿនបង្វិលត្រូវបានគេដឹងថាកើនឡើងក្នុងរយៈពេលយ៉ាងយូរ ក៏ប៉ុន្តែកម្រនឹងមានច្រើនជាង ១% ភាគរយពីមួយឆ្នាំទៅមួយឆ្នាំ។ នៅពេលបណ្ដាប្រទេសដែលមានអតិផរណាខ្ពស់ និងអតិផរណាទាប ត្រូវបានប្រៀបធៀបរវាងភាពខុសគ្នានៃកំណើនរូបិយវត្ថុ គឺមានកាន់តែច្រើនពីប្រទេសមួយទៅប្រទេសមួយទៀតជាជាងភាពខុសគ្នារវាងកំណើននៃទិន្នផលសរុបពិត(real output growth) និងល្បឿនបង្វិលរូបិវយវត្ថុ (velocity money)។ ជាលទ្ធផល អត្រានៃការពង្រីករូបិយវត្ថុ គឺជាកត្តាចម្បងដែលមានភាពខុសគ្នានៃអត្រាអតិផរណាទូទាំងប្រទេស។ ប្រទេសដែលមានអតិផរណាខ្ពស់ គឺជាប្រទេសដែលមានកំណើនរូបិយវត្ថុយ៉ាងឆាប់រហ័ស (rapid money growth)។ ដូចគ្នានេះ កត្តាលេចធ្លោមានអត្រាអតិផរណាខុសគ្នាក្នុងរយៈពេលជាច្រើនទសវត្សរ៍កន្លងមកក្នុងប្រទេសតែមួយ(ឧ.អត្រាអតិផរណាទាបរបស់សហរដ្ឋអាម៉េរិកនៅទសវត្សរ៍ឆ្នាំ ១៩៩០ បើប្រៀបធៀបនឹងទសវត្សរ៍ឆ្នាំ ១៩៧០) គឺអត្រាកំណើនរូបិយវត្ថុខុសគ្នា។ ទសវត្សរ៍ដែលអត្រាអតិផរណាកើនខ្ពស់ គឺជាទសវត្សរ៍ដែលមានកំណើនរូបិយវត្ថុយ៉ាងឆាប់

រហ័ស។ ភាពលេចធ្លោនៃកំណើនរូបិយវត្ថុនៅក្នុងគណនេយ្យភាពសម្រាប់អតិផរណា ត្រូវបានគេហៅថា HYPERINFLATION ។ ផលប៉ះពាល់សម្រាប់ការគ្រប់គ្រងអតិផរណា គឺស្មើនឹងទិសដៅត្រង់ដូចគ្នា។ ដើម្បីសម្រេចបាននូវអតិផរណាសូន្យគ្រាន់តែតម្រូវឱ្យធនាគារកណ្តាលដែលគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុត្រូវជៀសវាងពីការពង្រីកការផ្គត់ផ្គង់រូបិយវត្ថុយ៉ាងឆាប់រហ័ស (ជាពិសេសការកែសម្រួលកំណើនល្បឿនបង្វិលពង្រីកការផ្គត់ផ្គង់រូបិយវត្ថុក្នុងអត្រាលឿនជាងទិន្នផលផលិតផល និងសេវាកម្មពិតរបស់សេដ្ឋកិច្ច។

ប្រព័ន្ធធនាគារសហព័ន្ធ អាចរក្សាអតិផរណាឱ្យស្មើនឹងសូន្យ (gP = 0) ជាមធ្យមភាគដោយការគ្រប់គ្រងកំណើនក្នុងស្តុករូបិយវត្ថុជាដុល្លារអាម៉េរិក (gM) ឱ្យបានត្រឹមត្រូវ។ បណ្តាធនាគាកណ្តាលលើពិភពលោក (ដូចជាអូស្រ្តាលី កាណាដា តំបន់អឺរ៉ុប ញូវហ្សេឡែន ស៊ុយអែត ចក្រភពអង់គ្លេស) នៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ធនាគារកណ្តាលនីមួយៗ បានប្រកាសពីទិសដៅគោលសម្រាប់អត្រាអតិផរណាដែលជាញឹកញាប់កំណត់កម្រិតពី ១ភាគរយ ទៅ ៣ភាគរយ ហើយទទួលបានជោគជ័យក្នុងការរក្សា អត្រាអតិផរណានៅក្នុងកម្រិតនោះដែរ។ សេដ្ឋវិទូខ្លះ បានពន្យល់ការវិភាគខាងលើនេះថាជាការពន្យល់ពី "demand-pull"។ សមីការបាន "supply shock" ដែលជាហេតុធ្វើឱ្យមានការកើនឡើងយ៉ាងខ្លាំងនៅក្នុងកម្រិតថ្លៃទូទៅ (មិនត្រឹមតែការកើនឡើងទាក់ទងនឹងថ្លៃមួយចំនួន ដូចជាថ្លៃប្រេងប៉ុណ្ណោះទេ) សេដ្ឋកិច្ចធ្លាក់ចុះយ៉ាងខ្លាំង។ ក្នុងការអនុវត្តជាក់ស្តែង ករណី "supply shock" គឺកម្រនឹងកើតមានណាស់ សម្រាប់អតិផរណាដែលជាទូទៅមានរយៈពេលខ្លី។ ជាឧទាហរណ៍ អត្រាអតិផរណារបស់សហរដ្ឋអាម៉េរិក ៩.2 % នៅក្នុងឆ្នាំ១៩៨០ (ត្រូវបានវាស់ដោយ GDP បរិត្តផរណា gP = ៩.២ %) កំណើន អវិជ្ជមាននៃផលិតផលក្នុងស្រុកសរុបពិត (ដោយសារតែផ្នែកខ្លះនៃថ្លៃប្រេង OPEC ឆ្នាំ ១៩៧៩–១៩៨០) មានសម្រាប់ 0.២% តែប៉ុណ្ណោះ (gy = –0.២%)។ ទន្ទឹមនឹងនេះ កំណើនស្តុករូបិយវត្ថុ (រង្វាស់រូបិយវត្ថុ M1, ១២/១៩៨០-១២/១៩៧៩) ដែលមានកម្រិតពិន្ទុ ៧.0ភាគរយ (*gM* = ៩.0%) ។ កំណើនប្រមាណ ២% ក្នុងល្បឿនបង្វិលចំណូលរូបិយវត្ថុ M1។ ចំពោះរង្វាស់រូបិយវត្ថុ M2 និងល្បឿនបង្វិលរបស់វាទិន្ន័យនីមួយៗមានកម្រិតពិន្ទុ ៨,៥% និង 0,៥%។ សមីការនៃបម្រែបម្រួល (equation of exchange) ក៏ប្រាប់យើងដែរថាផ្ទុយពីអ្វីដែលក្រេឌីតមួយចំនួនបានប្រើដើម្បីបង្ហាញថា "កំណើនច្រើនពេក" មិនអាចជាបុព្វហេតុអតិផរណានោះទេ។ អត្រាកំណើនប្រាក់ចំណូលពិតខ្ពស់ជាង (*gy*) អត្រាអតិផរណាទាបជាង (*gP*) និងអញ្ញត្រផ្សេងទៀត (*gM* និង *gV*) គឺស្មើគ្នា។ ប្រសិនបើ ការកើនឡើងអតិផរណា ត្រូវបានផ្សារភ្ជាប់ជាមួយនឹងសេដ្ឋកិច្ចដែលឡើងកំដៅខ្លាំង (*gy* ស្ថិរភាពរយៈពេលវែង) ការពន្យល់គឺថាទាំងអតិផរណាកើនឡើង និងការកើនឡើងជាបណ្តោះអាសន្នក្នុងកម្រិតកំណើនពិត គឺជាផលប៉ះពាល់ការកើនឡើងនៃកំណើនរូបិយវត្ថុពីមុន។ អ្វីដែលមើលទៅដូចជាអតិផរណាជំរុញការចំណាយ "cost-push inflation" គឺច្រើនតែជាអតិផរណាជំរុញតម្រូវការ "demand-pull inflation" មានការភាន់ច្រឡំ។ ឧបមាថា ការពង្រីកការផ្គត់ផ្គង់រូបិយវត្ថុជំរុញឱ្យមានការកើនឡើងនូវតម្រូវការទំនិញ និងសេវាកម្មសម្រាប់លក់រាយ។ អ្នកលក់រាយអាចពន្យារពេលដំឡើងថ្លៃទំនិញដែលមាននៅក្នុងស្តុក ប៉ុន្តែ(លក់កាន់តែធំ) ការបញ្ជាទិញដែលមានទំហំកាន់តែធំជាងមុនពីអ្នកលក់ដុំ។ អ្នកលក់ដុំបានបញ្ជាទិញពីរោងចក្រមកវិញ។ ចំណែកឯរោងចក្របង្កើនតម្រូវការវត្ថុ

ធាតុដើម និងកម្លាំងពលកម្មដោយធ្វើឱ្យតម្លៃសម្ភារៈ និងអត្រាប្រាក់ឈ្នួលកើនឡើង។ ដំណាក់ការពេងចក្រនានា អាចឆ្លងកាត់ការចំណាយរបស់ពួកគេឱ្យដល់អ្នកលក់ដុំ ហើយបានធ្វើដូចគ្នាចំពោះអ្នកលក់រាយ។ នៅគ្រប់កម្រិតនីមួយៗការកើនឡើងថ្លៃហាក់ដូចជាត្រូវបានជំរុញដោយបញ្ចូលថ្លៃដើម។ ប៉ុន្តែការកើនឡើងថ្លៃដើមនេះ បណ្តាលមកពីតម្រូវការកំណើនរូបិយវត្ថុប៉ុណ្ណោះ។

### ១.៤.៣- ផលវិបាកនៃអតិផរណា (Consequences of Inflation)

អតិផរណា អាចបង្កគ្រោះថ្នាក់យ៉ាងខ្លាំង។ គ្រោះថ្នាក់ គឺធំជាងវិសាលភាពដែលអត្រាអតិផរណាជាក់ស្តែងខុសគ្នាពីអត្រាអតិផរណាដែលបានរំពឹងទុក (anticipated inflation)។ នៅពេលដែលការរំពឹងទុកថានឹងមានការធ្លាក់ចុះយ៉ាងឆាប់រហ័សនៃអំណាចទិញប្រាក់ដុល្លារ (អត្រាអតិផរណាខ្ពស់) លក្ខខណ្ឌទូទាត់ជាប្រាក់ដុល្លារនាពេលអនាគតត្រូវបានកែសម្រួលតាមនោះ។

អ្នកខ្ចីប្រាក់ និងអ្នកផ្តល់កម្ចីដែលរំពឹងទុកថា អតិផរណាខ្ពស់ព្រមទទួលយកជាងអត្រាការប្រាក់ខ្ពស់(ប្រាក់ដុល្លារសងជាងប្រាក់កម្ចី) ដើម្បីរក្សាអត្រាការប្រាក់ពិត (អំណាចទិញលើការសងត្រឡប់ប្រាក់កម្ចី)រវាងពួកគេ។ សមីការនៃសាមញ្ញរវាងទំនាក់ទំនងអត្រាការប្រាក់មានតែនាម ទៅនឹងអត្រាអតិផរណាដែលរំពឹងទុកគឺ $(1 + i) = (1 + r) \times (1 + gP^e)$ ដែល $i$ ជាអត្រាការប្រាក់នាមករណ៍ $r$ គឺជាអត្រាការប្រាក់ពិត និង $gP^e$ គឺជាអត្រាអតិផរណាដែលរំពឹងទុក។ សមីការនេះជួនកាលត្រូវបានគេហៅថា "Fisher relationship" បន្ទាប់ពីអ្នកសេដ្ឋកិច្ចរូបិយវត្ថុ IRVING FISHER នៅដើមសតវត្សរ៍ទី២០។ លោក Fisher បានអះអាងថាអត្រាការប្រាក់ពិតដែលមានលំនឹងសមតា គឺឯករាជ្យពីអត្រាអតិផរណាដែលរំពឹងទុក ដូច្នេះការកើនឡើងអតិផរណាដែលរំពឹងទុកត្រូវបានពាក់ព័ន្ធទាំងស្រុងទៅនឹងអត្រាការប្រាក់នាមករណ៍។

បើទោះបីជា អ្នកផ្តល់ប្រាក់កម្ចី និងអ្នកសុំខ្ចីប្រាក់ មិនទទួលរងពីអត្រាអតិផរណាខ្ពស់ នៅពេលអត្រាត្រូវបានគេគិតទុកជាមុនក៏ដោយ សម្រាប់អ្នកកាន់ទម្រង់រូបិយវត្ថុដែលមិនមានការចាប់អារម្មណ៍ដូចជារូបិយប័ណ្ណជាដើម។ អតិផរណាដែលត្រូវបានគេរំពឹងទុកខ្ពស់ នឹងធ្វើឱ្យពួកគេស្មើនឹងពន្ធខ្ពស់លើការកាន់កាប់រូបិយវត្ថុរបស់ពួកគេ។ អតិផរណាអាចធ្វើជាឧបករណ៍ផ្លាស់ប្តូរយុទ្ធសាស្ត្រដែលមានតម្លៃសម្រាប់ការកាន់កាប់រូបិយប័ណ្ណតូចជាងមុន ដូចជាការធ្វើដំណើរកាន់តែច្រើនទៅធនាគារដើម្បីដកប្រាក់កាន់តែតិចជារៀងរាល់ពេល។ តាមទស្សនៈនៃការលុបបំបាត់ការចំណាយដែលមិនចាំបាច់ក្នុងការសន្សំសំចៃលើសាច់ប្រាក់ កម្រិតអតិផរណាទាប គឺច្បាស់ជាពេញចិត្តជាងកម្រិតអតិផរណាខ្ពស់ សំណើរមួយសម្រាប់សម្រេចបានលទ្ធផល "ល្អប្រសើរបំផុត" ជាសំណើដែលត្រូវបានពិភាក្សាយ៉ាងទូលំទូលាយបំផុតក្នុងទ្រឹស្តីសុទ្ធនៃគោលនយោបាយរូបិយវត្ថុ គឺជាអត្រាអតិផរណាគួរតែមានលក្ខណៈអវិជ្ជមានគ្រប់គ្រាន់ដែលអត្រាការប្រាក់មានតែនាម គឺស្មើនឹងសូន្យ (ដែលហានិភ័យសញ្ញាប័ណ្ណ សម្រាប់សញ្ញាប័ណ្ណមានកាលវសានខ្លី)។

អត្រាការប្រាក់នាមករណ៍ខ្ពស់ជាងមុនមានន័យថា រូបិយប័ណ្ណទូទាត់មកវិញនូវប្រាក់ចំណេញទាបជាងមូលប័ត្របំណុល។ នេះជំរុញឱ្យមនុស្សសន្សំសំចៃលើការកាន់កាប់សាច់ប្រាក់ដែលជាសកម្មភាពមួយដែលប្រសើរបំផុតពីទស្សនៈរបស់បុគ្គលម្នាក់ៗ ក៏ប៉ុន្តែមានតម្លៃខ្ពស់ពីទស្សនៈរបស់សង្គម។

តាមសមីការ Fisher អាចត្រូវបានគេមើលឃើញថាការសម្រេចបាននូវអត្រាការប្រាក់នាមករណ៍សូន្យ បង្កឱ្យមានអត្រាអតិផរណាប្រមាណស្មើនឹងអវិជ្ជមាននៃអត្រាការប្រាក់ជាក់ស្តែង ដែលបង្ហាញពីបរិត្តផរណាប្រហែល ២-៣ ភាគរយក្នុងមួយឆ្នាំ។ បន្ថែមពន្ធលើសមតុល្យសាច់ប្រាក់យ៉ាងហោចណាស់មានគ្រោះថ្នាក់ផ្សេងទៀតកើតឡើងពីអតិផរណាខ្ពស់ សូម្បីតែនៅពេលរំពឹងទុកឥតខ្ចោះក៏ដោយ។ ជាមួយនឹងអតិផរណាខ្ពស់តម្លៃបោះពុម្ពផ្សាយលែងប្រើបានលឿន ដូច្នេះអ្នកកំណត់តម្លៃត្រូវតែទទួលរងការចំណាយលើការកែតម្រូវថ្លៃមានតែនាម ។

## ១.៤.៤- អតិផរណាដែលមិនអាចគ្រប់គ្រងបាន ( Unanticipated Inflation )

នៅពេលអត្រាអតិផរណា ត្រូវបានគេគិតទុកជាមុនមិនត្រឹមត្រូវ នោះការជួញដូរហិរញ្ញវត្ថុមានការខកចិត្ត។ ប្រសិនបើ អត្រាអតិផរណាប្រែជាខ្ពស់ជាងការរំពឹងទុករបស់អ្នកខ្ចីប្រាក់ នឹងត្រូវសងជាប្រាក់ដុល្លារដែលមិនសូវមានតម្លៃតាមការចំណាយរបស់អ្នកឱ្យខ្ចី ដែលទទួលបានអំណាចទិញតិចជាងការរំពឹងទុក។ ប្រសិនបើ អត្រាអតិផរណាប្រែជាទាបជាងការរំពឹងទុករបស់អ្នកឱ្យខ្ចីប្រាក់នឹងទទួលបានការចំណាយពីអ្នកសុំខ្ចីប្រាក់ (សន្មតថាអ្នកសុំខ្ចីប្រាក់អាចធ្វើការទូទាត់ប្រាក់ពិតបានកាន់តែច្រើន)។ ឧទាហរណ៍ រដ្ឋាភិបាលសហព័ន្ធ គឺជាកូនបំណុលដ៏ធំបំផុតរបស់សហរដ្ឋអាម៉េរិក ទទួលបានពីអតិផរ-ណាដែលមិនបានគ្រោងទុក ហើយនឹងបាត់បង់នៅពេលអតិផរណាតិចជាងការរំពឹងទុក។ ជាលទ្ធផល រដ្ឋាភិបាលសហព័ន្ធ មានភាពលំអៀងទៅរកអតិផរណាកម្រិតខ្ពស់។ នៅពេលអត្រាអតិផរណានាពេលអនាគត មានភាពមិនប្រាកដប្រជាកម្រិតខ្ពស់ ដូច្នេះហានិភ័យនៃប្រាក់ចំណេញ និងការខាតបង់បែបនេះលើមូលប័ត្របំណុលថ្មី គឺមានទំហំកាន់តែធំ ហើយប្រឈមមុខនឹងហានិភ័យមូលប័ត្របំណុល (ដូចជាប្រាក់បញ្ញើ ប្រាក់កម្ចី សញ្ញាប័ណ្ណ)។ ដោយសារតែអតិផរណាមានលក្ខណៈប្រែប្រួលនៅពេលអត្រាអតិផរណាកើនឡើង ការកើនសេដ្ឋកិច្ចអតិផរណាកម្រិតខ្ពស់ បានបង្អាក់ដល់វិស័យធនាគារ និងទីផ្សារមូលប័ត្របំណុល។ ផលចំណេញសុទ្ធពីការកាន់កាប់សញ្ញាប័ណ្ណ និងប្រាក់កម្ចីដែលមានកាលវសានរយៈពេលវែង ឧទាហរណ៍៖ ប្រាក់ចំណេញរបស់ក្រុមហ៊ុនដែលមានរយៈពេល៣០ឆ្នាំ ឬប្រាក់កម្ចីមានអត្រាថេររយៈពេល៣០ឆ្នាំ គឺងាយនឹងមានការប្រែប្រួលអតិផរណា។ នៅពេលដែលសេដ្ឋកិច្ចឈានទៅរកអតិផរណាខ្ពស់ និងការប្រែប្រួល ដូច្នេះមូលប័ត្របំណុលរយៈពេលវែងបែបនេះនឹងរលាយបាត់។ ការ វិនិយោគរយៈពេលវែង ត្រូវបានលើកទឹកចិត្តដោយហានិភ័យកាន់តែខ្លាំងក្នុងការផ្តល់ហិរញ្ញប្បទានរបស់ពួកគេ។ រូបិយប័ណ្ណអតិផរណាខ្ពស់(High-inflation currency) បានធ្វើឱ្យទីផ្សារភាគហ៊ុនធ្លាក់ចុះផងដែរ បើទោះបីជាហេតុផលមិនមានការកាត់បន្ថយឱ្យបានច្បាស់លាស់ក៏ដោយ។ មូលហេតុដែលទំនងជា(Aarstol-2000) គឺថាអតិផរណាខ្ពស់ត្រូវបានផ្សារភ្ជាប់ជាមួយនឹង "សំលេងរំខាន" កាន់តែច្រើនក្នុងកម្រិតថ្លៃដែលទាក់ទិន ពោលគឺជាការផ្លាស់ប្តូរបណ្តោះអាសន្ននៃថ្លៃដែលទាក់ទងដោយសារតម្លៃខុសគ្នា ត្រូវបានកែសម្រួលក្នុងល្បឿនខុសគ្នា។ ដូច្នេះ វិនិយោគិនមិនអាចជឿជាក់លើរបាយការណ៍ប្រាក់ ចំណូលរបស់ក្រុមហ៊ុនដែលបានចុះបញ្ជីនៅក្នុងផ្សារហ៊ុនឡើយ។ ប្រាក់ចំណេញខ្ពស់សម្រាប់ក្រុមហ៊ុនមួយអាចមានសំណាងបណ្តោះអាសន្ន ដោយសារលទ្ធផលថ្លៃកើនឡើងដោយចៃដន្យមុនពេលរួម បញ្ចូលថ្លៃ។ ក្នុងសេដ្ឋកិច្ចបែបនេះ អ្នកសន្សំបានគេចចេញពីទីផ្សារភាគ

ហ៊ុនក៏ដូចជាពីទីផ្សារសញ្ញាប័ណ្ណ និងប្រាក់កម្ចី។ ពួកគេសន្សំបានតិចហើយបង្វែរប្រាក់សន្សំរបស់ពួកគេទៅជា "របងអតិផរណា" ដូចជាផ្ទះ និងមាសជាជាងបន្ថែមទៅនឹងភាគហ៊ុនសេដ្ឋកិច្ចរបស់រោងចក្រ និងម៉ាស៊ីន។ ហេតុផលទី២ ដែលអាចធ្វើឱ្យអតិផរណាកាត់បន្ថយតម្លៃភាគហ៊ុន គឺថាប្រព័ន្ធពន្ធលើប្រាក់ចំណូលរបស់ក្រុមហ៊ុនក្នុងប្រទេសជាច្រើន មិនត្រូវបានធ្វើសន្ទស្សន៍ពេញលេញទេ។ ក្រុមហ៊ុនប្រឈមនឹងបន្ទុកពន្ធខ្ពស់ជាងមុននៅពេលអតិផរណាកើនឡើង។ លោក Javier Andrés និងលោក Ignacio Hernando (1999) បានសិក្សាស្រាវជ្រាវនៅប្រទេស OECD បានរាយការណ៍ថាការធ្លាក់ចុះអតិផរណាត្រឹម ១ភាគរយ នឹងជំរុញផលិតផលក្នុងស្រុកសរុបសម្រាប់ចំណូលមនុស្សម្នាក់ៗពី ០.៥-២.០ភាគរយ។ តើអតិផរណាមានអត្ថ-ប្រយោជន៍អ្វីឬទេ? សេដ្ឋវិទូម៉ាក្រូសេដ្ឋកិច្ចខ្លះ ធ្លាប់ជឿថាអតិផរណាខ្ពស់អាចកាត់បន្ថយអចិន្ត្រៃយ៍នៃ អត្រាអនិកម្មភាព។ ជំនឿមួយដែលត្រូវបានដាក់បញ្ចូលក្នុងជំនាន់ដំបូងនៃខ្សែកោង "Phillips curve"។ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ខណៈពេលដែលអតិផរណាកាន់តែខ្ពស់ជាងនេះ មានការភ្ញាក់ផ្អើលកាន់តែខ្លាំង។ អតិផរណាគួរឱ្យភ្ញាក់ផ្អើលដែលបានកាត់បន្ថយការងារ ឬបញ្ឈប់ការងារ។ ការលក់ប្រាក់ដុល្លារឡើងខ្ពស់ មិនអាចនឹកស្មានដល់(កាត់បន្ថយការងារ) តាមរយៈប្រាក់ឈ្នួលជាដុល្លារកាត់បន្ថយហួសពីការរំពឹងទុកដោយអត្រាអនិកម្មភាពទាបជាងអត្រាធម្មតា។ នៅពេលកម្មកររំពឹងទុកថា នឹងមានអត្រាអតិផរណាខ្ពស់ ដូចដែលពួកគេបានជួបប្រទះនៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០ ហើយអត្រាអនិកម្មភាពនឹងវិលត្រឡប់រកអត្រាធម្មតាវិញ "PHILLIPS CURVE"។ តាមរយៈតក្កវិជ្ជាដូចគ្នា ការកាត់បន្ថយអតិផរ-ណាគួរឱ្យភ្ញាក់ផ្អើល អាចបង្កើនអនិកម្មភាពលើសពីអត្រាអតិផរណាធម្មតា ដែលធ្វើឱ្យអតិផរណាកើនឡើងថ្លៃ។ ទោះបីជាការមូលមតិគ្នាផ្ទុយនឹងអតិផរណាខ្ពស់មានការរីករាលដាលក៏ដោយ ក៏មានមតិខុសគ្នាថាតើអត្រាអតិផរណា ០ភាគរយ ប្រសើរជាងអត្រា +៣ភាគរយ ឬ -៣ភាគរយ? មានករណីសំខាន់ពីរនៃអត្រាអតិផរណាវិជ្ជមាន។ តាមរយៈលោក GEORGE AKERLOF លោក William Dickens និងលោក George Perry (ឆ្នាំ១៩៩៦) បានអះអាងថាអតិផរណាកម្រិតសូន្យនឹងនាំឱ្យគ្មានប្រសិទ្ធភាព ដោយសារតែប្រាក់ឈ្នួល និងកម្រិតថ្លៃមានភាពស្អិតរមួត។ បើតាមទស្សនៈរបស់ពួកគេ ករណីមានអតិផរណាតិចតួចនឹងផ្តល់នូវ "grease"ដល់ប្រព័ន្ធសេដ្ឋកិច្ច។

តាមរយៈលោក Ben Bernanke ជាទេសាភិបាលធនាគារកណ្តាល (Fed) បានលើកឡើងថាអតិផរណាវិជ្ជមាន អាចរក្សាអត្រាការប្រាក់នាមករណ៍ខ្ពស់ជាងលើកម្រិតអតិផរណាសូន្យទាបជាងរក្សាបាននូវសមត្ថភាពរបស់ធនាគារកណ្តាលក្នុងការកាត់បន្ថយអត្រាការប្រាក់ ប្រសិនបើគោលនយោបាយរូបិយវត្ថុធូរលុងគឺមានភាពចាំបាច់។ នៅក្នុងកម្រិតពេញចិត្តនៃអតិផរណាសូន្យ តាមរយៈលោក William Poole (1999) បានរកឃើញគុណវិបត្តិនៅក្នុងកត្តាទាំងពីរនេះ។ លោកបានកត់សម្គាល់ថាប្រសិនបើអតិផរណាពិតជាធ្វើឱ្យមានភាពរឹងមាំនៃប្រាក់ឈ្នួលមានតែនាម មានភាពងាយស្រួលក្នុងការរស់នៅ សម្រាប់ហេតុផលនោះ វាទំនងជាមានភាពរឹងមាំ។ ផ្ទុយករណីលើកទីពីរ លោកបានអះអាងថាអត្រាការប្រាក់ទាប មិនអាចពង្រីកគោលនយោបាយរូបិយវត្ថុឱ្យមានប្រសិទ្ធភាពទេ។ តាមរយៈលោក Poole ថាការអនុគ្រោះដល់អតិផរណាសូន្យ គឺគោលនយោបាយកាត់បន្ថយភាពមិនប្រាកដប្រជានៃអតិផរណានាពេលអនាគតដោយងាយស្រួលបំផុតក្នុងកិច្ចសន្យាហិរញ្ញវត្ថុ។ ហើយបង្រួមអប្បបរមាបង្ខូច

ទ្រង់ទ្រាយដែលទាក់ទងនឹងពន្ធដែលមិនមានអត្រាទាប។ ក្នុងការពេញចិត្តនៃអត្រាអតិផរណាអវិជ្ជមាន "បរិមាណល្អបំផុតនៃរូបិយវត្ថុ" ដែលត្រូវបានកត់សម្គាល់ខាងលើសម្រាប់ការកាត់បន្ថយចំណាយលើការខាតបង់នៃការកាន់កាប់រូបិយប័ណ្ណ។ សម្រាប់ហេតុផលផ្សេងគ្នា តាមរយៈលោក George Selgin (1997) បានសិក្សាលើករណីនៃការធ្លាក់ចុះកម្រិតថ្លៃក្នុងសេដ្ឋកិច្ចជាមួយនឹងការធ្វើឱ្យប្រសើរឡើងផលិតកម្ម។ លោកបានកត់សម្គាល់ថា វាមានអត្ថប្រយោជន៍ក្នុងការធ្វើឱ្យថ្លៃផលិតផលជាក់លាក់ធ្លាក់ចុះបានខណៈពេលដែលការចំណាយថ្លៃដើមធ្លាក់ចុះ។ តាមទស្សនៈរបស់គាត់ដោយប្រើគោលនយោបាយរូបិយវត្ថុពង្រីក ដើម្បីដំឡើងថ្លៃផ្សេងទៀត ដើម្បីបង្កើតអតិផរណាទូទៅមិនមានអ្វីដើម្បីបង្កើនប្រសិទ្ធិភាពទេ ប៉ុន្តែផ្ទុយទៅវិញបង្កើនបន្ទុកកែតម្រូវដែលដាក់នៅលើប្រព័ន្ធតម្លៃ។

## ១.៥- ភាពខុសគ្នារវាងតម្លៃរូបិយវត្ថុមានតែនាម និងតម្លៃរូបិយវត្ថុពិត (Nominal vs. The real value of money)

តម្លៃបច្ចុប្បន្ននៃរូបិយវត្ថុមានតែនាម(nominal value of money) គឺជាទាក់ទងនឹងពាក្យថា "រូបិយវត្ថុ" ដោយខ្លួនឯងផ្ទាល់ដែលជាឯកតានៃរង្វាស់តម្លៃរូបិយវត្ថុ។ តម្លៃពិតនៃរូបិយវត្ថុ(real value of money) គឺទាក់ទងនឹងពាក្យថា "អំណាចទិញ" របស់ខ្លួនលើទំនិញ។

ដូច្នេះ តម្លៃបច្ចុប្បន្នរូបិយវត្ថុ ១ដុល្លារគឺ៖ ១នឹងក្រដាសប្រាក់ ២០ដុល្លារ គឺ២០។ តម្លៃពិតរូបិយវត្ថុគឺជាចំនួនទំនិញ និងសេវាកម្មក្នុងមួយឯកតាដែលលុយអាចទិញបាន និងជាកម្រិតថ្លៃទំនិញដែលត្រូវបានជួញដូរក្នុងសេដ្ឋកិច្ច។

វាស្មើនឹង៖ $PV = \frac{1}{P}$ , P ជាកម្រិតថ្លៃមធ្យមភាគនៅក្នុងសេដ្ឋកិច្ច។ តម្លៃពិតរូបិយវត្ថុ គឺជាអ្វីដែលយើងតែងតែចង់និយាយនៅពេលយើងប្រើពាក្យថាតម្លៃ"រូបិយវត្ថុ។"

## ១.៦- តើការបង្កើតរូបិយវត្ថុគឺជាអ្វី? (What is money creation?)

ការបង្កើតរូបិយវត្ថុ គឺជាដំណើរការដែលនាំឱ្យមានការកើនឡើងនៃការផ្គត់ផ្គង់រូបិយវត្ថុ។ ការផ្គត់ផ្គង់រូបិយវត្ថុ នេះអាចត្រូវបានបែងចែកជាពីរប្រភេទធំៗ គឺ៖

- រូបិយប័ណ្ណ (Currency)៖ នេះគឺក្រដាសប្រាក់ និងកាសដែលកំពុងចរាចរណ៍ក្នុងប្រទេស។ វាតំណាងឱ្យប្រហែលរូបិយវត្ថុ 5% នៃការផ្គត់ផ្គង់រូបិយវត្ថុរបស់ពិភពលោក។
- សៀវភៅជាគណនី (Book money)៖ នេះគឺជារូបិយវត្ថុដែលមានទម្រង់ជាគណនេយ្យ។ វាតំណាងឱ្យ ៩៥% នៃការផ្គត់ផ្គង់រូបិយវត្ថុរបស់ពិភពលោក។ រូបិយវត្ថុនេះ មិនមានជារូបរាងទេ វាគ្រាន់តែជាបន្ទាត់ដែលលេចឡើងលើឥណពន្ធ ឬឥណទាននៃគណនីធនាគារ។ ជាមូលហេតុដែលធនាគារភ័យខ្លាចរឿងមួយក្នុងអំឡុងពេលមានវិបត្តិរូបវន្តបុគ្គលម្នាក់ៗ នឹងសម្រេចចិត្តលុបចោលគណនីពួកគេដោយខ្លាចដួលរលំធនាគារ។ ចលនាភ័យស្លន់ស្លោតែម្នាក់ឯងបាននាំឱ្យមានការបិទធនាគារមួយចំនួនដែលអសមត្ថភាពខាងរាងកាយក្នុងការចេញផ្សាយក្រដាសប្រាក់ និងកាស។ ប្រសិទ្ធភាពរូបិយវត្ថុនេះ ពិតជាមិនមានទេ វាគឺជាការចុះបញ្ជូលគណនេយ្យសាមញ្ញមួយ។ ការបង្កើតរូបិយវត្ថុ គឺមានជាអចិន្ត្រៃយ៍ហើយត្រូវបានគ្រប់គ្រង

តាមទ្រឹស្តីដោយធនាគារកណ្តាល។ ពួកគេគឺជាអ្នកដែលសម្រេចចិត្តលើកម្រិតនៃការបង្កើតរូបិយវត្ថុដែលពួកគេចង់បាន។

ជាទូទៅ មានរូបភាពមិនត្រឹមត្រូវនៃការបង្កើតរូបិយវត្ថុតភ្ជាប់ជាមួយពាក្យ(printing press)។ មនុស្សសាមញ្ញតែងតែមានរូបភាពខុសប្លែកពីការបង្កើតរូបិយវត្ថុ ដែលពួកគេភ្ជាប់ជាមួយ "សារព័ត៌មានបោះពុម្ព"។ មានតែអ្នកក្លែងបន្លំទេដែលដំណើរការម៉ាស៊ីនបោះពុម្ពដូចនៅក្នុងខ្សែភាពយន្ត ប៉ុន្តែទោះបីជាមានអ្វីក៏ដោយធនាគារកណ្តាល និងអ្នកក្លែងបន្លំទាំងនោះមានអ្វីមួយដូចគ្នា។ អ្នកក្លែងបន្លំប៉ុណ្ណោះដែលមានម៉ាស៊ីនបោះពុម្ពប្រាក់ ប៉ុន្តែទោះបីជាមានអ្វីក៏ដោយ រវាងធនាគារកណ្តាល និងអ្នកក្លែងបន្លំទាំងនោះមិនមានអ្វីមួយដូចគ្នាទេ។ អ្នកឈ្នះរង្វាន់ណូបែលផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ចលោក Maurice Allais ក៏ជឿជាក់ផងដែរថាមិនមានភាពខុសគ្នារវាងរូបិយវត្ថុដែលបង្កើតដោយធនាគារកណ្តាល និងអ្នកក្លែងបន្លំ (ដាក់ទណ្ឌកម្មតាមច្បាប់)។ វាត្រូវបានបង្កើតឡើងដោយគ្មានអ្វីសោះ ហើយនាំទៅរកលទ្ធផលដូចគ្នា។ ភាពខុសគ្នាតែមួយគឺថាអ្នកដែលទទួលបានអត្ថប្រយោជន៍ពីវាខុសគ្នា។ អ្វីដែលត្រូវពិចា-រណា។

### ១.៦.១- យន្តការផ្សេងៗគ្នានាំឱ្យមានការបង្កើតប្រាក់ ( The different mechanisms leading to money creation )

ប្រសិនបើ ពាក្យស្នើសុំប្រាក់កម្ចី ត្រូវបានទទួលយកដោយធនាគារ វានឹងបញ្ចូលទៅក្នុងគណនីរបស់អ្នកដាក់ពាក្យស្នើសុំជាមួយនឹងចំនួនប្រាក់កម្ចី។ ឧទាហរណ៍៖ ប្រសិនបើអ្នកត្រូវការប្រាក់នូវចំនួន ២០០,០០០ ដុល្លារដើម្បីទិញគេហដ្ឋានរបស់អ្នក ធនាគារនឹងបញ្ចូលគណនីរបស់អ្នកជាមួយនឹងចំនួនទឹកប្រាក់នេះ ហើយចំនួននេះបង្ហាញឥណពន្ធនៅលើគណនីធនាគារ។ វាផ្តល់ជាបុរេប្រទានឱ្យអ្នកនូវចំនួន ២០០,០០០ដុល្លារ។ ដើម្បីផ្តល់ប្រាក់កម្ចីនេះ ធនាគារអាចប្រើប្រាក់បញ្ញើដែលប្រមូលបានទាំងអស់ (ការសន្សំរយៈពេលខ្លី និងវែងរបស់អតិថិជន)។ ដូច្នេះ វាប្រើលុយសន្សំរបស់អ្នកដើម្បីរកប្រាក់ចំណេញ។ មានប្រសិទ្ធិភាពនៅពេលធនាគារផ្តល់ប្រាក់កម្ចីដល់អតិថិជន អតិថិជនត្រូវបង់អត្រាការប្រាក់(រឿងធម្មតា)។ តាមពិត ធនាគារឱ្យខ្ចីប្រាក់ដែលមិនមែនជាប្រាក់របស់ធនាគារ(ប្រាក់អតិថិជន) វាគ្រាន់តែជាសិទ្ធិដែលផ្តល់ដោយធនាគារកណ្តាល។ តាមរយៈការចុះបញ្ចូលគណនេយ្យសាមញ្ញ (ភ្ជាប់នឹងការបង្កើតប្រាក់កម្ចីថ្មី) ដូច្នេះមានការបង្កើតប្រាក់ពីប្រាក់បញ្ញើធនាគារ។ ធនាគារបំប្លែងប្រាក់សន្សំរបស់អតិថិជនទៅជាប្រាក់កម្ចីថ្មី។ ប៉ុន្តែការបង្កើតលុយមិនបញ្ចប់នៅត្រឹមនេះទេ។ នេះមានប្រសិទ្ធិភាពចំនួនប្រាក់កម្ចីក៏បង្កើតប្រាក់កម្ចីថ្មីៗដែរ។ នេះត្រូវបានគេហៅថាប្រាក់បញ្ញើ ឬមេគុណឥណទាន (credit multiplier) ។

ឧទាហរណ៍៖ អ្នកនឹងទទួលបាន ២០០,០០០ ដុល្លារពីធនាគាររបស់អ្នកដើម្បីទិញផ្ទះរបស់អ្នក។ អ្នកចំណាយទាំងម្ចាស់ចាស់ ឬអ្នកសាងសង់ផ្ទះនេះ។ ពួកគេដាក់ប្រាក់ចំនួន ២០០,០០០ អឺរ៉ូ ដែលអ្នកឱ្យពួកគេចូលទៅក្នុងគណនីធនាគាររបស់ពួកគេនៅឯធនាគាររបស់ពួកគេ។ បន្ទាប់មក ធនាគារនោះ បានទទួលប្រាក់សន្សំដែលខ្លួនអាចខ្ចីជាថ្នូរនឹងការផ្តល់ប្រាក់កម្ចីថ្មីៗ។ វាគឺជាវិលជុំដោយគ្មានទីបញ្ចប់នៃការបង្កើតប្រាក់។ ទោះយ៉ាងណាក៏ដោយ មានដែនកំណត់ចំពោះការបង្កើតប្រាក់ប្រភេទនេះ

ដោយ សារតែច្បាប់ Basell III ។ បទបញ្ញត្តិទាំងនេះស្តីពីការធ្វើសោធនភាពធនាគា ដែលកំណត់ដោយអាជ្ញាធរ។ វិធានទាំងនេះចែងថាធនាគារត្រូវតែមានសមាមាត្រសោធនភាព ៨%(អត្រាទុនបម្រុងកាតព្វកិច្ច)បូកនឹងប័ណ្ណបំណុល ២,៥% ពោលគឺ១០.៥%។ សមាមាត្រនេះ រារាំងធនាគារពីការផ្តល់ប្រាក់កម្ចី សន្សំទាំងអស់ដែលអាចរកបានមកពីអតិថិជនរបស់ខ្លួន។ ម្យ៉ាងវិញទៀត នៅពេលធនាគារទទួលបានប្រាក់សន្សំ €១,០០០ ពីអតិថិជនធនាគារត្រូវរក្សាទុកប្រាក់បម្រុង €១០៥ (១,០០០*១០.៥/១០០)។ ដូច្នេះ ធនាគារអាចផ្តល់នូវប្រាក់កម្ចីត្រឹមតែ €៨៩៥ ប៉ុណ្ណោះ។ សម្រាប់ធនាគារបន្ទាប់ អាចទទួលបានឥណទានដែលអាចខ្ចីបានតែ €៨០១ ប៉ុណ្ណោះ។

នេះជាដែនកំណត់មេគុណឥណទាន (credit multiplier) ដើម្បីបង្កើតរូបិយវត្ថុ។ ជាមួយនឹងការដាក់ប្រាក់ដំបូងចំនួន €១,០០០ ក្នុងការហាមឃាត់ការបង្កើតរូបិយវត្ថុតាមទ្រឹស្តី គឺប្រហែល €៤,៥០០ (៨៩៥ + ៨០១។ល។) ឬគុណឥណទាន ៤.៥ (៤,៥០០/១,០០០)។ ដែនកំណត់ផ្សេងទៀតនៃការបង្កើតរូបិយវត្ថុដោយមេគុណឥណទានគឺជាតម្រូវការ។ ដើម្បីផ្តល់នូវប្រាក់កម្ចីថ្មីៗចាំបាច់ត្រូវមានថវិកាពីតួអង្គសេដ្ឋកិច្ចផ្សេងៗ។ នៅពេលមានវិបត្តិសេដ្ឋកិច្ច តម្រូវការទាំងនេះត្រូវបានកាត់បន្ថយ ដោយសារទំនុកចិត្តរបស់វិនិយោគិនមានកម្រិតទាបនាពេលអនាគត។ សម្រាប់ធនាគារ ត្រូវតែរកអតិថិជនដែលខ្លួនចាត់ទុកថាជាធាតុដែលបាត់បង់។ មេគុណឥណទានមិនត្រូវបានប្រើក្នុងកម្រិតទ្រឹស្តីអតិបរមាទេ។

## ១.៦.២- ការបង្កើតរូបិយវត្ថុតាមរយៈបំណុល

ដើម្បីផ្តល់នូវឥណទានថ្មី (ការបង្កើតរូបិយវត្ថុ) ធនាគារ ត្រូវតែមានធនធាន។ ប្រសិនបើ ប្រាក់បញ្ញើរបស់អតិថិជនមិនអនុញ្ញាតឱ្យធនាគារផ្តល់ប្រាក់កម្ចីថ្មីទេ ធនាគារអាចងាកទៅរកធនាគារកណ្តាល ហើយសុំខ្ចីប្រាក់ពីធនាគារកណ្តាល។ ធនាគារផ្តល់គណនីដល់អតិថិជនរបស់ខ្លួនជាមួយចំនួនប្រាក់កម្ចី ហើយចំនួនទឹកប្រាក់ដូចគ្នាត្រូវបានបញ្ចូលទៅក្នុងគណនីធនាគារពាណិជ្ជ។ ស្របជាមួយនឹងធនាគារដូចគ្នា ត្រូវបានបញ្ចូលចំនួនទឹកប្រាក់នៃប្រាក់កម្ចីដោយធនាគារកណ្តាល ដែលជំពាក់ប្រាក់កម្ចីទៅក្នុងគណនីរបស់ខ្លួន។ តើអ្នកណាផ្តល់ហិរញ្ញប្បទានឱ្យដល់ធនាគារកណ្តាល? គ្មាននោះធនាគារកណ្តាលអាចបង្កើតរូបិយវត្ថុបានច្រើនតាមដែលខ្លួនចង់បានដោយការបញ្ចូលគណនេយ្យសាមញ្ញ ហើយវាគ្មានជំពាក់អ្នកណាឡើយ។ នេះគឺជាឥទ្ធិពលនៃប្រព័ន្ធរូបិយវត្ថុ។ នេះគឺជាប្រភពដើមនៃការបង្កើតរូបិយវត្ថុ។ ក្រោយមកទៀត វាអាចផ្តល់ប្រាក់កម្ចីនេះដល់ធនាគារពាណិជ្ជកម្ម ឬទិញវិក្កយបត្ររតនាគារ (treasury bills)។ គោលបំណងរបស់វា គឺបញ្ចូលរូបិយវត្ថុទៅក្នុងសេដ្ឋកិច្ចពិត ដើម្បីផ្តល់នូវហិរញ្ញប្បទានដល់ការអភិវឌ្ឍន៍របស់ខ្លួន។ បញ្ហានេះគឺថាធនាគារពាណិជ្ជមិនចាំបាច់បញ្ចូលប្រាក់នេះទៅក្នុងសេដ្ឋកិច្ចពិតទេ។ អស់រយៈពេលជាច្រើនឆ្នាំមកហើយយើងបានឃើញការរឹតបន្តឹងច្បាប់សម្រាប់ធនាគារ ដើម្បីទទួលបានឥណទានប៉ុន្តែពួកគេមានសាច់ប្រាក់ងាយស្រួលលើស (excess liquidity) ពីធនាគារកណ្តាល។

នេះគឺជាភាពចម្លែកនៃប្រព័ន្ធរូបិយវត្ថុ។ ធនាគារកណ្តាល ផ្តល់ប្រាក់កម្ចីដល់ធនាគារពាណិជ្ជកម្ម ដោយមិនដឹងថាពួកគេនឹងធ្វើអ្វីជាមួយនឹងរូបិយវត្ថុ។ ជាលទ្ធផល រូបិយវត្ថុនេះបញ្ចប់នៅលើទីផ្សារហិរញ្ញវត្ថុ ហើយមិនមែននៅក្នុងសេដ្ឋកិច្ចពិតទេ!

ទោះយ៉ាងណា ចំនួនទឹកប្រាក់ដែលបានផ្តល់ឱ្យធនាគារមិនមានកំណត់ទេ។ រៀងរាល់សប្តាហ៍ ធនាគារកណ្តាលកំណត់ចំនួនទឹកប្រាក់ដែលខ្លួនបានត្រៀមផ្តល់ជូនធនាគារ រក្សាការគ្រប់គ្រងទ្រឹស្តីពីការបង្កើតរូបិយវត្ថុ។ ចំនួននេះប្រែប្រួលយោងទៅតាមគោលបំណងរបស់ធនាគារកណ្តាលដើម្បីប្រយុទ្ធប្រឆាំងបរិត្តផរណាជំរុញកំណើន។ល។ ធនាគារដែលផ្តល់ការប្រាក់ខ្ពស់បំផុតដល់ធនាគារកណ្តាលត្រូវបានវិភាជរូបិយវត្ថុជាមួយនឹងអត្រាទាបនាពេលបច្ចុប្បន្ន រូបិយវត្ថុត្រូវបានផ្តល់ឱ្យធនាគារស្ទើរតែមិនគិតថ្លៃសេវា។

ជាមួយនឹងប្រាក់សេវាឥតគិតថ្លៃនេះ (ឬក្នុងតម្លៃទាបបំផុត) ធនាគារទាំងនេះអាចផ្តល់ប្រាក់កម្ចីប្រសិនបើពួកគេចង់បាន។ ប្រសិនបើប្រាក់កម្ចីថ្មីត្រូវបានផ្តល់ឱ្យ ប្រាក់ដែលបានបង្កើតនឹងកើនឡើងទ្វេដង។ មានលុយបង្កើតឡើងដោយធនាគារកណ្តាល និងលុយបង្កើតដោយធនាគារពាណិជ្ជកម្មជាមួយនឹងផលប៉ះពាល់នៃមេគុណឥណទានដែលខ្ញុំបានរៀបរាប់ខាងលើ។ សម្រាប់ធនាគារទាំងនេះ គឺមានវាសនាល្អ! ពួកគេផ្តល់ប្រាក់កម្ចីដែលបានមកពីអតិថិជនរបស់ខ្លួន ឬពីធនាគារកណ្តាល។ ប្រាក់នេះមិនមែនជារបស់ពួកគេទេ ប៉ុន្តែធនាគារអាចទទួលបានប្រាក់ចំណេញយ៉ាងសំខាន់ពីវា (អត្រាការប្រាក់លើប្រាក់កម្ចី)។ ហានិភ័យតែមួយគត់ គឺប្រាក់កម្ចីនឹងមិនត្រូវបានសងវិញទេ។ ប៉ុន្តែប្រសិនបើនេះជាករណីធនាគារអាចរឹបអូសទ្រព្យសម្បត្តិដែលទាក់ទងប្រាក់កម្ចី។ ជាឧទាហរណ៍៖ ប្រសិនបើអ្នកមិនអាចសងបំណុលលើផ្ទះរបស់អ្នក វារឹបអូសផ្ទះរបស់អ្នកហើយលក់វា ដើម្បីសងប្រាក់កម្ចីរបស់វា។ វាជាការងារដ៏ អស្ចារ្យមួយក្នុងនាមជាធនាគារិក។ ពួកគេឈ្នះគ្រប់ពេល។

### ១.៦.៣- ឧបករណ៍បង្កើតរូបិយវត្ថុរបស់ធនាគារកណ្តាល ( Central Bank in Money creation instrument:

- អត្រាទុនបម្រុងកាតព្វកិច្ច៖ នេះគឺជាអត្រាដែលត្រូវប្រើសម្រាប់អនុបាតសោធនភាព Basell III អនុវត្តចំពោះធនាគារពាណិជ្ជកម្ម។ បច្ចុប្បន្ន វាគឺ ៨%។ វាត្រូវនឹងប្រាក់ដែលធនាគារត្រូវតម្កល់ទុក ហើយមិនអាចខ្ចីបាននៅពេលទទួលបានមូលនិធិ (ពីការសន្សំរបស់អតិថិជន ឬ ធនាគារកណ្តាល)។ ធនាគារកណ្តាលបានកំណត់អត្រានេះ។ ដើម្បីកាត់បន្ថយចំនួនប្រាក់កម្ចី ដូច្នេះការបង្កើតប្រាក់វាចាំបាច់ត្រូវបង្កើនអត្រានេះ។ ដូច្នេះ ឥទ្ធិពលនៃមេគុណឥណទាន (credit multiplier) ត្រូវបានកាត់បន្ថយ។ ផ្ទុយទៅវិញ តាមរយៈការទម្លាក់អត្រានេះធនាគារកណ្តាលអនុគ្រោះដល់ការបង្កើតប្រាក់។ ដើម្បីកាត់បន្ថយចំនួនប្រាក់កម្ចី ដូច្នេះការបង្កើតប្រាក់ វាចាំបាច់ត្រូវបង្កើនអត្រានេះ។ ដូច្នេះឥទ្ធិពលនៃមេគុណឥណទានត្រូវបានកាត់បន្ថយ។ ផ្ទុយទៅវិញ តាមរយៈការទម្លាក់អត្រានេះធនាគារកណ្តាលអនុគ្រោះដល់ការបង្កើតប្រាក់។

- អត្រាផ្តល់ហិរញ្ញប្បទានឡើងវិញ៖ នេះគឺជាអត្រាដែលធនាគារពាណិជ្ជកម្មអាចកែខ្លួនឡើងវិញជាមួយធនាគារកណ្តាល។ អត្រានេះទាបធនាគារពាណិជ្ជកាន់តែព្យាយាមខ្ចីប្រាក់ (លុយមានតម្លៃថោក) ដែលបង្កើនការបង្កើតរូបិយវត្ថុ។ ផ្ទុយទៅវិញ ការបង្កើនអត្រាផ្តល់ឥណទានឡើងវិញ កាត់បន្ថយការបង្កើតរូបិយវត្ថុ។ វាត្រូវនឹងអត្រាការប្រាក់សំខាន់ៗដែលអ្នកបានស្គាល់។
- ប្រតិបត្តិការទីផ្សារបើកចំហ៖ នេះគឺជាប្រតិបត្តិការដែលអនុវត្តដោយធនាគារកណ្តាល ដើម្បីទិញ ឬលក់មូលប័ត្ររដ្ឋាភិបាល (ប័ណ្ណរតនាគារ) លើទីផ្សារអន្តរធនាគារ។ ប្រសិនបើ ធនា-គារកណ្តាលលក់មូលប័ត្រ វានឹងស្តាត្រឡប់សាច់ប្រាក់ងាយស្រួលពីធនាគារពាណិជ្ជ។ សាច់ប្រាក់ងាយមិនអាចផ្តល់ឥណទានថ្មី ដែលមានឥទ្ធិពលកាត់បន្ថយការបង្កើតរូបិយវត្ថុឡើយ។ ផ្ទុយទៅវិញ តាមរយៈការទិញមូលប័ត្រសាធារណៈប្រតិបត្តិការ (QE) ធនាគារកណ្តាលផ្តល់សាច់ប្រាក់ងាយស្រួលដល់ធនាគារពាណិជ្ជ ដូច្នេះជំរុញបង្កើតរូបិយវត្ថុតាមរយៈផលគុណឥណទាន (credit multiplier)។

ទាំងអស់នេះ គឺទ្រឹស្តីពីព្រោះនៅចុងបញ្ចប់ធនាគារធ្វើអ្វីដែលពួកគេចង់បានពួកគេមានសេរីភាពក្នុងការឱ្យខ្ចី ឬអត់ឱ្យខ្ចី (ដូច្នេះដើម្បីបញ្ចូលសាច់ប្រាក់ងាយស្រួលនេះទៅក្នុងសេដ្ឋកិច្ចពិត)។ ធនាគារទាំងនេះ គ្រប់គ្រងពិភពលោកដែលមានការគ្រប់គ្រងលើការបង្កើតរូបិយវត្ថុ អតិផរណា កំណើន ការវិនិយោគ។ល។ សាច់ប្រាក់ងាយនឹងផ្តល់ផលល្អដល់ស្ថាប័នហិរញ្ញវត្ថុឱ្យដល់ប្រជាជន ដែលមានធន្ទះផ្តល់ឱ្យពួកគេ។

### ១.៦.៤- ប្រតិបត្តិការទីផ្សារបើកចំហ (Open market operation-OMO)

ជាមធ្យោបាយចម្បងដែលធនាគារកណ្តាលប្រើប្រាស់សម្រាប់អនុវត្តនូវគោលនយោបាយរូបិយវត្ថុ។ ឥទ្ធិពលផ្ទាល់ ៣យ៉ាងនៃទីផ្សារបើកចំហ៖

- បម្រែបម្រួលដល់ទុនបម្រុងជាការបម្រួញនៅក្នុងការផ្គត់ផ្គង់រូបិយវត្ថុ ដំណើររួញនៃការផ្គត់ផ្គង់រូបិយវត្ថុចុងក្រោយ។
- បម្រែបម្រួលអត្រាការប្រាក់សម្រាប់រយៈពេលវេលា ៣គឺ រយៈពេលខ្លី រយៈពេលមធ្យម រយៈពេលវែង ការទិញ ឬលក់ធនប័ណ្ណតាមបែបណាមួយ។
- បម្រែបម្រួលពីការរំពឹងទុកជាការកើនឡើងនូវការទិញមូលប័ត្ររបស់ធនាគារកណ្តាល។

គោលនយោបាយរូបិយវត្ថុពង្រីក ធ្វើឱ្យអត្រាការប្រាក់ថយចុះផលិតកម្ម និងការវិនិយោគកើនឡើង និងការកើនឡើងចំណាយប្រើប្រាស់របស់គ្រួសារផងដែរ។ ឥទ្ធិពលនៃប្រតិបត្តិការទីផ្សារបើកចំហមានឥទ្ធិពលធនប័ណ្ណរបស់ធនាគារបានជះឥទ្ធិពលលើប្រាក់បម្រុងទុក (ស្ថាប័នទទួលប្រាក់បញ្ញើ) មានឥទ្ធិពលលើថ្លៃ និងទិន្នផលនៃធនប័ណ្ណ មានឥទ្ធិពលដល់ការរំពឹងទុកផ្នែកឯកជនយ៉ាងច្បាស់លាស់។ គោលនយោបាយរូបិយវត្ថុមាន ២ប្រភេទគឺ គោលនយោបាយរូបិយវត្ថុពង្រីក (expansionary mone- tary policy) និងគោលនយោបាយរូបិយវត្ថុបង្រួម (Contractionary monetary policy)។ គោលនយោបាយរូបិយវត្ថុពង្រីក សំដៅលើគោលនយោបាយបង្កើនបរិមាណការផ្គត់ផ្គង់រូបិយវត្ថុ។ វី

ឯគោល នយោបាយរូបិយវត្ថុបង្រួម សំដៅលើគោលនយោបាយបន្ថយបរិមាណការផ្គត់ផ្គង់រូបិយវត្ថុ។ គោលនយោបាយទាំង២នេះ មានគោលដៅកែប្រែបរិមាណរូបិយវត្ថុមូលដ្ឋាន ដែលមានប្រាក់បម្រុងធនាគារ និងរូបិយវត្ថុក្រៅធនាគារតាមរយៈការអនុវត្តឧបករណ៍គោលនយោបាយរូបិយវត្ថុ។

## ១.៧- ទីផ្សាររូបិយវត្ថុ និងមូលប័ត្រក្នុងម៉ាក្រូសេដ្ឋកិច្ច ( Money and bond markets in monetary macroeconomics )

ចំពោះ "ទីផ្សាររូបិយវត្ថុ" មូលប័ត្របំណុលក្នុងម៉ាក្រូសេដ្ឋកិច្ចត្រូវបានចាត់ទុកថាជាទីផ្សារតម្រូវការរូបិយវត្ថុ និងការផ្គត់ផ្គង់រូបិយវត្ថុជាអន្តរកម្មជាមួយនឹងលំនឹងសមតា ដែលតំណាងឱ្យការបោសសម្អាតរូបិយវត្ថុនៅក្នុងទីផ្សារ។ ការប្រើភាសាអង់គ្លេសនៃពាក្យ "BONDS" សំដៅលើទីផ្សារមូលប័ត្របំណុលរយៈពេលខ្លី ជាពិសេសប័ណ្ណបំណុលរតនាគារ។ ដើម្បីបង្ហាញពីការប្រើប្រាស់ ជាទូទៅការរួមបញ្ចូលគ្នានេះត្រូវបានកំណត់ដោយពាក្យថា( ទីផ្សារមូលនិធិសង្គហៈ ) និងកាន់កាប់មូលប័ត្របំណុលរយៈពេលខ្លី ។ កត់សម្គាល់ថាសម្រាប់ការប្រើប្រាស់ពាក្យរបស់យើង "ទីផ្សាររូបិយវត្ថុ" ក្នុងសៀវភៅនេះ អនុវត្តតាមទ្រឹស្តីម៉ាក្រូសេដ្ឋកិច្ច។

សម្រាប់រូបិយវត្ថុ និងម៉ាក្រូសេដ្ឋកិច្ច គឺឱ្យនិយមន័យថា "សញ្ញាប័ណ្ណ( bonds)" ភ្ជាប់ទៅនឹងទ្រព្យសកម្មដែលមិនមែនហិរញ្ញវត្ថុ រួមមានប្រាក់កម្ចី និងប័ណ្ណភាគហ៊ុន។ ដូច្នេះពាក្យថា "សញ្ញាប័ណ្ណ" និង "ឥណទាន" ត្រូវបានចាត់ទុកជាពាក្យត្រឹមត្រូវ។ ការប្រើពាក្យនេះ សំដៅដល់ "ទីផ្សារមូលប័ត្របំណុល" ឬឥណទាន ឬប្រាក់កម្ចី ត្រូវបានចាត់ទុកជាទីផ្សារទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ។

រូបិយវត្ថុ គឺមានមុខងារជាច្រើនដោយពុំអាចកំណត់អត្តសញ្ញាណទ្រព្យសកម្មឱ្យបានជាក់លាក់នោះទេ ច្រើនតែបង្កបញ្ហាធ្ងន់ធ្ងរដល់ការកំណត់អត្តសញ្ញាណរបស់វាថែមទៀត ពីព្រោះថាទ្រព្យសកម្មមានខុសៗគ្នា និងមានមុខងារខុសៗគ្នា។ល។ បញ្ហានឹងវិធានការជាក់ស្តែងរបស់រូបិយវត្ថុ គឺមិនមែនជារឿងថ្មីនោះទេ ហើយរូបិយវត្ថុក៏មិនប្រើទម្រង់ស្រួចស្រាវខ្លាំងនោះដែរនាពេលបច្ចុប្បន្ននេះ។ ការវិវត្តដំបូងនៃសេដ្ឋកិច្ចគ្មានរូបិយវត្ថុ (barter economy) បានផ្លាស់ប្តូរទៅជាសេដ្ឋកិច្ចរូបិយវត្ថុវិញ )monetary economy) ដែលមានទម្រង់ទូទាត់ចំនួនមួយ ឬច្រើនជាងមួយ។ ទម្រង់មួយនៃរូបិយប័ណ្ណទាំងនេះ គឺជារូបិយប័ណ្ណដែលមានទម្រង់ជាកាសធ្វើឡើងពីលោហៈដ៏មានតម្លៃជាមួយនឹងតម្លៃប្តូរប្រាក់ ដែលវាយ៉ាងហោចណាស់ស្មើនឹងតម្លៃនៃលោហៈនៅក្នុងកាសនោះដែរ។

ជាទូទៅ កាសទាំងនេះត្រូវបានបញ្ចូលនូវអំណាចអាជ្ញាធររបស់ព្រះមហាក្សត្រ ហើយត្រូវបានគេប្រកាសថា "legal tenderដែលតម្រូវឱ្យអ្នកលក់ " ឬម្ចាស់បំណុលទទួលយកកាសទាំងនេះក្នុងការទូទាត់។ ការដេញថ្លៃស្របច្បាប់ស្ថិតក្នុងកាលៈទេសៈជាក់លាក់ ត្រូវបានបន្ថែមមុខងារជាមធ្យោបាយទូទាត់ដោយប័ណ្ណបំណុលរបស់មនុស្សម្នាក់ ឬស្ថាប័នហិរញ្ញវត្ថុ ដែលគួរឱ្យទុកចិត្តបាននៅសតវត្សរ៍ទី១៨ និង ១៩ ដោយបានចេញវិក័យបត្រប្តូរប្រាក់នៅចក្រភពអង់គ្លេសដំបូង។ ទោះយ៉ាងណា កាសទាំងនេះមិនត្រូវបានក្លាយជាមធ្យោបាយទូទាត់ ដែលអាចទទួលយកបានជាទូទៅនោះទេ។

ការលេចចេញនូវមុខងាររបស់ធនាគារពាណិជ្ជកម្មឯកជន[៦] បន្ទាប់ពីសតវត្សរ៍ទី១៨ នៅចក្រភពអង់គ្លេសបាននាំឱ្យមានការបោះផ្សាយក្រដាសប្រាក់ ជាឯកជនដោយធនាគារពួកគេ ហើយចុ (លុយ)ងក្រោយក៏មានការបញ្ជាដកលុយ។ ការទាក់ទាញពីធនាគារទាំងនេះ សម្រាប់អ្នកដែលមានប្រាក់តម្កល់ជាមួយធនាគារពួកគេ។ ទោះបីយ៉ាងណា ការរក្សាប្រាក់បញ្ញើតាមតម្រូវការរបស់ធនាគារបានក្លាយជារឿងធម្មតាក្នុងចំណោមសហគ្រាស និងអ្នកមានលុយច្រើននៅដើមសតវត្សរ៍ទី ២០។ ហើយប្រជាប្រិយភាពនៃប្រាក់បញ្ញើបែបនេះ បានចាប់ផ្តើមមានប្រជាប្រិយភាពក្នុងចំណោមមនុស្សម្នាសាមញ្ញ បានកើតឡើងក្នុងសតវត្សរ៍ទី ២០។ ជាមួយនឹងប្រជាប្រិយភាពនេះ ប្រាក់បញ្ញើតាមតម្រូវការ បានក្លាយជាធាតុផ្សំនៃមធ្យោបាយទូទាត់ក្នុងសេដ្ឋកិច្ចជាមួយនឹងបរិមាណប្រាក់បញ្ញើ ដែលកាន់តែធំជាងបរិមាណរូបិយប័ណ្ណ។

នាពាក់កណ្តាលសតវត្សរ៍ទី១៩ នៅក្នុងចក្រភពអង់គ្លេស សេដ្ឋវិទូ និងធនាគារិក បានប្រឈមនឹងបញ្ហានៅចំពោះមុខ ថាតើត្រូវដោះស្រាយបំណុលដែលមានតម្រូវការរបស់ធនាគារពាណិជ្ជកម្មលើ

រូបិយប័ណ្ណដូចជារូបិយវត្ថុឬអត់ដោយសារធនាគារពាណិជ្ជកម្ម ស្ថិតក្នុងភាពក្មេងខ្ចីនៅឡើយ ? ហើយត្រូវបានគេយកចិត្តទុកដាក់ចំពោះតែបុគ្គលដែលមានទ្រព្យសម្បត្តិ និងសហគ្រាសធំៗប៉ុណ្ណោះ។ ខណៈពេលដែលបានដំណើរការជាមធ្យោបាយទូទាត់ក្នុងចំណោមក្រុមទាំងនេះ ប្រជាជនភាគច្រើនមិនបានប្រើប្រាស់វានោះទេ។ ក្នុងបរិបទបែបនេះ មានការជជែកវែកញែកគួរឱ្យកត់សម្គាល់លើមុខងាររបស់រូបិយវត្ថុ ក្រដាសប្រាក់) និងកាសនិងគោលនយោបាយរូបិយវត្ថុ និងបទប្បញ្ញត្តិរូបិយវត្ថុឱ្យបាន ( សមស្របនាពាក់កណ្តាលសតវត្សរ៍ទី១៩ នៅប្រទេសអង់គ្លេស។

បញ្ហាទំនាស់ទាំងនេះ បានកើតឡើងជុំវិញការលេចចេញប្រាក់បញ្ញើតម្រូវការរបស់ធនាគារ ដែលអាចជំនួសឱ្យគ្នាបាន បើទោះបីរូបិយប័ណ្ណមិនល្អឥតខ្ចោះក៏ដោយ ហើយថាតើពីមុនជាផ្នែកមួយនៃការផ្គត់ផ្គង់រូបិយវត្ថុការវិវត្តបន្ថែមទៀតនៃប្រា ?ក់បញ្ញើតម្រូវការ និងធនាគារ នៅចុងសតវត្សរ៍ទី១៩ និងពាក់កណ្តាលសតវត្សរ៍ទី ២០ នៅចក្រភពអង់គ្លេស កាណាដា និងសហរដ្ឋអាម៉េរិក បាននាំឱ្យមានសុវត្ថិភាពដែលទាក់ទងនឹងការប្រើប្រាស់ប្រាក់បញ្ញើតម្រូវការ ហើយការបង្កើតឱ្យមានការជំនួសឱ្យគ្នាយ៉ាងជិតស្និទ្ធដោយរូបិយប័ណ្ណ។

ដូច្នេះ ការទទួលស្គាល់ខ្លឹមសាររបស់រូបិយវត្ថុ នៅអំឡុងត្រីមាសទី២ នៃសតវត្សរ៍ទី២០ បានឱ្យក្លាយជារូបិយប័ណ្ណដែលស្ថិតក្នុងដៃរបស់សាធារណជន និងប្រាក់បញ្ញើនៅក្នុងធនាគារពាណិជ្ជកម្ម។ ក្នុងអំឡុងពេលនោះ ប្រាក់បញ្ញើសន្សំមិនអាចពិនិត្យបាននោះទេ ហើយធនាគារបានកាន់កាប់ប្រាក់ទាំងនេះ អាចទទួចឱ្យមានការជូនដំណឹងជាមុន នៅមុនពេលដកប្រាក់ដោយផ្ទាល់របស់អ្នកដាក់ប្រាក់បញ្ញើ ដូច្នេះពួកគេមិនអាចដកតម្កល់ប្រាក់បញ្ញើបានទេ ហើយមិនអាចដកបានជាសាច់ប្រាក់ដែលជាមធ្យោបាយទូទាត់បានឡើយ។ អាស្រ័យហេតុនេះ រហូតមកដល់ពាក់កណ្តាលសតវត្សរ៍ទី២០ ការចាត់ចែងរូបិយវត្ថុមានលក្ខណៈតូចចង្អៀត បានកំណត់និមិត្តសញ្ញារូបិយវត្ថុដោយ M1។

[៦] *Many of the bankers were originally goldsmiths who maintained safety vaults and whose customers would depositgold coins with them for security reasons. When a depositor needed to make a payment to someone, he could write a note/letter authorizing the recipient to withdraw a certain amount from the deposits of the payer with the goldsmith.*

ហេតុមកដល់ពាក់កណ្តាលសតវត្សរ៍ទី ២០ ការតម្កល់ប្រាក់បញ្ញើតាមតម្រូវការ នៅក្នុងប្រទេសភាគច្រើន មិនបានបង់ការប្រាក់ទេ ហើយប្រាក់បញ្ញើសន្សំនៅក្នុងធនាគារពាណិជ្ជកម្មបានអនុវត្តដូច្នេះដែរសូម្បីតែត្រូវមានរបាំងច្បាប់ (Ceiling) លើអត្រាការប្រាក់ក៏ដោយ។ ក្នុងអំឡុងទសវត្សរ៍ ១៩៥០ ការផ្លាស់ប្តូរនូវការអនុវត្តរបស់ធនាគារលើប្រាក់បញ្ញើសន្សំទាំងនេះកាន់តែមានលក្ខណៈកាន់តែជិត និងជំនួសឱ្យដាក់តម្កល់ប្រាក់បញ្ញើតាមតម្រូវការ ដូច្នេះទំនាស់ដ៏ធំនៅទសវត្សរ៍ឆ្នាំ១៩៥០ ទាក់ទងនឹងប្រាក់សន្សំ ថាតើប្រាក់បញ្ញើសន្សំគួរ ឬមិនគួរ ត្រូវបានរាប់បញ្ចូលក្នុងការចាត់ចែងរូបិយវត្ថុមានលក្ខណៈតូចចង្អៀត។ ទោះយ៉ាងណា នៅដើមទសវត្សរ៍ឆ្នាំ១៩៦០ សេដ្ឋវិទូភាគច្រើនបានវាស់វែងការផ្គត់ផ្គង់រូបិយវត្ថុដោយ M2 ពោល គឺ M1 បូកនឹងប្រាក់បញ្ញើសន្សំក្នុងធនាគារពាណិជ្ជកម្ម ដោយបានមិនរាប់បញ្ចូលប្រភេទប្រាក់បញ្ញើណាមួយនៅក្នុងស្ថាប័នហិរញ្ញវត្ថុផ្សេងទៀតឡើយ។ ទម្រង់ការផ្លាស់ប្តូរ M2 នេះ ត្រូវបានគេស្គាល់ថា គឺជាទ្រឹស្តីរបស់លោក Milton Friedman (វិធានវាស់វែងរូបិយវត្ថុ គិតចាប់តាំងពីលោក (Milton Friedman មកម្លេះ គឺជាអ្នកគាំទ្រដ៏សំខាន់ម្នាក់នៅអំឡុងទសវត្សរ៍ ១៩៥០ និង ១៩៦០។

ក្នុងសហរដ្ឋអាម៉េរិក នាអំឡុងទសវត្សរ៍១៩៦០ អត្រាការប្រាក់ទីផ្សារលើមូលបត្របំណុល និងប័ណ្ណបំណុល បានកើនឡើងគួរឱ្យកត់សម្គាល់ដោយបានខ្ពស់ជាងរបាំងច្បាប់)Ceilling) បានកំណត់ដោយអាជ្ញាធរបទប្បញ្ញត្តិលើអត្រាការប្រាក់ដែលត្រូវបង់ប្រាក់បញ្ញើសន្សំក្នុងធនាគារពាណិជ្ជកម្ម។ ការប្រកួតប្រជែងក្នុងវិស័យនេះ មិនមានការគ្រប់គ្រងបានល្អដែលនាំឱ្យមានការផ្លាស់ប្តូរលក្ខណៈរូបិយវត្ថុប្រហាក់ប្រហែល (near-monies) ដែលមានស្រាប់ក្នុងអន្តរការីដែលមិនមែនហិរញ្ញវត្ថុ និងធ្វើឱ្យកាន់តែខិតជិតប្រាក់បញ្ញើតម្រូវការ ហើយក៏ឈានទៅរកការបង្កើតទ្រព្យសម្បត្តិផ្សេងទៀត ក្នុងវិស័យដែលមិនមានការគ្រប់គ្រងច្បាស់លាស់នេះ។

ដូច្នេះ ទ្រព្យបំណុលដែលមិនមែនជាអន្តរការីហិរញ្ញវត្ថុ អាចជំនួសឱ្យគ្នាបាន។ ទ្រព្យបំណុលខ្លះស្ថិតនៅក្បែរបំណុលដទៃទៀតជាង ប៉ុន្តែភាគច្រើននៅតែមានភាពមិនល្អឥតខ្ចោះចំពោះរូបិយប័ណ្ណ និងប្រាក់បញ្ញើទេ។ ភាពជិតស្និទ្ធកាន់តែខ្លាំងឡើងរបស់ពួកគេ បានបង្កើតឱ្យមានភាពចម្រូងចម្រាសដូចគ្នា ដែលបានកើតឡើងក្នុងសតវត្សរ៍ទី១៩ អំពីតួនាទីនៃប្រាក់បញ្ញើតាមតម្រូវការ ហើយទសវត្សរ៍ឆ្នាំ ១៩៥០ បានកើតឡើងអំពីប្រាក់បញ្ញើសន្សំនៅក្នុងធនាគារពាណិជ្ជកម្ម។ ការវិវត្តស្រដៀងគ្នានេះការប្រកែកគ្នាបានកើតឡើងនៅប្រទេសកាណាដា និងចក្រភពអង់គ្លេស។ នេះជាសំណួរដ៏សំខាន់ក្នុងភាពចម្រូងចម្រាសទាំងនេះ ថាតើត្រូវមានទ្រព្យសម្បត្តិយ៉ាងដូចម្តេច ប្រភេទរូបិយវត្ថុ ?M1 ជាមធ្យោបាយទូទាត់ចម្បងដែលត្រូវដាក់បញ្ចូលនៅក្នុងរង្វាស់នៃរូបិយវត្ថុ?

## ១.៧.១- ការវិវឌ្ឍន៍រូបិយវត្ថុ និងរូបិយវត្ថុប្រហាក់ប្រហែល ចាប់តាំងពី ១៩៤៥ (Evolution of money and near-monies since 1945)

ការវិវត្តនិយមន័យរូបិយវត្ថុ មានតាំងពីឆ្នាំ១៩៤៥មកម្លេះ បានទទួលស្គាល់ជាទូទៅថារូបិយប័ណ្ណដែលស្ថិតនៅក្នុងដៃរបស់សាធារណជន និងតម្កល់ប្រាក់បញ្ញើនៅធនាគារពាណិជ្ជកម្ម គឺបាន

កំណត់ថា (M1)។ ខ្លឹមសារនេះបានសង្កត់ធ្ងន់ទៅលើតួនាទីនៃមធ្យោបាយទូទាត់។ តម្កល់ប្រាក់បញ្ញើត្រូវបានកំណត់តាមគោលការណ៍ជាច្រើន ការប្រាក់មិនអាចត្រូវបានបង់តាមច្បាប់ ឬមិនត្រូវបានបង់ បរិមាណប្រាក់បម្រុងទុកខ្លះ ត្រូវរក្សាទុកដោយស្របច្បាប់ ឬត្រូវបានរក្សាតាមទម្លាប់របស់ធនាគារជាដើម។

ផ្ទុយពីខ្លឹមសារខាងលើនេះ ការវិវឌ្ឍន៍ជាច្រើនបាននាំឱ្យមានការបង្កើត និងជំនួសជាថ្មីសម្រាប់ប្រាក់បញ្ញើតម្រូវការ និងការបង្កើនប្រាក់បញ្ញើសន្សំ (saving deposit) កាន់តែច្រើន ដើម្បីប្រាក់បញ្ញើតម្រូវការ។ នៅប្រទេសកាណាដា ការវិវត្តនេះ បានបង្កើនភាពងាយស្រួលដល់ប្រាក់បញ្ញើសន្សំជាមួយធនាគារ ដែលគ្រប់គ្រងត្រួតត្រាជាចុងក្រោយនៃវិស័យហិរញ្ញវត្ថុជាមួយនឹងការកើនឡើងភាពងាយផ្នែកបំណុលរបស់ស្ថាប័នហិរញ្ញវត្ថុដែលមិនមែនហិរញ្ញវត្ថុ ដូចជាសមាគមឥណទាន[៧] សមាគមបញ្ចាំ និងសមាគមប្រាក់កម្ចី។

សហរដ្ឋអាម៉េរិករហូតដល់ទសវត្សរ៍ឆ្នាំទី១៩៧០ បម្រែបម្រួលបានបង្កើនសាច់ប្រាក់ងាយស្រួលជាចម្បងនៃប្រាក់បញ្ញើចរន្ត (time deposit) ក្នុងធនាគារពាណិជ្ជកម្ម និងប្រាក់បញ្ញើសន្សំ (saving deposit) ក្នុងគណនីសន្សំដែលមានភាគហ៊ុននៅក្នុងសមាគមប្រាក់កម្ចី។ នៅចក្រភពអង់គ្លេសដែលមានការកើនឡើងសាច់ប្រាក់ងាយស្រួល ការកើនឡើងសម្រាប់ប្រាក់បញ្ញើក្នុងគណនីធនាគារលក់រាយ និងសង្គហៈសង្គម។ ដោយសារការវិវត្តនេះនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ និង ១៩៧០ ការសិក្សាជាច្រើនបានបង្កើតទ្រព្យសម្បត្តិទាំងនេះ មានភាពកាន់តែច្រើនឡើង។

ការវិវត្តនៃការជំនួសឱ្យគ្នាយ៉ាងជិតរូបិយវត្ថុ M1 បាននាំឱ្យមានភាពចម្រូងចម្រាសសារជាថ្មីម្តងទៀត នៅពាក់កណ្តាលសតវត្សរ៍ទី២០ ដោយផ្អែកទៅលើខ្លឹមសាររូបិយវត្ថុដ៏ត្រឹមត្រូវមួយ។ ជាពិសេសនៅត្រីមាសទី៣ នៃសតវត្សរ៍ទី២០ មានការកើនឡើងយ៉ាងឆាប់រហ័សនៃប្រាក់បញ្ញើសន្សំក្នុងគណនីធនាគារពាណិជ្ជកម្ម និងអន្តរការីហិរញ្ញវត្ថុដែលមិនមែនជាធនាគារ ដោយសារតែបំណុលរបស់ពួកគេកាន់តែមានការផ្លាស់ប្តូរកាន់ច្រើនទៅនឹងប្រាក់បញ្ញើតម្រូវការ ដោយវាមិនបានក្លាយជាប្រព័ន្ធផ្សព្វផ្សាយនៃការបង់ប្រាក់ដោយផ្ទាល់។

ការណ៍នេះនាំឱ្យទទួលយក M2 ជារូបិយវត្ថុដ៏ត្រឹមត្រូវ បើទោះបីជាពុំមានការជំទាស់ក៏ដោយ។ នៅត្រីមាសទី៤ ដូចដែលបានរៀបរាប់ខាងលើនេះ មាននវានុវត្តន៍ជាច្រើនដែលធ្វើឱ្យមានការទទួលខុសត្រូវជាច្រើនរបស់អន្តរការីហិរញ្ញវត្ថុ បានកើនឡើងកាន់តែខ្លាំងដែលនាំឱ្យមានការទទួលស្គាល់ M2 ជាខ្លឹមសាររូបិយវត្ថុដ៏ត្រឹមត្រូវ បើទោះបីជាពុំមានការជំទាស់ក៏ដោយក្តី។ ដូចនេះ នៅក្នុងត្រីមាសទី៤ ដូចបានរៀបរាប់ខាងលើនេះ មានការបង្កើតថ្មីជាច្រើនឱ្យមានការទទួលខុសត្រូវរបស់អន្តរការីហិរញ្ញវត្ថុដែលមិនអាចប្រកែកបាន កាន់តែច្រើនពីប្រាក់បញ្ញើតាមតម្រូវការ។ នេះបាននាំឱ្យមានការអនុម័ត ឬយ៉ាងហោចណាស់ ត្រូវតែមានហេតុផលពង្រីកឱ្យកាន់តែធំទូលំទូលាយពីនិមិត្តសញ្ញារូបិយវត្ថុ M3 និង M4 ជាដើម។

---

៧ An example of these is caisses populaires in Quebec, Canada.

### ១.៧.២- នវានុវត្តន៍ផ្នែកហិរញ្ញវត្ថុ ( Financial innovations )

នវានុវត្តន៍ផ្នែកហិរញ្ញវត្ថុមានសន្ទុះយ៉ាងខ្លាំង ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៦០។ នវានុវត្តន៍ផ្នែកហិរញ្ញវត្ថុ បានរួមបញ្ចូលទាំងការផ្លាស់ប្តូរបច្ចេកទេសក្នុងការផ្តល់នូវសេវាប្រាក់បញ្ញើផ្សេងៗ ដូចជាម៉ាស៊ីនដាក់ ឬដកប្រាក់ស្វ័យប្រវត្តិ ប្រព័ន្ធទូរស័ព្ទតាមធនាគារ ប្រព័ន្ធទូរស័ព្ទតាមអនឡាញ និងប្រើប្រព័ន្ធកុំព្យូទ័រ។ល។ វាក៏រួមបញ្ចូលការបង្កើតទ្រព្យសកម្មថ្មីៗ មានដូចជាមូលនិធិសង្គហៈ (Matual fund) និងទីផ្សាររូបិយវត្ថុជាដើម។ ជារឿយៗ ត្រូវបានប្តូរទៅជាសាច់ប្រាក់បានយ៉ាងងាយ ស្រួល។ មានការរីករាលដាលដំបូងនៃកាតឥណទាន (credit card) បន្ទាប់មកទៀត ជាកាតឥណពន្ធឬកាតឥណទាន ហើយថ្មីៗនេះមានបង្កើត និងលក់កាតអេឡិចត្រូនិក ដែលពេលខ្លះត្រូវបានគេស្គាល់ថាជាកាបូបអេឡិចត្រូនិច ឬកាតឆ្លាតវៃ។ លើសពីនេះទៀត ការប្រកួតប្រជែងក្នុងចំណោមអន្តរការីហិរញ្ញវត្ថុផ្សេងៗគ្នា នៅក្នុងការផ្តល់នូវបំណុលដែលជាប្រាក់បញ្ញើតម្រូវការ ឬអាចបម្លែងទៅជាប្រាក់តម្កល់បានតាមទូរស័ព្ទ និងតាមអ៊ីនធឺណែតបានកើនឡើងគួរឱ្យកត់សម្គាល់ នាប៉ុន្មានទសវត្សរ៍ថ្មីៗនេះ។

នវានុវត្តន៍ថ្មីៗជាច្រើន បានធ្វើឱ្យមានភាពខុសគ្នារវាងប្រាក់បញ្ញើតម្រូវការ និងប្រាក់បញ្ញើសន្សំ ហើយក៏បានធ្វើឱ្យភាពខុសគ្នារវាងធនាគារ និងអន្តរការីហិរញ្ញវត្ថុមួយចំនួន ដែលជាអ្នកផ្គត់ផ្គង់បំណុលងាយស្រួល (liquid liabilities)។ ដំណើរការនវានុវត្តន៍នេះ និងការវិវត្តរបស់ស្ថាប័នហិរញ្ញវត្ថុ មានលំនាំត្រួតគ្នាក្នុងការផ្តល់សេវាកម្មហិរញ្ញវត្ថុនៅតែបន្ត។

កាតឥណទាន (credit card) បានអនុញ្ញាតឱ្យអ្នកបង់ប្រាក់សម្រាប់ធ្វើការទូទាត់ទិញទំនិញ និងសេវា នៅពេលដំណាលគ្នាមានការទទួលបានជាបំណុលដែលជំពាក់ក្រុមហ៊ុនជាកាតឥណទាន។ ដោយសារតែលទ្ធផលចុងក្រោយរបស់អ្នកសេដ្ឋកិច្ចភាគច្រើនជ្រើសរើសយកមិនរួមបញ្ចូលការប្រើប្រាស់កាតឥណទាន ឬខ្លឹមសាររបស់រូបិយវត្ថុ។ ហើយក៏មិនមែនជាកាតឥណទានដែលជាសាច់ប្រាក់ប្រហាក់ប្រហែល។ ទោះជាយ៉ាងណា ការប្រើប្រាស់របស់ពួកគេបានកាត់បន្ថយតម្រូវការសម្រាប់អ្នកទិញដែលកាន់រូបិយវត្ថុ និងកាត់បន្ថយតម្រូវការសាច់ប្រាក់។

កាតឥណពន្ធ (debit card) ត្រូវបានប្រើដើម្បីទូទាត់សម្រាប់ការទិញដោយផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកចេញពីគណនីធនាគាររបស់អ្នកទិញដែលភាគច្រើនជាគណនីប្រាក់បញ្ញើតម្រូវការ។ គេជំនួសដោយតម្រូវការក្នុងការទូទាត់ជារូបិយប័ណ្ណ ឬការចេញជាមូលប្បទានប័ត្រ។ ដូច្នេះ គេកាត់បន្ថយការកាន់កាប់ជារូបិយប័ណ្ណ។ គេក៏កាត់បន្ថយការទូទាត់ជាមូលប្បទានប័ត្រផងដែរ។ ទោះយ៉ាងណាក៏ដោយគេមិនរារាំងដល់តម្រូវការដើម្បីរក្សាសមតុល្យក្នុងគណនីធនាគារឥណពន្ធ ត្រូវបានបង្កើតឡើង។ ត្រូវបានគេរំពឹងថា នឹងមានផលប៉ះពាល់តិចតួចចំពោះការកាន់កាប់ប្រាក់បញ្ញើដែលអាចកើនឡើង ឬថយចុះ។

ការផ្ទេរតាមប្រព័ន្ធអេឡិចត្រូនិច គឺជាបន្ទេរតាមប្រព័ន្ធតាមអនឡាញ ដែលធ្វើឡើងតាមរយៈប្រព័ន្ធអ៊ីនធឺណេត។ គេកាត់បន្ថយតម្រូវការប្រើមូលប្បទានប័ត្រ សម្រាប់ការទូទាត់ការទិញលើទំនិញ និងសេវាកម្ម។ ទោះយ៉ាងណា ការផ្ទេរប្រាក់តាមអេឡិចត្រូនិកអាចមិនប៉ះពាល់ដល់ប្រាក់បញ្ញើក្នុងធនា-គារ ឬការធ្វើបែបនោះមានតិចតួច ដោយសារការអនុវត្តន៍ការគ្រប់គ្រងរូបិយវត្ថុបានប្រសើរជាងមុន

ដែលទទួលបានដោយធនាគារតាមប្រព័ន្ធអ៊ីនធឺណេត។ កាតឆ្លាតវៃ (smart card) បានបញ្ចូលសាច់ប្រាក់ជាក់លាក់មួយអាចត្រូវបានប្រើ ដើម្បីទូទាត់ប្រាក់នៅពេលទិញទំនិញ និងសេវាកម្មផ្សេងៗ។ ដោយសារតែអត្រាប្រេវ៉ាឡង់កើនឡើងនៃធនាគារតាមអ៊ីនធឺណេត និងកាតឥណពន្ធ ប័ណ្ណឆ្លាតវៃ ដែលទំនងត្រូវបានប្រើជាចម្បងសម្រាប់ការទូទាត់ប្រាក់តិចតួច ដូចជាកាតទូរស័ព្ទ កាតថតចម្លង កាតបណ្ណាល័យជាដើម។ កាតឆ្លាតវៃ បានកាត់បន្ថយតម្រូវការការកាន់កាប់ជារូបិយប័ណ្ណ និងកាត់បន្ថយតម្រូវការប្រាក់(រូបិយវត្ថុ)។

ហេតុដូច្នេះ នវានុវត្តន៍ហិរញ្ញវត្ថុក្នុងទម្រង់ឥណពន្ធ និងកាតឆ្លាតវៃ បានកាត់បន្ថយការកាន់កាប់រូបិយប័ណ្ណជាជាងការដាក់ប្រាក់តម្កល់។ នវានុវត្តន៍ផ្នែកហិរញ្ញវត្ថុក្នុងទម្រង់នៃបន្ទេរតាមអ៊ីនធឺណេតបានជួយសម្រួលដល់ការវិនិយោគសមតុល្យទំនេរក្នុងពេលតែមួយ អាចនឹងមានប្រាក់បញ្ញើសន្សំមូលនិធិទីផ្សារដែលបានការប្រាក់ខ្ពស់ជាដើម ដោយសារការកាត់បន្ថយតម្រូវការប្រាក់បញ្ញើ។

ប៉ុន្មានទសវត្សរ៍ថ្មីៗនេះ ការកាត់បន្ថយថ្លៃសេវានៃឈ្នួញកណ្តាល សម្រាប់ការផ្ទេរប្រាក់ និងទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុដូចជាសញ្ញាប័ណ្ណ និងភាគហ៊ុន ជាបដិវត្តន៍ (អ៊ីនធឺណេតក្នុងវិស័យធនាគារអេឡិចត្រូនិក មានន័យថាកាត់បន្ថយតម្រូវការរូបិយវត្ថុ)។ ជ្រុងមួយនៃបញ្ហានេះ គឺដោយសារការកាត់បន្ថយតម្រូវការនៃសមតុល្យ ផ្ទុយពីការរំពឹងទុកលើការចំណាយប្រើប្រាស់។ ការកាត់បន្ថយនេះ បានកើតឡើងដោយសារបុគ្គលម្នាក់ៗ អាចមានភាពងាយស្រួល និងការចំណាយទាបជាងមុន ដើម្បីឆ្លើយតបទៅនឹងតម្រូវការចំណាយដែលមិនបានរំពឹងទុកដោយប្តូរពីទ្រព្យសកម្មផ្សេងៗជារូបិយវត្ថុ។

### ១.៧.៣- ការវិវឌ្ឍន៍ទ្រឹស្តីរូបិយវត្ថុ (Theoretical developments of money)

បើតាមទ្រឹស្តីរបស់លោក កេនស៍ (១៩៣៦) បានណែនាំពីតម្រូវការរូបិយវត្ថុដែលអាចប៉ាន់ស្មានបានថាជាកត្តាជំរុញប្រាកដ៏សំខាន់ក្នុងការកាន់កាប់រូបិយវត្ថុ។ លោក Milton Friedman (1956) បានបកស្រាយឡើងវិញនូវទ្រឹស្តីនៃបរិមាណរូបិយវត្ថុ ដើម្បីបញ្ជាក់អំពីតួនាទីរបស់រូបិយវត្ថុដែលលោកបានបញ្ជាក់ពីតួនាទីរបស់រូបិយវត្ថុ ក្នុងអំណាចទិញដែលមានលក្ខណៈជាបណ្តោះអាសន្នដោយពាក់ព័ន្ធនឹងពេលវេលាដែលអតិថិជនយល់ថាល្អ ឬមិនល្អ។ មានទ្រឹស្តីជាច្រើនទៀត និងការសិក្សាលើទ្រឹស្តីទាំងនេះ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៥០ និង ១៩៦០ ត្រូវបានចង្អុលបង្ហាញពីការអភិវឌ្ឍន៍ជំនួសដោយប្រើរូបិយវត្ថុ មានលក្ខណៈពិសេសនៃការវិវត្តន៍ហិរញ្ញវត្ថុរបស់សេដ្ឋកិច្ច។

នៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ការវិវត្តន៍ទាំងនេះ បាននាំឱ្យមានការរៀបចំឡើងវិញនូវមុខងាររបស់រូបិយវត្ថុ ដើម្បីបញ្ជាក់ពីការរក្សាតម្លៃ (store of value) ក្នុងករណីទ្រព្យសកម្មទាំងនេះ ដែលទាក់ទងទៅនឹងទ្រព្យសកម្មច្រើនជាងទិដ្ឋភាពនៃមធ្យោបាយទូទាត់។ ជាលទ្ធផលនៃការផ្លាស់ប្តូរ ដោយបានផ្តោតទៅលើការជំនួសដោយបំណុលរបស់ធនាគារ និងបំណុលរបស់អន្តរការីហិរញ្ញវត្ថុដទៃទៀត។

ដូចនេះ សម្រាប់ការផ្លាស់ប្តូរនេះ ខ្លឹមសាររបស់រូបិយវត្ថុ ត្រូវបានគាំទ្រទាំងពីរផ្នែកនៃការផ្លាស់ប្តូរនៅក្នុងការវិភាគតម្រូវការរូបិយវត្ថុ និងការផ្គត់ផ្គង់រូបិយវត្ថុដ៏សមស្របនឹងបង្ហាញពីមុខងាររក្សាតម្លៃ (store of value) និងការសិក្សាវិភាគជាច្រើនផ្សេងទៀត។ ទោះយ៉ាងណាក៏ដោយ វត្តមាននៃទ្រព្យ

សម្បត្តិជាច្រើន ដែលបំពេញមុខងាររបស់រូបិយវត្ថុនៅក្នុងកម្រិតខុសៗគ្នា ការវិភាគទ្រឹស្តីសុទ្ធសាធមិនបានបង្ហាញថាជាមធ្យោបាយច្បាស់លាស់ ចំពោះការវាស់ស្ទង់ ឬវាស់វែងរូបិយវត្ថុនោះទេ។

លើសពីនេះទៀត ក្នុងទំនាស់លើបញ្ហានេះនៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ អ្នកស្រាវជ្រាវជាច្រើននៃគំរូម៉ូដែលកេនស៍និយម បានលើកយកអថេរម៉ាក្រូសេដ្ឋកិច្ចដែលទាក់ទងនឹងរូបិយវត្ថុជាប្រាក់ចំណូលជាតិមានតែនាម (nominal national income) និងអត្រាការប្រាក់ ដែលបានរកឃើញខ្លឹមសារមានលក្ខណៈទូលំទូលាយប្រភេទរូបិយវត្ថុ M2 ដោយរួមបញ្ចូលប្រាក់បញ្ញើជាច្រើនប្រភេទនៃអន្តរការីហិរញ្ញវត្ថុមិនមែនធនាគារ និងប័ណ្ណបំណុលរបស់រតនាគារផ្សេងៗទៀត និងប័ណ្ណបំណុលរដ្ឋាភិបាលផងដែរ។

រហូតមកដល់ទសវត្សឆ្នាំ១៩៧០ ការងារជាក់ស្តែងតាមរយៈខ្លឹមសាររូបិយវត្ថុបានកំណត់ខាងលើបាននាំមកនូវលទ្ធផលជាច្រើន ដោយមានអំណះអំណាងលម្អិតបន្ថែម បើទោះបីជាមានការព្រមព្រៀងគ្នាថាប្រភេទរូបិយវត្ថុ M2 ឬរូបិយវត្ថុទូលំទូលាយ អនុវត្តបានល្អប្រសើរក្នុងការពន្យល់ពីអថេរម៉ាក្រូសេដ្ឋកិច្ចដែលពាក់ព័ន្ធច្រើនជាងខ្លឹមសាររូបិយវត្ថុតូចចង្អៀតក៏ដោយ។

ការមូលមតិគ្នានេះ បានរលុបបាត់ទៅវិញនៅទសវត្សរ៍ឆ្នាំ ១៩៧០ និង ១៩៨០ ក្នុងការប្រឈមនឹងការកើនឡើងនូវភស្តុតាងជាក់ស្តែង ដែលមិនមានផលបូកសរុបប្រភេទរូបិយវត្ថុ M1, M2 ឬ រូបិយវត្ថុទូលំទូលាយ មានទំនាក់ទំនងនឹងស្ថិរភាពជាមួយប្រាក់ចំណូលជាតិមានតែនាម (nominal national income)ទេ។ ការស្រាវជ្រាវលើទិន្នន័យក្នុងឆ្នាំ ១៩៧០ និង១៩៨០ បានបង្ហាញថា៖ (ក)-មុខងារតម្រូវការសម្រាប់រូបិយវត្ថុសរុបដែលមានលក្ខណៈសាមញ្ញ គឺមិនមានស្ថិតស្ថេរ និង(ខ)-មិនមានទំនាក់ទំនងស្ថិរភាពជាមួយនឹងប្រាក់ចំណូលជាតិតែនាមឡើយ។ សម្រាប់ផលបូកសរុបខាងលើបានជំរុញឱ្យមានទម្រង់មុខងារថ្មីជាច្រើនសម្រាប់ការកំណត់ខ្លឹមសាររូបិយវត្ថុ។ ការកំណត់ស្ថិរភាពនៃមុខងារតម្រូវការរូបិយវត្ថុ បាននាំទៅរកការបង្កើតនូវបច្ចេកទេសអេកូណូមេទ្រីកដែលបណ្តាលឱ្យមានការវិភាគលើគំរូកែប្រែកំហុសនៃទិន្នន័យបែបស៊េរី និងការទាញយកមុខងាររយៈពេលវែង និងខ្លីដាច់ដោយឡែកពីគ្នាសម្រាប់រូបិយវត្ថុ។

លើសពីនេះទៀត សម្រាប់បន្តសិក្សាអំពីអស្ថិរភាពនៃមុខងារតម្រូវការរូបិយវត្ថុ M2 និងនៅតែបន្តឱ្យនិយមន័យជារូបិយវត្ថុទូលាយដដែល ចាប់តាំងពីឆ្នាំ ១៩៨០ បាននាំឱ្យបង្កើនការពេញចិត្តលើប្រភេទរូបិយវត្ថុ M1 មួយចំនួនលើការប្រមូលផ្តុំទូលំទូលាយសម្រាប់ការបង្កើតគោលនយោបាយរូបិយវត្ថុ និងការសន្មតដោយហេតុនេះបង្វែរការផ្លាស់ប្តូរឆ្ពោះទៅរកប្រភេទរូបិយវត្ថុ M2 និងរូបិយវត្ថុទូលាយផ្សេងទៀត ដែលបានកើតឡើងនៅទសវត្សរ៍ឆ្នាំ ១៩៥០ និង ១៩៦០។

បន្ថែមពីនេះទៀត ការសិក្សាពិសោធន៍ពីអស្ថិរភាពជាក់ស្តែងនៃមុខងារតម្រូវរូបិយវត្ថុ បានធ្វើឱ្យមានការថយចុះគួរឱ្យកត់សម្គាល់ បន្ទាប់ពីទសវត្សរ៍ឆ្នាំ១៩៨០ ព្រមទាំងការសិក្សាវិភាគ និងការសិក្សាពិសោធន៍លើនិយមន័យរូបិយវត្ថុ។ បន្ថែមលើសពីនេះទៀត បន្ទាប់ពីទសវត្សរ៍ឆ្នាំ ១៩៨០ គោលនយោបាយរូបិយវត្ថុ និងម៉ាក្រូសេដ្ឋកិច្ចដែលមានធនាគារកណ្តាល និងអ្នកស្រាវជ្រាវជាច្រើន បានជ្រើសយកដោយផ្តោតលើអត្រាការប្រាក់ដែលជាឧបករណ៍គោលនយោបាយរូបិយវត្ថុដ៏សមស្រប។ ហេតុនេះអាចកាត់បន្ថយការផ្គត់ផ្គង់រូបិយវត្ថុ និងតម្រូវការរូបិយវត្ថុ ក្រៅពីហេតុផលម៉ាក្រូសេដ្ឋកិច្ច។ ការពិភាក្សាអំពីការផ្លាស់ប្តូរនេះ និងផលប៉ះពាល់របស់វាសម្រាប់គំរូម៉ាក្រូសេដ្ឋកិច្ច និងការវិភាគគោលនយោបាយ។

### ១.៧.៤- មូលដ្ឋានរូបិយវត្ថុ និងតួគុណរូបិយវត្ថុ ( Monetary base and monetary base multiplier )

ការផ្គត់ផ្គង់រូបិយវត្ថុ គឺទាក់ទងនឹងមូលដ្ឋានរូបិយវត្ថុ (monetary base) ដែលជួនកាលគេហៅថា "reserve base" ដោយមូលដ្ឋានមេគុណរូបិយវត្ថុ(monetary multiplier)។ ករណីមេគុណនេះធំជាង១ រូបិយវត្ថុមូលដ្ឋានត្រូវបានគេស្គាល់ថាជារូបិយវត្ថុដែលមានថាមពលខ្ពស់។ យើងកំណត់ប្រើ និមិត្តសញ្ញាប្រភេទរូបិយវត្ថុ M0។ លក្ខណៈទូទៅរបស់ប្រភេទរូបិយវត្ថុ M0 គឺ៖

M0 = រូបិយប័ណ្ណក្នុងដៃរបស់ធនាគារសាធារណៈមិនមែនជាធនាគារ + រូបិយប័ណ្ណដែលកាន់កាប់ដោយធនាគារពាណិជ្ជកម្ម + ប្រាក់បម្រុងដែលកាន់កាប់ដោយធនាគារពាណិជ្ជជាមួយនឹងធនាគារកណ្តាល។

ធនាគារកណ្តាលអាចគ្រប់គ្រងរូបិយវត្ថុតាមរយៈប្រតិបត្តិការទីផ្សារបើកចំហ(OMO)និងវិធានការផ្សេងទៀត។ មូលដ្ឋានមេគុណរូបិយវត្ថុ "monetary base multiplier" ត្រូវបានគេកំណត់ថា $\partial M/\partial M0$ ។ ប្រសិនបើ តម្លៃតួគុណរូបិយវត្ថុនេះគឺនៅថេរ ឬមុខងារនៃអថេរតូចៗ របស់ធនាគារកណ្តាលអាចគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុ ដោយការផ្លាស់ប្តូររូបិយវត្ថុមូលដ្ឋាន។

ទោះយ៉ាងណា ការកត់សម្គាល់របស់យើងនៅក្នុងមេរៀននេះស្តីពីអស្ថិរភាពនៃមុខងារតម្រូវការរូបិយវត្ថុនាប៉ុន្មានទសវត្សរ៍ថ្មីៗនេះ បានបញ្ជាក់ថាមេគុណនេះមិនមានមុខងារថេរ ឬមិនមានស្ថិរភាពនៃអថេរតូចៗ ដោយសារតែនវានុវត្តន៍ភាពយ៉ាងទូលំទូលាយ ដូច្នេះធនាគារកណ្តាលគ្រប់គ្រងលើមូលដ្ឋានរូបិយវត្ថុ មិនបានធានានូវការគ្រប់គ្រងប្រហាក់ប្រហែលគ្នាលើការផ្គត់ផ្គង់រូបិយវត្ថុនោះទេ។ រូបិយវត្ថុមូលដ្ឋាន គឺចាំបាច់ត្រូវបានកត់សម្គាល់ដោយមេគុណរូបិយវត្ថុជាប្រាក់ចំណូលជាតិមានតែនាម (money to nominal income) ដែលត្រូវបានគេកំណត់ថាជា $\partial Y/\partial M$, ដោយនិមិត្តិសញ្ញាជា Y= nominal national income។

ដូច្នេះ $Y \equiv MV$ ដែល V ជាល្បឿនបង្វិលរូបិយវត្ថុ មេគុណនៃរូបិយវត្ថុស្មើនឹង V។ ជាទូទៅ មេគុណនៃរូបិយវត្ថុនេះមិនមែនថេរទេ ក៏ប៉ុន្តែអប្បបរមា (minimum) គឺជាមុខងារនៃអថេរជាច្រើន រួមមានទាំងអត្រាការប្រាក់(interest rate)។ មុខងារទាំងនេះអាច ឬក៏មិនអាចមានស្ថិតស្ថេរ។ ដូច្នេះការគ្រប់គ្រងរបស់ធនាគារកណ្តាលលើមូលដ្ឋានរូបិយវត្ថុ មិនចាំបាច់ធានានូវការគ្រប់គ្រងកម្រិតខ្ពស់នៃប្រាក់ចំណូលមានតែនាម (nominal income) នោះទេ ដោយសារអស្ថិរភាពនៃមូលដ្ឋានរូបិយវត្ថុ ឬអស្ថិរភាពនៃល្បឿននៃការចរាចរណ៍រូបិយវត្ថុ ឬទាំងពីរ។

## ១.៨- ភាពខុសគ្នារវាងអត្រាការប្រាក់ និងការផ្គត់ផ្គង់រូបិយវត្ថុ (Interest rates versus money supply

ធនាគារកណ្តាល អនុវត្តការគ្រប់គ្រងលើអត្រាការប្រាក់របស់សេដ្ឋកិច្ចបន្ថែមលើការផ្គត់ផ្គង់រូបិយវត្ថុ ឬជំនួសប្រើឧបករណ៍គោលនយោបាយរូបិយវត្ថុ។ ទាក់ទិននឹងឧបករណ៍គោលនយោបាយរូបិយវត្ថុ គឺពិតជាឧបករណ៍ដែលត្រូវបានប្រើជាកម្មវត្ថុចម្បង ត្រូវបានកំណត់ដោយធនាគារកណ្តាល។ ប្រសិន

បើការផ្គត់ផ្គង់រូបិយវត្ថុត្រូវបានប្រើជាឧបករណ៍ចម្បងលើអត្រាការប្រាក់របស់សេដ្ឋកិច្ចនឹងមានការផ្លាស់ប្តូរការឆ្លើយតបនឹងការផ្លាស់ប្តូររបស់ធនាគារកណ្តាលក្នុងការផ្គត់ផ្គង់រូបិយវត្ថុ ដែលមានលក្ខណៈមិនល្អ។

ប្រសិនបើ អត្រាការប្រាក់ត្រូវបានប្រើជាឧបករណ៍គោលនយោបាយរូបិយវត្ថុ ជាបឋមតម្រូវការរូបិយវត្ថុរបស់សេដ្ឋកិច្ចនឹងផ្លាស់ប្តូរ ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអត្រាការប្រាក់។ ករណីនេះប្រសិនបើទីផ្សាររូបិយវត្ថុក្បាលំនឹងសមតាទីផ្សារ ធនាគារកណ្តាលត្រូវតែសម្រួលការផ្លាស់ប្តូរតម្រូវការរូបិយវត្ថុ ដោយការផ្លាស់ប្តូរដ៏សមស្របក្នុងការផ្គត់ផ្គង់រូបិយវត្ថុ ហេតុដូច្នេះការផ្គត់ផ្គង់រូបិយវត្ថុនឹងក្លាយជារឿងដែលមិនអាចទទួលយកបាន។

ខណៈពេលការធ្វើជម្រើសរវាងការផ្គត់ផ្គង់រូបិយវត្ថុ និងអត្រាការប្រាក់ អាចជារឿងតូចតាចក្រោមរូបភាពប្រាកដប្រជា និងស្ថិរភាពមុខងារតម្រូវការរូបិយវត្ថុ ប៉ុន្តែវាមិនទំនងជារឿងតូចតាចដែលស្ថិតក្រោមរូបភាពមិនប្រាកដប្រជា និងមុខងារតម្រូវការរូបិយវត្ថុដែលមិនមានស្ថិតស្ថេរទេ។ ដូច្នេះ ធនាគារកណ្តាលត្រូវបង្ខំចិត្តធ្វើការជ្រើសរើសរវាងជម្រើសទាំងពីរនេះ។

បញ្ហាទាំងនេះ ត្រូវបាននាំដល់ការជជែកវែកញែកឱ្យកាន់តែសមស្របលើការវិភាគម៉ាក្រូសេដ្ឋកិច្ចដែលបានកំណត់ដោយធនាគារកណ្តាលក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចនៃគោលនយោបាយរូបិយវត្ថុ ក្នុងការប្រើប្រាស់អត្រាការប្រាក់ជាឧបករណ៍គោលនយោបាយរូបិយវត្ថុចម្បង និងបោះបង់តួនាទីសម្រាប់ការផ្គត់ផ្គង់រូបិយវត្ថុ។ គំរូម៉ូដែលនេអូកេនស៍ )New-Keynesian (សម្រាប់រយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ មានរួមបញ្ចូលនូវសម្មតិកម្មបែបនេះ។ បញ្ហាទាំងនេះ ត្រូវបានពិភាក្សាល្អិតល្អន់នៅក្នុងបទបង្ហាញម៉ូដែលគំរូទាំងនេះនៅក្នុងជំពូកនេះនៃមេរៀនបន្ទាប់។

### ១.៨.១- តួនាទីធនាគារក្នុងនាមជាអន្តរការីហិរញ្ញវត្ថុ

( Role of banks as financial intermediaries )

ធនាគារ មិនត្រឹមតែជាអន្តរការីហិរញ្ញវត្ថុតែមួយគត់ក្នុងសេដ្ឋកិច្ចតែប៉ុណ្ណោះទេ ប៉ុន្តែបានដើរតួនាទីក្នុងការពង្រីកប្រាក់កម្ចីរបស់ពួកគេ ដោយតម្រូវឱ្យមានការបង្កើតបំណុលឱ្យកាន់តែច្រើនរបស់ពួកគេ គឺឱ្យកាន់តែធំធេង និងមានការទទួលស្គាល់ជាទូទៅផងដែរ។ ធនាគារបានទទួលនូវប្រាក់បញ្ញើគ្មានកាលកំណត់ និងប្រាក់បញ្ញើមានកាលកំណត់ ហើយភាពខុសគ្នាពីអន្តរការីហិរញ្ញវត្ថុផ្សេងទៀត ដែលបំណុលរបស់ពួកគេអាចទទួលយកបាន និងមានភាពងាយស្រួលជាសាច់ប្រាក់ ប្រាក់បញ្ញើតម្រូវការ គឺជាមធ្យោបាយទូទាត់តាមទម្រង់បែបបទនៃរូបិយវត្ថុ។

លើសពីនេះទៀត ទ្រព្យបំណុលផ្សេងទៀតរបស់ពួកគេ ជាប្រាក់បញ្ញើមានកាលកំណត់ គឺអាចជំនួសឱ្យយ៉ាងជិតស្និទ្ធជាមួយនឹងរូបិយប័ណ្ណ និងប្រាក់បញ្ញើតម្រូវការ។ តាមរយៈការប្រៀបធៀបបំណុលរបស់អន្តរការីហិរញ្ញវត្ថុដែលមិនមែនជាធនាគារ និងមិនមែនជាមធ្យោបាយទូទាត់ដោយផ្ទាល់ទេ ហើយក៏មិនអាចជំនួសឱ្យគ្នាបានល្អឥតខ្ចោះឡើយ។ តួនាទីពិសេសនៃបំណុលរបស់ធនាគារនៅក្នុងសេដ្ឋកិច្ចធនាគារជាប្រភេទអន្តរការីហិរញ្ញវត្ថុ និងប្រព្រឹត្តកម្មចំពោះគោលនយោបាយរូបិយវត្ថុ គឺមានសារសំខាន់ណាស់។

### ១.៨.២- ភាពផុយស្រួយនៃប្រព័ន្ធហិរញ្ញវត្ថុ (Fragility of the financial system)

ប្រព័ន្ធហិរញ្ញវត្ថុត្រូវបានគេនិយាយថា មានភាពផុយស្រួយក្នុងន័យថាវាងាយនឹងមានវិបត្តិ។ បញ្ហានេះ រួមមានការពឹងផ្អែកលើប្រព័ន្ធទុនបម្រុងប្រភាគ (fractional reserve system) និងបញ្ជូនទ្រព្យសម្បត្តិ (transmutation)។ ប្រព័ន្ធហិរញ្ញវត្ថុកាន់កាប់តែផ្នែកតូចមួយចំនួននៃបំណុល តែភាគច្រើនប្រាក់បញ្ញើជាទុនបម្រុង (កាន់កាប់ជារូបិយប័ណ្ណ និងប្រាក់បញ្ញើជាមួយធនាគារកណ្តាល) ហើយមិនអាចសងប្រាក់បញ្ញើទាំងនេះបានទេ ប្រសិនបើអ្នកដាក់ប្រាក់បញ្ញើមានបំណងភ្លាមៗ និងព្យាយាមដកប្រាក់យ៉ាងច្រើននៃគណនីប្រាក់បញ្ញើរបស់ពួកគេ។

ការដកប្រាក់ពីធនាគារ ត្រូវបានគេស្គាល់ថាជា "ការដំណើរដកប្រាក់"ពីធនាគារ ហើយបានបង្ហាញយ៉ាងច្បាស់ គឺថាអ្នកដាក់ប្រាក់បញ្ញើ ដែលកំពុងឈររង់ចាំចូលធនាគារដើម្បីដកប្រាក់បញ្ញើរបស់ពួកគេវិញ។ ការផ្ទេរ ឬបញ្ជូនទ្រព្យសកម្ម មានន័យថាវាជាបំណុលរបស់ធនាគារមានកាលវសាន្ត (maturity) រយៈពេលខ្លីជាងទ្រព្យសកម្មរបស់ពួកគេមាន។ ករណីដំណើរការដកប្រាក់ពីធនាគារ ប្រសិនបើធនាគារព្យាយាមលក់ទ្រព្យសកម្មរបស់ខ្លួនក្នុងរយៈពេលខ្លី វាទំនងនឹងការខាតបង់លើចំនួនទឹកប្រាក់ដែលអាចទទួលបាន ប្រសិនបើវាកាន់កាប់ទ្រព្យសកម្មហូតដល់កាលវសាន្ត (maturity) ឬលក់វាក្នុងឱកាសដែលល្អប្រសើរនោះ។

ដូចគ្នានេះផងដែរ សូមកត់សម្គាល់ថាផ្នែកដ៏សំខាន់នៃទ្រព្យសកម្មដែលកាន់កាប់ដោយធនាគារ គឺស្ថិតក្នុងទម្រង់ជាប្រាក់កម្ចីនៃទីផ្សារដែលមិនមែនជាបំណុល (non-marketable loans) ដែលមានភាពលំបាកក្នុងការបំប្លែងទៅជាសាច់ប្រាក់ក្នុងរយៈពេលខ្លីបាន។ ដូចនេះ ប្រព័ន្ធទុនបម្រុងប្រភាគ (fractional reserve system) នឹងការផ្ទេរទ្រព្យសកម្មរបស់ខ្លួន ដោយពឹងផ្អែកលើការជឿទុកចិត្តរបស់អ្នកដាក់ប្រាក់បញ្ញើជាសាច់ប្រាក់ងាយស្រួល និងសោធនភាពរបស់ធនាគារ។

ការលេចចេញនូវការមិនជឿទុកចិត្តទាំងស្រុងទៅលើសមត្ថភាពរបស់ធនាគារ ក្នុងការផ្តល់សេវាដកប្រាក់ពីធនាគារ។ បើទោះបីជា វាកើតឡើងដោយសារពាក្យចចាមអារ៉ាមមិនយុត្តិធម៌ ឬវាគ្រាន់តែជាការរីករាលដាលពីស្ថាប័នហិរញ្ញវត្ថុផ្សេងក៏ដោយ ក៏វានៅតែអាចធ្វើឱ្យកើតឡើង ព្រមទាំងការបដិសេធដោយស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត ដើម្បីគាំទ្រ និងផ្តល់ការឱ្យខ្ចី។

ករណីនេះអាចបណ្តាលឱ្យមានការបិទទ្វារធនាគារ។ ការការពារខ្លះប្រឆាំងនឹងព្រឹត្តិការណ៍បែបនេះ ត្រូវបានផ្តល់ឱ្យមានការធានារ៉ាប់រងលើប្រាក់បញ្ញើជារឿយៗ ដោយទីភ្នាក់ងារសាធារណៈ ដូច្នេះអ្នកដាក់ប្រាក់បញ្ញើ មិនចាំបាច់ព្រួយបារម្ភអំពីសុវត្ថិភាពនៃប្រាក់បញ្ញើរបស់ពួកគេ និងគោលនយោបាយជាសិទ្ធិផ្តាច់មុខរបស់ធនាគារកណ្តាល "អ្នកឱ្យខ្ចីប្រាក់ចុងក្រោយ"។ បើទោះបីជាមិនមានអ្នកឱ្យខ្ចីប្រាក់ពីធនាគារឯកជនក៏ដោយ ក៏ធនាគារកណ្តាលនឹងធ្វើដូច្នោះដែរ។

### ១.៩- ភាពខុសគ្នានៃការវិភាគសេដ្ឋកិច្ច (Different modes of analysis of economy)

ទីផ្សាររូបិយវត្ថុ គឺក៏ជាទីផ្សារមួយក្នុងចំណោមទីផ្សារនៅក្នុងសេដ្ឋកិច្ចរូបិយវត្ថុមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធជាមួយការវិភាគលើទីផ្សារផ្សេងទៀតនៅក្នុងសេដ្ឋកិច្ច។ ការវិភាគជាឯកតោភាគីស្តីពី

រូបិយវត្ថុ និងទីផ្សារផ្សេងទៀតនៅក្នុងសេដ្ឋកិច្ច ត្រូវបានធ្វើឡើងតាមរយៈវិធីសាស្រ្តមួយក្នុងចំណោមវិធីសាស្រ្តទាំងពីរ៖ ការវិភាគតាមរយៈមីក្រូហិរញ្ញវត្ថុនៃទីផ្សារសម្រាប់ទំនិញនីមួយៗនៅក្នុងសេដ្ឋកិច្ច។ ខណៈពេលដែលវាអាចមានប្រភេទផ្សេងគ្នានៃគំរូម៉ូដែលបែបនេះ ភាគច្រើនត្រូវបានបង្កើតឡើងដែលអាចវិភាគបានតាមកម្រិតនៃសេដ្ឋកិច្ចដោយដាក់សម្មតិកម្មនៃទីផ្សារល្អឥតខ្ចោះ(ការប្រកួតប្រជែងល្អឥតខ្ចោះ និងការបោសសម្អាតទីផ្សារភ្លាមៗ)៖ ក្នុងករណីអវត្តមាននៃភាពមិនល្អឥតខ្ចោះនៃទីផ្សារ ដូចជាការប្រព្រឹត្តិកម្ម និងប្រតិបត្តិការថ្លៃដើម។ល។ ទៅលើការវិភាគទីផ្សារនីមួយៗ។ គំរូម៉ូដែលមីក្រូសេដ្ឋកិច្ចត្រូវបានបោះបង់សម្មតិកម្មមួយ ឬច្រើនសម្រាប់ទីផ្សារដែលបានជ្រើសរើស។ គំរូម៉ូដែលមីក្រូសេដ្ឋកិច្ចបានសន្មតថាការប្រកួតប្រជែងល្អឥតខ្ចោះត្រូវបានគេហៅថាគំរូម៉ូដែលវ៉ាល់រ៉ាសៀន(Walrasian models)។ ពួកគេមានការពិបាកវិភាគ លុះត្រាតែសម្មតិកម្មថាមានលំនឹងសមតា ពោលគឺតម្រូវការស្មើនឹងការផ្គត់ផ្គង់នៅក្នុងទីផ្សារទាំងអស់ត្រូវបានបង្ហាញឱ្យឃើញ។ គំរូម៉ូដែលវ៉ាល់រ៉ាសៀន (Walrasian models) បានផ្តល់គំរូម៉ូដែលមីក្រូសេដ្ឋកិច្ច ដែលគេទទួលស្គាល់ថាជាគំរូលំនឹងទូទៅរបស់ Walrasian's law។

## ១.១០- គំរូម៉ូដែលក្លាស៊ីក (The classical paradigm)

ក្រុមនៃគំរូម៉ូដែលរបស់ក្លាស៊ីក គឺស្របទៅនឹងក្របខ័ណ្ឌលំនឹងសមតាទូទៅរបស់គំរូម៉ូដែលរបស់ Walrasian ហើយបានសន្មតថាទីផ្សារបង្កើតប្រាក់ឈ្នួល និងថ្លៃឈ្នួលពលកម្ម សម្រាប់ទំនិញនីមួយៗនៅក្នុងកម្រិតនៃតម្រូវការ និងការផ្គត់ផ្គង់មានលក្ខណៈស្មើគ្នា (ជម្រះទីផ្សារ)។ មានទីផ្សារមួយ គឺជាទីផ្សារកម្លាំងពលកម្មដែលបានបោសសម្អាត វាបានបញ្ជាក់ថារាល់កម្មករដែលមានបំណងផ្គត់ផ្គង់កម្លាំងពលកម្មតាមរយៈប្រាក់ឈ្នួលដែលមានស្រាប់នឹងមានការងារធ្វើពេញលេញ ហើយប្រាក់ឈ្នួលនីមួយៗ នឹងអាចផ្តល់ការងារដល់កម្មករទាំងអស់ ដែលខ្លួនចង់បានតាមរយៈប្រាក់ឈ្នួលដែលមានឱ្យដល់ទីផ្សារ។[៨]

ស្ថានភាពនេះនៅក្នុងបរិបទនៃការវិភាគរយៈពេលវែងត្រូវបានគេស្គាល់ថាជា "ការងារពេញលេញ" ដូច្នេះ សញ្ញាណសម្គាល់នៃគំរូម៉ូដែលរបស់ក្លាស៊ីក គឺថានៅក្នុងលំនឹងសមតាសម្រាប់រយៈពេលវែង ពួកគេបានបង្ហាញពីនិកម្មភាពពេញលេញ។[៩] ទោះយ៉ាងណាក៏ដោយ យើងមើលឃើញពីការសង្កត់ធ្ងន់របស់ពួកក្លាស៊ីកលើការសម្អាតទីផ្សាការងារ ដែលមានផលប៉ះពាល់ដល់លំនឹងសមតានេះច្រើនតែត្រូវបានគេនិយាយដូចជាវា គឺជាការសន្មតដែលមិនត្រូវបានម៉ត់ចត់ទេ។

### ១.១០.១- ទស្សនៈរបស់សេដ្ឋវិទូក្លាស៊ីក (Traditional classical idea)

[៨] *In the short-run of the classical models, with errors in expectations, market clearance can imply a level of employment different from the full-employment (long-run equilibrium) level.*

[៩] *The difference between an assumption of full employment and one that is an implication of the equilibrium state is that the former rules out the studies of the properties of the system when it is in disequilibrium; the latter does not necessarily do so. In addition, the former can rule out a distinction between short-run and long-run equilibrium.*

"វិធីសាស្ត្របែបបុរាណ(ក្លាស៊ីក)" ត្រូវបានលើកឡើងក្នុងសៀវភៅនេះ សម្រាប់ទស្សនៈខុសៗគ្នាបន្តិចបន្តួចស្តីពីការប្រែប្រួលសេដ្ឋកិច្ចនាពាក់កណ្តាលសតវត្សរ៍ទី១៨ រហូតដល់ការចេញផ្សាយទ្រឹស្តីទូទៅរបស់លោក Keynes ក្នុងឆ្នាំ១៩៣៦។ ក្នុងវិសាលភាពគួរឱ្យកត់សម្គាល់ពីទស្សនៈទាំងនេះត្រូវបានសាយភាយផ្លាស់ប្តូរក្នុងចំណោមអ្នកនិពន្ធទៅតាមពេលវេលា។ ទោះក្នុងករណីណាក៏ដោយ ក៏ពុំមានកែបង្រួមអត្ថន័យទាំងស្រុងនោះទេ បើទោះបីជាមានការទទួលស្គាល់តាមទ្រឹស្តីរួមរបស់លោកចន មេណាដ កេសន៍ ក៏ដោយ។ ឥឡូវនេះ ពួកគេបានចាត់ទុកដូចជាមានគំរូម៉ូដែលកែបង្រួមគ្នាមួយ។ យើងអាចហៅសេចក្តីថ្លែងការណ៍រួមដ៏តូចចង្អៀតនៃទស្សនៈរបស់សេដ្ឋវិទូក្លាស៊ីក មិនត្រូវបានគេនិយាយថាជាគំរូម៉ូដែលបង្រួមរួម សូម្បីតែក្នុងអំឡុងពេលរុងរឿងរបស់គំរូម៉ូដែលនេះក្នុងអំឡុងសតវត្សរ៍ទី១៩ និងដើមសតវត្សរ៍ទី២០ ក៏ដោយ ប៉ុន្តែគំនិតរបស់វាត្រូវបានបញ្ចូលទៅក្នុងគំរូម៉ូដែលក្លាស៊ីកនិយមបែបថ្មី។

សមាសធាតុពីរនៃគំរូម៉ូដែលក្លាស៊ីកទាក់ទងដោយផ្ទាល់ទៅនឹងសេដ្ឋកិច្ចរូបិយវត្ថុគឺទ្រឹស្តីបរិមាណរូបិយវត្ថុសម្រាប់កម្រិតតម្លៃ និងទ្រឹស្តីមូលនិធិដែលអាចកម្ចីបានកម្រិតអត្រាការប្រាក់។ ទ្រឹស្តីលើការងារធ្វើ គឺជាការវិភាគលើទីផ្សារការងារ(ពលកម្ម) និងរួមបញ្ចូលសម្មតិកម្មថាមានលំនឹងសមតាទីផ្សារដែលបានបង្ហាញថាភាពមានការងារពេញលេញ ដូច្នេះទស្សនៈសេដ្ឋវិទូក្លាស៊ីក ពុំមានទ្រឹស្តីនៃអនិកម្មភាពឬបប្រែបម្រួលការងារលើបម្រែបម្រួលសរុបក្នុងកម្រិតដំណើរការសេដ្ឋកិច្ចសម្រាប់រយៈពេលវែងនោះទេ។ ដូច្នេះ វាពុំមានទ្រឹស្តីនៃគម្លាតនៃអនិកម្មភាព និងទិន្នផលសរុបពីកម្រិតការងារពេញលេញរបស់ពួកគេឡើយ។

ទោះយ៉ាងណា សមាសធាតុផ្សំមួយទៀតនៃគំនិតបុរាណបែបក្លាស៊ីក គឺពន្យល់អំពីវដ្តអាជីវកម្មរបស់វា ដែលអនុញ្ញាតឱ្យមានសកម្មភាពសេដ្ឋកិច្ចក្នុងការឆ្លើយតបរបស់សេដ្ឋកិច្ចទៅនឹងវិបត្តិសេដ្ឋកិច្ចជាក់ស្តែង ដូច្នេះការពន្យល់បែបនេះពិតជាបានបង្វែរទិសដៅពីកម្រិតការងារពេញលេញ។ វិធីសាស្ត្របែបបុរាណខ្វះការធ្វើសមាហរណកម្មលើទ្រឹស្តីមីក្រូសេដ្ឋកិច្ច និងលទ្ធផលការងារផ្អែកលើលទ្ធផលនៃការពន្យល់អំពីវដ្តអាជីវកម្មក៏ដូចជាការលាយបញ្ចូលគ្នារវាងទ្រឹស្តីបរិមាណ និងទ្រឹស្តីមូលនិធិដែលអាចខ្ចីប្រាក់បាន។ សរុបជារួម ខណៈពេលដែលវិធីសាស្ត្រនេះ មានសមាសធាតុជាច្រើននៃទ្រឹស្តីម៉ាក្រូសេដ្ឋកិច្ច វាខ្វះក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចរួមបញ្ចូលគ្នា។ វាក៏ខ្វះការព្យាបាលជាក់លាក់នៃតម្រូវការសរុបសម្រាប់ទំនិញដែលបច្ចុប្បន្នមាននៅក្នុងទំនាក់ទំនងខ្សែកោង IS ដែលជាមូលដ្ឋានគ្រឹះដ៏សំខាន់នៃម៉ាក្រូសេដ្ឋកិច្ចបច្ចុប្បន្ន។

## ១.១០.២- ទ្រឹស្តីតម្រូវការសរុបនៃសេដ្ឋកិច្ចក្លាស៊ីក (Theory Of Aggregate Demand In the Traditional Classical )

ពុំមានទ្រឹស្តីម៉ាក្រូសេដ្ឋកិច្ចជាក់លាក់តាមគំរូម៉ូដែលរបស់ពួកក្លាស៊ីកឡើយ វាមិនបានបញ្ចូលជាទ្រឹស្តីសម្រាប់ការកំណត់តម្រូវការសរុបសម្រាប់ទំនិញ(រូបិយវត្ថុ)ទេ។[១០] ផ្ទុយទៅវិញ វិធីសាស្ត្រនេះ

[១០] *The analysis of aggregate demand requires the concept of the multiplier, which was propose only in the 1930s.*

បានសិក្សាលើទីផ្សារលើទំនិញនីមួយៗ ដាច់ដោយឡែកពីគ្នានៅក្នុងលក្ខខណ្ឌមីក្រូសេដ្ឋកិច្ច ពោលគឺទាក់ទងនឹងការវិភាគលើតម្រូវការ និងការផ្គត់ផ្គង់។[១១] ជំនួសឱ្យទ្រឹស្តីនៃតម្រូវការសរុបសម្រាប់ទំនិញទាំងស្រុងវិធីសាស្រ្តបែបបុរាណតាមបែបជាក់លាក់ ប៉ុន្តែកាន់តែច្បាស់ជាងនេះទៅទៀតត្រូវបានដោះស្រាយតាមច្បាប់របស់ (Say's law) ដែលបានបញ្ជាក់ថា ការផ្គត់ផ្គង់សរុបបង្កើតបានទំនិញ (តែងតែបានចូលរួម) តាមតម្រូវការរបស់ខ្លួន ដូច្នេះទ្រឹស្តីដាច់ដោយឡែកនៃតម្រូវការសរុប មិនចាំបាច់ឬទាមទារជាក់លាក់នោះទេ។

Say's law មាននៅគ្រប់ទីកន្លែងនៅក្នុងការវិភាគ ដែលផ្តល់ដោយសេដ្ឋវិទូជាច្រើននៅសម័យកាលបុរាណ។ ក្នុងចំណោមច្បាប់ផ្សេងទៀតវាត្រូវបានចារទុកដោយលោក Adam Smith នៅសតវត្សរ៍ទី១៨ និងដើមសតវត្សរ៍ទី១៩ ដែលរួមមានលោក David Ricardo នៅពាក់កណ្តាលសតវត្សរ៍ទី១៩ និងលោក Alfred Marshall នៅចុងសតវត្សរ៍ទី១៩។ បើទោះយ៉ាងណា Say's law មិនមានសុពលភាពសម្រាប់សេដ្ឋកិច្ចរូបិយវត្ថុដែលមានទំនិញជា (រូបិយវត្ថុ និងកាស) និងមូលប័ត្របំណុលសម្រាប់ហេតុផលជាច្រើននៅក្នុងសេដ្ឋកិច្ចនោះទេ។

ក្នុងចំណោមទ្រឹស្តីទាំងនោះ គឺថានៅក្នុងសេដ្ឋកិច្ចរូបិយវត្ថុ អ្នកលក់ទំនិញទាំងអស់មិនមែនជាអ្នកទិញទំនិញដោយស្វ័យប្រវត្តិនោះទេ ព្រោះតែផ្នែកមួយនៃប្រាក់ចំណូលរបស់អ្នកលក់ ត្រូវបានរក្សាទុកដែលអាចត្រូវបានរាប់បញ្ចូលជារូបិយវត្ថុ ឬសញ្ញាប័ណ្ណ (រួមបញ្ចូលទាំងប្រាក់បញ្ញើសន្សំនៅក្នុងធនាគារ) ច្រើនជាងការប្តូរទៅជាការចំណាយលើទំនិញ(រូបិយវត្ថុ)។ កំណត់ចំណាំ៖ ទ្រឹស្តីទំនើបនៃតម្រូវការសរុប មិនត្រូវរាប់បញ្ចូលក្នុង Say's law នោះទេ ដូច្នេះវាមិនមែនជាផ្នែកមួយនៃម៉ាក្រូសេដ្ឋកិច្ចទំនើបទៀតឡើយ។

### ១.១០.៣- គំរូទ្រឹស្តីនៃអូក្លាស៊ីក ( Neoclassical model )

សម្រាប់ "គំរូម៉ូដែលរបស់នេអូក្លាស៊ីក" គឺជាឈ្មោះថ្មីដែលត្រូវបានផ្តល់ឱ្យប្រើឡើងវិញនៃគំនិតសេដ្ឋកិច្ចរបស់ក្លាស៊ីក (បុរាណ) ដែលបានផ្តល់គំរូម៉ូឌែលថ្មីឡើងវិញ និងបានរកឃើញក្នុងដំណាក់កាលចុងក្រោយនៃទ្រឹស្តីទូទៅក្នុងក្របខ័ណ្ឌបង្រួមរួមទ្រឹស្តីជាថ្មី។ ក្របខ័ណ្ឌគំរូម៉ូដែលរបស់នេអូក្លាស៊ីក គឺជាការវិភាគលើក្របខ័ណ្ឌសមីការខ្សែកោង (IS-LM)។ សម្រាប់ការសិក្សាស្រាវជ្រាវឡើងវិញ រួមមានការពន្លឿនការគិតគូរពីទ្រឹស្តីក្លាស៊ីក (បុរាណ) ដូចជាពាក្យថា "ទ្រព្យសម្បត្តិ/ពីហ្គូ" និងផលប៉ះពាល់ទៅលើតុល្យភាពពិតលើតម្រូវការទំនិញ ក៏ដូចជាការបន្ថែមជាតុថ្មីនៃតម្រូវការប្រថុយប្រថានចំពោះរូបិយវត្ថុ និងការវិភាគយ៉ាងជាក់លាក់នៃទីផ្សារទំនិញក្នុងកម្រិតម៉ាក្រូសេដ្ឋកិច្ច។

លើសពីនេះទៀត ជាតុខ្លះនៃគំនិតសេដ្ឋកិច្ចក្លាស៊ីក ដូចជាទ្រឹស្តីបរិមាណរូបិយវត្ថុ ជាទ្រឹស្តីមូលនិធិឱ្យខ្ចីប្រាក់ និងច្បាប់របស់សាយ (Say's law) និងភាពចែកដាច់ពីគ្នារវាងភាពជាក់ស្តែងនៃសេដ្ឋកិច្ច និងសេដ្ឋកិច្ចរូបិយវត្ថុ ត្រូវបានគេបោះបង់ចោលនៅក្នុងដំណើរការបង្វិលប្រាក់។ ជាលទ្ធផលនៃគំរូម៉ូដែលក៏ខុសគ្នាពីគំនិតបែបបុរាណតាមរយៈការធ្វើសមាហរណកម្មម៉ាក្រូសេដ្ឋកិច្ចដែរ។ គំរូម៉ូដែលបែប

---

[១១] *The analysis of aggregate demand requires the concept of the multiplier, which was proposed only in the 1930s.*

បុរាណ ជាទូទៅត្រូវបានបដិសេធចោលភាគច្រើននៃវិជ្ជាជីវៈសេដ្ឋកិច្ច ពីទសវត្សរ៍ឆ្នាំ១៩៤០ ដល់ឆ្នាំ១៩៧០ បើទោះបីជាវានៅតែបន្តកើតមាន ដូចជាការដាក់បញ្ចូលក្នុងការសិក្សាវិភាគនេះក៏ដោយ។

បើទោះយ៉ាងណា ការកែលម្អគំរូម៉ូដែលសេដ្ឋកិច្ចក្លាស៊ីកឡើងវិញ និងការបន្ថែមលើគំរូម៉ូដែលសេដ្ឋកិច្ចក្លាស៊ីកនៅតែបន្តធ្វើក្នុងទសវត្សរ៍ទាំងនេះ។ គំរូម៉ូដែលដ៏លេចធ្លោ នៅក្នុងទសវត្សរ៍ទាំងនេះ គឺជាគំរូម៉ូឌែលរបស់លោកកេនស៍។ គំរូបែបបុរាណ បើទោះបីជា គំរូម៉ូដែលថ្មីបានប្រើឡើងវិញនៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០ ក៏ដោយ ហើយចាប់តាំងពីពេលនោះមក បានយកទម្រង់គំរូម៉ូដែលផ្សេងៗគ្នា។ ទាំងនេះ គឺជាមនោគមវិជ្ជាសេដ្ឋកិច្ចនៅក្នុងឆ្នាំ១៩៧០ តាមគំរូបុរាណបែបទំនើប និងគំរូបុរាណបែបថ្មី។

### ១.១០.៤- វិធីសាស្ត្រនៃរូបិយវត្ថុនិយមនាទសវត្សរ៍ ១៩៧០ (Monetary methods of the 1970s)

វិធីសាស្ត្ររបស់រូបិយវត្ថុនិយម(monetarist) ត្រូវបានគេទទួលស្គាល់ថាលោក St Louis (1970) គឺជាអ្នករូបិយវត្ថុ ហើយឈ្មោះរូបិយវត្ថុនិយមនេះ ត្រូវបានគេផ្ដល់ឱ្យលើការវិភាគដ៏សំខាន់មួយលើការពង្រីកទ្រឹស្ដី និងបានផ្ដួចផ្ដើមគំនិតសេដ្ឋវិទូនៃធនាគារសហព័ន្ធសហរដ្ឋរបស់លោក St Louis នៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០។ សម្រាប់សេដ្ឋកិច្ចរយៈពេលខ្លី គំរូម៉ូដែលរបស់ពួកគេ មិនបានកំណត់ថានិកម្មភាពពេញលេញ(full employment) និងមិនបានបញ្ជាក់ពីភាពមានការងារពេញលេញនៅក្នុងសេដ្ឋកិច្ចនោះទេ។ គំរូម៉ូដែលរូបិយវត្ថុនិយម មានភាពស្រដៀងនឹងគំរូម៉ូដែលរបស់លោកកេនស៍ ដែលទាក់ទងទៅនឹងផលប៉ះពាល់គោលនយោបាយរូបិយវត្ថុលើទិន្នផលសរុប (output) និងនិកម្មភាព (employment) ប៉ុន្តែពួករូបិយវត្ថុនិយម បានបដិសេធចោលលើមូលដ្ឋានគ្រឹះរបស់លោកកេនស៍ ដែលមានជំនឿជឿជាក់លើគោលនយោបាយសារពើពន្ធ។ សម្រាប់សេដ្ឋកិច្ចរយៈពេលវែង វាជាគំរូម៉ូដែលរបស់ពួកក្លាស៊ីក។ ម្យ៉ាងវិញទៀត វាជាមនោគមវិជ្ជាសេដ្ឋកិច្ចនាឆ្នាំ១៩៧០ វាគឺជាកូនកាត់រវាងគំរូម៉ូដែលរបស់ពួកក្លាស៊ីក និងគំរូម៉ូដែលរបស់កេនស៍និយម បានធ្វើឱ្យមានការផ្លាស់ប្ដូរកាន់តែឆ្ងាយពីគំរូម៉ូដែលរបស់ កេនស៍និយមសម្រាប់សេដ្ឋវិទូជាច្រើន។

បើទោះយ៉ាងណា មិនមានទ្រឹស្ដីថ្មីជាមូលដ្ឋានណាមួយដែលមានអាយុកាលខ្លី ហើយត្រូវបានជំនួសនៅដើមទសវត្សរ៍ឆ្នាំ១៩៨០ ដោយគំនិតទាក់ទងទៅនឹងគំរូម៉ូដែលបែបបុរាណ ដែលនៅទីបំផុតបានយកទម្រង់នៃគំរូបុរាណបែបទំនើប។

## ១.១១- គោលនយោបាយរូបិយវត្ថុ (Monetary policy)

ការកំណត់បទដ្ឋានវិភាគលើរូបិយវត្ថុ គឺថាធនាគារកណ្ដាលអនុវត្តការគ្រប់គ្រងសេដ្ឋកិច្ច ដោយពិនិត្យលើការផ្គត់ផ្គង់រូបិយវត្ថុសរុប (aggregate supply)។ ក្នុងករណីនេះ ការវិភាគលើតម្រូវការរូបិយវត្ថុសរុប(aggregate demand) ត្រូវបានគេហៅថាខ្សែកោង៖ IS–LM។ ការវិភាគលើទីផ្សាររូបិយវត្ថុ បង្កើតបានសមីការខ្សែកោង IS ។ ទោះយ៉ាងណាក៏ដោយ ប្រភេទនៃសេដ្ឋកិច្ចខ្លះ ការគ្រប់គ្រងអត្រាការប្រាក់ អាចជាមធ្យោបាយមួយក្នុងការគ្រប់គ្រងតម្រូវការរូបិយវត្ថុសរុបច្រើនជាងការផ្គត់

ផ្គត់ផ្គង់រូបិយវត្ថុសរុប។ ធនាគារកណ្តាលនៃប្រទេសអភិវឌ្ឍន៍មួយចំនួនរួមទាំងសហរដ្ឋអាម៉េរិក កាណាដា និងអង់គ្លេស បច្ចុប្បន្ននេះ ហាក់ដូចជាពឹងផ្អែកកាន់តែខ្លាំងលើអត្រាការប្រាក់ជាជាងការផ្គត់ផ្គង់លុយសរុប ដែលជាឧបករណ៍នៃគោលនយោបាយរូបិយវត្ថុជាចម្បង។[១២]

សម្រាប់សេដ្ឋកិច្ចប្រទេសរបស់ពួកគេ ការវិភាគលើខ្សែកោង LM ពុំសូវសមស្របនោះទេ។ ផ្ទុយទៅវិញ ការវិភាគលើខ្សែកោង IRT(interest rate target) ដែលបន្ថែមលើខ្សែកោង IS កំណត់តម្រូវការលុយសរុបនៅក្នុងគំរូវិភាគ។ ការវិភាគលើខ្សែកោង IS–LM និង IS–IRT ត្រូវបានបង្ហាញលម្អិតក្នុងជំពូកទី១៣ នៃសៀវភៅចំណងជើង "សេដ្ឋកិច្ចរូបិយវត្ថុ" ។ ប្រសិនបើធនាគារកណ្តាលកំណត់អត្រាការប្រាក់ជាឧបករណ៍នៃគោលនយោបាយរូបិយវត្ថុហួសហេតុពេក ដែលមានគោលបំណងផ្គត់ផ្គង់បរិមាណរូបិយវត្ថុសរុប ទៅតាមអត្រាការប្រាក់នោះដែរ។ ធនាគារកណ្តាល អាចធ្វើឱ្យមានការផ្លាស់ប្តូរសមស្របទៅតាមមូលដ្ឋាននៃរូបិយវត្ថុ ដោយការស្ម័គ្រចិត្ត ឬអនុញ្ញាតឱ្យធនាគារពាណិជ្ជកម្ម អាចខ្ចីលុយពីធនាគារកណ្តាលបាន។ ក្នុងករណីនេះ ការផ្គត់ផ្គង់រូបិយវត្ថុបានក្លាយទៅជារឿងមិនល្អសម្រាប់សេដ្ឋកិច្ច។

## ១.១២- ទ្រឹស្តីគោលនយោបាយរូបិយវត្ថុ និង គោលនយោបាយសារពើពន្ធ

(Definitions of monetary and fiscal policies)

សារសំខាន់នៃគោលនយោបាយពាក់ព័ន្ធនឹងសេដ្ឋកិច្ចរូបិយវត្ថុ ដោយសារតែផលប៉ះពាល់នៃគោលនយោបាយរូបិយវត្ថុមកលើសេដ្ឋកិច្ច។ គោលនយោបាយរូបិយវត្ថុ ត្រូវបានគេចាត់ទុកថា ជាការផ្លាស់ប្តូរគោលនយោបាយនៃការផ្គត់ផ្គង់រូបិយវត្ថុ ឬ/និងអត្រាការប្រាក់ (interest rate)។ ការគ្រប់គ្រងគោលនយោបាយរូបិយវត្ថុ ត្រូវធ្វើឡើងដោយធនាគារកណ្តាល ឬអាជ្ញាធររូបិយវត្ថុ ដែលពាក្យទាំង២នេះមានន័យខ្លឹមសារដូចគ្នា។

តាមគំរូម៉ូដែលរបស់លោក Walrasian និងគំរូម៉ូដែលក្លាស៊ីកបែបទំនើប បានគូសបញ្ជាក់ថា លំនឹងសមតាសេដ្ឋកិច្ចរូបិយវត្ថុ ទោះបីក្នុងរយៈពេលខ្លីក៏ដោយ ក៏មិនមានផលវិជ្ជមានអ្វីទាក់ទងនឹងលទ្ធផលខ្ពស់ ឬទាបនៃភាពអត់ការងារធ្វើ ដោយប្រតិបត្តិការជាប្រព័ន្ធ ឬការរំពឹងទុករបស់ពួកគេ។ តាមលោក (Friedman, ១៩៧៧ Lucas, ១៩៩៦) បានគូសបញ្ជាក់ថាបើទោះបីជាមានផលប៉ះពាល់ បណ្តោះអាសន្នក្នុងរយៈពេលខ្លីនៃគោលការណ៍ចៃដន្យក៏ដោយ។ ចំពោះគំរូម៉ូដែលរបស់លោក កេនស៍បានគូសបង្ហាញថា មានអត្ថប្រយោជន៍បែបនេះ សម្រាប់សេដ្ឋកិច្ចរយៈពេលខ្លី។

គោលនយោបាយសារពើពន្ធ គឺជាការចំណាយ និងការកម្រិតពន្ធរបស់រដ្ឋាភិបាល នៅពេលមានឱនភាពថវិកា ឬអតិរេកថវិកា។ ការអនុវត្តគោលនយោបាយនេះ គឺដើម្បីផ្លាស់ប្តូរកម្រិតសេដ្ឋកិច្ច។ ខណៈពេលដែលឱនភាពថវិការបស់រដ្ឋាភិបាល អាចត្រូវបានផ្គត់ផ្គង់តាមរយៈការកើនឡើងនៃការផ្គត់ផ្គង់លុយ (បន្ទុកត្រូវបានអមដោយការថយចុះនៅក្នុងនោះដែរ) មុខងារម៉ាក្រូសេដ្ឋកិច្ច គឺជាគោលនយោបាយសារពើពន្ធមួយ ដែលការផ្គត់ផ្គង់លុយត្រូវតែរក្សាឱ្យមានស្ថិរភាពជាប្រចាំ។ ដូច្នេះ ការផ្តល់

[១២] This is also so for the European Central Bank, which claims to treat the interest rate as its primary monetary policy instrument but also monitors monetary aggregates.

ប្រាក់កម្ចី ត្រូវតែផ្ដល់ដោយហិរញ្ញប្បទានរបស់រដ្ឋាភិបាលតាមរយៈការកើនឡើង នៅក្នុងមូលប័ត្របំណុលរបស់ខ្លួនបានដាក់លក់ជាសាធារណៈ។

ដូចគ្នានេះដែរ អតិរេកសារពើពន្ធ ត្រូវបានវាស់វែងដោយបានសន្មតថា តម្រូវឱ្យទិញសញ្ញាប័ណ្ណ (មូលបត្របំណុល)ពីធនាគារកណ្ដាល និងប្រាក់សោធននិវត្តរបស់ពួកគេ ដោយមិនផ្លាស់ប្ដូរការផ្គត់ផ្គង់លុយនៅក្នុងចរន្តសេដ្ឋកិច្ច។ ហេតុផលនេះ សម្រាប់គោលនយោបាយសារពើពន្ធ គឺដើម្បីបែងចែកផលប៉ះពាល់នៃការផ្លាស់ប្ដូរអថេរសារពើពន្ធពីការផ្គត់ផ្គង់លុយរបស់ពួកគេ។ ដូចនេះ គោលនយោបាយសារពើពន្ធ គឺជាការអនុវត្តន៍នូវគោលនយោបាយថវិកា។

ជាតុពិតនៃគោលនយោបាយសារពើពន្ធ និងគោលនយោបាយរូបិយវត្ថុ គឺមានទំនាក់ទំនងគ្នាទៅវិញទៅមក។ ដូច្នេះ មានប្រទេសខ្លះ និយមប្រើនូវគោលនយោបាយទាំងនេះផ្សេងៗគ្នា។ ទោះយ៉ាងណាក៏ដោយ គោលបំណងនៃគោលនយោបាយរបស់ពួកគេត្រូវបានចាត់ទុកថាជាគំនិតឯករាជ្យ។ ដូច្នេះ គោលនយោបាយសារពើពន្ធពង្រីក ត្រូវបានផ្ដល់ដោយការបង្កើនការផ្គត់ផ្គង់លុយ ត្រូវបានចាត់ទុកជាសមាសធាតុពីរយ៉ាង គឺគោលនយោបាយសារពើពន្ធពង្រីក និងគោលនយោបាយរូបិយវត្ថុពង្រីក។

គោលនយោបាយសារពើពន្ធគឺជាការប្រើប្រាស់ចំណាយ និងការយកពន្ធរបស់រដ្ឋាភិបាល ដែលជះឥទ្ធិពលមកលើសេដ្ឋកិច្ច។ នៅពេលរដ្ឋាភិបាលធ្វើការសម្រេចលើការទិញទំនិញ និងសេវារបស់ខ្លួនការបង្វែរការទូទាត់ដែលរដ្ឋបែងចែក ឬពន្ធដែលរដ្ឋត្រូវប្រមូលគឺជាប់ពាក់ព័ន្ធនឹងគោលនយោបាយសារពើពន្ធ។ ផលប៉ះពាល់បឋមផ្នែកសេដ្ឋកិច្ចពីបម្រែបម្រួលថវិការបស់រដ្ឋាភិបាល ដែលមានមកលើក្រុមជាក់លាក់មួយចំនួន ពោលគឺការកាត់បន្ថយពន្ធសម្រាប់គ្រួសារដែលមានកូន។ ១. បង្កើនប្រាក់ចំណូលជាក់ស្ដែងរបស់ពួកគេ។ ទោះបីយ៉ាងណា ការពិភាក្សាអំពីគោលនយោបាយសារពើពន្ធ ជាទូទៅផ្ដោតលើផលប៉ះពាល់នៃបម្រែបម្រួលថវិការបស់រដ្ឋាភិបាលមកលើសេដ្ឋកិច្ចទាំងមូល។ ទោះបីជាការប្រែប្រួលខាងពន្ធដារ ឬការចំណាយ ដែល "រក្សានៅកម្រិតប្រាក់ចំណូលអព្យាក្រឹត្យ" អាចត្រូវបានបកស្រាយថាជាគោលនយោបាយសារពើពន្ធ ហើយអាចប៉ះពាល់ដល់កម្រិតទិន្នផលសរុបដោយការកែសម្រួលការលើកទឹកចិត្តដែលប្រឈមដោយក្រុមហ៊ុនសហគ្រាស ឬរូបវន្តបុគ្គលក៏ដោយ ប៉ុន្តែពាក្យថា "គោលនយោបាយសារពើពន្ធ" ជាធម្មតាត្រូវបានប្រើ ដើម្បីពិពណ៌នាអំពីឥទ្ធិពលមកលើកម្រិតទូទៅនៃការចំណាយ និងពន្ធដាររបស់សេដ្ឋកិច្ចទាំងមូល និងជាពិសេសគម្លាតរវាងការចំណាយ និងពន្ធដារ។

# ជំពូកទី ២

# សារសំខាន់នៃធនាគារកណ្តាល

# ESSENCE OF THE CENTRAL BANKING

## ២.១- ប្រវត្តិសង្ខេបនៃធនាគារកណ្តាល ( Briefly history of central bank )

ប្រវត្តិធនាគារកណ្តាល ត្រូវបានបង្កើតឡើងនៅប្រទេសស៊ុយអែតនាឆ្នាំ១៦៦៨ និងបន្ទាប់មកទៀត នៅចក្រភពអង់គ្លេស ត្រូវបានបង្កើតធនាគារកណ្តាលអង់គ្លេសនៅក្នុងសតវត្សរ៍ទី១៧។ នាដើមសតវត្សរ៍ទី២០ ធនាគារកណ្តាលនៅតាមបណ្តាប្រទេសនានាត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ ក្រោយពីបណ្តាប្រទេសស្ថិតក្រោមអាណានិគមបានទទួលឯករាជ្យភាព។ ធនាគារកណ្តាល មានឈ្មោះផ្សេងៗគ្នា ដូចជាធនាគារបម្រុង ( Reserve bank ) អាជ្ញាធររូបិយវត្ថុ ( Monetary authority ) ឬធនាគារជាតិ ( National bank )ជាដើម។

ឧទាហរណ៍ នៅប្រទេសកម្ពុជាធនាគារកណ្តាលមានឈ្មោះថាធនាគារជាតិនៃកម្ពុជា គឺជាធនាគារកណ្តាល និងជាអាជ្ញាធរអាណាព្យាបាលនៃប្រព័ន្ធធនាគារ។ សម្រាប់ដើមទុនធនាគារកណ្តាល ត្រូវបានចុះបញ្ជី និងកាន់កាប់ផ្តាច់មុខដោយរដ្ឋាភិបាល និងមិនអាចផ្ទេរ ឬដាក់ឱ្យជាប់លក្ខខណ្ឌអ្វីឡើយ។ នៅប្រទេសកម្ពុជាធនាគារកណ្តាល មានឋានៈជាអ្នកទទួលសិទ្ធិជាអចិន្ត្រៃយ៍ពីរដ្ឋាភិបាល និងស្វ័យភាពក្នុងការគ្រប់គ្រងធ្វើរបាយការណ៍ស្តីពីការអនុវត្តន៍ភារកិច្ចរបស់ខ្លួន និងលទ្ធផលដែលសម្រេចបានជូនរដ្ឋសភា និងរាជរដ្ឋាភិបាល។

តាមបណ្តាប្រទេសភាគច្រើន ធនាគារកណ្តាលគឺជាផ្នែកមួយរបស់រដ្ឋាភិបាល ពោលគឺជាសេនាធិការរបស់រដ្ឋាភិបាលដែលមានស្វ័យភាព និងឯករាជ្យមានកម្រិតនៅក្នុងការរៀបចំ និងអនុវត្តនូវគោលនយោបាយរូបិយវត្ថុ។

ឧទាហរណ៍ នៅសហរដ្ឋអាម៉េរិកមានធនាគារកណ្តាលមានចំនួន១២ នៅតាមតំបន់ផ្សេងៗគ្នា។ ធនាគារគណ្តាលទាំងនេះ បើទោះបីពុំមែនជាផ្នែកមួយរបស់រដ្ឋាភិបាលក្តី និងត្រូវបានកាន់កាប់ជាលក្ខណៈឯកជនដោយធនាគារជាសមាជិក (Member banks)ក៏ដោយ។ ប៉ុន្តែក្រុមប្រឹក្សាភិបាល ត្រូវបានជ្រើសតាំងដោយប្រធានាធិបតីសហរដ្ឋអាម៉េរិក។ ធនាគារកណ្តាលនេះ មានសេរីភាពច្រើននៅក្នុងការបំពេញតួនាទីរបស់ខ្លួន ពីព្រោះឥតពឹងផ្អែកលើថវិការបស់រដ្ឋាភិបាលឡើយ។ ដូចនេះ មូលនិធិ

របស់ធនាគារកណ្តាលបានមកពីកម្រៃសេវាកម្មនានា និងការជួញដូរមូលប័ត្រ។ ធនាគារកណ្តាលរបស់សហរដ្ឋអាម៉េរិក ( Fed) មានសកម្មភាពក្នុងនាមជាទីភ្នាក់ងាររបស់រដ្ឋាភិបាល។

សរុបសេចក្តី ធនាគារកណ្តាលមានលក្ខណៈជាធនាគារិកនៃធនាគារ (Banker's bank) និងជាទីប្រឹក្សារបស់រដ្ឋាភិបាលក្នុងវិស័យហិរញ្ញវត្ថុ និងជាអ្នកត្រួតពិនិត្យលើប្រព័ន្ធហិរញ្ញវត្ថុ និងធនាគារ។

## ២.២- រចនាសម្ព័ន្ធធនាគារសហព័ន្ធ (Fed)[១៣]

ប្រព័ន្ធធនាគារសហរដ្ឋអាម៉េរិក៖ ជាបណ្តាញនៃធនាគារសហព័ន្ធ (Fed) ដែលទំនាក់ទំនងរបស់វាជាមួយនឹងសាធារណជន។

គំនូសតាងទី១ បង្ហាញពី៖ រចនាសម្ព័ន្ធធនាគារសហព័ន្ធសហរដ្ឋ (Federal bank structure)




១-ក្រុមប្រឹក្សាទេសាភិបាល៖ ក្រុមប្រឹក្សាភិបាលរបស់ធនាគារសហព័ន្ធមានសមាជិក៧រូប ដែលតែងតាំងដោយសភាជាតិមានអាណត្តិ ១៤ឆ្នាំ (គ្រប់សមាជិកទាំងអស់ត្រូវគេកំណត់ហើយជំនួសជាបន្តបន្ទាប់ជារៀងរាល់ឆ្នាំ)។

២-គណៈកម្មាធិការទីផ្សារបើកចំហរបស់សហព័ន្ធ៖ ត្រូវគេរៀបចំឱ្យបម្រើសាធារណៈសម្រាប់ការលក់ និងទិញសញ្ញាប័ណ្ណ ឬមូលប័ត្រ។ មាន៥រូបមកពីក្រុមប្រឹក្សាភិបាល និង៥រូបមកពីធនាគារសហព័ន្ធ។

៣-ក្រុមប្រឹក្សាយោបល់របស់សហព័ន្ធ៖ មានសមាជិក១២រូប និងមានអាណត្តិដូចគ្នា និងក្រុមប្រឹក្សាភិបាលទទួលខុសត្រូវប្រឹក្សាយោបល់ ឬដាក់ចេញគោលនយោបាយធនាគារ។

---

១៣ *Source: The Federal bank of America*

៤-ធនាគារសហព័ន្ធ៖ ប្រទេសជាច្រើនមានធនាគារកណ្ដាលតែមួយគត់ ដូចជាធនាគារប្រទេសថៃ ឬកម្ពុជា ប៉ុន្តែសហរដ្ឋអាម៉េរិកមានធនាគារសហព័ន្ធ១២។

៤.១- ធនាគារកណ្ដាល៖ ជាអ្នកបង្កើតគោលនយោបាយរូបិយវត្ថុ គឺជាអ្នកដឹកនាំធនាគារឱ្យមានប្រសិទ្ធភាពសេដ្ឋកិច្ចដែលធានាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងរូបិយវត្ថុ (បោះផ្សាយរូបិយវត្ថុ ឬផ្ដល់កម្ចីនៅគ្រាបន្ទាល់) ជាពិសេសតាមដានគ្រប់គ្រងអតិផរណា។ សម្រាប់ប្រព័ន្ធ Quasi-Public Bank៖ ធនាគារសហព័ន្ធ១២ ស្ដែងចេញជា (មានចរិកលក្ខណៈ)ជាធនាគារ (Quasi-bank)។ ដោយសារតែធនាគារទាំងនោះស្ថិតក្រោមការត្រួតត្រារបស់រដ្ឋ និងឯកជន (មានម្ចាស់ជារដ្ឋ និងឯកជន)។ ចុងក្រោយធនាគារសហព័ន្ធគឺជាវិធានការរបស់ធនាគារិកឯកជន ដែលមានន័យថាវាគឺជាធនាគារិករបស់គ្រឹះស្ថានហិរញ្ញវត្ថុ ជាពិសេសធនាគារពាណិជ្ជ ដែលពួកគេទទួលខុសត្រូវកាន់កាប់ប្រាក់បញ្ញើ ជាគ្រឹះស្ថានទទួលប្រាក់បញ្ញើ ហើយផ្ដល់ឥណទានដល់សាធារណៈជន។

៤.២- រចនាសម្ព័ន្ធរបស់ធនាគារកណ្ដាល៖ ប្រទេសកម្ពុជាដើរតាមប្រព័ន្ធធនាគារ គឺធនាគារជាតិ ឬជាធនាគារកណ្ដាល (Franco phone) ដែលមានសិទ្ធិពេញលេញដើម្បីត្រួតពិនិត្យធនាគារពាណិជ្ជ និងគ្រឹះស្ថានហិរញ្ញវត្ថុដទៃទៀត។ ធនាគារកណ្ដាលកម្ពុជាមានបេសកម្មចម្បង គឺកំណត់ និងដឹកនាំគោលនយោបាយរូបិយវត្ថុក្នុងក្របខ័ណ្ឌនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជាក្នុងគោលដៅរក្សាថ្លៃឱ្យមានស្ថិរភាពសំដៅបង្កលក្ខណៈងាយស្រួល ដើម្បីធ្វើសេដ្ឋកិច្ចមានការរីកចម្រើន។ ការកំណត់គោលដៅគោលនយោបាយរូបិយវត្ថុ ដោយបានពិគ្រោះយោបល់ជាមួយរាជរដ្ឋាភិបាលក្នុងក្របខ័ណ្ឌនយោបាយេសដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងអនុវត្ត និងត្រួតពិនិត្យ នយោបាយរូបិយវត្ថុ និងប្តូរប្រាក់ឱ្យសម្រេចទៅតាមគោលដៅដែលបានកំណត់។ សរុបជារួមវិភាគស្ថានភាពសេដ្ឋកិច្ច និងរូបិយវត្ថុជាប្រក្រតីរួចចេញផ្សាយលទ្ធផល ព្រមទាំងលើកសំណើរ និងវិធានការជូនរដ្ឋាភិបាល។

- ប្រធានទេសាភិបាល៖ ធនាគារជាតិនៃព្រះរាជាណាចក្រកម្ពុជា ឬគោលនយោបាយធនាគារកណ្ដាលត្រូវបានដាក់ចេញ ឬត្រូវបានបង្កើតឡើងវិញដោយប្រធានទេសាភិបាល។ ក្នុងប្រធានក្រុមទេសាភិបាលមានសមាជិក១១ ទៅ ១៣រូប យោងតាមគោលនយោបាយរបស់ប្រទេស។ ពួកគេមកពីគ្រឹះស្ថានរដ្ឋ និងឯកជន។
- ប្រធានទេសាភិបាល និងទេសាភិបាលរង៖ ប្រទេសជាច្រើន ប្រធានទេសាភិបាល និងទេសាភិបាលរងត្រូវតែងតាំងឡើងដោយរដ្ឋាភិបាល និងមានអាណត្តិ៧ឆ្នាំ ឬតាមអាណត្តិរបស់រដ្ឋាភិបាល។ រាល់សមាជិកទាំងអស់ គេមិនអនុញ្ញាតមានភាគហ៊ុនគ្រឹះស្ថានហិរញ្ញវត្ថុទេ។

## ២.៣- ប្រវត្តិសង្ខេបធនាគារជាតិនៃកម្ពុជា (Briefly history of NBC)

### ២.៣.១- ប្រវត្តិសង្ខេបពីឆ្នាំ ១៩៥៤ ដល់ ១៩៧៥

ក្រុមប្រឹក្សាភិបាលប្រព័ន្ធធនាគារប្រទេសកម្ពុជាមានការវិវត្តន៍ ៥ ដំណាក់កាលចម្បងៗ។ ក្រោយពីចុងឆ្នាំ១៩៥៤ បន្ទាប់ពីទទួលបានឯករាជ្យ ប្រព័ន្ធធនាគារយើងទទួលស្វ័យភាពមុនប្រព័ន្ធឥណ្ឌូចិន ដែលអាចចង្កើតក្រដាសប្រាក់រៀលបាន ប៉ុន្តែស្ថិតក្រោមចំណុះរបស់រាជរដ្ឋាភិបាលដោយទាក់ទងនឹងក្រសួងហិរញ្ញវត្ថុ។ លុះដល់ឆ្នាំ១៩៥៥ ទើបមានស្វ័យភាពពីរាជរដ្ឋាភិបាល។ ចាប់ពីឆ្នាំ១៩៥៤ ដល់ឆ្នាំ១៩៦៣ ប្រព័ន្ធធនាគារនៃកម្ពុជាមានពីរថ្នាក់គឺ ធនាគារកណ្តាល និងធនាគារពាណិជ្ជកម្ម។ នៅចុងឆ្នាំ១៩៦៣ ប្រទេសកម្ពុជាកាន់របបប្រទេសពាក់កណ្តាលសង្គមនិយម និងពាក់កណ្តាលសេរី ដែលតម្រូវឱ្យធនាគារពាណិជ្ជជាធនាគាររបស់រដ្ឋ ហើយត្រូវបានធ្វើជាតូបនីយកម្មដោយព្រះករុណាព្រះបាទនរោត្តមសីហនុ នៅចុងឆ្នាំដដែលនោះដែរ។

ប្រព័ន្ធធនាគារខ្មែរកាលនោះរួមមាន៖

- ធនាគារជាតិនៃកម្ពុជា
- គ្រឹះស្ថានឥណទានបីស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីររាជសហករណ៍ ត្រូវបានបង្កើតឡើងតាំងពីឆ្នាំ១៩៥៦ គឺមានសហករណ៍ផលិតកម្ម សហករណ៍ឧបភោគ ឬបរិភោគ សហករណ៍ឥណទាន។ ធនាគារពាណិជ្ជមានចំនួនប្រាំបី ដែលក្នុងនោះបួនជាធនាគារក្នុងស្រុក និងបួនទៀតជាបរទេស។

១- ធនាគារក្នុងស្រុកមាន៖

- ធនាគារកម្ពុជាពាណិជ្ជ
- ធនាគារភ្នំពេញ
- ធនាគារសុវណ្ណភូមិ
- ធនាគារខ្មែរ

២- ធនាគារបរទេសមាន ៖

- ធនាគារជាតិសម្រាប់ពាណិជ្ជកម្ម និងឧស្សាហកម្ម (BNCI) ក្រោយមកប្តូរឈ្មោះជា (Banque Nationale de Paris) របស់បារាំង។
- ធនាគារឥណ្ឌូចិន
- ធនាគារធាទើរ៉ែត
- ធនាគារហុងកុង និងសៀងហៃ

ដោយសារតែមានវិបត្តិធ្ងន់ធ្ងរក្នុងវិស័យធនាគារនៅខែវិច្ឆិកាឆ្នាំ១៩៦៣ ធនាគារឯកជនក្នុងស្រុក និងបរទេសទាំង៨ ត្រូវបានបិទទ្វារ និងបានធ្វើជាតូបនីយកម្ម ដើម្បីបង្កើតឡើងវិញជាធនាគារដែលរដ្ឋកាន់កាប់មានជាអាទិ៍ ធនាគារខ្មែរសម្រាប់ពាណិជ្ជកម្ម ធនាគារឥណទានជាតិ ធនាគារអភិវឌ្ឍន៍ និងធនាគារកសិកម្មជនបទ។ ធនាគារជាតិនៃកម្ពុជាមានការប្រែប្រួលជាសំខាន់ ក្នុងអំឡុងឆ្នាំ១៩៦៤ ដោយបានប្រែក្លាយពីទម្រង់ជាស្ថាប័នពាក់កណ្តាលស្វយ័ត ទៅជាធនាគាររដ្ឋក្រោមទ្រង់ទ្រាយជាស្ថាប័នសាធារណៈ ដែលមានលក្ខណៈឧស្សាហកម្ម និងពាណិជ្ជកម្ម។ ក្នុងចំណោមគ្រឹះស្ថានឥណទានទាំង៣ សហករណ៍ឥណទាន បានធ្វើសកម្មភាពឥណទានយ៉ាងទូលំទូលាយទូទាំងប្រទេសនៅក្រៅប្រព័ន្ធ

ធនាគារ ដើម្បីគាំទ្រដល់ប្រជារាស្ត្រក្រីក្រ។ សកម្មភាពឥណទានទាំងនេះ ជាសារសំខាន់ធ្វើឡើងមុនការបង្កើតធនាគារកសិកម្មជនបទនាឆ្នាំ១៩៧០។ ចាប់ពីឆ្នាំ១៩៧០មក ប្រព័ន្ធធនាគារបានធ្វើសេរីភាវូបនីយកម្មជាថ្មី ដើម្បីបង្កលក្ខណៈឱ្យធនាគារឯកជនធ្វើសកម្មភាព ទន្ទឹមនឹងធនាគាររដ្ឋក្រោមការណែនាំ និងត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា។ អំឡុងពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ បន្ទាប់ពីថ្ងៃលន់នល់ ធ្វើរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ប្រព័ន្ធធនាគារបានបែកចេញជា ២ថ្នាក់វិញ គឺធនាគារកណ្ដាល ឬធនាគារជាតិ និងធនាគារពាណិជ្ជ ប៉ុន្តែក្នុងអំឡុងពេលនោះ ធនាគារពាណិជ្ជក៏នៅតែមានពាក់ព័ន្ធនឹងក្រសួងហិរញ្ញវត្ថុដែរ។ ចន្លោះពីឆ្នាំ១៩៧៩ រហូតដល់បច្ចុប្បន្ននេះ ប្រព័ន្ធធនាគាររបស់កម្ពុជាបែងចែកជាពីរមានដូចជា៖

ក- ប្រព័ន្ធធនាគារ ១ថ្នាក់៖

ផ្ដើមចេញពីចំណុចសូន្យ និងដោយបាតដៃទទេ ធនាគារជាតិនៃកម្ពុជាត្រូវបានបង្កើតឡើងវិញនៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៩ និងមានឈ្មោះថា ធនាគារជាតិនៃប្រជាជនកម្ពុជា។ ថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៨០ (៦ខែក្រោយបង្កើតធនាគារជាតិនៃប្រជាជនកម្ពុជា) ប្រាក់រៀលថ្មីត្រូវបានបោះផ្សាយឱ្យធ្វើចរាចរណ៍។ ប្រព័ន្ធធនាគារកម្ពុជាក៏ចាប់កំណើតឡើងពីនោះមក តាមរយៈការរៀបចំរចនាសម្ព័ន្ធក្បាលម៉ាស៊ីនដឹកនាំ និងសកម្មភាពប្រតិបត្តិការនៅទីស្នាក់ការកណ្ដាល និងការពង្រីកបណ្ដាញនៅតាមខេត្ត ឬក្រុងទូទាំងប្រទេស។ ក្នុងអំឡុងពេលនោះ ប្រព័ន្ធធនាគារកម្ពុជាមានលក្ខណៈជាប្រព័ន្ធធនាគារតែ ១ថ្នាក់ (mono bank system ) ដើរតួនាទីជាធនាគារកណ្ដាលផង ជាធនាគារពាណិជ្ជផង រតនាគារជាតិផង តាមរយៈប្រតិបត្តិការរបស់ខ្លួន។ ចាប់ពីឆ្នាំ១៩៨៩មក ប្រព័ន្ធធនាគារត្រូវបានកែទម្រង់ជាបន្តបន្ទាប់ពោល គឺផ្ទេរពីធនាគារខេត្ត ឬក្រុងទៅជាធនាគារឯកទេសខេត្ត ឬក្រុង ដែលធ្វើសកម្មភាពតាមរបបស្វ័យភិបាលសេដ្ឋកិច្ច និងស្វ័យភាពហិរញ្ញវត្ថុលើតំបន់ដែនដីរបស់ខ្លួន។ ធនាគារជាតិនៃកម្ពុជាបំពេញតួនាទីណែនាំត្រួតពិនិត្យធនាគារឯកទេសទាំងនោះ។

មុខងារជាបេឡានៃថវិការដ្ឋ ក៏បានផ្ទេរឱ្យក្រសួងហិរញ្ញវត្ថុវិញ តាំងពីចុងឆ្នាំ១៩៩១។ ធនាគារជាតិនៃកម្ពុជាទទួលយកឈ្មោះចាស់ជាផ្លូវការជា "ធនាគារជាតិនៃកម្ពុជា" វិញតាមច្បាប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩២ ស្ដីពីការប្ដូរឈ្មោះអង្គការចាត់តាំងភារកិច្ចរបស់ធនាគារនៃប្រជាជនកម្ពុជា និងបានរុះរើទីតាំងមកនៅកន្លែងចាស់វិញ បន្ទាប់ពីសាងសង់អាគារថ្មី នឹងមានលំនាំដូចអាគារដើមរបស់ខ្លួន។ ការវិនិយោគបរទេសលើវិស័យធនាគារបានចាប់ផ្ដើមឆ្នាំ១៩៩១ អាស្រ័យដោយការផ្លាស់ប្ដូររបបសេដ្ឋកិច្ចប្រមូលផ្ដុំមកជារបបសេដ្ឋកិច្ចទីផ្សារសេរីវិញ។

ខ-ប្រព័ន្ធធនាគារ ២ថ្នាក់៖

លទ្ធផលនៃការបោះឆ្នោតជាសាកលនៅឆ្នាំ១៩៩៣ បាននាំមកនូវបរិយាកាសថ្មីដល់ប្រជាជាតិកម្ពុជាទាំងមូល ក៏ដូចជាប្រព័ន្ធធនាគារផងដែរ។ ប្រព័ន្ធធនាគារនៅកម្ពុជាមានការប្រែប្រួលជាថ្មី ពោលគឺបើកទូលាយអាជីវកម្មលើវិស័យធនាគារ ដោយបង្កើតធនាគារពាណិជ្ជក្រោមច្បាប់ក្នុងស្រុកផង ឬក្រោមទ្រង់ទ្រាយជាសាខារបស់ធនាគារបរទេសផង។ ប្រការនេះតម្រូវឱ្យធនាគារជាតិនៃកម្ពុជាពង្រឹង

តួនាទីជាធនាគារកណ្តាល បង្កើនសមត្ថភាព បទបញ្ជាណែនាំ និងត្រួតពិនិត្យធនាគារពាណិជ្ជទាំងអស់។

គ្រឹះស្ថានហិរញ្ញវត្ថុទាំងនោះ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និងត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា និងស្ថិតនៅក្រោមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា ដែលបានអនុម័តឆ្នាំ១៩៩៦។ លក្ខណៈជាប្រព័ន្ធធនាគារមាន ២ថ្នាក់ បានរៀបចំ និងពង្រឹងជាបន្តបន្ទាប់។ ទន្ទឹមនឹងនោះ ធនាគារជាតិនៃកម្ពុជាបានធ្វើឱ្យសម្រេចជាមូលដ្ឋានក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ស្ថិរភាពថ្លៃប្រាក់រៀល ស្ថិរភាពអត្រាប្តូរប្រាក់ និងការបង្កើតទុនបម្រុងអន្តរជាតិក្នុងបណ្តាឆ្នាំកន្លងៗមក។

បច្ចុប្បន្ននេះ[១៤] ស្ថានភាពប្រព័ន្ធធនាគារនៅកម្ពុជាមានធនាគារពាណិជ្ជ ៥២ ធនាគារឯកទេស ១៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពីសាធារណជន ៦ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ៧៥ គ្រឹះស្ថានឥណទានជនបទ ២៤៦ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ១៥ អ្នកដំណើរការតតិយភាគី ៤ គ្រឹះស្ថានផ្តល់សេវាទូទាត់ ២៤ ក្រុមហ៊ុនចែករំលែកព័ត៌មាន ១ ការិយាល័យតំណាងធនាគារបរទេស ៦ និងអាជីវកម្មប្តូរប្រាក់ ២,៨៨៩។

## ២.៣.២- រចនាសម្ព័ន្ធគ្រប់គ្រងធនាគារកណ្តាល (Organization of CB)[១៥]

ក.១- ការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា

ក្រុមប្រឹក្សាភិបាល គឺជាអង្គភាពគ្រប់គ្រងជាន់ខ្ពស់បំផុតរបស់ធនាគារជាតិនៃកម្ពុជា ដែលដឹកនាំដោយទេសាភិបាល ហើយជំនួសពេលអវត្តមានដោយទេសាភិបាលរង។ ក្នុងករណីដែលមានការចាំបាច់ទេសាភិបាលអាចតែងតាំងឧបការីយមួយរូប ឬច្រើនរូប។

ក្រុមប្រឹក្សាភិបាលមានសមាជិក៧រូប ដែលមានទេសាភិបាល ទេសាភិបាលរង និងអគ្គនាយកដ្ឋានជាសមាជិក ។ សមាជិកនៃក្រុមប្រឹក្សាភិបាល ត្រូវបានតែងតាំងសម្រាប់រយៈពេល៤ឆ្នាំ និងអាចត្រូវបានតែងតាំងជាថ្មីបានតែ១ដងគត់។ សមាជិកនៃក្រុមប្រឹក្សាភិបាល ត្រូវបានតែងតាំងផ្លាស់ប្តូរ ឬបញ្ឈប់ពីតំណែងដោយអនុក្រឹត្យ។ ក្រុមប្រឹក្សាភិបាលមានសមាជិក៧រូបគឺ៖

- ទេសាភិបាល (១រូប)
- ទេសាភិបាលរង (២រូប)
- តំណាងប្រមុខរដ្ឋភិបាល (១រូប)
- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (១រូប)
- តំណាងមជ្ឈដ្ឋានឧត្តមសិក្សា (១រូប)
- តំណាងឱ្យមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា(១រូប)

➢ ក្រុមប្រឹក្សាភិបាលមានភារកិច្ច៖

[១៤] *Source: Bullatine of National bank of Cambodia(p,2020)*

[១៥] Source: The Federal bank of America

- រៀបចំនយោបាយសម្រាប់កិច្ចប្រតិបត្តិការរបស់ធនាគារជាតិនៃកម្ពុជា
- ចេញប្រកាសបញ្ញាសារាចរ និងសេចក្តីណែនាំផ្សេងៗ ដើម្បីគ្រប់គ្រងកិច្ចការរបស់ NBC
- ចងក្រងបទបញ្ញាផ្ទៃក្នុង
- តាក់តែងលក្ខន្តិកបុគ្គលិក បង្កើតនាយកដ្ឋានធនាគារជាតិ
- បង្កើតគណៈកម្មាធិការត្រួតពិនិត្យបញ្ជីគណនេយ្យ
- បង្កើតគណៈកម្មាធិការសម្រាប់បណ្តុះបណ្តាលវិជ្ជាជីវៈបុគ្គលិក

➢ ធនគារជាតិនៃកម្ពុជាមានរចនាសម្ព័ន្ធ ដូចតទៅៈ

ក. អគ្គលេខាធិការដ្ឋានគ្រប់គ្រងផ្ទាល់នូវ
- ខុទ្ទកាល័យធនាគារជាតិនៃកម្ពុជា
- នាយកដ្ឋានបុគ្គលិក
- នាយកដ្ឋានគណនេយ្យ
- នាយកដ្ឋានគតិយុត្តិ
- មណ្ឌលសិក្សាបច្ចេកទេសធនាគារ
- ធនាគារពាណិជ្ជកម្មក្រៅប្រទេស
- សាខាធនាគារខេត្ត/ក្រុង

ខ. អគ្គនាយកដ្ឋានគ្រប់គ្រងផ្ទាល់នូវ
- នាយកដ្ឋានត្រួតពិនិត្យ
- នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច
- នាយកដ្ឋានប្រតិបត្តិការ
- នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់

គ. អគ្គបេឡាគ្រប់គ្រងផ្ទាល់នូវ
- នាយកដ្ឋានបោះពុម្ពផ្សាយ និងឃ្លាំងបេឡា
- នាយកដ្ឋានរោងពុម្ព

ឃ. អគ្គធិការដ្ឋានមានសមត្ថកិច្ចបញ្ជាណែនាំទៅលើ
- នាយកដ្ឋានអធិការកិច្ចប្រតិបត្តិការណ៍
- នាយកដ្ឋានអធិការកិច្ចទូទៅ

➢ ធនាគារជាតិនៃកម្ពុជាមានភារកិច្ច និងមុខងារដូចតទៅ ៖
- កំណត់គោលដៅនយោបាយរូបិយវត្ថុ ដោយពិគ្រោះជាមួយរដ្ឋាភិបាលក្នុងក្របខ័ណ្ឌនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា។
- ត្រិះរិះរកការអនុវត្តន៍ និងត្រួតពិនិត្យនយោបាយរូបិយវត្ថុ និងប្តូរប្រាក់ឱ្យស្របទៅតាមការកំណត់គោលនយោបាយ ដែលបានកំណត់។

- ធ្វើការវិភាគស្ថានភាពសេដ្ឋកិច្ច និងរូបិយវត្ថុជាប្រក្រតីរួចចេញផ្សាយលទ្ធផល ហើយលើកសំណើរ និងវិធានការណ៍ទៅរដ្ឋាភិបាល។
- ផ្ដល់ ឬដកអាជ្ញាប័ណ្ណអាជីវកម្ម ចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងគ្រឹះស្ថានឯទៀតដែលពាក់ព័ន្ធដូចជា ស្នងការគណនី គ្រឹះស្ថានជម្រះបញ្ជីជាដើម ព្រមទាំងចេញបទបញ្ញា និងត្រួតពិនិត្យគ្រឹះស្ថានទាំងនោះ។
- ត្រួតពនិត្យប្រព័ន្ធទូទាត់ក្នុងព្រះរាជាណាចក្រកម្ពុជា និងកែលម្អប្រសិទ្ធិភាពប្រព័ន្ធទូទាត់អន្តរធនាគារ។
- ទទួលភាពផ្ដាច់មុខជាអ្នកបោះផ្សាយរូបិយវត្ថុនៃព្រះរាជាណាចក្រកម្ពុជា។
- ទទួលខុសត្រូវ និងអនុវត្តក្នុងនាមនៃព្រះរាជាណាចក្រកម្ពុជានូវកិច្ចការទាំងឡាយណាជាលទ្ធផលក្នុងការចូលរួមនៃព្រះរាជាណាចក្រកម្ពុជាជាមួយស្ថាប័នជាតិសាធារណៈក្នុងកិច្ចការធានាឥណទានរូបិយវត្ថុ។
- តម្លើងជញ្ជីងទូទាត់។
- ចូលរួមក្នុងការគ្រប់គ្រងបំណុល និងឥណទេយ្យជាមួយប្រទេសក្រៅ។
- ចូលរួមក្នុងការបង្កើត និងត្រួតពិនិត្យទីផ្សាររូបិយវត្ថុ និងទីផ្សារហិរញ្ញវត្ថុ។
- ផ្ដល់ ឬដកហូតអាជ្ញាប័ណ្ណគ្រឹះស្ថានណាដែលចូលរួមអាជីវកម្ម ទីផ្សារប្ដូរប្រាក់ សង្ហារឹមត្បូងថ្ម និងលោហៈធាតុមានតម្លៃព្រមទាំងចេញបទបញ្ញា និងត្រួតពិនិត្យគ្រឹះស្ថាន។
- កំណត់អត្រាប្ដូរប្រាក់

➢ ទេសាភិបាល និងទេសាភិបាលរង៖

ទេសាភិបាល និងទេសាភិបាលរងធនាគារជាតិ ឬសហព័ន្ធនៅស្ទើគ្រប់ប្រទេសទាំងអស់ គឺជ្រើសតាំងដោយរដ្ឋាភិបាលអាចមានរយៈពេលរហូតដល់ ៧ឆ្នាំ ឬទៅតាមអាណត្តិរបស់រដ្ឋាភិបាល ប៉ុន្តែគេអាចជ្រើសតាំងជាថ្មីផងដែរ។ ទេសាភិបាលត្រូវតែទទួលខុសត្រូវគ្រប់គ្រង និងប្រតិបត្តិកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលធនាគារ។ ទេសាភិបាលរងទាំងពីរត្រូវបានបែងចែកការងារខុសគ្នាតាមតួនាទីទទួលខុសត្រូវ។ នៅពេលទេសាភិបាលធនាគារអវត្តមាន ទេសាភិបាលរងមានសិទ្ធិបន្តអនុវត្តការងាររបស់ទេសាភិបាល។ នៅក្នុងប្រទេសកម្ពុជាទេសាភិបាលធនាគារមានតួនាទីជាអ្នកដឹកនាំទី១ នៃធនាគារ កណ្ដាល និងមេដឹកនាំក្រុមប្រឹក្សាទាំងនយោបាយ និងកិច្ចការរបស់ធនាគារ។ ទេសាភិបាលមានសិទ្ធ អំណាចធ្វើការទាំងឡាយណា ដែលមិនបានកំណត់ក្នុងក្រុមប្រឹក្សាភិបាលរបស់ធនាគារ។ ទេសាភិបាលរងមានសិទ្ធិអំណាច និងបំពេញភារកិច្ចទាំងឡាយណា ដែលទេសាភិបាលបានកំណត់ឱ្យធ្វើប៉ុណ្ណោះ។ ដោយយោងតាមគោលការណ៍ តើភាពខុសគ្នារវាងរចនាសម្ព័ន្ធគ្រប់គ្រងផ្ទាល់នៃធនាគារជាតិ និងប្រទេសដទៃទៀតមានន័យយ៉ាងដូចម្ដេច? ចម្លើយនឹងពន្យល់នៅពេលសិក្សា។ ទេសាភិបាល និងទេសាភិបាលរង ត្រូវតែងតាំង ផ្លាស់ប្ដូរ ឬបញ្ឈប់តំណែងដោយព្រះរាជក្រឹត្យតាមសំណើររបស់រដ្ឋាភិបាល និងមានប្រាក់បៀវត្សដូចសមាជិករបស់រដ្ឋាភិបាលដែរ។

➢ អគ្គលេខាធិការ ៖

ដោយឡែក អគ្គលេខាធិការត្រូវតែប្រតិបត្តិដោយផ្ទាល់ ក្រោមការណែនាំរបស់ទេសាភិបាល សម្របសម្រួលជាមួយទេសាភិបាលរងទាំងពីរ និងរាយការណ៍រាល់សកម្មភាពផ្លាស់ប្តូរជូនក្រុមប្រឹក្សាប្រតិបត្តិ និងក្រុមប្រឹក្សាភិបាលនៅលើវិស័យធនាគារ និងនយោបាយរូបិយវត្ថុ ដែលមន្ត្រីក្រោមឱវាទបានអនុវត្តកន្លងមក ជាពិសេសអគ្គលេខាធិការត្រូវតែភ្ជាប់ការងារជាមួយក្រសួងពាក់ព័ន្ធ និងផ្នែកឯកជន។ ធនាគារីក គឺជាប្រធាន ឬជាតំណាងធនាគាររដ្ឋ និងឯកជននានា។ គេមានសិទ្ធិប្រតិបត្តិ ដោយឯករាជ្យ និងអនុលោមតាមសារាចររបស់ធនាគារជាតិ។ ស្ថាប័នហិរញ្ញវត្ថុរបស់រដ្ឋរួមមាន៖ ធនាគារជាតិ រតនាគារ និងសាខារបស់ធនាគាររដ្ឋនៅតាមបណ្តាខេត្តនានា។ អ្នកដឹកនាំបុគ្គលិក និងសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់ធនាគារកណ្តាលមិនត្រូវផ្តល់ពត៌មាន ដែលទាក់ទងនឹងវិជ្ជាជីវៈសម្ងាត់របស់ខ្លួនបានទេ លើកលែងតែមានករណីចាំបាច់ ដែលច្បាប់បានអនុញ្ញាត ឬការបង្គាប់បញ្ជាពីតុលាការ(មាត្រា ១៦) រាល់ការតែងតាំង ដោយអនុក្រឹត្យ សេចក្តីប្រកាស និងសេចក្តីសម្រេច។ ចំណាំ៖ ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជាផ្តាច់ចេញពីធនាគារជាតិ ផ្ទេរទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២។

### ២.៣.៣- ធនាគារិក

ធនាគារិក គឺជាប្រធាន ឬជាតំណាងធនាគាររដ្ឋ និងឯកជននានា។ គេមានសិទ្ធិប្រតិបត្តិដោយឯករាជ្យ និងអនុលោមតាមសារាចររបស់ធនាគារកណ្តាល។ ស្ថាប័នហិរញ្ញវត្ថុរបស់រដ្ឋរួមមាន៖ ធនាគារកណ្តាល រតនាគារ និងសាខារបស់ធនាគាររដ្ឋនៅតាមបណ្តាខេត្តនានា។ ថ្នាក់ដឹកនាំបុគ្គលិក និងសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់ធនាគារកណ្តាល មិនត្រូវផ្តល់នូវព័ត៌មានដែលទាក់ទងនឹងវិជ្ជាជីវៈសម្ងាត់របស់ខ្លួនបានទេ លើកលែងតែមានករណីចាំបាច់ដែលច្បាប់បានអនុញ្ញាត ឬការបង្គាប់បញ្ជាពីតុលាការ ហើយរាល់ការតែងតាំងធនាគារិក ដែលចេញដោយអនុក្រឹត្យ សេចក្តីប្រកាស និងសេចក្តីសម្រេច។

សេចក្តីសន្និដ្ឋានរបស់ធនាគារិកតាមបច្ចេកទេស គឺការរដ្ឋលរលំមានទំនាក់ទំនងទៅនឹង ៖

- ការបង្វិលទុនទ្រព្យសកម្មក្នុងពាណិជ្ជកម្មរវាងលុយបាត និងដុល្លារ ដែលស្របនឹងការស្រុតចុះនៃសេដ្ឋកិច្ចប្រទេសថៃក្នុងវិបត្តិសេដ្ឋកិច្ចនៅអាស៊ីនៅឆ្នាំ ១៩៩៧-១៩៩៨។
- ការជំពាក់របស់អ្នកខ្ចីមកពីធនាគារ ហើយប័ណ្ណជានារបស់អតិថិជនពិបាកលក់ដោយសារស្ថានភាពជំនួញ។
- ការផ្តល់ឥណទានបរាជ័យជាមួយកសិករ។
- ប្រាក់តម្កល់នៅធនាគារជាតិតិចតួចពេកមិនអាចស្រោចស្រង់បាន។ នេះគ្រាន់តែជាការវិនិច្ឆ័យរបស់ធនាគារិកប៉ុណ្ណោះ។
- ការដាក់កំណត់ចូលទីផ្សារដទៃគឺជាការដាក់បណ្តឹងលើធនាគារមិនឱ្យពង្រីកទីផ្សារហិរញ្ញវត្ថុច្រើនពេក។ ជាទូទៅ ធនាគារឯកទេសតែងតែចង់ពង្រីកមូលនិធិរបស់ខ្លួនតាមរយៈការពង្រីកកម្ចីឱ្យទៅអតិថិជន ទោះបីជាខ្លួនមានប្រាក់បម្រុងតិចតួចក៏ដោយ។ ស្ថានភាពបែបនេះអាចផ្តល់ផលអាក្រក់ដល់អ្នកដាក់ប្រាក់បញ្ញើ ដូចជាការពន្យាសំណង។ល។

- ការត្រួតពិនិត្យអំពីការប្តូរប្រាក់បរទេស គឺជាអនុភាពរបស់ធនាគារកណ្តាលក្នុងការត្រួតពិនិត្យការប្តូរប្រាក់បរទេស និងដាក់កំហិតតឹងរឹងលើការខ្ចីមូលនិធិបរទេស ដើម្បីដំណើរការ។ ធនាគារកណ្តាលបានដាក់លក្ខខណ្ឌរាល់មូលនិធិ ដែលធនាគារខ្ចីនៅក្នុងស្រុកត្រូវតែដំណើរការនៅក្នុងស្រុក និងទប់ស្កាត់លុយកខ្វក់ពីបរទេស។ ធនាគារពាណិជ្ជកម្ម និងធនាគារឯកជនត្រូវតែបង្ហាញចរន្តតួលេខដូរប្រាក់ជាប្រចាំ និងទ្រព្យសកម្មជូនភ្នាក់ងារស៊ើបអង្កេតហិរញ្ញវត្ថុ (Bank Inspection Agent)។

ខ.១. រចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា



## ២.៣.៤- តួនាទីសំខាន់របស់ធនាគារកណ្ដាល ( The role of central bank operation )

ធនាគារកណ្ដាល មានការទទួលខុសត្រូវលើការគ្រប់គ្រងគោលនយោបាយរូបិយវត្ថុ ដែលធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងរូបិយវត្ថុ ជាពិសេសការគ្រប់គ្រងកម្រិតអតិផរណា។ ធនាគារកណ្ដាល គឺជាអ្នកឱ្យប្រាក់កម្ចីចុងក្រោយទៅឱ្យធនាគារ និងជាអ្នកត្រួតពិនិត្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ ក្រៅពីនេះ ធនាគារកណ្ដាលត្រូវរក្សាទុកទុនបម្រុងជារូបិយប័ណ្ណបរទេសដូចជា មាស និងមូលប័ត្របំណុលចារីក។ល។ និងអន្តរាគមន៍សំដៅលើការគ្រប់គ្រងអត្រាប្ដូរប្រាក់ផងដែរ។

ធនាគារកណ្ដាល បានដើរតួយ៉ាងសំខាន់នៅក្នុងប្រព័ន្ធហិរញ្ញវត្ថុសេដ្ឋកិច្ច វាមានការទាក់ទាញយ៉ាងខ្លាំងពីមហាសាធារណជន និងបានចាត់ទុកដាក់ប្រាក់បញ្ញើធនាគារ គឺជាមធ្យោបាយទូទាត់ ឬជាមធ្យោបាយដោះដូរក្រដាសប្រាក់ និងកាស (N&C) ការដាក់ប្រាក់បញ្ញើធនាគារ គឺជារូបិយវត្ថុ។ ធនាគារអាចបង្កើតប្រាក់បញ្ញើធនាគារបានយ៉ាងសាមញ្ញ ដោយសារតែទីផ្សារបំណុល (MD) និងទីផ្សារមិនមែនបំណុល (NMD)។ ការរៀបចំនេះ ខណៈពេលដោះស្រាយលក្ខខណ្ឌភាពខ្វះខាត សាច់ប្រាក់ងាយស្រួលប្រៀបធៀបនឹងក្រដាសប្រាក់ និងកាស ដែលបានធ្វើពីលោហៈមានតម្លៃ (ការផ្គត់ផ្គង់ខ្វះខាត) ត្រូវបានផ្សារភ្ជាប់ជាមួយនឹងបញ្ហាមួយចំនួនៈ

- ការផ្គត់ផ្គង់ប្រាក់កម្ចីធនាគារ(បង្កើតប្រាក់កម្ចីធនាគារ)ត្រូវបានកំណត់ដោយតម្រូវការ ប្រាក់កម្ចី និងភាពអាចជឿជាក់បាន ឬអាចទទួលយកបាននៃគម្រោងរបស់អ្នកខ្ចី (ដូចជារូបវន្តបុគ្គល ក្រុមហ៊ុន និងរដ្ឋាភិបាល)។
- ធនាគារកំពុងតែប្រកួតប្រជែងជាមួយអាជីវកម្មមួយផ្សេងទៀតដែលទំនោរទៅរកភាពធូរលុង បើស្ថានភាពចុងក្រោយអាចធ្វើឱ្យធនាគារមិនមានស្ថិតស្ថេរ។ ដូច្នេះ តម្រូវឱ្យមានបទបញ្ញារឹងមាំ និងការត្រួតពិនិត្យ។
- ដោយសារតែការផ្គត់ផ្គង់ប្រាក់កម្ចី(តាមទ្រឹស្ដី) គ្មានដែនកំណត់កម្រិតអតិផរណា និងមហាអតិផរណា (hyperinflation) គឺជាហានិភ័យដែលនៅតែបន្តមាន។

- ដោយសារការផ្គត់ផ្គង់ប្រាក់កម្ចី (តាមទ្រឹស្តី) គ្មានដែនកំណត់(សូមមើលរូបភាពទី១) បានបង្ហាញពីតម្លៃនៃរូបិយវត្ថុ គឺមិនមាននោះទេ។ ដូច្នេះ ការអន្តរាគមន៍របស់ធនាគារកណ្តាលគឺជាភាពចាំបាច់។

ធនាគារកណ្តាលមិនគួរធ្វើឱ្យមានភាពភ្ញាក់ផ្អើលនោះទេ គឺថានៅក្នុងគ្រាដ៏លំបាកបែបនេះ។ ធនាគារកណ្តាលតម្រូវឱ្យមានតួនាទីសំខាន់៖

- ដើម្បីគ្រប់គ្រងអត្រាការប្រាក់រយៈពេលខ្លី ជាពិសេសអត្រាប្រាក់កម្ចីរធនាគារ ដូច្នេះការជះឥទ្ធិពលដល់តម្រូវការប្រាក់កម្ចី ឬបង្កើតប្រាក់កម្ចីដែលហៅថា "គោលនយោបាយរូបិយវត្ថុ"។
- ដើម្បីផ្ទៀងផ្ទាត់ និងត្រួតពិនិត្យប្រព័ន្ធធនាគារ និងប្រព័ន្ធហិរញ្ញវត្ថុដែលមិនមានស្ថិរភាព។

កត្តាដូចបានរៀបរាប់លើទាំងនេះ គឺជាតួនាទីស្នូលរបស់ធនាគារកណ្តាល។ បណ្តាធនាគារកណ្តាលភាគច្រើន គឺជាអង្គភាពដែលចាប់អារម្មណ៍ខ្លាំងសំដៅលើកត្តាមួយចំនួន មានដូចខាងក្រោម៖

- ខ្លឹមសារនៃធនាគារកណ្តាល
- ធនាគារិក និងជាទីប្រឹក្សារដ្ឋាភិបាល
- ការគ្រប់គ្រងរូបិយវត្ថុ និងប្រព័ន្ធធនាគារ
- ការរៀបចំ និងអនុវត្តគោលនយោបាយរូបិយវត្ថុ

ទន្ទឹមនឹងនេះ ធនាគារកណ្តាលផ្តល់នូវសេវាចម្បងសំខាន់ៗ មានដូចជា៖

- ផាត់ទាត់មូលប័ត្ររវាងគ្រឹះស្ថានធនាគារផ្សេងៗ
- រក្សាទុកនូវប្រាក់បម្រុងទុកធនាគាររបស់គ្រឹះស្ថានធនគារទាំងឡាយ
- ផ្តល់សាច់ប្រាក់ឱ្យ និងទទួលសាច់ប្រាក់ពីគ្រឹះស្ថានធនាគារ
- ផ្តល់កម្ចីអប្បហារឱ្យទៅគ្រឹះស្ថានធនាគារ

ដូចនេះ មុខងារចម្បងសំខាន់ៗរបស់ធនាគារកណ្តាល៖ មានសិទ្ធិផ្តាច់មុខក្នុងការផ្សាយចេញក្រដាសប្រាក់។ ជាធនាគារិកឱ្យរដ្ឋាភិបាលបម្រើសេវាកម្មហិរញ្ញវត្ថុឱ្យរដ្ឋាភិបាល និងជាធនាគារនៃធនាគារក្នុងនាមជាអ្នកឱ្យខ្ចីចុងក្រោយ។ ជាអ្នកគ្រប់គ្រងទុនបម្រុងជារូបិយប័ណ្ណបរទេស។ ជាអ្នកត្រួតពិនិត្យ និងកំណត់និយ័តកម្មចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ កំណត់អត្រាការប្រាក់ផ្លូវការគ្រប់គ្រងអតិផរណា និងអត្រាប្តូរប្រាក់។ រៀបចំ និងអនុវត្តគោលនយោបាយរូបិយវត្ថុ ដើម្បីមានឥទ្ធិពលដល់ការផ្គត់ផ្គង់រូបិយវត្ថុ និងឥណទានសរុបនៅក្នុងសេដ្ឋកិច្ច។

ចំពោះច្បាប់នៃប្រទេសកម្ពុជា ធនាគារកណ្តាលមានមុខងារ និងភារកិច្ច ដូចជា៖

- កំណត់គោលដៅនៃនយោបាយរូបិយវត្ថុ ដោយពិគ្រោះយោបល់ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជានៅក្នុងក្របខ័ណ្ឌនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងអនុវត្ត និងត្រួតពិនិត្យនយោបាយរូបិយវត្ថុ និងប្តូរប្រាក់ឱ្យសម្រេចទៅតាមគោលដៅដែលបានកំណត់។
- វិភាគស្ថានភាពសេដ្ឋកិច្ច និងរូបិយវត្ថុជាប្រក្រតី រួចចេញផ្សាយលទ្ធផល ហើយលើកសំណើរ និងវិធានការជូនរាជរដ្ឋាភិបាល។

- ផ្តល់ ឬដកហូតអាជ្ញាប័ណ្ណអាជីវកម្ម ចេញបទបញ្ជា និងត្រួតពិនិត្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងគ្រឹះស្ថានពាក់ព័ន្ធ ដូចជាស្នងការគណនេយ្យ និងគ្រឹះស្ថានជម្រះបញ្ជីជាដើម។
- ត្រួតពិនិត្យប្រព័ន្ធទូទាត់ និងកែលម្អប្រសិទ្ធភាពនៃប្រព័ន្ធអន្តរធនាគារ និងបម្រើសេវាកម្មធនាគារជូនរដ្ឋាភិបាល។
- ទទួលភារកិច្ចផ្តាច់មុខជាអ្នកបោះផ្សាយរូបិយវត្ថុជាតិ។
- គ្រប់គ្រងទុនបម្រុងអន្តរជាតិរបស់ប្រទេស ដោយរក្សាបរិមាណមួយឱ្យគ្រប់គ្រាន់សម្រាប់ធានាឱ្យប្រតិបត្តិការអន្តរជាតិរបស់ប្រទេស។

ដូច្នេះ ធនាគារកណ្តាល មានបេសកម្មចម្បងគឺ កំណត់ និងដឹកនាំគោលនយោបាយរូបិយវត្ថុក្នុងក្របខ័ណ្ឌនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅរក្សាកម្រិតថ្លៃឱ្យមានស្ថិរភាព សំដៅបង្កលក្ខណៈងាយស្រួលដើម្បីធ្វើឱ្យសេដ្ឋកិច្ចរីកចម្រើន។

ក្រាហ្វិកទី១ បង្ហាញពី៖ ការផ្គត់ផ្គង់ និងតម្រូវការរបស់កម្ចីធនាគារ ( Supply and bank's demand )




ផ្អែកលើសារសំខាន់នៃធនាគារកណ្តាល ត្រូវបានរៀបចំដូចខាងក្រោម៖

- គ្រឹះស្ថានធនាគារកណ្តាល៖ ប្រព័ន្ធហិរញ្ញវត្ថុ
- បរិបទរបស់ធនាគារកណ្តាល៖ ស្ថិរភាពហិរញ្ញវត្ថុ
- តារាងតុល្យការរបស់ធនាគារកណ្តាល
- ការបង្កើតរូបិយវត្ថុ( លុយ )

- មុខងាររបស់ធនាគារកណ្តាល

## ២.៤- គ្រឹះស្ថានធនាគារកណ្តាល៖ ប្រព័ន្ធហិរញ្ញវត្ថុ (central bank: the financial system)

ប្រព័ន្ធហិរញ្ញវត្ថុ គឺជាទីផ្សារហិរញ្ញវត្ថុមួយជួយសម្របសម្រួលដល់ការបង្កើត និងលក់ឧបករណ៍ហិរញ្ញវត្ថុ។ ទីផ្សារហិរញ្ញវត្ថុនៅក្នុងសេដ្ឋកិច្ច គឺជាការបង្ហូរនូវសញ្ច័យធន ឬការសន្សំទៅឱ្យសហគ្រាស ដែលត្រូវការទុនវិនិយោគសម្រាប់ទិញមូលធនរូបវន្ត (Physical capital) សម្រាប់ពង្រីកផលិតកម្ម។ ទីផ្សារហិរញ្ញវត្ថុមានទីផ្សារចំនួន២៖

- ទីផ្សារទី១ (Primary market) ជាទីផ្សារចេញផ្សាយហ៊ុនថ្មីដែលពាក់ព័ន្ធនឹងការបែងចែកជាដំបូងនូវឧបករណ៍ហិរញ្ញវត្ថុ ដែលទើបបង្កើតថ្មី។
- ទីផ្សារទី២ ឬទីផ្សារបន្ទាប់ (Secondary market) ជាទីផ្សារជួញដូរឧបករណ៍ហិរញ្ញវត្ថុដែលមាន ឬចេញផ្សាយស្រាប់។

សរុបជារួម លំហូរមូលនិធិនេះតែងប្រព្រឹត្តទៅតាមរយៈគ្រឹះស្ថានហិរញ្ញវត្ថុ ដែលជាអ្នកចូលរួមក្នុងការទិញលក់ឧបករណ៍ហិរញ្ញវត្ថុ ឬអន្តរការីហិរញ្ញវត្ថុនៅលើទីផ្សារហិរញ្ញវត្ថុ។ ប្រព័ន្ធហិរញ្ញវត្ថុមានប្រយោជន៍ក្នុងការណែនាំពីធនាគារកណ្តាល ដោយបានពិពណ៌នាសង្ខេបពីប្រព័ន្ធហិរញ្ញវត្ថុដែលជាប់វិបទវិស័យធនាគារ។ ប្រព័ន្ធហិរញ្ញវត្ថុត្រូវបានបង្ហាញយ៉ាងសាមញ្ញ ដូចក្នុងរូបភាពទី២។

### ២.៤.១- ប្រព័ន្ធហិរញ្ញវត្ថុ (Financial system)

ប្រព័ន្ធហិរញ្ញវត្ថុ គឺជាទីផ្សារមួយជួយសម្រួលដល់ការបង្កើត និងលក់ឧបករណ៍ហិរញ្ញវត្ថុ។ តួនាទីសេដ្ឋកិច្ចរបស់ទីផ្សារហិរញ្ញវត្ថុ គឺការបង្ហូរនូវសញ្ច័យធន ឬការសន្សំទៅឱ្យសហគ្រាស ដែលត្រូវការទុនវិនិយោគសម្រាប់ទិញមូលធនសម្ភារៈ និងបរិក្ខាព្រមទាំងទំនិញអន្តរការីសម្រាប់ការពង្រីកផលិតកម្ម។ គោលដៅចម្បងរបស់ទីផ្សារហិរញ្ញវត្ថុ គឺសម្រួលដល់លំហូរមូលនិធិពីអ្នកឱ្យខ្ចីទៅកាន់អ្នកសុំខ្ចី។ ប្រព័ន្ធហិរញ្ញវត្ថុមានសារសំខាន់ទាក់ទងនឹងការខ្ចីប្រាក់ និងការផ្តល់ប្រាក់កម្ចី និងសមាសធាតុចូលរួមមានចំនួនប្រាំមួយភ្នាក់ងារ៖

- ទីមួយ៖ អ្នកខ្ចីប្រាក់ (អង្គភាពសេដ្ឋកិច្ចមានអតិរេក) និងអ្នកខ្ចីប្រាក់ (ផ្នែកសេដ្ឋកិច្ចមានឱនភាព) ពោលគឺអង្គភាពសេដ្ឋកិច្ចមិនមែនអន្តរហិរញ្ញវត្ថុ ធ្វើការផ្តល់ប្រាក់កម្ចី និងខ្ចីប្រាក់។ ពួកគេក៏អាចត្រូវបានគេហៅថាអ្នកផ្តល់ប្រាក់កម្ចី និងអ្នកខ្ចីប្រាក់ (ភាពខុសគ្នាពីអន្តរការីហិរញ្ញវត្ថុដែលធ្វើម្តងទាំងពីរ)។ អ្នកផ្តល់ប្រាក់កម្ចី បានព្យាយាមរកប្រាក់ចំណូលអតិបរមាលើរូបិយវត្ថុអតិរេករបស់ពួកគេ ហើយអ្នកសុំខ្ចីប្រាក់ បានព្យាយាមចំណាយអប្បបរមាសម្រាប់ការប្រាក់របស់ពួកគេ។
- ទីពីរ៖ អន្តរការីហិរញ្ញវត្ថុ ដែលមានដំណើរការផ្តល់ប្រាក់កម្ចី និងការខ្ចីប្រាក់សម្រាប់រយៈពេលមធ្យម។ ពួកគេធ្វើអន្តរាគមន៍រវាងអ្នកផ្តល់ប្រាក់កម្ចី និងអ្នកសុំខ្ចីប្រាក់ចុងក្រោយ និងព្យាយាមបង្កើនប្រាក់ចំណេញឱ្យបានច្រើនបំផុតរវាងអ្វី ដែលពួកគេចំណាយសម្រាប់បំណុល

(ប្រាក់កម្ចី) និងរកប្រាក់ចំណូលលើទ្រព្យសម្បត្តិ (ប្រាក់កម្ចីលើសបំណុល)។ ក្នុងករណីធនាគារនេះ គេហៅថាកម្រិតសមាមាត្រធនាគារ (bank margin)។ ជាការពិត ពួកគេព្យាយាមចំណាយតិចបំផុតលើប្រាក់បញ្ញើ ហើយរកប្រាក់ចំណេញឱ្យបានច្រើនបំផុត។ (នេះជាមូលហេតុដែលអ្នកត្រូវតែតាមដាននៅពេលដែលពួកគេផ្តល់ជូនអ្នកនូវទឹកប្រាក់ ឬពេលដែលពួកគេចង់ផ្តល់ប្រាក់កម្ចីឱ្យទៅអ្នក)។

- ទីបី៖ ឧបករណ៍ហិរញ្ញវត្ថុ ដែលត្រូវបានបង្កើតឡើងដើម្បីបំពេញនូវតម្រូវការហិរញ្ញវត្ថុរបស់អ្នកចូលរួមផ្សេងៗទៀត ។ ឧបករណ៍ទាំងនេះអាចធ្វើទីផ្សារលក់បាន (treasury bills) ឬមិនអាចធ្វើទីផ្សារបាន (ឧទាហរណ៍ទីកន្លែងផ្ទេរគណនីធនាគារ ដែលបានប្រើ)។
- ទីបួន៖ ការបង្កើតប្រាក់នៅពេលមានតម្រូវការ។ ដូចដែលអ្នកស្គាល់ធនាគារ (ជារួម) មានសមត្ថភាពពិសេសក្នុងការបង្កើតប្រាក់បញ្ញើផ្ទាល់ខ្លួន(=រូបិយវត្ថុ) ពីព្រោះសាធារណជនបានទទួលយកប្រាក់បញ្ញើរបស់ពួកគេជាមធ្យោបាយទូទាត់។
- ទីប្រាំ៖ ទីផ្សារហិរញ្ញវត្ថុ៖ ការរៀបចំស្ថាប័ន និងអនុសញ្ញានានាដែលមានសម្រាប់បញ្ហា និងការធ្វើពាណិជ្ជកម្ម (ដោះស្រាយ) នូវឧបករណ៍ហិរញ្ញវត្ថុ។
- ទីប្រាំមួយ៖ ការកំណត់ថ្លៃ ឧទាហរណ៍តម្លៃភាគហ៊ុន និងបំណុលតម្លៃ(អត្រាការប្រាក់) ត្រូវបានរកឃើញ និងកំណត់នៅក្នុងទីផ្សារហិរញ្ញវត្ថុ។ កម្រិតថ្លៃគឺមានការបែងចែកមុខងារមូលនិធិ។

គំនូសតាងទី ២៖ ប្រព័ន្ធហិរញ្ញវត្ថុ (financial system)



តើអ្វីជាគ្រឹះស្ថានហិរញ្ញវត្ថុ (financial institution)? គឺជាគ្រឹះស្ថាន ដែលកៀរគរមូលនិធិពីអ្នកសន្សំ ដើម្បីយកទៅធ្វើហិរញ្ញប្បទានទុនជាចម្បងដល់ទ្រព្យសកម្មហិរញ្ញវត្ថុ ដូចជាកម្ចីប្រាក់បញ្ញើ និងមូលប័ត្រផ្សេងៗ។ ទន្ទឹមនឹងនេះដែរ គ្រឹះស្ថានហិរញ្ញវត្ថុគឺជាភ្នាក់ងារសេវាហិរញ្ញវត្ថុឱ្យអតិថិជន ដោយបង្វែរមូលនិធិពីអ្នកវិនិយោគ ដែលមានអតិរេកមូលនិធិ (surplus fund) ទៅឱ្យសហគ្រាស និងស្ថាប័នរដ្ឋាភិបាលនានា ដែលជាអ្នកត្រូវការមូលនិធិ។ គ្រឹះស្ថានទទួលប្រាក់បញ្ញើ (Depository institutions) គឺជាគ្រឹះស្ថានធនាគារដែលមានប្រាក់បញ្ញើច្រើនប្រភេទនៅផ្នែកទ្រព្យអកម្មរបស់ខ្លួន។ គ្រឹះស្ថានទាំងនេះរួមមាន៖ ធនាគារពាណិជ្ជកម្មផ្តោតលើការផ្តល់កម្ចីសម្រាប់ពាណិជ្ជកម្ម។ ធនាគារសំចៃ (Saving banks) ផ្តោតលើការផ្តល់កម្ចីសម្រាប់អចលនទ្រព្យ។ សហគមសន្សំ និងកម្ចី (Saving & loan asso-ciations) មានតួនាទីជាប្រពៃណីក្នុងការផ្តល់កម្ចីសម្រាប់អចលនទ្រព្យដែរ។ សហព័ន្ធឥណទាន (credit union) ផ្តល់កម្ចីទៅឱ្យតែឯកត្តជន ដែលជាសមាជិករបស់សហព័ន្ធឥណទាន។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុផ្តល់ឥណទានជនបទដល់កសិករ និងសហគ្រាសធុនតូចសម្រាប់បង្កើត និងពង្រីកមុខរបរ ឬទិញមធ្យោបាយកសិកម្ម។

## ២.៤.២- សមាសធាតុនៃប្រព័ន្ធហិរញ្ញវត្ថុ (Element of financial system)

សមាសធាតុទាំងនេះ គឺជាភ្នាក់ងាររបស់ធនាគារដែលបានចូលរួមក្នុងប្រព័ន្ធហិរញ្ញវត្ថុ ពោលគឺជាភ្នាក់ងាររបស់ធនាគារក្រៅពីគោលការណ៍ជារួម (ម្ចាស់បំណុលហិរញ្ញវត្ថុ និងកូនបំណុលហិរញ្ញវត្ថុ)។ នេះគោលការណ៍រួមមានគឺ៖ អ្នកផ្តល់កម្ចីប្រាក់ និងអ្នកកម្ចីប្រាក់គឺជាអន្តរការីហិរញ្ញវត្ថុ។ សម្រាប់ភ្នាក់ងារអ្នកចូលរួមជាសម្ព័ន្ធភាពនេះ បានដើរតួយ៉ាងសំខាន់ក្នុងការសម្រួលដល់ដំណើរការផ្តល់ប្រាក់កម្ចី និងឱ្យប្រាក់កម្ចីសម្រាប់ទីផ្សារចម្បង ឬទីផ្សារទី១ និងទីផ្សារមូលធន ឬទីផ្សារទី២។

អ្នកគ្រប់គ្រងមូលនិធិដែលចូលរួមយ៉ាងសកម្មក្នុងសិក្សាវិភាគហិរញ្ញវត្ថុដ៏ស្មុគស្មាញ ដើរតួនាទីយ៉ាងសំខាន់ក្នុងការបែងចែកទ្រព្យសម្បត្តិ និងស្វែងរកតម្លៃនិយ័តករនៃទីផ្សារហិរញ្ញវត្ថុ និងភ្នាក់ងារវាយតម្លៃ។

ដូច្នេះ ភ្នាក់ងារអ្នកចូលរួមពុំមែនជាសម្ព័ន្ធភាពនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុនោះទេគឺ៖

- ការប្រែប្រួលហិរញ្ញវត្ថុ និងឈ្មួញកណ្តាល (Financial exchanges & broker-dealers)
- អ្នកគ្រប់គ្រងមូលនិធិ (Fund managers)
- និយ័តករ (Regulators)
- ភ្នាក់ងារវាយតម្លៃ (Rating agencies)

ឧបករណ៍ហិរញ្ញវត្ថុចែកចេញជាច្រើនប្រភេទ គឺជាឧបករណ៍ទូទាត់ ឬបង់ប្រាក់ ដូចជារូបិយប័ណ្ណ មូលប្បទានប័ត្រ ប័ណ្ណឥណពន្ធ និងប័ណ្ណឥណទាន ដែលបានដើរតួនាទីជាមធ្យោបាយទូទាត់ និងឧបករណ៍វិនិយោគ ដូចជាភាគហ៊ុន(សន្លឹកហ៊ុន) សញ្ញាប័ណ្ណ(មូលប័ត្របំណុល) និងការជួញដូរមូលប័ត្រនាអនាគត។ ដូចនេះឧបករណ៍ទូទាត់បានកាត់បន្ថយនូវការចំណាយប្រតិបត្តិការ និងសម្រួល

ដល់ឯកទេសកម្មក្នុងដំណើរការផលិតកម្ម និងការដោះដូរ។ ការកាត់បន្ថយថ្លៃដើមប្រតិបត្តិការ និងការលើកកម្ពស់ឯកទេសកម្មទាំងនេះ មិនត្រឹមតែកើតឡើងនៅក្នុងដំណើរការផ្លាស់ប្តូរពីសេដ្ឋកិច្ចដោះដូរទំនិញនិងទំនិញនៅក្នុងសេដ្ឋកិច្ចរូបិយវត្ថុប៉ុណ្ណោះទេ។ ប៉ុន្តែថែមទាំងពាក់ព័ន្ធនឹងនវានុវត្តន៍បន្ថែមទៀតលើឧបករណ៍ទូទាត់ ដូច្នេះនវានុវត្តន៍លើឧបករណ៍ទូទាត់បន្តជំរុញឱ្យមានកំណើនទិន្នផលសរុប។ បើតាម រយៈរូបភាពទី៣ខាងក្រោមនេះ បានបង្ហាញពីគោលបំណងសមាសធាតុជាច្រើននៃប្រព័ន្ធហិរញ្ញវត្ថុ និងភ្នាក់ងារដែលបានចូលរួមជាសម្ព័ន្ធភាពក្នុងសេដ្ឋកិច្ច។

តើធនាគារកណ្តាលបានចូលរួមនៅក្នុងសមាសធាតុអ្វីខ្លះ? ចម្លើយគឺថាមានការចូលរួមជាមួយបណ្តាភ្នាក់ងារទាំងអស់ មានភ្នាក់ងារខ្លះចូលរួមដោយផ្ទាល់ និងមានភ្នាក់ងារខ្លះចូលរួមដោយប្រយោល។ សូមមើលរូបភាពទី៣ បង្ហាញពីធនាគារកណ្តាល ដែលកាន់កាប់មូលប័ត្របំណុល (debt securi-ties) និងប្រាក់បញ្ញើ (issues deposits) ហើយធនាគារកណ្តាលក៏ពាក់ព័ន្ធនឹងទីផ្សារអន្តរធនាគារផងដែរ។ តើអ្វីដែលធនាគារកណ្តាល មិនអាចបង្ហាញបាន គឺសកម្មភាពរបស់ធនាគារកណ្តាលនៅក្នុងទីផ្សារហិរញ្ញវត្ថុក្នុងនាមជាអ្នកទិញ និងអ្នកលក់មូលប័ត្រជាក់លាក់មួយ ដែលហៅថាប្រតិបត្តិការទីផ្សារបើកចំហ (OMO) និងតួនាទីសំខាន់របស់ធនាគារកណ្តាលក្នុងការបង្កើតថ្លៃ និងបង្កើតរូបិយវត្ថុ។

គំនូសតាងទី៣ បង្ហាញពីៈ សមាសធាតុនៃប្រព័ន្ធហិរញ្ញវត្ថុ (Element of financial system)




រូបភាពទី២ មិនបង្ហាញពីគោលបំណងរួមរបស់ធនាគារកណ្តាលឡើយ។ យើងនឹងសិក្សាអំពីបញ្ហាទាំងអស់នេះ។ យើងចាប់ផ្តើមសិក្សាជាមួយនឹងគោលបំណងរួមរបស់ធនាគារកណ្តាល។

## ២.៥- ធនាគារកណ្ដាល៖ ស្ថិរភាពហិរញ្ញវត្ថុ (Central banking: financial stability)

ការសិក្សាទាំងនេះ មាននៅក្នុងផ្នែកខាងក្រោម៖

- កម្មវត្ថុនៃស្ថិរភាពហិរញ្ញវត្ថុ
- តើអ្វីជាស្ថិរភាពហិរញ្ញវត្ថុ?
- តើអ្វីជាតម្លៃខាងក្រៅរូបិយវត្ថុ?
- តើស្ថិរភាពហិរញ្ញវត្ថុសម្រេចបានដោយរបៀបណានៅក្នុងស្រុក?
- ការផ្តោតអារម្មណ៍នៅទូទាំងពិភពលោក

### ២.៥.១- កម្មវត្ថុនៃស្ថិរភាពហិរញ្ញវត្ថុ (Objective of financial stability)

ស្ថិរភាពហិរញ្ញវត្ថុមានពីរកត្តាសំខាន់៖

- ស្ថិរភាពថ្លៃ (Price stability)
- លក្ខខណ្ឌស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុ (Stable conditions in the financial system)

ស្ថិរភាពថ្លៃ (Price stability)៖ គឺឱ្យមានកម្រិតទាប និងស្ថិរភាព (មិនប្រែប្រួល) ក្នុងកម្រិតថ្លៃទូទៅសំដៅដល់អត្រាអតិផរណា។ ជាប្រវត្តិសាស្ត្របានបង្ហាញថានៅពេលអតិផរណាទាប វាមាននិន្នាការមិនងាយនឹងបង្កហានិភ័យនោះទេ។ *តើអតិផរណាទាបគឺជាអ្វី?* នៅបណ្ដាប្រទេសភាគច្រើនលើពិភពលោកមានទំនោរចង់បានអតិផរណាប្រមាណពី ២-៣% ប្រចាំឆ្នាំ។ ហេតុអ្វីបានជាអត្រាអតិផរណាប្រចាំឆ្នាំ ២-៣% ហើយគ្មានអត្រាអតិផរណា ០% ប្រចាំឆ្នាំ? គណៈកម្មាធិការវាយតម្លៃមិនមានបញ្ហាតែមួយនេះទេ។ ប៉ុន្តែបញ្ហាសេដ្ឋកិច្ចបច្ចុប្បន្នបានកំណត់អត្រាអតិផរណា ០% ប្រចាំឆ្នាំ គឺនៅជិតនឹងកម្រិតបរិត្តផរណា (ការធ្លាក់ចុះថ្លៃបានជះឥទ្ធិពលអវិជ្ជមានយ៉ាងខ្លាំងទៅលើការចំណាយ និងការ វិនិយោគ) និងអត្រាអតិផរណា ២-៣% ប្រចាំឆ្នាំ គឺអាចអនុគ្រោះឱ្យបាន និងអាចរក្សាកម្រិតបរិត្តផរណាបាន។

*សំណួរដាក់ស្តែង*៖ គឺថាហេតុអ្វីបានជាអាចទទួលយកបានអត្រាអតិផរណាប្រមាណចន្លោះពី ២-៣% ប្រចាំឆ្នាំ? ចម្លើយគឺថានៅក្នុងកម្រិតអតិផរណានេះមិនមានផលប៉ះពាល់ដល់ដំណើរការសម្រេចចិត្តរបស់អង្គភាពសេដ្ឋកិច្ចនោះទេ។ នេះមានន័យថាការចាប់អារម្មណ៍របស់អាជីវកម្ម គឺផ្តោតទៅលើផលិតកម្ម ហើយមិនត្រូវបង្វែរទិសទៅរកការខិតខំ ដើម្បីការពារការបាត់បង់អំណាចទិញនោះទេ។

ផលប៉ះពាល់នៃកម្រិតអត្រាអតិផរណាខ្ពស់លើកំណើនផលិតផលក្នុងស្រុកសរុប គឺត្រូវបានគេដឹងលឺ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនៃទសវត្សរ៍ដំបូងនៃសតវត្សរ៍ទី២០នេះ ឧទាហរណ៍ប្រទេសអាហ្វ្រិកបានកត់ត្រានូវអត្រាអតិផរណាខ្ពស់បំផុត ដែលមិនធ្លាប់មានប្រមាណ ៧ ០០០ ០០០ ០០០ ០០០ ០០០ ០០០ ហើយផលិតផលក្នុងស្រុកសរុបបានរួញតូចប្រមាណ ៥០% និងអត្រាអនិកម្មភាពបានកើនឡើងដល់ ៩០%។ *តើនេះអាចជាមេរៀនដែរឬទេ?* អត្រាអតិផរណាគួរតែទាប ដូច្នេះវាមិនមែនជាកត្តាសំខាន់ក្នុងការសម្រេចចិត្តខាងសេដ្ឋកិច្ចនោះទេ។

លក្ខខណ្ឌស្ថិរភាព (Stable conditions)៖ ក្នុងប្រព័ន្ធហិរញ្ញវត្ថុត្រូវបានសម្រេចនៅពេលដែលមានទំនុកចិត្តខ្ពស់ថាអន្តរការីហិរញ្ញវត្ថុ និងទីផ្សារហិរញ្ញវត្ថុមានស្ថិរភាពពេល គឺអាចបំពេញកាតព្វកិច្ចដោយគ្មានការរំខានដល់សកម្មភាពសេដ្ឋកិច្ច។ នេះពុំមានន័យថា ស្ថាប័នហិរញ្ញវត្ថុនីមួយៗ សុទ្ធតែមិនអាចទទួលបរាជ័យនោះឡើយ។ ប្រព័ន្ធហិរញ្ញវត្ថុ គឺមិនអាចស្ថិតស្ថេរនោះទេ លុះត្រាតែការបរាជ័យជាប្រព័ន្ធដែលមានលទ្ធផលកម្រិតខ្ពស់។ ធាតុផ្សំទាំងពីរនៃស្ថិរភាពហិរញ្ញវត្ថុមានទំនាក់ទំនងនឹងគ្នា។ ធនាគារកណ្តាលផ្តោតជាសំខាន់ទៅលើ៖

*"ធាតុផ្សំពីរនៃស្ថិរភាពហិរញ្ញវត្ថុ ពោលគឺស្ថិរភាពថ្លៃ និងស្ថិរភាពហិរញ្ញវត្ថុមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ។ ការខកខានមិនបានថែរក្សាធាតុមួយក្នុងចំណោមធាតុទាំង២នេះ ផ្តល់នូវប្រតិបត្តិការដែលមិនច្បាស់លាស់សម្រាប់មូលហេតុដែលកំពុងដំណើរការនៅក្នុងទិសដៅទាំងពីរ។ ឧទាហរណ៍៖ អតិផរណាខ្ពស់អាចនាំឱ្យមានគោលនយោបាយរូបិយវត្ថុតឹងរឹង អត្រាការប្រាក់ខ្ពស់ជាងមុន និងការកើនឡើងនូវប្រាក់កម្ចីមិនដំណើរការរបស់ធនាគារ និងការធ្លាក់ចុះនៃតម្លៃទ្រព្យ និងវត្ថុបញ្ចាំដែលអាចធ្វើឱ្យធនាគារ និងការបរាជ័យផ្សេងទៀតនៅក្នុងវិស័យហិរញ្ញវត្ថុ។ ផ្ទុយទៅវិញ ការរំខាននៅក្នុងប្រព័ន្ធហិរញ្ញវត្ថុនឹងធ្វើឱ្យយន្តការបញ្ជូនគោលនយោបាយរូបិយវត្ថុមិនសូវមានប្រសិទ្ធភាព ហើយអាចប៉ះពាល់ដល់ការផ្លាស់ប្តូរកម្រិតថ្លៃទូទៅ "*

## ២.៥.២- តើអ្វីជាស្ថិរភាពហិរញ្ញវត្ថុ? (Why financial stability?)

ស្ថិរភាពហិរញ្ញវត្ថុត្រូវបានចាត់ទុកថាមានសារសំខាន់ចំពោះសមិទ្ធិផលនៃកំណើនសេដ្ឋកិច្ច និងកម្រិតការងារកើនខ្ពស់ប្រកបដោយនិរន្តរភាព។ ស្ថិរភាពហិរញ្ញវត្ថុគឺជាមូលដ្ឋានគ្រឹះនៃការបង្កើតបរិយាកាសសេដ្ឋកិច្ច ដែលជាអំណោយផលដល់ការធ្វើអាជីវកម្ម ពោលគឺទាំងសងខាងនៃផលិតផលក្នុងស្រុកសរុបរួមមានផ្នែកតម្រូវការ និងផ្នែកការផ្គត់ផ្គង់៖

តាមរយៈរូបមន្ត៖

- C + I = GDE + X - M = GDP
- C + I = DD (domestic demand)
- x – M = TAB (trade account balance)
- C + I = GDP
- GDE + TAB = GDP (expenditure on)

## ២.៥.៣- តើអ្វីជាតម្លៃខាងក្នុង និងខាងក្រៅរូបិយវត្ថុ?

### ២.៥.៣.១- តម្លៃខាងក្នុងរបស់រូបិយវត្ថុ

តម្លៃនៃរូបិយវត្ថុមាន ២យ៉ាងគឺ៖ តម្លៃខាងក្នុងរបស់រូបិយវត្ថុ និងតម្លៃខាងក្រៅរបស់រូបិយវត្ថុ។ តម្លៃខាងក្នុងរបស់រូបិយវត្ថុ គឺជាកម្លាំងទិញរបស់រូបិយវត្ថុសម្រាប់ទំនិញ និងសេវាកម្មក្នុងបរិមាណថេរណា

មួយ។ តម្លៃនៃរូបិយវត្ថុមានទំនាក់ទំនងច្រាសសមាមាត្រគ្នាជាមួយនឹងកម្រិតថ្លៃ។ ប្រសិនបើកម្លាំងថ្លៃកើនឡើងនាំឱ្យតម្លៃរូបិយវត្ថុធ្លាក់ចុះ។

រូបមន្តតម្លៃរូបិយវត្ថុគឺៈ តម្លៃរូបិយវត្ថុ = ១/កម្រិតថ្លៃ។ កម្រិតថ្លៃ ត្រូវបានវាស់តាមរយៈសន្ទស្សន៍ថ្លៃរបស់ទំនិញ និងសេវាកម្មដែលប្រើប្រាស់។ ដើម្បីគណនាសន្ទស្សន៍ថ្លៃ គេជ្រើសរើសយកទំនិញ និងសេវាកម្មប្រើប្រាស់សំខាន់ៗមួយចំនួន ដែលតំណាងឱ្យការប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់គ្រួសារមករៀបចំបញ្ចូលក្នុងកន្ត្រក់ទំនិញ ដោយកត់ត្រានូវថ្លៃឯកតារបស់ទំនិញ និងសេវាកម្មនីមួយៗគិតតាមថ្លៃលក់រាយលើទីផ្សាររួមគណនារកចំណែកជាភាគរយនៃការចំណាយទិញទំនិញ និងសេវាកម្មនីមួយៗធៀបនឹងការចំណាយសរុបសម្រាប់ការទិញទំនិញ និងសេវាកម្មទាំងអស់សម្រាប់មួយកន្ត្រក់ទំនិញ។ តម្លៃរូបិយវត្ថុ ឬអំណាចទិញរបស់រូបិយវត្ថុមានប្រែប្រួលទៅតាមអត្រាអតិផរណា (ការប្រែប្រួលជាភាគរយនៃសន្ទស្សន៍ថ្លៃ)។ ឥទ្ធិពលនៃការប្រែប្រួលកម្រិតថ្លៃបណ្តាលឱ្យមានការប្រែប្រួលតម្លៃរូបិយវត្ថុ អាចដោយសារតែមូលហេតុសំខាន់ៗ មានដូចជាៈ

- ការប្រែប្រួលនៃបរិមាណការផ្គត់ផ្គង់រូបិយវត្ថុ
- ការប្រែប្រួលនៃតម្រូវការសរុប និងការប្រែប្រួលថ្លៃផលិតកម្ម

មានកត្តាដទៃទៀតដែលមានឥទ្ធិពលលើការប្រែប្រួលកម្រិតថ្លៃបណ្តាលឱ្យមានការប្រែប្រួលតម្លៃរូបិយវត្ថុជះឥទ្ធិពលទៅដល់ៈ

- ការវិភាជន៍ធនាគារ
- ការងារធ្វើ និងការបែងចែកចំណូលចំណាយ

### ២.៥.៣.២- តម្លៃខាងក្រៅរបស់រូបិយវត្ថុ

តម្លៃខាងក្រៅរបស់រូបិយវត្ថុជាអត្រាប្តូរប្រាក់ (exchange rate)។ អត្រាប្តូរប្រាក់ គឺជាតម្លៃរូបិយប័ណ្ណមួយធៀបនឹងតម្លៃរូបិយប័ណ្ណមួយផ្សេងទៀតប៉ុណ្ណោះ។ អត្រាប្តូរប្រាក់ មានកម្រិតខុសគ្នារវាងអត្រាទិញចូល (bid price) នឹងអត្រាលក់ចេញ (asked price)។ អត្រាប្តូរប្រាក់មធ្យម (middle rate) ជាអត្រាគិតជាមធ្យមរវាងអត្រាទិញចូល និងអត្រាលក់ចេញ។ អត្រាប្តូរប្រាក់ជាក់ស្តែង (spot rate) គឺជាអត្រាប្តូរប្រាក់ដែលត្រូវបានប្រើប្រាស់នៅក្នុងខណៈទូទាត់។ អត្រាប្តូរប្រាក់ផ្លូវការ ត្រូវបានកំណត់ឡើងដោយធនាគារជាតិ។ ចំពោះអត្រាប្តូរប្រាក់ទីផ្សារ (market exchange rate) អាចប្រែប្រួលទៅតាមស្ថានភាពនៃការផ្គត់ផ្គង់ និងតម្រូវការរូបិយវត្ថុ។

### ២.៥.៣.៣- របបនៃអត្រាប្តូរប្រាក់

របបនៃអត្រាប្តូរប្រាក់មានៈ

- អត្រាប្តូរប្រាក់អណ្តែត (floating/flexible exchange rate) គឺជាអត្រាប្តូរប្រាក់ដែលអាចកើនឡើង ឬធ្លាក់ចុះតាមយន្តការរបស់ទីផ្សារប្តូរប្រាក់។

- អត្រាប្តូរប្រាក់ថេរ (fixed exchange rate) គឺសំដៅលើអត្រាប្តូរប្រាក់អណ្តែតក្រោមការគ្រប់គ្រង (managed float) របស់ធនាគារកណ្តាលតាមរយៈការធ្វើអន្តរាគមន៍រូបិយវត្ថុ ដោយទិញ ឬលក់រូបិយប័ណ្ណ ដើម្បីរក្សាអត្រាប្តូរប្រាក់ឱ្យមានស្ថិរភាពក្នុងកម្រិតណាមួយ។

### ២.៥.៣.៤- ឥទ្ធិពលនៃការប្រែប្រួលអត្រាប្តូរប្រាក់

កត្តាកំណត់នៃការប្រែប្រួលអត្រាប្តូរប្រាក់ គឺជាការប្រែប្រួលជញ្ជីងពាណិជ្ជកម្មដែលអាចបណ្តាលមកពី៖

- ការប្រែប្រួលនូវការនិយមការប្រើប្រាស់ (consumer preference)
- ការប្រែប្រួលកម្រិតប្រាក់ចំណូល (related income)
- ការប្រែប្រួលកម្រិតផលិតភាព (related productive)
- ការប្រែប្រួលកម្រិតថ្លៃ (related price level)
- ការប្រែប្រួលអត្រាការប្រាក់ពិត (real interest rate)
- ការអន្តរាគមន៍របស់ធនាគារកណ្តាលក្នុងការកែតម្រូវបរិមាណផ្គត់ផ្គង់រូបិយវត្ថុ
- ជាពិសេសការអនុវត្តគោលនយោបាយសារពើពន្ធ។

ទន្ទឹមនឹងនេះដែរ កត្តាដូចបានរៀបរាប់ទាំងនេះ ជាកត្តាដទៃផ្សេងទៀត មានឥទ្ធិពលលើការប្រែប្រួលអត្រាប្តូរប្រាក់៖

- ស្ថិរភាពថ្លៃ (price stability)
- ជញ្ជីងពាណិជ្ជកម្ម (balance on trade)
- លំហូរមូលនិធិឆ្លងដែន (Cross-border capital flows)
- កំណើនសេដ្ឋកិច្ច (Economic growth)

### ២.៥.៣.៥- ទីផ្សារប្តូរប្រាក់បរទេស

សេរីភាវូបនីយកម្ម និងសកលភាវូបនីយកម្ម បានជំរុញឱ្យមានកំណើនដ៏ធាប់រហ័សនូវលំហូរឆ្លងដែននៃទំនិញ និងសេវាកម្ម និងលំហូរមូលធនហិរញ្ញវត្ថុ។ ប្រតិបត្តការប្តូរប្រាក់ ជាការទិញលក់នូវឧបករណ៍ហិរញ្ញវត្ថុមួយចំនួនដូចជា មូលប័ត្របំណុលរយៈពេលខ្លី និងមូលប្បទានប័ត្រ។ សម្រាប់ទីផ្សារបរទេសគឺជាប្រព័ន្ធមួយ ដែលមានការចូលរួមពីសំណាក់គ្រឹះស្ថានធនាគារ ឈ្មួញកណ្តាល និងកម្រៃជើងសារ (dealers and brokes) ព្រមទាំងធនាគារកណ្តាល ដើម្បីសម្រួលដល់ការទិញលក់រូបិយប័ណ្ណបរទេសនានាជូនឯកត្តជន សហគ្រាស និងស្ថាប័នរដ្ឋាភិបាល ហើយភាគច្រើនលើសលុបនៃប្រតិបត្តិការប្តូរប្រាក់បរទេស គឺច្រើនពាក់ព័ន្ធទៅនឹងការទិញលក់ប្រាក់បញ្ញើ និងមូលប័ត្រនានាដែលចារិកជារូបិយប័ណ្ណបរទេស។ ចំពោះការទិញលក់រូបិយប័ណ្ណបរទេសក្នុងទម្រង់ជាក្រដាសប្រាក់ គឺមានបរិមាណតិចតួចប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត ប្រតិបត្តការប្តូរប្រាក់បរទេសភាគច្រើនប្រព្រឹត្តិទៅនៅតាមទីផ្សាររំលងបញ្ជា (OTC) ដោយប្រើប្រាស់ប្រព័ន្ធកុំព្យូទ័រ និងបណ្តាញទូរស័ព្ទ។

### ២.៥.៤- តើស្ថិរភាពហិរញ្ញវត្ថុសម្រេចបានដោយរបៀបណាក្នុងប្រទេសមួយ? (How is financial stability achieved domestically)?

បានកត់សម្គាល់ឱ្យឃើញថា មានកត្តាពីរសម្រាប់ស្ថិរភាពថ្លៃពេល គឺលក្ខខណ្ឌស្ថិរភាពក្នុងវិស័យហិរញ្ញវត្ថុ និងស្ថិរភាពថ្លៃ។ កាលពីអតីតរឿងនេះត្រូវបានសម្រេចដោយធនាគារកណ្តាល ដែលបានដាក់ចេញនូវវិធានការណ៍ និងមធ្យោបាយនានាមានដូចជា៖

- ជានានូវភាពអាចរកបាននៃក្រដាសប្រាក់ និងកាស ដែលកំពុងចរាចរណ៍នៅក្នុងការកំណត់តម្លៃរូបិយវត្ថុដែលងាយស្រួល ដើម្បីជាមធ្យោបាយមួយធ្វើឱ្យប្រតិបត្តិការហិរញ្ញវត្ថុមានឥទ្ធិពល។
- បង្កើតប្រព័ន្ធទូទាត់ជាតិ និងប្រព័ន្ធទូទាត់អន្តរធនាគារប្រកបដោយប្រសិទ្ធភាព។
- គាំទ្រដល់ការអភិវឌ្ឍន៍ប្រាក់ដែលមានប្រសិទ្ធិភាពសញ្ញាប័ណ្ណ និងទីផ្សារប្តូរប្រាក់បរទេស។
- ត្រួតពិនិត្យហានិភ័យហិរញ្ញវត្ថុរបស់ធនាគារ។
- គាំទ្រដល់ការអភិវឌ្ឍប្រព័ន្ធធនាគារប្រកបដោយប្រសិទ្ធភាព។
- ផ្តល់ទីកន្លែង(សាច់ប្រាក់ងាយស្រួល)ដើម្បីជួយដល់ធនាគារក្ស័យធនក្នុងកាលៈទេសៈលំបាក ដើម្បីការពារប្រព័ន្ធហិរញ្ញវត្ថុ ត្រូវបានគេស្គាល់ថាអ្នកផ្តល់ប្រាក់កម្ចីមុខងារចុងក្រោយ (មិនត្រូវច្រឡំជាមួយការរៀបចំសាច់ប្រាក់ងាយស្រួលរបស់ធនាគារ ដែលជាធាតុផ្សំគោលនយោបាយរូបិយវត្ថុ)។

ជំហានទី១ នៃស្ថិរភាពហិរញ្ញវត្ថុ និងស្ថិរភាពថ្លៃត្រូវបានសម្រេចតាមរយៈការអនុវត្តគោលនយោបាយរូបិយវត្ថុ ដើម្បីការពារតម្លៃនៃរូបិយប័ណ្ណ។ នេះគឺជាគោលដៅចម្បងរបស់ធនាគារកណ្តាល។ វាមានប្រយោជន៍ក្នុងការបង្ហាញពីទស្សនៈរបស់ធនាគារកណ្តាលលើការចូលរួមចំណែករបស់ខ្លួនចំពោះស្ថិរភាពហិរញ្ញវត្ថុ និងសមាហរណកម្មស្ថិរភាពថ្លៃ៖

*"តួនាទីរបស់ធនាគារសហព័ន្ធសហរដ្ឋ ក្នុងការអនុវត្តន៍គោលនយោបាយរូបិយវត្ថុ ត្រួតពិនិត្យធនាគារ និងផ្តល់សេវាទូទាត់ដល់ស្ថាប័នតម្កល់ប្រាក់បញ្ញើជួយរក្សាស្ថិរភាពនៃប្រព័ន្ធហិរញ្ញវត្ថុ"។*

*"ដោយប្រើឧបករណ៍គោលនយោបាយរូបិយវត្ថុនៅពេលកំណត់វា ធនាគារកណ្តាលសហព័ន្ធអាចលើកកម្ពស់ និងរក្សាស្ថិរភាពថ្លៃ និងកាត់បន្ថយការឡើងចុះឱ្យសមស្របក្នុងសកម្មភាពសេដ្ឋកិច្ចដែលជួយលើកកម្ពស់សុខមាលភាព និងស្ថិរភាពនៃស្ថាប័នហិរញ្ញវត្ថុ និងទីផ្សារ។ ធនាគារកណ្តាលសហព័ន្ធក៏ជួយលើកកម្ពស់ស្ថិរភាពហិរញ្ញវត្ថុតាមរយៈការត្រួតពិនិត្យ និងបទប្បញ្ញត្តិរបស់អង្គការលេខធនាគារជាច្រើនប្រភេទ ដើម្បីជានាសុវត្ថិភាព និងភាពរឹងមាំរបស់ពួកគេ។ លើសពីនេះទៀត ធនាគារកណ្តាលសហព័ន្ធដំណើរការយន្តការទូទាត់សំខាន់ៗមួយចំនួន និងត្រួតពិនិត្យប្រតិបត្តិការនៃប្រព័ន្ធទូទាត់ ដោយមានគោលដៅពង្រឹងស្ថិរភាពប្រព័ន្ធទូទាត់"។*

*"នៅពេលដែលការគំរាមកំហែងដល់ស្ថិរភាពនៃប្រព័ន្ធហិរញ្ញវត្ថុត្រូវបានគេដឹងថា មានវត្តមានធនាគារអាចធ្វើអន្តរាគមន៍ ដើម្បីទ្រទ្រង់វាំងអន្តរការី និងទីផ្សារ ដើម្បីសម្រួលដល់ការទូទាត់ និងសំណង ដែលអាចនឹងមិនត្រូវបានបិទបញ្ចប់។ ក្នុងករណីធ្ងន់ធ្ងរការគាំទ្រផ្នែកហិរញ្ញវត្ថុបន្ទាន់ពី*

*ធនាគារ អាចត្រូវបានគេផ្តល់ជូន ដែលហៅថាមុខងារអ្នកផ្តល់ប្រាក់កម្ចីចុងក្រោយ ប៉ុន្តែនេះត្រូវបានធ្វើនៅពេល ដែលការបរាជ័យនៃស្ថាប័នមួយអាចធ្វើឱ្យស្ថាប័នផ្សេងទៀតធ្លាក់ចុះ បើមិនដូច្នេះទេ មិនអាចទទួលយកបាន។ មុខងារនេះ អាចពាក់ព័ន្ធនឹងការឱ្យខ្ចីប្រាក់របស់ធនាគារទៅស្ថាប័ន ដែលបរាជ័យដើម្បីការពារការបរាជ័យរបស់ខ្លួន ហេតុដូច្នេះហើយ ដើម្បីបញ្ឈប់ផលប៉ះពាល់នៃការដួលរលំរបស់វាពីការរីករាលដាលតាមរយៈប្រព័ន្ធហិរញ្ញវត្ថុ។ បណ្តាញសុវត្ថិភាពនេះ មានដើម្បីការពារស្ថិរភាពនៃប្រព័ន្ធហិរញ្ញវត្ថុទាំងមូល និងមិនមែនដើម្បីការពារស្ថាប័ននីមួយៗ ឬគ្រប់គ្រងពួកគេ និងម្ចាស់ភាគហ៊ុនឡើយ"។*

*"ការប្រើប្រាស់មុខងារ LOLR របស់ធនាគារត្រូវតែមានភាពត្រឹមត្រូវដោយយកចិត្តទុកដាក់ចំពោះការខូចខាត ដែលអាចបណ្តាលមកពីប្រព័ន្ធហិរញ្ញវត្ថុ និងសេដ្ឋកិច្ចកាន់តែធំទូលាយ ប្រសិនបើការធ្វើអន្តរាគមន៍មិនបានកើតឡើង។ នេះក៏ព្រោះតែតួនាទីរបស់ LOLR តម្រូវឱ្យមានការប្រើប្រាស់ថវិកាសាធារណៈ ហើយក៏អាចលើកទឹកចិត្តដល់ការប្រថុយប្រថានហួសហេតុ (ហេតុដូចនេះភាពផុយស្រួយផ្នែកហិរញ្ញវត្ថុ) ប្រសិនបើស្ថាប័ននានាជឿជាក់ថាពួកគេនឹងជួយសង្គ្រោះនៅពេលណា ដែលពួកគេជួបការលំបាក។ ហានិភ័យទាំងនេះ មានន័យថាធនាគារ និង FSA ត្រូវការសហការយ៉ាងជិតស្និទ្ធនៅពេលមានបញ្ហាកើតឡើង ហើយជូនដំណឹងដល់រតនាគារ"។*

### ២.៥.៥- ការចាប់អារម្មណ៍ជាសកល ( Worldwide focus )

ស្ថិរភាពហិរញ្ញវត្ថុមានការចាប់អារម្មណ៍នៅទូទាំងពិភពលោក ដែលជាមូលដ្ឋានគ្រឹះនៃប្រព័ន្ធហិរញ្ញវត្ថុរបស់ពិភពលោក ដែលមានទំនាក់ទំនងគ្នាទៅវិញទៅមក។ បញ្ហានេះមានការឆ្លងកាត់ព្រំដែនរវាងគ្នាទៅវិញទៅមក។ ហើយថ្មីៗនេះការផ្តោតអារម្មណ៍ទាំងនេះ ដោយសារការវិវត្តនៃកត្តាមួយចំនួនដូចជា៖

- មានវិបត្តិសេដ្ឋកិច្ចខ្លះនៅចុងសតវត្សរ៍ទី២០ និងដើមសតវត្សរ៍ទី២១
- នវានុវត្តន៍ហិរញ្ញវត្ថុ ដែលជំរុញដោយការបង្កើតឥតឈប់ឈរ
- ជឿនលឿនផ្នែកបច្ចេកវិទ្យា
- ការពឹងអាស្រ័យគ្នាទៅវិញទៅមកនៃសេដ្ឋកិច្ចពិភពលោក

ការវិវត្តទាំងនេះបាននាំឱ្យមានស្ថិរភាពហិរញ្ញវត្ថុជាអន្តរជាតិខ្លះផងដែរ។ ជាឧទាហរណ៍ គឺជាគំនិតផ្តួចផ្តើម ដើម្បីទទួលយកនូវស្តង់ដារគន្លឹះសម្រាប់ប្រព័ន្ធហិរញ្ញវត្ថុល្អ ដោយស្ថាប័នដូចជាមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ធនាគារពិភពលោក (WB) ប្រទេស G20 និងគណៈកម្មាធិការបាហ្សល (រួមមានG20 ដែរ)។ វិស័យទាំងនេះគ្របដណ្តប់លើ៖

- តម្លាភាពគោលនយោបាយរូបិយវត្ថុ និងហិរញ្ញវត្ថុ
- តម្លាភាពគោលនយោបាយសារពើពន្ធ
- ការផ្សព្វផ្សាយទិន្នន័យ
- បញ្ហាក្ស័យធន
- រដ្ឋាភិបាលសាជីវកម្ម

- គណនេយ្យ និងសវនកម្ម
- ការទូទាត់ និងសំណង់
- សុចរិតភាពទីផ្សារ
- គ្រប់គ្រងធនាគារ
- បទប្បញ្ញត្តិស្តីពីមូលប័ត្រ
- ត្រួតពិនិត្យជានារ៉ាប់រង
- គ្រប់គ្រងបំណុលសាធារណៈ

សរុបសេចក្តី វាមានប្រយោជន៍ដោយបានដកស្រង់សុន្ទរកថាសំខាន់ៗរបស់ប្រធាន និងនាយកប្រតិបត្តិនៃធនាគារសហព័ន្ធនៃទីក្រុងញូវយ៉ក (ថ្លែងនៅសន្និសីទអន្តរជាតិនៃការគ្រប់គ្រងធនាគារនៅបាហ្សល ប្រទេសស្វីស)។ គាត់បាននិយាយថា៖

*"នៅក្នុងពិភពលោក ទំនាក់ទំនងទីផ្សារឧបករណ៍ហិរញ្ញវត្ថុ និងហានិភ័យកាន់តែមានភាពស្មុគស្មាញ ការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព គឺមានសារសំខាន់ជាងពេលណាទាំងអស់ ដើម្បីរក្សាស្ថិរភាពហិរញ្ញវត្ថុទាំងក្នុង និងក្រៅប្រទេស។ ដើម្បីរក្សាប្រសិទ្ធិភាព និងពាក់ព័ន្ធអ្នកត្រួតពិនិត្យ ត្រូវយល់ពីរបៀប និងទំហំសេដ្ឋកិច្ច និងបច្ចេកវិទ្យាផ្សេងទៀត ដែលកំពុងផ្លាស់ប្តូរធនាគារ និងហិរញ្ញវត្ថុ...យើងត្រូវតែយកចិត្តទុកដាក់ជាកិច្ចខិតខំប្រឹងប្រែងរបស់យើង ដើម្បីធានាបាននូវប្រតិបត្តិការប្រកបដោយសុវត្ថិភាព និងត្រឹមត្រូវនៃទីផ្សារហិរញ្ញវត្ថុកុំរាំងការច្នៃប្រឌិត និងបង្កើនការច្នៃប្រឌិត ដែលកំពុងផ្លាស់ប្តូរធនាគារ និងហិរញ្ញវត្ថុជំនួសឱ្យពិភពលោកពិតសម្រាប់ធនាគារ និងហិរញ្ញវត្ថុកាន់តែប្រសើរ"។*

## ២.៦- តារាងតុល្យការរបស់ធនាគារកណ្តាល (Balance sheet of central bank)

តារាងតុល្យការរបស់ធនាគារកណ្តាលឆ្លុះបញ្ចាំងអំពីសកម្មភាពរបស់ធនាគារកណ្តាល។

១- ផ្នែកទ្រព្យសកម្ម៖

- មូលប័ត្ររដ្ឋាភិបាលមានចំណែកយ៉ាងច្រើន នៅក្នុងទ្រព្យសកម្មរបស់ធនាគារកណ្តាល (Fed) នៅសហរដ្ឋអាម៉េរិក មូលប័ត្ររដ្ឋាភិបាលមានចំណែកជាង ៨០% នៃទ្រព្យសកម្មសរុបរបស់ធនាគារកណ្តាលតាមតំបន់ទាំងអស់។
- ការឱ្យកម្ចីតាមបង្អួចអប្បហារ (Discount window loans) ដែលធនាគារកណ្តាលផ្តល់ឱ្យធនាគារពាណិជ្ជ និងគ្រឹះស្ថានទទួលប្រាក់បញ្ញើដទៃ។ ការឱ្យកម្ចីនេះច្រើនមានចំណែកតិចតួចប៉ុណ្ណោះនៅក្នុងទ្រព្យសកម្ម។
- មាស និងលោហៈធាតុមានតម្លៃ ដែលមួយផ្នែកតម្កល់ទុកនៅធនាគារក្រៅប្រទេសកាលពីយុគស្តង់ដារមាស។
- ទុនបម្រុងជារូបិយប័ណ្ណបរទេស ដែលមានមូលប័ត្រចារឹកជារូបិយប័ណ្ណបរទេស ព្រមទាំងប្រាក់បញ្ញើ និងសាច់ប្រាក់ជារូបិយប័ណ្ណបរទេសសម្រាប់ប្រើប្រាស់ក្នុងការធ្វើអន្តរាគមន៍ ដើម្បីរក្សាស្ថិរភាពអត្រាប្តូរប្រាក់។

- ការផ្តល់ហិរញ្ញប្បទានចំពោះការបង់កូតាសសមាជិករបស់អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិគិតជាសិទ្ធិដកហូតពិសេស(SDR)។
- សាច់ប្រាក់ ដែលពុំទាន់ត្រូវបានផាត់ទាត់។

២- ផ្នែកទ្រព្យអកម្ម៖

ក្រដាសប្រាក់ ដែលត្រូវបានផ្សាយចេញដោយធនាគារកណ្តាល។

- ប្រាក់បញ្ញើជាប្រាក់បម្រុងធនាគារដែលមានប្រាក់បម្រុងកាតព្វកិច្ច និងប្រាក់ទុនបម្រុងអតិរេក។
- ប្រាក់បញ្ញើរបស់រដ្ឋាភិបាលក្នុងស្រុក និងប្រាក់បញ្ញើរបស់ស្ថាប័នផ្លូវការ ដូចជាប្រាក់បញ្ញើរបស់ធនាគារកណ្តាល និងរដ្ឋាភិបាលនៃប្រទេសដទៃជាដើម។
- ដើមទុនធនាគារកណ្តាល ដែលមានកម្រិតមួយដ៏ទាបធៀបទៅនឹងទ្រព្យសកម្មសរុប។

តារាងតុល្យការរបស់ធនាគារកណ្តាលត្រូវបានបង្កើតឡើង មានសមីការដូចខាងក្រោមនេះ៖

**ទ្រព្យសកម្ម ( Assets ) = បំណុល( Liabilities ) + មូលធន (Equity)**

យើងបានបង្ហាញអំពីសមាសធាតុតារាងតុល្យការទូទៅរបស់ធនាគារកណ្តាល មានសមីការទ្រព្យសកម្ម = គណនីបំណុល + គណនីមូលធន។ សមាសធាតុនៃតារាងតុល្យការនេះ មិនអើពើពីស្តុករូបិយវត្ថុ (គណនីដើមទុន និងគណនីទុនបម្រុង) គណនីបំណុល "ផ្សេងៗទៀត" នោះទេ (ម្ចាស់បំណុលការកែសម្រួលវាយតម្លៃទុនបម្រុង។ល។ និងទ្រព្យសកម្មគណនីអាចទទួលបានក្នុងការផ្ទេរ។ល។ ពីព្រោះទាំងនេះមិនមានសារសំខាន់ក្នុងរបាយការណ៍ធំទូលាយរបស់ធនាគារកណ្តាល (សូមមើលតារាងតុល្យភាពលេខ១)។

យើងក៏បង្ហាញតារាងតុល្យភាពទូទៅនៃវិស័យធនាគារឯកជន ដើម្បីបង្ហាញពីទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងធនាគារកណ្តាលនឹងធនាគារឯកជន (សូមមើលតារាងតុល្យភាពលេខ ២)។

| BALANCE SHEET 1: CENTRAL BANK (USD BILLIONS) | | | |
|---|---|---|---|
| Assets | | Liabilities | |
| | | A. Notes and coins | 1,000 |
| | | B. Deposits | |
| E. Foreign assets | 1,000 | 1. Government | 900 |
| | | 2. Bank's reserves (TR) | 500 |
| F. Loans to government | 1,100 | Required reserves (RR) (500) | |
| | | Excess reserves (ER) (0) | 50 |

| | | | |
|---|---|---|---|
| G. Loans to banks ( BR ) @ KIR | 400 | C. Foreign loans<br>D. Central bank securities | 50 |
| Total | 2,500 | Total | 2,500 |

| BALANCE SHEET 2: BANKS ( USD BILLIONS ) | | | |
|---|---|---|---|
| Assets | | Liabilities | |
| C. Notes and coins | 100 | | |
| D. Reserves with CB ( TR ) | | | |
| Required reserves ( RR ) ( 500 ) | 500 | A. Deposits of NBPS | 5,000 |
| Excess reserves ( ER ) ( 0 ) | | | |
| F. Loans to government | 1,000 | B. Loans from CB ( BR ) | 400 |
| G. Loans to NBPS | 3,800 | | |
| Total | 5,400 | Total | 5,400 |

កត់ចំណាំថាសមាសធាតុនៅក្នុងតារាងតុល្យការទាំងពីរ ត្រូវបានគូសបញ្ជាក់។ កត់សម្គាល់ផងដែរថាឯកតារូបិយវត្ថុ គឺជាការប្រឌិតកម្មនៅក្នុងស្រុក។ ដោយប្រើលេខកូដរូបិយប័ណ្ណគឺ UDS ( ដូចជា USD, GBP, EUR, JPY, ZAR ជាដើម )។

## ២.៦.១- គណនីបំណុល ( Liabilities )

### ២.៦.១.១- ក្រដាសប្រាក់ និងកាស ( Notes and Coins )

នៅបណ្ដាប្រទេសភាគច្រើន មានក្រុមហ៊ុនសម្រាប់ផលិតក្រដាសប្រាក់ និងកាស ( ជាក្រុមហ៊ុនផលិត) ដែលជាទូទៅក្រុមហ៊ុនទាំងនេះ គឺជាបុត្រសម្ព័ន្ធរបស់ធនាគារកណ្ដាល។ ហើយបរិមាណទឹកប្រាក់ប្រភេទទាំងនេះ ឆ្លុះបញ្ចាំងពីបរិមាណសរុបក្រដាសប្រាក់ និងកាស (N&C) ដែលចេញផ្សាយដោយធនាគារកណ្ដាល ដូចក្នុងឧទាហរណ៍នេះ ១,០០០ពាន់លានដុល្លារ។ នេះមិនមែនត្រឹមតែជាបរិមាណទឹកប្រាក់ក្រដាស និងកាសទេ ប៉ុន្តែនេះជាបរិមាណសរុប ត្រូវបានចេញផ្សាយឱ្យប្រើដល់គ្រឹះស្ថាន ធនាគារ និងសាធារណៈតាមរយៈភ្នាក់ងារគ្រឹះស្ថានធនាគារ។ នៅពេលដែលគ្រឹះស្ថានធនាគារទិញក្រដាសប្រាក់ និងកាស (N&C) ពួកគេនឹងត្រូវបានទូទាត់ និងដោះស្រាយសំណងតាមរយៈប្រព័ន្ធទូទាត់អន្តរធនាគារ (ប្រាក់បម្រុងទុករបស់គ្រឹះស្ថានធនាគារ យើងនឹងសិក្សានៅពេលក្រោយ)។ តាមបណ្ដាប្រទេសភាគច្រើន ធនាគារកណ្ដាលជាអ្នកបោះពុម្ពផ្សាយក្រដាសប្រាក់ និងកាស (N&C)

ផ្តាច់មុខ។ សម្រាប់បទបញ្ញត្តិច្បាប់នេះ ត្រូវបានប្រើដោយធនាគារអង់គ្លេសពីប្រវត្តិសាស្ត្រដ៏យូរលង់ (អង់គ្លេសនៅឆ្នាំ១៦៩៤ ត្រូវបានគេទទួលស្គាល់ជាទូទៅក្នុងការផលិតក្រដាសប្រាក់ និងកាស (N&C) គឺរូបិយវត្ថុ។ បន្ទាប់មកទៀតប្រាក់បញ្ញើធនាគារ (Bank Deposit) បានចូលរួមជាភាគភាពនៃទ្រព្យសម្បត្តិ ដែលបានក្លាយជាមធ្យោបាយទទួលយកជាទូទៅនៃការទូទាត់ ឬជាមធ្យោបាយទូទាត់ (=និយមន័យរូបិយវត្ថុ)។

ដូច្នេះ ស្តុករូបិយវត្ថុ (ហៅថាប្រភេទរូបិយវត្ថុ M3 រួមមានទាំងប្រាក់បញ្ញើធនាគារទាំងអស់របស់ប្រាក់បញ្ញើធនាគារ) គឺជាផលបូករវាង N&C + BD ដែលបានកាន់កាប់ដោយវិស័យឯកជនមិនមែនជាធនាគារនៅក្នុងស្រុក ដែលប្រើពាក្យកាត់ថា "NBPS"។ ក្នុងតារាងតុល្យការលេខ ១-២៖ ប្រភេទក្រដាសប្រាក់ និងកាស (N&C) កាន់កាប់ប្រាក់សរុបដោយគណនី NBPS = UDS ១,០០០ [ចេញបោះផ្សាយដោយធនាគារកណ្តាលប្រភេទ (គណនី A) តិចជាង ១០០ដុល្លារ [កាន់កាប់ដោយធនាគារទូប្រាក់ និង ATMs (គណនី C)] = ៩០០ដុល្លារ។ ក្នុងតារាងតុល្យការលេខ២ យើងបានឃើញថាប្រាក់បញ្ញើធនាគារបានកាន់កាប់ដោយ NBPS = ៥,០០០ដុល្លារ (គណនី A)។

ដូច្នេះ៖

M3 = N&C + BD held by the NBPS

= USD 900 + USD 5,000

= USD 5,900.

គំនូសតាងទី៤ បង្ហាញពី៖ តើអ្វីជារូបិយវត្ថុ? (what is money?)




### ២.៦.២.២- ប្រាក់បញ្ញើរដ្ឋាភិបាល (Government deposit)

ក្នុងនាមជាធនាគារិករបស់រដ្ឋាភិបាល គឺមានមុខងារដ៏សំខាន់ក្នុងការគ្រប់គ្រងមូលនិធិរបស់រដ្ឋាភិបាលកណ្តាល។ ជាទូទៅរដ្ឋាភិបាលមានគណនីចំនួនពីរនៅក្នុងគណនីធនាគារកណ្តាលដែលគេហៅ

ថាគណនី (Exchequer account) និងគណនី (Payment General account) ដែលមានប្រើនៅតាមបណ្តាប្រទេសភាគច្រើន។ តាមបណ្តាប្រទេសខ្លះទៀត រដ្ឋាភិបាលកណ្តាលក៏មានធនាគារដែលជាធនាគារឯកជនធំៗចូលរួមផងដែរ។ នៅក្នុងគណនីដែលគេហៅថាគណនេយ្យពន្ធ និងគណនីកម្ចីដែលសរសេរជាអក្សរកាត់ដោយ(TLAs)។ ជាកត្តាជំរុញដ៏សំខាន់សម្រាប់ដោះស្រាយបញ្ហានេះ គឺដើម្បីចៀសវាងផលប៉ះពាល់ដែលរំខានដល់ទីផ្សាររូបិយវត្ថុនៃការប្រែប្រួលគណនីពន្ធធំៗ ដែលទាក់ទឹងទៅនឹងការចំណាយរបស់រដ្ឋាភិបាលនៅពេលជាក់លាក់ណាមួយ (តម្រូវការចាំបាច់របស់ធនាគារកណ្តាលដើម្បីសម្រួលដល់ធនាគារ)។ បណ្តាប្រទេសខ្លះទៀត គណនី (TLAs) មានការប្រែប្រួលប្រាក់បញ្ញើរបស់រដ្ឋាភិបាលរវាងធនាគារ និងធនាគារកណ្តាល ត្រូវបានប្រើជាឧបករណ៍ដ៏មានឥទ្ធិពលមួយដើម្បីជះឥទ្ធិពលទៅលើសាច់ប្រាក់ងាយស្រួលរបស់ធនាគារសម្រាប់ការអនុវត្តគោលនយោបាយរូបិយវត្ថុ។

### ២.៦.២.៣- ប្រាក់បញ្ញើធនាគារ (Bank deposit)

ធនាគារ មានគណនីពីរជាមួយធនាគារកណ្តាល៖ គណនីទុនបម្រុង (reserve account) និងគណនីទូទាត់សំណង (settlement account) ដែលមានការទូទាត់ជាមួយនឹងធនាគារកណ្តាល។ តាមបណ្តាប្រទេសខ្លះទៀត ធនាគារមានគណនីតែមួយប៉ុណ្ណោះ ដែលជាគណនីទុនបម្រុងត្រូវបានកាន់កាប់សម្រាប់ការទូទាត់ណាមួយកើតឡើង។

*តើគណនីទុនបម្រុងគឺជាអ្វី?* នៅតាមបណ្តាប្រទេសភាគច្រើន ធនាគារមានតម្រូវការទុនបម្រុងកាតព្វកិច្ច ពោលគឺមានរក្សាទុកទុនបម្រុងកាតព្វកិច្ច (RR) ស្មើនឹងចំនួនប្រាក់បញ្ញើសរុបនៃអនុបាតតម្រូវការទុនបម្រុង (r)។

RR = BD x *r*.

ពិនិត្យមើលតារាងតុល្យការលេខ១ ដល់លេខ២ បង្ហាញថាធនាគារកំពុងកាន់កាប់ប្រាក់បញ្ញើ UDS ៥,០០០ ពាន់លាន។ ប្រសិនបើយើងសន្មតថា *r* = ១០%, យើងមាន៖

RR = UDS 5,000 x 0.1

= UDS 500

តារាងតុល្យការនេះក៏បង្ហាញផងដែរថាធនាគារអនុវត្តតាមទុនបម្រុងកាតព្វកិច្ច៖ ចំនួនទឹកប្រាក់នៅក្នុងគណនីទុនបម្រុងរបស់ធនាគារ(រួម) (TR) = USD ៥០០ ។ នេះធ្វើឱ្យសមហេតុផលខាងសេដ្ឋកិច្ច ពីព្រោះធនាគារកណ្តាលមិនយកចិត្តទុកដាក់លើសមតុល្យធនាគារដោយខ្លួនឯងទេ។ ហេតុដូច្នេះធនាគារកណ្តាលរក្សាតុល្យភាពនេះឱ្យនៅអប្បបរមា ។ បើទោះយ៉ាងណា ធនាគារមានអាជីវកម្មក្នុងការផ្តល់ប្រាក់កម្ចី ហើយនេះបង្កើតប្រាក់បញ្ញើ។ ដូច្នេះ RR របស់ពួកគេកើនឡើងជាលំដាប់។ ដូច្នេះ នៅពេលដែលប្រាក់បញ្ញើពីធនាគារកើនឡើង RR របស់ពួកគេ កើនឡើងជាបន្តបន្ទាប់។ ដូច្នេះ នៅពេលដែលការដាក់ប្រាក់បញ្ញើរបស់ធនាគារកើនឡើង RR របស់ពួកគេត្រូវបានផ្តល់ដោយ៖

$$\Delta RR = \Delta BD \times r$$

ឧទាហរណ៍៖ ប្រសិនបើប្រាក់បញ្ញើពីធនាគារកើនឡើងពី UDS ៥,០០០ ដល់ UDS ៦,០០០ ដែលធនាគារមានកាតព្វកិច្ចត្រូវបង្កើនសមតុល្យ RR របស់ខ្លួនដោយUDS១០០៖

$\Delta RR = \Delta BD \times r$

= UDS 1,000 × 0.1

= UDS 100

តើពួកគេធ្វើយ៉ាងដូចម្តេច? ពួកគេមិនអាចធ្វើបានដោយខ្លួនឯងនោះទេ។ នេះគឺជាចំណុចសំខាន់នៃគោលនយោបាយរូបិយវត្ថុនៅក្នុងប្រទេសភាគច្រើន។ ធនាគារបង្កើតប្រាក់តាមរយៈធនាគារកណ្តាល (CBM) មានតែធនាគារកណ្តាលដែលអាចរៀបចំតារាងតុល្យការដោយខ្លួនឯង។ ក្នុងតារាងតុល្យការលេខ១ ដល់លេខ២ ដូចយើងដឹងថា TR = RR ។ *តើធនាគារមានទុនបម្រុងលើស (ER) ដែលផ្តល់ឱ្យដោយ TR - RR = ER?* ចម្លើយ គឺមិនថាតើពួកគេអាចជួយវាបានទេ។ ដោយសារតែពួកគេមិនមានចំណាប់អារម្មណ៍លើផ្នែកណាមួយនៃ TR ។

ទោះយ៉ាងណាក៏ដោយ មានកាលៈទេសៈពិសេសនៅពេលដែលពួកគេធ្វើ (ដូចជាក្នុងដំណាក់កាលនៃ QE នៅសហរដ្ឋអាម៉េរិកក្នុងឆ្នាំ២០១០ (ក្រោយមកទៀត ត្រូវបានអនុវត្តនៅចក្រភពអង់គ្លេស និងកន្លែងផ្សេងទៀត) ក្នុងកាលៈទេសៈទាំងនេះ អត្រាការប្រាក់ទាបជាផ្នែកគោលនយោបាយរូបិយវត្ថុពង្រីក។ ដូចបាននិយាយហើយថា ការទូទាត់ការបោសសម្អាតអន្តរធនាគារកើតឡើងលើគណនីធនាគារនៅធនាគារកណ្តាល។ *តើវាដំណើរការដោយរបៀបណា?* អតិថិជនធនាគារផ្ទេរប្រាក់បញ្ញើនៅជុំវិញប្រព័ន្ធជារៀងរាល់ថ្ងៃ។

ចុងបញ្ចប់នៃថ្ងៃ (ធនាគារបិទសៀវភៅរបស់ពួកគេជារៀងរាល់ថ្ងៃ) ចំនួនទឹកប្រាក់ត្រូវបានទូទាត់តាមរយៈគណនីទុនបម្រុង។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើធនាគារ (A) បាត់បង់សាច់ប្រាក់សុទ្ធ ១០០លានដុល្លារ និងធនាគារ (B) ទទួលបានប្រាក់ចំណេញសុទ្ធ ១០០លានដុល្លារនោះ តារាងតុល្យការរបស់ពួកគេប្រែប្រួលដូចដែលបានបង្ហាញនៅលើតារាងតុល្យការលេខ៣ ដល់លេខ៥។

| BALANCE SHEET 3: CENTRAL BANKS (USD MILLIONS) | | | |
|---|---|---|---|
| Assets | | Liabilities | |
| | | Reserve account:<br>Bank A<br>Bank B | <br>- 100<br>+ 100 |
| Total | 0 | | 0 |

| BALANCE SHEET 4: BANK A (USD MILLIONS) | | | |
|---|---|---|---|
| Assets | | Liabilities | |
| Reserve accounts at CB | - 100 | Deposits (Company A) | - 100 |
| Total | - 100 | Total | - 100 |

| BALANCE SHEET 5: BANK B ( USD MILLIONS ) | | | |
|---|---|---|---|
| Assets | | Liabilities | |
| Reserve accounts at CB | + 100 | Deposits ( Company A ) | + 100 |
| Total | + 100 | Total | + 100 |

| BALANCE SHEET 6: CENTRAL BANKS ( USD MILLIONS ) | | | |
|---|---|---|---|
| Assets | | Liabilities | |
| | | Reserve account: | |
| | | Bank A ( before interbank ) | - 100 |
| | | Bank B ( after interbank ) | + 100 |
| | | Bank A ( before interbank ) | + 100 |
| | | Bank B ( after interbank | - 100 |
| Total | 0 | Total | 0 |

| BALANCE SHEET 7: BANK A ( USD MILLIONS ) | | | |
|---|---|---|---|
| Assets | | Liabilities | |
| Reserve accounts at CB | - 100 | Deposits ( Company A ) | - 100 |
| Reserve accounts at CB | + 100 | Loan from Bank B | + 100 |
| Total | 0 | Total | 0 |

| BALANCE SHEET 8: BANK B ( USD MILLIONS ) | | | |
|---|---|---|---|
| Assets | | Liabilities | |
| Reserve accounts at CB | + 100 | | |
| Reserve accounts at CB | - 100 | Deposits ( Company A ) | + 100 |
| Loan to Bank A | + 100 | | |
| Total | + 100 | Total | + 100 |

សម្រាប់មេរៀននេះ យើងនឹងបន្តសិក្សានៅពេលក្រោយទៀត នៅពេលដែលធនាគារធ្វើប្រតិបត្តការវាងគ្នាទៅវិញទៅមក គណនីទុនបម្រុងរបស់ធនាគារពុំមានការប្រែប្រួលនោះទេ (លើកលែងតែប្រាក់កាសត្រូវបានបង្កើត = BD+)។ ទោះយ៉ាងណាក៏ដោយ នៅពេលដែលធនាគារកណ្តាលធ្វើប្រតិបត្តិការបម្រែប្រួលទុនបម្រុងនោះ ទើបគណនីធនាគារបម្រុង (BR) គឺវាមានផលប៉ះពាល់។

#### ២.៦.២.៤- មូលប័ត្ររបស់ធនាគារកណ្តាល ( Centarl bank securities )

នៅក្នុងកាលៈទេសៈចាំបាច់ ធនាគារកណ្តាលអនុវត្តប្រាក់កម្ចីពីបរទេស។ ជាទូទៅ ធនាគារកណ្តាលជួបបញ្ហាតុល្យភាពនៃគណនីទូទាត់បំណុល។

មូលប័ត្រធនាគារកណ្តាល ត្រូវបានគេឱ្យឈ្មោះជាច្រើនទៅតាមប្រទេសផ្សេងៗគ្នា។ រីឯនៅក្នុងអាហ្វ្រិកខាងត្បូង ការកិច្ចសន្យាសងបំណុលត្រូវបានហៅថាវិញ្ញាបនបត្រ ( certificates ) នៅប្រទេសបុតស្វាណា ត្រូវបានពួកគេហៅថាប័ណ្ណបំណុល ( Bills ) ជាដើម។ មូលប័ត្រទាំងនេះ គឺមូលប័ត្ររយៈពេលខ្លី ( មានកាលកំណត់តិចជាង១ឆ្នាំ ) ហើយត្រូវបានចេញផ្សាយសម្រាប់គោលបំណងគោលនយោបាយរូបិយវត្ថុតែប៉ុណ្ណោះ។ ធនាគារអ្នកបោះផ្សាយចេញវិញ្ញាបនបត្រប្រាក់បញ្ញើ ( Certificate of deposit ) ដើម្បីកៀរគរមូលនិធិរយៈពេលខ្លី ដោយពុំបាច់លក់ទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗនោះទេ មានដូចជាប័ណ្ណរតនាគារ ( treasury bill ) ជាដើម។ វិញ្ញាបនបត្រនេះ ភាគច្រើនមានតម្លៃចារិកអប្បបរមាចាប់ពី ១០០,០០០ដុល្លារឡើង និងមានកាលវសាន្តពី២សប្តាហ៍ដល់ទៅ១ឆ្នាំ។ ចំពោះប័ណ្ណបំណុលរតនាគារ ( Treasury bill, T-bill ) ជាមូលប័ត្រ ឬសញ្ញាប័ណ្ណរដ្ឋ និងអាចមានកាលវសាន្តពី១៣ ដល់ ២៦ សប្តាហ៍។ សម្រាប់ប័ណ្ណបំណុលរតនាគារនេះ ត្រូវបានលក់តាមវិធីលទ្ធកម្មជាលាយល័ក្ខអក្សរ ពោលគឺការដេញថ្លៃ និងលក់តាមតម្លៃអប្បហារធៀបនឹងតម្លៃចារិក។

## ២.៧- ការបង្កើតរូបិយវត្ថុ ( Money creation )

### ២.៧.១- គណនីទ្រព្យសកម្ម ( Assets account )

#### ២.៧.១.១- ទ្រព្យសកម្មបរទេស ( Foreign Assets )

| BALANCE SHEET 9: CENTRAL BANK ( USD BILLIONS ) | | | |
|---|---|---|---|
| Assets | | Liabilities | |
| | | A. Notes and coins | 1,000 |
| E. Foreign assets | 1,000 | B. Deposits | |
| | | 1. Government | |
| F. Loans to government | 1,100 | 2. Banks′ reserves ( TR ) | 900 |
| | | Required reserves ( RR ) ( 500 ) | 500 |
| G. Loan to banks ( BR ) @ KR | 400 | Excess reserves ( ER ) ( 0 ) | |
| | | C. Foreign loans | 50 |
| | | D. Central bank securities | 50 |
| Total | 2,500 | Total | 2,500 |

| BALANCE SHEET 10: BANKS ( USD BILLIONS ) | | | |
|---|---|---|---|
| Assets | | Liabilities | |
| C. Notes and coins | 100 | | |
| D. Reserves with CB ( RT ) | 500 | | |
| Required reserves ( RR ) ( 500 ) | | A. Deposits of NBPS | 5000 |
| Excess reserves ( ER ) ( 0 ) | | | |
| E. Loans to government | 1,000 | B. Loans from CB ( BR ) | 400 |
| F. Loans to NBPS | 3,800 | | |
| Total | 5,400 | Total | 5,400 |

ដូចបានឃើញក្នុងតារាងតុល្យការលេខ១ (សូមរំលឹកឡើងវិញក្នុងតារាងតុល្យការលេខ៩ ដើម្បីឱ្យងាយស្រួលយល់) ដែលជាទូទៅធនាគារកណ្ដាល គឺមានទ្រព្យសកម្មចំនួន៣ប្រភេទ។ ហើយទ្រព្យសកម្មបរទេសប្រភេទ (គណនី E) រួមមានការកាន់កាប់ជាមាស និងការវិនិយោគបរទេសពីបរទេស។ ជាឧទាហរណ៍៖ ប្រាក់បញ្ញើធនាគារ (ជាដុល្លារ) និងប័ណ្ណរតនាគារ (treasury bills) និងសញ្ញាប័ណ្ណ (bonds) របស់រដ្ឋាភិបាល។ ទាំងនេះ គឺជាការរក្សាទុនបម្រុងពីរូបិយប័ណ្ណបរទេសតាមបណ្ដាប្រទេសជាច្រើនដែលមានទ្រព្យសកម្មបរទេស (គណនី E) បានឆ្លុះបញ្ចាំងពីតួនាទីរបស់អ្នកថែរក្សាទុនបម្រុង ប្ដូរប្រាក់បរទេស(forex reserves)របស់ប្រទេស។ បណ្ដាប្រទេសខ្លះទៀត បញ្ចូលការវិនិយោគទាំងនេះក្នុងមូលនិធិដាច់ដោយឡែកមួយ ដែលគេហៅថាមូលនិធិអធិបតេយ្យ (sovereign fund)។

## ២.៧.១.២- ការផ្ដល់កម្ចីឱ្យដល់រដ្ឋាភិបាល (Loans to government)

ជាទូទៅ ប្រភេទ(គណនី F) ជាប្រាក់កម្ចីឱ្យដល់រដ្ឋាភិបាល មានដូចជាប័ណ្ណបំណុលរតនាគារ (treasury bills) និងសញ្ញាប័ណ្ណរដ្ឋ (government bonds) ដែលជាតម្រូវការរូបិយវត្ថុ (Money Demand)។ ក្នុងចំណោមគណនីទាំងនេះ ត្រូវបានប្រើនៅក្នុងប្រតិបត្តិការទីផ្សារបើកចំហរ ពោលគឺក្នុងការគ្រប់គ្រងសាច់ប្រាក់ងាយស្រួលរបស់ធនាគារ។ ដូចនេះ កម្ចីរបស់រដ្ឋាភិបាល មានប័ណ្ណបំណុលរតនាគារ និងប័ណ្ណបំណុលរដ្ឋតាមរយៈតម្រូវការថវិកា សម្រាប់ការគ្រប់គ្រងចំណាយហិរញ្ញវត្ថុសាធារណៈ។

## ២.៧.១.៣- ការផ្ដល់កម្ចីឱ្យដល់ធនាគារ (Loans to banks)

ប្រភេទ (គណនី G) ជាប្រាក់កម្ចីឱ្យដល់ធនាគារ គឺជាចំណុចសំខាន់នៃគោលនយោបាយរូបិយវត្ថុ។ ជាទូទៅ ធនាគារកណ្ដាលភាគច្រើនបានជំរុញឱ្យធនាគារខ្ចីប្រាក់ពីធនាគារបម្រុង (BR) ក្នុង

កម្រិតអត្រាការប្រាក់ដ៏សំខាន់ពី KIR គ្រប់ពេលវេលា។ KIR ត្រូវបានប្រើឈ្មោះជាច្រើនប្រភេទដូចជា DISCOUNT RATE, REPO RATE, BANK RATE និង BASE RATE។

ឧទាហរណ៍៖ ចំនួនទឹកប្រាក់បានខ្ចីពី KIR គឺមានបរិមាណ ៤០០ពាន់លានដុល្លារ មានន័យថា ធនាគារកំពុងអនុវត្តតាមទុនបម្រុងកាតព្វកិច្ច (RR) ដែលភាគច្រើនជាលទ្ធផលនៃធនាគារបម្រុងទុន (BR) របស់ពួកគេ។

គំនូសតាងទី៥ បង្ហាញពី៖ កម្រិតមធ្យមភាគរបស់ធនាគារ (Bank margin)




គេមើលការពិពណ៌នានេះ ការទៅប្រៀបធៀបទៅនឹងតារាង ដែលបង្ហាញតារាងតុល្យការរួមរបស់ធនាគារ (ក្នុងតារាងតុល្យការលេខ១០) នៅក្នុងរូបភាពទី៥ ។

សេចក្តីសង្ខេបនូវការអនុវត្តតាម (ព័ត៌មានលម្អិត) មានដូចខាងក្រោម៖

- ធនាគារកណ្តាលជំរុញធនាគារខ្ចីប្រាក់ពីធនាគារបម្រុង (Bank Reserve) លើទីផ្សារ KIR
- សូម្បីតែធនាគារបម្រុងទុន (BR) ជាចំណែកតូចតាចមួយនៃបំណុលក៏ដោយនៃទីផ្សារ KIR មានឥទ្ធិពលខ្លាំងលើអត្រាប្រាក់បញ្ញើរបស់ធនាគារដែរ។ នេះដោយសារតែ ធនាគារបានបំពេញពេញលេញក្នុងចំណោមធនាគារមួយផ្សេងទៀតសម្រាប់ប្រាក់បញ្ញើ ដើម្បីទូទាត់ប្រាក់សំណងទៅឱ្យធនាគារកណ្តាល ដែលអត្រាប្រាក់បញ្ញើដុំរបស់ពួកគេកើនឡើងដល់កម្រិតទាបជាងកម្រិតអត្រាទីផ្សារ KIR នោះ ។ ដូចនេះ អត្រាការប្រាក់ដុំប៉ះពាល់ដល់អត្រាលក់រាយ (retail rate) នៃទីផ្សារហិរញ្ញវត្ថុ។
- ធនាគារគឺជាអង្គភាព ដែលត្រូវរកប្រាក់ចំណេញបានច្រើនបំផុត។ ពួកគេព្យាយាមរកប្រាក់ចំណូលឱ្យបានសមាមាត្រថេររវាងអ្វី ដែលពួកគេបង់សម្រាប់ប្រាក់បញ្ញើ និងរកប្រាក់ចំណូលលើទ្រព្យសម្បត្តិ។
- ដូច្នេះ នៅពេលដែលថ្លៃដើមនៃបំណុលមានការប្រែប្រួល ធ្វើឱ្យអត្រាការប្រាក់ប្រែប្រួលសម្រាប់ប្រាក់កម្ចីរបស់ពួកគេ (ទ្រព្យសកម្មធំបំផុត) អត្រាការប្រាក់គោលសម្រាប់ប្រាក់

កម្ចីគឺជាអត្រាគោល(PR) ហើយអត្រាប្រាក់កម្ចីទាំងអស់ត្រូវបានផ្សារភ្ជាប់ទៅនឹងអត្រាគោល។

- កម្រិតនៃអត្រាការប្រាក់គោល PR (ជាពិសេសតាមលក្ខខណ្ឌជាក់ស្តែង) មានឥទ្ធិពលយ៉ាងខ្លាំងទៅលើតម្រូវការប្រាក់កម្ចី (loan)។
- តម្រូវការប្រាក់កម្ចីគឺជាសមភាគីនៃការបង្កើតរូបិយវត្ថុ (លុយ)។
- ការផ្តល់ប្រាក់កម្ចីជាថ្មី ឬការបង្កើតប្រាក់ជាថ្មីជាមូលដ្ឋានថ្មីមួយ (C + I = GDE = DD) មានកម្រិតខ្ពស់ពេកទាក់ទងទៅនឹងសមត្ថភាពសេដ្ឋកិច្ចក្នុងការផ្គត់ផ្គង់ទំនិញ ដែលមានតម្រូវការដែលជាកត្តាជំរុញនាំឱ្យមានអតិផរណា។
- អតិផរណាខ្ពស់បានជះឥទ្ធិពលដល់ការសម្រេចចិត្តសេដ្ឋកិច្ច ដូច្នេះកំណើនផលិតផលក្នុងស្រុកសរុប (GDP growth) ។

កត្តាខាងលើនេះ ត្រូវបានបង្ហាញដើម្បីណែនាំអ្នកអានអំពីមុខងាររបស់ធនាគារកណ្ដាល។ ដូចយើងបានឃើញថា មុខងារសំខាន់របស់ធនាគារកណ្ដាល គឺគោលនយោបាយរូបិយវត្ថុ។ ប៉ុន្តែធនាគារកណ្ដាលនៅមានមុខងារច្រើនទៀត មុននឹងសិក្សាមុខងាររបស់ធនាគារកណ្ដាលផ្សេងទៀត យើងត្រូវតែសិក្សាស្វែងយល់ពីមុខងារបង្កើតរូបិយវត្ថុរបស់ធនាគារកណ្ដាល។

## ២.៨- មុខងារធនាគារកណ្ដាលបង្កើតរូបិយវត្ថុ (Functions of central bank to creating money)

### ២.៨.១- សមាសធាតុនៃការផ្គត់ផ្គង់រូបិយវត្ថុ (Element of money supply)

ការផ្គត់ផ្គង់រូបិយវត្ថុ គឺជាបរិមាណរូបិយវត្ថុ ដែលមានបរិមាណគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ក្នុងសេដ្ឋកិច្ចនៅក្នុងការទិញទំនិញ និងសេវាកម្ម។ ការផ្គត់ផ្គង់រូបិយវត្ថុត្រូវបានវាស់វែង និងបែងចែកជា៤ប្រភេទ៖

- M0៖ រូបិយវត្ថុមូលដ្ឋាន (money base)
- M1៖ បរិមាណរូបិយវត្ថុតាមន័យចង្អៀត (money narrow)
- M2៖ បរិមាណរូបិយវត្ថុតាមន័យទូលាយ (money broader)
- M3៖ បរិមាណរូបិយវត្ថុតាមន័យទូលាយបំផុត (money broadest)

ជាទូទៅ គណនីទ្រព្យសកម្ម និងគណនីបំណុលរបស់ធនាគារគឺមិនមានស្ថិរភាពនោះទេ។ គណនីទ្រព្យទាំង២នេះ គឺកើនឡើងជាចម្បងអាស្រ័យលើប្រាក់កម្ចីធនាគារ ឬការបង្កើតប្រាក់ថ្មី។

ឧទាហរណ៍៖ រំលឹកឡើងវិញលើបរិមាណក្រដាសប្រាក់ទូលាយ M3 ត្រូវបានបង្កើតឡើងដោយធនាគារកណ្ដាលមានក្រដាសប្រាក់ និងកាស (N&C) និងប្រាក់បញ្ញើធនាគារ (BD) ដែលបានកាន់កាប់ដោយវិស័យឯកជនមិនមែនធនាគារក្នុងស្រុក ដែលគេហៅកាត់ថា "NBPS"៖

$$M3 = N\&C + BD$$

ក្នុងចំណោមគណនីប្រាក់បញ្ញើធនាគារ (BD) គឺធំជាងគេ (+/- ៩៥%)។ គណនីប្រាក់បញ្ញើធនាគារកើនឡើង នៅពេលធនាគារផ្តល់នូវប្រាក់កម្ចីថ្មី = buy NMD +MD។

| BALANCE SHEET 11: COMPANY A (USD MILLIONS) | | | |
|---|---|---|---|
| Assets | | Liabilities | |
| Goods<br>Bank deposits | - 10<br>+ 10 | | |
| Total | 0 | Total | 0 |

| BALANCE SHEET 12: COMPANY B (USD MILLIONS) | | | |
|---|---|---|---|
| Assets | | Liabilities | |
| Goods | + 10 | Bank loan (overdraft) | + 10 |
| Total | + 10 | Total | + 10 |

| BALANCE SHEET 13: BANK A (USD MILLIONS) | | | |
|---|---|---|---|
| Assets | | Liabilities | |
| Loan to company B | + 10 | Deposit of Company A | + 10 |
| Total | + 10 | Total | + 10 |

គណនីប្រាក់បញ្ញើក្រុមហ៊ុន (A) គឺជាផលិតផលដែលមានតម្រូវការដោយក្រុមហ៊ុន (B) ដែលត្រូវការទឹកប្រាក់ចំនួន ១០លានដុល្លារ ដើម្បីបញ្ជាទិញទំនិញ ហើយធនាគារ (A) ទទួលបានប្រាក់កម្ចី។ បន្ទាប់ពីការត្រួតពិនិត្យឥណទានធនាគារផ្តល់ដោយក្រុមហ៊ុន (B) ប័ណ្ណរូបារូបណ៍ (overdraft facili-ty)។ បន្ទាប់មកក្រុមហ៊ុន(B)បានចេញមូលប្បទានប័ត្រមានទឹកប្រាក់ចំនួន ១០លានដុល្លារលើឥណទានលើសប័ណ្ណរូបារូបណ៍របស់ខ្លួន ហើយបានបង្ហាញមូលប្បទានប័ត្រទៅឱ្យក្រុមហ៊ុន (A) និងទទួលការដឹកជញ្ជូនទំនិញ។ ក្រុមហ៊ុន(A)បានទទួលប្រាក់ជាមូលប្បទានប័ត្រពីធនាគារ (B)។ មូលប្បទានប័ត្រត្រូវបានដាក់តាមរយៈប្រព័ន្ធទូទាត់អន្តរធនាគារ ហើយតារាងតុល្យការរបស់ភាគីនីមួយៗ បានបញ្ចប់ ដូចបានបង្ហាញក្នុងតារាងតុល្យការលេខ ១១-១៣។ វានឹងបង្ហាញឱ្យឃើញថា ប្រាក់បញ្ញើធនាគាររបស់ក្រុមហ៊ុនមានចំនួនទឹកប្រាក់កើនឡើងដល់ប្រភេទរូបិយវត្ថុ M3 ដែលកាន់កាប់ដោយ (NBPS) ហើយប្រភពរបស់វា គឺជាការកើនឡើងនូវការផ្តល់ប្រាក់កម្ចីឱ្យក្រុមហ៊ុន (B) ហើយប្រើប្រាស់ (ប្រភពពិតនៃតម្រូវការប្រាក់កម្ចី ($\Delta$ = change):

$$\Delta M2 = \Delta BD = \Delta bank\ loans.$$

សំណួរបានកើតឡើង៖ *តើធនាគារពិតជាអាចធ្វើវាបានប្រាកដឬទេ?* ច្បាស់ជាត្រូវតែមានហ្វ្រាំងទប់លើប្រព័ន្ធនេះមែនទេ? ចម្លើយ គឺថាធនាគារធ្វើបែបនេះជារៀងរាល់ថ្ងៃ។ តាមពិតប្រព័ន្ធនេះត្រូវបានរចនាឡើង ដើម្បីអនុញ្ញាតឱ្យវាកើតឡើង។ ការចាប់ហ្វ្រាំងលើប្រព័ន្ធនេះ មានន័យថាជាយន្តការការពារការកើនឡើងនៃការបង្កើតប្រាក់ដែលរីករាលដាល ដែលយើងបានឃើញថាគឺជាគោលនយោបាយរូបិយវត្ថុ ហើយវាដំណើរការតាមរយៈការប្រែប្រួលអត្រាការប្រាក់ដោយកំណត់ថា KIR ត្រូវធ្វើឱ្យមានប្រសិទ្ធភាពដោយធនាគារ ដែលបានខ្ចីប្រាក់ពីធនាគារកណ្តាល (មានន័យថា BR)។

### ២.៨.២- គោលការណ៍នៃការបង្កើតរូបិយវត្ថុ (Principle of money creation)

ធនាគារកណ្តាល និងធនាគារគឺជាផលិតកររូបិយវត្ថុ។ រូបិយវត្ថុរបស់ធនាគារកណ្តាល រួមមានក្រដាសប្រាក់ និងកាស (N&C) និងប្រាក់បញ្ញើចរន្តរបស់ធនាគាររួមទាំងប្រាក់បញ្ញើរបស់រដ្ឋាភិបាលនៅធនាគារកណ្តាលផងដែរ។ ការបង្កើតរូបិយវត្ថុតាមរយៈធនាគារកណ្តាលរួមមាន៖

- ធនាគារកណ្តាលផ្តល់កម្ចីឱ្យរដ្ឋាភិបាល និងធនាគារ។
- ធនាគារកណ្តាលទិញរូបិយប័ណ្ណ និងមូលប័ត្រលើទីផ្សារហិរញ្ញវត្ថុ។

ការបង្កើតរូបិយវត្ថុតាមរយៈធនាគារ៖

- ការផ្តល់កម្ចីរបស់ធនាគារដោយបង្កើតគណនីប្រាក់បញ្ញើចរន្ត។
- ការផ្តល់រូបិយវត្ថុឥណទាន និងត្រូវបានបាត់ទៅវិញ នៅពេលណាអ្នកខ្ចីប្រាក់សងបំណុលត្រឡប់ឱ្យទៅគ្រឹះស្ថានធនាគារវិញ។
- ការទិញមូលប័ត្ររបស់រដ្ឋាភិបាល ឬសញ្ញាប័ណ្ណរដ្ឋាភិបាលពីសំណាក់ធនាគារ ដោយប្រើប្រាស់គណនីធនាគារ។

ករណីប្រាក់ទុនបម្រុងធនាគារ គឺជាសាច់ប្រាក់ ដែលមាននៅក្នុងគណនីបេឡាធនាគារ និងប្រាក់បញ្ញើនៅឯធនាគារកណ្តាល។ ទន្ទឹមនឹងនេះ ប្រាក់ទុនបម្រុងធនាគារចែកចេញជា២ប្រភេទ៖

- ប្រាក់ទុនបម្រុងកាតព្វកិច្ច (required reserve)
- ប្រាក់ទុនបម្រុងអតិរេក ឬលើស (excess reserve)

ចំពោះប្រាក់ទុនបម្រុងកាតព្វកិច្ច គឺជាបរិមាណប្រាក់ទុនបម្រុងអប្បបរមាដែលគ្រឹះស្ថានធនាគារនីមួយៗត្រូវតម្កល់រក្សាទុកនៅក្នុងគណនីធនាគារកណ្តាល។ អនុបាតនៃប្រាក់ទុនបម្រុងកាតព្វកិច្ចត្រូវកំណត់ដោយធនាគារកណ្តាល។

គួរកត់ចំណាំ៖ គ្រឹះស្ថានធនាគារ អាចផ្តល់ប្រាក់កម្ចីបានតែលើមូលដ្ឋាននៃប្រាក់បម្រុងអតិរេក (excess reserve)។

## ២.៩- មុខងាររបស់ធនាគារកណ្តាល (Functions of central banks)

ជាទូទៅ មុខងាររបស់ធនាគារកណ្តាលត្រូវបានគូសបញ្ជាក់ដូចខាងក្រោម៖

- អ្នកបោះផ្សាយក្រដាសប្រាក់ និងកាស(N&C)
- ធនាគារិករដ្ឋាភិបាល

- ទីប្រឹក្សារដ្ឋាភិបាល
- អ្នករកប្រាក់បម្រុងជាសាច់ប្រាក់របស់ធនាគារ
- អ្នកបោសសម្អាតកណ្តាល និងទូទាត់ឥណទេយ្យអន្តរធនាគារ
- អ្នកថែរក្សាមាស និងប្រាក់បម្រុងបរទេសដទៃទៀតរបស់ប្រទេស
- ការគ្រប់គ្រងប្រាក់ និងប្រព័ន្ធធនាគារ
- អ្នកឱ្យខ្ចីចុងក្រោយ
- ការគ្រប់គ្រងបំណុលសាធារណៈ
- ការបង្កើត និងប្រតិបត្តិនៃគោលនយោបាយរូបិយវត្ថុ
- ប្រតិបត្តិការទីផ្សារបើកចំហ
- ការប្រមូល និងបកស្រាយស្ថិតិសេដ្ឋកិច្ច
- អ្នកគ្រប់គ្រងធនាគារ
- រដ្ឋបាលនៃការគ្រប់គ្រងការផ្លាស់ប្តូរ (កន្លែងដែលអាចអនុវត្តបាន)

ទោះជាយ៉ាងណា នេះគឺជាមុខងារបម្លែមរបស់ធនាគារកណ្តាលតែប៉ុណ្ណោះ។ មុខងារជាច្រើនរបស់ធនាគារកណ្តាល ត្រូវបានដាក់បញ្ចូលក្នុងក្របខ័ណ្ឌគោលនយោបាយរូបិយវត្ថុដ៏សមស្របមួយ។ ឧទាហរណ៍ដូចជា៖ មុខងារធនាគារិក គឺជាទីប្រឹក្សាឱ្យរដ្ឋាភិបាល និងការគ្រប់គ្រងបំណុលសាធារណៈ ដែលជាកាតព្វកិច្ចផ្តាច់មុខ។ ស្រដៀងគ្នានេះដែរ ធនាគារកណ្តាលជាអ្នកផ្តល់កម្ចីចុងក្រោយ អ្នករក្សាប្រាក់បម្រុងកាតព្វកិច្ច ការគ្រប់គ្រងប្រាក់ និងកាស និងការគ្រប់គ្រងប្រព័ន្ធធនាគារជាដើម។ ដូចនេះ ក្របខ័ណ្ឌគោលនយោបាយរូបិយវត្ថុដ៏សមស្របបន្ថែមទៀតនៃមុខងាររបស់ធនាគារកណ្តាល ត្រូវបានបង្ហាញនៅក្នុងតារាងខាងក្រោមនេះ។

ចំពោះមុខងារទាំងនេះ ភាគច្រើនមានទំនាក់ទំនងរវាងគ្នាទៅវិញទៅមក។ ការសិក្សាផ្នែកនេះស្តីពីមុខងារសំខាន់ពីរចុងក្រោយរបស់ធនាគារកណ្តាលមិនត្រូវការបកស្រាយឱ្យបានលម្អិតទេ។ ដូច្នេះ យើងនឹងផ្តោតលើការសិក្សាលើមុខងារសេវាកម្ម និងប្រព័ន្ធគាំទ្រសាជីវកម្មផ្ទៃក្នុង។ ស្ថាប័ន ឬអង្គភាពមួយត្រូវរៀបចំរចនាសម្ព័ន្ធអង្គការលេខរបស់ខ្លួន ដើម្បីអនុវត្តមុខងារ ឬអាជីវកម្មឱ្យមានប្រសិទ្ធភាព។ ទន្ទឹមនឹងនេះ ធនាគារកណ្តាលផ្តល់មុខងារសេវាកម្មសេដ្ឋកិច្ច និងស្ថិតិក៏មានសារសំខាន់ គឺជាតម្រូវការជាក់ស្តែងផងដែរ។ យើងអាចនិយាយបានថា ធនាគារកណ្តាល គឺមាននាយកដ្ឋានសេដ្ឋកិច្ចស្ថិតិដ៏ល្អប្រណិតពីប្រតិបត្តិការរបស់ធនាគារកណ្តាលជូនដល់រដ្ឋាភិបាល និងសាធារណជនតាមរយៈការបោះពុម្ពផ្សាយព្រឹត្តិបត្ររបស់ខ្លួនជាប្រចាំ៖

- ព្រឹត្តិបត្រប្រចាំត្រីមាស និងរបាយការណ៍ប្រចាំឆ្នាំ
- របាយការណ៍ប្រចាំខែអំពីទ្រព្យសម្បត្តិ និងបំណុល និងការចេញផ្សាយទិន្នន័យដែលបានជ្រើសរើស
- របាយការណ៍ និងរបាយការណ៍របស់គណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ (MPC)

តារាង៖ មុខងាររបស់ធនាគារកណ្តាល

| |
|---|
| ការបង្កើត និងអនុវត្តគោលនយោបាយរូបិយវត្ថុ (សំដៅសម្រេច និងរក្សាស្ថិរភាពថ្លៃ) |
| ការបង្កើតក្របខ័ណ្ឌគោលនយោបាយរូបិយវត្ថុ |
| ឥទ្ធិពលលើកម្រិតអត្រាការប្រាក់ (តាមរយៈការគ្រប់គ្រងសាច់ប្រាក់ងាយស្រួលរបស់ធនាគារ) |
| ប្រតិបត្តិការទីផ្សារបើកចំហ |
| ធនាគារិក និងជាទីប្រឹក្សារដ្ឋាភិបាល |
| ធនាគារិករបស់រដ្ឋាភិបាល |
| ការគ្រប់គ្រងបំណុលសាធារណៈ |
| រដ្ឋបាលនៃការគ្រប់គ្រងការផ្លាស់ប្តូរ |
| ការគ្រប់គ្រងប្រព័ន្ធរូបិយវត្ថុ និងធនាគារ |
| អ្នកឱ្យខ្ចីចុងក្រោយ (ចំណាំ៖ មិនមែនមុខងារគោលនយោបាយរូបិយវត្ថុទេ) |
| ការគ្រប់គ្រងរូបិយប័ណ្ណ (ក្រដាសប្រាក់ និងកាស) |
| ធនាគារិកទៅក្នុងវិស័យធនាគារឯកជន |
| ការទូទាត់សំណងតាមឥណទេយ្យអន្តរធនាគារ |
| ការគ្រប់គ្រងធនាគារ |
| ការត្រួតពិនិត្យប្រព័ន្ធទូទាត់ |
| ការគ្រប់គ្រងរូបិយវត្ថុបម្រុងជាមាស និងប្តូរប្រាក់បរទេស |
| ការអភិវឌ្ឍន៍ទីផ្សារបំណុល |
| ការផ្តល់សេវាស្ថិតិ និងសេដ្ឋកិច្ច |
| ការផ្តល់សេវា និងប្រព័ន្ធគាំទ្រដល់សាជីវកម្ម |

ក្នុងការបោះពុម្ពផ្សាយនូវព្រឹត្តិបត្រប្រចាំត្រីមាសគឺជាព័ត៌មានលម្អិតបំផុត។ ក្រៅពីការត្រួតពិនិត្យឡើងវិញនូវសេដ្ឋកិច្ចប្រចាំត្រីមាស និងអត្ថបទ ដែលមានចំណាប់អារម្មណ៍អំពីធនាគារផ្តល់នូវព័ត៌មានលម្អិតបំផុតស្តីពី៖

- រូបិយវត្ថុ និងធនាគារ
- ទីផ្សារមូលធន
- គណនីហិរញ្ញវត្ថុជាតិ
- ហិរញ្ញវត្ថុសាធារណៈ
- ទំនាក់ទំនងសេដ្ឋកិច្ចអន្តរជាតិ
- សូចនាករសេដ្ឋកិច្ចទូទៅ
- ព័ត៌មានសំខាន់ៗ (ទិន្នន័យដែលបានជ្រើសរើសជាចម្បង)។

ទិន្នន័យទាំងនេះគឺជាប្រភពព័ត៌មាន ដែលចាំបាច់បំផុតសម្រាប់អ្នកធ្វើគោលនយោបាយរូបិយវត្ថុឱ្យដល់ធនាគារកណ្តាលផ្ទាល់ខ្លួនឯង រដ្ឋាភិបាល អ្នកសិក្សាវិភាគ និងអ្នកសិក្សាស្រាវជ្រាវជាដើម។

ក្រៅពីមុខងារសំខាន់ទាំងពីរខាងលើនេះ យើងនៅសល់មុខងារសំខាន់ចំនួន៣ផ្សេងទៀត។ យើងនឹងសិក្សាពិភាក្សាលើមុខងារសំខាន់ទាំងបីនេះតាមលំដាប់លំដោយមានដូចខាងក្រោម៖

- ធនាគារ និងទីប្រឹក្សារដ្ឋាភិបាល
- ការគ្រប់គ្រងប្រាក់ និងប្រព័ន្ធធនាគារ
- ការបង្កើត និងអនុវត្តគោលនយោបាយរូបិយវត្ថុ (គោលបំណង ដើម្បីសម្រេច និងថែរក្សា)

## ២.៩.១- គោលការណ៍រួមរបស់ធនាគារកណ្តាល (Principle of central banks)

ធនាគារកណ្តាលប្រកាន់ខ្ជាប់នូវគោលការណ៍បីយ៉ាងសំខាន់៖

១. គ្រប់គ្រងដោយប្រុងប្រយ័ត្ន និងរក្សាការសម្ងាត់របស់ធនាគារ គឺការទទួលខុសត្រូវដ៏សំខាន់មួយសម្រាប់ធនាគារ ដែលចាំបាច់ត្រូវតែរក្សាអាថ៌កំបាំងអធិតេយ្យភាព និងសុវត្ថិភាពប្រព័ន្ធហិរញ្ញវត្ថុ។ ធនាគារកណ្តាលត្រូវបានទទួលការបង្គាប់បញ្ជាពីរដ្ឋាភិបាលមើលទៅលើ៖

- ពង្រឹងសេវាកម្មហិរញ្ញវត្ថុមិនឱ្យផ្លុះផ្លាយ។
- មិនត្រូវធ្វើឱ្យរីករវដោយបង្កអស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុ។
- បញ្ចេញសកម្មភាពអធិបតេយ្យហិរញ្ញវត្ថុរបស់ខ្លួន ក្នុងការទប់ស្កាត់ប្រការមិនល្អដោយស្មារតីប្រុងប្រយ័ត្នខ្ពស់ និងប្រកបដោយជំនាញជាក់លាក់។

២. ដឹកនាំដំណើរការគោលនយោបាយរូបិយវត្ថុគឺគោលការណ៍សំខាន់ដែលជាក្តីសង្ឃឹមរបស់ប្រជារាស្ត្រ។ ចំណុចសំខាន់ៗ មានដូចជា ៖

- រក្សាស្ថិរភាពថ្លៃ។
- រក្សាកម្រិតរួមតូចនៃអនិកម្មភាព ឬដែលដើម្បីសម្រេចឱ្យបាននូវគោលដៅ។ គោលដៅនេះ ធនាគារកណ្តាលនឹងប្រើប្រាស់អត្រាការប្រាក់ និងអត្រាប្តូរប្រាក់ក្នុងការទប់ទល់នឹងបម្រែបម្រួលបរិមាណរូបិយវត្ថុ។
- ភារកិច្ចគ្រប់គ្រងរូបិយវត្ថុដទៃទៀត គឺតួនាទីបន្ថែម និងចាំបាច់ ដើម្បីបម្រើផលប្រយោជន៍សង្គមទាំងមូល។

៣. ធនាគារត្រូវប្រកាន់ភ្ជាប់ខ្សែរយៈរបស់ខ្លួនក្នុងការត្រួតពិនិត្យរូបិយវត្ថុដោយប្រើនូវ៖

- ការភ្ជាប់ធនាគារិកជាមួយរដ្ឋាភិបាល
- ការភ្ជាប់ធនាគារិកជាមួយធនាគារដទៃទៀត
- ការត្រួតពិនិត្យលើការកាន់កាប់រូបិយប័ណ្ណបរទេសក្នុងស្រុក
- ការផលិតរូបិយវត្ថុ

## ២.៩.២- តួគុណប្រាក់បញ្ញើធនាគារ (Deposit Multiplier)

យើងបានឃើញថា៖ ធនាគារមានលក្ខណៈពិសេសពីរ គឺទិដ្ឋភាពដើមទុនដំបូងរបស់ធនាគារមានកម្រិតទាប និងធនាគារអាចបង្វិលបំណុលរបស់ខ្លួនបានឆាប់រហ័សទៅតាមតម្រូវការរបស់អតិថិជន។

លក្ខណៈពិសេសទាំងពីរនេះបានជំរុញឱ្យធនាគារមានលទ្ធភាពគ្រប់គ្រងលើសោធនភាព សន្ទនីយភាព និងប្រាក់ចំណេញ។ ដើម្បីទប់ស្កាត់មិនឱ្យក្ស័យធនធនាគារ និងមិនធ្វើឱ្យទ្រព្យសកម្មថយចុះនោះទេ ដែលគេបានហៅថា "សោធនភាព"។ ចំណែកឯទ្រព្យសកម្ម គឺលទ្ធភាពដែលធនាគារពាណិជ្ជសម្រាប់ទូទាត់សងទៅឱ្យអ្នកដាក់ប្រាក់បញ្ញើតែប៉ុណ្ណោះ។

*តើធនាគារបង្កើតរូបិយវត្ថុដូចម្តេច?*

ធនាគារ មានសិទ្ធិបង្កើតរូបិយវត្ថុ ឬទ្រព្យសន្ទនីយភាព និងទុនបម្រុងសម្រាប់ជាមធ្យោបាយក្នុងការចំណាយរបស់ខ្លួន ដោយសារតែលទ្ធភាពនេះ ធនាគារមានតួនាទីតែមួយគត់ខាងផ្នែកហិរញ្ញវត្ថុសម្រាប់សេដ្ឋកិច្ច និងរាប់បញ្ចូលជាស្ថាប័ន ដែលមានឥទ្ធិពលបំផុតលើវត្ថុមានបរិមាណរូបិយវត្ថុ។ ធនាគារអាចមានលទ្ធភាពបង្កើតបាន គឺប្រាក់បញ្ញើ និងផ្តល់ប្រាក់កម្ចី ប៉ុន្តែអ្វីៗទាំងអស់នេះ ត្រូវបានកំណត់ដោយបរិមាណប្រាក់តម្កល់រក្សាទុក។ អត្រាសាច់ប្រាក់តម្រូវឱ្យតម្កល់រក្សាទុក គឺជាអត្រាតម្កល់រក្សាទុកជាសាច់ប្រាក់បញ្ញើ ដែលត្រូវបញ្ចូលក្នុងធនាគារ និងការកាន់កាប់បរិមាណរូបិយវត្ថុ។

យើងអាចរកឃើញសាច់ប្រាក់ប៉ុន្មានត្រូវបានតម្កល់រក្សាទុក គឺអាស្រ័យលើតួគុណប្រាក់បញ្ញើ។ អត្រាតម្រូវការប្រាក់តម្កល់រក្សាទុក ចែកចេញជាពីរប្រភេទ៖

ក- លក្ខន្តិកតម្រូវការសាច់ប្រាក់បញ្ញើ គឺជាតម្រូវការប្រាក់តម្កល់ចាំបាច់ក្នុងធនាគារពីទុនដើមអប្បបរមា។

ខ- តម្រូវការតម្កល់ប្រាក់ផ្តាច់ (Non–Calable Deposit) គឺជាតម្រូវការសាច់ប្រាក់សម្រាប់បម្រុងទុកនៅធនាគារកណ្តាល ដោយមិនមានសិទ្ធិដកមកវិញទេ ទោះបីជាធនាគារដើម ប្រកាសរំលាយស្ថាប័នរបស់ខ្លួនក៏ដោយ។ ជាទូទៅ វាមានកម្រិត ១ភាគរយ តែប៉ុណ្ណោះ ហើយគេប្រើមូលនិធិទាំងនេះសម្រាប់ទូទាត់ហានិភ័យ និងជំនួយសប្បុរសធម៌ពីធនាគារ។

តួគុណបញ្ញើ (Deposit Multiplier) គឺជាផលគុណដែលបានបង្កើតរូបិយវត្ថុតម្កល់រក្សាទុកក្នុងធនាគារកណ្តាល ដើម្បីគណនាកំណើនប្រាក់បញ្ញើនៅក្នុងធនាគារ។ រូបមន្តរបស់វាគឺ៖

តួគុណប្រាក់បញ្ញើ (Deposit multiplier) = បម្រែបម្រួលអនុបាតប្រាក់បញ្ញើ(Change deposit ratio) ចែកនឹងបម្រែបម្រួលប្រាក់បម្រុង(Change in reserve)

តួគុណប្រាក់បញ្ញើ (Deposit multiplier) = 1/អនុបាតប្រាក់បម្រុង(required reserve ratio)

តួគុណប្រាក់បញ្ញើ (Deposit multiplier) = 1/(1-L)

ឧទាហរណ៍៖

អត្រាតម្រូវឱ្យតម្កល់រូបិយវត្ថុគឺ ២៥ភាគរយ ហេតុនេះតួគុណបញ្ញើស្មើនឹង ៤។ វាមានន័យថា ប្រសិនបើកំណើន ១លានដុល្លារ តម្កល់រក្សាទុកក្នុងធនាគារបានបង្កើតឱ្យមានកំណើនបញ្ញើ ៤លាន។ ដូចនេះ ធនាគារមានលទ្ធភាពគ្រប់គ្រាន់សម្រាប់ទទួលប្រាក់បញ្ញើ ដោយលៃរក្សាទុក ២៥ភាគរយ សម្រាប់តម្កល់រក្សាទុក ៧៥ភាគរយ សម្រាប់ផ្តល់កម្ចី។

បរិមាណកម្ចីបានបង្កើតបញ្ញើថ្មីសម្រាប់ធនាគារដទៃ ដែលទទួលបានប្រាក់កម្ចី និងចាប់ផ្តើមកំណត់ប្រាក់តម្កល់ និងផ្តល់កម្ចីបន្តទៀតតាមរយៈការកំណត់តួគុណបញ្ញើរបស់គេ។

ការបង្កើតសាច់ប្រាក់តាមរយៈកម្ចីជាមួយនឹងធនាគារជាច្រើន បានបង្ហាញដំណើរការមួយដែលពហុធនាគារ ឬធនាគារចម្រុះបង្កើតបរិមាណរូបិយវត្ថុរបស់ខ្លួនតាមរយៈសាច់ប្រាក់កម្ចី និងតម្កល់ទុក។ ដើម្បីបង្ហាញឱ្យឃើញច្បាស់នៅក្នុងដំណើរការរួម យើងសូមពិនិត្យដោយប្រុងប្រយ័ត្នទៅលើដំណើរការផ្តល់កម្ចី។ នៅក្នុងមួយដំណាក់កាលកម្ចី គឺមាន ៧៥ភាគរយ ពីបំណុលរបស់ធនាគារ និងបញ្ញើចំនួន ៧៥ ភាគរយពីបញ្ញើមុន។

ការបង្កើតសាច់ប្រាក់តាមរយៈកម្ចីជាមួយនឹងធនាគារជាច្រើន បានបង្ហាញដំណើរការមួយដែលពហុធនាគារ ឬធនាគារចម្រុះ បង្កើតបរិមាណរូបិយវត្ថុរបស់ខ្លួនតាមរយៈសាច់ប្រាក់កម្ចី និងតម្កល់ទុក។ ដើម្បីបង្ហាញឲ្យឃើញកាន់តែច្បាស់ ក្នុងដំណើរការរួមយើងសូមពិនិត្យដោយប្រុងប្រយ័ត្នលើដំណើរការផ្តល់កម្ចី។ នៅក្នុងមួយដំណាក់កាលកម្ចី គឺមាន ៧៥ភាគរយ ពីបំណុលរបស់ធនាគារ និងបញ្ញើចំនួន ៧៥ ភាគរយពីបញ្ញើមុន។

យើងហៅសមាមាត្រនេះថា L និងលទ្ធផលពេញលេញរបស់វាគឺ៖

$S = 1 + L^2 + L^3 + \dots L^n$

គុណនឹង L៖ $LS = L + L^2 + L^3 + \dots L^{n+1}$

ដកសមីការទាំង២ចេញ យើងនឹងទទួលបាន៖

$S(1 - L) = 1$

$S = 1 / 1 - L$

តួគុណបញ្ញើអាចខុសពីការគណនា របស់យើងខាងលើដោយមូលហេតុ បីយ៉ាង ៖

- អត្រាតម្រូវការប្រាក់តម្កល់កាន់តែតូច កាលណារដ្ឋាភិបាលត្រូវការលុយសម្រាប់ចរាចរណ៍។
- វាមិនពិតប្រាកដទេថា រាល់កម្ចីដែលធនាគារផ្តល់នឹងចូលមកក្នុងតម្កល់វិញ នៅពេលសងរួច។

ជួនកាលធនាគារ សម្រេចចិត្តជ្រើសរើស មិនឲ្យចេញលុយតម្កល់រតនាគារ និងធនាគារជាតិ (នៅប្រទេសយើងធនាគារកណ្តាល គ្រប់គ្រងរួមរវាងរតនាគារ និងធនាគារជាតិ តែរតនាគារវិញគ្រាន់តែជាកន្លែងតម្កល់ទុកលុយប៉ុណ្ណោះ) គឺអាជ្ញាធរសាធារណៈទេ ដែលទទួលខុសត្រូវលើនិយ័តកម្ម និងការត្រួតពិនិត្យស្ថាប័នហិរញ្ញវត្ថុ និងទីផ្សាររូបិយវត្ថុ និងហិរញ្ញវត្ថុជាតិ។ រចនាសម្ព័ន្ធនៃរតនាគារកណ្តាល រួមមានក្រុមប្រឹក្សាភិបាល ធនាគារកណ្តាល ទេសាភិបាល ទេសាភិបាលរង ដែលរៀបរាប់ខាងលើរួចហើយ។ ទីភ្នាក់ងារដើមរបស់ធនាគារជាតិត្រូវតាំង ស្ថិតនៅ ភ្នំពេញ និងអាចបើកសាខា ឬភ្នាក់ងារក្នុង និងក្រៅប្រទេស លុះត្រាតែមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល។ រតនាគារជាអ្នកផ្តល់

បញ្ញើផ្តាច់មុខដល់ធនាគារជាតិ រីឯធនាគារជាតិទទួលប្រាក់ពីរតនាគារជាតិ ហើយចេញជូសនូវទឹកប្រាក់ដែលរតនាគារជាតិ ត្រូវចំណាយរួមទាំងកម្រៃប្រតិបត្តិការផង។ ចំណូលរូបិយប័ណ្ណរបស់រតនាគារជាតិ ត្រូវលក់ឲ្យធនាគារជាតិ និងគិតតាមអត្រាប្តូរប្រាក់ប្រចាំថ្ងៃ។

មុនពេលបន្តសិក្សាឲ្យបានលម្អិតថែមទៀត អំពីថាតើធនាគារអាចគ្រប់គ្រងទ្រព្យ និងបំណុលរបស់ខ្លួនយ៉ាងដូចម្តេច ដើម្បីធ្វើឲ្យទទួលបានប្រាក់ចំណេញខ្ពស់បំផុត អ្នកគួរតែយល់អំពីប្រតិបត្តិការជាមូលដ្ឋានរបស់ធនាគារ។ នៅក្នុងលក្ខខណ្ឌទូទៅធនាគារបង្កើតប្រាក់ចំណេញ តាមរយៈការលក់នូវបំណុលដែលមានលក្ខណៈពិសេសមួយស៊េរី (ជាពិសេស គឺការបន្សំចូលគ្នានៃសន្ទនីយភាពហានិភ័យ និងចំណូលការប្រាក់) និងប្រើប្រាស់វាដើម្បីទិញទ្រព្យបន្តដែលមានលក្ខណៈពិសេសមួយស៊េរី។ ដើម្បីធ្វើការវិភាគលើប្រតិបត្តិការរបស់ធនាគារដែលអាចកំបាំងថែមទៀតយើងប្រើឧបករណ៍ដែលត្រូវគេហៅឈ្មោះថា ធីអាខោន (T-Account )។

ឧទាហរណ៍៖ អំពីធីអាខោនសម្រាប់ជាឧបករណ៍របស់ធនាគារគឺ

| A Bank | | | |
|---|---|---|---|
| Assets | | Liabilities | |
| Vault Cash | + 100 | Checkable deposit | + 100 |

នៅពេលដែលមូលប្បទានប័ត្រត្រូវបានគេសរសេរលើធីអាខោន

| A Bank | | | |
|---|---|---|---|
| Assets | | Liabilities | |
| Reserves | + 100 | Checkable deposit | + 100 |

នៅពេលមូលប្បទានប័ត្រត្រូវគេដាក់ជាគណនីនៅធនាគារមួយដែលមូលប្បទានប័ត្រនេះ គេដាក់ចូលទៅផ្នែកផ្សេងទៀតនោះ ធនាគារដែលទទួលបានទុនបម្រុង ចំណេញលើប្រាក់បញ្ញើស្មើទៅនឹងមូលប្បទានប័ត្រ។ ដូចនេះ នៅពេលដែលធនាគារទទួលបានប្រាក់បញ្ញើបន្ថែម ធនាគារទទួលបានចំនួនទុនបម្រុងស្មើគ្នា។

# ជំពូកទី ៣

# ធនាគារិកជាទីប្រឹក្សាឱ្យរដ្ឋាភិបាល

BANKER AND ADVISOR TO GOVERNMENT

## ៣.១- តើអ្វីជាធនាគារ ? (What´s banking ?)

ជាទូទៅធនាគារ (Banking) គឺជាស្ថាប័នហិរញ្ញវត្ថុដែលធ្វើប្រតិបត្តិការផ្តល់សេវាកម្មហិរញ្ញវត្ថុច្រើនប្រភេទ ដូចជាទទួលប្រាក់បញ្ញើមិនមានមុខសញ្ញាប្រើប្រាស់ និងប្រាក់សន្សំពីសាធារណជនផ្តល់ឥណទានឱ្យឯកត្តជន និងក្រុមហ៊ុនអាជីវកម្មជំនួញ ដោយយកការប្រាក់ព្រមទាំងផ្តល់សេវាលើការងារទូទាត់ និងធ្វើវិនិយោគមូលនិធិស្ថិតក្រោមរូបភាពដូចជា សញ្ញាប័ណ្ណ (bond) និងមូលប័ត្រមានតម្លៃដើម្បីស្វែងរកនូវប្រាក់ចំណេញសម្រាប់ម្ចាស់ភាគហ៊ុន។ ធនាគារ គឺជាស្ថាប័ន ឬគ្រឹះស្ថានសម្រាប់ទទួលបញ្ញើ ឬបណ្តាក់ទុនជាបណ្តាញប្រមូលប្រាក់សន្សំដែលឥតប្រើប្រាស់ ឬនៅទំនេរក្នុងសេដ្ឋកិច្ច

យកទៅវិភាជនៅតាមគ្រប់វិស័យសេដ្ឋកិច្ចតាមរយៈការឱ្យឥណទាន ដើម្បីជួយជំរុញលើកស្ទួយសកម្មភាព និងអភិវឌ្ឍសេដ្ឋកិច្ចសង្គម។

### ៣.១.១- ហេតុអ្វីយើងសិក្សាពីធនាគារ? (why we are study the bank? )

ធនាគារ គឺជាស្ថាប័នហិរញ្ញវត្ថុទទួលយកប្រាក់បញ្ញើ និងផ្ដល់កម្ចី។ ពាក្យថាធនាគារ គឺជាក្រុមហ៊ុនដូចជាធនាគារពាណិជ្ជកម្ម សមាគមសន្សំ និងបំណុល។ ធនាគារសន្សំរួម និងសហគមឥណទានសុទ្ធតែមានតួនាទីប្រហាក់ប្រហែលគ្នា ប៉ុន្តែគេសង្កេតឃើញថា មានភាពខុសគ្នាលើគោលនយោបាយគ្រប់គ្រងហិរញ្ញវត្ថុ។ ធនាគារមានដំណើរការដូចក្រុមហ៊ុនដែរ ដោយគ្រាន់តែជំនួញលើរូបិយវត្ថុ។ ចាប់តាំងពីទសវត្សរ៍ទី៧០មក ធនាគារបានកើនឡើងយ៉ាងរហ័ស ដោយសារតែផ្ដល់សុវត្ថិភាពដល់អ្នកជំនួញ។ ទន្ទឹមគ្នានេះ ដំណើរការដែលមានភាពអាប់អួ និងភាពបរាជ័យនៃធនាគារពាណិជ្ជកម្មក៏មានច្រើនដែរ ពីព្រោះការស្រុតចុះនៃល្បឿនសេដ្ឋកិច្ចដែលរដ្ឋាភិបាលមិនអាចត្រួតពិនិត្យសេដ្ឋកិច្ចរដ្ឋ និងតម្រូវការប្រាក់តម្កល់ចេះតែកើនឡើងច្រើនពេក។

ក្រោមច្បាប់ប្រទេសកម្ពុជា ធនាគារគឺនីតិសម្បទាពិសេសក្នុងការរើសយកប្រតិបត្តិការធនាគារជាមុខរបរប្រក្រតី។ ហើយប្រតិបត្តិការដែលជាសកម្មភាពធនាគាររួមមាន៖

- ការផ្ដល់នូវឥណទានគ្រប់ប្រភេទដល់សាធារណជន ដោយមានកម្រៃរាប់បញ្ចូលទាំងឥណទានភតិសន្យា និងការសន្យាតាមហត្ថលេខា។
- ការទទួលប្រាក់បញ្ញើមិនមានមុខសញ្ញាប្រើពីសាធារណជន។
- ប្រព្រឹត្តកម្ម និងដាក់ឱ្យអតិថិជនប្រើប្រាស់នូវមធ្យោបាយទូទាត់ជារូបិយវត្ថុ ឬជារូបិយប័ណ្ណ។

១. តួនាទីសំខាន់ៗ របស់ធនាគារក្នុងខឿនសេដ្ឋកិច្ចជាតិ៖

- តួនាទីអន្តរការី (Intermediation role)៖ បង្វិលប្រាក់សន្សំដែលបានទទួលពីអង្គភាព គ្រួសារឱ្យទៅជាឥណទានសម្រាប់ឱ្យក្រុមហ៊ុនផ្សេងៗយកទៅវិនិយោគ។
- តួនាទីទូទាត់ (Payment role)៖ ការធ្វើទូទាត់ទំនិញ និងសេវាជួសឱ្យអតិថិជនរបស់ខ្លួន (តាមរយៈការចេញផ្សាយ និងទូទាត់មូលប្បទានប័ត្រ ការផ្ទេរប្រាក់ និងការបើកប្រាក់ឱ្យ)។
- តួនាទីជាអ្នកធានា (Guarantor role)៖ ធានាសងបំណុលជួសអតិថិជននៅពេលអតិថិជនមិនអាចសងបាន (តាមរយៈការចេញផ្សាយលិខិតឥណទានជាដើម)។
- តួនាទីជាភ្នាក់ងារ (Agency role)៖ ចាត់ចែង និងការការពារទ្រព្យសម្បត្តិរបស់អតិថិជន ឬចេញផ្សាយ និងទទួលទូទាត់សងវិញនូវមូលប័ត្រជំនួសមុខឱ្យអតិថិជន។

២. ធនាគារមានសារសំខាន់បីយ៉ាង ដែលទាមទារឱ្យយើងសិក្សា៖

- ផ្ដល់ការទាក់ទងពីបុគ្គលសន្សំទៅបុគ្គលចង់វិនិយោគ
- ដើរតួនាទីសំខាន់ក្នុងការកំណត់ការផ្គត់ផ្គង់រូបិយវត្ថុ និងការបញ្ជូនប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុទៅសេដ្ឋកិច្ច។

- ប្រភពនៃការរីកចម្រើនខាងហិរញ្ញវត្ថុ ដែលពង្រីកមធ្យោបាយសន្សំប្រាក់របស់យើង។ នៅក្នុងស្ថាប័នហិរញ្ញវត្ថុ ប្រព័ន្ធធនាគារខុសពីគ្នា ដែលគេបានប្រើប្រាស់ក្នុងពិភពលោកនេះ។

បណ្តាប្រទេសនៅក្រោមអាណានិគមអង់គ្លេសបានប្រើប្រព័ន្ធរួមគ្នា គេហៅថាដោយឡែកនៅបណ្តាប្រទេសដែលធ្លាប់ស្ថិតក្រោមអាណានិគមបារាំងភាគច្រើនប្រើប្រាស់ប្រព័ន្ធធនាគារកណ្តាល ឬធនាគារជាតិ យើងមិនអាចពន្យល់ពីមូលហេតុណាមួយ បានជាប្រទេសនីមួយៗនិយមប្រើប្រព័ន្ធខុសគ្នា។ ប៉ុន្តែប្រទេសរីកចម្រើននិយមប្រើប្រព័ន្ធរបស់អង់គ្លេស ដោយសារវិសាលភាពអត្ថប្រយោជន៍ និងការទាក់ទងពាណិជ្ជកម្មអន្តរជាតិ។ ជាប្រវត្តិសាស្ត្រ ក្រៅពីនេះមានពីរប្រព័ន្ធនៃគ្រឹះស្ថានហិរញ្ញវត្ថុដូចជា ៖

- ធនាគារសហព័ន្ធ ឬរតនាគារ (Federal Bank/Treasury)៖ ប្រព័ន្ធដែលគេអនុវត្ត សម្រាប់ប្រទេសស្ថិតក្នុងប្រព័ន្ធ (Common Wealth Nations) ដែលជាប្រទេសទទួលស្គាល់ដោយអង់គ្លេស។
- ធនាគារកណ្តាល/ធនាគារជាតិ (Central/National Bank)៖ ជាធនាគារជាតិ ឬធនាគារកណ្តាលជាប្រព័ន្ធ ដែលអនុវត្តសម្រាប់ប្រទេសនៅក្នុង (Francophonic Society) ជាប្រទេសទទួលស្គាល់ដោយបារាំង។ ភាពខុសប្លែកនៃប្រព័ន្ធទាំងនេះ គឺជាធនាគារសហព័ន្ធអន្តរាគមន៍ ឬឱ្យខ្ចីក្នុងគ្រាបន្ទាល់ ករណីពិសេសធនាគារសហព័ន្ធត្រួតពិនិត្យធនាគាររដ្ឋ។

សូមក្រឡេកមើលតារាងខាងក្រោមនេះ និងឃើញពីភាពខុសគ្នានៃប្រព័ន្ធធនាគារកណ្តាល៖

| Commonwealth National | Francophnic Society |
|---|---|
| -Reserve bank of American | -National bank of Cambodia |
| -State Bank (52 states) | -Reserve of Cambodia |
| -Financial Intermediaries | -Financial Intermediaries |

ភាពខុសគ្នាក្នុងប្រព័ន្ធនេះ គឺបណ្តាប្រទេសដែលធ្លាប់ជាអតីតអាណានិគមអង់គ្លេសទាំងអស់មានធនាគារមួយដែលបានជួយអន្តរាគមន៍ ឬឧបត្ថម្ភមួយក្នុងករណីចាំបាច់។ បន្ទាប់មកគេមានធនាគារសហព័ន្ធ ដែលទទួលខុសត្រូវលើបណ្តាធនាគារនៅក្នុងរដ្ឋនីមួយៗ។

ឧទាហរណ៍រួមមាន៖ អូស្ត្រាលី កាណាដា អង់គ្លេស អាម៉េរិក ណូវែលសឺឡង់ និងអតីតសហភាពសូវៀត សុទ្ធតែប្រើប្រព័ន្ធធនាគារសហព័ន្ធ។

ដោយឡែកបណ្ដាប្រទេសមួយភាគតូច បានប្រតិបត្តិតាមប្រព័ន្ធធនាគារកណ្ដាល ឬធនាគារជាតិ មានដូចជាធនាគារកណ្ដាលដាណឺម៉ាក ធនាគារកណ្ដាលបារាំង ធនាគាកណ្ដាល ឬធនាគារជាតិនៃកម្ពុជា និងធនាគារកណ្ដាលថៃជាដើម ។ល។ យើងពិតជាមិនអាចនិយាយបានថា ប្រព័ន្ធធនាគារកណ្ដាលប្រទេសមួយណាសំខាន់ជាងប្រទេសមួយណានោះទេ ប៉ុន្តែលក្ខណៈមួយដែលធនាគារកណ្ដាលបណ្ដាប្រទេសធ្លាប់ជាអតីតអាណានិគមអង់គ្លេសមានឥទ្ធិពលជាង គឺភាពងាយស្រួលក្នុងការចាយវាយឆ្លងកាត់ប្រទេស និងការវិនិយោគទុន។

### ៣.១.២- ប្រភេទនៃធនាគារ (Types of bank)

ធនាគារ គឺជាគ្រឹះស្ថានហិរញ្ញវត្ថុ៖

- ធនាគារពាណិជ្ជ
- ធនាគារសន្សំ
- សហជីពឥណទាន

} និងឥណទានមានតួនាទីដូចគ្នា តែគោលនយោបាយខុសគ្នា

- ធនាគារកណ្ដាល
- ធនាគារពាណិជ្ជ
  - ទុនតិចពេកយើងមិនអាចមានរូបិយវត្ថុច្រើនទេ ដែលយើងមិនអាចបើកអាជីវកម្មបានទេ។
  - រូបិយវត្ថុច្រើនបំផុតទទួលបានពីអ្នកដាក់ប្រាក់បញ្ញើ ហើយបន្ទាប់មកផ្ដល់កម្ចីទៅក្រុមគ្រួសារ ឬ អាជីវកម្ម។

ទិដ្ឋភាពទាំងពីរនៃធនាគារនាំឱ្យមានអ្វីដែលជាទូទៅ គេចាត់ទុកថាជាបញ្ហានៃការគ្រប់គ្រងរបស់ធនាគារកណ្ដាល គឺដើម្បីផ្សះផ្សាជម្លោះរបស់ធនាគារក្នុងគោលដៅសោធនភាព (លទ្ធភាពនៃការសងបំណុល) សន្ទនីយភាព និងប្រាក់ចំណេញ។

- អនុបាតសាធនភាព៖

  បំណុល = បំណុលសរុប / ទ្រព្យសរុប

  Time Interest = IncomeBIT /Interest
- សន្ទនីយភាព៖

  Current ratio = Current assets / Current liability

  Quick ratio = (Current assets-Inventory)/Current liability

### ៣.១.៣- តួនាទីរបស់ធនាគារ (The role of bank)

សាជីវកម្ម និងឧស្សាហកម្មធំៗអតិថិជនឯកត្តជន អាជីវកម្មតូចតាចទាំងអស់ បានពឹងផ្អែកលើធនាគារពាណិជ្ជ ដើម្បីបំពេញតម្រូវការគ្រប់ប្រភេទតម្រូវការហិរញ្ញវត្ថុ។ សម្រាប់តួនាទីទាំងបីផ្ដល់ជាវិភាគទានដ៏សំខាន់ចំពោះសេដ្ឋកិច្ច។

## ៣.២- មុខងារនៃប្រាក់បញ្ញើ ( Function of deposit )

### ៣.២.១- ប្រភេទសេវានៃប្រាក់បញ្ញើ ( Types of deposit services )

តើគេទទួលប្រាក់បញ្ញើយ៉ាងដូចម្ដេច? ទោះជាយ៉ាងណាក៏ដោយដើម្បីបង្កើន ឬពន្លឿនលំហូរចូលប្រាក់បញ្ញើ និងធ្វើឱ្យកាន់តែងាយដល់អតិថិជនសព្វថ្ងៃនេះ។ ធនាគារបានដាក់ចេញនូវមធ្យោបាយបន្ថែមជាច្រើន ដើម្បីទទួលបានប្រាក់បញ្ញើ។

- សេវាកម្មងាយស្រួលៈ ធនាគារពាណិជ្ជជាច្រើន ដើម្បីសម្រេចបាននូវឧត្ដមភាពប្រៀបធៀបពួកគេ បានផ្ដល់ភាពងាយស្រួលកាន់តែប្រសើរឡើង ដូចជាកន្លែងដាក់ប្រាក់សុវត្ថិភាពដែលជាប្រអប់ដាក់ប្រាក់ប្រព័ន្ធបច្ចេកវិទ្យា ឬការទាក់ទងដោយឥតយកថ្លៃ ធ្វើឱ្យងាយស្រួលដល់អតិថិជន។
- ប្រព័ន្ធផ្ទេរមូលនិធិតាមអេឡិចត្រូនិចៈ បង្កើតប្រព័ន្ធផ្ទេរប្រាក់តាមអេឡិចត្រូនិច (EFTS) បានបង្កើនមធ្យោបាយថែមទៀត ដើម្បីដាក់ប្រាក់ជាគណនីដោយអត់ត្រូវការអតិថិជនមកដល់ធនាគារ ឬការចំណាយពេលច្រើននោះទេ។
- ការផ្ទេររវាងធនាគារៈ អ្នកផ្ទេរតាមតេឡេក្រាម (Wire transfers) មានមធ្យោបាយដទៃទៀត ដើម្បីធ្វើប្រាក់បញ្ញើជាគណនី ដោយមិនចាំបាច់ពាក់ព័ន្ធជាមួយបេឡាករ។
- ការផ្ទេរក្នុងធនាគារៈ វិធីសាស្ត្រសាមញ្ញបំផុត ដែលឥណទានត្រូវបានគេផ្ដល់ គឺការស្រង់ឥណទានដាក់ចូលក្នុងឥណទានដូចគ្នា ក្នុងទម្រង់ជាសកម្មភាពប្រាក់បញ្ញើ។

### ៣.២.២- ការត្រួតពិនិត្យប្រាក់បញ្ញើ ( Control deposit )

ការពិនិត្យប្រាក់បញ្ញើៈ មុនពេលទទួលយកប្រាក់បញ្ញើពីអតិថិជន វាជាការសំខាន់ណាស់ដែលត្រូវពិនិត្យវា ដូចនេះធនាគារដឹងថាធនាគារទទួលបានចំនួនប៉ុន្មាន?

- រូបិយប័ណ្ណក្លែងក្លាយៈ យើងត្រូវការពិនិត្យរូបិយប័ណ្ណក្លែងក្លាយយ៉ាងយកចិត្តទុកដាក់ នៅពេលទទួលយកប្រាក់បញ្ញើ ប្រសិនបើមានរូបិយប័ណ្ណក្លែងក្លាយត្រូវតែប្រគល់ឱ្យអ្នកដាក់ប្រាក់វិញ។
- រូបិយបដិភោគ (បញ្ជាក់លើខ្នងឯកសារ)ៈ មូលប្បទានប័ត្រតំណាងឱ្យសាច់ប្រាក់ ឬប្រាក់បញ្ញើគួរតែត្រូវគេពិនិត្យដើម្បីរៀបចំជាក្រដាសរូបិយបដិភោគ។ ដោយការទទួលឱ្យចារលើក្រដាសរូបិយបដិភោគបេឡាករធ្វើការនេះឱ្យបានល្អទាំងធនាគារ និងអតិថិជនរបស់ខ្លួន។
- ប្រាក់បញ្ញើអាជីវកម្មៈ តាមច្បាប់ជាទូទៅរូបិយប័ណ្ណ និងមូលប្បទានប័ត្រគេត្រូវរាប់ពិនិត្យហើយផ្ទៀងផ្ទាត់ ទោះជាយ៉ាងណាក៏ដោយក៏មានអតិថិជនអាជីវកម្មជាច្រើនបានដាក់ប្រាក់

បញ្ញើរបស់គេជាកាស និងរូបិយប័ណ្ណយ៉ាងច្រើន។ ករណីទាំងនេះ ធនាគារ និងអ្នកដាក់ប្រាក់បញ្ញើបានយល់ព្រមគ្នាថាចំនួនប្រាក់ទាំងនេះ ត្រូវទទួលស្គាល់តាមចំនួនដែលផ្ទៀងផ្ទាត់ឃើញចុងក្រោយ ដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យពេលដាក់ និងពេលដក (ត្រួតពិនិត្យជាមួយគ្នាទៅវិញទៅមកពេលដាក់ និងដក)។

### ៣.២.៣- មុខងារទូទាត់ (Function of payment)

មូលប្បទានប័ត្រជាមធ្យោបាយងាយស្រួល ហើយមានសុវត្ថិភាពសម្រាប់ទូទាត់ ហើយត្រូវបានគេទទួលយក និងមានការជឿជាក់។

ឧទាហរណ៍៖ រូបិយវត្ថុងាយបាត់ និងត្រូវគេលួច។ ប្រសិនបើ ការទូទាត់ត្រូវគេធ្វើឡើងជាសាច់ប្រាក់វិក្កយបត្រ ដែលគេផ្ដល់អាចងាយបាត់។ ការទូទាត់ទំនើបវិញ យើងប្រើតាមយន្តការទូទាត់ដូចជាប្រព័ន្ធផ្ទេរប្រាក់តាមអេឡិចត្រូនិច ឬអេធីអឹម (ATM) ដើម្បីទទួលបាននូវសាច់ប្រាក់ដោយមិនប្រើមូលប្បទានប័ត្រ។

### ៣.២.៤- មុខងារឥណទាន (Function of credit)

គឺមានប្រភេទផលប័ត្រ៤ ជាមូលដ្ឋាននៅក្នុងធនាគារពាណិជ្ជក្នុងការរាយការណ៍ទៅឱ្យភ្នាក់ងាររដ្ឋាភិបាល។

- ឥណទានអចលនទ្រព្យ៖ សម្រាប់មូលនិធិផ្ដល់នូវការពាក់ព័ន្ធ និងអចលនទ្រព្យដែលធ្វើហិរញ្ញប្បទាន។ សម្រាប់អគារការិយាល័យថ្មីបណ្ដុំហាងលក់ទំនិញការកសាងផ្ទះ។ ការពាក់ព័ន្ធរបស់គេមានពីរទម្រង់គឺឥណទានសាងសង់ និងឥណទាននិក្ខេប (Mortgage Loan)។
- ឥណទានធនាគារ៖ សំដៅទៅលើការផ្ដល់ឥណទានយ៉ាងច្រើនដាក់ធនាគារផ្សេងៗ ពីធនាគារមួយទៅធនាគារមួយផ្សេងទៀត ដែលជារឿយៗការផ្ដល់ឱ្យធនាគារដែលមានការទាក់ទង។
- ឥណទានអតិថិជន៖ ផ្ដោតសំខាន់លើការផ្ដល់ឥណទានទៅឱ្យអាជីវកម្មតូចតាច និងតម្រូវការរបស់អតិថិជនដទៃទៀត។
- ឥណទានឧស្សាហកម្ម និងពាណិជ្ជកម្ម៖ ផ្ដោតសំខាន់លើប្រភេទឥណទានធំៗ ដែលផ្ដល់ទៅឱ្យធនាគារ។ ឥណទានមួយចំនួនមានរយៈពេលលើសមួយឆ្នាំ។ ឥណទានប្រភេទនេះភាគច្រើនមានរយៈពេលខ្លីជាងមួយឆ្នាំ។ កាលវសានសាមញ្ញបំផុត គឺមានរយៈពេល ៣ខែ។

## ៣.៣- ការគ្រប់គ្រងសេវាឥណទាន (Credit services management)

### ៣.៣.១- ដំណើរការឥណទាន (Credit processing)

ដំណើរការឥណទានមានបីដំណាក់កាល៖

**ក. ការបង្កើតអាជីវកម្ម និងការវិភាគឥណទាន៖**

ការបង្កើតអាជីវកម្ម ជាដំណើរការបង្កើតទីផ្សារសេវាកម្មធនាគារដល់អតិថិជនសក្តានុពល និងអតិថិជនដែលមានស្រាប់។ ចំណុចចាប់ផ្តើមសាមញ្ញនៃការខិតខំប្រឹងប្រែងក្នុងការបង្កើតអាជីវកម្មគឺការស្រាវជ្រាវទីផ្សារ និងការគ្រប់គ្រង ដែលដាក់ចេញនូវគោលដៅស្ថានភាពឥណទាន(ផ្តល់កម្ចីត្រឹមប៉ុន្មាន...អតិថិជនប្រភេទណា...) និងបង្ហាញពីតំបន់អាជីវកម្មមានសក្តានុពល។ ចំណុចសំខាន់ យើងត្រូវវិភាគហានិភ័យនៃការខកខាន (មិនបានសងត្រឡប់) ហើយផ្តោតជាសំខាន់លើការណែនាំឱ្យមានហានិភ័យសំខាន់ៗ ដោយយោងលើការវិភាគលើហ្វាយស៊ីនៃឥណទាន មានដូចខាងក្រោម៖

- ចារឹកលក្ខណ (Character)៖ សំដៅលើភាពស្មោះត្រង់របស់អតិថិជន។ ប្រសិនបើមានការសង្ស័យខ្លាំងគេមិនផ្តល់ឥណទានទេ។
- ដើមទុន (Capital)៖ សំដៅលើស្ថានភាពទ្រព្យសម្បត្តិរបស់អ្នកខ្ចី។
- សមត្ថភាព (Capacity)៖ ពាក់ព័ន្ធទាំងសិទ្ធិប្តឹងផ្លូវច្បាប់ និងជំនាញគ្រប់គ្រងក្នុងការថែរក្សាប្រតិបត្តិការ។
- លក្ខខណ្ឌ (Condition)៖ បរិយាកាសសេដ្ឋកិច្ច ឬការផលិតកត្តាបែងចែកដែលជះឥទ្ធិពលលើប្រតិបត្តិការរបស់ក្រុមហ៊ុន។
- វត្ថុបញ្ចាំ (Collateral)៖ គឺជាប្រភពនៃការទូទាត់មកវិញទី២របស់អ្នកឱ្យខ្ចី (បើគេមិនសងគេរឹបអូស) ក្នុងករណីដែលការខកខាន (មិនសងត្រឡប់មកវិញពីអ្នកខ្ចី)។

## ខ. ការអនុវត្តន៍ឥណទាន និងរដ្ឋបាល៖

នៅពេលឥណទានត្រូវបានគេអនុម័តវាជាកិច្ចព្រមព្រៀងរវាងអ្នកឱ្យខ្ចី និងអ្នកខ្ចី ដូចជាតារាងទូទាត់តម្រូវការវត្ថុបញ្ចាំភាពងាយស្រួលឥណទាន។

## គ. ការពិនិត្យមើល(ឡើងវិញ)ឥណទាន៖

ការខិតខំពិនិត្យឥណទានឡើងវិញត្រូវបានគេធ្វើឡើងក្រោយពីអនុម័តឥណទានរួច វាត្រូវបានគេធ្វើឡើងដោយផ្ទាល់ ដើម្បីកាត់បន្ថយហានិភ័យផងដែរ។ ការត្រួតពិនិត្យការងារឥណទានមានស្រាប់ និងដោះស្រាយឥណទានដែលមានបញ្ហាភាពចាំបាច់នៃការវិភាគឥណទានទាំងអស់ ត្រូវគេតាមដានឈរលើកត្តានៃការផ្តល់ឥណទាន ដូចជា៖

គ.១. ចរិតលក្ខណៈ៖

ធនាគារិកជាច្រើនយល់ស្របថាកត្តាដែលធំបំផុតនៃឥណទានដែលជោគជ័យ គឺភាពស្មោះត្រង់ និងកេរ្តិ៍ឈ្មោះរបស់អ្នកខ្ចី ហើយអ្នកខ្ចីដែលមិនស្មោះត្រង់ជាធម្មតាមិនមានការប្តេជ្ញាក្នុងការបង់បំណុលរបស់គេត្រឡប់មកវិញទេ។

គ.២. ការប្រើប្រាស់មូលនិធិឥណទាន៖

វិជ្ជាជីវៈគណនេយ្យរបស់អ្នកវិភាគ និងជំនាញហិរញ្ញវត្ថុ គឺសំខាន់ណាស់នៅក្នុងការកំណត់សមត្ថភាពរបស់អ្នកខ្ចីក្នុងការទូទាត់ឥណទានពីចំណូលសាច់ប្រាក់។

គ.៣. ប្រភពទី១ នៃការទូទាត់ (សំណង)៖

ជាទូទៅចំណូល (លំហូរ) សាច់ប្រាក់ពីប្រតិបត្តិការអាជីវកម្ម គឺជាប្រភពទូទាត់សំណងឥណទាន។ វត្ថុបញ្ចាំតែងតែត្រូវបានគេមើលឃើញថាជាប្រភពសំណងទី២ជាអ្នកធានា ឬសាក្សី (ផ្តិតមេដៃ) មិនមែនជាប្រភពទី១នៃការទូទាត់សំណងទេ។

### ៣.៣.២- សេវាប្រាក់បញ្ញើអតិថិជន (Customer deposit service)

បញ្ញើជាកិច្ចសន្យាដែលបុគ្គលម្នាក់ហៅថា "អ្នកខ្ចី" យកចលនវត្ថុទៅដាក់ផ្ញើនឹងបុគ្គលម្នាក់ទៀតហៅថា "អ្នកទទួលបញ្ញើ" ដែលយល់ព្រមទទួលទុកអចលនវត្ថុនោះ ហើយសន្យាថានឹងសងប្រគល់ឱ្យអ្នកផ្ញើវិញនៅពេលអ្នកផ្ញើស្នើសុំ។ ទាក់ទងនឹងវិស័យធនាគារចលនវត្ថុទាំងនោះ រួមមានប្រាក់មូលប័ត្រ ឬទ្រព្យដទៃទៀត ដែលមានតម្លៃផ្សេងៗ។ ន័យម្យ៉ាងទៀត ប្រាក់បញ្ញើគឺជាឥណទេយ្យហិរញ្ញវត្ថុរបស់ក្រុមហ៊ុនជំនួញ ក្រុមហ៊ុនគ្រួសារ និងរដ្ឋាភិបាលត្រូវទារពីធនាគារ។ ប្រភេទប្រាក់បញ្ញើ (Types of Deposits) មានបីប្រភេទគឺ ៖

១- ប្រាក់បញ្ញើចរន្ត (Demand Deposit/Current Account)៖ ប្រាក់បញ្ញើចរន្តជាប្រភេទគណនី ដែលអតិថិជនអាចដាក់ផ្ញើប្រាក់ជាប្រាក់រៀល ប្រាក់ដុល្លារ ឬក៏ប្រាក់បាត។ គណនីនេះ អតិថិជនប្រើប្រាស់មូលប្បទានប័ត្រ (Check/Cheque) ជាមធ្យោបាយក្នុងការទូទាត់ទំនិញ ឬសេវាបានដោយមិនចាំបាច់កាន់សាច់ប្រាក់តាមខ្លួន ហើយផ្តល់នូវភាពងាយស្រួល និងហ័សព្រមទាំងសុវត្ថិភាពខ្ពស់ក្នុងការទូទាត់។ ក្នុងការប្រើប្រាស់គណនីនេះ អតិថិជនពុំទទួលបាននូវការប្រាក់ទេ តែធនាគារបានជួយសម្រួល និងផ្តល់លទ្ធភាពចំណេញដល់អតិថិជនវិញតាមរយៈការប្រើប្រាស់បម្រើសេវាកម្មរបស់ខ្លួនចំពោះអតិថិជន។

២- ប្រាក់បញ្ញើសំចៃ ឬគណនីសន្សំ (Saving Deposit/Saving Account)៖ ជាប្រភេទគណនីបានដាក់ផ្ញើដោយរូបវន្តបុគ្គល និងនីតិបុគ្គល (ក្រុមហ៊ុនសហគ្រាស) ហើយអតិថិជនអាចដាក់ផ្ញើជារូបិយប័ណ្ណផ្សេងៗ ដូចជាបញ្ញើជាប្រាក់រៀល បញ្ញើជាដុល្លារ និងអាចដកប្រាក់ប្រើពេលណាក៏បានទៅតាមតម្រូវការរបស់ខ្លួន។ ចំពោះអតិថិជនបើកគណនីនេះ ធនាគារចេញសៀវភៅសន្សំ (Passbook) ដោយផ្តល់ជូនដោយមិនគិតថ្លៃ ដើម្បីទុកជាឧបករណ៍ក្នុងការដាក់ប្រាក់ និងដកប្រាក់ទៅតាមប្រតិបត្តិការប្រចាំថ្ងៃ និងការបញ្ជាក់ពីកម្មសិទ្ធិចេញច្បាស់លាស់។

៣- ប្រាក់បញ្ញើមានកាលកំណត់ ឬគណនីមានកាលកំណត់ (Term Deposit/Fixed Account)៖ ជាប្រភេទប្រាក់បញ្ញើដែលធនាគារផ្តល់ជម្រើសដ៏ល្អដល់អតិថិជនក្នុងការផ្ញើប្រាក់ ដើម្បីឱ្យទទួលបាននូវអត្រាការប្រាក់ខ្ពស់។ ប្រាក់បញ្ញើនេះមានរយៈពេលផ្សេងគ្នាដូចជា ៣ខែ ៦ខែ ៩ខែ ១២ខែ។ បើកាលវសាន្តនៃប្រាក់បញ្ញើកាន់តែយូរអត្រាការប្រាក់កាន់តែខ្ពស់។ បុគ្គលបើកគណនីមានកាលកំណត់នេះមានក្រុមហ៊ុនរូបវន្តបុគ្គលជាដើម។ ធនាគារចេញវិញ្ញាបនបត្រប្រាក់បញ្ញើ (Certificate Deposit) ជូនអតិថិជន ដើម្បីបញ្ជាក់ពីការផ្ញើប្រាក់នេះ។ វិ

ញ្ញាបនប័ត្រប្រាក់បញ្ញើនេះ ហុចលទ្ធភាពឱ្យអតិថិជនយកទៅដាក់ជាវត្ថុធានាយ៉ាងប្រសើរក្នុងការខ្ចីប្រាក់ ដើម្បីបំពេញនូវតម្រូវការរបស់ខ្លួន។ ប្រសិនបើអតិថិជនមកដកប្រាក់មុនកាលកំណត់នៃការសន្យាផ្ញើប្រាក់ធនាគារធ្វើការពិន័យ តែផ្ទុយទៅវិញ ចំពោះអតិថិជនណាដែលពុំបានដកប្រាក់នៅកាលវសានត្តនៃប្រាក់បញ្ញើរបស់ខ្លួន ធនាគារនឹងគិតការប្រាក់ជូនដល់អតិថិជននោះដោយផ្អែកលើរយៈពេលហួសកំណត់។

### ៣.៣.៣- សេវាប្រាក់កម្ចីធនាគារ ( Bank loan services )

មូលហេតុដ៏សំខាន់ក្នុងការបង្កើតធនាគារ គឺឱ្យអតិថិជនខ្ចីប្រាក់។ ភាគច្រើននៃប្រាក់កម្ចីមានចំនួនប្រហែលពាក់កណ្ដាល ឬជាងពាក់កណ្ដាលនៃទ្រព្យសកម្មសរុប ហើយផ្ដល់ប្រាក់ចំណូលប្រហែលពីរភាគបីនៃប្រាក់ចំណូលសរុបរបស់ធនាគារ។ ទោះបីជាយ៉ាងណា ហានិភ័យច្រើនតែកើតឡើងពីប្រតិបត្តិការឥណទាននេះដែរ។ ដូចនេះ ធនាគារគួរតែធ្វើការគ្រប់គ្រងឱ្យបានល្អ។ ឥណទាន គឺជាការផ្ដល់ឱ្យ ឬសន្យាផ្ដល់ឱ្យនូវមូលនិធិសម្រាប់ជាទុនអាជីវកម្ម ដែលត្រូវសងវិញដោយមានការប្រាក់ ឬការធានាតាមហត្ថលេខា ដើម្បីសងជួសកូនបំណុលចំពោះម្ចាស់បំណុល។ ប្រតិបត្តិការឥណទាន គឺសកម្មភាពមួយដោយគិតកម្រៃដែលបុគ្គលម្នាក់បានដាក់ ឬសន្យាដាក់ទុនឱ្យបុគ្គលម្នាក់ទៀតប្រើប្រាស់ ឬទទួលយកដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ឬដោយមានសន្យាចុះហត្ថលេខា ដូចជាការសន្យាធានាសង ការសងតាមរយៈការលក់វត្ថុធានាជាដើម។ ប្រភេទនៃប្រាក់កម្ចី (Types of Loans) ធនាគារ ឱ្យខ្ចីប្រាក់ច្រើនប្រភេទចំពោះអតិថិជនសម្រាប់គោលបំណងច្រើនប្រភេទ ដូចជាការវិនិយោគ ការទិញរថយន្តទិញលំនៅដ្ឋាន សម្រាប់ការសិក្សានៅមហាវិទ្យាល័យ។ ប្រភេទនៃការឱ្យខ្ចីរបស់ធនាគារអាចចាត់ថ្នាក់ដោយផ្អែកទៅតាមគោលបំណងនៃការប្រើប្រាស់ប្រាក់កម្ចីរបស់អតិថិជនដូចជាៈ

- ការឱ្យខ្ចីផ្នែកអចលនវត្ថុ (Real estate loans) គឺជាការឱ្យខ្ចីរយៈពេលខ្លីសម្រាប់ការសាងសង់ និងអភិវឌ្ឍដីធ្លី និងការឱ្យខ្ចីរយៈពេលវែង ដើម្បីផ្ដល់ទុនសម្រាប់ការទិញដីកសិកម្ម គេហដ្ឋានសំណង់ពាណិជ្ជកម្ម។
- ការឱ្យខ្ចីចំពោះគ្រឹះស្ថានហិរញ្ញវត្ថុ (Financial Institution Loans) ជាការផ្ដល់ឥណទានដល់ធនាគារ ក្រុមហ៊ុនធានារ៉ាប់រង ក្រុមហ៊ុនហិរញ្ញវត្ថុ និងស្ថាប័នហិរញ្ញវត្ថុផ្សេងៗ។
- ការឱ្យខ្ចីផ្នែកពាណិជ្ជកម្ម និងឧស្សាហកម្ម ការឱ្យខ្ចីនេះត្រូវបានផ្ដល់ឱ្យក្រុមហ៊ុនជំនួញសម្រាប់ការទូទាត់ការទិញសារពើភ័ណ្ឌ ការបង់ពន្ធ និងសម្រាប់បើកប្រាក់បៀវត្សសម្រាប់ការពង្រីកបន្ថែមនូវអាជីវកម្មរបស់ខ្លួនជាដើម។
- ការឱ្យខ្ចីចំពោះបុគ្គល (Loans to Individual) ជាឥណទានសម្រាប់ការទូទាត់លើការទិញរថយន្ត កែលម្អគេហដ្ឋាន ទូទាត់ថ្លៃថែទាំសុខភាព និងចំណាយផ្ទាល់ខ្លួនផ្សេងៗ។

### ៣.៣.៤- សេវាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ( Microfinance institution services )

មីក្រូហិរញ្ញវត្ថុ គឺធនាគារសម្រាប់ជនក្រីក្រមានន័យថាចំនួនឱ្យខ្ចីមានទំហំតូចៗ។ តាមរយៈធនាគារអភិវឌ្ឍន៍ជនបទ ប្រតិបត្តិការមីក្រូហិរញ្ញវត្ថុជាតិ និងអន្តរជាតិបានផ្ដល់ជូនសេវាឥណទានគាំទ្រដល់

ការអភិវឌ្ឍន៍ជនបទ ដោយឈរលើគោលការណ៍ទីផ្សារសេរី ដើម្បីវឌ្ឍនភាពប្រសិទ្ធភាព និងស្ថិរភាព។ រាជរដ្ឋាភិបាលបានកំណត់ច្បាស់ថាមីក្រូហិរញ្ញវត្ថុ គឺជាយន្តការមួយមិនអាចខ្វះបានក្នុងជួយដល់ការងារអភិវឌ្ឍន៍សហគមកម្ពុជាលើគ្រប់វិស័យ។ ក្នុងនោះការផ្តល់នូវសេវាឥណទានជនបទកំពុងតែមមាញឹក ផ្តល់ទុនជូនប្រជាជនដោយផ្ទាល់នៅទូទាំងប្រទេស។ លើវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាចាប់កំណើតតាំងពីឆ្នាំ ១៩៩២-១៩៩៣។ បច្ចុប្បន្នមានការរីកចម្រើនគួរឱ្យកត់សម្គាល់។

សេវាមីក្រូហិរញ្ញវត្ថុភាគច្រើនសម្រាប់ធនាគារពាណិជ្ជកម្ម បានផ្តល់សេវា និងឥណទាន បានតែទីប្រជុំជន ឬទីក្រុងតែប៉ុណ្ណោះ។ ចំណែកប្រជាជននៅតាមទីជនបទ ពុំអាចមានលទ្ធភាពខ្ចីប្រាក់ពីធនាគារពាណិជ្ជបានឡើយ។ សេវាមីក្រូហិរញ្ញវត្ថុ មានឥណទានទោល ឥណទានជាក្រុម ការសន្សំប្រាក់ ការហ្វឹកហ្វឺន កាចុះតាមដាន និងផ្តល់យោបល់ដល់ប្រជាជនដែលបានខ្ចីប្រាក់។ ការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចែកចេញជាពីរគឺ៖

- ឥណទានទោល៖ ផ្តល់ជូនអតិថិជនជាឯកត្តជន ហើយតម្រូវការឱ្យមានទ្រព្យសម្បត្តិដាក់ធានា ដើម្បីការពារនៅពេលមានការខកខានក្នុងការសងបំណុលត្រឡប់វិញ។ ឥណទានប្រភេទនេះ ត្រូវបានផ្តល់សម្រាប់មុខរបរជំនួញខ្នាតតូច និងមធ្យមពី ១០០ - ៥០០ដុល្លារអាម៉េរិក និងអត្រាការប្រាក់អាស្រ័យលើគោលនយោបាយរបស់ប្រតិបត្តិការនីមួយៗ។
- ឥណទានជាក្រុម ៖ ប្រភេទឥណទានសម្រាប់ប្រជាពលរដ្ឋក្រីក្រ ដែលមានមុខរបរជំនួញ តូចៗ ឬមុខរបរកសិកម្ម ដោយមិនតម្រូវឱ្យមានទ្រព្យសម្បត្តិធានាទេ ប៉ុន្តែអតិថិជនត្រូវចងក្រងគ្នាជាក្រុមពី ៣ ទៅ ១០នាក់ សម្រាប់ធានាគ្នាទៅវិញទៅមក។ ទំហំឥណទានចាប់ពី ២០ ទៅ ១០០ ដុល្លារអាម៉េរិក។ អត្រាការប្រាក់ នៅចន្លោះពី ៣% ទៅ ៥% ក្នុងមួយខែ អាស្រ័យលើគោលនយោបាយរបស់ប្រតិបត្តិការនីមួយៗ។

### ៣.៣.៥- តួនាទីសំខាន់របស់ធនាគារក្នុងសេដ្ឋកិច្ច

(Role of bank for economics)

អន្តរការីរកប្រាក់ចំណេញតាមរយៈភាពខុសគ្នារវាងប្រាក់កម្ចី និងប្រាក់បញ្ញើ។ អន្តរការីបានផ្តល់សេវាកម្ម៤ប្រភេទ ដែលប្រជាជនយល់ព្រមបង់ជូន៖

១. ការបង្កើតសាច់ប្រាក់៖

គឺជាទ្រព្យសកម្មសន្ទនីយភាព (ងាយបម្លែងជាសាច់ប្រាក់)។ ទ្រព្យសកម្មនេះ បានមកតាមរយៈអតិថិជនយកមកផ្ញើ ហើយធនាគារប្រើវាជាទុនសម្រាប់ការផ្គត់ផ្គង់រូបិយវត្ថុ។ អន្តរការីធនាគារបង្កើតសាច់ប្រាក់ដោយកម្ចីរយៈពេលខ្លី (ប្រាក់បញ្ញើ) និងផ្តល់កម្ចីរយៈពេលវែង។ កម្ចីរយៈពេលខ្លីមានន័យថាយកប្រាក់បញ្ញើសម្រាប់ដំណើរការចូលត្រៀមខ្លួនជាស្រេច ដើម្បីបង់ជូនអតិថិជនវិញនៅពេលត្រូវការ។ កម្ចីរយៈពេលវែងមានន័យថាអ្នកខ្ចីយកលុយទៅប្រើបានយូរ ដោយគ្រាន់តែបង់ការប្រាក់ប៉ុណ្ណោះ ជូនកាលរយៈពេលរហូតដល់ ២០-២៥ឆ្នាំ ដូចជាការទិញអគារអាជីវកម្មលំនៅដ្ឋាន។ល។

២. ការបន្ថយចំណាយអប្បបរមានៃការទទួលមូលនិធិ៖

គឺជាមុខងារទី២ដែលអន្តរការីហិរញ្ញវត្ថុត្រូវតែប្រតិបត្តិ។ តាមធម្មតាអ្នកខ្ចីបុលពិតជាលំបាកក្នុងការស្វែងរកកម្ចី ដោយចំណាយពេលវេលា ចំណាយឱកាស ដោយសារតែអន្តរការីធនាគារអ្នកមកខ្ចីទទួលបានសេវាកម្មល្អ។ ចំណាយកម្ចីទាប ដោយសារអន្តរការីមានលទ្ធភាពប្រមូលប្រាក់បញ្ញើពីអតិថិជនបានច្រើន ហើយធ្វើការផ្តល់កម្ចី។

៣. ការបន្ថយចំណាយអប្បបរមានៃការត្រួតពិនិត្យអ្នកខ្ចី៖

គឺជាមុខងាររបស់អន្តរការីរបស់ធនាគារក្នុងការជ្រើសរើសអ្នកខ្ចីប្រាក់ ដែលមានលទ្ធភាពសងវិញ ដោយធ្វើយ៉ាងណាប្រើប្រាស់ចំណាយអធិការកិច្ចទាប និងប្រើពេលវេលាតិចបំផុត។

៤. បង្រួមហានិភ័យ៖

គឺអន្តរការីហិរញ្ញវត្ថុចង់កាត់បន្ថយភាពបាត់បង់ដោយចៃដន្យ។ គេត្រូវកាត់បន្ថយអ្នកខ្ចី ដែលមិនគោរពតាមគោលការណ៍ ព្រោះមិនគ្រាន់តែបាត់បង់ប្រាក់តែប៉ុណ្ណោះទេ។ ប៉ុន្តែថែមទាំងបណ្តាលឱ្យបាត់បង់ជំនឿទុកចិត្តរបស់អ្នកដាក់ប្រាក់បញ្ញើទៀតផង។

និយ័តកម្មធនាគារកណ្តាលប្រើជាមធ្យោបាយគឺ ៖

- ការកំណត់បរិមាណកម្ចីធនាគារ៖

គឺជាការកំណត់របស់ធនាគារកណ្តាល ឬសហព័ន្ធលើការកំណត់លក្ខខណ្ឌ និងទឹកប្រាក់អតិបរមាដែលអតិថិជនអាចឱ្យខ្ចី។ ករណីមួយចំនួនដែលធនាគារកំណត់ចង្អុលទៅលើធនាគារណាដែលខ្ចីបានតាមកម្រិតប្រាក់តម្កល់។ នៅក្នុងពេលចាំបាច់ធនាគារកណ្តាលមានសិទ្ធិផ្អាកអាជីវកម្មបណ្តោះអាសន្នដើម្បីត្រួតពិនិត្យបរិមាណប្រាក់ផ្តល់កម្ចី។

- ការត្រួតពិនិត្យអត្រាការប្រាក់៖

គឺតួនាទីរបស់ធនាគារកណ្តាលនៅក្នុងការត្រួតពិនិត្យអត្រាការប្រាក់បញ្ញើ និងប្រាក់កម្ចី។ ជាទូទៅ ធនាគារកណ្តាលចេញច្បាប់អត្រាការប្រាក់ក្នុងកម្រិតខុសគ្នារវាងកម្ចី និងបញ្ញើ ដើម្បីឱ្យធនាគារពាណិជ្ជទទួលបានផលកម្រៃ។ ប្រសិនបើ ធនាគារណាមួយផ្តល់អត្រាការប្រាក់ខ្ពស់ពេកអាចក្លាយជាធនាគារផ្តាច់មុខ អាចផ្តល់នូវផលវិបាកច្រើនដល់សង្គមសេដ្ឋកិច្ច។

ឧទាហរណ៍៖ ភាគច្រើននៃធនាគារនៅសហរដ្ឋអាម៉េរិកផ្តល់អត្រាការប្រាក់បញ្ញើក្នុងរវាង ៣-៧ ភាគរយ ទន្ទឹមនឹងនេះ កម្រិតអតិផរណា ២-៣ ភាគរយ។ ប្រសិនបើ ធនាគារណាមួយមិនគោរពតាមអត្រាការប្រាក់កំណត់បែបនេះ ដូចជាបង្កើនអត្រាការប្រាក់ខ្ពស់ជាងនេះ នោះតុលាការសភាពាណិជ្ជកម្មនឹងធ្វើការផាកពិន័យ។ សម្រាប់ប្រទេសអូស្ត្រាលីក៏ដូចគ្នាដែរ ហើយប្រតិបត្តិច្បាប់បែបនេះ ដើម្បីជានាការប្រកួតប្រជែងប្រកបដោយសុក្រឹត្យភាព។

ធនាគារកណ្តាលកត់សម្គាល់ថា ប្រសិនបើ គេមិនទប់ស្កាត់ទេអាចឱ្យមានការដួលរលំនៃការវិនិយោគទុន។ ធនាគារតូចៗ និងការបាត់បង់ការងារធ្វើព្រមទាំងផលវិបាកដល់សង្គមដទៃទៀត។ ម្យ៉ាងទៀតប្រសិនបើ សេដ្ឋកិច្ចមានការរីកចម្រើនធនាគារទាំងឡាយមិនអាចដំឡើងអត្រាការប្រាក់ ដើម្បីទាក់ទាញអតិថិជនបានទេ។ ព្រោះអតិថិជនដែលធ្វើប្រាក់ពេលមុនអាចទទួលការខកចិត្ត និងមិនយុត្តិធម៌។

- អត្រាទុនទ្រព្យសាច់ប្រាក់តិចបំផុត៖

គឺជាការកំណត់របស់ធនាគារកណ្តាលទៅលើតម្រូវការបញ្ញើប្រាក់បម្រុងទុក ឬតម្កល់ជារូបិយវត្ថុនៅធនាគារកណ្តាល ឬប័ណ្ណជានា។ ប្រការដែលថាធនាគារកណ្តាល ធ្វើបែបនេះគឺចូលរួមចំណែកដល់ការការពារសំណងអតិថិជនយ៉ាងហោចណាស់ពាក់កណ្តាល។ ប្រសិនបើធនាគារឯកជន ឬធនាគារពាណិជ្ជកម្មណាមួយដួលរលំធនាគារកណ្តាលអាចជួយទប់ស្កាត់ការដួលរលំធនាគារនានាតាមរយៈការផ្តល់កម្ចីបន្ថែម និងកាត់បន្ថយមហិច្ឆិតារបស់ធនាគារពាណិជ្ជកម្ម ដែលផ្តល់កម្ចីដល់ឯកជនច្រើនពេក ឬលួចទៅធ្វើវិនិយោគក្រៅពីធនាគារ។

## ៣.៤- មុខងារចម្បងរបស់ធនាគារកណ្តាល ( The Major function of Central Bank )

មុខងារចម្បងរបស់ធនាគារកណ្តាលដូចបានមើលឃើញនៅក្នុងតួនាទីក្នុងនាមជាធនាគារិក និងជាទីប្រឹក្សាឱ្យរដ្ឋាភិបាល។ ធនាគារកណ្តាលមានការទទួលខុសត្រូវ៖ ត្រូវបន្តណែនាំដល់ទីផ្សារអន្តរធនាគារឱ្យកាន់តែប្រសិទ្ធភាព ក៏ដូចជាតួនាទីរបស់ធនាគារកណ្តាលក្នុងការគ្រប់គ្រងសាច់ប្រាក់ងាយស្រួលរបស់ធនាគារជាដើម។ មុខងារចម្បងបន្ថែមរបស់ធនាគារកណ្តាល ដូចខាងក្រោម៖

- ទីផ្សារអន្តរធនាគារ
- ការគ្រប់គ្រងសាច់ប្រាក់ងាយស្រួលរបស់ធនាគារ
- ធនាគារិករបស់រដ្ឋាភិបាល
- គណនីបង់ពន្ធ និងគណនីឥណទាន
- ការគ្រប់គ្រងបំណុលសាធារណៈ
- ការគ្រប់គ្រងត្រួតពិនិត្យការប្តូរប្រាក់

## ៣.៥- ទីផ្សារអន្តរធនាគារ ( The Interbank markets )

ទីផ្សារអន្តរធនាគារមានចំនួនបីគឺ៖

- ទីផ្សារអន្តរធនាគាររវាងធនាគារ និងធនាគារកណ្តាល
- ទីផ្សារអន្តរធនាគាររវាងធនាគារកណ្តាល និងធនាគារ
- ទីផ្សារអន្តរធនាគាររវាងធនាគារ និងធនាគារ

ជាថ្មីម្តងទៀត តារាងតុល្យការលេខ១ ខាងក្រោមនេះចង់បង្ហាញពីតារាងតុល្យការរបស់ធនាគារកណ្តាល និងធនាគារ។ ចំពោះប្រភេទគណនីដែលចង់បង្ហាញក្នុងតារាងតុល្យការនេះគឺជាមុខងាររបស់អន្តរធនាគាររវាងក្រុមហ៊ុន IBM។

ករណីក្រុមហ៊ុន IBM គឺជាកន្លែងទូទាត់សំណងរវាងអន្តរធនាគារដែលបានកើតឡើង ហើយក៏ជាទីកន្លែងចាប់ផ្តើមធ្វើគោលនយោបាយរូបិយវត្ថុផងដែរ។ នៅតាមបណ្តាប្រទេសខ្លះ ធនាគារមានគណនីចំនួនពីរជាមួយនឹងធនាគារកណ្តាលគឺ៖ គណនីបម្រុងទុនដែលក្នុងនោះមានគណនីទុនបម្រុងកាតព្វកិច្ចត្រូវបានកាន់កាប់ និងគណនីទូទាត់សំណង ដែលការទូទាត់សំណងរវាងអន្តរធនាគារ នៅពេលមានប្រតិបត្តិការកើតឡើង។ តាមបណ្តាប្រទេសខ្លះទៀត ធនាគារពាណិជ្ជមានគណនីតែមួយគត់

ជាមួយនឹងធនាគារកណ្តាល ហើយគណនីនេះមានឈ្មោះជាច្រើន ដូចជាគណនីបម្រុងទុន គណនីទូទាត់សំណង គណនីបម្រុងសាច់ប្រាក់ជាដើម។ យើងកំណត់ហៅថា "គណនីបម្រុងទុន"។

| BALANCE SHEET 1: CENTRAL BANK (USD BILLIONS) | | | |
|---|---|---|---|
| Assets | | Liabilities | |
| | | H. Notes and coins | 1,000 |
| | | I. Deposits | |
| D. Foreign assets | 1,000 | 3. Government | 900 |
| | | 4. Bank's reserves (TR) | 500 |
| E. Loans to government | 1,100 | a. Required reserves (RR) | |
| | | (500) | |
| F. Loans to banks (borrowed | 400 | b. Excess reserves (ER) (0) | |
| reserves - BR) @ KIR | | J. Foreign loans | 100 |
| | | K. Central bank securities | |
| **Total** | **2,500** | **Total** | **2,500** |

| BALANCE SHEET 2: BANK (USD BILLIONS) | | | |
|---|---|---|---|
| Assets | | Liabilities | |
| C. Notes and coins | 100 | | |
| D. Reserves with central bank (TR) | 500 | A. Deposits of NBPS (BD) | |
| 1. Required reserves (RR = 500) | | | 5,000 |
| 2. Excess reserves (ER = 0) | | B. Loans from central | |
| E. Foreign loans | 1,000 | bank (BR) @ KIR | 400 |
| Central bank securities | 3,800 | | |
| **Total** | **5,400** | **Total** | **5,400** |

ក្នុងគណនីនេះ ធនាគារពាណិជ្ជកម្មមានឈ្មោះថា គណនីទុនបម្រុងកាតព្វកិច្ច (Require Reserve)។ បើសិនករណី មានគណនីបម្រុងទុនលើស(Excess Reserve) នោះ។ យើងអាចសរុបផលបូកនៃគណនីទាំងពីរនេះ ដោយកំណត់បាន "ផលបូកបម្រុងទុនសរុប (Total reserve)" ។

ដែលមានសមីការដូចខាងក្រោម៖

$$TR = RR + ER.$$

ដូចនេះ ក្រុមហ៊ុន IBM មានប្រតិបត្តិការនៅក្នុងទីផ្សារ៣ប៉ុណ្ណោះ ដែលជាទីផ្សារពិត គឺជាទីផ្សារធនាគាររបស់ក្រុមហ៊ុន IBM ។ ហើយអត្រា IBM ត្រូវបានបង្ហាញជាមួយនឹងទីផ្សារ KIR មាននៅក្នុងរូបភាពទី២។[១៦] ដូចដែលយើងបានដឹងហើយថាទីផ្សារ KIR ត្រូវបានកំណត់ដោយគណៈកម្មការគោលនយោបាយរូបិយវត្ថុ (MPC)។ វាបង្ហាញពីឥទ្ធិពលកម្រិតអត្រានៃក្រុមហ៊ុន IBM ។ ចូរកត់ចំណាំថា វាមាននៅទីផ្សារ KIR។

ក្រាហ្វិកទី២ បង្ហាញពីៈ ឥទ្ធិពលកម្រិតអត្រារបស់ KIR




Source: interbank rate @ KIR

## ៣.៥.១- ទីផ្សារអន្តរធនាគាររវាងធនាគារ និងធនាគារកណ្តាល (The bank-to-central bank interbank market)

ពីដំបូងយើងបានសិក្សាពីក្រុមហ៊ុន IBM គឺទីផ្សារអន្តរធនាគារ និងធនាគារកណ្តាល "ទីផ្សារ" ឬហៅថា "b2cb IBM"។ វាគឺជាការ "គ្រប់គ្រង" ទីផ្សារ ដែលជាលំហូរផ្លូវតែមួយពីធនាគារទៅធនាគារកណ្តាលក្នុងទម្រង់នៃទុនបម្រុងកាតព្វកិច្ចជាសាច់ប្រាក់។ ដូចបានរៀបរាប់ខាងលើ យើងនឹងយោងលើបរិមាណទុនបម្រុងកាតព្វកិច្ចជាសាច់ប្រាក់ ដូចជាទុនបម្រុងកាតព្វកិច្ច (Required Reserve)។

សម្រាប់គណនីទុនបម្រុងកាតព្វកិច្ចរបស់ធនាគារ ត្រូវបានរក្សាទុកនៅលើគណនីទុនបម្រុងជាមួយនឹងធនាគារកណ្តាល។ តាមបណ្តាប្រទេសភាគច្រើននៃសមតុល្យនៃគណនីទុនបម្រុងកាតព្វកិច្ចពុំសូវចាប់អារម្មណ៍ជាធាតុសំខាន់នៅក្នុងគោលនយោបាយរូបិយវត្ថុទេ។ ជាតុផ្ទុំសំខាន់មួយទៀតនៃគោលនយោបាយរូបិយវត្ថុនៅតាមបណ្តាប្រទេសភាគច្រើន តម្រូវឱ្យធនាគារពាណិជ្ជកម្មរក្សាទុកទុន

[១៦] *The data span is almost 10 years, and is for a particular country, which has a good record in term of the conduct of monetary policy. The central bank's target is interest rates, and it manages rates via creating a permanent bank liquidity shortage (LS), which makes the KIR effective. This means, as seen in the figure, that the unfettered IBM rate is set by the banks with reference to the KIR. In mormal times, this is the style of policy adopted by most central bank.*

បម្រុងនៅក្នុងធនាគារកណ្តាលសម្រាប់រយៈពេលខ្លី (នឹងសិក្សាពេលក្រោយ) ដូចជាករណីទុនបម្រុងលើស (ER) សម្រាប់ប្រព័ន្ធធនាគារ គឺមិនមាននោះទេ។ ដើម្បីធ្វើឱ្យកាន់តែប្រសើរឡើងនៃគណនីទុនបម្រុងកាតព្វកិច្ច(RR)៖ នៅតាមបណ្តាធនាគារប្រទេសភាគច្រើនតម្រូវតាមលក្ខន្តិក ដើម្បីរក្សាសមាមាត្រជាក់លាក់ ឬប្រាក់បញ្ញើរបស់ពួកគេក្នុងគណនីមួយជាមួយនឹងធនាគារកណ្តាល។ ករណីនេះ វាមានដើមកំណើតពីទុនបម្រុងកាសមាសដែលកាន់កាប់ដោយធនាគារិក(goldsmith)កាលពីសតវត្សរ៍ទី១៧ ហើយក្រោយមកកាន់កាប់ប្រាក់បញ្ញើដោយធនាគារអង់គ្លេសវិញម្តង។

ក្នុងតារាងតុល្យការ (១ និង ២) មានប្រាក់បញ្ញើធនាគារ (Bank Deposit) ចំនួន USD 5,000 billion ។ ដូច្នេះ ពួកគេកំពុងកាន់ទុនបម្រុងអប្បបរមាដែលមានតម្រូវការ (TR = RR) ពួកគេធ្វើដូច្នេះ ដូចបានកត់សម្គាល់ថា ធនាគារកណ្តាលមិនបានបង់ការប្រាក់ទៅលើប្រាក់ទុនបម្រុងទេ។[១៧] កំណត់សម្គាល់ផងដែរ ក្នុងឧទាហរណ៍ ធនាគារត្រូវបានកំពុងខ្ចីប្រាក់ USD 400 billion ពីធនាគារកណ្តាល ដូច្នេះពួកគេនឹងមិនមានទុនបម្រុងលើសទេ (ER)។ សរុបរួម ទំនាក់ទំនងនឹងក្រុមហ៊ុន b2cb IBM គឺ៖

$$BD \times r = RR = TR.$$
$$5{,}000\ billion \times 0.01 = 5{,}000\ billion = TR$$
$$ER = 0.$$

## ៣.៥.២- ទីផ្សារអន្តរធនាគាររវាងធនាគារកណ្តាល និងធនាគារ

(The central bank-to-bank interbank market)

ករណីទី២ ការសិក្សាលើក្រុមហ៊ុន IBM ស្តីពី "ទីផ្សារអន្តរធនាគារ" រវាងធនាគារកណ្តាល និងធនាគារ ឬហៅកាត់ថា cb2b IBM។ វាគឺជាទីផ្សារ "ការគ្រប់គ្រង" ដែលស្ថិតនៅចំណុចស្នូលនៃគោលនយោបាយរូបិយវត្ថុរបស់ធនាគារកណ្តាលប្រទេសភាគច្រើន។ វាឱ្យតំណាងឱ្យប្រាក់កម្ចីពីធនាគារកណ្តាលទៅកាន់ធនាគារធនាគារបម្រុង(Bank reserve)។ ធនាគារកណ្តាល បានផ្តល់ទុនបម្រុងទាំងនេះនៅទីផ្សារ KIR ។

ដូចយើងដែលបានឃើញនៅក្នុងតារាងតុល្យការខាងលើ។

BR= USD 400 billion.

នៅតាមបណ្តាប្រទេសភាគច្រើន គោលនយោបាយរូបិយវត្ថុ មានគោលបំណងជានាន្ទវបំណុលធនាគារដែលជំពាក់ធនាគារកណ្តាលគ្រប់ពេលវេលា។ ដូច្នេះទីផ្សារ KIR ត្រូវតែធ្វើឱ្យមានប្រសិទ្ធិភាពនៅផ្នែកខ្លះនៃបំណុលធនាគារ (បំណុលធនាគារ = BD + BR)។ ទីផ្សារ KIR មានឥទ្ធិពលយ៉ាងខ្លាំងទៅលើអត្រាការប្រាក់បញ្ញើធនាគារ និងមានកម្រិតតិច ឬច្រើនតាមរយៈការកម្រិតមធ្យមភាគអត្រា

[១៧] *In some countries, the central bank does, but this takes place under extrems conditions of high bank liquidity when there is no other option. High liquidity renders monetary policy ineffective, and paying interest is an effort to make policy partially effective. This is a complicated story on which we will be silent in this book in the interests of our keeping the principles unfettered.*

ប្រាក់គោលរបស់ធនាគារ។[១៨] យើងនឹងបង្ហាញនៅពេលក្រោយលម្អិត គឺជាពិធីសារគោលនយោបាយរូបិយវត្ថុ ដែលទទួលបានជោគជ័យយ៉ាងខ្លាំង។

### ៣.៥.៣- ទីផ្សារអន្តរធនាគាររវាងធនាគារ និងធនាគារ (bank-to-bank interbank market)

ទីផ្សារអន្តរធនាគាររវាងធនាគារ និងធនាគារ ឬហៅថា b2b IBM ។ ទីផ្សារទាំងនេះ ដំណើរការនៅក្នុងថ្ងៃធ្វើការរបស់ធនាគារ ប៉ុន្តែជាពិសេសនៅពេលបិទបញ្ជីអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ (ធនាគារ "បិទបញ្ជី" ប្រចាំថ្ងៃ)។ ឧទាហរណ៍៖ អតិថិជនរបស់ក្រុមហ៊ុនសាជីវកម្ម (A) បានដកប្រាក់សំណងពីគណនីប្រាក់បញ្ញើធនាគារ (A) ចំនួន ១០០ ពាន់លានដុល្លារ ហើយបានដាក់បញ្ចូលទៅក្នុងគណនីធនាគារ (B) ពីព្រោះធនាគារ (B) បានផ្ដល់នូវអត្រាការប្រាក់ខ្ពស់។ តើការទូទាត់ប្រតិបត្តិការទាំងនេះកើតឡើងយ៉ាងដូចម្ដេចរវាងធនាគារទាំងពីរ? វាកើតឡើងលើគណនីបម្រុងរបស់ធនាគារ (Bank's reserve) គណនី items B2 ក្នុងតារាងតុល្យការ ១ និងគណនី item D សម្រាប់ទុនបម្រុងជាមួយនឹងធនាគារកណ្ដាលនៅក្នុងតារាងតុល្យការ ២។
តារាងតុល្យការ ៣-៦ បានបង្ហាញពីប្រវត្តិនៃប្រតិបត្តិការ៖

| BALANCE SHEET 3: COMPANY A (USD BILLIONS) | | | |
|---|---|---|---|
| **Assets** | | **Liabilities** | |
| Deposit at Bank A | -100 | | |
| Deposit at Bank B | +100 | | |
| **Total** | **0** | **Total** | **0** |

| BALANCE SHEET 4: BANK A (USD BILLIONS) | | | |
|---|---|---|---|
| **Assets** | | **Liabilities** | |
| Reserve account at CB | -100 | Deposits (Company A) | -100 |
| **Total** | **-100** | **Total** | **-100** |

| BALANCE SHEET 5: BANK B (USD BILLIONS) | | | |
|---|---|---|---|
| **Assets** | | **Liabilities** | |
| Reserve account at CB | +100 | Deposits (Company A) | +100 |
| **Total** | **+100** | **Total** | **+100** |

[១៨] The singular is applicable because the banks always have the same prime rate-certainly in the vast majority of contries.

| BALANCE SHEET 6: CENTRAL BANK ( USD BILLIONS ) | | | |
|---|---|---|---|
| Assets | | Liabilities | |
| | | Reserve account:<br>Bank A<br>Bank B | <br>-100<br>+100 |
| Total | 0 | Total | 0 |

ដោយសន្មតថាការបិទបញ្ជីអាជីវកម្មធនាគារទាំងពីរកាលពីម្សិលមិញ ធនាគារទាំងនេះមិនបានខ្ចីប្រាក់ពីធនាគារកណ្តាល (BR = 0) នោះទេ។ ពួកគេក៏ពុំមានប្រាក់ ដែលលើសណាមួយជាមួយនឹងធនាគារកណ្តាលនេះដែរ ដោយ( TR = RR; ER = 0 )៖

- ធនាគារ Bank A ឥឡូវខ្វះទុនបម្រុងកាតព្វកិច្ច (RR) មានចំនួនទឹកប្រាក់ ១០០ ពាន់លានដុល្លារ។ ដូច្នេះ មិនបានអនុវត្តតាមទុនបម្រុងកាតព្វកិច្ចនោះទេ ( TR <RR ) ។
- ឥឡូវនេះ ធនាគារមានទុនបម្រុងអតិរេករបស់ធនាគារ (B) ដែលឥឡូវនេះមានទុនបម្រុងលើស ( TR > RR ឬ TR – RR = ER = USD 100 billion )។

| BALANCE SHEET 7: BANK A ( USD BILLIONS ) | | | |
|---|---|---|---|
| Assets | | Liabilities | |
| | | Deposits ( Company A )<br>Loan ( Bank B ) | -100<br>+100 |
| Total | 0 | Total | 0 |

| BALANCE SHEET 8: BANK B ( USD BILLIONS ) | | | |
|---|---|---|---|
| Assets | | Liabilities | |
| Loan to Bank A | +100 | Deposits ( Company A ) | +100 |
| Total | +100 | Total | +100 |

យើងសន្មតថានេះ គឺជាប្រតិបត្តិការតែមួយគត់ដែលកើតឡើងប្រចាំថ្ងៃ ហើយធនាគារ (B)មិនមានប្រាក់កម្ចីដែលខ្ចីពីធនាគារកណ្តាលទេ។ ឥឡូវនេះ យើងជិតបញ្ឈប់សកម្មភាពអាជីវកម្មហើយ។ ប្រព័ន្ធទូទាត់អន្តរធនាគារអេឡិចត្រូនិក បានបង្ហាញព័ត៌មានទាំងពីរដែលមានព័ត៌មានខាងលើ ដែលទាក់ទងនឹងប្រតិបត្តិការនីមួយៗ។ ធនាគារ (A) ត្រូវការខ្ចីប្រាក់ ១០០ពាន់លានដុល្លារ ហើយធនាគារ

(B)បានដាក់បញ្ចូលគណនីបម្រុងលើស(ER)ទៅគណនីណាមួយដែលក្នុងនោះមានអត្រាការប្រាក់។ ចុងបញ្ចប់នៃថ្ងៃធ្វើអាជីវកម្ម គឺមានតែធនាគារផ្សេងទៀត(ករណីនេះមានធនាគារ A)។

ដំណើរការសម្អាតអន្តរធនាគារចុងក្រោយនៃថ្ងៃអាជីវកម្មប្រព្រឹត្តិទៅលើគណនីទុនបម្រុងដូចគ្នាទាំងនេះជាមួយនឹងធនាគារកណ្តាល។ ករណីក្រុមហ៊ុន b2b IBM មានអតិរេកធនាគារសម្រាប់ធនាគារ B នឹងដាក់បញ្ចូលទុនបម្រុងលើស (ER) មានទឹកប្រាក់ចំនួន USD 100 billion ជាមួយធនាគារ (A) ហើយនេះនឹងកើតឡើងតាមអត្រារបស់ក្រុមហ៊ុន IBM (បន្ទាប់ពីមានបញ្ហាខ្លះ) ។ ធនាគារ (B ) នឹងណែនាំធនាគារកណ្តាលឱ្យដកប្រាក់បម្រុងខាងឥណពន្ធ និងគណនីទុនបម្រុងរបស់ធនាគារ (A) ខាងឥណទាន។ តារាងតុល្យការរបស់ធនាគារកណ្តាលនឹងមិនផ្លាស់ប្តូរទេ ហើយតារាងតុល្យការរបស់ធនាគារបង្ហាញឡើងដូចនៅក្នុងតារាងតុល្យការ ៧ និង ៨ ។

| CLIENT F | | **4,000** | 4,000 |
| TOTAL | 6,000 | 4,000 | 10,000 |

តារាងទី៣៖ Out-clearing book: Bank C ( pounds )

| | BANK A | BANK B | TOTAL |
|---|---|---|---|
| CLIENT G | **5,000** | | 5,000 |
| CLIENT H | | **1,000** | 1,000 |
| CLIENT I | **2,000** | | 2,000 |
| TOTAL | **7,000** | **1,000** | 8,000 |

អន្តរធនាគារ គឺជារូបវន្តបុគ្គលដែលបានបង្ហាញពីឥណទានរបស់ពួកគេខុសផ្សេងៗគ្នា និង ទទួលបានឥណទានខុសៗគ្នា (សៀវភៅទូទាត់សំណង)។ ជាលទ្ធផល ត្រូវបានបង្ហាញនៅក្នុងតារាង ៤។ ហើយធនាគារ (B) ទទួលបានទឹកប្រាក់ចំនួន ៧,០០០ផោន ជាប្រាក់បញ្ញើធនាគារ។ នៅខណៈពេលធនាគារ (A) បានដកប្រាក់បញ្ញើទឹកប្រាក់ចំនួន ៥,០០០ផោន និងធនាគារ (C) បានដកប្រាក់បញ្ញើទឹកប្រាក់ចំនួន ២,០០០ផោន។ ធនាគារនីមួយៗ បានទូទាត់សំណងរវាងគណនីធនាគារពួកគេម្នាក់ៗ៖

- Bank A paid Bank B 4,000 pounds ( 6,000 – 2,000 ).
- Bank B paid Bank C 1,000 pounds ( 7,000 – 6,000 ).
- Bank C paid Bank B 3,000 pounds ( 4,000 – 1,000 ).

តារាងទី ៤៖ Total claims on and against ( pounds )

| | | BANK A | BANK B | BANK C | TOTAL |
|---|---|---|---|---|---|
| CLAIMS AGAINST | BANK A | X | **6,000** | **7,000** | 13,000 |
| | BANK B | **2,000** | X | **1,000** | 3,000 |

| | | | | | |
|---|---|---|---|---|---|
| | BANK C | 6,000 | 4,000 | X | 1,000 |
| | TOTAL | 8,000 | 10,000 | 8,000 | 26,000 |

ពីដំបូងចំនួនទឹកប្រាក់ត្រូវបានទូទាត់ជាក្រដាសប្រាក់របស់ធនាគារ ហើយតារាងតុល្យការរបស់ធនាគារនឹងត្រូវបានប្រែប្រួលដូចដែលបានចង្អុលបង្ហាញនៅក្នុងតារាងតុល្យការលេខ ៥-៧។

តារាងទី ៥៖ ឥណទេយ្យ និងសំណង(ជាផោន)

| BALANCE SHEET 5: BANK A (POUNDS) | | | |
|---|---|---|---|
| Assets | | Liabilities | |
| | | Deposits | -5,000 |
| | | Bank notes issued (Bank B) | +4,000 |
| | | Bank notes issued (Bank C) | +1,000 |
| Total | 0 | Total | 0 |

| BALANCE SHEET 6: BANK B (POUNDS) | | | |
|---|---|---|---|
| Assets | | Liabilities | |
| Bank notes (Bank A) | +4,000 | Deposits | +7,000 |
| Bank notes (Bank C) | +3,000 | | |
| Total | +7,000 | Total | +7,000 |

| BALANCE SHEET 7: BANK C (POUNDS) | | | |
|---|---|---|---|
| Assets | | Liabilities | |
| Bank notes (Bank A) | +1,000 | Deposits | -2,000 |
| | | Bank notes issued (Bank B) | +3,000 |
| Total | +1,000 | Total | +1,000 |

បន្ទាប់មកទៀត នៅពេលគណនីចរន្តបានក្លាយជាគណនីប្រាក់កម្ចីឱ្យគ្នាទៅវិញទៅមក (ហៅថាប្រាក់កម្ចីអន្តរធនាគារ)។ តារាងតុល្យការរបស់ពួកគេ នឹងបង្ហាញពីការប្រែប្រួលដែលបានបង្ហាញនៅក្នុងតារាងតុល្យការលេខ ៨-១០។

| BALANCE SHEET 8: BANK A (POUNDS) | | | |
|---|---|---|---|
| Assets | | Liabilities | |
| | | Deposits | -5,000 |
| | | Interbank loan (Bank B) | +4,000 |

| | | | |
|---|---|---|---|
| | | Interbank loan ( Bank C ) | +1,000 |
| **Total** | **0** | **Total** | **0** |

| BALANCE SHEET 9: BANK B ( POUNDS ) | | | |
|---|---|---|---|
| **Assets** | | **Liabilities** | |
| Interbank loan ( Bank A )<br>Interbank loan ( Bank C ) | +4,000<br>+3,000 | Deposits | +7,000 |
| **Total** | **+7,000** | **Total** | **+7,000** |

| BALANCE SHEET 10: BANK C ( POUNDS ) | | | |
|---|---|---|---|
| **Assets** | | **Liabilities** | |
| Interbank loan ( Bank A ) | +1,000 | Deposits<br>Interbank loan ( Bank B ) | -2,000<br>+3,000 |
| **Total** | **+1,000** | **Total** | **+1,000** |

បើតាមរយៈលោក Jevons[២៦] បានអះអាងឱ្យយើងដឹងថាក្រុមហ៊ុន Clearing House (CH) មានឈ្មោះជាផ្លូវការបានលេចមុខជាលើដំបូងនៅទីក្រុងឡុងដ៍នាឆ្នាំ១៧៧៥។ មុខងារសំខាន់របស់ក្រុមហ៊ុននេះ គឺសម្រាប់ធ្វើប្រតិបត្តិការការទូទាត់សំណង និងដើម្បីធានាការទូទាត់បំណុលប្រកបដោយ សុវត្ថិភាព។ នៅក្នុងតារាងតុល្យការលេខ៥ បង្ហាញពីទិន្នផលសរុបសុទ្ធនៃក្រុមហ៊ុន Clearing House (CH) ដែលបានដើរតួជំនួសឱ្យធនាគារក្នុងការដោះស្រាយបំណុល ដូចបានបង្ហាញក្នុងតារាងតុល្យ-ការនៃប្រតិបត្តិការខាងលើរបស់ក្រុមហ៊ុន Clearing House (CH)។ ជាឧទាហរណ៍របស់យើងការទូទាត់សំណងកើតឡើងរវាងធនាគារ(A) និងធនាគារ (C) ដោយធនាគារទាំងពីរមិនបានដោះស្រាយជាមួយគ្នានោះទេ។ ប៉ុន្តែនេះបានដោះស្រាយសំណងជាមួយធនាគារ (B) វិញ (សូមមើលតារាងតុល្យការលេខ ១ ១-១៣)។

| | BANK A | BANK B | BANK C | TOTAL |
|---|---|---|---|---|
| CLAIMS ON | 8,000 | 10,000 | 8,000 | 26,000 |
| CLAIMS AGAINST | -13,000 | -3,000 | -10,000 | -26,000 |
| TOTAL | -5,000 | 7,000 | -2,000 | 0 |

| BALANCE SHEET 11: BANK A ( POUNDS ) |
|---|

[២៦] *Jevons, 1875:264*

| Assets | | Liabilities | |
|---|---|---|---|
| | | Deposits<br>Interbank loan ( Bank B ) | -5,000<br>+5,000 |
| Total | 0 | Total | 0 |

| BALANCE SHEET 12: BANK B ( POUNDS ) | | | |
|---|---|---|---|
| Assets | | Liabilities | |
| Interbank loan ( Bank A )<br>Interbank loan ( Bank C ) | +5,000<br>+2,000 | Deposits | +7,000 |
| Total | +7,000 | Total | +7,000 |

| BALANCE SHEET 13: BANK C ( POUNDS ) | | | |
|---|---|---|---|
| Assets | | Liabilities | |
| | | Deposits<br>Interbank loan ( Bank B ) | -2,000<br>+2,000 |
| Total | 0 | Total | 0 |

បើតាមរយៈលោក Jevons[២៧] បានបង្ហាញថា៖ (បានបោះពុម្ពផ្សាយសៀវភៅនៅឆ្នាំ ១៨៧៥ ដោយផ្តោតលើការបោះពុម្ពផ្សាយចន្លោះពីឆ្នាំ ១៨៦០-១៨៧០)៖

*"សម្រាប់ពេលថ្មីៗនេះ ការផ្តល់យោបល់ក្នុងការអនុវត្តន៍ឱ្យមានប្រសិទ្ធភាពសម្រាប់សមតុល្យធនាគារ ត្រូវបានទូទាត់ដោយធនាគារកណ្តាលអង់គ្លេស ដែលក្នុងនោះធនាគារក្រុងនីមួយៗ ត្រូវតែដាក់ប្រាក់តម្កល់មួយភាគធំជាសាច់ប្រាក់ដែលនៅសល់របស់ពួកគេ"។*

នេះបានបង្ហាញពីមុខងាររបស់ធនាគារកណ្តាលនៃការបោសសម្អាតទីផ្សាររូបិយវត្ថុ និងប្រតិបត្តិការទូទាត់សំណង ដែលជាមជ្ឈមណ្ឌលដ៏សំខាន់របស់ធនាគារកណ្តាលអង់គ្លេស។ ឧទាហរណ៍ខាងលើនេះ ដែលមានការប្រែប្រួលតារាងតុល្យការរបស់ធនាគារទាំងនេះ ត្រូវបានបង្ហាញក្នុងតារាងតុល្យការពីលេខ ១៤-១៧។

| BALANCE SHEET 14: CENTRAL BANK A ( POUNDS ) | | | |
|---|---|---|---|
| Assets | | Liabilities | |
| | | Banks´ reserve accounts | |
| | | Bank A | -5 000 |

[២៧] *Jevons, 1875:267*

| | | | |
|---|---|---|---|
| | | Bank B | +7 000 |
| | | Bank C | -2 000 |
| | 0 | | 0 |

| BALANCE SHEET 15: CENTRAL BANK A ( POUNDS ) | | | |
|---|---|---|---|
| Assets | | Liabilities | |
| Reserve account at CB | -5,000 | Deposits | -5,000 |
| **Total** | **-5,000** | **Total** | **-5,000** |

| BALANCE SHEET 16: BANK B ( POUNDS ) | | | |
|---|---|---|---|
| Assets | | Liabilities | |
| Reserve account at CB | +7,000 | Deposits | +7,000 |
| **Total** | +7,000 | **Total** | **+7,000** |

| BALANCE SHEET 17: BANK C ( POUNDS ) | | | |
|---|---|---|---|
| Assets | | Liabilities | |
| Reserve account at CB | -2,000 | Deposits | -2,000 |
| **Total** | **-2,000** | **Total** | **-2,000** |

នៅតាមបណ្តាប្រទេសភាគច្រើន មានប្រព័ន្ធទូទាត់សំណង និងប្រព័ន្ធសម្អាតអន្តរធនាគារ ជាទូទៅគេបានហៅថា "ប្រព័ន្ធសម្អាតស្វ័យប្រវត្ត (ACB)" គឺជាប្រព័ន្ធតម្រូវឱ្យមានបរិមាណទឹកប្រាក់ត្រូវបង់ ឬបញ្ចូលទៅក្នុងគណនីធនាគារកណ្តាល។ ហើយមានបណ្តាប្រទេសភាគច្រើន ក៏មានប្រព័ន្ធសម្រាប់ការទូទាត់សំណងដែលមានបរិមាណទឹកប្រាក់ច្រើនផងដែរ ប៉ុន្តែការទូទាត់សំណងទាំងនេះ មិនត្រូវបានទូទាត់សំណងតាមរយៈគណនីធនាគារកណ្តាលឡើយ។ វាត្រូវបានគេហៅថា ប្រព័ន្ធទូទាត់សំណងទាន់ពេលជាក់ស្តែង (RTGS)។ ចំណែកប្រព័ន្ធសម្អាតស្វ័យប្រវត្ត (ACB) នៅតែមានប្រើ ក៏ប៉ុន្តែសម្រាប់ការទូទាត់សំណងតិចតួចតែប៉ុណ្ណោះ។

## ៤.៦- ការត្រួតពិនិត្យប្រព័ន្ធទូទាត់ ( Supervision of payments system )

នៅតាមបណ្តាប្រទេសភាគច្រើន មានប្រព័ន្ធទូទាត់ ( payments systems ) ចំនួនបី៖

- ប្រព័ន្ធ RTGS សម្រាប់ការទូទាត់រយៈពេលវែង
- ប្រព័ន្ធ ACB សម្រាប់ការទូទាត់រាយរង មានដូចជា ( Cheques & ETFs )
- ប្រព័ន្ធទូទាត់ប្រាក់សម្រាប់ម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ ( ATM ) ប្រតិបត្តិការរវាងធនាគារ។

ប្រព័ន្ធទាំងបីនេះ និងប្រព័ន្ធដទៃផ្សេងទៀត អាចចូលរួមជាមួយប្រព័ន្ធដែលគេហៅថា "ប្រព័ន្ធទូទាត់ថ្នាក់ជាតិ(NPS)"។ ប្រព័ន្ធទាំងនេះ បានប្រើប្រាស់ដើម្បីទូទាត់សំណងងាយស្រួលនៅក្នុងធនាគារកណ្ដាល ដោយសារតែប្រព័ន្ធទាំងនេះ គឺជាប្រព័ន្ធមានសុវត្ថិភាព។ នៅពេលមានការទូទាត់ត្រូវបានធ្វើឡើងដោយធនាគារ ហើយពួកគេត្រូវបានបង្កើតទុនបម្រុងដែលមានស្រាប់។ ប្រសិនបើការទូទាត់ទាំងនេះ បណ្ដាលឱ្យធនាគារនីមួយៗ មានគណនីទុនបម្រុងកាតព្វកិច្ច (RR) ចុងបញ្ចប់នៃអាជីវកម្មប្រចាំថ្ងៃរបស់ពួកគេ មានតម្រូវការស្វែងរកមូលនិធិពីទីផ្សារអន្តរធនាគារ ឬពីធនាគារកណ្ដាលក្នុងទម្រង់នៃប្រាក់កម្ចី។ នៅទីបំផុតធនាគារកណ្ដាលត្រូវតែទទួលខុសត្រូវចំពោះប្រព័ន្ធទូទាត់ជាតិ(NPS) ហើយត្រួតពិនិត្យមូលដ្ឋានគ្រឹះនៃស្ថិរភាពហិរញ្ញវត្ថុ។ សរុបជារួម សម្រាប់ការត្រួតពិនិត្យប្រព័ន្ធទាំង៣នេះបានប្រើប្រាស់នៅតាមបណ្ដាប្រទេសភាគច្រើន។ ប្រព័ន្ធនីមួយៗ បានប្រើទៅតាមប្រព័ន្ធទូទាត់បំណុលដោយឡែកៗពីគ្នាទៅតាមទម្រង់នៃមធ្យោបាយទូទាត់។

### ៤.៦.១- ប្រតិបត្តិការធនាគារកណ្ដាល (Central bank transactions)

សារសំខាន់នៃប្រតិបត្តិការរបស់ធនាគារកណ្ដាល គឺបញ្ហាគោលនយោបាយរូបិយវត្ថុ។ នៅក្នុងមេរៀនមុន យើងបានសិក្សាអំពីសាច់ប្រាក់ងាយស្រួលរបស់ធនាគារបានគូសបញ្ជាក់ជាចម្បងរវាងធនាគារកណ្ដាល និងទីផ្សារហិរញ្ញវត្ថុ ដែលទាក់ទិននឹងផលវិបាកចំពោះភាពងាយស្រួលនៃសាច់ប្រាក់របស់ធនាគារ។ អានរំលឹកមេរៀនឡើងវិញ (សូមមើលតារាងតុល្យការទី១៨)។

| BALANCE SHEET 18: CENTRAL BANK (USD MILLIONS) | |
|---|---|
| **Assets** | **Liabilities** |
| | A. Notes and coins |
| E. Foreign assets | B. Deposits |
| | 1. Government |
| | 2. Bank (TR) |
| F. Government securities (claims on govt) | a. RR |
| | b. ER |
| G. Loans to banks (borrowed reserves - BR) | C. Foreign loans |
| | D. Central bank securities |

យើងបង្ហាញពីការប្រែប្រួលសមីការនៃ($\Delta$NER)៖

$$\Delta NER = \Delta(E - C) + \Delta(F - B1) - \Delta A - \Delta B2a - \Delta D.$$

ការប្រែប្រួលអថេរសមីការនៃ NER របស់គណនី (B2b-G) នៃប្រព័ន្ធធនាគារមួយ គឺជាករណីផលដកចេញដោយការប្រែប្រួលជាតុផ្សេងៗទៀតនៅក្នុងតារាងតុល្យការជាក្រុមអថេរដ៏ត្រឹមត្រូវ ដែល (ត្រូវបានគេហៅថាជាប្រភពប្រែប្រួលនៃតារាងតុល្យការរបស់ BSSoC)។

ហេតុដូច្នេះ៖

| | |
|---|---|
| $\Delta NER$ | = |
| $\Delta(E - C)$ | = net foreign assets (NFA) |
| $+\Delta(F - B1)$ | = net loans to government (NLG) |
| $-\Delta A$ | = notes and coins in circulation |
| $-\Delta B2a$ | = RR |
| $-\Delta D$ | = central bank securities (CBS). |

ហេតុផលជាក់ស្តែងនៃការប្រែប្រួលនេះ គឺប្រតិបត្តិការដែលមានមូលដ្ឋាននៃ(BSSoC)។ យើងដែលបានបញ្ជាក់ថា ប្រសិនបើប្រាក់បញ្ញើផ្លាស់ទីពីធនាគារមួយទៅកាន់ធនាគារមួយ សាច់ប្រាក់ងាយស្រួលនៃ (NER) នឹងមិនប្រែប្រួលនោះទេ។ ទន្ទឹមនឹងនេះដែរ ធនាគារកណ្តាលមានទំនាក់ទំនងជាមួយ និង/ឬនៅពេលប្រាក់បញ្ញើធនាគារ និង/ឬមានតម្រូវការប្រែប្រួលក្រដាសប្រាក់ និងកាស (N&C) ហើយមានបម្រែបម្រួលនៃ (NER)។

ដូច្នេះយើងបានឃើញថា BSSoC មានពីរផ្នែក៖

- Passive BSSoC.
- Operational BBoC.

BSSoC ផ្នែកអកម្មគឺ៖

- ការផ្លាស់ប្តូរនូវបរិមាណប្រាក់បញ្ញើធនាគារ៖ មានផលវិបាកសម្រាប់ទុនបម្រុងកាតព្វកិច្ច។ ខណៈពេលដែលកត្តាទាំងនេះ មិនដំណើរការធនាគារកណ្តាលមានឥទ្ធិពលដោយប្រយោលទៅលើវា។
- ក្រដាសប្រាក់ និងកាស (N&C) ដែលកំពុងចរាចរណ៍។ ជាតុទាំងនេះ ត្រូវបានជះឥទ្ធិពលដោយតម្រូវការសម្រាប់ក្រដាសប្រាក់ និងកាស (N&C) ពីសាធារណជន និងធនាគារ។

BSSoC ប្រតិបត្តិការមាន៖

- NFA (ទ្រព្យសកម្មបរទេស)។ ឧទាហរណ៍៖ ការលក់ forex ទៅឱ្យធនាគារ (ប្តូរប្រាក់បរទេស) នឹងថយចុះ NER (ការកើនឡើង LS) ។
- NLG (ការទិញ ឬលក់មូលប័ត្ររដ្ឋាភិបាល និងការផ្លាស់ប្តូរប្រាក់បញ្ញើរបស់រដ្ឋាភិបាល)។ ឧទាហរណ៍៖ ការលក់ TBs ទៅឱ្យធនាគារវានឹងថយចុះ NER (ការកើនឡើង LS)។

- ការបោះផ្សាយមូលប័ត្ររបស់ធនាគារកណ្តាល (CBS) ។ ការបោះផ្សាយជាថ្មីនឹងថយចុះ NER (ការកើនឡើង LS)។
- អនុបាតតម្រូវការទុនបម្រុង (*r*) វាអាចធ្វើឱ្យប្រែប្រួលដោយធនាគារកណ្តាល។ ការកើនឡើងអត្រា *r* វានឹងថយចុះ NER (ការកើនឡើង LS)។

### ៤.៦.២- បញ្ហាតូច ឬធំរបស់ធនាគារ (Large/small bank problem)

នៅតាមបណ្តាប្រទេសខ្លះទៀត វិស័យធនាគារត្រូវបានគ្របដណ្តប់ដោយធនាគារធំៗ។ វាអាចមានភាពស្ទាក់ស្ទើរដោយសារធនាគារធំៗក្នុងការដោះស្រាយទីផ្សារអន្តរធនាគារជាមួយធនាគារតូចៗ។ នេះមានន័យថា នៅពេលប្រាក់បញ្ញើរផ្ទេរពីធនាគារតូចៗទៅកាន់ធនាគារធំៗ។ បន្ទាប់មក ប្រហែលជាមិនអាចយកថវិកាត្រឡប់មកប្រើប្រាស់វិញបាននោះទេ ហើយទីផ្សារអន្តរធនាគារក៏មិនច្បាស់លាស់ដែរ។ នេះមានន័យថា ធនាគារកណ្តាលនឹងត្រូវផ្តល់ឱ្យធនាគារតូចៗនៅ KIR ។

ឧទាហរណ៍៖ ប្រាក់បញ្ញើចំនួន USD ១០០លាន បានផ្ទេរពីគណនីធនាគារតូចៗទៅកាន់គណនីធនាគារធំ (សូមមើលតារាងតុល្យការទលេខ ១៩-២១)។

| BALANCE SHEET 19: CENTRAL BANK A (USD MILLIONS) | | | |
|---|---|---|---|
| Assets | | Liabilities | |
| | | Banks' reserve account<br>Small banks<br>Large banks | <br>-100<br>+100 |
| Total | 0 | Total | 0 |

| BALANCE SHEET 20: SMALL BANKS (USD MILLIONS) | | | |
|---|---|---|---|
| Assets | | Liabilities | |
| Reserve account at CB | -100 | Deposits | -100 |
| Total | -100 | Total | -100 |

| BALANCE SHEET 21: LARGE BANKS (USD MILLIONS) | | | |
|---|---|---|---|
| Assets | | Liabilities | |
| Reserve account at CB | +100 | Deposits | +100 |
| Total | +100 | Total | +100 |

សម្រាប់ដំណោះស្រាយជាក់ស្តែង គឺជាប្រតិបត្តិការអន្តរធនាគារ។ ទោះយ៉ាងណាក៏ដោយបើសិនធនាគារធំៗបដិសេធមិនផ្តល់ប្រាក់កម្ចីឱ្យដល់ធនាគារតូចៗនោះ។ ធនាគារកណ្តាល អាចជួយបានតិចតួចណាស់តាមរយៈការលើកទឹកចិត្តឱ្យមានកិច្ចសន្យាបញ្ចាំ ឬកិច្ចសន្យាទិញលក់តែប៉ុណ្ណោះ។ ប្រតិបត្តិការនេះធ្វើឡើងដោយមានវត្ថុបញ្ចាំ។

### ៤.៦.៣- **ទំនុកចិត្តនឹងដំណើរការរបស់ធនាគារ** (Confidence and the bank run)

ភាពច្របូកច្របល់នៅតែបន្តមានសម្រាប់អ្នកផ្តល់ប្រាក់កម្ចីចុងក្រោយ។ ការផ្តល់ប្រាក់កម្ចីធនាគារសម្រាប់គោលបំណងគោលនយោបាយរូបិយវត្ថុ គឺមានចេតនាស្ទើរតែទាំងស្រុងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ធនាគារកណ្តាល។ នេះមិនមែនជាការវិវត្តចុងក្រោយទេ។ វាគឺជាការផ្តល់ប្រាក់កម្ចីជាដំបូងគេដែលក្នុងនោះវាត្រូវបានបង្កើតឡើងដោយធនាគារកណ្តាល ពីព្រោះពួកគេចង់ធ្វើឱ្យទីផ្សារ (KIR) មានប្រសិទ្ធភាពក្នុងការគ្រប់គ្រងអត្រាការប្រាក់។ អ្នកផ្តល់ប្រាក់កម្ចីចុងក្រោយ (last resort) នៃធនាគារកណ្តាល គឺបញ្ហាស្ថិរភាពហិរញ្ញវត្ថុ (financial stability)។ នៅពេលធនាគារ មានបញ្ហាករណីបាត់បង់ទំនុកចិត្តលើធនាគារ ត្រូវបានបញ្ឈប់ដំណើរការធនាគារនោះដែលមិនអាចបំពេញតាមតម្រូវការប្រាក់បញ្ញើ។ វិស័យធនាគារនឹងបរាជ័យប្រសិនបើប្រាក់បញ្ញើដែលបានបាត់បង់មិនត្រូវបានកែច្នៃក្នុងទីផ្សារអន្តរធនាគារទេនោះ។ ធនាគារផ្សេងទៀតនឹងមិនសប្បាយចិត្តលើរឿងនេះទេ (ឧទាហរណ៍៖ មានធនាគារ ធំ ឬធនាគារតូចខាងលើស្រាប់)។ ដូច្នេះវានឹងបន្សល់ទុកបញ្ហាឱ្យធនាគារកណ្តាល ដើម្បីសម្រេចចិត្តថាតើត្រូវជួយសង្គ្រោះធនាគារនោះដែរឬទេ? នេះគឺជាបញ្ហាចាំបាច់ ហើយវាមានជាប់ទាក់ទងទៅនឹងការបរាជ័យនៃប្រព័ន្ធធនាគារ។ វានាំឱ្យមានសំណួរថាតើធនាគារមានទំហំធំៗប៉ុណ្ណាទើបមិនអាចទទួលបរាជ័យ?

*ក្នុងន័យនេះទាក់ទិននឹងទ្រព្យសកម្មរបស់ធនាគារកណ្តាលអង់គ្លេស៖*[២៨]

*"នៅពេលដែលការគំរាមកំហែងដល់ស្ថិរភាពនៃប្រព័ន្ធហិរញ្ញវត្ថុ ត្រូវបានគេដឹងថាមានវត្តមានរបស់ធនាគារកណ្តាល អាចជួយធ្វើអន្តរាគមជាអន្តរការីទីផ្សារ ដើម្បីសម្រួលដល់មធ្យោបាយទូទាត់និងការទូទាត់សំណងដែលអាចនឹងមិនត្រូវបានបញ្ចប់។ ក្នុងករណីមានបញ្ហាធ្ងន់ធ្ងរការគាំទ្រផ្នែកហិរញ្ញវត្ថុបន្ទាន់ពីធនាគារកណ្តាលអាចត្រូវបានគេផ្តល់ជូន ដែលគេហៅថាមុខងារអ្នកផ្តល់ប្រាក់កម្ចីចុងក្រោយ (LOLR) ប៉ុន្តែនេះត្រូវបានធ្វើនៅពេលដែលការបរាជ័យនៃស្ថាប័នមួយអាចធ្វើឱ្យស្ថាប័នផ្សេងទៀតធ្លាក់ចុះដែរ បើមិនដូច្នេះទេអាចទទួលយកបាន។ មុខងារនេះអាចពាក់ព័ន្ធនឹងការឱ្យខ្ចីប្រាក់របស់ធនាគារ កណ្តាលទៅស្ថាប័នដែលបរាជ័យដើម្បីការពារការបរាជ័យរបស់ខ្លួន ដូច្នេះដើម្បីបញ្ឈប់ផលប៉ះពាល់នៃការជួលរលំរបស់វាពីការរីករាលដាលតាមរយៈប្រព័ន្ធហិរញ្ញវត្ថុ។ បណ្តាញសុវត្ថិភាពនេះ*

---

[២៨] www.boe.gov.uk

*មានដើម្បីការពារស្ថេរភាពនៃប្រព័ន្ធហិរញ្ញវត្ថុទាំងមូល និងមិនមែនការពារស្ថាប័ននីមួយៗ ឬអ្នកគ្រប់គ្រង និងម្ចាស់ភាគហ៊ុនឡើយ"។*

*"ការប្រើប្រាស់មុខងារអ្នកផ្តល់ប្រាក់កម្ចីចុងក្រោយ (LOLR) របស់ធនាគារត្រូវតែមានភាពត្រឹមត្រូវដោយប្រុងប្រយ័ត្នចំពោះការខូចខាតដែលនឹងបណ្តាលឱ្យប្រព័ន្ធហិរញ្ញវត្ថុ និងសេដ្ឋកិច្ចវិការលដាល ប្រសិនបើអន្តរាគមមិនកើតឡើង។ នេះក៏ព្រោះតែតួនាទីរបស់ (LOLR) តម្រូវឱ្យមានការប្រើប្រាស់ថវិការសាធារណៈ ហើយក៏អាចលើកទឹកចិត្តដល់ការប្រថុយប្រថានហួសហេតុ ហេតុដូចនេះភាពផុយ) ប្រសិនបើគ្រឹះស្ថាននានាជឿជាក់ថា ពួកគេនឹងនៅក្រៅឃុំ (ស្រួយផ្នែកហិរញ្ញវត្ថុ(bailed out) នៅពេលណាដែលពួកគេជួបការលំបាក។ ហានិភ័យទាំងនេះ មានន័យថាធនាគារ និង FSA ត្រូវការសហការយ៉ាងជិតស្និទ្ធនៅពេលមានបញ្ហាកើតឡើង ហើយជូនដំណឹងដល់គេនាគារ។ ធនាគារក៏ត្រូវបំពេញសេចក្តីត្រូវការរបស់ក្រុមប្រឹក្សាភិបាលរបស់ខ្លួនផងដែរថាតើរាល់ហានិភ័យដែលខ្លួនទទួលយកគឺជាការគ្រប់គ្រងទាក់ទងនឹងមូលនិធិដើមទុនផ្ទាល់របស់ធនាគារ នៅពេលដែលពួកគេត្រូវយកមកដាក់ក្នុងតារាងតុល្យការរបស់ធនាគារ។"*

*ទស្សនៈរបស់ធនាគារសហព័ន្ធអាហ្វ្រិកខាងត្បូង៖ "ធនាគារសហព័ន្ធផ្តល់សាច់ប្រាក់ងាយស្រួលដល់ធនាគារក្នុងអំឡុងពេលខ្វះសាច់ប្រាក់ជាបណ្តោះអាសន្ន។ មុខងារនេះ ត្រូវបានគេហៅថាសកម្មភាពផ្តល់ប្រាក់កម្ចីចុងក្រោយរបស់ធនាគារ។"*

*"មុខងារនេះមានន័យថា ផ្តល់ជំនួយដល់ធនាគារដែលប្រឈមនឹងបញ្ហាសាច់ប្រាក់ងាយស្រួល។ ជំនួយបែបនេះ ត្រូវបានផ្តល់ឱ្យតែបន្ទាប់ពីការវិភាគពេញលេញបញ្ហាដែលធ្វើឱ្យធនាគារបែបនេះ និងមូលហេតុបញ្ហាដែលពួកគេបានកើតឡើង។ ជំនួយនេះនឹងត្រូវផ្តល់ជូនតែលើលក្ខខណ្ឌជាក់លាក់ ហើយគោលបំណងរបស់វា គឺដើម្បីការពារការក្ស័យធនរបស់ធនាគារដែលបានទទួលជំនួយ និង/ឬចៀសវាងគ្រោះថ្នាក់នៃបញ្ហា ដែលបានចំណាយទៅធនាគារផ្សេងទៀតតាមរយៈដំណើរការលើធនាគារបែបនេះ។"*

*"ធនាគារដែលក្ស័យធនច្រើនតែមិនអាចសងបំណុលត្រឡប់ឱ្យអ្នកផ្ញើប្រាក់ ហើយគោលបំណងសំខាន់នៃការសុំជំនួយជាពិសេស គឺដើម្បីការពារអ្នកដាក់ប្រាក់បញ្ញើ។ ទោះយ៉ាងណាជំនួយមិនប្រាកដមិនត្រូវបានធានា ឬផ្តល់ឱ្យដោយស្វ័យប្រវត្តទេ ហើយធនាគារអាចនឹងក្ស័យធនដែលនាំឱ្យមានការលំបាកយ៉ាងខ្លាំងសម្រាប់អ្នកដាក់ប្រាក់បញ្ញើ ដែលបាត់បង់ប្រាក់បញ្ញើរបស់ខ្លួននៅឯធនាគារបែបនេះ។ ដូច្នេះការថែរក្សាស្ថេរភាពនៅក្នុងប្រព័ន្ធធនាគារគឺមានសារសំខាន់បំផុតសម្រាប់ប្រទេសណាមួយ។"*

## ៤.៧- ការគ្រប់គ្រងរូបិយប័ណ្ណ (Currency (N&C) management)

ធនាគារកណ្តាល (មានភាគច្រើន) មានសិទ្ធិផ្តាច់មុខក្នុងការផលិតនូវផលិតក្រដាសប្រាក់ និងកាស (N&C) នៅក្នុងប្រទេសរបស់ពួកគេ។ ធនាគារកណ្តាល មានកាតព្វកិច្ចធានាភាពមិនត្រឹមត្រូវនៃក្រដាសប្រាក់ និងកាស ដែលមានគុណភាពអាចទទួលយកបាននៅក្នុងដែនសាធារណៈ។ នេះគឺដើម្បីធានាថាប្រតិបត្តិការតូចៗ អាចបន្តបានដោយមិនមានការរំខានដល់សេដ្ឋកិច្ច។

នៅតាមបណ្តាប្រទេសភាគច្រើន ក្រុមហ៊ុនផលិតក្រដាសប្រាក់ និងកាស (N&C) គឺជាក្រុមហ៊ុនផលិតក្រដាសប្រាក់ និងកាសរបស់ធនាគារកណ្តាល។ ក្រុមហ៊ុនទាំងនេះ ត្រូវបានគេឃើញមានឈ្មោះដូចជាក្រុមហ៊ុន LC Mint Company(Pty) Limited និងក្រុមហ៊ុន LC Bank Note Company(Pty) limited គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារកណ្តាល។ មានបណ្តាប្រទេសខ្លះទៀត បានផ្តល់មុខងារផលិតក្រដាសប្រាក់ និងកាសនេះឱ្យទៅប្រទេសដទៃផ្សេង។

សម្រាប់ការសិក្សានេះ យើងចង់គូសបញ្ជាក់នូវចំណុចមួយចំនួនរបស់ធនាគារកណ្តាល មានដូចខាងក្រោម៖

- ការដេញថ្លៃតាមច្បាប់
- សិទ្ធិក្នុងការបោះផ្សាយ
- កំណត់ប្រភេទក្រដាសប្រាក់ និងកាស
- ការរចនារៀបចំក្រដាសប្រាក់ និងកាស
- ចេញផ្សាយក្រដាសប្រាក់ និងកាស
- គ្រប់គ្រងគុណភាពនៃក្រដាសប្រាក់ និងកាសក្នុងការចរាចរណ៍
- គ្រប់គ្រងការយល់ដឹងពីការផ្សព្វផ្សាយការការពារការក្លែងបន្លំ
- សាខាមានមុខងារទាក់ទងនឹងក្រដាសប្រាក់ និងកាស

រាល់ក្រដាសប្រាក់ និងកាស (N&C)ទាំងអស់ បានបោះផ្សាយដោយធនាគារកណ្តាល គឺជាអ្នកដេញថ្លៃស្របច្បាប់ (legal tender)។ នេះមានន័យថា ពួកគេត្រូវតែទទួលយកក្នុងការទូទាត់ (ចំនួនជាក់លាក់) ឱ្យសមល្មម។ ធនាគារកណ្តាល មានសិទ្ធិផ្តាច់មុខក្នុងការផលិតក្រដាសប្រាក់ និងកាសនៅក្នុងស្រុក។ សិទ្ធិនេះ ត្រូវបានប្រគល់ឱ្យធនាគារកណ្តាលដោយរដ្ឋាភិបាលដូចមានចែងក្នុងលក្ខន្តិកៈនៃការគ្រប់គ្រងធនាគារកណ្តាល។

ការកំណត់ប្រភេទ (denomination) ក្រដាសប្រាក់ និងកាស គឺពឹងផ្អែកលើកត្តាជាច្រើន ប៉ុន្តែជាពិសេសអត្រាអតិផរណា និងអត្រាប្តូរប្រាក់។ ប្រសិនបើប្រទេសដែលមានកម្រិតអតិផរណាខ្ពស់ពីអតីតកាលនោះ ដោយអត្រាប្តូរប្រាក់របស់ខ្លួនធៀបនឹងរូបិយប័ណ្ណប្រាក់ដុល្លារអាមេរិក។ ឧទាហរណ៍៖ ក្រដាសប្រាក់របស់ធនាគារនៅក្នុងប្រទេសមួយដែលមានកម្រិតអតិផរណាខ្ពស់ពីអតីតកាល ត្រូវបានបង្ហាញនៅក្នុងប្រអប់ទី២។

ម្យ៉ាងវិញទៀត នៅពេលអត្រាប្តូរប្រាក់ក្នុងស្រុកធៀបនឹងប្រាក់ដុល្លារអាមេរិក គឺ USD/1.50។ នៅតាមបណ្តាប្រទេសដែលកម្រិតអតិផរណាខ្ពស់កន្លងមក សម្រាប់ប្រភេទប្រាក់កាសមានកម្រិតទាបនឹងពុំមានប្រើនោះទេ។

ពាក់ព័ន្ធនឹងការរចនាក្រដាសប្រាក់ និងកាស ការរចនាឡើងវិញថ្មីទាំងអស់ ត្រូវតែមានការយល់ព្រមជាមុនពីរដ្ឋាភិបាលសិន មុនពេលធនាគារកណ្តាលត្រូវបានដាក់ឱ្យដំណើរការក្រដាសប្រាក់ និងកាសនោះ។ ការអនុវត្តន៍ដូចគ្នាចំពោះការកំណត់ប្រភេទក្រដាសប្រាក់ និងកាស (denomination) ទោះបីជាធនាគារកណ្តាលផ្តល់អនុសាសន៍ណែនាំក៏ដោយ។

ទាក់ទិននឹងបញ្ហាក្រដាសប្រាក់និងកាសរបស់ធនាគារកណ្តាល៖

- គណនាក្រដាសប្រាក់ និងកាសរបស់ធនាគារនឹងតម្រូវការជាថ្មីរបស់ប្រទេសប្រចាំឆ្នាំ។
- បញ្ចូលក្រដាសប្រាក់ និងកាសជាថ្មីចូលទៅចរាចរណ៍បន្តយោងទៅតាមតម្រូវការ និង
- ធានាថាមានក្រដាសប្រាក់ និងកាសជាថ្មីគ្រប់គ្រាន់ ដើម្បីជំនួសប័ណ្ណដែលបានចរាចរណ៍លើទីផ្សារ ដោយសារតែ "កខ្វក់" និងការបន្លំ (ក្លែងក្លាយ) ក្រដាសប្រាក់។

សម្រាប់គុណភាពនៃក្រដាសប្រាក់ និងកាស ដែលកំពុងចរាចរណ៍គឺមានសារសំខាន់សម្រាប់ហេតុផលជាច្រើនរួមមាន៖

- ដើម្បីជៀសវាងការលួចចម្លង ឬបោះពុម្ព (ក្លែងបន្លំ)។ ធនាគារកណ្តាលអនុវត្តតាមការជឿនលឿនខាងបច្ចេកវិទ្យា ហើយណែនាំអំពីលក្ខណសុវត្ថិភាព និងបច្ចេកទេស ដើម្បីនាំមុខអ្នកក្លែងបន្លំ។
- ដើម្បីធានាថាការបែងចែក និងមេកានិចនៃក្រដាសប្រាក់ និងកាសអាចធ្វើទៅបាន។
- ដើម្បីធានាថាពួកគេអាចទទួលយកបានសមាជិកជាភ្ញៀវទេសចរជាតិ និងអន្តរជាតិ។
- ដើម្បីលើកស្ទួយមុខមាត់ប្រទេសជាអន្តរជាតិ។

ធនាគារកណ្តាល ទទួលដោះដូរក្រដាសប្រាក់ និងកាសដែលខូចត្រឡប់ទៅវិញ។ ក្រដាសប្រាក់និងកាសត្រូវបានដាក់បញ្ញើរក្សាទុកនៅធនាគារ នឹងត្រូវបញ្ជូនបន្តទៅធនាគារកណ្តាល ដើម្បីទូទាត់ត្រឡប់មកវិញ។ ការយល់ដឹងជាសាធារណៈសម្រាប់ការពារការក្លែងបន្លំក្រដាសប្រាក់ និងកាស គឺជាមុខងារមួយផ្សេងទៀតរបស់ធនាគារកណ្តាល។ ក្នុងន័យនេះ ធនាគារកណ្តាលតែងតែក្រើនរំលឹកដល់សាធារណជនពីសុវត្ថិភាពក្រដាសប្រាក់ និងកាស ដូច្នេះ ការការពារការរីករាលដាលនៃក្រដាសប្រាក់និងកាសក្លែងក្លាយរបស់ធនាគារ។ ដូចនេះ ធនាគារកណ្តាលភាគច្រើនសាខារបស់ធនាគារកណ្តាលសម្រាប់ការគ្រប់គ្រងក្រដាសប្រាក់ និងកាសមានមុខងារចម្បងៗគឺ៖

- ទទួលយកប្រាក់បញ្ញើច្រើន និងដកក្រដាសប្រាក់ និងកាសពីធនាគារ(ប៉ុន្តែភាគច្រើនវាអនុវត្តចំពោះក្រដាសប្រាក់)។ ក្រដាសប្រាក់ និងកាសគឺជាទ្រព្យសម្បត្តិដែលមិនមានការចាប់អារម្មណ៍សម្រាប់ធនាគារ។ ពួកគេព្យាយាមរក្សាការកាន់កាប់ឱ្យនៅកម្រិតអប្បបរមា (ក្នុងទូ និងទូ (ATMs)។ ក្រដាសប្រាក់ និងកាសដែលលើស ត្រូវបានតម្កល់ទុកនៅធនាគារកណ្តាល (គណនីបម្រុងទុនរបស់ពួកគេ) ហើយការដកប្រាក់ត្រូវបានធ្វើឡើងក្នុងការស្មានទុកជាមុនពីតម្រូវការជាសាធារណៈ (មុន និងអំឡុងពេលបើកប្រាក់ខែ)។ ទាំងនេះ ត្រូវបានបង់ដោយគណនីឥណពន្ធទៅក្នុងគណនីបម្រុងរបស់ធនាគារ។
- ដើម្បីធានាថាមានក្រដាសប្រាក់ និងកាសរបស់ធនាគារដែលមានគុណភាព ដែលអាចទទួលយកបាន។
- ដើម្បីត្រួតពិនិត្យក្រដាសប្រាក់ និងកាសរបស់ធនាគារ ដែលមិនបំពេញតាមស្តង់ដារគុណភាពក្រដាសប្រាស់ និងកាសត្រូវបានបំផ្លាញចោល(ខូច)។

ទោះបីជាសាខារបស់ធនាគារកណ្តាល ត្រូវបានគេប្រើដោយកម្រក៏ដោយ ក៏សាធារណជនមានលទ្ធភាពទទួលបានកន្លែងដាក់ប្រាក់តាមសាខារបស់ធនាគារកណ្តាលនានា សម្រាប់ជំនួសក្រដាសប្រាក់និងកាសធនាគារដែលមានបញ្ហាផងដែរ។

## ៤.៨- ការត្រួតពិនិត្យប្រព័ន្ធធនាគារ ( Bank supervision )

បេសកកម្មរបស់ធនាគារកណ្តាល គឺជាសមិទ្ធិផល និងថែរក្សាស្ថិរភាពហិរញ្ញវត្ថុ។ មូលដ្ឋានគ្រឹះនៃស្ថិរភាពហិរញ្ញវត្ថុ គឺបទប្បញ្ញត្តិ និងការត្រួតពិនិត្យប្រព័ន្ធធនាគារក្នុងគោលបំណង ដើម្បីទទួលបាននូវប្រព័ន្ធធនាគារដែលមានប្រសិទ្ធិភាព និងរឹងមាំឱ្យដល់អ្នកដាក់ប្រាក់បញ្ញើ និងសេដ្ឋកិច្ចទាំងមូល។

បទប្បញ្ញត្តិ និងការត្រួតពិនិត្យរបស់ធនាគារកណ្តាលមាន ៤ ប្រការ ដូចខាងក្រោម៖

- ស្ថាប័ននៃប្រព្រឹត្តកម្មវិធាន (បទប្បញ្ញត្តិ)
- តាមដានពិនិត្យ (សង្កេតមើលថាតើបទបញ្ញត្តិ ដែលបានបង្កើតត្រូវបានគោរព ឬអត់)
- ការត្រួតពិនិត្យ (ការប្រតិបត្តិអាកប្បកិរិយារបស់អ្នកចូលរួម)
- ការអនុវត្តន៍ (ធានាថាច្បាប់ត្រូវបានគោរពតាម)

សម្រាប់ប្រធានបទស្តីពីបេសកកម្មរបស់ធនាគារកណ្តាល មានសារសំខាន់ណាស់ វាទាមទារការយកចិត្តទុកយ៉ាងខ្លាំង ដើម្បីគោលបំណងទទួលបាននូវប្រព័ន្ធធនាគារដែលមានប្រសិទ្ធភាព។ ផ្ទុយទៅវិញ យើងនឹងនិយាយពីហានិភ័យធំៗ មានដូចជា៖

- ហេតុផលសម្រាប់បទប្បញ្ញត្តិ (Rationale for regulation)
- គោលបំណងនៃបទប្បញ្ញត្តិ (Objectives of regulation)

### ៤.៨.១- ហេតុផលសម្រាប់បទប្បញ្ញត្តិច្បាប់ ( Rationale for regulation )

វិស័យហិរញ្ញវត្ថុ បានដើរតួយ៉ាងសំខាន់នៅក្នុងសេដ្ឋកិច្ច នៅពេលអវត្តមានផ្នែកខ្លះនៃយន្តការសេដ្ឋកិច្ច ដែលត្រូវបានខូចខាតយ៉ាងធ្ងន់ធ្ងរ។ ប្រសិនបើប្រព័ន្ធទូទាត់បរាជ័យ ឬធនាគារត្រូវបានបិទទ្វារដំណើរការ(ដូចជាបានកើតឡើងនៅក្នុងប្រទេសអាហ្សង់ទីនក្នុងឆ្នាំ ២០០១/២ ដែលវិស័យសេដ្ឋកិច្ចត្រូវបានកាត់បន្ថយសកម្មភាពពាណិជ្ជកម្មតាមរយៈប្រព័ន្ធបាត់ធ័រ)។ វិស័យហិរញ្ញវត្ថុ ក៏ជានិយោជកដ៏សំខាន់មួយ និងជាភ្នាក់ងារទាក់ទាញការប្តូរប្រាក់បរទេសយ៉ាងសំខាន់ ប្រសិនបើត្រូវបានគ្រប់គ្រងបានត្រឹមត្រូវ។ វិស័យនេះក៏ទទួលខុសត្រូវផងដែរ ក្នុងការបែងចែកដើមទុនឱ្យដល់វិស័យវិនិយោគិនដល់ផលិតភាពឱ្យបានល្អបំផុត។ សនិទានភាពសម្រាប់ការអន្តរាគមន៍ពីរដ្ឋាភិបាលគឺ "ភាពមិនត្រឹមត្រូវនៃទីផ្សារ" មានន័យថាប្រព័ន្ធហិរញ្ញវត្ថុនឹងបង្កើតលទ្ធផលល្អប្រសើរបំផុត ក្នុងករណីដែលគ្មានបទប្បញ្ញត្តិ។ ដូច្នេះអន្តរាគមរបស់រដ្ឋាភិបាលមានអត្ថប្រយោជន៍ជាសុខុមាលភាព។ សម្រាប់អតិថិជននិងអ្នកចូលរួមចង់បានបទប្បញ្ញត្តិថែមទាំងត្រៀមការចំណាយផងដែរ។ ខ្លឹមសារ "សនិទានភាព" សម្រាប់បទប្បញ្ញត្តិគឺ "ហេតុអ្វីបទប្បញ្ញត្តិចាំបាច់"។

មានសនិទានភាពមួយចំនួនដូចជា៖

- ដំណើរការខុសប្រក្រតីជាប្រព័ន្ធ។
- ភាពមិនល្អឥតខ្ចោះនៃទីផ្សារ។
- បញ្ហាគ្រោះថ្នាក់ខាងសីលធម៌។
- ជញ្ជីងសេដ្ឋកិច្ច។

- ទំនុកចិត្តរបស់អ្នកប្រើប្រាស់ និងតម្រូវការរបស់អ្នកប្រើប្រាស់សម្រាប់បទប្បញ្ញត្តិច្បាប់។
- អ្នកផ្គត់ផ្គង់តម្រូវការសម្រាប់បទប្បញ្ញត្តិ។

យើងគ្រាន់តែពន្យល់លើអ្វីដែលបានរៀបរាប់ដំបូងតែប៉ុណ្ណោះៈ ដូចដែលយើងបានលើកឡើង ប្រព័ន្ធហិរញ្ញវត្ថុ បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងសេដ្ឋកិច្ច ហើយភាពបរាជ័យ ឬដំណើរការមិនត្រឹមត្រូវនៃប្រព័ន្ធហិរញ្ញវត្ថុ អាចរំខានដល់សកម្មភាពសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ។ ធនាគារ គឺជាអន្តរការីហិរញ្ញវត្ថុតែមួយគត់រវាងគ្រប់វិស័យនៃសេដ្ឋកិច្ច(មានភ្នាក់ងារៈ គ្រួសារ សហគ្រាស រដ្ឋាភិបាល និងបរទេស) និងអន្តរការីហិរញ្ញវត្ថុផ្សេងទៀត។ ហើយលើសពីនេះទៀត ប្រព័ន្ធធនាគារ បានផ្តល់នូវការទូទាត់ និងប្រព័ន្ធទូទាត់សំណង សម្រាប់ប្រតិបត្តិការទាំងឡាយ ដែលកើតឡើងនៅក្នុងសេដ្ឋកិច្ច។ ភាពបរាជ័យរបស់ធនាគារដ៏ធំមួយ មិនត្រឹមតែបង្កឱ្យមានការខាតបង់ដល់អ្នកដាក់ប្រាក់កម្ចី និងម្ចាស់ភាគហ៊ុន តែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យរំខានដល់ការទូទាត់ និងប្រតិបត្តិការទូទាត់សំណងដែលមានប្រសិទ្ធភាពដែលអាចកើតមានភ្លាមៗ និងអាចមាននៅពេលខ្លះ។

### ៤.៨.២- គោលបំណងនៃបទប្បញ្ញត្តិ (objectives of regulation)

គោលបំណងនៃបទប្បញ្ញត្តិ ត្រូវបានកំណត់យ៉ាងចង្អៀតៈ

- ដើម្បីលើកកម្ពស់ស្ថិរភាពហិរញ្ញវត្ថុ
- ដើម្បីលើកកម្ពស់ការប្រកួតប្រជែងដោយយុត្តិធម៌ និងសមត្ថភាព
- ដើម្បីលើកកម្ពស់ការការពារអតិថិជន។

គោលបំណងខាងលើពីរដំបូង អាចត្រូវបានដាក់បញ្ចូលក្រោមចំណងជើងថាប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់។

## ៤.៩- ការគ្រប់គ្រងអត្រាប្តូរប្រាក់ (Management of exchange rate)

ការត្រួតពិនិត្យការប្តូរប្រាក់ មានចែងក្នុងបទប្បញ្ញត្តិស្តីពីការត្រួតពិនិត្យការប្តូរប្រាក់ គឺត្រូវបានបង្កើតឡើងស្ថិតក្រោមការគ្រប់គ្រងរបស់អង្គភាពពាក់ព័ន្ធ និងការទទួលខុសត្រូវរបស់ក្រសួងសេដ្ឋកិច្ច ឬរតនាគារ។ ក្រសួងសេដ្ឋកិច្ច ឬរតនាគាចាត់ចែងរដ្ឋបាល និងប្រតិបត្តិការគ្រប់គ្រងផ្លាស់ប្តូរលក្ខខណ្ឌនៃបទប្បញ្ញត្តិស្តីពីការត្រួតពិនិត្យការប្តូរប្រាក់។ ដូចនេះ ទេសាអភិបាលរបស់ធនាគារកណ្តាល បានបង្កើតនាយកដ្ឋានត្រួតពិនិត្យការប្តូរប្រាក់ដែលមានការទទួលខុសត្រូវសម្រាប់ការគ្រប់គ្រងប្រចាំថ្ងៃការប្តូរប្រាក់។

ក្រសួងសេដ្ឋកិច្ច ឬរតនាគាក៏ស្ថិតក្រោមបទប្បញ្ញត្តិស្តីពីការត្រួតពិនិត្យការប្តូរប្រាក់ ដែលបានតែងតាំងធនាគារមួយចំនួនជាអ្នកចែកចាយបន្ត និងអនុញ្ញាតឱ្យការប្តូរប្រាក់បរទេសប្រតិបត្តិ។ ការតែងតាំងនេះផ្តល់សិទ្ធិឱ្យធនាគារទិញ និងលក់អត្រាប្តូរប្រាក់បរទេសស្របតាមលក្ខខណ្ឌមួយចំនួន និងក្នុងដែនកំណត់ដោយបទប្បញ្ញត្តិត្រួតពិនិត្យការប្តូរប្រាក់។ អ្នកចែកចាយបន្ត មានការអនុញ្ញាតមិនមែនជាភ្នាក់ងារសម្រាប់នាយកដ្ឋានត្រួតពិនិត្យការប្តូរប្រាក់ទេ។ ប៉ុន្តែធ្វើសកម្មភាពក្នុងនាមអតិថិជនរបស់ពួកគេនៅក្នុងបទប្បញ្ញត្តិបានចែង។

បទប្បញ្ញត្តិត្រួតពិនិត្យការប្តូរប្រាក់ បានបង្កើតឡើងដើម្បីរឹតត្បិតធ្វើចរាចរសេរីរបស់ទីផ្សារប្តូរប្រាក់បរទេស ដើម្បីការពារសេដ្ឋកិច្ចក្នុងស្រុកពីការប្រែប្រួលដ៏ធំ និងការរំខានក្នុងចលនាមូលធន និងវិបត្តិសេដ្ឋកិច្ចផ្សេងទៀត ដូចជាការឡើងថ្លៃទំនិញជាដើម។ វាត្រូវបានគេរចនាឡើង ដើម្បីការការពារការបម្រុងទុកសម្រាប់គោលបំណងសំខាន់ៗ។

វាមានសារសំខាន់មួយចំនួនសម្រាប់ការត្រួតពិនិត្យការប្តូរប្រាក់ មានអ្នកខ្លះនិយាយថាវាគ្មានសារសំខាន់ទេ វាមានតែគុណវិបត្តិតែប៉ុណ្ណោះ៖

- វាធ្វើឱ្យមានផលអវិជ្ជមានទៅដល់កិត្តិយសរបស់ប្រទេសជាតិ។
- ពួកគេបានធ្វើឱ្យរាំងស្ទះដល់កម្រិតតម្លៃ។ តម្លៃទីផ្សារការប្តូរប្រាក់ផ្លូវការ ត្រូវស្ថិតក្រោមការវាយតម្លៃក្នុងរយៈពេលណាមួយ។ ដូចនេះការបង្កើតទីផ្សារងងឹតក្នុងទីផ្សារការប្តូរប្រាក់ដែលមានអត្រាប្តូរប្រាក់ = តម្លៃពិត។
- វាលើកទឹកចិត្តជាច្រើនដល់ការផ្លាស់ប្តូរដែលមិនមានការត្រួតពិនិត្យការប្តូរប្រាក់។
- ពួកគេបានលើកទឹកចិត្តដល់អ្នក ដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភឱ្យមានទីលំនៅបានគ្រប់ទីកន្លែង។
- ពួកគេបានធ្វើឱ្យរដ្ឋាភិបាលដែលអសមត្ថភាពអាចបន្តកាន់អំណាចបានយូរជាងនេះ។
- ដោយមានការដាក់កម្រិតទៅលើការពង្រីកខ្លួនទៅកាន់ប្រទេសដ៏ទៃទៀត ដែលពួកគេអាចរាំងដល់ការអភិវឌ្ឍន៍ដល់ក្រុមហ៊ុនក្នុងស្រុកមួយចំនួន។
- ពួកគេបានបង្អាក់ការវិនិយោគបរទេស។
- វាមានកម្រិតថ្លៃ និងចំណាយពេលច្រើនដល់ធនាគារកណ្តាល ដែលផ្តល់សិទ្ធិទៅដល់ក្រុមហ៊ុនចែកចាយ ដែលមានការអនុញ្ញាតនៅទីផ្សារប្តូរប្រាក់បរទេសអាជីវកម្ម និងសាធារណៈ។
- ពួកគេបណ្តាលឱ្យមានការខកចិត្តដ៏ធំសម្រាប់អ្នកចែកចាយអាជីវកម្ម និងសាធារណៈ ដែលមានការអនុញ្ញាតក្នុងការចូលរួមចំណែកដល់គុណវិបត្តិ ដែលបានរៀបរាប់ខាងលើដូចជាការលើកទឹកចិត្តអ្នក ដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភអោយមានទីលំនៅបានគ្រប់ទីកន្លែង។

## ៤.១០- លក្ខណៈទូទៅនៃអត្រាប្តូរប្រាក់ (Nature of exchange rate)

អត្រា៖ គឺជាចំនួនរូបិយវត្ថុដែលអ្នកឱ្យខ្ចីទទួលបាន នៅពេលដែលអ្នកឱ្យខ្ចីផ្តល់ឥណទាន

អត្រាការប្រាក់៖ ជាអនុបាតការប្រាក់នៃចំនួនដែលឱ្យខ្ចី។

ឧទាហរណ៍៖ ឧបមាថាគេឱ្យខ្ចី ១០០ដុល្លារ ហើយនៅចុងឆ្នាំ គេទទួលបាន ១១០ដុល្លារ មកវិញ។ អត្រាដែលគេបង់គឺ ១០ដុល្លារ ហើយអត្រាការប្រាក់ គឺ១០%។ ដូច្នេះ ($10 / $100 = 0.10)

១. ការកំណត់អត្រាការប្រាក់ទីផ្សារ

អ្នកសន្សំប្រាក់សរុប ឬអ្នកផ្តល់កម្ចីសរុប នឹងការផ្គត់ផ្គង់មូលនិធិទៅឱ្យទីផ្សារឥណទាន។ អ្នកខ្ចីប្រាក់សរុបនឹងត្រូវការមូលនិធិពីទីផ្សារឥណទាន។ បរិយាកាសសព្វថ្ងៃកាន់តែបង្ហាញឱ្យឃើញថា មាន

ការជឿជាក់កាន់តែខ្លាំងលើការប្រកួតប្រជែងថ្លៃ ហើយថ្លៃសំខាន់ៗនៅក្នុងការប្រកួតប្រជែងនេះ គឺអត្រាការប្រាក់។

ក១. អត្រាការប្រាក់សម្រាប់មូលនិធិផ្ដល់ឥណទាន

អត្រាការប្រាក់ ត្រូវបានកំណត់ដោយច្បាប់នៃតម្រូវការ និងការផ្គត់ផ្គង់។ តម្រូវការរូបិយវត្ថុ និងការផ្គត់ផ្គង់រូបិយវត្ថុ គឺត្រូវបានកំណត់ដោយកត្តាជាច្រើន។ ក្នុងចំណោមកត្តាចូលរួម គឺការរំពឹងទុកអំពីអតិផរណា ឬថ្លៃអនាគត ជាពិសេសកត្តានៃវិស័យឯកជនការកើនឡើង និងការចង់បានសន្ទនីយភាព។

ខ១. ការផ្គត់ផ្គង់ឥណទាន

អត្រាការប្រាក់សមតា គឺត្រូវបានកំណត់ដោយទំនាក់ទំនងរវាងតម្រូវការរូបិយវត្ថុ និងការផ្គត់ផ្គង់រូបិយវត្ថុសម្រាប់ផ្ដល់កម្ចី។ ពួកសេដ្ឋវិទូភ្លាសិកជឿជាក់ថា ប្រាក់សន្សំ ឬមូលនិធិសម្រាប់ផ្ដល់កម្ចីមានតម្លៃវិជ្ជមានទាក់ទងនឹងអត្រាការប្រាក់។

ពួកសេដ្ឋវិទូអះអាងថា ប្រាក់សន្សំគឺធ្វើឱ្យកើនឡើងនូវកម្រិតប្រាក់ចំណូលរបស់ក្រុមគ្រួសារ។ ហើយអត្រាការប្រាក់ជះឥទ្ធិពលយ៉ាងខ្លាំងដោយលំហូរមូលនិធិសម្រាប់ផ្ដល់កម្ចី (ការផ្គត់ផ្គង់ និងតម្រូវការ) មិនមែនជាភាគហ៊ុននៃមូលនិធិដែលនៅចរាចរនោះទេ។ បន្ថែមទៅនឹងលំហូរប្រាក់សន្សំការកើនឡើងការផ្គត់ផ្គង់រូបិយវត្ថុដែលផ្ដល់កម្ចី និងការធ្លាក់ចុះតម្រូវការរូបិយវត្ថុ បានជះឥទ្ធិពលលើការផ្គត់ផ្គង់មូលនិធិកម្ចី។

គ១. តម្រូវការឥណទាន

អត្រាការប្រាក់៖ តម្រូវការមូលនិធិផ្ដល់កម្ចីពឹងផ្អែកលើមូលនិធិនៃថ្លៃដើមទាំងនោះ ឬអត្រាការប្រាក់ពិត។ ជាទូទៅគេជឿជាក់ថា ខណៈពេលដែលកម្ចីរបស់វិស័យឯកជន មានភាពរសើប ឬមានភាពយឺតនៃអត្រាការប្រាក់។ ជាអត្រាការប្រាក់គូសនៅលើខ្សែកោងតម្រូវការមូលនិធិផ្ដល់កម្ចី រួមជាមួយនឹងខ្សែកោងផ្គត់ផ្គង់មូលនិធិផ្ដល់កម្ចី។

២. អត្រាការប្រាក់ពិតផ្ទុយពីអត្រាការប្រាក់ធម្មតា

- អត្រាការប្រាក់ធម្មតា៖ ជាចំនួនដែលអ្នកផ្ដល់កម្ចីទទួលបាន ឬត្រូវបានគេឱ្យនិយមន័យថាជាអត្រាប្ដូរប្រាក់រវាងប្រាក់ដុល្លារនៅថ្ងៃនេះ និងប្រាក់ដុល្លារនៅថ្ងៃណាមួយនាថ្ងៃអនាគត។
- អត្រាផ្ដល់កម្ចីយកការប្រាក់នៅតម្លៃពិតប្រាកដមួយលើកំណើនរូបិយវត្ថុរបស់ពួកគេ នៅរយៈពេលណាមួយ។ យើងបានហៅអត្រានេះថា ជាអត្រាការប្រាក់ពិត។

ផ្ទុយទៅវិញអត្រាការប្រាក់ពិត គឺជាអត្រានៃការប្រែប្រួលរវាងទំនិញ និងសេវាកម្ម (ទំនិញពិតនៅថ្ងៃនេះ) ទំនិញ និងសេវាកម្មនាពេលអនាគត។ អត្រាការប្រាក់ពិត គឺស្មើអត្រាការប្រាក់ធម្មតា ដកនឹង អត្រាអតិផរណា។

សមីការដែលទាក់ទងនឹងអត្រាការប្រាក់ពិត និងអត្រាការប្រាក់ធម្មតា។ សមីការសាមញ្ញមួយអាចត្រូវបានគេប្រើប្រាស់ដើម្បីបង្ហាញទំនាក់ទំនងរវាងអត្រាការប្រាក់ពិត និងអត្រាការប្រាក់ធម្មតា។

គេបង្ហាញវាដូចខាងក្រោម ៖

**អត្រាការប្រាក់ធម្មតា (i) = អត្រាការប្រាក់ពិត (r) + អត្រារំពឹងទុកលើអតិផរណា ( Pe )**

សមីការនេះ ត្រូវបានគេរៀបចំដើម្បីបង្ហាញថា៖

**អត្រាការប្រាក់ពិត (r) = អត្រាការប្រាក់ធម្មតា (i) - អត្រាអតិផរណាដែលគេរំពឹងទុក ( Pe )**

យើងអាចចែកឱ្យដាច់រវាងអត្រាការប្រាក់ពិត និងអត្រាការប្រាក់ធម្មតាដែលខ្សែកោងតម្រូវការ និងខ្សែកោងផ្គត់ផ្គង់របស់មូលនិធិផ្តល់ឥណទាន។ នៅក្នុងអត្រាការប្រាក់នៅចំណុចសមតាដើម គឺត្រូវបានកំណត់ដោយទំនាក់ទំនងរវាងតម្រូវការ និងការផ្គត់ផ្គង់នៅត្រង់ចំណុចសមតា (Equilibrium) បានបង្ហាញពីតម្រូវការ និងការផ្គត់ផ្គង់ ប្រសិនបើអត្រាផរណាត្រូវគេរំពឹងថាមាន**តម្លៃសូន្យ**។

ឧទាហរណ៍៖ អត្រាប្តូរប្រាក់រវាងរូបិយវត្ថុនៃប្រទេសពីរ គឺជាកម្រិតថ្លៃនៃរូបិយវត្ថុដែលជានិវាសនជននៃប្រទេសទាំងពីរដោះដូរគ្នាទៅវិញទៅមក។

អត្រាប្តូរប្រាក់មានពីរប្រភេទគឺ៖ អត្រាប្តូរប្រាក់តាមថ្លៃទីផ្សារ និងអត្រាប្តូរប្រាក់ពិត។

១.១. អត្រាប្តូរប្រាក់តាមថ្លៃទីផ្សារ៖ អត្រាប្តូរប្រាក់តាមថ្លៃទីផ្សារ គឺជាថ្លៃប្រៀបធៀបនៃរូបិយវត្ថុរបស់ប្រទេសពីរ។

ឧទាហរណ៍ ប្រសិនបើអត្រាប្រាក់រៀលធៀបនឹងដុល្លារស្មើនឹង ៤,០០០រៀល ក្នុងមួយដុល្លារ មានន័យថា ប្រសិនបើយើងយកប្រាក់ចំនួន ៤,០០០រៀល យកទៅដូរនៅលើទីផ្សារប្តូរប្រាក់ នោះយើងនឹងបានប្រាក់ដុល្លារស្មើនឹង ១ដុល្លារ។ ដូច្នេះ នៅពេលដែលគេនិយាយថា អត្រាប្តូរប្រាក់រវាងប្រទេសពីរ គឺជាអត្រាប្តូរប្រាក់តាមថ្លៃទីផ្សារ។

១.២. អត្រាប្តូរប្រាក់ពិត៖ អត្រាប្តូរប្រាក់ពិត គឺជាថ្លៃប្រៀបធៀបនៃទំនិញនៅក្នុងប្រទេសពីរ។ គឺអត្រាប្តូរប្រាក់ពិត បានបង្ហាញឱ្យឃើញនូវអត្រាដែលយើងអាចដោះដូរទំនិញរបស់ប្រទេសមួយជាមួយនឹងទំនិញនៃប្រទេសមួយទៀត។ ដូចនេះ អត្រាប្តូរប្រាក់ពិតនេះយើងអាចហៅម៉្យាងទៀតថា "លក្ខខណ្ឌពាណិជ្ជកម្ម"។ ដើម្បីកំណត់នូវទំនាក់ទំនងរវាងអត្រាប្តូរប្រាក់ពិត និងអត្រាប្តូរប្រាក់តាមថ្លៃទីផ្សារ យើងត្រូវពិនិត្យមើលនូវមុខទំនិញមួយមុខដែលផលិតដោយប្រទេសជាច្រើន។

ឧទាហរណ៍៖ ខោកាត់ស្រាប់ នៅប្រទេសកម្ពុជា ខោកាត់ស្រាប់១ មានតម្លៃ ៨០,០០០ រៀល។ ចំណែកនៅសហរដ្ឋអាម៉េរិក ខោកាត់ស្រាប់១ មានតម្លៃ ៤០ ដុល្លារអាម៉េរិក។ ដើម្បីប្រៀបធៀបនូវថ្លៃនៃខោកាត់ស្រាប់នៃប្រទេសទាំងពីរ យើងត្រូវតែដូរថ្លៃឱ្យទៅជារូបិយវត្ថុតែមួយសិន។ ប្រសិនបើយើងដូរ ៨០,០០០ រៀល ដោយចែកនឹង ៤,០០០ រៀល យើងនឹងទទួលបាន ២០ ដុល្លារអាម៉េរិក។ ដូច្នេះ ខោកាត់ស្រាប់នៅកម្ពុជាមានថ្លៃត្រឹម ២០ ដុល្លារប៉ុណ្ណោះ។ ហើយខោកាត់ស្រាប់នេះដូចគ្នាមានតម្លៃ

៤០ ដុល្លារអាម៉េរិក នៅសហរដ្ឋអាម៉េរិក ពោលគឺនៅសហរដ្ឋអាម៉េរិកខោកាត់ស្រាប់ដូចគ្នានេះថ្លៃជាង នៅប្រទេសកម្ពុជាពីរដង។

ដូច្នេះ យើងអាចគណនាបាន៖

អត្រាប្តូរប្រាក់ = [(៤,០០០រៀល/ដុល្លារ) X (៨០,០០០រៀលខោកម្ពុជា)]/(៤០ ដុល្លារខោអាម៉េរិក) = ២ ខោកម្ពុជា/ខោអាម៉េរិក

ដូច្នេះ តាមថ្លៃនិងអត្រាប្តូរប្រាក់នេះ ខោ២នៅកម្ពុជា អាចទិញបានតែខោ១ នៅអាមេរិច។

យើងអាចសរសេរ៖

**អត្រាប្តូរប្រាក់ = [អត្រាប្តូរប្រាក់ថ្លៃទីផ្សារ x ថ្លៃទំនិញក្នុងស្រុក]/ទំនិញបរទេស**

យើងអាចសរសេរបានម៉្យាង៖

អត្រាប្តូរប្រាក់ពិត = អត្រាប្តូរប្រាក់តាមថ្លៃទីផ្សា x អនុបាតថ្លៃទំនិញ

$$E = e \times (P/P^*)$$

ដូច្នេះ ប្រសិនបើអត្រាប្តូរប្រាក់ពិតខ្ពស់ នោះទំនិញបរទេសនឹងថោក ហើយទំនិញក្នុងស្រុកនឹងថ្លៃ។ ប្រសិនបើអត្រាប្តូរប្រាក់ពិតទាប ទំនិញបរទេសនឹងថ្លៃ ហើយទំនិញក្នុងស្រុកនឹងថោក។

យើងមានទំនាក់ទំនងរវាងអត្រាប្តូរប្រាក់ពិត និងអត្រាប្តូរប្រាក់តាមទីផ្សារដូចតទៅ៖

អត្រាប្តូរប្រាក់ពិត = អត្រាប្តូរប្រាក់តាមថ្លៃទីផ្សារ X អនុបាតថ្លៃទំនិញ

$$E = e \times (P/P^*)$$

ដូច្នេះយើងអាចសរសេរបានថា៖

$$e = E / (P/P^*)$$

យើងឃើញថា អត្រាប្តូរប្រាក់តាមថ្លៃទីផ្សារអាស្រ័យអត្រាប្តូរប្រាក់ពិត និងកម្រិតថ្លៃនៅក្នុងប្រទេសទាំងស្រុង។ ប្រសិនបើអត្រាប្តូរប្រាក់ពិតនៅដដែល នៅពេលដែលថ្លៃឡើង នោះអត្រាប្តូរប្រាក់តាមថ្លៃទីផ្សារនឹងធ្លាក់ចុះ។

យើងអាចសរសេរបានថា៖

**ការប្រែប្រួលនៃ e = % ប្រែប្រួលនៃ E + % ប្រែប្រួលនៃ P* - % ប្រែប្រួលនៃ P**

ប្រសិនបើយើងតាង π ជាអត្រាអតិផរណាក្នុងប្រទេស ហើយ π* ជាអត្រាអតិផរណានៅបរទេស
យើងបាន៖

% ប្រែប្រួលនៃ e = %ប្រែប្រួលនៃ E + (π*- π)

ឬ

Δ **អត្រាប្តូរប្រាក់តាមថ្លៃទីផ្សារ** = Δ អត្រាប្តូរប្រាក់ពិត + **ផលដកនៃអតិផរណា**

ដូច្នេះ ប្រសិនបើកម្ពុជាមានអតិផរណាខ្ពស់ជាងសហរដ្ឋអាម៉េរិក ប្រាក់ដុល្លារអាចទិញនូវប្រាក់រៀលបានកាន់តែច្រើន។ ប្រសិនបើកម្ពុជាមានអតិផរណាទាបជាងសហរដ្ឋអាម៉េរិកនោះ ដុល្លារអាចទិញប្រាក់រៀលបានកាន់តែតិចទៅៗ។

ដោយឈរមូលដ្ឋាននៃការវិភាគខាងលើ យើងអាចសន្និដ្ឋានបានថា៖

*ទីមួយ* - អត្រាប្តូរប្រាក់ពិតពាក់ព័ន្ធនឹងការនាំចេញសុទ្ធ។ នៅពេលដែលអត្រាប្តូរប្រាក់ពិតទាប ទំនិញក្នុងស្រុកថោកជាងទំនិញនាំចូល ដែលធ្វើឱ្យការនាំចេញសុទ្ធកើនឡើង។

*ទីពីរ* - តុល្យភាពជញ្ជីងពាណិជ្ជកម្ម (ការនាំចេញសុទ្ធ) ត្រូវស្មើនឹងលំហូរចេញនូវមូលធន ដែលស្មើនឹងការវិនិយោគ។ សញ្ជ័យកំណត់ដោយអនុគមន៍ការប្រើប្រាស់ និងអត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ។

ទំនាក់ទំនងរវាងការនាំចេញសុទ្ធ និងអត្រាប្តូរប្រាក់ពិត មានមេគុណប្រាប់ទិសធ្លាក់ចុះដោយសារតែអត្រាប្តូរប្រាក់ពិតទាបនាំឱ្យទំនិញក្នុងស្រុកថោក។ សម្រាប់ខ្សែកោងនៃអតិរេកសញ្ជ័យលើសវិនិយោគ (S-I) ត្រង់ឡើងលើ ដោយសារតែអញ្ញត្តិទាំងពីរនេះ ពោលគឺសញ្ជ័យ និងវិនិយោគមិនអាស្រ័យនឹងអត្រាប្តូរប្រាក់ទេ។

ប្រសិនបើ ការវិនិយោគនៅក្នុងស្រុកកើនឡើងដោយមានអត្រាប្តូរប្រាក់នៅថេរ ផលដក)S-Iនឹ(ង ធ្លាក់ចុះ ដូច្នេះការនាំចេញសុទ្ធ )NXនឹងធ្លាក់ចុះ (ដែរ។ ដូច្នេះ កំណើនការវិនិយោគក្នុងស្រុកនឹងបង្កើតឱ្យមានឱនភាពពាណិជ្ជកម្ម។ បានបង្ហាញឱ្យឃើញថា កំណើនវិនិយោគរំកិលខ្សែបន្ទាត់ត្រង់ )S-Iទៅខាងឆ្វេងវិញ ដោយកាត់បន្ថយការនាំចេញសុទ្ធ ( (NX) និងបង្កើននូវអត្រាប្តូរប្រាក់។

គោលនយោបាយពាណិជ្ជកម្ម គឺជាគោលនយោបាយដែលមានទិសដៅធ្វើឱ្យមានឥទ្ធិពលដោយផ្ទាល់លើបរិមាណផលិតផល និងសេវាដែលត្រូវការនាំចេញ និងនាំចូល។ គោលនយោបាយពាណិជ្ជកម្មមានទិសដៅបង្កើនការនាំចេញ ឬគាំពារឧស្សាហកម្មក្នុងស្រុកពីការប្រណាំងប្រជែងពីបរទេសដោយយោងលើការនាំចូល ឬការកំណត់បរិមាណទំនិញ និងសេវា ដែលត្រូវនាំចូលដោយប្រើប្រាស់

ប្រព័ន្ធអនុគ្រោះពន្ធ "កូតា"។ គោលនយោបាយនេះ ការពារឧស្សាហកម្មក្នុងស្រុកហៅថាគោលនយោបាយការពារនិយម។

ដោយសារតែអត្រាប្តូរប្រាក់ពិតកើនឡើង ទំនិញ និងសេវាផលិតក្នុងស្រុកថ្លៃជាងទំនិញ និងសេវានាំចូល។ ដូច្នេះនៅចំណុចសមតាថ្មីការនាំចេញនឹងត្រូវកាត់បន្ថយ។ ជាលទ្ធផលការអនុវត្តគោលនយោបាយការពារនិយមធ្វើឱ្យទាំងការនាំចេញ និងការនាំចូលត្រូវធ្លាក់ចុះ។

វិទ្យាសាស្ត្រសេដ្ឋកិច្ច មានសម្មតិកម្មដ៏ល្បីល្បាញមួយ គឺច្បាប់ស្តីពីថ្លៃមួយ ( The Law of One Price) «ទំនិញតែមួយមិនអាចលក់តាមថ្លៃផ្សេងគ្នានៅកន្លែងខុសគ្នានៅពេលជាមួយគ្នាទេ»។ ប្រសិនបើអង្ករមួយបាវនៅភ្នំពេញថ្លៃជាងនៅកំពង់ចាមនោះ ឈ្មួញនឹងទិញអង្ករពីកំពង់ចាម ដើម្បីយកមកលក់នៅភ្នំពេញ ដើម្បីយកចំណេញ។

ប្រសិនបើយើងប្រើច្បាប់ស្តីពីថ្លៃមួយនៅលើទីផ្សារអន្តរជាតិ នោះយើងបានសមមូលនៃអនុភាពទិញ (Purchasing Power Parity)។

ទ្រឹស្តីសមមូលនៃអនុភាពទិញ មានផលប៉ះពាល់ពីរយ៉ាងគឺៈ

- ដោយសារខ្សែរបន្ទាត់ការនាំចេញសុទ្ធនៅរាបស្មើ នោះការប្រែប្រួលនៃសញ្ជ័យ និងការវិនិយោគ មិនប៉ះពាល់ដល់អត្រាប្តូរប្រាក់ពិត ឬអត្រាប្តូរប្រាក់តាមថ្លៃទីផ្សារឡើយ។
- ដោយសារអត្រាប្តូរប្រាក់ពិត មានលក្ខណៈតាមការប្រែប្រួលនៃអត្រាប្តូរប្រាក់តាមថ្លៃទីផ្សារនឹងនាំឲ្យទំនិញឡើងថ្លៃ។

## ៤.១១- ការគ្រប់គ្រងទ្រព្យសកម្មបរទេស (Management of foreign assets)

ទ្រព្យសកម្មបរទេសគឺកាន់កាប់ប្រាក់បញ្ញើរបស់ធនាគារ នៅក្នុងធនាគារបរទេស និងមូលប័ត្របរទេស ដូចជាមូលប័ត្ររតនាគារអាម៉េរិក និងប័ណ្ណបំណុលរបស់រដ្ឋាភិបាល(GBP)ជាដើម។ ការគ្រប់គ្រងដោយប្រយ័ត្នប្រយែងនៃទុនបម្រុងទ្រព្យសកម្មបរទេស គឺជាមុខងារសំខាន់របស់ធនាគារកណ្តាលត្រូវបានគ្របដណ្តប់លើៈ

- ហេតុអ្វីបានជាធនាគារកណ្តាលកាន់កាប់ទ្រព្យសម្បត្តិបរទេស?
- ហេតុអ្វីបានជាធនាគារកណ្តាលកម្រិតទុនបម្រុងដែលចង់បាន?
- ការគ្រប់គ្រងទ្រព្យសម្បត្តិបម្រុងរបស់បរទេស
- ដុល្លារអាម៉េរិកក្នុងការគ្រប់គ្រងទុនបម្រុងទ្រព្យសម្បត្តិបរទេស។

### ៤.១១.១- ហេតុអ្វីធនាគារកណ្តាលកាន់កាប់ទ្រព្យសកម្មបរទេស? (Why do central banks hold foreign assets?)

ធនាគារកណ្តាលកាន់កាប់ទ្រព្យសកម្មបរទេស/ផ្លាស់ប្តូរទ្រព្យសកម្ម សម្រាប់ហេតុផលសំខាន់ៗបួនយ៉ាងគឺៈ

- ធនាគារកណ្តាល គឺជាអ្នកថែរក្សាទុនបម្រុងទ្រព្យសកម្មបរទេសរបស់ប្រទេស។ អ្វីដែលសំខាន់ ពួកគេកាន់ភាគហ៊ុនបម្រុងទុកក្នុងនាមរដ្ឋាភិបាល និងសាធារណជន។ និយាយម៉្យាងទៀត ពួកគេត្រូវបានទាមទារដោយរដ្ឋាភិបាលតម្រូវឱ្យមានទុនបម្រុងគ្រប់គ្រាន់។
- ដើម្បីធ្វើអន្តរាគមន៍ពេលគឺ ដើម្បីលក់ ឬទិញប្តូរប្រាក់បរទេសនៅទីផ្សារបរទេស ដើម្បីជះឥទ្ធិពលលើតម្លៃរូបិយប័ណ្ណ។ ភាគហ៊ុននៃការប្តូររូបិយប័ណ្ណបរទេស ត្រូវបានទាមទារសម្រាប់គោលបំណងនេះ។
- សម្រាប់គោលបំណងប្រតិបត្តិការ។ ឧទាហរណ៍គឺការផ្តត់ផ្គង់រដ្ឋាភិបាលជាមួយ forex ដើម្បីជួយឱ្យវាអាចសងប្រាក់កម្ចីបរទេសដែលមានភាពចាស់ទុំ។ មួយវិញទៀតគឺអាចផ្គត់ផ្គង់ forex ទៅកាន់ទីផ្សារ ប្រសិនបើមានតម្រូវការច្រើនខុសពីធម្មតា (ឧទាហរណ៍ ប្រសិនបើក្រុមហ៊ុនអាកាសចរណ៍ត្រូវការចំណាយសម្រាប់ការទិញយន្តហោះ) ដើម្បីការពារការធ្លាក់ចុះអត្រា ប្តូរប្រាក់ភ្លាមៗ។
- ការវិនិយោគបរទេស (inward) មានទំនោរកើតឡើងនៅក្នុងប្រទេស ដែលមានទុនបម្រុងបរទេសខ្ពស់ និងមានស្ថេរភាព។

ទ្រព្យសកម្មបរទេសដែលកាន់កាប់ដោយធនាគារកណ្តាល ដូចជាមូលនិធិទ្រព្យសកម្ម ហើយគោលការណ៍គ្រប់គ្រងផលប័ត្រទាំងនេះ ត្រូវបានអនុវត្តរួមទាំងការធ្វើពិពិធកម្ម(diversification)ដែរ។ ដោយហេតុផលនេះ បណ្តាប្រទេសភាគច្រើន ធ្វើពិពិធកម្មទ្រព្យវិនិយោគទុនបរទេសរបស់ពួកគេទៅជា រូបិយប័ណ្ណដូចជា USD, EUR, JPY, CAD និងមាសជាដើម ជាទូទៅសម្រាប់ហេតុផលធ្វើពិពិធកម្ម។

## ៤.១១.២- កម្រិតទុនបម្រុងដែលចង់បាន (The desired level of reserves)

ពុំមានច្បាប់ណាឱ្យល្អឥតខ្ចោះសម្រាប់ទុនបម្រុង forex នោះទេ។ ការពិចារណាក្នុងរឿងនេះមានច្រើនយ៉ាងរួមមាន៖

- វិសាលភាពនៃការផ្លាស់ប្តូរអត្រាប្តូរប្រាក់។
- កម្រិតខ្ពស់នៃទុនបម្រុងបង្កើនភាពជឿជាក់នៃគោលនយោបាយអត្រាប្តូរប្រាក់របស់ធនាគារកណ្តាល។
- កម្រិតទុនបម្រុងជះឥទ្ធិពលដល់មុខមាត់ប្រទេសជាទូទៅ។
- "ភាពបើកចំហ" នៃសេដ្ឋកិច្ចដែលត្រូវបានវាស់វែងដោយពាណិជ្ជកម្មបរទេស/ផលិតផលក្នុងស្រុកសរុប។
- ភាពបត់បែននៃសេដ្ឋកិច្ច-សមត្ថភាពក្នុងការកែតម្រូវការផ្លាស់ប្តូរលំហូរមូលធនបរទេស និងពាណិជ្ជកម្មបរទេស។
- ថ្លៃដើមនៃការកាន់កាប់ទុនបម្រុង ប្រសិនបើអត្រាការប្រាក់ក្នុងស្រុកខ្ពស់ជាងអត្រាការប្រាក់បរទេស វាមានតម្លៃថ្លៃក្នុងការកាន់កាប់ប្រាក់បម្រុងបរទេស(forex)។

ខណៈពេលដែលមិនមានគោលការណ៍ណែនាំឱ្យបានច្បាស់លាស់ទេះ កម្រិតនៃប្រាក់បម្រុងស្មើនឹងតម្លៃនៃការនាំចូលសម្រាប់ក្នុងរយៈពេល ៣ ខែបន្ទាប់។

### ៤.១១.៣- ការគ្រប់គ្រងទុនបម្រុងទ្រព្យសម្បត្តិបរទេស

(Foreign asset reserve management)

ដូចបានបង្ហាញពីដំបូង ការគ្រប់គ្រងប្រាក់បម្រុងទុករបស់ប្រទេស រួមបញ្ចូលគោលការណ៍ទាំងអស់ ដែលបានបកស្រាយនៅក្នុងការគ្រប់គ្រងផលប័ត្រលើកលែងតែនៅទីនេះហានិភ័យចម្បង គឺជាហានិភ័យរូបិយប័ណ្ណ (currency risk)។

ទោះយ៉ាងណា ហានិភ័យរូបិយប័ណ្ណភាគច្រើនត្រូវបាន "វិធីផ្សេងគ្នា" (ដូចជាករណី asset sp e-cific risk) ដោយការវិនិយោគនៅក្នុងប្រទេសធំៗ៖ រូបិយប័ណ្ណធំៗ មានបម្រែបម្រួលទ្វេដងដូច្នេះហើយលទ្ធផលគឺមានហានិភ័យតិចតួច ប្រសិនបើធនាគារកណ្តាលវិនិយោគនៅក្នុងរូបិយប័ណ្ណសំខាន់ៗនៅក្នុងសមាមាត្រស្មើៗគ្នា។ រូបភាពទី១ បង្ហាញពីទំហំហានិភ័យ ឬពិពិធកម្មជាប្រែណី ដោយសារតែបរិមាណរូបិយប័ណ្ណដែលកាន់កាប់មិនគ្រប់គ្រាន់មានដូចជា USD, GBP, EUR, CAD, JPY និងCNY។

ក្រាហ្វិកទី៤ បង្ហាញ៖ ហានិភ័យ (Risk)




ការពិចារណាផ្សេងទៀតដែលទាក់ទងនឹងទ្រព្យសកម្មរូបិយប័ណ្ណបរទេសរួមមាន៖

- ប្រភេទឧបករណ៍។
- សង្វេបកាលវសាន្ត (រយៈពេល ៣ ខែរបស់ GBP ឬប័ណ្ណរតនាគាររយៈពេល ១០ ឆ្នាំរបស់ GBP)។

- បង្កើតដែនកំណត់សម្រាប់ទ្រព្យសកម្មជាក់លាក់។
- ការប្រើប្រាស់ប្រព័ន្ធព័ត៌មានគ្រប់គ្រងសម្រាប់៖
  - វាស់ស្ទង់បង្ហាញពីហានិភ័យ
  - ធានាថាហានិភ័យទាំងនេះ ត្រូវបានគ្រប់គ្រង និង
  - ការវាស់ស្ទង់លទ្ធផលបាន។
- ការប្រើប្រាស់ ឬមិនប្រើរបស់អ្នកគ្រប់គ្រងមូលនិធិខាងក្រៅ។ ជាទូទៅ ធនាគារកណ្តាលគ្រប់ គ្រងផលប័ត្រផ្ទាល់ខ្លួន ដោយសារហេតុផលសុវត្ថិភាព ការសម្ងាត់ ការចំណាយ និងរូបភាព (ធនាគារកណ្តាលមិនចង់ឱ្យគេដឹងថាខ្លួនគ្មានជំនាញក្នុងការគ្រប់គ្រងផលប័ត្រផ្ទាល់ខ្លួន)

## ៤.១១.៤- ដុល្លារអាម៉េរិកក្នុងការគ្រប់គ្រងទ្រព្យសកម្មជាទុនបម្រុង

(The USD in foreing asset reserve management)

អត្ថប្រយោជន៍នៃការធ្វើពិពិធកម្មក៏ដោយប្រាក់ដុល្លារនៅតែជាមធ្យោបាយវិនិយោគចម្បង(ប្រាក់បញ្ញើមូលប័ត្ររតនាគារ និងសញ្ញាប័ណ្ណជាដើម) សារសំខាន់ទាក់ទងនឹងប្រាក់ដុល្លារអាម៉េរិកក្នុងការកាន់កាប់ទ្រព្យសកម្មបរទេស អាចត្រូវបានកំណត់ដោយកត្តាមួយចំនួន៖

- តួនាទីបន្តរបស់ដុល្លារអាម៉េរិកជារូបិយប័ណ្ណបម្រុងអន្តរជាតិបឋម។
- ទីផ្សារហិរញ្ញវត្ថុជាដុល្លារអាម៉េរិកផ្តល់ជូននូវឧបករណ៍ និងទីផ្សារពារយ៉ាងច្រើនដែលមានប្រតិបត្តិការធំៗ អាចត្រូវបានសម្រេច។
- ភាគច្រើនការនាំចេញ និងការនាំចូលរបស់ប្រទេសនីមួយៗ ត្រូវបានកំណត់ជាប្រាក់ដុល្លារអាម៉េរិក(USD)។
- បំណុលគិតជាដុល្លារអាម៉េរិក បង្កើតជាសមាមាត្រដ៏សំខាន់នៃបំណុលខាងក្រៅរបស់ប្រទេសភាគច្រើន។
- ដុល្លារអាម៉េរិក ត្រូវបានប្រើប្រាស់ស្ទើរតែទាំងស្រុងនៅគ្រប់ទីកន្លែង និងក្នុងប្រតិបត្តិការរវាងធនាគារកណ្តាល និងធនាគារ ដែលត្រូវបានអនុញ្ញាតឱ្យធ្វើការប្តូរជារូបិយប័ណ្ណបរទេស។

## ៤.១២- ការអភិវឌ្ឍន៍ទីផ្សារបំណុល (Development of the debt market)

ទីផ្សារហិរញ្ញវត្ថុ គឺទីផ្សារជួយសម្រួលដល់ការបង្កើត និងលក់ឧបករណ៍ហិរញ្ញវត្ថុ។ ឧបករណ៍ហិរញ្ញវត្ថុ គឺជាមូលប័ត្រដែលអាចមានទម្រង់ជាវិញ្ញាបនបត្រ ឬការចុះបញ្ជីក្នុងគណនីដែលតំណាងសិទ្ធិលើឥណទេយ្យ និងផ្តល់ឱ្យម្ចាស់មូលប័ត្រនូវកម្មសិទ្ធិលើឥណទេយ្យ។ ឧបករណ៍ហិរញ្ញវត្ថុ ជាឥណ ទេយ្យរបស់អ្នកឱ្យខ្ចីមូលនិធិ ចំពោះការទទួលយកចំណូលពីអ្នកខ្ចីមូលនិធិដែលជាអ្នកត្រូវការមូលនិធិនេះសម្រាប់ធ្វើហិរញ្ញប្បទានដល់ការវិនិយោគ។ ទន្ទឹមនឹងនេះ ទីផ្សារហិរញ្ញវត្ថុមានសារសំខាន់សម្រាប់តួនាទីសេដ្ឋកិច្ច ដែលជាទីកន្លែងបង្វែរនូវសញ្ច័យធនទៅឱ្យសហគ្រាសដែលត្រូវការទុនវិនិយោគ។ ដូចនេះ ទីផ្សារហិរញ្ញវត្ថុមាន២ប្រភេទសំខាន់គឺទីផ្សារទី១ សំដៅដល់ទីផ្សារចេញផ្សាយហ៊ុនថ្មីពាក់

ព័ន្ធការបែងចែកដំបូងនូវឧបករណ៍ហិរញ្ញវត្ថុដែលទើបបង្កើតថ្មី និងទីផ្សារទី២សំដៅដល់ទីផ្សារជួញដូរឧបករណ៍ហិរញ្ញវត្ថុដែលមាន ឬចេញផ្សាយស្រាប់។ ទីផ្សារបំណុល (debt market) រួមមាន៖

- ទីផ្សារបំណុលរយៈពេលខ្លី បង្កើតទីផ្សារបំណុលអាចលក់បាន (ST-MD) និងទីផ្សារបំណុលមិនអាចលក់បាន (ST-NMD) ។ ទីផ្សារបំណុលទាំងមូល ត្រូវបានគេសំដៅទៅលើរូបិយវត្ថុ (មាននិយមន័យខុសគ្នា ពីព្រោះការកំណត់ថ្លៃកើតឡើងនៅក្នុងទីផ្សារបំណុលរយៈពេលខ្លី (STDM) ទាំងមូល។
- ទីផ្សារបំណុលរយៈពេលវែង(LT-DM) បង្កើតទីផ្សារបំណុលអាចលក់បាន និងទីផ្សារបំណុលមិនអាចលក់បាន (LT-NMD)។ ទីផ្សារសញ្ញាប័ណ្ណគឺជាទីផ្សារ (LT-MD) ហើយវានៅដាច់ដោយឡែកពីគ្នាពីព្រោះការកំណត់ថ្លៃកើតឡើងជាចម្បងនៅក្នុងទីផ្សារនេះ។

ធនាគារកណ្តាល មានចំណាប់អារម្មណ៍លើទីផ្សារហិរញ្ញវត្ថុទាំងអស់ ពីព្រោះនេះជាទីកន្លែងឱ្យខ្ចីប្រាក់ និងការផ្តល់ប្រាក់កម្ចីបានកើតឡើង(ភាគហ៊ុន និងការខ្ចីប្រាក់ជាប្រចាំ) និងទីកន្លែងបង្កើតលុយ។ ទោះយ៉ាងណា ធនាគារកណ្តាលមានចំណាប់អារម្មណ៍ពិសេសនៅក្នុងទីផ្សារបំណុល ពីព្រោះទីផ្សារនេះគឺជាទីផ្សារដែលវាដំណើរការ ហើយផ្នែកដ៏សំខាន់នៃស្ថេរភាពហិរញ្ញវត្ថុ(ធនាគារកណ្តាលមានជាតុចូលសំខាន់)។ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ការឱ្យខ្ចីប្រាក់ និងការផ្តល់ប្រាក់កម្ចី ចាប់ផ្តើមចេញពីធនាគារ។ ជាបឋម ទីផ្សារហិរញ្ញវត្ថុទាំងមូលគឺជាទីផ្សារ (ST-NMD) តាមរយៈប្រព័ន្ធធនាគារ។

ឧបករណ៍(ST-MD) ត្រូវបង្ហាញខ្លួនដំបូងគេបង្អស់ គឺមូលប័ត្ររតនាគារដែលជាប័ណ្ណបំណុលរបស់រដ្ឋាភិបាល ដែលជាធម្មតាត្រូវបានអនុវត្តដោយសុវត្ថិភាពដោយធនាគារកណ្តាល (ហៅថាមូលប័ត្រធនាគារកណ្តាល)។ បន្ទាប់មកទៀត ត្រូវបានចេញផ្សាយនូវគោលបំណងនៃគោលនយោបាយរូបិយវត្ថុ និងស្ថានភាពខាងក្រោយសាច់ប្រាក់ងាយដែលលើស ដែលបានបង្កើតឡើងដោយការលក់មូលនិធិម្ចាស់ជំនួយ (forex) ដោយរដ្ឋាភិបាលទៅឱ្យធនាគារកណ្តាល។ តារាងតុល្យការទី ២២-២៥ បង្ហាញពីជំហាននៃការបង្កើតសាច់ប្រាក់ងាយរងគ្រោះលើស(ER), (r = 10%)។

| BALANCE SHEET 22: GOVERNMENT (USD BILLIONS) | | | |
|---|---|---|---|
| Assets | | Liabilities | |
| Deposit at foreign bank (1) | +100 | | |
| Deposit at foreign bank (2) | -100 | | |
| Deposit at foreign bank (3) | +100 | Donation (1) | +100 |
| Deposit at foreign bank (4) | -100 | | |
| Goods (5) | +100 | | |
| Total | +100 | Total | +100 |

| BALANCE SHEET 23: CENTRAL BANK (USD BILLIONS) | |
|---|---|
| Assets | Liabilities |

| | | | |
|---|---|---|---|
| Deposit at foreign bank ( 3 ) | +100 | Government deposit ( 3 )<br>Government deposit ( 4 )<br>Reserve accounts ( TR ) ( 5 )<br>( RR = + 10 )<br>( ER = +90 ) | <br>+100<br>-100<br>+100 |
| **Total** | **+100** | **Total** | **+100** |

| BALANCE SHEET 24: BANK A ( USD BILLIONS ) | | | |
|---|---|---|---|
| **Assets** | | **Liabilities** | |
| Reserve accounts ( TR ) ( 5 )<br>( RR = + 10 )<br>( ER = +90 ) | +100 | Deposits ( NBPS ) ( 5 ) | +100 |
| **Total** | **+100** | **Total** | **+100** |

| BALANCE SHEET 25: NPBS ( USD BILLIONS ) | | | |
|---|---|---|---|
| **Assets** | | **Liabilities** | |
| Goods ( 5 )<br>Deposits at bank ( 5 ) | -100<br>+100 | | |
| **Total** | **0** | **Total** | **0** |

សន្មតថាធនាគារមានតុល្យភាពពីដំបូង (គ្មាន ER) និង (គ្មាន BR)ទេ។ ពួកគេមាន( មាន ER) មានចំនួនទឹកប្រាក់ ៩០ពាន់លានដុល្លារ (ចំនួនទឹកប្រាក់ ១០ពាន់លានដុល្លារ ត្រូវបានរក្សាទុនក្នុងគណនី ទុនបម្រុងកាតព្វកិច្ច (RR)។ អត្រាការប្រាក់នឹងធ្លាក់ចុះយ៉ាងខ្លាំង ធនាគារកណ្តាលអាចទប់ស្កាត់បញ្ហានេះដោយបានចេញប័ណ្ណបំណុលរបស់ធនាគារកណ្តាល។ មានបង្ហាញក្នុងតារាងតុល្យការ ២៦-២៧។

| BALANCE SHEET 26: CENTRAL BANK ( USD BILLIONS ) | | | |
|---|---|---|---|
| **Assets** | | **Liabilities** | |
| | | CB bills<br>Reserve accounts ( TR )<br>( RR = +10 )<br>( ER = 0 ) | <br>+90<br>+10 |

| | | | |
|---|---|---|---|
| Total | +100 | Total | +100 |

| BALANCE SHEET 27: BANK A ( USD BILLIONS ) | | | |
|---|---|---|---|
| Assets | | Liabilities | |
| CB bills | | | |
| Reserve accounts ( TR ) | +90 | | |
| ( RR = +10 ) | -90 | | |
| ( ER = 0 ) | | | |
| Total | 0 | Total | 0 |

ដើម្បីធ្វើឱ្យលំហាត់នេះកាន់តែច្បាស់លាស់ យើងបង្ហាញឱ្យឃើញថាតារាងតុល្យការ ២៨-២៩ ត្រូវបានបង្ហាញពីប្រសិទ្ធភាពជាក់ស្ដែង។ ការពង្រីកឥទ្ធិពលនៃការផ្ដល់អំណោយ (donation) ត្រូវបានចាត់ថ្នាក់ជាអព្យាក្រឹត (neutratised)។

| BALANCE SHEET 28: CENTRAL BANK ( USD BILLIONS ) | | | |
|---|---|---|---|
| Assets | | Liabilities | |
| | | CB bills | |
| Deposit at foreign bank | +100 | Reserve accounts ( TR ) | +90 |
| | | ( RR = +10 ) | +10 |
| | | ( ER = 0 ) | |
| Total | +100 | Total | +100 |

| BALANCE SHEET 29: BANK A ( USD BILLIONS ) | | | |
|---|---|---|---|
| Assets | | Liabilities | |
| CB bills | | | |
| Reserve accounts ( TR ) | +90 | | |
| ( RR = +10 ) | -90 | Deposits ( NBPS ) | +100 |
| ( ER = 0 ) | | | |
| Total | +100 | Total | +100 |

ជាទូទៅ ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើន ប្រើពាក្យថា "អន្តរការីហិរញ្ញវត្ថុ" មានប្រវត្តិមកពីចក្រភពអង់គ្លេសនាសតវត្សរ៍ទី១៧ ត្រូវបានលើកទឹកចិត្តឱ្យប្រើនៅក្នុងទីផ្សារហិរញ្ញវត្ថុ ពាក្យថា "dis-

count house"៖ ពួកគេបានចាប់ផ្តើមជីវិតជាមេខ្យល់ប័ណ្ណពាណិជ្ជកម្ម និងត្រូវបានបង្កើតជាធនាគារឯកទេស។ ដែលបានទទួលប្រាក់បញ្ញើរយៈពេលខ្លីពីធនាគារ និងអ្នកដាក់ប្រាក់បញ្ញើផ្សេងទៀតក្នុង) បានវិនិយោគនៅក្នុង(ករណីខ្លះ STMD និងបង្កើតទីផ្សារលើទ្រព្យសម្បត្តិទាំងនេះ។ ការលើកទឹកចិត្តគឺថាវាមិនមែនជាចំណាប់អារម្មណ៍របស់ធនាគារក្នុងការធ្វើទីផ្សារទេ ពីព្រោះពួកគេលូតលាស់នៅក្នុងទីផ្សារដែលមិនមានប្រសិទ្ធិភាពទាក់ទងនឹងរឹមធំទូលាយ។

Discount houses គឺជាកង្វះខាតជីវិតរបស់ធនាគារ ពីព្រោះពួកគេបានកាត់បន្ថយមធ្យមភាគប្រាក់ចំណេញរបស់ធនាគារតាមរយៈបង្កើតទីផ្សារបំណុលឡើង និងការអប់រំវិស័យសេវាកម្មហិរញ្ញវត្ថុ។ ពួកគេក៏ជាឧបករណ៍ក្នុងការបង្កើតទ្រព្យសកម្មថ្មីក្នុងទម្រង់ជា CP, NCDs និងសញ្ញាប័ណ្ណផងដែរ។ តាមបណ្តាប្រទេសភាគច្រើន មិនបានលើកទឹកចិត្តទៅដល់ discount house នោះទេ ក្រុមហ៊ុនចែកចាយបានព្យាយាមណែនាំវិធីសាស្ត្របឋមក្នុងការបោះផ្សាយប័ណ្ណ និងបង្កើតទីផ្សារបំណុល ហើយតែងតែទទួលបាននូវជោគជ័យ ពីព្រោះតែការស្ទាក់ស្ទើររបស់ធនាគារដើម្បីបង្កើតទីផ្សារបំណុល។

បន្ទាប់ពីមានការអភិវឌ្ឍន៍ទីផ្សាររូបិយវត្ថុមក ជារួមមានកម្លាំងរុញច្រានក្នុងការអភិវឌ្ឍន៍ទីផ្សារភាគហ៊ុន ក្នុងនាមជាអ្នកផ្តល់នូវភាគហ៊ុនរយៈពេលវែង (preference shares) និងភាគហ៊ុនធម្មតា (ordinary/common shares)។ នេះបានកើតឡើងដោយសារតែ មានការស្ទាក់ស្ទើរក្នុងការវិនិយោគលើមូលប័ត្របំណុលសម្រាប់រយៈពេលវែងប៉ុណ្ណោះ។

ទីផ្សារមូលប័ត្របំណុល(Bond market) ជួនកាលត្រូវបានផ្តួចផ្តើមឡើងយ៉ាងត្រឹមត្រូវដោយធនាគារកណ្តាលនៅក្នុងទម្រង់នៃការបង្កើត និងបោះពុម្ពផ្សាយ "អត្រាគំរូ" របស់រដ្ឋាភិបាល។ នេះត្រូវបានរៀបចំឡើង ដើម្បីជំរុញការចាប់អារម្មណ៍ពីធនាគារ និងសហគមមូលប័ត្រ (stockbroking community) ហើយជារឿយៗ ត្រូវបានប្រតិកម្មដោយធនាគារកណ្តាល ដែលបានដើរតួជាអ្នកបង្កើតទីផ្សារមូលប័ត្របំណុល ពោលគឺកើតចេញពីការទិញ(ដេញថ្លៃ) និងការលក់(ផ្តល់ជូន) ក្នុងពេលដំណាលគ្នាលើប័ណ្ណបំណុលដែលមានស្រាប់ទាំងអស់។

គំនិតផ្តួចផ្តើមទាំងនេះ ជំរុញឱ្យសកម្មភាពនៅលើទីផ្សារបំណុល និងណែនាំឱ្យមានទីផ្សារទី២ (secondary market) ដែលបង្កើតឡើងដោយធនាគារ ឬឈ្មួញកណ្តាល (stockbroker)។ ទីផ្សារមូលប័ត្របំណុលសាជីវកម្ម បានធ្វើតាមរយៈខ្សែកោង (risk-free yield curve) គឺតម្រូវឱ្យមានជាក្របខ័ណ្ឌគោលការណ៍ (benchmark)។ ក្នុងចំណោមគោលការណ៍នៃគោលការណ៍វិនិយោគ គឺថាតម្លៃតបស្នងរបស់មូលប័ត្ររដ្ឋាភិបាល (government securities) គឺអត្រាទាបបំផុតដែលអាចទទួលយកបាន ពីព្រោះវាផ្តល់អត្រាគ្មានហានិភ័យ(rfr) ហើយរាល់ការវិនិយោគដ៏ទៃទៀត ត្រូវតែផ្តល់មកវិញនូវតម្លៃតបស្នងវិញដែលបានកំណត់ថា(rrr) = (rp)៖

$$rrr = rfr + rp$$

*សំណួរសួរថា៖* ហេតុអ្វីបានជាធនាគារកណ្តាលចង់បានទីផ្សារហិរញ្ញវត្ថុសកម្ម?

*ចម្លើយគឺ៖*

- វាចាំបាច់ត្រូវធ្វើឱ្យប្រតិបត្តិទីផ្សារបើកចំហ (OMO) ដោយឱ្យមានប្រសិទ្ធភាព ដើម្បីជះឥទ្ធិពលឱ្យដល់សាច់ប្រាក់ងាយស្រួលរបស់ធនាគារ ហើយវាអាចប្រតិបត្តិបាននៅក្នុងទីផ្សារសាច់ប្រាក់តែប៉ុណ្ណោះ។
- ដើម្បីស្វែងរកឱ្យឃើញកម្រិតថ្លៃប្រកបដោយប្រសិទ្ធភាព ដែលជាផលិតផលនៃទីផ្សារសាច់ប្រាក់ងាយស្រួលតម្រូវឱ្យអត្រាការប្រាក់អាចមានប្រតិកម្មភ្លាមៗ សម្រាប់ការប្រែប្រួលធ្វើឱ្យរំញោចដល់គោលនយោបាយរូបិយវត្ថុ។

# ជំពូកទី ៥

# ក្របខ័ណ្ឌនៃគោលនយោបាយរូបិយវត្ថុ

# FRAMEWORK OF MONETARY POLICY

## ៥.១- សេចក្តីផ្តើម (Introduction)

ក្របខ័ណ្ឌនៃមុខងាររបស់ធនាគារកណ្តាល យើងបានទុកមុខងារដ៏សំខាន់បំផុតរបស់ធនាគារកណ្តាលសម្រាប់សិក្សានៅផ្នែកចុងក្រោយ មុខងារសំខាន់បំផុត គឺគោលនយោបាយរូបិយវត្ថុ។ យើងមិនអាចប្រកែកបានឡើយថាការកើនឡើងខ្លាំងពេកនៃស្តុករូបិយវត្ថុ គឺបុព្វហេតុនៃអតិផរណា។ ដោយសារតែអតិផរណាខ្ពស់ជះឥទ្ធិពលអវិជ្ជមានដល់សេដ្ឋកិច្ច យើងត្រូវការគោលនយោបាយដែលទាក់ទងនឹងកំណើនស្តុករូបិយវត្ថុគឺគោលនយោបាយរូបិយវត្ថុ។ ប្រទេសទាំងអស់មានធនាគារកណ្តាល និងមានគោលនយោបាយរូបិយវត្ថុរបស់ពួកគេ។ ទោះយ៉ាងណាក៏ដោយ គោលនយោបាយរូបិយវត្ថុមិនត្រូវបានរៀបចំអនុវត្ត និងប្រតិបត្តិឱ្យបានល្អឥតខ្ចោះនោះទេ។ ក្នុងតារាងទី១ ខាងលើនេះ បានបែងចែងគោលនយោបាយរូបិយវត្ថុជា៣ផ្នែក។ ផ្នែកទាំង៣នេះ គឺជាបេះដូងនៃគោលនយោបាយរូបិយវត្ថុរបស់ធនាគារកណ្តាល ប៉ុន្តែមានការពិភាក្សាជាច្រើនទៀត ដូចជាការវាស់វែងរូបិយវត្ថុ ការបង្កើតរូបិយវត្ថុ ក្របខ័ណ្ឌគោលនយោបាយរូបិយវត្ថុជាដើម។

ផ្នែកទាំងនេះត្រូវបានរៀបចំមានដូចខាងក្រោម៖

- ការកំណត់អត្រាការប្រាក់
- ការវាស់វែងរូបិយវត្ថុ
- អត្តសញ្ញាណរូបិយវត្ថុ៖ ប្រភពនៃការបង្កើតរូបិយវត្ថុ
- បទប្បញ្ញត្តិច្បាប់
- គោលបំណងនៃគោលនយោបាយរូបិយវត្ថុ
- ស្ថិរភាពថ្លៃ
- អតិផរណាដែលផ្តោតលើក្របខ័ណ្ឌគោលនយោបាយរូបិយវត្ថុ
- គណនេយ្យភាពគោលនយោបាយ និងតម្លាភាព
- ដែនកំណត់នៃគោលនយោបាយរូបិយវត្ថុ
- ឧបករណ៍នៃគោលនយោបាយរូបិយវត្ថុ
- ឯករាជ្យភាពរបស់ធនាគារកណ្តាល

### ៥.១.១- ការកំណត់អត្រាការប្រាក់ទីផ្សារ

អ្នកសន្សំប្រាក់សរុប ឬអ្នកផ្តល់កម្ចីសរុប និងការផ្គត់ផ្គង់រូបិយវត្ថុទៅឱ្យទីផ្សារហិរញ្ញវត្ថុ។ អ្នកខ្ចីប្រាក់ ត្រូវការមូលនិធិពីទីផ្សារហិរញ្ញវត្ថុ។ បរិយាកាសសព្វថ្ងៃកាន់តែបង្ហាញឱ្យមានការជឿជាក់កាន់តែខ្លាំងលើការប្រកួតប្រជែងកម្រិតថ្លៃ ហើយថ្លៃសំខាន់ៗនៅក្នុងការប្រកួតប្រជែងនេះ គឺអត្រាការប្រាក់។

#### ក. អត្រាការប្រាក់សម្រាប់រូបិយវត្ថុផ្តល់កម្ចី

អត្រាការប្រាក់ ត្រូវបានកំណត់ដោយច្បាប់តម្រូវការ និងការផ្គត់ផ្គង់រូបិយវត្ថុ។ តម្រូវការនៃការផ្គត់ផ្គង់រូបិយវត្ថុ គឺត្រូវបានកំណត់ដោយកត្តាជាច្រើន។ ក្នុងចំណោមកត្តាចូលរួម គឺការរំពឹងទុកអំពីអតិផរណា ឬថ្លៃអនាគត ជាពិសេសវិស័យឯកជនការកើនឡើង និងការចង់បានសន្ទនីយភាព។

### ខ. ការផ្គត់ផ្គង់រូបិយវត្ថុ

អត្រាការប្រាក់លំនឹងសមតា គឺត្រូវបានកំណត់ដោយទំនាក់ទំនងរវាងតម្រូវការរូបិយវត្ថុ និងការផ្គត់ផ្គង់រូបិយវត្ថុសម្រាប់ផ្តល់ប្រាក់កម្ចី។ ពួកសេដ្ឋវិទូក្លាស៊ិចនិយមជឿជាក់ថាប្រាក់សន្សំ ឬរូបិយវត្ថុផ្តល់ប្រាក់កម្ចីមានតម្លៃវិជ្ជមានទាក់ទងនឹងអត្រាការប្រាក់។ សេដ្ឋវិទូបានអះអាងថាប្រាក់សន្សំ គឺធ្វើឱ្យកើនឡើងនូវកម្រិតប្រាក់ចំណូលរបស់ភ្នាក់ងារគ្រួសារ។ អត្រាការប្រាក់ជះឥទ្ធិពលយ៉ាងខ្លាំងលើលំហូរនៃរូបិយវត្ថុផ្តល់ប្រាក់កម្ចី (ការផ្គត់ផ្គង់ និងតម្រូវការ) មិនមែនជាភាគហ៊ុននៃរូបិយវត្ថុដែលនៅចរាចរនោះទេ។ បន្ថែមទៅនឹងលំហូរប្រាក់សន្សំ ការកើនឡើងការផ្គត់ផ្គង់រូបិយវត្ថុដែលផ្តល់ប្រាក់កម្ចី និងការធ្លាក់ចុះតម្រូវការរូបិយវត្ថុបានជះឥទ្ធិពលលើការផ្គត់ផ្គង់រូបិយវត្ថុផ្តល់ប្រាក់កម្ចី។

### គ. តម្រូវការរូបិយវត្ថុ

អត្រាការប្រាក់ គឺតម្រូវការមូលនិធិផ្តល់កម្ចីពឹងផ្អែកលើមូលនិធិនៃថ្លៃដើមទាំងនោះ ឬអត្រាការប្រាក់ពិត។ ជាទូទៅ គេជឿជាក់ថាខណៈពេលដែលកម្ចីរបស់វិស័យឯកជនមានភាពរសើប ឬមានភាពយឺតនៃអត្រាការប្រាក់។

## ៩.១.២- ប្រតិបត្តិការមូលដ្ឋានរបស់ធនាគារ

មុនពេលបន្តសិក្សាឱ្យបានលម្អិតថែមទៀតអំពីការដែលថា តើធនាគារអាចគ្រប់គ្រងទ្រព្យសកម្ម និងបំណុលរបស់ខ្លួនយ៉ាងដូចម្តេច? ដើម្បីធ្វើឱ្យទទួលបានប្រាក់ចំណេញខ្ពស់បំផុត អ្នកគួរតែយល់អំពីប្រតិបត្តិការជាមូលដ្ឋានរបស់ធនាគារ។ ក្នុងលក្ខខណ្ឌទូទៅ ធនាគារបង្កើតប្រាក់ចំណេញតាមរយៈការលក់បំណុល ដែលមានលក្ខណៈពិសេសមួយស៊េរី (ជាពិសេសគឺការបន្សំចូលគ្នានៃសន្ទនីយភាពហានិភ័យ និងចំណូលការប្រាក់) និងប្រើប្រាស់វា ដើម្បីទិញទ្រព្យបន្តដែលមានលក្ខណៈពិសេសមួយស៊េរី។ ដើម្បីធ្វើការវិភាគលើប្រតិបត្តិការរបស់ធនាគារដែលអាចកំបាំងថែមទៀត យើងប្រើឧបករណ៍ដែលត្រូវគេហៅឈ្មោះថា ធីអាខោន (T-Account)។

ឧទាហរណ៍ ៖ អំពីធីអាខោនសម្រាប់ជាឧបករណ៍របស់ធនាគារគឺ នៅពេលដែលមូលប្បទានប័ត្រត្រូវបានគេសរសេរលើធីអាខោន

| Bank A | | | |
|---|---|---|---|
| Assets | | Liabilities | |
| Vault cash | +100 | Checkable deposit | +100 |
| Total | +100 | Total | +100 |

| Bank A | | | |
|---|---|---|---|
| Assets | | Liabilities | |
| Reserve | +100 | Checkable deposit | +100 |
| Total | +100 | Total | +100 |

នៅពេលមូលប្បទានប័ត្រត្រូវគេដាក់ជាគណនីនៅធនាគារមួយ ដែលមូលប្បទានប័ត្រនេះ គេដាក់ចូលទៅផ្នែកផ្សេងទៀតនោះធនាគារ ដែលទទួលបានទុនបម្រុងចំណេញលើប្រាក់បញ្ញើស្មើទៅនឹងមូលប្បទានប័ត្រ។ ដូចនេះ នៅពេលដែលធនាគារទទួលបានប្រាក់បញ្ញើបន្ថែម ធនាគារទទួលបានចំនួនទុនបម្រុងស្មើគ្នា។

### ៥.១.៣- ការវាស់វែងរូបិយវត្ថុ ( measuring money )

អ្នកបានដឹងហើយថាស្តុករូបិយវត្ថុ ត្រូវបានបង្កើតឡើងដោយក្រដាសប្រាក់ និងកាស និងប្រាក់បញ្ញើធនាគារ ដែលជាសិទ្ធិផ្ដាច់មុខរបស់ធនាគារកណ្ដាល (NBPS)។ យើងមាន សំណួរពីរទាក់ទងនឹងបញ្ហានេះ៖ តើធនាគារកណ្ដាលគណនាភាគហ៊ុនរូបិយវត្ថុយ៉ាងដូចម្ដេច? តើរយៈពេលប៉ុន្មាននៃការដាក់ប្រាក់បញ្ញើធនាគារ? ធនាគារកណ្ដាលនៅលើទូទាំងពិភពលោកបានឱ្យនិយមន័យផ្សេងៗគ្នានៃបរិមាណរូបិយវត្ថុ ពី M1-M5 ។ ធនាគារកណ្ដាល បានរួមបញ្ចូលក្រដាសប្រាក់ និងកាស ដែលកាន់កាប់ដោយធនាគារកណ្ដាល (NBPS) និងភាពខុសគ្នារបស់ធនាគារកណ្ដាលទាំងនេះ គឺនៅត្រង់ពាក្យថាកាលវសាន្ត(maturity)នៃប្រាក់បញ្ញើធនាគាររបស់ធនាគារកណ្ដាល(NBPS) ហើយបរិមាណប្រាក់បន្ថែមកាន់តែច្រើននៅក្នុងទ្រព្យសកម្មសាច់ប្រាក់ប្រហាក់ប្រហែល (near-money assets) ដទៃទៀត។ ដើម្បីជាប្រយោជន៍ដល់ការសិក្សា យើងនឹងលើកយកការវាស់វែងប្រភេទរូបិយវត្ថុ M3។ ប្រភេទរូបិយវត្ថុ M3 មានរួមបញ្ចូលទាំងក្រដាសប្រាក់ និងកាស (N&C) មានក្នុងដៃរបស់ធនាគារកណ្ដាល (NBPS) និងប្រាក់បញ្ញើរបស់ធនាគារកណ្ដាល (NBPS) ទាំងអស់របស់ធនាគារ។ យើងចង់បញ្ជាក់ពីមូលដ្ឋានទាំងនេះ ភាគច្រើនប្រាក់បញ្ញើធនាគារ គឺមានរយៈពេលខ្លី។ ថាតើគេគណនាការកាន់កាប់បរិមាណប្រាក់សរុបរបស់ធនាគារកណ្ដាល (NBPS) បានយ៉ាងដូចម្ដេច? សូមមើលសមតុល្យរបស់ធនាគារកណ្ដាល និងធនាគារបានបង្ហាញតារាងតុល្យការពី ១ ដល់ ២។ អ្នកសិក្សានឹងឃើញថាក្រដាសប្រាក់ និងកាស (N&C) បានកាន់កាប់ដោយធនាគារកណ្ដាល (NBPS) អាចទទួលបានពីតារាងតុល្យការទាំងពីរដូចខាងក្រោមនេះ៖

ដំណោះស្រាយ នៅក្នុងតារាងតុល្យការរបស់ធនាគារកណ្ដាល។ ដូច្នេះ ស្តុកនៃរូបិយវត្ថុ N&C កាន់កាប់ដោយធនាគារ NBPS៖

N&C of NBPS = USD 1 000 billion – USD 100 billion

= USD 900 billion.

| BALANCE SHEET 1: CENTRAL BANK ( USD BILLIONS ) | | | |
|---|---|---|---|
| **Assets** | | **Liabilities** | |
| D. foreign assets | 1,000 | A. Notes and coins | 1,000 |
| | | B. Deposits | |
| E. Loans to government | 1,100 | 1. Government | 900 |
| | | 2. Banks' reserve accounts (TR) | 500 |
| F. Loans to banks (borrowed reserves - BR) @ KIR | 400 | C. Foreign loans | 100 |
| **Total** | **2,500** | **Total** | **2,500** |

| BALANCE SHEET 2: BANKS ( USD BILLIONS ) | | | |
|---|---|---|---|
| **Assets** | | **Liabilities** | |
| D. Notes and coins | 100 | A. Deposits of NBPS | 5,000 |
| E. Reserves with CB ( TR ) | 500 | | |
| F. Loans to government | 1,000 | B. Loans from CB ( BR ) | 400 |
| G. Loans to NBPS | 3,800 | | |
| **Total** | **5,400** | **Total** | **5,400** |

អ្នកអាចកត់សម្គាល់ បានធនាគារមានគណនីបំណុលពីរប្រភេទ ( សូមមើលតារាងតុល្យការ ២ )។ ប្រភេទគណនី A ( ប្រាក់បញ្ញើរបស់ធនាគារ NBPS ) គឺជារូបិយវត្ថុ ។ ដូច្នេះប្រភេទរូបិយវត្ថុ M3 ត្រូវបានបង្កើតឡើង ( សូមមើលរូបភាពទី១ ) តាមរយៈ៖

M3 = N&C + BD of the domestic NBPS

= UDS 1 000 billion – UDS 100 billion + UDS 5 000 billion

= UDS 5 900 billion

ធនាគារកណ្តាល គណនាប្រភេទរូបិយវត្ថុ M3 ក៏ដូចជាសមាសធាតុចូលចូលរួម (ភ្នាក់ងារ) ដោយរួមបញ្ចូលក្នុងតារាងតុល្យការបង្រួមរួមគ្នា (consolidated balance sheet) រវាងធនាគារ និងធនាគារកណ្តាល។ នៅតាមបណ្តាប្រទេសភាគច្រើនក៏មាន "ស្ថាប័នរូបិយវត្ថុ" ផ្សេងទៀត (ដូចជាធនាគារជនបទ( rural banks )ធនាគារសង្គហៈ( mutual banks) ធនាគារអចលនទ្រព្យ និងធនាគារដទៃទៀត)៖ ត្រូវបានបង្រួមរួមគ្នាជាមួយតារាងតុល្យការរបស់ធនាគារកណ្តាល និងធនាគារ។

គំនូសតាងទី ៧ បង្ហាញពី៖ តើអ្វីទៅជារូបិយវត្ថុ M3 ? ( What is money M3 ? )




ក្នុងតារាងតុល្យការបង្រួមរួមគ្នា បានបង្ហាញក្នុងតារាងតុល្យការ៣ ដែលហៅថា៖ តារាងតុល្យការបង្រួមរួមគ្នានៃ MBS ( Money bank system )។

| BALANCE SHEET 3: MBS ( USD BILLIONS ) | | | |
|---|---|---|---|
| **Assets** | | **Liabilities** | |
| D. foreign assets | 1,000 | A. Notes and coins of NBPS | 900 |
| | | B. Deposits | |
| E. Loans to government | 2,100 | 1. Government | 900 |
| | | 2. NBPS | 5,000 |
| F. Loans to NBPS | 3,800 | C. Foreign loans | 100 |
| **Total** | **6,900** | **Total** | **6,900** |

តើតារាងតុល្យការបង្រួមរួមគ្នាមានន័យយ៉ាងដូចម្តេច ? តារាងតុល្យការបង្រួមរួមគ្នា គឺវាបានរួមបញ្ចូលនូវប្រតិបត្តិការអន្តរធនាគារទាំងអស់ ដើម្បីបង្កភាពងាយស្រួលយល់ដឹងពីប្រភេទគណនីដែលពាក់ព័ន្ធទាំងនេះ ត្រូវបានគូសពន្លិចពណ៌ក្រហមនៅក្នុងតារាងតុល្យការពី ៤ ដល់ ៥។

<u>កំណត់ចំណាំ៖</u>

- ប្រាក់កម្ចីធនាគារកណ្តាលឱ្យដល់ធនាគារមានទឹកប្រាក់ ៤០០ពាន់លានដុល្លារ នៅក្នុងតារាងតុល្យការ ៤ ត្រូវបានទូទាត់សងបំណុលដោយធៀបជាមួយនឹងប្រាក់កម្ចីធនាគារកណ្តាលមានទឹកប្រាក់ ៤០ពាន់លានដុល្លារ នៅក្នុងតារាងតុល្យការ ៥។
- ប្រាក់បម្រុងរបស់ធនាគារត្រូវបានកាត់ចេញ ៥០០ពាន់លានដុល្លារ បានបង្ហាញនៅក្នុងតារាងតុល្យការទាំង២ )។

- ប្រភេទរូបិយវត្ថុ (N&C)៖ចំនួនទឹកប្រាក់ (១០០០ពាន់លានដុល្លារ) – (១០០ពាន់លានដុល្លារ) = (៩០០ពាន់លានដុល្លារ) (សូមមើលប្រភេទគណនី A នៅក្នុងតារាងតុល្យការបង្រួមរួមគ្នា)។

| BALANCE SHEET 4: CENTRAL BANK (USD BILLIONS) | | | |
|---|---|---|---|
| Assets | | Liabilities | |
| D. foreign assets | 1,000 | A. Notes and coins | 1,000 |
| | | B. Deposits | |
| E. Loans to government | 1,100 | 1. Government | 900 |
| | | 2. Banks' reserve | 500 |
| F. Loans to banks (borrowed | 400 | accounts (TR) | |
| reserves - BR) @ KIR | | C. Foreign loans | 100 |
| Total | 2,500 | Total | 2,500 |

| BALANCE SHEET 5: BANKS (USD BILLIONS) | | | |
|---|---|---|---|
| Assets | | Liabilities | |
| C. Notes and coins | 100 | A. Deposits of NBPS | 5,000 |
| D. Reserves with CB (TR) | 500 | | |
| E. Loans to government | 1,000 | B. Loans from CB (BR) | 400 |
| F. Loans to NBPS | 3,800 | | |
| Total | 5,400 | Total | 5,400 |

តារាងតុល្យការបង្រួមរួមគ្នានៃ (MBS) នៅក្នុង (តារាងតុល្យការ ៣)នៃស្តុករូបិយវត្ថុ ត្រូវបានគេបង្ហាញយ៉ាងច្បាស់ (ប្រភេទគណនីត្រូវបានគូសពន្លិចពណ៌ក្រហមឱ្យឃើញច្បាស់) គឺជាប្រភេទគណនី (A) ជាក្រដាសប្រាក់ និងកាសរបស់ (NBPS) និងប្រភេទគណនី (B) ដែលជាប្រាក់បញ្ញើនៃអនុគណនី (B2) របស់ (NBPS) ត្រូវបានគណនា៖

M3 = A + B2

= UDS 900 billion + UDS 5 000 billion

= UDS 5 900 billion.

ក្នុងចំណោមសមាសធាតុរូបិយវត្ថុទាំងពីរប្រភេទ យើងដឹងថាក្រដាសប្រាក់ និងកាស (N&C) របស់ធនាគារកណ្តាល គឺប្រភេទរូបិយវត្ថុតែនាម។ នៅតាមបណ្តាប្រទេសភាគច្រើនសមាមាត្រនៃក្រដាសប្រាក់ និងកាស (N&C) ក្នុងប្រភេទរូបិយវត្ថុ (M3) គឺមានកម្រិតទាបត្រឹមតែ ២% តែប៉ុណ្ណោះ។ យើងដឹងថាធនាគារកណ្តាល គឺជាអ្នកបោះផ្សាយក្រដាស និងកាសផ្តាច់មុខ (ភាគច្រើន) ហើយមិនបាន

ប្រើប្រាស់ក្រដាសប្រាក់ និងកាស (N&C) ដើម្បីបង្កើតនូវរូបិយវត្ថុថ្មីនោះទេ។ ធនាគារកណ្ដាល គ្រាន់តែប្រព្រឹត្តិកម្មទៅនឹងតម្រូវការក្រដាសប្រាក់ និងកាស (N&C) ដែលជាប្រាក់បញ្ញើធនាគារត្រូវបានប្រើសម្រាប់ការទូទាត់។ យើងបានដឹងថា រូបិយវត្ថុថ្មីត្រូវបានបង្កើតឡើងដោយការផ្ដល់ប្រាក់កម្ចីរបស់ធនាគារ (ក្នុងស្រុក និងបរទេស)។ ប្រភពនៃការបង្កើតរូបិយវត្ថុទាំងនេះក៏ត្រូវបានមើលឃើញផងដែរក្នុងតារាងតុល្យការបង្រួមរួមគ្នា (តារាងតុល្យការ ៣)។

## ៥.២- អត្តសញ្ញាណរូបិយវត្ថុ៖ ការបង្កើតរូបិយវត្ថុ )Money identity: money creation)

### ៥.២.១- សេចក្ដីផ្ដើម (Introduction)

ចម្លងការតារាងតុល្យការបង្រួមរួមគ្នាទាំងនេះ ដើម្បីបង្កភាពងាយស្រួលយោងរបាយការណ៍ (សូមមើលតារាងតុល្យការ ៦)។

| BALANCE SHEET 6: MBS (USD BILLIONS) | | | |
|---|---|---|---|
| Assets | | Liabilities | |
| D. foreign assets | 1,000 | A. Notes and coins of NBPS | 900 |
| | | B. Deposits | |
| E. Loans to government | 2,100 | 1. Government | 900 |
| | | 2. NBPS | 5,000 |
| F. Loans to NBPS | 3,800 | C. Foreign loans | 100 |
| Total | 6,900 | Total | 6,900 |

បានបង្ហាញយ៉ាងច្បាស់នៃតារាងតុល្យការដែលមានប្រភេទគណនី A + B2 ត្រូវតែស្មើនឹងរាល់គណនីទ្រព្យសកម្មទាំងនេះ ដកចេញប្រភេទគណនីបំណុលដែលនៅសេសសល់ទាំងនេះ។

ដូច្នេះ៖

$$M3 = A + B2 \quad = (D + E + F) - (B1 + C).$$

បានបង្ហាញថា ការបង្រួមរួមគ្នានូវប្រភេទគណនីទ្រព្យសកម្ម និងគណនីបំណុលដែលពាក់ព័ន្ធនឹងធាតុទាំងនេះ ដូចជា៖

- Foreign assets and foreign loans (D – C).
- Loans to government and government deposits (E – B1).

ដូច្នេះ៖

$$M3 = A + B2 \quad = (D - C) + (E - B1) + F.$$

គណនាបរិមាណរូបិយវត្ថុ(M3) នៅក្នុងតារាងតុល្យការ៦៖

$$M3 = A + B2 \quad = (D - C) + (E - B1) + F$$

M3 = 900 + 5 000 = ( 1 000 – 100 ) + ( 2 100 – 900 ) + 3 800

= 5 900

= 900 +1 200 + 3 800

= 5 900.

ខ្លឹមសារ៖

Money stock ( M3 ) = its "counterparts" = Net foreign assets

+ net loans to government

+ loans to NBPS.

នេះជាអត្តសញ្ញាណរូបិយវត្ថុ៖ ប្រភេទរូបិយវត្ថុ M3 គឺជាប្រភេទរូបិយវត្ថុដែលមាន "សមាសធាតុរូបិយវត្ថុ" របស់ស្តុករូបិយវត្ថុ( ចំនួនទឹកប្រាក់បានចរាចរ ) ដែលរួមមានទ្រព្យសកម្មបរទេសសុទ្ធ( NFA ) បូកប្រាក់កម្ចីសុទ្ធរបស់រដ្ឋាភិបាល ( NLG ) បូកប្រាក់កម្ចីរបស់ធនាគារ ( NBPS )។

ភស្តុតាងបានបង្ហាញថា បម្រែបម្រួលណាមួយនៃស្តុករូបិយវត្ថុ ត្រូវតែស្មើនឹងបម្រែបម្រួលទ្រព្យសកម្មបរទេសសុទ្ធ( NFA ) បូកបម្រែបម្រួលប្រាក់កម្ចីសុទ្ធរបស់រដ្ឋាភិបាល( NLG ) បូកនឹងបម្រែបម្រួលប្រាក់កម្ចីរបស់ធនាគារ ( LNBPS )គឺ៖

$$\Delta M3 = \Delta NFA + \Delta NLG + \Delta LNBPS.$$

នេះជាអត្តសញ្ញាណរូបិយវត្ថុ៖ វាផ្តល់ការវិភាគពីប្រភពការប្រែប្រួលតារាងតុល្យការរបស់ ( BSSoC ) ក្នុងនាមប្រភេទរូបិយវត្ថុ M3។ នេះជាប្រភពជាក់ស្តែង គឺជាប្រតិបត្តិការដែលស្ថិតក្រោមការគ្រប់គ្រងរបស់ ( BSSoC ) គឺជា៖

- ទ្រព្យសកម្មបរទេសសុទ្ធ ( NFA )៖ ធនាគារ និងធនាគារកណ្តាល ដែលទាក់ទិនក្នុងទីផ្សារប្តូរប្រាក់បរទេស។ ប្រសិនបើស្ថាប័នទាំងនេះមិនធ្វើអ្វីទាំងអស់ក្នុងទីផ្សារ( Forex ) ទីផ្សារនោះនឹងសម្អាតអត្រាប្តូរប្រាក់ជាក់លាក់មួយ។ ប្រសិនបើ ពួកគេធ្វើការផ្លាស់ប្តូរសមីការតម្រូវការការផ្គត់ផ្គង់នៃទីផ្សារ( Forex ) ហើយបង្កើតរូបិយវត្ថុ បំផ្លាញរូបិយវត្ថុ ហើយទីផ្សារនោះនឹងសម្អាតក្នុងអត្រាប្តូរប្រាក់ខុសគ្នា។
- ប្រាក់កម្ចីសុទ្ធឱ្យដល់រដ្ឋាភិបាល ( NLG )៖
  - ✓ ធនាគារ និងធនាគារកណ្តាលទិញ ឬលក់មូលប័ត្ររបស់រដ្ឋាភិបាល
  - ✓ ចលនានៃការដាក់ប្រាក់បញ្ញើ NBPS នៅធនាគាររដ្ឋាភិបាល (ដែលយើងសន្មតថាធនាគារនៅធនាគារកណ្តាលតែប៉ុណ្ណោះ) ឧទាហរណ៍៖ នៅពេលបង់ពន្ធ និងចលនានៃប្រាក់បញ្ញើរបស់រដ្ឋាភិបាលទៅឱ្យ( NBPS ) នៅពេលដែលរដ្ឋាភិបាលចំណាយប្រាក់យ៉ាងច្រើន។
- ប្រាក់កម្ចីឱ្យដល់ ( LNBPS )៖ តម្រូវការកម្ចីពី NBPS ដែលធនាគារពេញចិត្ត

នៅបណ្តាប្រទេសភាគច្រើនបានចាត់ទុកការបង្កើតរូបិយវត្ថុប្រភេទនេះ មានសារសំខាន់ជាងអ្វីៗទាំងអស់។ ចំណែកប្រទេសកំពុងអភិវឌ្ឍន៍ បានលើកឡើងពីតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតរូបិយវត្ថុនេះ។ ដូចមានក្នុងក្រាហ្វិកខាងក្រោមនេះ បង្ហាញពីអត្រាកំណើនប្រចាំឆ្នាំពីមួយឆ្នាំទៅមួយឆ្នាំសម្រាប់

ប្រភេទរូបិយវត្ថុ M3 ជាមួយនឹងប្រាក់បញ្ញើធនាគារ (LNBPS) ក្នុងអំឡុងពេល ៤០ឆ្នាំ សម្រាប់ការបង្កើតប្រភេទរូបិយវត្ថុ (M3) របស់ប្រទេសពួកគេ។ ហើយវាកាន់តែច្បាស់ណាស់ថាការបង្កើតរូបិយវត្ថុមានសារសំខាន់ជាងអ្វីៗទាំងអស់សម្រាប់ BSSoC នៃប្រភេទរូបិយវត្ថុ M3 គឺជាបម្រែបម្រួលរបស់ប្រាក់បញ្ញើរបស់ធនាគារ (LNBPS)។

ក្រាហ្វិកទី៥ បង្ហាញពី៖ M3 & LNBPS




### ៥.២.២- ឧទាហរណ៍៖ ប្រាក់កម្ចីពីធនាគារ (Loan from bank)

មានប្រយោជន៍ក្នុងការផ្តល់ ឧទាហរណ៍មួយចំនួនពីប្រភពនៃការប្រែប្រួលប្រភេទរូបិយវត្ថុ M3។ គួរកត់សម្គាល់ថា នៅទីនេះយើងមិនបង្ហាញពីផលប៉ះពាល់នៃការប្រែប្រួលលើតម្រូវការទុនបម្រុងកាតព្វកិច្ចរបស់ធនាគារទេ។ករណីនេះ យើងមិនចង់បង្វែរការចាប់អារម្មណ៍អំពីគោលការណ៍បង្កើតរូបិយវត្ថុទេ។ ប្រសិទ្ធភាពនៃការប្រែប្រួលប្រាក់បញ្ញើលើតម្រូវការទុនបម្រុងកាតព្វកិច្ច ត្រូវបានសិក្សាណែនាំនៅដំណាក់កាលក្រោយទៀត។ អ្នកនៅចងចាំបានថា នៅពេលដែលក្រុមហ៊ុន(A) លក់ទំនិញទៅក្រុមហ៊ុន (B) ហើយក្រុមហ៊ុន (B) ទទួលបានការទូទាត់ពីប្រាក់កម្ចីធនាគារ (A) ហើយប្រើប្រាស់ប្រាក់កម្ចីធនាគារ (A) សម្រាប់ទិញទំនិញបម្រែបម្រួលតារាងតុល្យការ ដែលពាក់ព័ន្ធត្រូវបានបង្ហាញក្នុងតារាងតុល្យការ ៧-៩ មានចំនួនទឹកប្រាក់ = USD ១០០ លាន)

| BALANCE SHEET 7: COMPANY A (USD MILLIONS) | |
|---|---|
| Assets | Liabilities |

| | | | |
|---|---|---|---|
| Goods<br>Deposits at Bank A | -100<br>+100 | | |
| Total | 0 | Total | 0 |

| BALANCE SHEET 8: COMPANY B ( USD MILLIONS ) | | | |
|---|---|---|---|
| Assets | | Liabilities | |
| Goods | +100 | Loan from Bank A | +100 |
| Total | +100 | Total | +100 |

| BALANCE SHEET 9: BANK A ( USD MILLIONS ) | | | |
|---|---|---|---|
| Assets | | Liabilities | |
| Loan to Company A | +100 | Deposits of Company A | +100 |
| Total | +100 | Total | +100 |

| BALANCE SHEET 10: MBS ( USD MILLIONS ) | | | |
|---|---|---|---|
| Assets | | Liabilities | |
| D. foreign assets | | A. Notes and coins of NBPS | |
| | | B. Deposits | |
| E. Loans to government | | 1. Government | |
| | | 2. NBPS | +100 |
| F. Loans to NBPS | +100 | C. Foreign loans | |
| Total | +100 | Total | +100 |

យើងបានឃើញថា តារាងតុល្យការនៃ (MBS) (សូមមើលតារាងតុល្យការ ១០) ប្រតិបត្តិការទាំងនេះ ត្រូវបានបង្ហាញកាន់តែច្បាស់លាស់។ សម្រាប់ (ការរៀបចំតារាងតុល្យការ) ប្រភេទរូបិយវត្ថុ M3 បានកើនឡើងចំនួនទឹកប្រាក់ ១០០លានដុល្លារ នៅផ្នែកបំណុលរបស់គណនី (B) ដែលបានកត់ត្រាក្នុងអនុគណនី (B2) របស់ធនាគារ NBPS គឺជាប្រភេទរូបិយវត្ថុ M3។ ប៉ុន្តែ ប្រភពជាក់ស្តែង គឺជាតម្រូវការប្រាក់កម្ចីរបស់ធនាគារ (NBPS) នៅផ្នែកទ្រព្យសកម្មនៃតារាងតុល្យការរបស់ (MBS) ប៉ុណ្ណោះ។

### ៥.២.៣- ឧទាហរណ៍៖ ការនាំចេញ (Exports)

ឧទាហរណ៍៖ សម្រាប់អ្នកនាំចេញក្នុងស្រុក ដោយអ្នកនាំចេញ (LC exporter) ប្រើគណនី LC Bank ដែលជាធនាគារជាសមាជិករបស់ NBPS។ បាននាំចេញនូវទំនិញមានចំនួនទឹកប្រាក់ ១០០ លានដុល្លារ ទៅកាន់សហរដ្ឋអាម៉េរិកក្នុងនាមជាអ្នកនាំចូល(US importer)។ ក្នុងនោះមានអត្រាប្តូរប្រាក់គឺ USD/10.0 (សូមមើលតារាងតុល្យការ ១១-១៣)។

| BALANCE SHEET 11: LC EXPORTER (NBPS) (USD MILLIONS) | | | |
|---|---|---|---|
| Assets | | Liabilities | |
| Goods | -100 | | |
| Deposits at Bank A | +100 | | |
| Total | 0 | Total | 0 |

| BALANCE SHEET 12: US IMPORTER (USD MILLIONS) | | | |
|---|---|---|---|
| Assets | | Liabilities | |
| Goods | +10 | | |
| US Bank deposits | -10 | | |
| Total | 0 | Total | 0 |

| BALANCE SHEET 13: US BANK (USD MILLIONS) | | | |
|---|---|---|---|
| Assets | | Liabilities | |
| | | Deposits of US Importer | -10 |
| | | Deposits of LC Exporter | +10 |
| Total | 0 | Total | 0 |

ពុំមានការប្រែប្រួលស្តុករូបិយវត្ថុ (ឧទាហរណ៍មិនមានការប្រែប្រួល (LC Bank) ក្នុងស្រុកក្នុងតារាងតុល្យការរបស់ធនាគារនោះទេ។ ឥឡូវ LC Exporter លក់ទំនិញមានទឹកប្រាក់ ១០០លានដុល្លារ អត្រាប្តូរប្រាក់ (USD) ឱ្យទៅ LC Bank (សូមមើលតារាងតុល្យការ ១៤-១៦)។

| BALANCE SHEET 14: LC EXPORTER (NBPS) (USD MILLIONS) | | | |
|---|---|---|---|
| Assets | | Liabilities | |
| Deposits at US Bank | -100 | | |
| Deposits at LC Bank | +100 | | |
| Total | 0 | Total | 0 |

| BALANCE SHEET 15: LC BANK (LCC MILLIONS) | | | |
|---|---|---|---|
| **Assets** | | **Liabilities** | |
| Deposits at US Bank | +100 | Deposits of LC Exporter | +100 |
| **Total** | **+100** | **Total** | **+100** |

| BALANCE SHEET 16: US BANK (USD MILLIONS) | | | |
|---|---|---|---|
| **Assets** | | **Liabilities** | |
| | | Deposits of LC Exporter | -10 |
| | | Deposits of LC Bank | +10 |
| **Total** | **0** | **Total** | **0** |

វាច្បាស់ណាស់ថាតារាងតុល្យការរបស់ LC Bank (ឧ. ធនាគារក្នុងស្រុក) បានប្រែប្រួល LC Bank បានទទួលប្រាក់បញ្ញើពីបរទេសចំនួនទឹកប្រាក់ ១០លានដុល្លារ (= forex) និងបង់ឱ្យអ្នកនាំចេញជាឥណទានដោយបញ្ចូលទៅគណនីរបស់គាត់។ ចំនួនទឹកប្រាក់ទាំងនេះ គឺបានកើនឡើងប្រាក់បញ្ញើក្នុងគណនីធនាគារក្នុងស្រុករបស់ NBPS = បានកើនM3។ និយាយពីតារាងតុល្យការរបស់គណនីធនាគារ(MBS) យើងឃើញមានការប្រែប្រួលដូចដែលបានចង្អុលបង្ហាញនៅក្នុងតារាងតុល្យការ១៧។ ប្រភេទរូបិយវត្ថុ M3 បានកើនឡើងចំនួនទឹកប្រាក់ ១០០លានដុល្លារ និង BSSoC បានកើនឡើងនៅក្នុងគណនីធនាគារ NFA (ការកើនឡើងប្រាក់បញ្ញើបរទេស)។ ធាតុពិត គឺជាប្រតិបត្តិការដែលជាការសម្រេចចិត្តលើផលប័ត្រ សម្រាប់ការទិញនៅ (Forex) ដោយ LC Bank នៅក្នុងស្រុក ។

អ្នកនាំចេញទំនិញ(LC exporter)បានដោះដូរនៅអត្រាប្តូរប្រាក់បរទេស(Forex) នៅក្នុងទីផ្សារប្តូរប្រាក់(Forex market)។ ទីផ្សារនេះ ត្រូវបានជម្រះនូវអត្រាប្តូរប្រាក់ឱ្យប្រសើរជាងមុន ដែលអត្រាប្តូរប្រាក់ USD/9.99 ជាងពេលដែលអត្រាប្តូរប្រាក់បរទេស Forex ត្រូវបានដកចេញដោយ (LC Bank) ពីឥទ្ធិពលនៃការផ្គត់ផ្គង់តម្រូវការពាណិជ្ជកម្មនៅក្នុងទីផ្សារ/ប្តូរប្រាក់បរទេស (Forex market)។

| BALANCE SHEET 17: MBS (LCC MILLIONS) | | | |
|---|---|---|---|
| **Assets** | | **Liabilities** | |
| D. foreign assets | +100 | A. Notes and coins of NBPS | |
| | | B. Deposits | |
| E. Loans to government | | 1. Government | +100 |

| | | | |
|---|---|---|---|
| F. Loans to NBPS | | 2. NBPS<br>C. Foreign loans | |
| Total | +100 | Total | +100 |

### ៥.២.៤- ឧទាហរណ៍៖ មូលប័ត្របំណុលរដ្ឋាភិបាល (government issues bonds)

ឧទាហរណ៍៖ រដ្ឋាភិបាលបានបោះផ្សាយសញ្ញាប័ណ្ណ (bonds) មានចំនួនទឹកប្រាក់ ១ ០០០ លានដុល្លារ។ ហើយពួកគេបានទិញមូលនិធិចូលនិវត្តន៍មួយចំនួនពី (= ជាសមាជិករបស់ NBPS) (សូមមើលតារាងតុល្យការលេខ ១៨-២១)។

| BALANCE SHEET 18: GOVERNMENT (USD MILLIONS) | | | |
|---|---|---|---|
| Assets | | Liabilities | |
| Deposits at CB | +1,000 | Bonds | +1,000 |
| Total | +1,000 | Total | +1,000 |

| BALANCE SHEET 19: CENTRAL BANK (USD MILLIONS) | | | |
|---|---|---|---|
| Assets | | Liabilities | |
| Loans to banks @ KIR | +1,000 | Government deposits | +1,000 |
| Total | +1,000 | Total | +1,000 |

| BALANCE SHEET 20: RETIREMENT FUNDS (NBPS) (USD MILLIONS) | | | |
|---|---|---|---|
| Assets | | Liabilities | |
| Bonds | +1,000 | | |
| Deposits at banks | -1,000 | | |
| Total | 0 | Total | 0 |

| BALANCE SHEET 21: BANKS (USD MILLIONS) | | | |
|---|---|---|---|
| Assets | | Liabilities | |
| | | Deposits of NBPS | -1,000 |
| | | Loans from CB @ KIR | +1,000 |
| Total | 0 | Total | 0 |

សកម្មភាពរបស់រដ្ឋាភិបាលបានធ្វើចម្រោះសាច់ប្រាក់ងាយស្រួលពីធនាគារ ហើយពួកគេពុំមានជម្រើសអ្វីក្រៅពីត្រូវការប្រាក់កម្ចីពីធនាគារកណ្តាល (យើងនឹងសិក្សានៅពេលបន្ទាប់)។ នៅពេលដែលតារាងតុល្យការរបស់ធនាគារ និងធនាគារកណ្តាលត្រូវបានបង្រួមរួមគ្នា( សូមមើលតារាងតុល្យការ ២២) យើងនឹងឃើញប្រភេទរូបិយវត្ថុ M3 បានថយចុះបរិមាណទឹកប្រាក់ USD ១០០ លាន ហើយគ្រឹះស្ថាន BSSoC បានធ្លាក់ចុះនៅក្នុងគ្រឹះស្ថាន NLG (ជាលទ្ធផលការកើនឡើងនៃប្រាក់បញ្ញើរបស់រដ្ឋាភិបាល)។ ជាតុពិត គឺជាការបោះផ្សាយសញ្ញាប័ណ្ណ( bond )។ នៅពេលដែលរដ្ឋាភិបាល មានតម្រូវការចំណាយរបស់រដ្ឋាភិបាល ក្នុងគោលបំណងបោះផ្សាយ ប័ណ្ណបំណុល ហើយស្ថានភាពនេះ នឹងត្រូវបានបង្កើតរូបិយវត្ថុជាថ្មីម្តងទៀត (ប្រភេទរូបិយវត្ថុ M3 នឹងកើនម្តងទៀត)។ វាមានសារសំខាន់ណាស់ដែលត្រូវយល់ ប្រសិនបើគ្រឹះស្ថានធនាគារ ត្រូវបានទិញសញ្ញាប័ណ្ណប្រភេទក្រដាសប្រាក់ M3 នោះដែរ ប្រភេទក្រដាសប្រាក់ M3 នឹងមានការកើនឡើង ដូចបានបង្ហាញនៅក្នុងតារាងតុល្យការលេខ ២២-២៤។

| BALANCE SHEET 22: MBS ( USD MILLIONS ) | | | |
|---|---|---|---|
| **Assets** | | **Liabilities** | |
| D. foreign assets | | A. Notes and coins of NBPS | |
| | | B. Deposits | |
| E. Loans to government | | 1. Government | +100 |
| | | 2. NBPS | -100 |
| F. Loans to NBPS | | C. Foreign loans | |
| **Total** | **0** | **Total** | **0** |

| BALANCE SHEET 23: BANKS ( USD MILLIONS ) | | | |
|---|---|---|---|
| **Assets** | | **Liabilities** | |
| Bonds | +1,000 | Deposits of NBS | +1,000 |
| **Total** | **+1,000** | **Total** | **+1,000** |

| BALANCE SHEET 24: MBS ( USD MILLIONS ) | | | |
|---|---|---|---|
| **Assets** | | **Liabilities** | |
| | | A. Notes and coins of NBPS | |
| D. foreign assets | | B. Deposits | |
| | | 1. Government | +1,000 |
| E. Loans to government | +1,000 | 2. NBPS | |

| | | | |
|---|---|---|---|
| (bonds)<br><br>F. Loans to NBPS | | C. Foreign loans | |
| Total | 0 | Total | 0 |

### ៥.២.៥- ឧទាហរណ៍៖ ក្រដាសប្រាក់របស់ធនាគារ (Example: bank notes)

សម្រាប់ឧទាហរណ៍ចុងក្រោយ៖ ធនាគារជាសមាជិករបស់ (NBPS) បានបញ្ចេញឱ្យប្រើនូវម៉ាស៊ីន (ATM) និងម៉ាស៊ីនដកក្រដាសប្រាក់ និងកាស មានទឹកប្រាក់ចំនួន ១០០លានដុល្លារ ជាមួយនឹងកាតឥណពន្ធរបស់ពួកគេ (ផ្នែកឥណពន្ធចរន្ត)(សូមមើលតារាងតុល្យការ ២៥ ដល់ ២៦)។ តារាងតុល្យការ ២៧ បង្ហាញពីទីតាំងគណនីរបស់ (MBS) ដែលដូចគ្នានឹងធនាគារ។ អ្នកនៅចាំបានថា M3 = N&C + BD ការកាន់កាប់របស់ក្រដាសប្រាក់ និងកាស (N&C) របស់ធនាគារកណ្តាល (NBPS) បានកើនឡើងចំនួនទឹកប្រាក់ ១០០លានដុល្លារ ហើយប្រាក់បញ្ញើរបស់ពួកគេបានថយចុះចំនួនដូចគ្នា។

ដូច្នេះស្តុករូបិយវត្ថុមិនបានផ្លាស់ប្តូរនោះទេមានតែសមាសភាពចូលរួមតែប៉ុណ្ណោះ។ សូមចងចាំថាប្រភេទគណនី (A) ក្នុងតារាងតុល្យការរបស់ (NBS) = គណនីបំណុលរបស់ (CB's N&C) ដកចេញនូវក្រដាសប្រាក់ និងកាស (N&C) ដែលកាន់កាប់ដោយធនាគារ។ នេះមិនមានការផ្លាស់ប្តូរនោះទេ ក្រោយមកទៀតត្រូវបានកាត់បន្ថយចំនួនទឹកប្រាក់ ១០០លានដុល្លារ ។

| BALANCE SHEET 25: BANKS (USD MILLIONS) | | | |
|---|---|---|---|
| Assets | | Liabilities | |
| | -100 | Deposits of NBS | -100 |
| Total | -100 | Total | -100 |

| BALANCE SHEET 26: NBPS (USD MILLIONS) | | | |
|---|---|---|---|
| Assets | | Liabilities | |
| N&C<br>Deposits at banks | +100<br>-100 | | |
| Total | 0 | Total | 0 |

| BALANCE SHEET 27: MBS (USD MILLIONS) | |
|---|---|
| Assets | Liabilities |

| | | | |
|---|---|---|---|
| D. foreign assets<br><br>E. Loans to government<br><br>F. Loans to NBPS | | A. Notes and coins of NBPS<br>B. Deposits<br>1. Government<br>2. NBPS<br>C. Foreign loans | +100<br><br><br>-100 |
| Total | 0 | Total | 0 |

### ៥.២.៦- ហាយនភាពរូបិយវត្ថុ (Money destruction)

នៅពេលគ្រឹះស្ថានធនាគារផ្តល់ប្រាក់កម្ចីជាថ្មីម្តងទៀត (ដល់រដ្ឋាភិបាល ឬ NBPS) ឬទិញពីទីផ្សារប្តូរប្រាក់បរទេស (forex) ដែលកត្តាទាំងនេះ គឺជាបង្កើតរូបិយវត្ថុឡើង។ ប្រភពធនធាននៃការបង្កើតរូបិយវត្ថុលើស គឺជាប្រាក់កម្ចីគ្រឹះស្ថានធនាគារក្នុងតារាងតុល្យការ និងតម្រូវការប្រាក់កម្ចីធនាគារក្នុងអត្ថន័យពិត។ ភាពជាក់ស្តែងស្តុកនៃរូបិយវត្ថុក៏អាចធ្លាក់ចុះផងដែរ ប៉ុន្តែ ករណីនេះកម្រកើតមានណាស់ដូច ដែលបានឃើញក្នុងរូបភាពទី២។ នៅតាមបណ្តាប្រទេសភាគច្រើនត្រូវបានអនុវត្តវាមិនមែនអត្រាកំណើនប្រភេទរូបិយវត្ថុ M3 ប្រចាំខែថយចុះនោះទេ។ ទោះយ៉ាងណាក៏ដោយ វាត្រូវបានខកចិត្ត បើសិនការធ្លាក់ចុះនូវស្តុករូបិយវត្ថុមិនត្រូវបានពិភាក្សា។ ឧទាហរណ៍៖ លោកស្រី A. នាងបានដកប្រាក់កម្ចីចំនួនទឹកប្រាក់ ៥០ ០០០ដុល្លារ ពីធនាគារនាពេលកន្លងមក ដើម្បីសងប្រាក់កម្ចីរបស់នាងនឹងសន្សំសមតុល្យទឹកប្រាក់ ៥០ ០០០ដុល្លារ លើគណនីធនាគាររបស់នាងតាមពេលវេលា ហើយសងធនាគារវិញនៅពេលកំណត់សងប្រាក់កម្ចី។

តារាងតុល្យការ ២៨-២៩ បង្ហាញពីប្រតិបត្តិការនេះ។

| BALANCE SHEET 28: MRS A (NBPS) (USD) | | | |
|---|---|---|---|
| Assets | | Liabilities | |
| Deposits at banks | -50,000 | Bank loan | -50,000 |
| Total | -50,000 | Total | -50,000 |

| BALANCE SHEET 29: BANK A (USD) | | | |
|---|---|---|---|
| Assets | | Liabilities | |
| Bank loans (NBPS) | -50,000 | Deposits of NBPS (M3) | -50,000 |
| Total | -50,000 | Total | -50,000 |

តារាងតុល្យការរបស់ (MBS) នឹងមានលក្ខណៈដូចគ្នានឹងធនាគារ (A) ដែរ (សូមមើលតារាងសមតុល្យ 30) ។

| BALANCE SHEET 30: MBS ( USD MILLIONS ) | | | |
|---|---|---|---|
| **Assets** | | **Liabilities** | |
| D. foreign assets | | A. Notes and coins of NBPS | |
| | | B. Deposits | |
| E. Loans to government | -50,000 | 1. Government | |
| | | 2. NBPS | -50,000 |
| F. Loans to NBPS | | C. Foreign loans | |
| Total | -50,000 | Total | -50,000 |

## ៥.២.៧- ប្រាក់បញ្ញើធនាគារ និងទុនបម្រុងកាតព្វកិច្ច

( Bank deposits and reserve requirement )

ដូចយើងបានឃើញថា តាមរយៈការបង្រួមរួមគ្នាតារាងតុល្យការរបស់ធនាគារ និងធនាគារកណ្តាល តម្រូវឱ្យឥណទេយ្យរបស់ក្រុមហ៊ុន cb2b IBM និងក្រុមហ៊ុន b2cb IBM ត្រូវបានគេដាក់រួមបញ្ចូលគ្នាយ៉ាងលម្អិត។ នេះបង្ហាញពីទិដ្ឋភាពនៃទីផ្សាររូបិយវត្ថុ និងគោលនយោបាយរូបិយវត្ថុ៖ ផលប៉ះពាល់នៃការប្រែប្រួលប្រាក់បញ្ញើធនាគារទៅលើទុនបម្រុងកាតព្វកិច្ចរបស់ធនាគារ (RR)។

អ្នកអាចរំលឹកឡើងវិញពីឧទាហរណ៍ទីមួយខាងលើ នៅពេលដែលក្រុមហ៊ុន (A) លក់ទំនិញទៅឱ្យក្រុមហ៊ុន (B) និងក្រុមហ៊ុន (B) ទទួលបានប្រាក់កម្ចីពីធនាគារ (A) ហើយប្រើប្រាក់កម្ចីនោះសម្រាប់ការទិញទំនិញនៅពេលនោះប្រាក់បញ្ញើធនាគារ (ប្រាក់ថ្មី) ត្រូវបានបង្កើតឡើង។ អ្វីដែលយើងមិនបានបង្ហាញ គឺឥទ្ធិពលទៅលើទុនបម្រុងកាតព្វកិច្ចរបស់ធននាគារ(RR)។

ឥឡូវយើង ត្រូវបន្ថែមតារាងតុល្យការរបស់ធនាគារកណ្តាល (សូមមើលតារាងតុល្យការ ៣១-៣៤) ( ប្រាក់កម្ចីធនាគារ = ១០០លានដុល្លារ និងអត្រាអនុបាត RR = ១០% ប្រាក់បញ្ញើធនាគារ)។

| BALANCE SHEET 31: COMPANY A ( USD MILLIONS ) | | | |
|---|---|---|---|
| **Assets** | | **Liabilities** | |
| Goods | -100 | | |
| Deposits at Bank A | +100 | | |
| Total | 0 | Total | 0 |

| BALANCE SHEET 32: COMPANY B ( USD MILLIONS ) | | | |
|---|---|---|---|
| **Assets** | | **Liabilities** | |
| Goods | +100 | Loans from Bank A | +100 |

| | | | |
|---|---|---|---|
| Total | +100 | Total | +100 |

| BALANCE SHEET 33: BANK A ( USD MILLIONS ) | | | |
|---|---|---|---|
| Assets | | Liabilities | |
| Loan to Company B<br>Reserves with CB ( TR )<br>( RR + 10 ) | +100<br>+10 | Deposits of Company A<br>Loan from CB @KIR | +100<br>+10 |
| Total | +110 | Total | +110 |

ឧទាហរណ៍នេះ មានទុនបម្រុងកាតព្វកិច្ចកើនឡើងមានទឹកប្រាក់ចំនួន ១០លានដុល្លារ (ការកើនឡើងប្រាក់បញ្ញើចំនួន ១០០លានដុល្លារ × ០.១០) ពីព្រោះធនាគារ (A) មិនអាចបង្កើតប្រាក់ធនាគារកណ្ដាលបានទេ។ ធនាគារកណ្ដាល នឹងធ្វើការផ្ដល់ប្រាក់បម្រុងធនាគារ(BR) ចំពោះប្រាក់ទុនបម្រុងសរុប (TR) របស់ធនាគារកើនឡើងមានទឹកប្រាក់ចំនួន ១០លានដុល្លារ (លទ្ធផលនៃ RR = +១០លានដុល្លារ)។

| BALANCE SHEET 34: CENTRAL BANK ( USD MILLIONS ) | | | |
|---|---|---|---|
| Assets | | Liabilities | |
| Loan to banks ( BR ) @ KIR | +10 | Bank reserves ( TR )<br>( RR + 10 ) | +10 |
| Total | +10 | Total | +10 |

យើងនឹងសិក្សានៅពេលបន្ទាប់ បម្រែបម្រួលទុនបម្រុងកាតព្វកិច្ច (RR) គឺគ្រាន់តែជាកត្តាមួយក្នុងចំណោមកត្តាជាច្រើន ដែលជះឥទ្ធិពលលើសាច់ប្រាក់ងាយស្រួលរបស់ធនាគារ ហើយការគ្រប់គ្រងសាច់ប្រាក់ងាយស្រួលរបស់ធនាគារ គឺជាធាតុផ្សំដ៏សំខាន់នៅក្នុងគោលនយោបាយរូបិយវត្ថុ។

## ៥.៣- បរិបទបទប្បញ្ញត្តិច្បាប់ ( Statutory environment )

នៅបណ្ដាប្រទេសជាច្រើន គោលនយោបាយរូបិយវត្ថុត្រូវបានគាំទ្រដោយបទប្បញ្ញត្តិច្បាប់ ដែលបញ្ជាក់ពីតួនាទីដ៏សំខាន់នៃគោលនយោបាយរូបិយវត្ថុ។ ឧទាហរណ៍៖ នៅសហរដ្ឋអាមេរិក ការទទួលខុសត្រូវក្នុងការកំណត់នូវគោលនយោបាយរូបិយវត្ថុដូចមានចែងនៅក្នុងច្បាប់នៃ (Federal reserve of Act of 1913)។[២៩] ធនាគារចក្រភពអង់គ្លេស (Bank of England Act of 1998) បានផ្ដល់ជាផ្លូវ

[២៩] European Centarl Bank Bank of England

ការនូវការទទួលខុសត្រូវលើប្រតិបត្តិកាកំណត់គោលនយោបាយរូបិយវត្ថុរបស់ធនាគារអង់គ្លេស។[៣០] ចំពោះអាណត្តិសម្រាប់ធនាគារកណ្តាលអឺរ៉ុប ដើម្បីអនុវត្តនូវគោលនយោបាយរូបិយវត្ថុ ដូចមានចែងក្នុងមាត្រា ១០៥(១)[៣១] នៃសន្ធិសញ្ញាបង្កើតសហគមអឺរ៉ុប។ រីឯនៅអាហ្វ្រិកខាងត្បូង ការទទួលខុសត្រូវក្នុងការកំណត់គោលនយោបាយរូបិយវត្ថុ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋអាហ្វ្រិកខាងត្បូងវិសោធនកម្មច្បាប់លើកទី៣ (Act 26 of 1996) និងច្បាប់ធនាគារសហព័ន្ធអាហ្វ្រិកខាងត្បូង (Act 90 of 1989)។

## ៥.៤- កម្មវត្ថុនៃគោលនយោបាយរូបិយវត្ថុ (Objectives of monetary policy)

កម្មវត្ថុនៃគោលនយោបាយរូបិយវត្ថុ គឺរក្សាស្ថិរភាពថ្លៃ (stable price) ដើម្បីចៀសវាងការអូសបន្លាយនៃអតិផរណា ឬបរិត្តផរណា។ ស្ថិរភាពថ្លៃ គឺរួមចំណែកដល់ការសម្រេចបាននូវកំណើនសកម្មភាពសេដ្ឋកិច្ច និងការងារពេញលេញតាមរយៈការកែលម្អតម្លាភាពនៃយន្តការថ្លៃ។ ស្ថិរភាពកម្រិតថ្លៃអាចធ្វើឱ្យអ្នកចូលរួមក្នុងទីផ្សារឆាប់សម្គាល់បានអំពីការប្រែប្រួលថ្លៃទំនិញ និងសេវាកម្មផ្សេងៗ និងងាយស្រួលក្នុងការអនុម័តចំពោះការចំណាយប្រើប្រាស់ និងការវិនិយោគ។ ឈរលើមូលដ្ឋានស្ថិរភាពថ្លៃ ធនាគារ អាចត្រូវបានវិភាជសេដ្ឋកិច្ចប្រកបដោយប្រសិទ្ធភាពខ្ពស់សម្រាប់ការកាត់បន្ថយនូវបុព្វលាភនៃហានិភ័យអតិផរណា (inflation risk) សម្រាប់អត្រាការប្រាក់មានតែនាម ដែលធ្វើឱ្យអត្រាការប្រាក់ពិតថយចុះ និងអាចបង្កើតការលើកទឹកចិត្តដល់ការវិនិយោគ។ ម្យ៉ាងវិញទៀត ដើម្បីចៀសវាងសកម្មភាពដែលមិនគាំទ្រផលិតភាព ក្នុងការគាំពារចំពោះឥទ្ធិពលអវិជ្ជមាននៃអតិផរណា និងបរិត្តផរណា។ មួយវិញទៀត កម្មវត្ថុនៃគោលនយោបាយរូបិយវត្ថុជួយបង្កាផលប៉ះពាល់ដល់ការបែងចែកចំណូល និងទ្រព្យសម្បត្តិដែលបណ្តាលមកពីអតិផរណា ឬបរិត្តផរណាមិនរំពឹងទុក។

ដូច្នេះ កម្មវត្ថុនៃគោលនយោបាយរូបិយវត្ថុរួមបញ្ចូលទាំងការរៀបចំ និងការអនុវត្តនូវគោលនយោបាយរូបិយវត្ថុ ដោយធនាគារកណ្តាលក្នុងទម្រង់ប្រតិបត្តិការទីផ្សារបើកចំហ ដើម្បីបង្ហាញពីសារសំខាន់នៃអត្រាការប្រាក់ ដែលមានប្រសិទ្ធិភាពដឹកម្រក្នុងគោលដៅណែនាំដល់គ្រឹះស្ថានផ្តល់នូវប្រាក់កម្ចីទៅនឹងភាពបត់បែនក្នុងការទ្រទ្រង់សកម្មភាពសេដ្ឋកិច្ច ដែលមានភាពយឺតទាំងនេះត្រូវតែមានរៀបចំទុកជាមុន។ ការសម្រេចបានកម្រិតអតិផរណាទាប និងកម្រិតទិន្នផលសរុបសេដ្ឋកិច្ចខ្ពស់ និងមាននិរន្តរភាព។

ក្រុមប្រឹក្សាភិបាលនៃធនាគារសហព័ន្ធ បានកំណត់គោលនយោបាយរូបិយវត្ថុដូចខាងក្រោម៖[៣២]

> *ពាក្យថា "គោលនយោបាយរូបិយវត្ថុ" សំដៅទៅលើសកម្មភាពដែលធ្វើឡើងដោយធនាគារសហព័ន្ធ ដូចជាធនាគារកណ្តាលដើម្បីជះឥទ្ធិពលដល់លទ្ធភាព និងថ្លៃដើមនៃរូបិយវត្ថុ និង ឥណទានដើម្បីជួយលើកកម្ពស់គោលដៅសេដ្ឋកិច្ចជាតិ"។*

---

[៣០] Federal Reserve board

[៣១] Bank of England

[៣២] *Bank of Canada*

ធនាគារកណ្តាលនៅតាមបណ្តាប្រទេសភាគច្រើន បានកំណត់នូវគោលនយោបាយរូបិយវត្ថុទាក់ទងនឹងគោលបំណងសេដ្ឋកិច្ចរបស់ខ្លួន។

ធនាគារកណ្តាលនៃប្រទេសអង់គ្លេស៖[៣៣]

*"គោលបំណងគោលនយោបាយរូបិយវត្ថុ គឺស្ថិរភាពថ្លៃ ដើម្បីរក្សាតម្លៃរូបិយវត្ថុ ឬដាក់មធ្យោបាយផ្សេងទៀត ដើម្បីទប់ស្កាត់អតិផរណា ឬការកើនឡើងជាទូទៅនៃតម្លៃទំនិញ និងសេវាកម្ម។ ភាពមិនប្រាកដប្រជាអំពីអតិផរណា ដូច្នេះអំពីកម្រិតថ្លៃនាពេលអនាគតកំពុងធ្វើឱ្យខូចខាតដល់ដំណើរការត្រឹមត្រូវនៃសេដ្ឋកិច្ច។ ជាមួយនឹងកម្រិតថ្លៃទូទៅ ដែលមានសញ្ញាស្ថិរភាពថ្លៃនីមួយៗ អាចត្រូវបានសិក្សាឱ្យកាន់តែច្បាស់ និងការសម្រេចចិត្តសមហេតុផលថាតើត្រូវសន្សំ ឬខ្ចីប្រាក់ តើត្រូវវិនិយោគប៉ុន្មាន និងប្រើប្រាស់ហើយត្រូវផលិតអ្វីនឹងពេលណា? តាមវិធីនេះស្ថិរភាពថ្លៃអាចជួយជំរុញកំណើនសេដ្ឋកិច្ចរយៈពេលវែងប្រកបដោយចីរភាព។*

ធនាគារកណ្តាលកាណាដា៖[៣៤]

*"គោលដៅគោលនយោបាយរូបិយវត្ថុរបស់ធនាគារកណ្តាលកាណាដា គឺចូលរួមចំណែកក្នុងការកើនឡើងនូវកម្រិតជីវភាពរស់នៅរបស់ប្រជាជនកាណាដាទាំងអស់ តាមរយៈអតិផរណាទាប និងមានស្ថិរភាពល្អ។ ជាពិសេស ធនាគារកណ្តាលមានគោលបំណងរក្សាអត្រាអតិផរណា ...នៅក្នុងគោលដៅដែលបានបង្កើតរួមគ្នាជាមួយរដ្ឋាភិបាល។ ចាប់តាំងពីឆ្នាំ ១៩៩៥ មក គោលដៅមានកម្រិតអតិផរណាពី ១ ទៅ ៣ ភាគរយ"។*

ទស្សនៈទាំងនេះ អាចត្រូវបានសំយោគដូចខាងក្រោម៖

- ធនាគារកណ្តាលមានគោលបំណងពីរ៖ គោលបំណងមួយដែលអាចត្រូវបានគេហៅថា គោលបំណងចម្បង (ត្រូវបានគេកំណត់ថាអតិផរណាទាប និងមានស្ថិរភាព) និង គោលបំណងមួយទៀត ដែលអាចត្រូវបានគេហៅថាគោលបំណងចុងក្រោយ (ត្រូវបានកំណត់ថាជាកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយនិរន្តរភាព)។
- គោលបំណងចុងក្រោយ គឺអថេរឯករាជ្យ (dependent variable)។ ទោះជាយ៉ាងណាក៏ដោយអតិផរណាទាប និងស្ថិរភាពមិនមែនជាលក្ខខណ្ឌគ្រប់គ្រាន់ សម្រាប់ការសម្រេចបានប្រសិទ្ធភាពខ្ពស់នេះទេ។ វាគឺផ្នែកមួយនៃកត្តាជាច្រើន ប៉ុន្តែវាគឺជាផ្នែកមួយដ៏សំខាន់បំផុត។
- ភាពមិនប្រាកដប្រជាពីអតិផរណា គឺមានគ្រោះថ្នាក់ដល់ដំណើរការត្រឹមត្រូវសេដ្ឋកិច្ច។ អតិផរណាខ្ពស់ ត្រូវបានផ្សារភ្ជាប់ជាមួយនឹងអត្រាការប្រាក់ពិតទាប និងអត្រាការប្រាក់មានតែនាមខ្ពស់ដែលនឹងបង្កជាហានិភ័យ។ ភាពប្រែប្រួលខ្ពស់មានន័យថា ហានិភ័យហើយអាជីវកម្មមិនពេញចិត្តនឹងហានិភ័យនេះទេ។ អាជីវកម្ម មិនធ្វើបានល្អក្នុងបរិ

[៣៣] *This section benefitted from www.reservebank.co.za*

[៣៤] *www.reservebank.co.za*

ស្ថានសេដ្ឋកិច្ច ដែលមានហានិភ័យខ្ពស់នោះទេ ពីព្រោះកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេត្រូវបានបញ្ជូនទៅរកហានិភ័យ។

- កម្រិតថ្លៃរួមដែលមានស្ថិរភាព និងអត្រាការប្រាក់ មានស្ថិរភាពមានន័យថាសញ្ញាសេដ្ឋកិច្ចសំខាន់ៗមានតម្លាភាពដែលនាំឱ្យមានហានិភ័យទាប និងមានភាពងាយស្រួលក្នុងការសម្រេចចិត្តវិនិយោគ។ តាមរបៀបនេះ ស្ថិរភាពថ្លៃរួមចំណែកដល់កំណើនសេដ្ឋកិច្ចរយៈពេលវែងខ្ពស់ និងមានចីរភាព។

ដើម្បីសម្រេចបាននូវគោលបំណងចម្បង និងចុងក្រោយ ធនាគារកណ្តាលមានគោលបំណងគោលនយោបាយរូបិយវត្ថុសម្រាប់រយៈពេលមធ្យម ហើយគោលបំណងគោលនយោបាយទាំងនេះរួមមានធ្វើឱ្យមានកំណើនប្រាក់កម្ចី ប្រាក់បញ្ញើធនាគារ និងស្ថិរភាពលើសូចនាករផ្សេងទៀត ដូចជាអត្រាប្តូរប្រាក់ និងតម្លៃទ្រព្យសកម្ម។ ការសិក្សាពិភាក្សាលើគោលនយោបាយរូបិយវត្ថុ អាចត្រូវបានសង្ខេបដូចក្នុងរូបភាពទី៣។ គម្លាតដ៏ធំគួរឱ្យកត់សម្គាល់ វាត្រូវបានបំពេញដោយផ្នែកប្រតិបត្តិការនៃគោលនយោបាយរូបិយវត្ថុ ដែលត្រូវបានរៀបរាប់លម្អិតនៅពេលក្រោយទៀត។

ធនាគារកណ្តាល អាចមានឥទ្ធិពលដល់ការប្រែប្រួលរូបិយវត្ថុមូលដ្ឋាន អញ្ញត្តិរូបិយវត្ថុ លំហូរឥណទាន និងតាមរយៈគោលនយោបាយនេះ បានធ្វើឱ្យមានការប្រែប្រួលអថេរម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗមួយចំនួនដូចជា៖

- អត្រាការប្រាក់
- ចំណូលជាតិសរុប និង
- អត្រាអតិផរណា

ដោយប្រើប្រាស់នូវឧបករណ៍នយោបាយរូបិយវត្ថុដែលមាន។

គំនូសតាងទី៨ បង្ហាញពី៖ កម្មវត្ថុនៃគោលនយោបាយរូបិយវត្ថុ ( Object of monetary policy )



### ៥.៤.១- ប្រតិបត្តិការទីផ្សារបើកចំហ ( Open market operation-OMO )

ប្រតិបត្តិការទីផ្សារបើកចំហ (OMO) គឺជាមធ្យោបាយដ៏ចម្បងដែលធនាគារកណ្តាលប្រើប្រាស់សម្រាប់អនុវត្តនូវនយោបាយរូបិយវត្ថុ។

ក- ឥទ្ធិពលផ្ទាល់៣យ៉ាងនៃទីផ្សារបើកចំហៈ

- បម្រែបម្រួលដល់ប្រាក់បម្រុងៈ ការបម្រួញនៅក្នុងការផ្គត់ផ្គង់រូបិយវត្ថុ ដំណើររួញនៃការផ្គត់ផ្គង់រូបិយវត្ថុចុងក្រោយ។
- បម្រែបម្រួលអត្រាការប្រាក់ៈ សម្រាប់រយៈពេលទាំង៣មានរយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង ដើម្បីការទិញ ឬលក់ធនប័ណ្ណតាមបែបណាមួយនោះ។
- បម្រែបម្រួលពីការរំពឹងទុកៈ ការកើនឡើងការទិញមូលប័ត្របំណុលរបស់ធនាគារកណ្តាល។ គោលនយោបាយរូបិយវត្ថុពង្រីកអាចធ្វើឱ្យអត្រាការប្រាក់ចុះថយ ជំរុញការកើនឡើងការវិនិយោគ និងចំណាយលើការប្រើប្រាស់របស់គ្រួសារកើនឡើង។

ខ- ឥទ្ធិពលលើប្រតិបត្តិការទីផ្សារបើកចំហៈ

ធនប័ណ្ណរបស់ធនាគារ បានជះឥទ្ធិពលលើប្រាក់បម្រុងទុក (ស្ថាប័នទទួលប្រាក់បញ្ញើ)។ ទន្ទឹមនឹងនេះ ប្រតិបត្តិការទីផ្សារបើកចំហ (OMO) មានឥទ្ធិពលលើកម្រិតថ្លៃ កម្រិតទិន្នផលនៃធនប័ណ្ណ និងមានឥទ្ធិពលដល់ការរំពឹងទុកផ្នែកឯកជនយ៉ាងច្បាស់លាស់។ ប្រតិបត្តិការទីផ្សារបើកចំហ (OMO) ផ្តល់ទំនុកចិត្តដល់សាធារណជន តាមរយៈការអនុវត្តនូវគោលនយោបាយរូបិយវត្ថុរបស់ធនាគារកណ្តាល។

### ៥.៤.២- បង្អួចអប្បហារ ( Discount window )

បង្អួចអប្បហារ គឺជាឧបករណ៍គោលនយោបាយរូបិយវត្ថុ ដែលជានាអំឡុងពេលមានកម្រិតរូបិយវត្ថុ ដើម្បីឆ្លើយតបនឹងការកើនឡើងចុះនូវប្រាក់ឱ្យខ្ចី ឬការបង្ហូរចេញនូវប្រាក់បម្រុង។ម្យ៉ាងវិញទៀត ដើម្បីឆ្លើយតបអ្នកឱ្យខ្ចីដំណាក់កាលទ័លច្រកចុងក្រោយ ចំពោះធនាគារជាសមាជិកទាំងមូល និងមិនមែនជាសមាជិក។ ដូច្នេះ លក្ខណៈពិសេសនៃបង្អួចអប្បហារជាយន្តកម្មនៃការកែតម្រូវនូវប្រាក់បម្រុង និងការផ្គត់ផ្គង់ឥណទានឱ្យមានស្ថិរភាពរបស់ធនាគារ និងប្រាក់កម្ចីអប្បហារដោយធនាគារពាណិជ្ជកម្ម និងធនាគារកណ្តាល។

### ៥.៤.៣- ទុនបម្រុងកាតព្វកិច្ច ( Reserve requirement )

ទុនបម្រុងកាតព្វកិច្ច(RR) ធានាដល់ស្ថិរភាពប្រាក់បញ្ញើ ប្រាក់បញ្ញើមានកាលកំណត់ឱនភាពនៃប្រព័ន្ធធនាគារ និងជំហររបស់ធនាគារជាដើម។ ប្រភពនៃទុនបម្រុងកាតព្វកិច្ចគឺជា ដំណាក់

កាលលក់ធនប័ណ្ណ(ឬទ្រព្យសកម្មផ្សេងៗ) ដូចជាការខ្ចីពីធនាគារកណ្តាល ការខ្ចីពីស្ថាប័នប្រាក់បញ្ញើផ្សេងៗ និងការខ្ចីពីមូលនិធិរូបិយវត្ថុអន្តរជាតិ។

*សំណួរ៖ ហេតុអ្វីបានជាតម្រូវឱ្យមានទុនបម្រុងកាតព្វកិច្ច?*

*ចម្លើយ៖ បម្រើការខ្ចីប្រាក់របស់អ្នកមានប្រាក់បម្រុងទុកសម្រាប់ការខ្ចីប្រាក់ចំពោះអ្នកគ្មានប្រាក់បម្រុងទុក និងឆ្លើយតបទៅនឹងការដកសាច់ប្រាក់ ឬការដាក់ប្រាក់បញ្ញើ។*

## ៥.៥- ស្ថិរភាពថ្លៃ ( Price stability )

### ៥.៥.១- សេចក្តីផ្តើម ( Introduction )

គោលបំណងចម្បងរបស់ធនាគារកណ្តាល សម្រេចឱ្យបានសមិទ្ធិផលនៃកម្រិតអតិផរណាទាប និងមានស្ថិរភាពអតិផរណា ហើយគោលបំណងចុងក្រោយរបស់ធនាគារកណ្តាល ដំណើរការគ្រប់គ្រងបរិមាណផ្គត់ផ្គង់រូបិយវត្ថុសរុបក្នុងសេដ្ឋកិច្ច ដើម្បីសម្រេចឱ្យបានគោលដៅម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ ដូចជាការបន្ទាប់អត្រាអតិផរណាបង្កើនការងារ និងកំណើនសេដ្ឋកិច្ច។ ដូច្នេះហើយយើងចង់បង្ហាញថា តើស្ថិរភាពថ្លៃ និងអត្ថប្រយោជន៍ស្ថិរភាពថ្លៃជាអ្វី?

### ៥.៥.២- តើស្ថិរភាពថ្លៃគឺជាអ្វី ( What Is Price Stability ? )

ECB (សូមមើលប្រអប់លេខ១) កំណត់ស្ថិរភាពថ្លៃថា "ការកើនឡើងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (HICP) ប្រចាំឆ្នាំសម្រាប់តំបន់អឺរ៉ូ (euro area) ឱ្យនៅក្រោមអត្រា ២% ហើយបានបន្ថែមថា "ស្ថិរភាពថ្លៃត្រូវរក្សាឱ្យបានក្នុងរយៈពេលមធ្យម"។ ធនាគារកណ្តាលផ្សេងទៀតបានកំណត់ស្រដៀងគ្នានេះដែរ។

ឧទាហរណ៍៖ កំណត់គោលដៅកម្រិតអតិផរណាពី ៣-៦%។ តើនេះមានន័យយ៉ាងដូចម្តេចចំពោះសេដ្ឋកិច្ច? វាមានន័យថាធនាគារកណ្តាលចង់សម្រេចបាននូវអតិផរណាទាបនៅលើមូលដ្ឋានប្រកបដោយនិរន្តរភាព ពីព្រោះសភាពការណ៍នេះនាំមកនូវការប្រែប្រួលតម្លៃទាប និងអត្រាការប្រាក់ដែលជាធាតុចូលដ៏សំខាន់ក្នុងការសម្រេចចិត្តសកម្មភាពអាជីវកម្ម។ មធ្យោបាយមួយទៀត ចំពោះវិស័យឯកជនអាចរៀបចំផែនការជាមុនទាក់ទងនឹងការចំណាយ និងការវិនិយោគ (C + I = GDE; GDE + TAB = GDP) ដោយមិនមានការរាំងស្ទះដោយសារតែភាពមិនច្បាស់លាស់នោះទេ។

### ៥.៥.៣- តើស្ថិរភាពថ្លៃមានអត្ថប្រយោជន៍អ្វីខ្លះ?

អត្ថប្រយោជន៍នៃស្ថិរភាពថ្លៃគឺមានវិសាលភាពធំធេងណាស់ដែល ECB បង្ហាញពីអត្ថប្រយោជន៍នៅក្នុងប្រអប់លេខ១ ដូចខាងក្រោមនេះ។

សង្ខេប៖

- ជាទូទៅ វារួមចំណែកដល់ការសម្រេចឱ្យបាននូវកម្រិតខ្ពស់ និងនិរន្តរភាពនៃទិន្នផលសរុបសេដ្ឋកិច្ច និងនិកម្មភាព។

- វាធ្វើឱ្យប្រសើរឡើងនូវតម្លាភាពនៃយន្តការថ្លៃ។
- វារួមចំណែកដល់ការនាំមកនូវស្ថិរភាពអត្រាការប្រាក់ ដែលជាថ្លៃសំខាន់បំផុតនៅក្នុងសេដ្ឋកិច្ចទាក់ទងនឹងការសន្សំ និងការសម្រេចចិត្តវិនិយោគ។
- វារួមចំណែកក្នុងការចៀសផុតពីសកម្មភាពអាជីវកម្មដែលមិនលូតលាស់ ការការពារហានិភ័យប្រឆាំងនឹងអតិផរណា ឬបរិត្តផរណា។
- វាជួយក្នុងការស្ដារឡើងវិញនូវការបែងចែកប្រាក់ចំណូល និងទ្រព្យសម្បត្តិ។
- វាចូលរួមចំណែកក្នុងការកាត់បន្ថយផលប៉ះពាល់ខុសពីឥរិយាបទសេដ្ឋកិច្ច ដែលបណ្ដាលមកពីផលប៉ះពាល់នៃអតិផរណាលើប្រព័ន្ធពន្ធ និងសន្តិសុខសង្គម។

សូមរំលឹកថាធនាគារកណ្ដាលដទៃផ្សេងទៀត ក៏បានបង្ហាញនូវមតិដូចគ្នាដែរ៖ ជាទូទៅ ស្ថិរភាពថ្លៃរួមចំណែកដល់ការសម្រេចបានកម្រិតសេដ្ឋកិច្ចខ្ពស់ ពោលគឺការសម្រេចគោលដៅចុងក្រោយ។

| ប្រអប់លេខ១៖ អត្ថប្រយោជន៍នៃស្ថិរភាពថ្លៃរបស់ (ECB) [៣៥] |
| --- |
| "គោលដៅនៃស្ថិរភាពថ្លៃសំដៅទៅលើកម្រិតថ្លៃរួមក្នុងសេដ្ឋកិច្ច។ វាមានន័យថាចៀសវាងទាំងអតិផរណាយូរ និងបរិត្តផរណា។ ស្ថិរភាពថ្លៃរួមចំណែកដល់ការសម្រេចបាននូវកម្រិតខ្ពស់នៃសកម្មភាពសេដ្ឋកិច្ចដែលមាននិកម្មភាព"<br>• ការកែលម្អតម្លាភាពនៃយន្តការថ្លៃនៅក្រោមស្ថិរភាពថ្លៃ ប្រជាជនអាចដឹងពីការផ្លាស់ប្ដូរថ្លៃ ដែលទាក់ទង (ឧទាហរណ៍៖ ថ្លៃរវាងទំនិញផ្សេងៗគ្នា) ដោយមិនមានការភ័ន្តច្រឡំដោយការផ្លាស់ប្ដូរកម្រិតថ្លៃទូទៅ។ ប្រការនេះអនុញ្ញាតឱ្យពួកគេធ្វើការសម្រេចចិត្តអំពីការប្រើប្រាស់ និងការសម្រេចចិត្តវិនិយោគ និងផ្ដល់ធនធានឱ្យកាន់តែមានប្រសិទ្ធភាព។<br>• ការកាត់បន្ថយភាពប្រថុយប្រថាននឹងអត្រាការប្រាក់ដើម (ឧទាហរណ៍៖ ម្ចាស់បំណុលនៃការស្នើសុំហានិភ័យទាក់ទងនឹងការកាន់កាប់ទ្រព្យសម្បត្តិមានតែនាម)។ កាត់បន្ថយអត្រាការប្រាក់ពិត និងបង្កើនការលើកទឹកចិត្តក្នុងការវិនិយោគ។<br>• ចៀសវាងសកម្មភាពមិនល្អ ដើម្បីការពារហានិភ័យពីអតិផរណា ឬបរិត្តផរណា។<br>• ការកាត់បន្ថយអតិផរណា ឬបរិត្តផរណា ដែលអាចធ្វើឱ្យប៉ះពាល់ដល់ឥរិយាបទសេដ្ឋកិច្ចដែលមានឥទ្ធិពលខុសគ្នានៃប្រព័ន្ធពន្ធ និងប្រព័ន្ធសន្តិសុខសង្គម។<br>• ការការពារការបែងចែកទ្រព្យសម្បត្តិ និងប្រាក់ចំណូលតាមអំពើចិត្តដែលជាលទ្ធផលនៃអតិផរណា ឬបរិត្តផរណាដែលមិនបានរំពឹងទុក។<br>"ខណៈពេលដែលកំណត់បង្កើតឱ្យច្បាស់នូវការរក្សាស្ថិរភាពថ្លៃ ដែលជាគោលបំណងចម្បងរបស់ ECB វាមិនបានផ្ដល់និយមន័យច្បាស់លាស់នៃអត្ថន័យស្ថិរភាពថ្លៃទេ។ ក្រុមប្រឹក្សាគ្រប់គ្រងរបស់ ECB បានកំណត់ស្ថិរភាពថ្លៃថា ការកើនឡើងប្រចាំឆ្នាំពីសន្ទស្សន៍តម្លៃទំនិញប្រើប្រាស់ (HICP) សម្រាប់តំបន់អឺរ៉ូក្រោមអត្រា ២%។ ស្ថិរភាពថ្លៃ នឹងត្រូវរក្សាទុកក្នុងរយៈពេលមធ្យម។" |

[៣៥] *www.reservebank.ci.za*

## ៥.៦- អតិផរណាផ្ដោតលើក្របខ័ណ្ឌគោលនយោបាយរូបិយវត្ថុ[៣៦]

(Inflation targeting monetary policy framework)

ដើម្បីសម្រេចឱ្យបានគោលបំណងចម្បងនៃស្ថិរភាពថ្លៃ មានប្រទេសជាច្រើនបានផ្ដោតលើអត្រាអតិផរណាដែលជាក្របខ័ណ្ឌគោលនយោបាយរូបិយវត្ថុ។ ស្ថិតក្រោមក្របខ័ណ្ឌនេះ គោលដៅចម្បងជួរមុខសម្រាប់អត្រាអតិផរណាត្រូវបានបម្រុងទុក ដើម្បីសម្រេចឱ្យបានក្នុងរយៈពេលសមរម្យដែលបានកំណត់ ត្រូវបានប្រកាសជាសាធារណៈដោយរដ្ឋាភិបាល។

ដូច្នេះ វាជាគោលដៅរបស់រដ្ឋាភិបាល ហើយវាត្រូវបានប្រតិបត្តិដោយធនាគារកណ្ដាលពីព្រោះធនាគារកណ្ដាល មានឧបករណ៍គោលនយោបាយរូបិយវត្ថុដើម្បីប្រតិបត្តិការ ដើម្បីសម្រេចឱ្យមានប្រសិទ្ធភាពល្អបំផុត។ ក្របខ័ណ្ឌគោលនយោបាយរូបិយវត្ថុ ដែលផ្ដោតលើកម្រិតអតិផរណា គឺមិនត្រឹមតែផ្ដោតលើគោលដៅតែម្យ៉ាងប៉ុណ្ណោះទេ។ ប៉ុន្តែក៏ផ្ដោតលើសមាសធាតុ ឬគុណសម្បត្តិផ្សេងទៀតនៃក្របខ័ណ្ឌគោលនយោបាយផងដែរគឺ៖

- វាធ្វើឱ្យកម្មវត្ថុនៃគោលនយោបាយរូបិយវត្ថុមានលក្ខណៈច្បាស់លាស់ ដោយហេតុនេះ ធ្វើឱ្យផែនការមានភាពប្រសើរឡើងនៅក្នុងវិស័យឯកជន និងវិស័យសាធារណៈ។
- វាបញ្ជាក់ច្បាស់ថារដ្ឋាភិបាល គឺជាផ្នែកមួយនៃកិច្ចប្រឹងប្រែង ដែលមានលក្ខណៈជាផ្លូវការ និងមានការសម្របសម្រួល ដែលមានអតិផរណាក្នុងការស្វែងរកគោលដៅសេដ្ឋកិច្ចទូលំទូលាយនៃកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយនិរន្តរភាព និងការបង្កើតការងារ។
- វាផ្ដោតលើគោលនយោបាយរូបិយវត្ថុ និងបង្កើនគណនេយ្យភាពរបស់រដ្ឋាភិបាល និងធនាគារកណ្ដាលដល់សាធារណជន។
- វាផ្ដល់នូវយុទ្ធសាស្ត្រមួយសម្រាប់ការរំពឹងទុកនៃអតិផរណានាពេលអនាគត ដែលមានឥទ្ធិពលលើកម្រិតថ្លៃ និងកម្រិតប្រាក់ឈ្នួល។
- ជារឿយៗវាបង្ហាញចំណុចខ្សោយនៃគោលដៅដែលអាចបត់បែនបាន ដូចដែលបានបង្ហាញនៅក្នុងជួរគោលដៅ(ករណីខ្លះ)ហើយត្រូវបានសម្រេចក្នុងរយៈពេលមួយ(រយៈពេលមធ្យម)

<u>ចំណុចសម្គាល់៖</u> ការសម្រេចចិត្តខ្លះទៀត ត្រូវបានអនុញ្ញាតតាមកាលៈទេសៈដែលអាចកើតមានឡើង ហើយការផ្ដោតតែលើកម្រិតអតិផរណាតែមួយ គឺមិនសមស្របនោះទេ។ ឧទាហរណ៍៖ ករណីគ្រោះមហន្តរាយធម្មជាតិ លំហូរមូលនិធិអន្តរជាតិធំ និងការរំខានផលប៉ះទង្គិចពីការផ្គត់ផ្គង់ទំនិញដូចជាការឡើងថ្លៃផលិតផលប្រេងដែលបណ្ដាលឱ្យមានការតក់ស្លុតជាខ្លាំង ដូចជាការធ្លាក់ចុះយ៉ាងខ្លាំងតម្រូវការផលិតផលកាកាវនៅក្នុងប្រទេស(Ghana) ឬវត្ថុធាតុដើមលោហៈធាតុទង់ដែងនៅក្នុងប្រទេស (Zambia) ជាដើម។ ក្នុងកាលៈទេសៈទាំងនេះ វិធានការអនុវត្តយ៉ាងម៉ត់ចត់ដើម្បីពារាំងជាសមត្ថភាព របស់ធនាគារកណ្ដាលក្នុងការដោះស្រាយប្រកបដោយប្រសិទ្ធភាពជាមួយនឹងបញ្ហាទាំងនេះ។

[៣៦] *This draws heavily on www.reservebank.co.za*

ភាពប្រុងប្រយ័ត្នមួយចំនួនត្រូវតែអនុវត្ត ដើម្បីចៀសវាងការខាតបង់ថ្លៃដើមដែលទាក់ទងនឹងកម្រិតទិន្នផលសរុប និងកម្រិតការងារ។

សូម្បីមានការអះអាងថា ជាសិទ្ធិផ្តាច់មុខរបស់ធនាគារកណ្តាលភាគច្រើនក៏ដោយ ប៉ុន្តែសារសំខាន់នៃភាពជឿជាក់លើធនាគារកណ្តាល និងគោលដៅគោលនយោបាយរូបិយវត្ថុរបស់ធនាគារកណ្តាល[៣៧]បញ្ជាក់យ៉ាងច្បាស់អំពីបញ្ហានេះ៖[៣៨]

*"វា...ជាការសំខាន់ណាស់គោលដៅអតិផរណាមិនត្រូវបានកំណត់ជាមុន ដោយអនុវត្តការសម្រេចចិត្ត។ គោលបំណងនៃការអនុវត្ត គឺដើម្បីសម្រេចបាននូវកម្រិតគោលដៅ។ ក្របខ័ណ្ឌគោលនយោបាយរូបិយវត្ថុផ្តោតលើអតិផរណាអាចទទួលបានជោគជ័យប្រសិនបើសាធារណជនជឿជាក់ថា ធនាគារកណ្តាលយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះបន្ទុកអតិផរណា។ អត្ថប្រយោជន៍នៃការកំណត់អតិផរណា គឺអាស្រ័យលើថាតើប្រាក់ឈ្នួល និងការកម្រិតថ្លៃឆ្លើយតបចំពោះគោលដៅអតិផរណារបស់អាជ្ញាធរដែរឬទេ? សម្រាប់ការទិញជាសាធារណៈ គឺចាំបាច់ដើម្បីទទួលបានអតិផរណាទាប និងគុណប្រយោជន៍របស់វាសម្រាប់ទាំងអស់គ្នា។ នេះតម្រូវឱ្យមានការខិតខំប្រឹងប្រែងថ្នាក់ជាតិដោយបង្កើនការរំពឹងទុកជុំវិញកម្រិតអតិផរណា។"*

ទិសគោលដៅកម្រិតអត្រាអតិផរណា ជំនួសដោយគោលដៅអត្រាកំណើនស្តុករូបិយវត្ថុ។ ក្នុងក្របខ័ណ្ឌគោលនយោបាយរូបិយវត្ថុដែលកំណត់ទិសដៅអត្រាអតិផរណានៅតែកំណត់ស្តុកនៃរូបិយវត្ថុនៃប្រាក់កម្ចីធនាគារ និងការពង្រីកប្រាក់កម្ចីធនាគារមានសារសំខាន់យ៉ាងខ្លាំង ហើយពួកគេត្រូវបានត្រួតពិនិត្យយ៉ាងជិតដល់ ប៉ុន្តែរួមគ្នាជាមួយសូចនាករសេដ្ឋកិច្ចផ្សេងទៀតដូចជា៖

- កម្រិតអត្រាការប្រាក់អន្តរជាតិ
- រូបរាងនិងមុខងារខ្សែកោងទិន្នផល
- ការផ្លាស់ប្តូរប្រាក់ឈ្នួលតែនាម និងប្រាក់ឈ្នួលពិត
- ការផ្លាស់ប្តូរការងារ
- ឯកតាថ្លៃឈ្នួលពលកម្ម
- គម្លាតរវាងសក្តានុពល និងទិន្នផលជាតិជាក់ស្តែង
- លក្ខខណ្ឌទីផ្សាររូបិយវត្ថុទូទៅ
- ការផ្លាស់ប្តូរតម្លៃទ្រព្យសកម្ម
- សមតុល្យសរុបនៃមុខងារទូទាត់
- លក្ខខណ្ឌនៃការធ្វើពាណិជ្ជកម្ម
- ការអភិវឌ្ឍន៍អត្រាប្តូរប្រាក់
- តម្រូវការប្រាក់កម្ចីពីវិស័យសាធារណៈ។

## ៥.៧- គណនេយ្យភាព និងតម្លាភាពនៃគោលនយោបាយរូបិយវត្ថុ

---

[៣៧] www.bankfengland.co.za

[៣៨] www.bankfengland.co.za

(Monetary policy accountability and transparency)[៣៩]

ផ្នែកមុនយើងបានលើកឡើងពីទ្រព្យសកម្មនៃក្របខ័ណ្ឌគោលនយោបាយរូបិយវត្ថុ ដោយផ្តោតលើកម្រិតអតិផរណាដែលទាក់ទងនឹងគណនេយ្យភាពនៃគោលនយោបាយរូបិយវត្ថុ និងតម្លាភាព។ យើងនឹងលើកយកបញ្ហាទាំងនេះមកសិក្សាបន្ថែមទៀត។ ជំហាននីមួយៗខាងក្រោម ត្រូវបានអនុវត្តដោយធនាគារកណ្តាលភាគច្រើន ដើម្បីលើកកម្ពស់គណនេយ្យភាព និងតម្លាភាព មានដូចជា៖

- គោលដៅអតិផរណាត្រូវបានប្រកាសជាសាធារណៈ។ តាមវិធីនេះ វាបង្ហាញយ៉ាងច្បាស់ថាធនាគារកណ្តាលទទួលខុសត្រូវចំពោះគោលដៅ និងធ្វើឱ្យការអនុវត្តក្របខ័ណ្ឌគោលដៅអតិផរណាមានតម្លាភាពតាមដែលអាចធ្វើទៅបាន។
- ការជូនដំណឹងអំពីគោលដៅបង្ហាញពីចេតនានៃគោលនយោបាយរូបិយវត្ថុជាក់លាក់។ ដូច្នេះវិស័យសាជីវកម្មត្រូវបានផ្តល់ព័ត៌មាន និងអាចរៀបចំផែនការបានល្អទាក់ទងនឹងការផលិត និងការពង្រីកផលិតកម្ម។
- ប្រសិនបើគោលដៅមិនត្រូវបានបំពេញធនាគារកណ្តាលត្រូវតែពន្យល់ពីស្ថានភាពនេះដល់សាធារណជន (នៅក្នុងសភា)។
- ទេសាភិបាលធនាគារកណ្តាលមានកាតព្វកិច្ចរាយការណ៍ទៅរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ (រដ្ឋសភា) ពីរដងក្នុងមួយឆ្នាំ និងរាយការណ៍អំពីជំហរនៃគោលនយោបាយរូបិយវត្ថុ។
- ជំហរគោលនយោបាយរូបិយវត្ថុរបស់ធនាគារកណ្តាលត្រូវបានផ្សព្វផ្សាយជាសាធារណៈដល់សាធារណជនតាមទម្រង់ផ្សេងៗគ្នា។
  - ✓ សេចក្តីថ្លែងការណ៍គោលនយោបាយរូបិយវត្ថុដែលត្រូវបានផ្សព្វផ្សាយបន្ទាប់ពីកិច្ចប្រជុំនីមួយៗរបស់គណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ (MPC)។
  - ✓ ក្នុងករណីខ្លះ ធនាគារកណ្តាលអញ្ជើញសាធារណជនឱ្យចូលរួមវេទិកាគោលនយោបាយរូបិយវត្ថុធ្វើឡើងនៅមជ្ឈមណ្ឌលធំៗនៃប្រទេសដែលការធ្វើបទបង្ហាញត្រូវបានធ្វើឡើង និងពិភាក្សាត្រូវបានធ្វើឡើង ដែលសាធារណជនចូលរួម។
  - ✓ ក្នុងករណីខ្លះទៀត ធនាគារកណ្តាលផ្សព្វផ្សាយការត្រួតពិនិត្យគោលនយោបាយរូបិយវត្ថុ។ ពិពណ៌នាលម្អិតបន្ថែមទៀតអំពីការសម្រេចចិត្តរបស់ធនាគារកណ្តាល និងវិភាគកត្តាដែលអាចមានឥទ្ធិពលលើអតិផរណានាពេលអនាគត។

ភាគច្រើននៃគណនេយ្យភាព និងតម្លាភាពនៃសមាសធាតុទាំងនេះ វាគឺជារឿងធម្មតាសម្រាប់ធនាគារកណ្តាលនៅក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុ ដែលផ្តោតលើទៅកម្រិតអតិផរណា។ ស្ថានភាពនេះមានរបាយការណ៍បង្ហាញពីធនាគារអង់គ្លេស៖[៤០]

---

៣៩ www.reservebank.co.za

៤០ www.reservebank.co.za

*"ការបង្កើនគណនេយ្យភាពចំពោះសភា និងសាធារណជនត្រូវបានសម្រេចតាមរយៈការបោះពុម្ពផ្សាយ និងបន្តបោះពុម្ពផ្សាយរបាយការណ៍អតិផរណារបស់ធនាគារ ក៏ដូចជាតាមរយៈការបង្ហាញខ្លួនដោយសមាជិក (MPC) មុនពេលគណៈកម្មាធិការជ្រើសរើសធនាគារ និងតាមរយៈរបាយការណ៍ប្រចាំឆ្នាំរបស់ធនាគារ។ អភិបាលក៏មានកាតព្វកិច្ចត្រូវសរសេរលិខិតចំហទៅកាន់អធិការបតី ប្រសិនបើអតិផរណាមានច្រើនជាង ១% នៅផ្នែកម្ខាងនៃគោលដៅកម្រិត ២,៥ % ។ ស្ថិតក្រោមកាលៈទេសៈមួយចំនួនច្បាប់នៃធនាគារអង់គ្លេស អនុញ្ញាតឱ្យធនាគារផ្តល់ការណែនាំដល់ធនាគារកណ្តាលក្នុងវិស័យគោលនយោបាយរូបិយវត្ថុក្នុងរយៈពេលកំណត់។ អំណាចទាំងនេះ អាចត្រូវបានប្រើប្រសិនបើធនាគារពេញចិត្តថាពួកគេត្រូវបានទាមទារក្នុងផលប្រយោជន៍សាធារណៈ ហើយមានករណីនេះតែ "ស្ថានភាពសេដ្ឋកិច្ចធ្ងន់ធ្ងរប៉ុណ្ណោះ។"*

## ៥.៨- ដែនកំណត់នៃគោលនយោបាយរូបិយវត្ថុ ( Limitations of monetary policy )

មានភស្តុតាងពីការសិក្សាខាងលើដែនកំណត់នៃគោលនយោបាយរូបិយវត្ថុ ដែលអាចទទួលយកបាន។ គោលបំណងចុងក្រោយរបស់រដ្ឋាភិបាល គឺដើម្បីលើកកម្ពស់សុខុមាលភាពរបស់ប្រទេសជាតិ។ មានកត្តាជាច្រើនដែលរួមចំណែកដល់សុខុមាលភាពរបស់ប្រជាជន គឺការអប់រំក្រមសីលធម៌វិជ្ជាជីវៈ វប្បធម៌ ធនធានរ៉ែ បច្ចេកវិទ្យា កំណើនប្រជាជន ស្ថិរភាពនយោបាយ និងស្ថិរភាពថ្លៃ។ល។ ស្ថិរភាពថ្លៃ គឺគ្រាន់តែជាកត្តាមួយក្នុងចំណោមកត្តាទាំងនេះ មានន័យថាធនាគារកណ្តាលមិនអាចទទួលបាននូវឧត្តមភាពខ្ពស់ក្នុងការលើកកម្ពស់សុខុមាលភាពប្រជាជាតិបានឡើយ វាគ្រាន់តែអាចចូលរួមវិភាគទានដល់ឧត្តមគតិនេះប៉ុណ្ណោះ។ ហើយស្ថិរភាពថ្លៃ គឺជាកត្តាតែមួយគត់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ធនាគារកណ្តាល។

ទិដ្ឋភាពរបស់ (ECB) គឺពាក់ព័ន្ធ៖[៤១]

*"ក្នុងរយៈពេលវែងធនាគារកណ្តាល អាចចូលរួមវិភាគទានដ៏មានសក្តានុពលកំណើនសេដ្ឋកិច្ចដោយរក្សាបរិស្ថាននៃស្ថិរភាពថ្លៃ។ វាមិនអាចលើកកម្ពស់កំណើនសេដ្ឋកិច្ចតាមរយៈការពង្រីកការផ្គត់ផ្គង់រូបិយវត្ថុ ឬរក្សាអត្រាការប្រាក់រយៈពេលខ្លីក្នុងកម្រិតមួយ ដែលមិនស៊ីគ្នានឹងស្ថិរភាពថ្លៃឡើយ។ វាអាចមានឥទ្ធិពលតែលើកម្រិតថ្លៃរួមប៉ុណ្ណោះ។"*

*"អតិផរណា គឺជាបាតុភូតរូបិយវត្ថុសម្រាប់រយៈពេលវែងនៃកម្រិតអតិផរណាខ្ពស់ ត្រូវបានផ្សារភ្ជាប់ជាមួយនឹងកំណើនរូបិយវត្ថុខ្ពស់។ ខណៈពេលដែលកត្តាផ្សេងទៀត (ដូចជាបម្រែបម្រួលតម្រូវការសរុប ការផ្លាស់ប្តូរបច្ចេកវិទ្យា ឬការតម្លើងថ្លៃទំនិញ) អាចជះឥទ្ធិពលដល់ការអភិវឌ្ឍន៍តម្លៃលើដួរផ្តេចជាងរយៈពេលខ្លី ឥទ្ធិពលរបស់វាអាចត្រូវបានទូទាត់ដោយការផ្លាស់ប្តូរគោលនយោបាយរូបិយវត្ថុ។"*

ធនាគារសហព័ន្ធអាហ្វ្រិកខាងត្បូងបានបញ្ជាក់អំពីបញ្ហានេះ៖[៤២]

---

[៤១] www.reservebank.co.za

*"...ធនាគារកណ្តាល...ជឿជាក់ថា ការចូលរួមចំណែកដ៏ល្អបំផុតនៃគោលនយោបាយរូបិយវត្ថុអាចធ្វើឱ្យមានកំណើនសេដ្ឋកិច្ច គឺផ្តល់នូវបរិយាកាសអតិផរណាទាប និងមានស្ថិរភាពដែលជាអំណោយផលដល់កំណើនរយៈពេលវែងប្រកបដោយចីរភាព" ។*

## ៥.៩- ឧបករណ៍នៃគោលនយោបាយរូបិយវត្ថុ ( Tools of monetary policy )

ធនាគារកណ្តាល អាចមានឥទ្ធិពលលើការប្រែប្រួលរូបិយវត្ថុមូលដ្ឋាន អញ្ញត្តិរូបិយវត្ថុ លំហូរឥណទាន និងតាមរយៈការប្រែប្រួលអថេរម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗមួយចំនួន ដូចជាអត្រាការប្រាក់ចំណូលជាតិ និងអត្រាអតិផរណា ដោយសារការប្រើប្រាស់នូវឧបករណ៍គោលនយោបាយរូបិយវត្ថុដែលមាន។ គោលនយោបាយរូបិយវត្ថុ មានមុខងារជាអ្នកត្រួតពិនិត្យនៅតាមបណ្តាប្រទេសភាគច្រើន ហើយក្រឡេកមើលពីអតីតកាល បានបង្ហាញពីឧបករណ៍គោលនយោបាយខ្លះ ដែលអាចធ្វើឱ្យធនាគារិករ័យក្មេងខ្លះមានឥទ្ធិពលខ្លាំង។

បច្ចុប្បន្ននេះ មានការជជែកវែកញែកតិចតួចពីឧបករណ៍គោលនយោបាយរូបិយវត្ថុ។ អត្ថិភាពនៃបទដ្ឋានឧបករណ៍គោលនយោបាយរូបិយវត្ថុមានតែមួយ និងភាពខុសគ្នាតែមួយគត់ ដែលមានការច្របូកច្របល់។ តើហេតុអ្វីយើងត្រូវជីកកកាយឧបករណ៍គោលនយោបាយរូបិយវត្ថុចាស់? ដោយសារតែ មូលហេតុទី១គឺភាពពេញលេញ (completeness) និងមូលហេតុទី២គឺប្រវត្តិសាស្ត្រ(history)។ យើងត្រូវតែរលឹកពីអតីតកាលគួរឱ្យខ្លាច ដែលទាក់ទងនឹងឧបករណ៍គោលនយោបាយរូបិយវត្ថុ គួរតែចៀសវាង។ បច្ចុប្បន្ននេះ ឧបករណ៍គោលនយោបាយរូបិយវត្ថុដែលមានប្រសិទ្ធភាពក៏អាចបង្កភាពអន្តរាយដល់ធនាគារកណ្តាលដែលមិនឯករាជ្យជាមួយនឹងប្រធានាធិបតី ឬនាយករដ្ឋមន្ត្រីផងដែរ។

ទន្ទឹមនេះដែរ លោក (Meijer) បានបង្ហាញពីបញ្ជីឧបករណ៍គោលនយោបាយរូបិយវត្ថុត្រូវបានប្រើពីអតីតកាល និងបច្ចុប្បន្ននេះមានដូចជា៖

- ការគ្រប់គ្រងបំណុលសាធារណៈ។
- ប្រតិបត្តិការទីផ្សារបើកចំហ (OMO)។
- គោលនយោបាយបញ្ចុះតម្លៃរបស់ធនាគារកណ្តាល។
- បម្រែបម្រួលតម្រូវការទុនបម្រុងសម្រាប់ធនាគារ ឬ (ជាទូទៅ) នៅក្នុងបទបញ្ជាគ្រប់គ្រងលើសមាសធាតុផលប័ត្ររបស់ធនាគារ និងស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត។
- ការអនុវត្តន៍ និងបម្រែបម្រួលនៃការរឹតបន្តឹងបរិមាណលើការផ្តល់ប្រាក់កម្ចីរបស់ធនាគារ (ឥណទាន "ពិដាន")
- ការគ្រប់គ្រងឥណទានជ្រើសរើស។
- ការដាក់ប្រាក់បញ្ញើ និង/ឬការត្រួតពិនិត្យអត្រាការប្រាក់។
- ការលះបង់សីលធម៌។
- បម្រែបម្រួលលក្ខខណ្ឌនៃប្រាក់ឈ្នួល ការទិញ និងការបង់រំលស់ (ឥណទានអតិថិជន) ។

[៤២] Meijer, 1992:302

- ការគ្រប់គ្រងបញ្ហាមូលធន។
- នាំចូលគ្រោងការណ៍ប្រាក់បញ្ញើ។
- ការខ្ចីប្រាក់ជាផ្លូវការ (ក្រោមលក្ខខណ្ឌជាក់លាក់) ។
- ការផ្លាស់ប្តូរបទប្បញ្ញត្តិស្តីពីការគ្រប់គ្រងការផ្លាស់ប្តូរ (ក្នុងលក្ខខណ្ឌជាក់លាក់) ។
- អន្តរាគមន៍របស់ធនាគារកណ្តាលនៅនឹងកន្លែង និងឆ្ពោះទៅរកទីផ្សារប្តូរប្រាក់បរទេស (ក្នុងលក្ខខណ្ឌជាក់លាក់) ។

ឧបករណ៍គោលនយោបាយរូបិយវត្ថុ ត្រូវបានចាត់ថ្នាក់ក្នុងទិសដៅថ្មី ដោយប្រយោលផ្តោតលើទីផ្សារ និងទិសដៅចាស់ដោយផ្ទាល់មិនផ្តោតលើទីផ្សារ។ យើងចាប់ផ្តើមសិក្សាពាក្យ ឧបករណ៍គោលនយោបាយរូបិយវត្ថុក្នុងទិសដៅចាស់ដោយផ្ទាល់មិនផ្តោតលើទីផ្សារ គឺជាឧបករណ៍គោលនយោបាយដែលត្រូវបានប្រើ ដើម្បីសម្រេចគោលបំណងនៃគោលនយោបាយរូបិយវត្ថុ ដោយសារចេញបទបញ្ជាពីប្រព្រឹត្តកម្មរបស់ធនាគារ។ ពួកគេមិនពឹងផ្អែកលើកម្លាំងទីផ្សារ ដើម្បីជំរុញឥទ្ធិពលលើឥរិយាបទរបស់ធនាគារទេ។ ជាទូទៅវាពាក់ព័ន្ធនឹងឥរិយាបទដែលអាចបត់បែនបាន ឬបញ្ជាក់ពីវិធានច្បាប់ជាក់លាក់។ ប្រសិនបើធនាគារមិនគោរពតាមវិធានការដាក់ទណ្ឌកម្ម ឬកាត់ទោសដែលអាចធ្វើទៅបានទេនោះ។

ឧទាហរណ៍រួមមាន៖

- ពិដានបរិមាណលើការផ្តល់ប្រាក់កម្ចីធនាគារ
- ពិដានអត្រាការប្រាក់ ដែលបានបញ្ជាក់ និង/ឬជាន់លើប្រាក់កម្ចី និងប្រាក់បញ្ញើ។
- ការគ្រប់គ្រងការផ្លាស់ប្តូរ
- ការត្រួតពិនិត្យបរិមាណដំណាលគ្នានៃប្រាក់បម្រុងធនាគារ និងការគ្រប់គ្រងអត្រាការប្រាក់។

សម្រាប់ឧបករណ៍តម្រង់ទិសដៅថ្មី/ដោយប្រយោល/ថ្មី ("ថ្មី" ក្នុងន័យនេះមានរយៈកាល ៣ ឬ ៤ ទសវត្សរ៍មុន) នៃឧបករណ៍គោលនយោបាយរូបិយវត្ថុ គឺជាអ្វីដែលត្រូវបានប្រើ ដើម្បីសម្រេចបានគោលបំណងនៃគោលនយោបាយរូបិយវត្ថុ ដែលមានឥទ្ធិពលទៅលើសកម្មភាពគ្រឹះស្ថានធនាគារ និងសាធារណជនក្នុងការគោរពតាមគោលការណ៍ផ្តល់ប្រាក់កម្ចី និងការខ្ចីប្រាក់របស់ពួកគេ។ ការជះឥទ្ធិពលនេះកើតមានឡើងពីការប្រែប្រួលអត្រាការប្រាក់ដែលការកើតឡើងនេះ ដោយសារតែធនាគារកណ្តាលគិតតាមអត្រាប្តូរប្រាក់ទីផ្សារហិរញ្ញវត្ថុ (មានទំនាក់ទំនងនឹង KIR)។ ការផ្លាស់ប្តូរអត្រាគ្រប់គ្រង (KIR) មិនមានន័យថា "តម្រង់ទិសដៅទីផ្សារ" ទេ។ ប៉ុន្តែវាអាស្រ័យលើការពិតដែលថាភាគច្រើននៃស្តុកប្រាក់គឺជាប្រាក់បញ្ញើរបស់ធនាគារ (NBPS)។ ដោយសារតែធនាគារនេះ មានលទ្ធភាពបង្កើតប្រាក់ ដោយគ្រាន់តែផ្តល់ប្រាក់កម្ចីតាមតម្រូវការប្រាក់កម្ចីប៉ុណ្ណោះ។

ដូច្នេះជាទូទៅ កម្លាំងផ្គត់ផ្គង់ និងតម្រូវការគឺអវត្តមាន ហើយអង្គភាពខ្លះត្រូវបានបង្កើតអត្រាការប្រាក់លោកុប្បត្តិ (genesis)។ ធនាគារកណ្តាល បានផ្តល់អត្រាតាមទម្រង់ (KIR) ហើយអត្រានេះបានជះឥទ្ធិពលលើអត្រារបស់ក្រុមហ៊ុន (b2b IBM) និងអត្រាប្រាក់បញ្ញើធនាគារ (បំណុលធនាគារ) និងតាមរយៈអត្រាប្រាក់កម្ចីធនាគារ។ អត្រាប្រាក់កម្ចីធនាគារ មានជះឥទ្ធិពលដល់តម្រូវការសាធារ

ណៈសម្រាប់ប្រាក់កម្ចីធនាគារ។ ដូច្នេះ ធនាគារកណ្តាលអនុវត្តនូវការវាស់វែងពីទំហំប្រាក់កម្ចីធនាគារដែលមានតម្រូវការ។

ដូច្នេះ (KIR) គឺមានប្រសិទ្ធភាពលុះត្រាតែធនាគារមានបំណុលដល់ធនាគារកណ្តាល ពោលគឺប្រើទុនបម្រុងធនាគារ។ នេះមានន័យថា ធនាគារកណ្តាលត្រូវតែបង្កើត និងរក្សាស្ថានភាពកង្វះសាច់ប្រាក់ងាយរងគ្រោះ(LS)។ នេះគឺជាទីតាំងប្រតិបត្តិការទីផ្សារបើកចំហ (OMO) ចូលរួមក្នុងទីផ្សារ។

ធនាគារកណ្តាលបានប្រើទីផ្សារបើកចំហសម្រាប់ឧបករណ៍ហិរញ្ញវត្ថុ ដើម្បីនាំមកនូវ៖

- ទិញ និងលក់មូលប័ត្ររបស់រដ្ឋាភិបាល (ប័ណ្ណរតនាគារ និងសញ្ញាប័ណ្ណរដ្ឋាភិបាល)
- ការប្តូររូបិយប័ណ្ណ (Forex) ជាមួយធនាគារ
- បោះផ្សាយ និងទិញមូលប័ត្ររបស់ធនាគារកណ្តាលឡើងវិញ
- ការផ្លាស់ប្តូរមូលនិធិរបស់រដ្ឋាភិបាលរវាងគណនី (Exchequer) នៅធនាគារកណ្តាល និង (TLAs) នៅធនាគារ។

ភាពមិនច្បាស់លាស់៖ នៅពេលវេលាមិនច្បាស់លាស់ណាមួយ កម្រិតអតិរេកសាច់ប្រាក់ងាយស្រួល អាចជាលទ្ធផលនាំឱ្យកើតឡើងដោយសារតែធនាគារកណ្តាលតាមរយៈ (OMO)។ ការជំរុញលើកទឹកចិត្ត គឺត្រូវបង្ខំឱ្យធនាគារទម្លាក់អត្រាការប្រាក់ឱ្យមកនៅកម្រិតទាបបំផុត។

សេចក្តីសង្ខេប៖ ក្នុងពេលវេលាធម្មតាឧបករណ៍នៃគោលនយោបាយរូបិយវត្ថុគឺ៖

- ការបង្កើតលក្ខខណ្ឌ LS (Liquidity shortage) ដើម្បីធ្វើឱ្យ (KIR) មានប្រសិទ្ធិភាព
- ការផ្លាស់ប្តូរ (KIR) ទៅតាមពេលវេលាសមស្រប
- ប្រតិបត្តិ (OMO) នៅក្នុងទម្រង់ផ្សេងៗគ្នា ដើម្បីធានាឱ្យបាននូវលក្ខខណ្ឌ LS

រូបភាពទី៤ បំពេញក្នុងរូបភាពទី៣ ដោយបញ្ចូលឧបករណ៍គោលនយោបាយរូបិយវត្ថុទាំងនេះ។ នៅពេលបញ្ចូលគ្នាពួកគេតំណាងឱ្យប្រតិបត្តិការគោលនយោបាយរូបិយវត្ថុ។

គំនូសតាងទី ៩ បង្ហាញពី៖ គោលនយោបាយរូបិយវត្ថុ (Monetary policy)



ការអនុវត្តន៍ឧបករណ៍ទាំងនេះប្រកបដោយប្រសិទ្ធភាពបាន គឺពឹងផ្អែកទៅលើប្រព័ន្ធហិរញ្ញវត្ថុ ដែលមានការវិវត្តដែលបង្ហាញពីកម្រិតថ្លៃ ដែលមានស្ថិរភាពផងដែរ។

## ៥.១០- ឯករាជ្យភាពរបស់ធនាគារកណ្តាល (Independence of central banks)

ការសិក្សាផ្នែកនេះ យើងពុំបានជជែកវែកញែកឱ្យបានច្បាស់លាស់ពីឯករាជ្យភាពធនាគារកណ្តាលនោះទេ។ ជាទូទៅ ធនាគារកណ្តាល ត្រូវតែទទួលយកនូវប្រតិបត្តិការឯករាជ្យភាពរបស់ខ្លួន និងជាទីប្រឹក្សាពិគ្រោះយោបល់ជាមួយរតនាគារតាមតម្រូវការ និងការការពារគោលនយោបាយរូបិយវត្ថុមិនឱ្យខូចខាត។ ចំពោះឯករាជ្យភាពរបស់ធនាគារកណ្តាល ត្រូវបានបញ្ចូលក្នុងលក្ខន្តិកច្បាប់នៅតាមបណ្តាប្រទេសភាគច្រើន។ ករណីធនាគារសហព័ន្ធនៃអាហ្វ្រិកខាងត្បូង ស្តីពីឯករាជ្យភាពធនាគារកណ្តាលត្រូវបានបញ្ចូលទៅក្នុងច្បាប់រដ្ឋធម្មនុញ្ញ ដូចមានចែងក្នុងមាត្រា ២៤ នៃផ្នែករងទី២ ស្តីពីឯករាជ្យភាពរបស់ធនាគារកណ្តាលនេះ៖

> " *ធនាគារសហព័ន្ធនៃអាហ្វ្រិកខាងត្បូង ដើម្បីបន្តវត្ថុបំណងរបស់ខ្លួន ត្រូវតែបំពេញនូវមុខងាររបស់ខ្លួនដោយឯករាជ្យ និងដោយគ្មានការភ័យខ្លាចការអនុគ្រោះ ឬការរើសអើង ប៉ុន្តែត្រូវតែមានការពិគ្រោះយោបល់ជាទៀងទាត់រវាងរតនាគារ និងសមាជិកគណៈរដ្ឋមន្ត្រី ដែលទទួលខុសត្រូវចំពោះបញ្ហាហិរញ្ញវត្ថុជាតិ*"។

## ៥.១១- ការវាស់កំណើនសេដ្ឋកិច្ច (Measurement economy growth)

យើងនឹងសិក្សាអំពីការលូតលាស់នៃសេដ្ឋកិច្ច និងការប្រែប្រួលនៃផលិតផលសរុបក្នុងស្រុកព្រមទាំងវដ្តនៃសេដ្ឋកិច្ច។ តើអ្វីជាផលិតផលក្នុងស្រុកសរុប (GDP)? ចម្លើយ៖ ផលិតផលសរុបក្នុងស្រុកសរុប គឺជាតម្លៃទំនិញ និងសេវាចុងក្រោយ ដែលបានផលិតនៅក្នុងប្រទេសមួយនៅរយៈពេលមួយដែលបានកំណត់ជាទូទៅក្នុងមួយឆ្នាំ។ *ផលិតផលសរុបក្នុងស្រុកជាចំនួនសរុបនៃតម្លៃបន្ថែម* គឺវាមិនមាន ភាពងាយស្រួលដូចការគិតនោះទេ ដើម្បីទទួលបានតម្លៃបន្ថែមនៃតម្លៃសរុបផលិតផលជាតិមួយ ព្រោះថាផលិតផលរបស់សហគ្រាសមួយ ដែលគេហៅថា ធាតុចេញ (Output) គឺតែងតែជាមុខចូលរបស់ សហគ្រាសមួយផ្សេងទៀត ដែលគេហៅថាធាតុចូល (Input)។ ប៉ុន្តែគេអាចគណនាផលិតផលសរុប គឺជាផលដករវាងតម្លៃទំនិញ និងសេវា ដែលបានលក់ និងតម្លៃទំនិញសេវាកម្មពាក់កណ្តាលសម្រេចដែលបានប្រើ (ជួនកាលហៅថាតម្លៃទំនិញអន្តរការី) ក្នុងការផលិត។

ចំណែកឯផលិតផលជាតិសរុប (GNP) គឺជាតម្លៃទំនិញ និងសេវាចុងក្រោយ ដែលបានផលិតដោយកត្តាផលិតកម្មដែលជាកម្មសិទ្ធរបស់ប្រទេសជាតិមួយនៅរយៈពេលមួយ ដែលបានកំណត់ជាទូទៅ គឺក្នុងមួយឆ្នាំ។ ផលិតផលជាតិសរុប (GNP) គឺជាសន្ទស្សន៍មួយដែលអាចឱ្យយើងធ្វើការប្រៀបធៀបពីការអភិវឌ្ឍន៍របស់ប្រទេសមួយជាមួយប្រទេសទៀត។

យើងចង់វាស់អត្រាកំណើនសេដ្ឋកិច្ច ដូច្នេះយើងអាចធ្វើ

- ប្រៀបធៀបសុខុមាលភាពសេដ្ឋកិច្ច
- ប្រៀបធៀបអន្តរជាតិ
- វដ្តសេដ្ឋកិច្ច

ទោះបីជាអត្រាកំណើនផលិតផលក្នុងស្រុកសរុប(GDP)ត្រូវបានគេប្រើសម្រាប់គោលបំណង ៣ វាក៏មិនមែនជាការវាស់ល្អឥតខ្ចោះនោះទេ។

១. ការប្រៀបធៀបសុខុមាលភាពសេដ្ឋកិច្ច (Economy welfare comparisons)

សុខុមាលភាពសេដ្ឋកិច្ចល្អប្រសើរនៅពេលដែលរាល់ការផលិតទំនិញ និងសេវាកម្មបានកើនឡើង។ ការកើនឡើងនៃទំនិញ និងសេវាកម្មធ្វើឱ្យផលិតផលក្នុងស្រុកសរុប (GDP) កើន។

ឧទាហរណ៍ ដោយសារតែផលិតផលក្នុងស្រុកសរុប (GDP) កើនឡើង ហើយផលិតផលក្នុងស្រុកសរុប (GDP) ក្នុងមនុស្សម្នាក់នៅក្នុងប្រទេសកម្ពុជា ៥៩៤ដុល្លារ កើនឡើងស្ទើរតែពីរដង បើប្រៀបធៀបទៅនឹង ២០០០ តើការកើនឡើងនៃផលិតផលក្នុងស្រុកសរុប (GDP) ដល់ចំណុចកំពូលដែរឬទេ? ការផ្លាស់ប្តូរខ្នាត់វាស់ទៀងទាត់ឬទេនៅក្នុងសុខុមាលភាពសេដ្ឋកិច្ច? វាមិនមែនទេ...ការអះអាងនេះ គឺថាសុខុមាលភាពសេដ្ឋកិច្ចពឹងផ្អែកលើកត្តាជាច្រើន ដែលវាមិនអាចវាស់វែងដោយផលិតផលក្នុងស្រុកសរុបពិត (realGDP) ឬមិនអាចវាស់វែងទៀងទាត់ដោយ ផលិតផលក្នុងស្រុកសរុប (realGDP)។

រូបមន្តគណនា(realGDP)៖

ឧទាហរណ៍៖ ដើម្បីរកអត្រាកំណើនផលិតផលក្នុងស្រុកសរុបពិត (realGDP) នៅចន្លោះឆ្នាំ២០០០ (១៩០) និងឆ្នាំ២០០២ (២៤០) តាមរយៈការសន្មតទិន្នន័យដែលបានប្រើសម្រាប់គណនា យើងបាន ៖

❖ អត្រាកំណើន Real GDP$_{2000\text{-}2002}$ $= \frac{RealGDP_{2002} - RealGDP_{2000}}{RealGDP_{2000}} \times 100$

$$= \frac{240 - 190}{190} \times 100 = 26{,}3\%$$

២. ការប្រៀបធៀបអន្តរជាតិ (International Comparisons)

រាល់បញ្ហាទាំងអស់យើងគ្រាន់តែត្រួតពិនិត្យឡើងវិញនូវឥទ្ធិពលទៅលើសុខុមាលភាពសេដ្ឋកិច្ចរបស់ប្រទេសនីមួយៗនៅលើពិភពលោក។ ប៉ុន្តែការប្រៀបធៀបផលិតផលក្នុងស្រុកសរុបពិត (realGDP) គឺជាសុខុមាលភាពសំខាន់នៃការប្រៀបធៀបសុខុមាលភាពអន្តរជាតិព្រមជាមួយគ្នានេះដែរ គេឃើញមានបញ្ហាពិសេសពីរកើតមានឡើងនៅក្នុងការធ្វើការប្រៀបធៀប។ បញ្ហាទី១៖ ផលិតផលក្នុងស្រុកសរុបពិត (realGDP) នៃប្រទេសនីមួយៗ គួរតែផ្លាស់ប្តូរទៅក្នុងឯកតារូបិយវត្ថុដូចទៅនឹងផលិតផលក្នុងស្រុកសរុបពិត (realGDP) នៃប្រទេសផ្សេងៗ។ បញ្ហាទី២៖ ថ្លៃដូចគ្នាគួរតែធ្វើការប្រៀបធៀបតម្លៃនៃទំនិញ និងសេវា។

ឧទាហរណ៍៖ ចូរក្រឡេកមើលបញ្ហាទាំងពីរនេះដោយ ការប្រៀបធៀបរវាងសហរដ្ឋអាម៉េរិក និងប្រទេសចិន។ នៅក្នុងឆ្នាំ២០០៨ (យើងអាចធ្វើការប្រៀបធៀបបាន) ផលិតផល

ក្នុងស្រុកសរុប (GDP) ក្នុងមនុស្សម្នាក់ៗក្នុងប្រទេសអាម៉េរិកមាន ៤៦,៨០០ដុល្លារ ដោយយោងតាម តួលេខរបស់ IMF។ ផលិតផលក្នុងស្រុកសរុប (GDP) ក្នុងមនុស្សម្នាក់ៗនៅក្នុងឆ្នាំ២០០៨ មាន ៣,១៨០ដុល្លារ។ ដូច្នេះ ផលិតផលក្នុងស្រុកសរុប (GDP) ក្នុងមនុស្សម្នាក់របស់ប្រជាជន អាម៉េរិកជិត ១៥ដង នៃប្រជាជនចិន។

៣. វដ្តសេដ្ឋកិច្ច ៖ (Economy Cycle)

គេតែងតែនិយាយថា សេដ្ឋកិច្ចមានការប្រែប្រួលមិនទៀងទាត់ការវាស់វែងភាពប្រែប្រួលនៃសេដ្ឋកិច្ច ជាពិសេសការកើនឡើង ឬថយចុះនៃផលិតផលក្នុងស្រុកសរុប (GDP) ហៅថាវដ្តសេដ្ឋកិច្ច។ តាមធម្មតាវដ្តសេដ្ឋកិច្ចមាន៤ គឺ៖

- ការថយចុះល្បឿនសេដ្ឋកិច្ច (Contraction) គឺជាការថយចុះនៃល្បឿនសេដ្ឋកិច្ចនៅរយៈពេលមួយ។ ឧទាហរណ៍៖ សេដ្ឋកិច្ចកម្ពុជាយើងបានធ្លាក់ចុះចាប់តាំងពីឆ្នាំ ១៩៩៥-១៩៩៧ និងពីឆ្នាំ ១៩៩៩-២០០២ និងចាប់ផ្តើមធ្លាក់ចុះម្តងទៀត ២០០៥-២០០៧។
- ការលូតលាស់សេដ្ឋកិច្ច (Expansion) គឺជាសម្ទុះនៃការលូតលាស់នៃសេដ្ឋកិច្ច។ ឧទាហរណ៍៖ ក្នុងកំឡុងឆ្នាំ១៩៩៨-១៩៩៩ និងសេដ្ឋកិច្ចកម្ពុជាបានកើតឡើង ហើយងើបមុខសារជាថ្មីម្តងទៀតក្នុងរវាងឆ្នាំ ២០០៣ ដល់ ២០០៤-២០០៥។
- ការស្រុតចុះសេដ្ឋកិច្ច (Trough) គឺជាការស្រុតចុះនៃសេដ្ឋកិច្ចដល់ចំណុចទាបបំផុតនារយៈពេលមួយ។ ឧទាហរណ៍៖ សេដ្ឋកិច្ចប្រទេសយើងបានស្រុតចុះយ៉ាងខ្លាំង នាឆ្នាំ ១៩៩៧-១៩៩៨ និង ២០០១-២០០២។
- ការលូតលាស់សេដ្ឋកិច្ចដល់កំពូល (Peak) គឺជាចំណុចកំពូលនៃការលូតលាស់សេដ្ឋកិច្ចរយៈពេលមួយ។ សេដ្ឋកិច្ចនៃប្រទេសយើងបានឈានដល់ចំណុចកំពូលក្នុងអំឡុងឆ្នាំ១៩៩៨-១៩៩៩ និង២០០៤ -២០០៥។

គួរកត់សម្គាល់ថា៖ យើងអាចជួបប្រទះនូវវិបត្តិសេដ្ឋកិច្ច (Recession) សំដៅទៅលើការចុះផលិតផលក្នុងស្រុកសរុបពិត (realGDP) ចំនួនពីរភាគបី និងវិបត្តិសេដ្ឋកិច្ចធ្ងន់ធ្ងរ (Depression) គឺសម្គាល់ដំណើរថយក្រោយនៃសេដ្ឋកិច្ច និងការស្រុតចុះយ៉ាងទាបបំផុតនៃសេដ្ឋកិច្ច។ ការប្រែប្រួលនៃផលិតផលក្នុងស្រុកសរុប (GDP) បានធ្វើឱ្យមានការចាប់អារម្មណ៍ពីសាធារណជន ដោយសារតែវាធ្វើឱ្យមានបម្រែមប្រួលកត្តាមីក្រូសេដ្ឋកិច្ចដទៃទៀត។ គេកត់សម្គាល់ថា បម្រែបម្រួលផលិតផលក្នុងស្រុកសរុប (GDP) មានឥទ្ធិពលទៅលើអនិកម្មភាព អតិផរណា ឱនភាពថវិកា និងនយោបាយរដ្ឋាភិបាល ដោយសារតែការយល់ដឹងអំពីឫសគល់ទាំងនេះ យើងនឹងមានលទ្ធភាពសិក្សាអំពីនយោបាយសម្រាប់ដោះស្រាយបញ្ហាម៉ាក្រូសេដ្ឋកិច្ច។

## ៥.១២- **ការវាស់អតិផរណា** (Measurement inflation)

១. អ្វីទៅជាអតិផរណា? (What is Inflation?)

មិនមែនសុទ្ធតែកម្រិតថ្លៃកើតឡើង បង្កើតជាអតិផរណានោះទេ។ កម្រិតថ្លៃនៃទំនិញ និងសេវាណានោះ ត្រូវបានកំណត់ដោយវិធីផ្សេងៗ។ ក្នុងទីផ្សារប្រកួតប្រជែងការជះឥទ្ធិពលទៅវិញទៅមកនៃអ្នកទិញ និងអ្នកលក់ជាច្រើន ដែលកំណត់បានកម្រិតថ្លៃ។ ក្នុងទីផ្សារប្រកួតប្រជែងមិនពេញលេញថ្លៃត្រូវបានកំណត់ដោយការសម្រេចចិត្តរបស់ផលិតករ។ ចំណែកឯក្នុងម៉ាក្រូសេដ្ឋកិច្ចថ្លៃផ្លាស់ប្តូរជាបន្តបន្ទាប់ ក្នុងខណៈពេលដែលទីផ្សារកែតម្រូវចំពោះការផ្លាស់ប្តូរលក្ខខណ្ឌទាំងឡាយ។ ជាការពិតណាស់មិនមែនការកើនឡើងនៃថ្លៃបូកបញ្ចូលគ្នាជាអតិផរណាទេ ពីព្រោះការកើនកម្រិតថ្លៃនៃទំនិញណាមួយនោះវាអាច ឬមិនអាចជាចំណែកនៃអតិផរណា។ ដូច្នេះ *អតិផរណាជាអ្វី?*

អតិផរណា (inflation) គឺជាការកើននៃកម្រិតថ្លៃរួម (Overall price level) នៅអំឡុងពេលណាមួយ។ វាកើតឡើងពេលដែលថ្លៃជាច្រើនកើនព្រមគ្នា។ បរិត្តផរណា (deflation) គឺជាការធ្លាក់ចុះនៃកម្រិតថ្លៃរួម។ វាកើតឡើងពេលថ្លៃជាច្រើនធ្លាក់ចុះរួមគ្នា ឬព្រមគ្នា។ វិធីមួយដើម្បីវាស់ការប្រែប្រួលនៃកម្រិតថ្លៃរួម គឺគណនាសន្ទស្សន៍ថ្លៃ (Price Index)។

២. សន្ទស្សន៍ថ្លៃ (Price Index)

សន្ទស្សន៍ថ្លៃ គឺជាផលធៀបរវាងថ្លៃនៃសំណុំទំនិញមួយក្នុងដំណាក់កាលណាមួយនោះជាមួយថ្លៃនៃសំណុំទំនិញនោះ នៅដំណាក់កាលគោល (Basic period) គុណនឹង ១០០។ សន្ទស្សន៍បង្ហាញឱ្យយើងឃើញថា តើថ្លៃមធ្យមនៃសំណុំទំនិញផ្លាស់ប្តូរយ៉ាងណាខ្លះពីពេលមួយ?

មានសន្ទស្សន៍ថ្លៃបីប្រភេទ ៖

- ផលិតផលក្នុងស្រុកសរុបបរិត្តផរណា (GDP Deflator)៖ ផលិតផលក្នុងស្រុកសរុបបរិត្តផរណា គឺជាផលធៀបនៃផលិតផលសរុបក្នុងស្រុកមានតែនាម និងផលិតផលសរុបក្នុងស្រុកពិតនៅឆ្នាំណាមួយនោះ។
- សន្ទស្សន៍ថ្លៃប្រើប្រាស់ (Consumer price:CPI)៖ សន្ទស្សន៍ថ្លៃប្រើប្រាស់វាស់តម្លៃនៃការទិញទំនិញ និងសេវាក្នុងទីផ្សារមួយ។
- សន្ទស្សន៍ថ្លៃផលិតករ (Producer Price Index:PPI)
  សន្ទស្សន៍ថ្លៃផលិតករ គឺជាសន្ទស្សន៍ថ្លៃទីបី ដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ ក៏ដូចជា សន្ទស្សន៍ថ្លៃ (CPI) ដែរ។ សន្ទស្សន៍ថ្លៃផលិតករ (PPI) គឺជាខ្នាត់វាស់តម្លៃទំនិញ និងសេវាក្នុងទីផ្សារណាមួយ។ វាវាស់ថ្លៃដែលផលិតករទទួលបាន ចំពោះផលិតផលនៅគ្រប់ដំណាក់កាលក្នុងអភិក្រមផលិតកម្មមិនមែនត្រឹមតែទំនិញ និងសេវាចុងក្រោយទេ។

៣. បច្ច័យនៃអតិផរណា (Effects of Inflation)

៣ក. អតិផរណាផ្លាស់ប្តូរបែងចែកចំណូល (Inflation change distribute of income)

សំណួរដែលសួរថា *តើយើងទទួលបានចំណេញ ឬខាតក្នុងពេលមានអតិផរណា? តើចំណូលរបស់យើងកើនលឿនជាង ឬក៏យឺតជាងថ្លៃនៃទំនិញដែលយើងទិញ?* ជាការពិតណាស់ប្រសិនបើចំណូលរបស់យើងថេរ ហើយថ្លៃវាកើនឡើងនោះ លទ្ធភាពទិញទំនិញ និងសេវាកម្មរបស់យើងមានការធ្លាក់ចុះ។ *តើអ្នកណាជាអ្នកមានចំណូលថេរ?* ជាទូទៅ អ្នកចូលនិវត្តន៍ជា

ច្រើនរស់នៅដោយសារតែប្រាក់ចូលនិវត្តន៍ប្រចាំខែថេរ។ ប៉ុន្តែមានប្រទេសខ្លះ ក៏បានគិតអតិផរណាចូលទៅក្នុងប្រាក់និវត្តន៍នេះដែរ។ នេះជាប្រាក់ឧបត្ថម្ភ ដែលត្រូវបានគិតបញ្ចូលជាស្វ័យប្រវត្តិ ពេលដែលកម្រិតថ្លៃទូទៅកើនឡើង។ ឧទាហរណ៍៖ ប្រសិនបើថ្លៃទំនិញកើនឡើង ១០ភាគរយ ប្រាក់ឧបត្ថម្ភក៏កើនឡើង ១០ភាគរយដែរ។

៣ខ. ម្ចាស់បំណុល និងកូនបំណុល (Creditor and Dector)

អ្នកដឹងហើយថា កូនបំណុលទទួលផលប្រយោជន៍ពីការខ្ចីប្រាក់នៅពេលមានអតិផរណា។ ជាការពិតណាស់ ប្រសិនបើខ្ញុំឱ្យអ្នកខ្ចី ១០០រៀល ដោយសងវិញក្នុងរយៈពេល ១ឆ្នាំ ហើយថ្លៃកើនឡើង ១០% ក្នុងចន្លោះពេលនោះប្រាក់ដែលខ្ញុំឱ្យអ្នកខ្ចីពេលទទួលបានតិចជាង ១០០រៀល ដូច្នេះ៖

Real interest rate = Nominal interest rate – Inflation

ប្រសិនបើយើងប្រមើលមើលឃើញថា ថ្លៃកើនឡើង ១០% ការពិតណាស់ ខ្ញុំដាក់បញ្ហានេះទៅក្នុងការពិនិត្យមើលទំនាក់ទំនងដែលខ្ញុំធ្វើឱ្យអ្នកពេលនោះ ខ្ញុំនឹងគិតឱ្យអ្នកនូវអត្រាការប្រាក់ណាមួយដែលអាចទប់ទល់ទៅនឹងការធ្លាក់ចុះថ្លៃ ដោយយោងទៅលើការ ប្រមើលមើលអតិផរណា។ ឧទាហរណ៍៖ ប្រសិនបើយើងឯកភាពលើអត្រាការប្រាក់ ១៥% ដូច្នេះនៅចុងឆ្នាំអ្នកសងវិញ ១១៥។ ភាពខុសគ្នារវាងអត្រាការប្រាក់ដែលបានខ្ចី និងអតិផរណា គឺអត្រាការប្រាក់ពិត (real interest rate)។ តាមការទំនាក់ទំនងរបស់យើងខ្ញុំនឹងទទួលបាននូវអត្រាការប្រាក់ពិត ៥% ដោយគិតពីអ្នកអត្រា ១៥% ខ្ញុំគ្មានបាត់បង់អ្វីដោយសារតែអតិផរណាទេ។ ចំពោះអតិផរណាដែលខ្ពស់ជាងការប្រាក់ដែលបានគិតអ្នកទទួលផលចំណេញ គឺកូនបំណុលចំណែកអតិផរណាទាបជាងការប្រាក់ដែលបានគិតអ្នកទទួលផលចំណេញ គឺម្ចាស់បំណុល។

៣គ. ភាពគ្មានប្រសិទ្ធភាព (Inefficiencies)

វានឹងមានការបាត់បង់ ទោះបីយើងបានប្រមើលមើលអតិផរណាក៏ដោយ បញ្ហាជាក់ស្តែងគឺជាការគិតគូរដែលត្រូវធ្វើឱ្យទាន់ពេល។ ក្នុងអំឡុងពេលដែលអតិផរណាកើនឡើងយ៉ាងឆាប់រហ័សនៅប្រទេសអូស្ត្រាលីនាទសវត្សរ៍ឆ្នាំ១៩៨០ ហើយម្ចាស់ហាងត្រូវតែគិត តម្លៃឡើងវិញយ៉ាងញឹកញាប់ ហើយបញ្ហានេះ ទាមទារពេលវេលាដើម្បីធ្វើឱ្យមានប្រសិទ្ធភាព។ បន្ថែមលើនេះទៀត បើសិនប្រជាជនគ្មានព័ត៌មានគ្រប់គ្រាន់ទេ ឬប្រសិនបើគេមិនយល់នូវអ្វីដែលកើតឡើងចំពោះថ្លៃទេនោះ គេនឹងជួបបញ្ហាក្នុងមុខរបរជំនួញរបស់ពួកគេ។

៣ឃ. ការប្រថុយប្រថានកើនឡើង និងកំណើនសេដ្ឋកិច្ចធ្លាក់ចុះ (Increase risk and slower economic growth)

ពេលដែលមិនបានប្រមើលមើលអតិផរណា នោះវានឹងមានការប្រថុយប្រថាននៃការធ្វើវិនិយោគក្នុងសេដ្ឋកិច្ច។ ដោយសារតែ មានភាពមិនច្បាស់លាស់នេះហើយ ដែលវិនិយោគស្ទាក់ស្ទើរក្នុងការដាក់ទុនវិនិយោគ និងការសន្យាធ្វើអ្វីមួយក្នុងរយៈពេលវែង។ ការវិនិយោគធ្លាក់ចុះហេតុនេះវាអាចធ្វើឱ្យកំណើនសេដ្ឋកិច្ចរយៈពេលវែងធ្លាក់ចុះផងដែរ។

៤. មូលហេតុទាំងឡាយនៃអតិផរណា៖ ( Basic causes of Inflation )

៤ក. អតិផរណាដោយសារថ្លៃ ( Inflation by price )

ការកើនឡើងជាបន្តបន្ទាប់នៃថ្លៃទំនិញមិនឈប់ឈរជាបាតុភូតអតិផរណា។ ជាទូទៅ វាជាបាតុភូតបន្តគ្នារវាងការកើនឡើងនូវថ្លៃរបស់កត្តាផលិតកម្មនានា។ ការកើនឡើងប្រាក់ខែរបស់បុគ្គលិក បានបង្កើតតម្រូវការថ្មីដែលជំរុញឱ្យមានការកើនឡើង តែការកើនឡើងប្រាក់ខែនេះ មិនមានការកើនឡើងប្រាក់ខែពិតនោះទេ បើកាលណាមានការកើនឡើងថ្លៃតាមទិសដៅសមាមាត្រគ្នានោះ។ បាតុភូតនេះ តម្រូវឱ្យកម្មករត្រូវទាមទារឱ្យមានការកើនឡើងជាបន្តទៀតនូវប្រាក់ខែទៀត។ ចំពោះកត្តាផលិតកម្មផ្សេងៗទៀត ដូចជាវត្ថុធាតុដើម និងអត្រាការប្រាក់កើនឡើងដូចគ្នានោះដែរ។ សោហ៊ុយហិរញ្ញវត្ថុជាបន្ទុកយ៉ាងធ្ងន់ធ្ងរ សម្រាប់សហគ្រាសក្នុងការធ្វើវិនិយោគទាំងនេះ ហើយផលិតផលមានការកើនឡើងជាលំដាប់ក្នុងអំឡុងពេលមួយនោះ។

៤ខ. អតិផរណាបណ្តាលមកពីតម្រូវការ ( Inflation by demand )

ការកើនឡើងនូវប្រាក់បៀវត្ស បានបង្កើតនូវតម្រូវការថ្មីលើទីផ្សារ។ ហើយវាបាននាំឱ្យមាននូវថ្លៃរបស់ទំនិញ និងជំរុញឱ្យមានការទាមទារឱ្យមានការតិតឡើងនូវប្រាក់ខែ ដើម្បីទូទាត់ឱ្យបានដូចពីមុន។

កំណើតតម្រូវការ → ការឡើងថ្លៃ → កំណើនផលទុន → កំណើនតម្រូវការ

៤គ. អតិផរណារូបិយវត្ថុ ( Monetary Inflation )

ហេតុការណ៍នេះ បានក្លាយជាច្បាប់ទៅហើយ បើកាលណាមានការកើនឡើងនូវថ្លៃ ខណៈពេលដែលបរិមាណតម្រូវការនៅដដែលនោះ បរិមាណតម្រូវការទៅសមាសភាពនឹងរូបិយវត្ថុសម្រាប់ចរាចរណ៍កើតមានជាមិនខាន។ បើកាលណាការកើនឡើងបរិមាណរូបិយវត្ថុក្នុងចរាចរពេលនោះថ្លៃរបស់រូបិយវត្ថុមានការធ្លាក់ចុះ ដោយសារការផ្គត់ផ្គង់ធំជាងតម្រូវការដែលធ្វើឱ្យមានការបាត់បង់អំណាចទិញរបស់វាចំពោះទំនិញជាទូទៅ។ ហេតុនេះ ត្រូវបានគេហៅថា *អតិផរណារូបិយវត្ថុ*។

តាមច្បាប់បរិមាណរូបិយវត្ថុ MV = P.Q, ដែល Q ទំហំនៃការលក់៖

P ថ្លៃទំនិញ ឬក៏កម្រិតថ្លៃទូទៅលើទីផ្សារ

M បរិមាណរូបិយវត្ថុក្នុងសារាចរណ៍

V ល្បឿនចរាចរណ៍

ដោយនៅក្នុងទ្រឹស្តីនេះ មានការលំបាកមួយចំនួនដូចជា *តើយើងអាចវាស់ល្បឿនចរាចរបានយ៉ាងណា?* ការវាស់វែងកម្រិតថ្លៃរួមរបស់ទំនិញយ៉ាងណានោះនៅក្នុងការអនុវត្តនេះ សូម្បីក្នុងទ្រឹស្តីក៏ជាការលំបាកដែរ ដែលត្រូវយកសន្ទស្សន៍ថ្លៃណានោះ។ ទ្រឹស្តីនេះក៏បានបង្កើតឡើងនូវសម្មតិកម្ម២ទៀត គឺល្បឿនរបស់រូបិយវត្ថុនៅថេរក្នុងរយៈពេលខ្លី និងចំនួនការលក់ដូរមិនមានការប្រែប្រួលទៅតាមថ្លៃនោះទេ។

ដូច្នេះ $\Delta P = (V.Q). \Delta M$

៥. ផលវិបាកនៃអតិផរណា ( Impact on Inflation )

៥ក. ផលវិបាកនៃរូបិយវត្ថុ ( Impact on Monetary )

ជាបឋមតួនាទីសំខាន់របស់ រូបិយវត្ថុមានបីគឺ៖

- ឧបករណ៍សម្រួលដល់ការដោះដូរ
- ឧបករណ៍ខ្នាត់រង្វាស់តម្លៃ
- ឧបករណ៍រក្សាតម្លៃ

កាលណាមានអតិផរណា បានធ្វើឱ្យវាមានការខូចខាតដល់តួនាទីទាំងបីនេះ ការបាត់បង់អំណាចទិញនៃរូបិយវត្ថុ ភ្នាក់ងារសេដ្ឋកិច្ច បានប្តូរវាឱ្យទៅជាទ្រព្យពិតនៅក្នុងដៃវិញ ដែលជាមូលហេតុនាំឱ្យរូបិយវត្ថុកាន់តែបាត់បង់នូវអំណាចទិញជាបន្តបន្ទាប់ទៅទៀត។

៥ខ. ផលវិបាកលើសកម្មភាពសេដ្ឋកិច្ច ( Impact on Activity Economy )

វាជាផលល្អ និងអាចជាផលអាក្រក់ សម្រាប់សហគ្រាសក្នុងការបណ្តាក់ទុនរកស៊ីដោយហេតុថាកាលណាមានអតិផរណានោះ សហគ្រាសប្រាកដជាមានភាពមិនច្បាស់លាស់ចំពោះការនាំចេញ និងនាំចូល។ អតិផរណា អាចមានផលប្រយោជន៍ចំពោះអ្នកនាំចេញសម្រាប់រយៈពេលខ្លី នេះក៏ដោយយើងមានប្រៀបខាងអត្រាប្តូរប្រាក់។ ចំពោះការនាំចូល អាចមានការរាំងស្ទះវិញ ដោយការនាំចូលពុំមានលទ្ធភាពគ្រប់គ្រាន់ សម្រាប់ការប្រកួតប្រជែងនោះទេ។

៥គ. ផលវិបាកនៃការបែងចែកទុន ( Impact on distribution capital )

ចំពោះសហគ្រាសដែលជំពាក់បំណុលគេអតិផរណាក៏ឱ្យអត្ថប្រយោជន៍ដែរ ដោយតម្លៃរូបិយវត្ថុធ្លាក់ចុះថ្លៃ ដែលជាមូលហេតុនាំឱ្យយើងឃើញថា ការទូទាត់សងនៅពេលនេះមានតម្លៃតិចជាងមានអតិផរណា តែចំពោះអ្នកមានបំណុលវិញព្រឹត្តិការណ៍វាជាដំណើរការអាក្រក់ទៅវិញ។

៦. គោលនយោបាយប្រឆាំង និងអតិផរណា ( Political protection inflation )

ដោយយើងសង្កេតទៅលើមូលហេតុនានានៃអតិផរណាពេលនោះ យើងអាចលើកឡើងនូវនយោបាយនានាដែលប្រឆាំង និងអតិផរណា ដូចជានយោបាយរូបិយវត្ថុ វាគឺជាឧបករណ៍គោលនយោបាយរបស់អាជ្ញាធររូបិយវត្ថុ ឬធនាគារកណ្តាល ដែលមានតួនាទីជាអ្នកអនុវត្ត និងការគ្រប់គ្រងបរិមាណសាច់ប្រាក់ក្នុងចរាចរនៅលើទីផ្សារ។ បើកាលណាមានចរាចរសាច់ប្រាក់ច្រើនពេកនោះ បានធ្វើឱ្យរូបិយវត្ថុត្រូវបាត់បង់នូវតម្លៃរបស់វា។

# ជំពូកទី ៦

# គោលនយោបាយរូបិយវត្ថុ

# MONETARY POLICY

## ៦.១- សេចក្តីផ្តើមនៃគោលនយោបាយរូបិយវត្ថុ ( Introduction to monetary policy )

### ៦.១.១- មុខងារចម្បងរបស់ធនាគារកណ្តាល ( Main function of CB )

តារាង៖ មុខងាររបស់ធនាគារកណ្តាល

| |
|---|
| ការបង្កើត និងអនុវត្តគោលនយោបាយរូបិយវត្ថុ ( សំដៅសម្រេច និងរក្សាស្ថិរភាពថ្លៃ ) |
| ការបង្កើតក្របខ័ណ្ឌគោលនយោបាយរូបិយវត្ថុ |
| ឥទ្ធិពលកម្រិតអត្រាការប្រាក់ ( តាមរយៈការគ្រប់គ្រងសាច់ប្រាក់ងាយស្រួលរបស់ធនាគារ ) |
| ប្រតិបត្តិការទីផ្សារបើកចំហ |
| ធនាគារិក និងជាទីប្រឹក្សារដ្ឋាភិបាល |
| ធនាគារិករបស់រដ្ឋាភិបាល |
| ការគ្រប់គ្រងបំណុលសាធារណៈ |
| រដ្ឋបាលនៃការគ្រប់គ្រងការផ្លាស់ប្តូរ |
| ការគ្រប់គ្រងប្រព័ន្ធរូបិយវត្ថុ និងធនាគារ |
| អ្នកឱ្យខ្ចីចុងក្រោយ ( ចំណាំ៖ មិនមែនមុខងារគោលនយោបាយរូបិយវត្ថុទេ ) |
| ការគ្រប់គ្រងរូបិយប័ណ្ណ ( ក្រដាសប្រាក់ និងកាស ) |
| ធនាគារិកទៅក្នុងវិស័យធនាគារឯកជន |
| ការទូទាត់សំណងតាមឥណទេយ្យអន្តរធនាគារ |
| ការគ្រប់គ្រងធនាគារ |
| ការត្រួតពិនិត្យប្រព័ន្ធទូទាត់ |
| ការគ្រប់គ្រងរូបិយវត្ថុបម្រុងជាមាស និងប្តូរប្រាក់បរទេស |
| ការអភិវឌ្ឍទីផ្សារបំណុល |
| ការផ្តល់សេវាស្ថិតិ និងសេដ្ឋកិច្ច |
| ការផ្តល់សេវា និងប្រព័ន្ធគាំទ្រដល់សាជីវកម្ម |

តារាងទី១ ខាងលើបង្ហាញពីក្របខ័ណ្ឌនៃមុខងាររបស់ធនាគារកណ្តាល។ សម្រាប់ការសិក្សាលើមុខងារសំខាន់ចុងក្រោយនៃសៀវភៅនេះ គឺគោលនយោបាយរូបិយវត្ថុ។ សៀវភៅនេះ បានបង្ហាញពីការវាស់វែងរូបិយវត្ថុ ការបង្កើតរូបិយវត្ថុ ក្របខ័ណ្ឌនៃគោលនយោបាយរូបិយវត្ថុ និងបញ្ហាពាក់ព័ន្ធដទៃ

ផ្សេងទៀត។ ផ្នែកទាំងនេះ គឺជាសាវតាផ្នែកចុងក្រោយនៃការសិក្សាអំពីគោលនយោបាយរូបិយវត្ថុតាមរយៈគំរូម៉ូដែលទាំងបី បន្ទាប់ពីមានបទបង្ហាញដ៏ខ្លីមួយស្តីអំពីយន្តការបញ្ចូលគោលនយោបាយរូបិយវត្ថុពី KIR នៃកម្រិតអតិផរណា។

**គំរូម៉ូដែលទាំងនេះរួមមាន៖**

- គំរូម៉ូដែលគោលនយោបាយរូបិយវត្ថុ
- គំរូម៉ូដែលគោលនយោបាយរូបិយវត្ថុ៖ អត្រាការប្រាក់ និងអត្រាអតិផរណា

គោលនយោបាយរូបិយវត្ថុ និងគោលនយោបាយសារពើពន្ធ គឺជាគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចរបស់រដ្ឋាភិបាលបានអនុវត្ត ដើម្បីរក្សាកំណើនសេដ្ឋកិច្ចសម្រាប់រយៈពេលមធ្យម ដោយរក្សាកម្រិតអត្រាអតិផរណាឱ្យនៅកម្រិតទាបបំផុត។ តើអ្វីជាខ្លឹមសារនៃគោលនយោបាយរូបិយវត្ថុ និងគោលនយោបាយសារពើពន្ធ?

## ៦.១.២- តើអ្វីជាគោលនយោបាយរូបិយវត្ថុ? ( What is monetary policy? )

គោលនយោបាយរូបិយវត្ថុ គឺជាដំណើរការគ្រប់គ្រងបរិមាណផ្គត់ផ្គង់រូបិយវត្ថុសរុបនៅក្នុងសេដ្ឋកិច្ច ដើម្បីសម្រេចនូវគោលដៅម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ ដូចជាការបន្ទាបអត្រាអតិផរណា ការបង្កើននិកម្មភាព និងកំណើនសេដ្ឋកិច្ច។ មួយវិញទៀត គោលដៅគោលនយោបាយរូបិយវត្ថុ គឺការបង្កើនបរិមាណរូបិយវត្ថុ ដើម្បីឆ្លើយតបនឹងតម្រូវការរូបិយវត្ថុសរុប ដែលមានការកើនឡើងតាមរយៈកំណើនសេដ្ឋកិច្ច។ ក្រៅពីនេះ គោលនយោបាយរូបិយវត្ថុក៏ត្រូវមានប្រតិកម្មជាមួយនឹងកត្តាដទៃទៀតដូចជាអត្រាការប្រាក់ល្បឿនបង្វិលជុំ អត្រាប្តូរប្រាក់ បរិមាណរូបិយវត្ថុ តម្រូវការ សេដ្ឋកិច្ច គុណភាពនៃប្រាក់កម្ចី ស្ថានភាពទីផ្សារមូលប័ត្រ និងលំហូរមូលនិធិឆ្លងដែន។ល។

**គោលនយោបាយរូបិយវត្ថុ មាន២ប្រភេទគឺ៖**

១- គោលនយោបាយរូបិយវត្ថុពង្រីកសំដៅលើការបង្កើនបរិមាណការផ្គត់ផ្គង់រូបិយវត្ថុសរុប

២- គោលនយោបាយរូបិយវត្ថុបង្រួមសំដៅលើការបន្ថយបរិមាណការផ្គត់ផ្គង់រូបិយវត្ថុសរុប

ធនាគារកណ្តាល ជាអ្នកចាប់ផ្តើមធ្វើយុទ្ធនាការនៃប្រាក់បញ្ញើ ដើម្បីឱ្យមានកម្រិតលំហូររូបិយវត្ថុនៅលើទីផ្សារ។ នៅពេលដែលរដ្ឋាភិបាល គាត់ត្រូវការមូលនិធិក្នុងគោលបំណង ដើម្បីដោះស្រាយបញ្ហាសេដ្ឋកិច្ច។ ធនាគារកណ្តាល បានដើរតួនាទីជាអ្នកផ្តល់រូបិយវត្ថុ ឬបោះសញ្ញាប័ណ្ណ (Bond) លក់នៅលើទីផ្សារក្នុងគោលបំណងប្រមូលយករូបិយវត្ថុ ដើម្បីផ្គត់ផ្គង់ឱ្យរដ្ឋាភិបាលក្នុងគោលដៅពង្រីកការវិនិ យោគទុន។ ដូចនេះ ដើម្បីដោះស្រាយនូវបញ្ហានេះ ធនាគារកណ្តាលខ្លួនឯងផ្ទាល់គួរគិតពិចារណាឱ្យបានម៉ត់ចត់ ដើម្បីបញ្ចៀសនូវអតិផរណាដែលបានកើតមានឡើងដោយប្រការណាមួយ។

ការបង្កើនប្រាក់បញ្ញើធនាគារ គឺជានីតិវិធីមួយធ្វើឱ្យមានចលនារូបិយវត្ថុ។ ការទទួលបញ្ញើសាច់ប្រាក់ ឬតាមរយៈមូលប្បទានប័ត្រ ដែលកត្តាទាំងនេះជាយុទ្ធសាស្រ្តមួយរបស់ធនាគារកណ្តាល ដើម្បីបង្កើនបរិមាណរូបិយវត្ថុ ដោយផ្តល់នូវការលើកទឹកចិត្តដល់ម្ចាស់បញ្ញើតាមរយៈអត្រាការប្រាក់។ ដោយសារតែការជឿទុកចិត្តរបស់ធនាគារម្ចាស់ប្រាក់បញ្ញើមិនទុកលុយចោលដោយអត់មានប្រយោជន៍ទេ វា

ជាមូលហេតុនាំឱ្យរូបិយវត្ថុមិនស្ថិតនៅក្រៅសៀគ្វីសេដ្ឋកិច្ច។ យើងឃើញថាដោយសារអត្រាការប្រាក់ និងបរិមាណរូបិយវត្ថុ ដែលធ្វើឱ្យងាយស្រួលបម្រែបម្រួលជាអវិជ្ជមានជាមួយការវិនិយោគទុន ដូច្នេះវាអាចជះឥទ្ធិពលដល់ការវិនិយោគទុន។ ការចំណាយលើវិនិយោគទុននឹងថយចុះនៅពេលដែលអត្រាការប្រាក់កើនឡើង។ ផ្ទុយមកវិញ សហគ្រាសនឹងខ្ចីប្រាក់ឱ្យបានកាន់តែច្រើន ដើម្បីវិនិយោគនៅពេលដែលអត្រាការប្រាក់ថយចុះ។

ទន្ទឹមនឹងនេះ ជាធម្មតាធនាគារជាអ្នកទទួលបានប្រាក់បញ្ញើ និងជាអ្នកឱ្យខ្ចីក្នុងគោលដៅនយោបាយម៉ាក្រូសេដ្ឋកិច្ចរបស់ខ្លួន។ ការវិនិយោគទុននឹងកើនឡើងនៅពេលដែលគេទទួលបានប្រាក់កម្ចីយ៉ាងច្រើនពីធនាគារក្នុងគោលបំណងពង្រីកការវិនិយោគទុនឱ្យបានច្រើន។

ឧទាហរណ៍៖ នៅសហរដ្ឋអាម៉េរិកឆ្នាំ ១៩៩១ អត្រាការប្រាក់ធ្លាក់ចុះ ប៉ុន្តែធនាគារមិនចង់មានប្រាក់កម្ចី ដោយសារតែមូលហេតុគឺថាធនាគារមានការឱ្យខ្ចីច្រើន ប៉ុន្តែមិនបានទូទាត់សងនៅចុងទសវត្សរ៍ទី៨០។ ប៉ុន្តែធនាគារចង់ឱ្យកម្ចីទៅកាន់រដ្ឋាភិបាលអាម៉េរិក ពោលគឺទិញប័ណ្ណរតនាគាររបស់រដ្ឋាភិបាល។ ការឱ្យខ្ចីទៅរដ្ឋាភិបាលជាកម្ចីមួយដែលមានសុវត្ថិភាព ពីព្រោះរដ្ឋាភិបាលអាម៉េរិកតែងតែសងបំណុលរបស់ខ្លួន។ ក្នុងឆ្នាំ១៩៩២ នៅពេលដែលអត្រាការប្រាក់ធ្លាក់ចុះជាបន្តបន្ទាប់ទៀត នៅពេលនោះយើងឃើញថា ផ្នែកឯកជននឹងកើនឡើងទៅវិញ។

សរុបជារួម យើងនឹងសិក្សាអំពីការលូតលាស់នៃសេដ្ឋកិច្ច និងការប្រែប្រួលនៃផលិតផលសរុបក្នុងស្រុក (GDP) ព្រមទាំងវដ្តនៃសេដ្ឋកិច្ច។ យើងចង់ដឹង ថាតើការធ្លាក់ចុះនៃសេដ្ឋកិច្ចមានផលប៉ះពាល់ដល់សង្គមយ៉ាងណា? ដូចជាអនិកម្មភាព អតិផរណា ស្ថានភាពថវិការ (Budget statut) និងស្ថិរភាពសង្គម (Social stability)។

### ៦.១.៣- តើអ្វីជាគោលនយោបាយសារពើពន្ធ? (what is fiscal policy?)

រដ្ឋាភិបាលបណ្តាប្រទេសនានាលើពិភពលោកត្រូវការប្រាក់ចំណូលចាំបាច់ ដើម្បីប្រើប្រាស់ក្នុងការដឹកនាំគ្រប់គ្រងអភិវឌ្ឍប្រទេសជាតិឱ្យមាន វិបុលភាព និងវឌ្ឍនភាព។ តើអ្វីជាលទ្ធភាពក្នុងការរកចំណូលចូលថវិកាជាតិ ដែលរដ្ឋាភិបាលអាចប្រតិបត្តិការបាន? តើអ្វីជាប្រសិទ្ធភាពនៃការចំណាយរបស់រដ្ឋាភិបាល? តើត្រូវមានប្រតិបត្តិការចំណូលចំណាយបែបណា ដើម្បីធានាបានការលូតលាស់របស់ប្រទេសជាតិ? ចម្លើយ គឺមានចែងក្នុងគោលនយោបាយសំខាន់ៗមួយចំនួន ក្នុងចំណោមគោលនយោបាយនានារបស់រដ្ឋាភិបាល។ ក្នុងនោះរួមមាន គោលនយោបាយថវិកា គោលនយោបាយរូបិយវត្ថុ គោលនយោបាយសារពើពន្ធ និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈជាដើម។

ទន្ទឹមនឹងនេះ គោលនយោបាយសារពើពន្ធ គឺសំដៅលើការយកពន្ធ និងវិធីសាស្ត្រកៀរគរចំណូលផ្សេងៗទៀត និងការចំណាយរបស់រដ្ឋាភិបាល ដើម្បីធ្វើការបែងចែកធនធានកម្រសេដ្ឋកិច្ចនៅក្នុងគោលបំណងជំរុញឱ្យមានកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងសមធម៌។ ហេតុដូច្នេះ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពគោលនយោបាយសារពើពន្ធ រដ្ឋាភិបាលត្រូវតែអនុវត្តសកម្មភាពសំខាន់ៗ មានដូចជា៖

(១)- ប្រសិទ្ធភាពនៃការគ្រប់គ្រង និងកៀរគរចំណូល និង

(២)- ការធ្វើវិចារណកម្មលើចំណាយ និងបែងចែកចំណាយថវិការវាងការប្រើប្រាស់ និងការវិនិយោគសាធារណៈឱ្យបានសមស្រប។

ក្នុងនោះដែរ រដ្ឋាភិបាលបណ្តាប្រទេសនីមួយៗ មានគោលដៅជាគោលការណ៍រួមចំនួនបួន ដើម្បីសម្រេចឱ្យបាននូវគោលបំណងសេដ្ឋកិច្ចគឺៈ

១-ការបែងចែកធនធាន

២-ស្ថិរភាពរូបនីយកម្ម

៣-កំណើន

៤-ការបែងចែកនៃប្រាក់ចំណូលនៃទ្រព្យសម្បត្តិឱ្យស្មើគ្នា។

ដូចនេះ គោលនយោបាយសារពើពន្ធ ក្រៅពីកម្រិតពន្ធ និងការចំណាយរបស់រដ្ឋាភិបាល។ គោលនយោបាយសារពើពន្ធ ត្រូវបានដើរតួនាទីយ៉ាងសំខាន់ក្នុងការបែងចែកកម្រិតធនធានកម្រសេដ្ឋកិច្ច និងជំរុញសង្វាក់ផលិតកម្មមានការកើន ឬថយចុះផងដែរ។ ហេតុដូច្នេះ គោលនយោបាយសារពើពន្ធមានទំនាក់ទំនងនឹងការប្រើប្រាស់របស់គ្រួសារ និងការចំណាយរបស់រដ្ឋាភិបាល ការកម្រិតពន្ធ និងការខ្ចីប្រាក់ ដែលជាកត្តាជះឥទ្ធិពលលើកម្រិតកំណើនសេដ្ឋកិច្ចតម្រូវការសរុប នៃកម្រិតផលិតផលជាតិសរុបសមីការៈ Y=AD=C+I+G+NX និងអត្រាអនិកម្មភាព ជាពិសេសដំណើរការលូតលាស់ពាណិជ្ជកម្មអន្តរជាតិ។ គោលនយោបាយសារពើពន្ធ ក៏ត្រូវបានគេប្រើដើម្បីធ្វើការផ្លាស់ប្តូរម៉ូដែលនៃការចំណាយរបស់រដ្ឋាភិបាលលើកត្តាផលិតកម្ម។ គោលនយោបាយសារពើពន្ធមានន័យថា ការបែងចែកប្រាក់ចំណូល និងទ្រព្យសម្បត្តិជាតិឡើងវិញរបស់រដ្ឋាភិបាល ដែលអាចសម្រេចបានតាមរយៈការផ្លាស់ប្តូរអត្រាពន្ធលើប្រាក់ចំណូល ឬទ្រព្យសម្បត្តិខុសគ្នា។ ពេលគឺគោលនយោបាយសារពើពន្ធក៏ជាយន្តការអន្តរាគមន៍រដ្ឋាភិបាល ចំពោះសេដ្ឋកិច្ចខ្នាតតូច (Microeconomic) ដើម្បីកែលម្អការប្រកួតប្រជែងសេដ្ឋកិច្ចទីផ្សារសេរី។ ទន្ទឹមនឹងនេះដែរ ការផ្លាស់ប្តូរគោលនយោបាយសារពើពន្ធក៏មានផលប៉ះពាល់លើតម្រូវការសរុប (aggregate demand) និងការផ្គត់ផ្គង់សរុប (aggregate supply) ផងដែរ។

តាមរយៈវិទ្យាសាស្ត្រសេដ្ឋកិច្ច គោលនយោបាយសារពើពន្ធ គឺជាការប្រើប្រាស់ចំណូល និងការចំណាយរបស់រដ្ឋាភិបាល ដើម្បីធ្វើឱ្យមានឥទ្ធិពលលើសកម្មភាពសេដ្ឋកិច្ចទាំងមូល។ ដូចនេះ គោលនយោបាយសារពើពន្ធ គឺជាផ្នែកមួយនៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចជាតិ ដើម្បីព្យាយាមរក្សាស្ថិរភាពកំណើនសេដ្ឋកិច្ចរយៈពេលវែង តាមរយៈការគ្រប់គ្រងអត្រាការប្រាក់ និងការផ្គត់ផ្គង់រូបិយវត្ថុ។ ក្នុងក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចជាតិ ដើម្បីរក្សាស្ថិរភាពលំនឹងកំណើនសេដ្ឋកិច្ចរយៈពេលវែង។ ដូចនេះ រដ្ឋាភិបាលប្រទេសនីមួយៗតែងតែប្រើនូវគោលនយោបាយរូបិយវត្ថុ និងគោលនយោបាយសារពើពន្ធ។ ក្នុងករណីសកម្មភាពសេដ្ឋកិច្ចធ្លាក់ចុះ ឬមានការរីកចម្រើនតិចតួចនោះ រដ្ឋាភិបាលប្រើនូវគោលនយោបាយសារពើពន្ធ។ ចំពោះ សកម្មភាពកំណើនសេដ្ឋកិច្ចខ្លាំងក្លា ដែលអាចធ្វើឱ្យមានកម្រិតអតិផរណាតម្រូវការកើនខ្ពស់នេះ អាចប្រើគោលនយោបាយរូបិយវត្ថុជំនួសវិញ។

ក្នុងទ្រឹស្តីសេដ្ឋកិច្ច គោលនយោបាយសារពើពន្ធគឺជាទ្រឹស្តីជំរុញឱ្យមានចរន្តសេដ្ឋកិច្ចខាងផ្នែកតម្រូវការជាជាងខាងផ្នែកផ្គត់ផ្គង់ក្នុងប្រព័ន្ធសេដ្ឋកិច្ចមានពីរផ្នែកសំខាន់គឺ៖

(១)- ផ្នែកតម្រូវការសរុប និង

(២)- ផ្នែកការផ្គត់ផ្គង់សរុប។

ពាក្យថា "គោលនយោបាយសារពើពន្ធ" ពុំមែនគ្រាន់តែជាចលករពន្ធតែមួយផ្នែកប៉ុណ្ណោះទេ។ ប៉ុន្តែក៏ជាចលករជំរុញកំណើនសេដ្ឋកិច្ចផងដែរ។ រដ្ឋាភិបាលប្រទេសនីមួយៗ មានគម្រោងបង្កើនការចំណាយថវិកាបន្ថែម ដើម្បីធ្វើឱ្យមានកំណើនសេដ្ឋកិច្ច ពីព្រោះបង្កើនការចំណាយរបស់រដ្ឋាភិបាល (G↑) នឹងជំរុញមានការកើនតម្រូវការសរុប (AD↑) តាមរយៈប្រាក់ចំណូល កើនឡើងនាំឱ្យកើនចំណាយលើការប្រើប្រាស់ (C↑) ឬប្រាក់សន្សំរបស់គ្រួសារ (S↑)។ ជាពិសេស ការចំណាយលើសេវាសាធារណៈរបស់រដ្ឋាភិបាល ដែលជាចលករជំរុញមានតម្រូវការសរុបកើន (AD↑) និងកម្លាំងចលករជំរុញឱ្យមានការវិនិយោគឯកជនកើនឡើង (I↑) និងជំរុញការផ្គត់ផ្គង់សរុបកើនឡើង (AS↑) ផងដែរ។

ទន្ទឹមនេះ គោលនយោបាយសារពើពន្ធមានយន្តការសំខាន់ៗ ដូចជា៖

- ការចំណាយរបស់រដ្ឋាភិបាល (Government Spending) និង
- ការកម្រិតពន្ធ (Taxes)
- ផ្គួបផ្គាបញ្ចូលគ្នាទាំងពីរ (Combinated with both)

ចំពោះគោលនយោបាយរូបិយវត្ថុវិញ មានយន្តការសំខាន់ៗដូចជា៖

- ការកម្រិតអត្រាការប្រាក់ (Interest) និង
- ការផ្គត់ផ្គង់រូបិយវត្ថុ ( Money supply)
- ផ្គួបផ្គាបញ្ចូលគ្នាទាំងពីរ (Combinated with both)

ដូច្នេះ គោលនយោបាយរបស់រដ្ឋាភិបាល គឺជាគោលនយោបាយថវិកាជាតិ ឬហៅថាគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចរបស់ជាតិ ដើម្បីជំរុញឱ្យមាន ស្ថិរភាពថ្លៃ អត្រាអនិកម្មភាព និងរក្សាកំណើនសេដ្ឋកិច្ចរយៈពេលវែង។ ដូចនេះ ដើម្បីអនុវត្តគោលនយោបាយខាងលើនេះចាំបាច់ត្រូវប្រើម៉ូដែលម៉ាក្រូសេដ្ឋកិច្ច។ *តើអ្វីជាគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច?*

ម៉ាក្រូសេដ្ឋកិច្ច គឺការសិក្សាផ្តោតទៅលើសេដ្ឋកិច្ចរបស់ប្រទេសជាតិទាំងមូល។ រួមមានការសិក្សាអំពីទិន្នផលជាតិសរុប អត្រានិកម្មភាព ដើម្បីឱ្យយល់ពីសកម្មភាពសេដ្ឋកិច្ចជាតិ។ ដូចនេះ ទ្រឹស្តីម៉ាក្រូសេដ្ឋកិច្ចបានបង្កើតម៉ូដែលនេះ ដើម្បីពន្យល់អំពីចលករសេដ្ឋកិច្ច៖

- ចំណូលជាតិ (National income)
- ផលិតផល (Output)
- ការប្រើប្រាស់ (Consumption)
- អត្រាអនិកម្មភាព (Unemployement rate)
- អតិផរណា (Inflation)

- ការសន្សំ (Saving)
- ការវិនិយោគ (Investment)
- ពាណិជ្ជកម្មអន្តរជាតិ (International Trade) និង
- ហិរញ្ញវត្ថុអន្តរជាតិ (International Finance)។

ដូចនេះ ផលិតផលក្នុងស្រុកសរុប (GDP) គឺជាចំណូលជាតិសរុបនៅក្នុងសកម្មភាពសេដ្ឋកិច្ច និងបរិមាណចំណាយសរុបលើទំនិញ និងសេវារបស់សេដ្ឋកិច្ច។ មានសមាសធាតុចំណាយចំនួន៤ យ៉ាងដូចជា៖ ចំណាយលើការប្រើប្រាស់របស់គ្រួសារ (C) ចំណាយលើការវិនិយោគ (I) ចំណាយរបស់រដ្ឋាភិបាល (G) និងការនាំចេញសុទ្ធ (NX) យើងអាចតាងសមីការសេដ្ឋកិច្ចគឺ៖ Y=GDP=C+I+G+NX ក្នុងបរិបទសេដ្ឋកិច្ចបើកចំហមានទំនាក់ទំនងនឹងពាណិជ្ជកម្មអន្តរជាតិ។ ករណីសេដ្ឋកិច្ចបិទមិនមានទំនាក់ទំនងនឹងពាណិជ្ជកម្មអន្តរជាតិ ឬមិនពាក់ព័ន្ធការខ្ចី និងការផ្តល់កម្ចីជាអន្តរជាតិ សមីការសេដ្ឋកិច្ចគឺ Y=GDP=C+I+G មានន័យថាការនាំចេញស្មើនឹងសូន្យ។

ជាលទ្ធផល គោលនយោបាយសារពើពន្ធ គឺដើម្បីគ្រប់គ្រងប្រាក់ចំណូល និងការចំណាយរបស់រដ្ឋាភិបាលជាចាំបាច់ដើម្បីប្រើប្រាស់ក្នុងការដឹកនាំ និងគ្រប់គ្រងអភិវឌ្ឍប្រទេសជាតិឱ្យមានវិបុលភាព និងវឌ្ឍនភាព។ គោលនយោបាយសារពើពន្ធ មានមុខងារបែងចែកថវិកាជាតិសម្រាប់ផ្តល់នូវទំនិញ និងសេវាដល់សង្គមជាតិទាំងមូល រួមមានការរៀបចំគោលនយោបាយថវិកា ដើម្បីធ្វើការបែងចែកធនធានសេដ្ឋកិច្ចប្រកបដោយ "សមភាព" និង "ការកែតម្រូវ" វិភាជប្រាក់ចំណូលជាតិ និងទ្រព្យសម្បត្តិប្រជាជាតិ។ ម្យ៉ាងវិញទៀត ដើម្បីរក្សានូវស្ថិរភាពនៃគោលនយោបាយថវិកាជាតិ និកម្មភាពពេញលេញ ស្ថិរភាពថ្លៃ និងអត្រាកំណើនសេដ្ឋកិច្ចឱ្យសមស្រប ដោយមិនមានផលប៉ះពាល់ដល់វិស័យពាណិជ្ជកម្ម និងតុល្យភាពជញ្ជីងទូទាត់ ដោយសារតែគោលនយោបាយសារពើពន្ធរបស់រដ្ឋាភិបាល។ ការផ្លាស់ប្តូរគោលនយោបាយសារពើពន្ធ និងសមាសភាពផ្សេងៗទៀតនៃចលករសេដ្ឋកិច្ច អាចមានការប្រែប្រួលចំណូលពន្ធ និងចំណាយសាធារណៈរដ្ឋាភិបាល។ គោលនយោបាយសារពើពន្ធ បានជះឥទ្ធិពលលើសកម្មភាពសេដ្ឋកិច្ច មានដូចជា៖ ការចំណាយលើការប្រើប្រាស់របស់គ្រួសារ និងការចំណាយរបស់រដ្ឋាភិបាល ការកម្រិតពន្ធ និងការខ្ចីប្រាក់។ ជាពិសេសកំណើនសេដ្ឋកិច្ចពាក់ព័ន្ធនឹងតម្រូវការសរុបនៃទិន្នផលជាតិសរុប និងអត្រាអនិកម្មភាព និងការវិនិយោគវិស័យឯកជនជាដើម។

គំនូសតាងទី១០ បង្ហាញពី៖ គោលនយោបាយរបស់រដ្ឋាភិបាល (Government policy)



ប្រសិនបើ កម្រិតផលិតផលក្នុងស្រុកសរុបទាបជាងកម្រិតការប្រើកម្លាំងពលកម្មឱ្យអស់លទ្ធភាពនោះ ហើយក៏គ្មានសេដ្ឋវិទូណាចង់ឃើញការខ្វះខាតធនធានសេដ្ឋកិច្ចបែបនេះដែរ។ ហើយក៏គ្មានសេដ្ឋវិទូណាម្នាក់ចង់ក្លាយទៅជាអ្នកគ្មានការងារធ្វើ ពីព្រោះកម្រិតផលិតផលក្នុងស្រុកសរុបទាបឡើយ។ ម្យ៉ាងវិញទៀត ប្រសិនបើផែនការចំណាយខ្ពស់ខ្លាំងពេក បង្កើតឱ្យមានសម្ពាធនៃអតិផរណានោះ ធ្វើឱ្យអ្នកវិភាគសេដ្ឋកិច្ចមានភាពស្មុគស្មាញក្នុងការបកស្រាយនូវសញ្ញាណនៃការប្រែប្រួលលើទីផ្សារ ដែលមិនអាចផ្តល់ផលគ្រប់គ្រាន់ល្អប្រសើរដល់សង្គមជាតិឡើយ។

ដូចនេះ ពួកសេដ្ឋវិទូ គឺចង់ឱ្យរដ្ឋាភិបាលធ្វើសកម្មភាពសមស្របដើម្បីកែប្រែការផ្លាស់ប្តូរផែនការចំណាយ ដែលផ្តល់ការប្រើប្រាស់កម្លាំងពលកម្មបានពេញលេញដោយគ្មានអតិផរណា។ នយោបាយសារពើពន្ធ រួមចំណែកកែប្រែអាករ និងការផ្ទេរចំណាយ ឬការទិញរបស់រដ្ឋាភិបាល បានធ្វើឡើងក្នុងគោលបំណងជាក់លាក់ណាមួយ ដើម្បីព្យាយាមកែប្រែ ទិន្នផលសរុប និកម្មភាព និងកម្រិតថ្លៃ។ ក្នុងបណ្តាប្រទេសអភិវឌ្ឍន៍មួយចំនួន ការចំណាយរបស់រដ្ឋភិបាលតែងតែច្រើនជាងចំណូលដែលបានមកពីការប្រមូលពន្ធ និងអាករ ដែលធ្វើឱ្យមាន "ឱនភាពថវិកា" ពេលណាចំណាយតិចជាងចំណូលនាំឱ្យមាន "អតិរេកថវិកា" ដើម្បីកំណត់ថាតើគោលនយោបាយប្រភេទណា ដែលរដ្ឋាភិបាលកំពុងធ្វើ? ដូចនេះ គោលនយោបាយរូបិយវត្ថុទាំង២ប្រភេទខាងលើនេះ គឺមានគោលដៅកែប្រែនូវបរិមាណរូបិយវត្ថុសរុបមូលដ្ឋាន មានដូចជាប្រាក់បម្រុងធនាគារ និងរូបិយវត្ថុក្រៅធនាគារ តាមរយៈការអនុវត្តនូវឧបករណ៍គោលនយោបាយរូបិយវត្ថុ។ គោលនយោបាយរូបិយវត្ថុមានឥទ្ធិពលលើបម្រែបម្រួលរូបិយវត្ថុមូលដ្ឋាន អញ្ញត្តិរូបិយវត្ថុ លំហូឥណទាន ដែលធ្វើឱ្យមានការប្រែប្រួលអថេរម៉ាក្រូសេដ្ឋកិច្ចសំខាន់មួយចំនួនដូចជា អត្រាការប្រាក់ចំណូលជាតិ និងអត្រាអតិផរណា។

ជាទូទៅ គោលនយោបាយសារពើពន្ធ គឺជាគោលនយោបាយត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាលសំដៅទៅលើគោលនយោបាយថវិកាជាតិ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងការចំណាយរបស់រដ្ឋាភិបាល និងការកម្រិតពន្ធ។ នៅក្នុងបរិបទវិបត្តិសេដ្ឋកិច្ច រដ្ឋាភិបាលអាចប្រើគោលនយោបាយទាំង២នេះដើម្បីជំរុញឱ្យមានកំណើនសេដ្ឋកិច្ចឡើងវិញ។ ទន្ទឹមនឹងនេះដែរ គោលនយោបាយរូបិយវត្ថុ គឺជាគោលនយោបាយដែលបង្កើតឡើង ដោយធនាគារកណ្តាលសំដៅលើគោលនយោបាយរូបិយវត្ថុរបស់ធនាគារកណ្តាលដែលពាក់ព័ន្ធនឹងការកំណត់ អត្រាការប្រាក់ និងការផ្គត់ផ្គង់រូបិយវត្ថុ។ គោលនយោបាយទាំងពីរនេះ មានទំនាក់ទំនងយ៉ាងជិតស្និតនឹងគោលនយោបាយហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋាភិបាលដើម្បីព្យាយាមកែតម្រូវស្ថានភាពតម្រូវការលើសថវិកា ឬខ្វះខាតថវិកាក្នុងក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចដែលធ្វើឡើងតាមវិធីផ្សេងៗគ្នា។

## ៦.២- គំរូម៉ូដែលគោលនយោបាយរូបិយវត្ថុ ( Models of monetary policy )

### ៦.២.១- គោលនយោបាយរូបិយវត្ថុ ( Monetary policy )

ធនាគារកណ្ដាល គឺជាអ្នកបោះផ្សាយផ្ដាច់មុខនូវក្រដាសប្រាក់ និងកាស (N&C) និងទុនបម្រុងធនាគារ ពោលគឺអ្នកផ្គត់ផ្គង់ផ្ដាច់មុខនូវរូបិយវត្ថុមូលដ្ឋាន។ ធនាគារកណ្ដាល អាចកំណត់លក្ខខណ្ឌមួយចំនួនដែលមានឥទ្ធិពលដល់ការឱ្យខ្ចីដល់ធនាគារ និងប្រាក់កម្ចីលើទីផ្សារអន្តរធនាគារផ្សេងៗ សម្រាប់រយៈពេលខ្លីការប្រែប្រួលអត្រាការប្រាក់លើទីផ្សាររូបិយវត្ថុ ជាពិសេស ទីផ្សារអន្តរធនាគារ ជាលទ្ធផលនៃការអនុវត្តគោលនយោបាយអត្រាការប្រាក់របស់ធនាគារកណ្ដាល អាចមានការប្រែប្រួលសកម្មភាពភ្នាក់ងារសេដ្ឋកិច្ច និងអថេរម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗមួយចំនួនដូចជាកម្រិតទិន្នផលសរុប កម្រិតថ្លៃ និងជញ្ជីងទូទាត់ជាដើម ហើយដំណើរការនេះគេហៅថា *"យន្តការបញ្ជូននៃគោលនយោបាយរូបិយវត្ថុ"*។ ឥទ្ធិពលនៃយន្តការបញ្ជូនគោលនយោបាយរូបិយវត្ថុរួមមានដូចខាងក្រោម៖

**ក-** ជះឥទ្ធិពលដល់បម្រែបម្រួលអត្រាការប្រាក់ផ្លូវការ៖ សំដៅដល់ធនាគារកណ្ដាល ជាអ្នកផ្ដល់មូលនិធិកម្ចីមានការប្រាក់ទៅឱ្យប្រព័ន្ធធនាគារ និងមានសិទ្ធិផ្ដាច់មុខក្នុងការផ្សាយចេញរូបិយវត្ថុ។ ដូចនេះធនាគារកណ្ដាល មានលទ្ធភាពគ្រប់គ្រាន់សម្រាប់កំណត់អត្រាការប្រាក់ផ្លូវការ។

**ខ-** ជះឥទ្ធិពលដល់អត្រាការប្រាក់ធនាគារ និងអត្រាការប្រាក់ទីផ្សារអន្តរធនាគារ៖ សំដៅដល់បម្រែបម្រួលអត្រាការប្រាក់ផ្លូវការ ដែលមានឥទ្ធិពលដោយផ្ទាល់លើអត្រាការប្រាក់លើទីផ្សាររូបិយវត្ថុ និងដោយប្រយោលដល់អត្រាការប្រាក់កម្ចី និងប្រាក់បញ្ញើធនាគារកំណត់សម្រាប់អតិថិជនរបស់ខ្លួន។

**គ-** ជះឥទ្ធិពលដល់ការរំពឹងទុក៖ សំដៅដល់ការរំពឹងទុក ចំពោះការប្រែប្រួលនៃអត្រាការប្រាក់ផ្លូវការសម្រាប់គ្រាខាងមុខអាចមានឥទ្ធិពលដល់អត្រាការប្រាក់សម្រាប់រយៈពេលមធ្យម និងរយៈពេលវែង។ ជាពិសេស អត្រាការប្រាក់រយៈពេលវែង ដែលអត្រាការប្រាក់ គឺចំណុះទៅនឹងការរំពឹងទុករបស់ទីផ្សារ ចំពោះការវិវត្តនៃអត្រាការប្រាក់សម្រាប់រយៈពេលខ្លី។ គោលនយោបាយរូបិយវត្ថុ ត្រូវបានបង្ហាញពីភាពប្រាកដប្រជា ដើម្បីទាក់ទាញជំនឿទុកចិត្តពីភ្នាក់ងារសេដ្ឋកិច្ចចំពោះស្ថានភាពថ្លៃ និងអត្រាការប្រាក់។

**ឃ-** ជះឥទ្ធិពលដល់ការសន្សំ និងការវិនិយោគ៖ សំដៅដល់ការប្រែប្រួលអត្រាការប្រាក់ធ្វើ ឱ្យប៉ះពាល់ដល់ការសន្សំ និងការវិនិយោគផ្នែកឯកជន។ ឧទាហរណ៍៖ បើសិនអត្រាការប្រាក់មានកម្រិតខ្ពស់ នោះបណ្ដាលឱ្យមានការថយចុះនូវតម្រូវការប្រាក់កម្ចីសម្រាប់ធ្វើហិរញ្ញប្បទានដល់ការវិនិយោគ និងការចំណាយលើការប្រើប្រាស់។

**ង-** ជះឥទ្ធិពលដល់តម្លៃទ្រព្យសម្បត្តិ៖ សំដៅដល់គោលនយោបាយរូបិយវត្ថុ អាចកែប្រែលក្ខខណ្ឌហិរញ្ញវត្ថុនៅក្នុងសេដ្ឋកិច្ច និងការរំពឹងទុករបស់ទីផ្សារ ហើយធ្វើឱ្យប៉ះពាល់ដល់តម្លៃទ្រព្យសកម្ម (ដូចជាថ្លៃភាគហ៊ុន និងមូលប័ត្របំណុល) ព្រមទាំងអត្រាការប្រាក់។

**ច-** ជះឥទ្ធិពលដល់ការផ្គត់ផ្គង់ឥណទាន៖ សំដៅដល់អត្រាការប្រាក់មានកម្រិតខ្ពស់ ដែលអាចបង្កើននូវហានិភ័យ ចំពោះអ្នកខ្ចីប្រាក់ក្នុងការប្រឈមមុខទល់នឹងការគ្មានលទ្ធភាពសងបំណុល។ ហេតុនេះ ធនាគារអាចនឹងកាត់បន្ថយមូលនិធិកម្ចីទៅឱ្យក្រុមហ៊ុន និងអ្នកប្រើប្រាស់ដែលជាហេតុធ្វើឱ្យការវិនិយោគ និងការចំណាយលើប្រើប្រាស់ថយចុះ។

**ឆ-** ជះឥទ្ធិពលលើបម្រែបម្រួលដល់តម្រូវការសរុប និងកម្រិតថ្លៃ៖ សំដៅដល់ការប្រែប្រួលនូវការវិនិយោគ និងការចំណាយលើការប្រើប្រាស់ ដោយបណ្ដាលឱ្យប្រែប្រួលដល់តម្រូវការក្នុងស្រុក។ ប្រសិនបើ តម្រូវការសរុបមានកម្រិតខ្ពស់ជាងការផ្គត់ផ្គង់សរុបនោះ គឺកម្រិតថ្លៃនឹងកើនឡើង។ ដូច្នេះការប្រែប្រួលតម្រូវការសរុប អាចធ្វើឱ្យប៉ះពាល់ដល់កម្រិតថ្លៃលើទីផ្សារពលកម្ម និងទីផ្សារទំនិញអន្តរការី។ សម្រាប់រយៈពេលវែង ការប្រែប្រួលបរិមាណផ្គត់ផ្គង់រូបិយវត្ថុសរុបនៅក្នុងសេដ្ឋកិច្ច និងឆ្លុះបញ្ចាំងតាមរយៈការប្រែប្រួលកម្រិតថ្លៃ ប៉ុន្តែពុំអាចមានឥទ្ធិពលជាអចិន្ត្រៃយ៍ដល់សកម្មភាពផលិតកម្មនោះទេ។ គោលការណ៍នេះគេហៅថាអព្យាក្រឹត្យភាពនៃរូបិយវត្ថុក្នុងរយៈពេលវែង ពីព្រោះកំណើនផលិតកម្ម គឺអាស្រ័យលើកត្តាផ្សេងៗទៀត ដូចជាបច្ចេកវិទ្យាផលិតភាពនៃការប្រើប្រាស់នូវធនធានកំណើនប្រាក់ចំណូល និងការពេញនិយមរបស់អ្នកចូលរួមទៅក្នុងទីផ្សារ។

សម្រាប់ការបង្ហាញឧបករណ៍សំខាន់នៃគោលនយោបាយរូបិយវត្ថុ៖

- បង្កើតសមីការ LS ដើម្បីធ្វើឱ្យមានប្រសិទ្ធភាពដល់ KIR
- ប្រែប្រួលឱ្យបានសមស្រប KIR
- អនុវត្ត OMO តាមទម្រង់ផ្សេងៗគ្នា ដើម្បីធានាឱ្យបាននូវស្ថានភាព LS

ការសិក្សាមេរៀននេះ បានបង្ហាញក្នុងរូបភាពទី១ ស្ដីពីឧបករណ៍ចម្បងក្នុងបរិបទនៃគោលបំណងគោលនយោបាយរូបិយវត្ថុ។ ផ្នែកនេះ ក៏បានបង្ហាញពីការអនុវត្តនូវឧបករណ៍គោលនយោបាយរូបិយវត្ថុទាំងនេះឱ្យមានប្រសិទ្ធភាព ដោយពឹងផ្អែកលើការវិវត្តប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលមានប្រសិទ្ធភាព។

គំនូសតាងទី១១ បង្ហាញពី៖ គោលនយោបាយរូបិយវត្ថុ ( Monetary policy )



គំរូគោលនយោបាយរូបិយវត្ថុ សិក្សាវិភាគលើបញ្ហាពាក់ព័ន្ធលើផ្នែកទាំងនេះ មានដូចជា៖

- គំរូតម្រូវការទុនបម្រុងកាតព្វកិច្ច (Required reserves model)
- គំរូការប្រាក់អន្តរធនាគារ (Interbank rate model)
- សសរស្តម្ភគោលនយោបាយរូបិយវត្ថុ (Quoins of monetary policy)

### ៦.២.២- គំរូតម្រូវការទុនបម្រុងកាតព្វកិច្ច (Firm required reserve model)

យើងចាប់ផ្តើមសិក្សាគំរូដំបូង៖ គំរូទុនបម្រុងកាតព្វកិច្ច (RR)។ ត្រង់ចំណុចនេះ ចូរកត់សម្គាល់ថាយើងសន្មតថាប្រភេទក្រដាសប្រាក់ និងកាស(N&C) មិនត្រូវបានចាត់ថ្នាក់ទុនបម្រុងទេ។ ក្នុងករណីដែលប្រភេទក្រដាសប្រាក់ និងកាស(N&C) ត្រូវបានចាត់ថ្នាក់ជាទុនបម្រុងនោះ (ក្នុងអត្ថបទនេះហៅថា "គំរូរូបិយវត្ថុមូលដ្ឋាន" គឺគ្រាន់តែជាផ្នែកតូចមួយនៃផ្ទៃរឿងនេះប៉ុណ្ណោះ ហើយការដាក់បញ្ចូលវាគ្រាន់តែជួយបិទបាំងគោលការណ៍តែប៉ុណ្ណោះ។

ឥឡូវនេះ អ្នកដឹងបានស្រាប់ហើយថា តាមលំនាំហេតុផលជាក់ស្តែងនៃការបង្កើតរូបិយវត្ថុមានលំហូរចេញពីប្រាក់កម្ចីធនាគារ(=ទ្រព្យសកម្មរបស់ធនាគារ) ទៅជារូបិយវត្ថុ(=បំណុលរបស់ធនាគារ)។ ករណីទុនបម្រុងកាតព្វកិច្ច (RR) បានបំពេញតួនាទីមួយនៅពេលដែលការដាក់ប្រាក់បញ្ញើ (=រូបិយវត្ថុ)កើនឡើង ដោយសារតែ *ការផ្តល់ប្រាក់កម្ចីថ្មីបន្ថែម ឬការទិញមូលប័ត្របោះផ្សាយជាថ្មី* (=ប្រាក់កម្ចីធនាគារ)ដែលជាចំនួនទឹកប្រាក់ ឬទុនបម្រុងកាតព្វកិច្ច (RR) ដែលត្រូវរក្សាទុកដោយសារការកើនឡើងរបស់ធនាគារកណ្តាល។ ប៉ុន្តែធនាគារ អាចទទួលបានទុនបម្រុងចាំបាច់បន្ថែមបានតែតាមរយៈការខ្ចីប្រាក់ពីធនាគារកណ្តាលប៉ុណ្ណោះ។

ឧទាហរណ៍៖ ស្តីពីការខ្ចីប្រាក់ និងការចំណាយរបស់រដ្ឋាភិបាល គឺជាឧទាហរណ៍ជាក់ស្តែងមួយ។ ត្រង់ចំណុចនេះយើងនឹងផ្តល់ជូនឧទាហរណ៍មួយទៀត (សូមមើលតារាងតុល្យភាពលេខ ១-៤)។ ដូចគ្នានឹងអ្វីដែលបានបង្ហាញកន្លងមកដែរ គ្រាន់តែដាក់បញ្ចូលទុនបម្រុងកាតព្វកិច្ច (RR) និងធនាគារកណ្តាល (CB)។

| BALANCE SHEET 1: COMPANY A (MILLIONS) | | | |
|---|---|---|---|
| Assets | | Liabilities | |
| Goods | - 100 | | |
| Deposit at bank | + 100 | | |
| Total | 0 | Total | 0 |

| BALANCE SHEET 2: COMPANY B (MILLIONS) | | | |
|---|---|---|---|
| Assets | | Liabilities | |

| | | | |
|---|---|---|---|
| Goods | + 100 | | + 100 |
| **Total** | **+ 100** | **Total** | **+ 100** |

| BALANCE SHEET 3: BANK ( MILLIONS ) | | | |
|---|---|---|---|
| **Assets** | | **Liabilities** | |
| Loans to Company B<br>Reserves at CB ( TR )<br>( RR = +10 ) | + 100<br>+ 10 | Deposits of Company A<br>Loan from CB @ KIR | + 100<br>+ 10 |
| **Total** | **+ 110** | **Total** | **+ 110** |

| BALANCE SHEET 4: CENTRAL BANK ( MILLIONS ) | | | |
|---|---|---|---|
| Assets | | Liabilities | |
| Loans to banks ( BR ) @ KR | + 10 | Bank reserves ( TR )<br>( RR = +10 ) | + 10 |
| Total | + 10 | Total | + 10 |

នៅត្រង់ចំណុចនេះ យើងសូមបញ្ជាក់ឡើងវិញថា គ្មានធនាគារណាអាចបង្កើតទុនបម្រុងបាននោះទេ។ មានតែធនាគារកណ្តាលប៉ុណ្ណោះទើបអាចធ្វើរឿងនេះបាន។ ដូច្នេះ តើមានអ្វីកើតឡើងក្នុងករណីខាងលើ? ចម្លើយដ៏សាមញ្ញ គឺថាវាមិនអាចកើតមានទេ លើកលែងតែធនាគារកណ្តាលអនុញ្ញាតឱ្យ...ទើបវាកើតឡើងដោយការផ្តល់នូវទុនបម្រុង (Bank note+BR = +RR) អ្នកដឹងស្រាប់ហើយថា កាលណាមានតម្រូវការទុនបម្រុងដែលអនុវត្តចំពោះប្រាក់បញ្ញើធនាគារគឺមានទំនាក់ទំនងមិនប្រែប្រួលរវាងទុនបម្រុងកាតព្វកិច្ច (RR) និងប្រាក់បញ្ញើធនាគារ (BD)៖

$$RR = BD \times r$$

ដូច្នេះប្រសិនបើ៖ BD = 100 million, $r$ = 10%, យើងទទួលបាន:

= 10 million.

នេះមានន័យថា ធនាគារមិនអាចផ្គត់ផ្គង់ប្រាក់កម្ចីបន្ថែមបានទេ លុះត្រាតែធនាគារកណ្តាលផ្គត់ផ្គង់ទុនបម្រុងធនាគារ (BR)។ ដូច្នេះប្រសិនបើមិនមានធនាគារកណ្តាល (CB) ផ្គត់ផ្គង់ទុនបម្រុង (BR) ទេនោះ ប្រព័ន្ធធនាគារនឹងត្រូវជាប់គាំង បើនិយាយពីប្រាក់កម្ចីថ្មី និងការបង្កើតរូបិយវត្ថុ។ មានភស្តុតាងបង្ហាញថា នៅក្នុងប្រព័ន្ធបែបនេះដោយសន្មតថាមានតម្រូវការប្រាក់កម្ចី នោះអត្រាការប្រាក់គោល (PR) នឹងការកើនឡើងដល់ចំណុចមួយ ដែលគម្រោងថ្មីលែងមានលទ្ធភាពដំណើរការតទៅទៀត។ សូមចងចាំថា៖ ក្រុមហ៊ុនសហគ្រាសត្រូវមានការរំពឹងទុកផលចំណេញពីគម្រោងដែលមានតម្រូវការខ្ចីប្រាក់ ដែលមានចំនួនច្រើនជាងការចំណាយប្រាក់កម្ចី។ គំរូនេះ អាចត្រូវបានបង្ហាញដូចក្នុងរូបភាពទី២។ នៅពេលដែលធនាគារគ្មានប្រាក់បម្រុងលើសនោះ គេមិនអាចខ្ចីប្រាក់ថ្មីបានទេ។

ដូច្នេះ ករណីមានការផ្លាស់ប្តូរដែលនាំឱ្យកើនឡើងនូវតម្រូវការប្រាក់កម្ចី (ពី $D_1$ ដល់ $D_2$) នោះ អត្រាការប្រាក់នឹងកើនឡើង។

ក្រាហ្វិកទី៦ បង្ហាញពី៖ ស្ថិរភាពរូបិយវត្ថុ (ធនាគារផ្តល់កម្ចី) (Monetary stability)




ច្បាស់ណាស់ថា នេះគឺករណីសំខាន់បំផុតដែលយើងនឹងធ្វើបទបង្ហាញបញ្ជាក់នៅទីនេះ។ ធនាគារកណ្តាលដែលប្រតិបត្តិការតាមគំរូម៉ូដែលនេះ (មានតិចតួចណាស់ដែលធ្វើ)[៤៣] ផ្តល់ទុនបម្រុងក្នុងទំហំមួយ ដែលស៊ីសង្វាក់គ្នាជាមួយនឹងគោលដៅកំណើនរូបិយវត្ថុរបស់ពួកគេ។ ការគណនា គឺមានលក្ខណៈសាមញ្ញ។ ប្រសិនបើប្រព័ន្ធធនាគារមានតុល្យភាព (= គ្មាន BR និង គ្មាន ER) ហើយស្តុករូបិយវត្ថុក្នុងទម្រង់ប្រាក់បញ្ញើធនាគារ (BD) ស្មើនឹង ១០០ ប៊ីលាន LCC ខណៈពេលដែលធនាគារកណ្តាល (CB) ចង់បានកំណើន ១២% នៃស្តុករូបិយវត្ថុក្នុងទម្រង់នេះ ក្នុងអំឡុងពេល១២ខែបន្ទាប់ (រហូតដល់១១២ប៊ីលានដុល្លារ) នោះគេនឹងផ្គត់ផ្គង់ទុនបម្រុង បន្ថែមរហូតដល់ទំហំ ១,២ ប៊ីលានដុល្លារ សម្រាប់វិស័យធនាគារប្រើប្រាស់ដើម្បី "ទ្រទ្រង់" ឱ្យមានកំណើនស្តុករូបិយវត្ថុចំនួន ១២ប៊ីលានដុល្លារ។ *តើធនាគារកណ្តាល សម្រេចបានលទ្ធផលនេះយ៉ាងដូចម្តេច?* ចម្លើយ គឺថា OMO ទិញមូលប័ត្ររដ្ឋរហូតដល់ទំហំ ១,២ ប៊ីលានដុល្លារ ។ យើងសន្មតថាទាំងនេះកើតចេញពីធនាគារ (ពួកគេនឹងបោះផ្សាយលក់វាតាមការដេញថ្លៃ)។ ធនាគារកណ្តាលនឹងធ្វើបែបនេះជាដំណាក់កាលៗ ដើម្បីចៀសវាងការធ្លាក់ចុះខ្លាំងអត្រាការប្រាក់ ទន្ទឹមជាមួយនឹងការបង្កើតទុនបម្រុងលើស (ER)។ ដើម្បីបង្ហាញឱ្យបានច្បាស់ យើងសន្មតថាវាត្រូវបានធ្វើឡើងក្នុងពេលតែមួយ (សូមមើលតារាងតុល្យការលេខ ៥-៦)។

[៤៣] *The author has come across this model incertain small countries. They are usually donor-receipt countries, and the model is forced upon them by multilateral international institutions in order to instil monetary discipline (in the servers absence thereof).*

| BALANCE SHEET 5: CENTRAL BANK ( MILLIONS ) | | | |
|---|---|---|---|
| **Assets** | | **Liabilities** | |
| Government bonds | +1,200 | Bank reserves ( TR )<br>( RR = +10 )<br>( ER = + 1,200 ) | +1,200 |
| **Total** | **+1,200** | **Total** | **+1,200** |

| BALANCE SHEET 6: BANKS ( MILLIONS ) | | | |
|---|---|---|---|
| **Assets** | | **Liabilities** | |
| Government bonds<br>Reserves at CB ( TR )<br>( RR = +0 )<br>( ER = + 1,200 ) | -1,200<br>+1,200 | | |
| **Total** | **0** | **Total** | **0** |

កំណត់សម្គាល់ធនាគារនឹងអាចបំពេញតាមតម្រូវការប្រាក់ ឬប្រាក់កម្ចីថ្មី។ ជាលទ្ធផលចុងក្រោយត្រូវបានបង្ហាញនៅក្នុងតារាងតុល្យការលេខ ៧-៨ ។

| BALANCE SHEET 7: CENTRAL BANKS ( MILLIONS ) | | | |
|---|---|---|---|
| **Assets** | | **Liabilities** | |
| | | Bank reserves ( TR )<br>( RR = +1,200 )<br>( ER = - 1,200 ) | |
| **Total** | **0** | **Total** | **0** |

| BALANCE SHEET 8: BANKS ( MILLIONS ) | | | |
|---|---|---|---|
| **Assets** | | **Liabilities** | |
| Reserves at CB ( TR )<br>( RR = +1,200 ) | 0 | Deposits of NBPS | +12 000 |

| | | | |
|---|---|---|---|
| ( ER = - 1,200 ) Loans to NBPS | +12 000 | | |
| Total | +12 000 | Total | +12 000 |

ស្តុករូបិយវត្ថុ បានកើនឡើងចំនួន ១២ ប៊ីលានដុល្លារ ហើយទុនបម្រុងលើស (ER) បានប្តូរទៅជាទុនបម្រុងកាតព្វកិច្ច(RR)។ នៅពេលនេះ មានភស្តុតាងបង្ហាញយ៉ាងច្បាស់ថានៅពេលដែល ប្រព័ន្ធមួយបានពង្រីកវិសាលភាពដល់ចំណុចមួយទុនបម្រុងលើស (ER) ទាំងអស់របស់ប្រព័ន្ធនេះប្តូរទៅជា(RR)នោះ វាមិនអាចពង្រីកបន្ថែមទៀតទេ។ ក្នុងប្រព័ន្ធនេះ គេអាចរកឃើញកម្រិតអត្រាការប្រាក់បានដោយសេរី ឥឡូវនេះវាឆ្លុះបញ្ចាំងពីឧបសគ្គចំពោះបរិមាណនៃកំណើនរូបិយវត្ថុ។ អត្រាការប្រាក់កម្ចីធនាគារគោល (PR) នឹងកើនឡើងយ៉ាងខ្លាំង។ ដូចដែលអ្នកសិក្សាអំពីរូបិយវត្ថុ និងធនាគារ បានដឹងហើយថា នេះគឺជាគំរូទ្រឹស្តីដ៏សំខាន់នៃ "ការផ្គត់ផ្គង់" រូបិយវត្ថុ។ កន្លងមកធនាគារកណ្តាលធំៗមួយចំនួន នៅលើពិភពលោកបានធ្វើគ្រាប់តាមគំរូនេះ ប៉ុន្តែបានបោះបង់ចោលវិញ ព្រោះវាមានផលប៉ះពាល់យ៉ាងខ្លាំងលើការគ្រប់គ្រងបរិមាណទុនបម្រុងរបស់ធនាគារ ដោយសារតែអត្រាការប្រាក់មានការប្រែប្រួលខ្លាំង។ ដូចបានកត់សម្គាល់នៅក្នុងតំបន់ខ្លះនៃប្រទេសកំពុងអភិវឌ្ឍលើពិភពលោក ហើយគំរូនេះត្រូវបានដាក់ឱ្យដំណើរការនៅធនាគារកណ្តាលជាផ្នែកមួយនៃកម្មវិធីអភិវឌ្ឍន៍ ដែលរួមបញ្ចូលនូវមូលនិធិម្ចាស់ជំនួយ។

### ៦.២.៣- គំរូទុនបម្រុងជាប្រាក់កម្ចី (Firm borrowed reserves model)

ក្រាហ្វិកទី៧ បង្ហាញពី៖ តម្រូវការ និងការផ្គត់ផ្គង់ប្រាក់កម្ចី (Demand and supply of loan)




ចំណុចសំខាន់ខ្លាំងមួយទៀត គឺគំរូម៉ូដែលរបស់ BR (សូមមើលរូបទី៣)។ ក្នុងគំរូនេះ ធនាគារកណ្តាលធានាថាធនាគារផ្សេងៗជាប់បំណុលធនាគារកណ្តាលគ្រប់ពេលវេលា ហើយធនាគារមានលក្ខខណ្ឌទុនបម្រុង ឬអត់ (ករណីនេះមានប្រទេសមួយចំនួន) គឺមិនមែនជារឿងសំខាន់ទេ។ ធនាគារ

កណ្តាល គឺពឹងផ្អែកទាំងស្រុងលើអត្រាការប្រាក់ដើម្បីបែងចែកមូលនិធិ(ជាក់ស្តែងគឺរូបិយវត្ថុថ្មី) ហើយធនាគារកណ្តាលគ្រប់គ្រងទាំងស្រុងលើអត្រាការប្រាក់។ ដូច្នេះ ជាក់ស្តែងណាស់ក្នុងប្រព័ន្ធគោលនយោបាយរូបិយវត្ថុ គឺសុទ្ធសឹងតែជាមាតិកាដែលមាននៅក្នុងសៀវភៅបញ្ជីរបស់ធនាគារកណ្តាល៖ "ប្រាក់កម្ចីធនាគារ" ធនាគារបម្រុង និង KIR ដែលអនុវត្តលើប្រាក់កម្ចីទាំងនេះ។ អត្ថិភាពនៃប្រាក់កម្ចីធនាគារ ដែលក្នុងនោះចំនួនទឹកប្រាក់ដែលជំពាក់ត្រូវបានហៅថាកង្វះខាតសាច់ប្រាក់ងាយស្រួល (LS) គឺជាអ្វីដែលធ្វើឱ្យ KIR មានអានុភាព និងឥទ្ធិពលលើអត្រាការប្រាក់របស់ធនាគារនៅក្នុងតារាងតុល្យការរបស់ពួកគេទាំងសងខាង និងតម្រូវការប្រាក់កម្ចី (អថេរសេដ្ឋកិច្ច ឬតម្លៃផ្សេងទៀតដូចជាអត្រាប្តូរប្រាក់) តាមរយៈអត្រាគោលប្រាក់កម្ចី (PR)។

ធនាគារកណ្តាល ធ្វើការព្យាករណ៍ប្រចាំថ្ងៃរយៈពេលវែងលើកត្តានានាដែលមានឥទ្ធិពលលើសាច់ប្រាក់ងាយស្រួលរបស់ធនាគារ ហើយមានផលប៉ះពាល់មកលើសមតុល្យទុនបម្រុងសុទ្ធរបស់ប្រព័ន្ធធនាគារដែលនឹងឆ្លុះបញ្ចាំងពីគណនីបម្រុងទុននៅចុងថ្ងៃអាជីវកម្ម បន្ទាប់មកអនុវត្តទីផ្សារបើកចំហ (OMO) ដើម្បីធានាថាធនាគារបានខ្ចីប្រាក់ពីធនាគារកណ្តាល (ឬអត់បើសិនចំនួនទឹកប្រាក់សុទ្ធនៅតែអវិជ្ជមាន)។ KIR ត្រូវបានអនុវត្តប្រាក់កម្ចីរបស់ធនាគារកណ្តាលដែលផ្តល់ដល់ធនាគារ មានធនាគារ កណ្តាលមួយចំនួនដែលចូលរួមក្នុងគំរូម៉ូដែលនេះ។ ធនាគារសហព័ន្ធអាហ្វ្រិកខាងត្បូងធ្វើតាមគំរូម៉ូដែលនេះដែរ។ ធនាគារជាប់បំណុលធនាគារកណ្តាលជាអចិន្ត្រៃយ៍ ហើយធនាគារនេះ អាចគ្រប់គ្រងអត្រាការប្រាក់កម្ចីរបស់ធនាគារតាមរបៀបមួយស្ទើរតែដូចគ្នាបេះបិទដូចបង្ហាញក្នុងរូបទី៤។

ក្រាហ្វិកទី៨ បង្ហាញពី៖ KIR & PR (month-end over 50 years)




ធនាគារកណ្តាលអង់គ្លេស ក៏អនុវត្តតាមគំរូម៉ូដែលនេះដែរដូចបានបង្ហាញខាងក្រោម៖[៩៤]

---

៩៤ www.bankfengland .co.uk

*"ការអនុវត្តជាក់ស្តែងលំនាំនៃប្រតិបត្តិការរបស់រដ្ឋាភិបាល និងធនាគារជាធម្មតានាំឱ្យមានកង្វះសាច់ប្រាក់លើទីផ្សារជារៀងរាល់ថ្ងៃ។ ធនាគារផ្គត់ផ្គង់សាច់ប្រាក់ ដែលប្រព័ន្ធធនាគារទាំងមូលត្រូវការ ដើម្បីបង្កើតបានសមតុល្យនៅចុងថ្ងៃទូទាត់នីមួយៗ។ ដោយសារធនាគារគឺអ្នកផ្គត់ផ្គង់សាច់ប្រាក់ចុងក្រោយទៅដល់ប្រព័ន្ធនោះ វាអាចជ្រើសរើសអត្រាការប្រាក់ធនាគារ និងការផ្គត់ផ្គង់ប្រាក់ទាំងនេះប្រចាំថ្ងៃ។ អត្រាការប្រាក់សម្រាប់ការផ្គត់ផ្គង់មូលនិធិទាំងនេះ ឆ្លងកាត់ប្រព័ន្ធហិរញ្ញវត្ថុយ៉ាងឆាប់រហ័ស ដែលជះឥទ្ធិពលលើអត្រាការប្រាក់សម្រាប់សេដ្ឋកិច្ចទាំងមូល។ នៅពេលធនាគារផ្លាស់ប្តូរអត្រាការប្រាក់របស់ខ្លួន ធនាគារពាណិជ្ជនឹងផ្លាស់ប្តូរអត្រាការប្រាក់គោលរបស់ខ្លួន ក្នុងការគណនាអត្រាប្រាក់បញ្ញើ និងអត្រាការប្រាក់កម្ចី"។*

យើងសូមបន្ថែមថា មានពេលវេលាដ៏អស្ចារ្យនៅពេលដែលវិធានការសំខាន់ៗត្រូវបានអនុវត្ត ដែលហួសពីការផ្តល់ប្រាក់កម្ចីពីធនាគារកណ្តាល(CB) ឱ្យដល់ធនាគារ និងឆ្ពោះទៅរកការបង្កើតអតិរេកនៃទីផ្សាររូបិយវត្ថុ (លក្ខខណ្ឌ a + ER)៖

*"ក្នុងខែមីនា ឆ្នាំ២០០៩ គណៈកម្មាធិការគោលនយោបាយរូបិយវត្ថុបានប្រកាសថាបន្ថែមលើការកំណត់ការប្រាក់របស់ធនាគារក្នុងអត្រា 0,៥% នឹងចាប់ផ្តើមដាក់បញ្ចូលប្រាក់ ដោយផ្ទាល់ទៅក្នុងសេដ្ឋកិច្ចដើម្បីបំពេញនូវគោលដៅអតិផរណា។[៩៥] សម្រាប់ឧបករណ៍គោលនយោបាយរូបិយវត្ថុ បានផ្លាស់ប្តូរឆ្ពោះទៅរកការផ្គត់ផ្គង់បរិមាណរូបិយវត្ថុជាជាងថ្លៃរបស់វា(អត្រារបស់ធនាគារ)។ ប៉ុន្តែគោលបំណងនៃគោលនយោបាយ មិនមានការផ្លាស់ប្តូរទេ គឺដើម្បីឆ្លើយតបទៅនឹងគោលដៅអតិផរណាចំនួន ២ភាគរយ លើរង្វាស់របស់ CPI នៃថ្លៃទំនិញប្រើប្រាស់។ ការជះឥទ្ធិពលលើបរិមាណរូបិយវត្ថុដោយផ្ទាល់ គឺជាមធ្យោបាយដ៏សំខាន់ខុសគ្នាដើម្បីឈានទៅដល់គោលដៅចុងក្រោយដូចគ្នា"។*

*"ការកាត់បន្ថយយ៉ាងច្រើន គួរឱ្យកត់សម្គាល់នូវអត្រាការប្រាក់ធនាគារ គឺជាកម្លាំងចលករដ៏ធំមួយដល់សេដ្ឋកិច្ច ប៉ុន្តែនៅពេលអត្រាធនាគារខិតជិតសូន្យ នោះការកាត់បន្ថយបន្ថែមទៀតទំនងជាមិនមានប្រសិទ្ធភាពទេទាក់ទងនឹងផលប៉ះពាល់លើអត្រាការប្រាក់ទីផ្សារ តម្រូវការ និងអតិផរណា។ ហើយអត្រាការប្រាក់មិនអាចទាបជាងសូន្យទេ។ ដូច្នេះ គណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ(MPC)ត្រូវមានការជំរុញបន្ថែមទៀត ដើម្បីគាំទ្រឱ្យមានតម្រូវការនៅទូទាំងសេដ្ឋកិច្ច។ ប្រសិនបើ ការចំណាយលើទំនិញ និងសេវាទាបពេក នោះអតិផរណា នឹងធ្លាក់ចុះទាបជាងគោលដៅរបស់វា"។*

*"MPC ជំរុញឱ្យមានការផ្គត់ផ្គង់រូបិយវត្ថុតាមរយៈការទិញទ្រព្យសកម្ម ដូចជាសញ្ញាបណ្ណរដ្ឋ និងសញ្ញាប័ណ្ណសាជីវកម្ម ដែលគោលការណ៍នេះហៅថា "ការសម្រួលខាងបរិមាណ"។ ជំនួសឱ្យការទម្លាក់អត្រាការប្រាក់របស់ធនាគារ ដើម្បីបង្កើនបរិមាណរូបិយវត្ថុនៅក្នុងសេដ្ឋកិច្ច នោះធនាគារនឹងផ្គត់ផ្គង់រូបិយវត្ថុបន្ថែមដោយផ្ទាល់។ នេះមិនពាក់ព័ន្ធនឹងការបោះពុម្ពក្រដាស*

---

[៩៥] *In this case to avoid deflation*

*ប្រាក់បន្ថែមទេ។ ផ្ទុយទៅវិញធនាគារត្រូវចំណាយលើទ្រព្យសកម្មទាំងនេះ ដោយបង្កើតរូបិយវត្ថុអេឡិកត្រូនិក និងផ្តល់គណនីប្រាក់កម្ចីរបស់សហគ្រាស ដែលខ្លួនបានទិញទ្រព្យសកម្មទាំងនោះ។ ប្រាក់បន្ថែមនេះ គាំទ្រឱ្យមានការចំណាយបន្ថែមនៅក្នុងសេដ្ឋកិច្ច ដើម្បីសម្រេចបានអតិផរណាតាមគោលដៅអនាគត"។*

ចូរយើងវិភាគសេចក្តីថ្លែងការណ៍នេះ៖ ធនាគារអង់គ្លេសបានទិញមូលប័ត្រ (សន្មតថាជាសញ្ញាប័ណ្ណរដ្ឋ) ពីមូលនិធិចូលនិវត្តន៍រហូតដល់ទំហំ ២០០ ប៊ីលានផោន។ ប្រព័ន្ធធនាគារជាប់បំណុលធនាគារនេះរហូតដល់ចំនួន ១០០ លានផោន។ [ចំណាំ យើងរំលងចំណុចលក្ខខណ្ឌទុនបម្រុងត្រង់ចំណុចនេះ ដើម្បីឱ្យមានលក្ខណៈសាមញ្ញ]។ ប្រតិបត្តិការនេះបានបង្កើនស្តុករូបិយវត្ថុរហូតដល់ ២០០ ប៊ីលានផោន និងបង្កើតបានទុនបម្រុងលើស ER ដែលចំនួនទឹកប្រាក់ ១០០ ផោន(ទឹកប្រាក់១០០ផោនទៀត ត្រូវបានប្រើសម្រាប់ទូទាត់សងទៅ BR ឱ្យទៅធនាគារកណ្តាលអង់គ្លេស)។ សម្រាប់ ER របស់ធនាគារជួយកាត់បន្ថយអត្រាការប្រាក់របស់ធនាគារ (ពោលគឺ KIR) និងដាក់សម្ពាធលើធនាគារក្នុងការផ្តល់ប្រាក់កម្ចីទៅដល់ NBPS ក្នុងអត្រាទាប។

វិភាគរបាយការណ៍៖ ទាក់ទងនឹងការឈានទៅដល់គោលដៅអតិផរណារបស់ធនាគារក្នុងរង្វង់ (២%) នោះយើងនិយាយអំពីអន្តរាយនៃបរិត្តផរណា (នៅពេលតម្លៃធ្លាក់ចុះ) ដែលធ្វើឱ្យទ្រព្យសកម្ម (ដូចជាផ្ទះសម្បែង) មានតម្លៃទាបខណៈពេលដែលរក្សាបំណុល (ជាវត្ថុបញ្ចាំបំណុល) មិនឱ្យមានការប្រែប្រួល។ កម្រិតបរិត្តផរណា បានជះឥទ្ធិពលអវិជ្ជមានយ៉ាងធ្ងន់ធ្ងរមកលើសមីការ៖ C + I = GDE ព្រោះវិនិយោគិនលើទ្រព្យសកម្មមានស្ថានភាពយ៉ាប់យ៉ឺន។

| BALANCE SHEET 9: RETIREMENT FUNDS (NBPS) (GBP BILLIONS) | | | |
|---|---|---|---|
| Assets | | Liabilities | |
| Government bonds | -200 | | |
| Deposits at banks | +200 | | |
| Total | 0 | Total | 0 |

| BALANCE SHEET 10: BANKS (GBP BILLIONS) | | | |
|---|---|---|---|
| Assets | | Liabilities | |
| Bank reserves (TR) | +100 | Deposits of NBPS | +200 |
| (ER = + 100) | | Loans from CB (BR) | -100 |
| Total | +100 | Total | +100 |

| BALANCE SHEET 11: BANK OF ENGLAND (GBP BILLIONS) |
|---|

| Assets | | Liabilities | |
|---|---|---|---|
| Government bonds<br>Deposits to banks ( BR ) | +200<br>-200 | Bank reserves ( TR )<br>( ER = + 100 ) | +100 |
| Total | +100 | Total | +100 |

ចំពោះធនាគារបម្រុងអូស្ត្រាលី មានទម្រង់ប្រតិបត្តិគោលនយោបាយរូបិយវត្ថុស្រដៀងគ្នា (ចំណាំះ ប្រាក់កម្ចីពេញមួយយប់ គឺជាប្រាក់កម្ចីពីធនាគារកណ្តាលឱ្យដល់ធនាគារ ហើយអត្រាអន្តរធនាគារត្រូវបានហៅថា "អត្រាសាច់ប្រាក់" )៖[៩៦]

*"ការសម្រេចលើគោលនយោបាយរូបិយវត្ថុ ពាក់ព័ន្ធនឹងការកំណត់អត្រាការប្រាក់លើប្រាក់កម្ចីពេញមួយយប់នៅក្នុងទីផ្សាររូបិយវត្ថុ។ អត្រាការប្រាក់ផ្សេងទៀត នៅក្នុងសេដ្ឋកិច្ចវងឥទ្ធិពលពីអត្រាការប្រាក់នេះក្នុងកម្រិតផ្សេងៗ ដូច្នេះឥរិយាបថនៃការខ្ចីប្រាក់ និងរបស់អ្នកឱ្យខ្ចីនៅលើទីផ្សារហិរញ្ញវត្ថុវងការប៉ះពាល់ដោយគោលនយោបាយរូបិយវត្ថុ (ទោះបីជាមិនមែនដោយគោលនយោបាយរូបិយវត្ថុក្តី)។ តាមរយៈបណ្តាញទាំងនេះ គោលនយោបាយ រូបិយវត្ថុមានឥទ្ធិពលលើសេដ្ឋកិច្ចក្នុងការឈានទៅដល់គោលដៅ...*

*"ជារៀងរាល់ថ្ងៃ ធនាគារមានភារកិច្ចរក្សាឱ្យមានលក្ខខណ្ឌទីផ្សាររូបិយវត្ថុ ដើម្បីរក្សាបាននូវអត្រាសាច់ប្រាក់ឱ្យខិតជិតគោលដៅប្រតិបត្តិការតាមការសម្រេចរបស់ក្រុមប្រឹក្សា។ អត្រាសាច់ប្រាក់ គឺជាអត្រាដែលគិតលើប្រាក់កម្ចីពេញមួយយប់រវាងអន្តរការីហិរញ្ញវត្ថុ។ វាមានឥទ្ធិពលយ៉ាងខ្លាំងលើអត្រាការប្រាក់ផ្សេងទៀត ហើយបង្កើតជាមូលដ្ឋានមួយដែលកំណត់ពីរចនាសម្ព័ន្ធអត្រាការប្រាក់នៅក្នុងសេដ្ឋកិច្ច...ការផ្លាស់ប្តូរគោលនយោបាយរូបិយវត្ថុ មានន័យថាការផ្លាស់ប្តូរគោលដៅប្រតិបត្តិការសម្រាប់អត្រាសាច់ប្រាក់ និងនាំទៅដល់ការផ្លាស់ប្តូររចនាសម្ព័ន្ធអត្រាការប្រាក់ដែលកើតមានទូទៅក្នុងប្រព័ន្ធហិរញ្ញវត្ថុ"។*

## ៦.២.៤- គំរូម៉ូដែលអត្រាអន្តរធនាគារ ( Interbank rate model )

គំរូ IBR គឺជាបម្រែបម្រួលគំរូរបស់ BR។ វាគឺជាគំរូមួយដែលធនាគារកណ្តាលមួយចំនួនប្រកាន់នូវគោលជំហររបស់ខ្លួនចំពោះគោលនយោបាយរូបិយវត្ថុ។ ពួកគេបានកំណត់វិសាលភាពគោលដៅដំណាក់កាលទីពីរនៃយន្តការបញ្ជូនគោលនយោបាយរូបិយវត្ថុ( MPTM )៖ អត្រាអន្តរធនាគារ។ ត្រូវចងចាំថានេះ គឺជា b2b IBM ដែលបានតម្រុយពី KIR *ដរាបណាធនាគារជាប់បំណុលធនាគារកណ្តាល (មានចំនួន+BR ក្នុងតារាងតុល្យការរបស់ពួកគេ)។* មានអំណះអំណាងថា នៅពេលដែលធនាគារ "ជួញដូរមូលប័ត្រ" ព្យាយាមបញ្ចៀសការខ្ចីប្រាក់ពីធនាគារកណ្តាល នៅក្នុងការផាត់ទាត់អន្តរធនាគារនោះពួកគេមានឆន្ទៈក្នុងការទូទាត់អត្រាអន្តរធនាគារដែលទាបជាងអត្រា KIR មួយភាគ។

[៩៦] *Bank reserve*

បញ្ហានេះ គឺភ្ជាប់ជាមួយលក្ខខណ្ឌ នោះគឺជាពេលដែលប្រព័ន្ធធនាគារមានតុល្យភាព (មិនមានអតិរេកជាមួយធនាគារកណ្តាល (គ្មាន-ER) និងគ្មានប្រាក់កម្ចីពីធនាគារកណ្តាល (គ្មាន BR) (= ស្ថានភាពខុសប្រក្រតីព្រោះការព្យាករណ៍របស់ធនាគារកណ្តាលអាចមានភាពមិនច្បាស់លាស់) គ្រាន់តែការគំរាមការខ្ចីប្រាក់ពីធនាគារកណ្តាល គឺគ្រប់គ្រាន់ដើម្បីធ្វើឱ្យ KIR មានប្រសិទ្ធភាពរួចស្រាប់ហើយ។ លើសពីនេះទៀត មានធនាគារកណ្តាលដែលអនុញ្ញាតឱ្យមាន ER និងធ្វើឱ្យគោលនយោបាយអត្រាការប្រាក់របស់ពួកគេមានប្រសិទ្ធភាព ដោយការទូទាត់អត្រាការប្រាក់លើចំនួនទឹកប្រាក់ទាំងនេះ ហើយអត្រាមានប្រសិទ្ធភាព រួចក្លាយជាអត្រានេះ។ [អត្រានេះហៅថា KIR-D សម្រាប់ KIR សម្រាប់ប្រាក់បញ្ញើធនាគារ ER ខណៈដែលអត្រាការប្រាក់កម្ចីរបស់ធនាគារកណ្តាល បានក្លាយជា KIR-L (ពោលគឺសម្រាប់ BR)] ដូច្នេះតាមរយៈយន្តការនេះ ធនាគារកណ្តាលអាចបង្កើតជា "ច្រកផ្លូវ KIR មួយ" ហើយវាក្លាយជាតម្រុយ ឬគោលដៅមួយនៃអត្រា b2b IBM ។ ច្បាស់ណាស់ថា KIR-L បង្កើតបានជាច្រកផ្លូវនៅថ្នាក់លើ និង KIR-D នៅថ្នាក់ក្រោម។

ឧទាហរណ៍ដ៏ល្អនៃវិធីសាស្ត្រនេះ ស្តីពីគោលនយោបាយរូបិយវត្ថុគឺជាប្រទេសកាណាដា។ ធនាគារកាណាដាចែងថា៖[៤៧]

*"ធនាគារអនុវត្តគោលនយោបាយរូបិយវត្ថុ ដែលមានឥទ្ធិពលលើអត្រាការប្រាក់ក្នុងរយៈពេលខ្លី។ កិច្ចការនេះអាចធ្វើបានដោយការបង្កើន និងបន្ថយអត្រាគោលពេញមួយយប់។*

*"អត្រាការប្រាក់ពេញមួយយប់ គឺជាអត្រាការប្រាក់ ដែលគ្រឹះស្ថានហិរញ្ញវត្ថុធំៗខ្ចីប្រាក់តែមួយថ្ងៃ (ឬពេញមួយយប់) ក្នុងចំណោមពួកគេ។ ធនាគារកំណត់កម្រិតគោលដៅសម្រាប់អត្រានោះ។ អត្រាគោលដៅពេញមួយយប់នេះជារឿយៗ គឺអត្រាការប្រាក់គោល ឬអត្រាគោលនយោបាយគោលរបស់ធនាគារ។*

*"ការផ្លាស់ប្តូរអត្រាគោលដៅពេញមួយថ្ងៃ មានឥទ្ធិពលលើអត្រាការប្រាក់ផ្សេងទៀត ដូចជាការខ្ចីបរិភោគ និងប្រាក់កម្ចីទិញផ្ទះសម្បែង។ វាក៏អាចប៉ះពាល់ដល់អត្រាប្តូរប្រាក់ដុល្លារកាណាដាផងដែរ។*

*"ឧបករណ៍ដែលធនាគារបានប្រើ ដើម្បីធានារក្សាអតិផរណាឱ្យក្នុងរង្វង់គោលដៅ គឺអត្រាធនាគារដែលជាអត្រាការប្រាក់ដែលធនាគារគិតលើប្រាក់កម្ចីរយៈពេលខ្លី ចំពោះស្ថាប័នហិរញ្ញវត្ថុ។*

ខ្លឹមសារសំខាន់នៃទម្រង់គោលនយោបាយរូបិយវត្ថុរបស់ធនាគារកណ្តាលអ៊ឺរ៉ុប (ECB) គឺបង្កើតនូវអត្រាការប្រាក់ "របៀង" ដែលក្នុងនោះ "អត្រាការប្រាក់ទីផ្សារពេញមួយយប់" (ពោល គឺអត្រា b2b IBM) ត្រូវបានកំណត់ (មានន័យដូចគ្នានឹងអ្វីដែលបានពន្យល់ពីខាងដើម)។ ធនាគារនេះប្រកាសពី "អត្រាការប្រាក់គោល" របស់ខ្លួន តាមពិតធនាគារកំណត់នូវអត្រារបស់ខ្លួនជាទៀងទាត់ ដើម្បីបង្ហាញពីជំហរគោលនយោបាយរូបិយវត្ថុរបស់ខ្លួន។

[៤៧] www.boc.co.ca

ដូចករណីនៅប្រទេសកាណាដាដែរ វាមាន KIR ចំនួនពីរ គឺជាអត្រាការប្រាក់លើសម្បទាកម្ចីម៉ាជីន (ពេលគឺសម្រាប់ប្រាក់កម្ចីពេញមួយយប់) ដែលបង្កើតអត្រាអតិបរមាសម្រាប់អត្រា b2b IBM ពេញមួយយប់(ដូច KIR-L ខាងលើ) និងអត្រាការប្រាក់លើសម្បទាប្រាក់បញ្ញើ (សម្រាប់ប្រាក់បញ្ញើពេញមួយយប់នៅពេលដែលប្រព័ន្ធធនាគារមានអតិរេក = ER) ដែលបង្កើតជាអត្រាអប្បបរមាសម្រាប់អត្រាពេញមួយយប់ (ដូច KIR-D ខាងលើ)។ ប្រតិបត្តិការទាំងនេះ (ការផ្តល់ប្រាក់កម្ចី និងការទទួលប្រាក់បញ្ញើ)មិនត្រូវបានអនុវត្តដោយផ្ទាល់ដោយ ECBនោះទេ ប៉ុន្តែដោយធនាគារជាតិថ្នាក់កណ្តាលនីមួយៗ (NCBs)។

ប្រព័ន្ធគោលនយោបាយរូបិយវត្ថុអាម៉េរិកធ្វើប្រតិបត្តិការតាមរបៀបស្រដៀងគ្នា។ ប្រព័ន្ធទុនបម្រុងសហព័ន្ធកំណត់គោលដៅ "អត្រាមូលនិធិសហព័ន្ធ" ដែលជាអត្រា b2b IBM។ ហើយវាកំណត់ពីទិសដៅសាច់ប្រាក់ងាយស្រួលនៃប្រព័ន្ធធនាគារ ដែលភាគច្រើនគេប្រើប្រាស់សម្បទាប្រាក់កម្ចី (មានចំនួន៣) ហៅថាច្រកអប្បហារនៅក្នុង "អត្រាអប្បហារ"។ ដោយសារកង្វះខាតសាច់ប្រាក់ងាយស្រួលអត្រានេះមានឥទ្ធិពលលើអត្រា b2b IBM ដែលថាមពលជះឥទ្ធិពលលើអត្រាប្រាក់បញ្ញើ និងអត្រាប្រាក់កម្ចីនៅក្នុងវិស័យធនាគារ (និងអត្រាប្តូរប្រាក់)[៤៨]។

## ៦.២.៥- សសរស្តម្ភនៃគោលនយោបាយរូបិយវត្ថុ (Quoins of monetary policy)

ឥឡូវនេះ អ្នកនឹងបានយល់ច្បាស់អំពីខ្លឹមសារសំខាន់នៃគោលនយោបាយរូបិយវត្ថុ។ វាជាគោលនយោបាយស្តីពីការបង្កើតរូបិយវត្ថុ ជាពិសេសអត្រាកំណើននៃការបង្កើតរូបិយវត្ថុ។ គ្មានធនាគារកណ្តាលណាមួយចង់បង្កើតឱ្យមានកំណើនរូបិយវត្ថុអវិជ្ជមាននោះទេ ពីព្រោះបញ្ហានេះអាចនាំឱ្យមានបរិត្តផរណា ហើយបរិត្តផរណាមានន័យថាការធ្លាក់ចុះនៃតម្លៃទ្រព្យសកម្ម ពោលគឺការធ្លាក់ចុះនូវទ្រព្យធន។ ការធ្លាក់ចុះនូវទ្រព្យធនមានន័យថាការធ្លាក់ចុះនូវការប្រើប្រាស់ និងការចំណាយវិនិយោគដែលជាកត្តាចលករដ៏ចម្បងនៃកំណើនសេដ្ឋកិច្ច។ ដូច្នេះ គោលនយោបាយនេះ មានគោលបំណងធានាបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពដែលទាមទារឱ្យមានស្ថិរភាពថ្លៃ និងអតិផរណាទាប។ ដូច្នេះ បើនិយាយពីអត្តសញ្ញាណគឺ DM x DV = DP x Deal GDP (សន្មតថា V ថេរ) DM3 មិនគួរលើសពីសមត្ថភាពពង្រីកសេដ្ឋកិច្ចក្នុងអត្រាមួយទេ ពោលគឺផលិតផលក្នុងស្រុកដុល Deal ដែលនឹងផ្តល់នូវ DP មិនលើសពីគោលដៅអតិផរណា (ករណីភាគច្រើនគឺ ២% ក្នុងមួយឆ្នាំ)។ ដូច្នេះ ការអនុវត្តគោលនយោបាយរូបិយវត្ថុ ត្រូវរួមមានគោលជំហរមួយស្តីពីភាពបត់បែននៃការផ្គត់ផ្គង់របស់សេដ្ឋកិច្ច។

អ្នកដឹងស្រាប់ហើយថា រូបិយវត្ថុត្រូវបានបង្កើតឡើងតាមរយៈប្រាក់កម្ចីធនាគារដែលផ្តល់ដល់រដ្ឋាភិបាល និង NBPS ហើយការទិញរបស់ធនាគារនូវមូលប័ត្រនៅផ្សារហ៊ុនក៏បង្កើតបានជារូបិយវត្ថុផងដែរ។ ដូច្នេះ កត្តាចលករនៃកំណើនរូបិយវត្ថុ គឺជាតម្រូវការប្រាក់កម្ចីរបស់រដ្ឋ និង NBPS និងការសម្រេចចិត្តរបស់ធនាគារ ដើម្បីទិញមូលប័ត្រពីផ្សារហ៊ុន (=ជាទូទៅ គឺជាកត្តាតូចតាច)។ តើអ្នកដឹង

[៤៨] http://www.federalreserve.gov/monetarypolicy/discountrate.htm

ទេថា ធនាគារកណ្តាលមានឧបករណ៍ក្នុងដៃក្នុងការគ្រប់គ្រងលើការបង្កើតរូបិយវត្ថុ ហើយទាំងនេះគឺជាលក្ខខណ្ឌទុនបម្រុងពេលគឺ KIR និង OMO (r ក៏អាចផ្លាស់ប្តូរដែរ ប៉ុន្តែគេកម្រប្រើណាស់)។

ផ្អែកតាមគំរូសហគ្រាសរបស់ RR លក្ខខណ្ឌទុនបម្រុងត្រូវបានប្រើ ដើម្បីទប់ស្កាត់កំណើន M3 លើបរិមាណតាមរយៈការបង្កើតបរិមាណធនបម្រុងដែលត្រូវការទុនបម្រុងលើស (ER) តាមរយៈការទិញពី OMO។ កម្រិតអត្រាការប្រាក់ គឺអាចរកឃើញដោយផ្ទាល់ (ឬគួរតែដូច្នោះ ពីព្រោះធនាគារកណ្តាលមិនអាចគ្រប់គ្រងទាំងពីរបានដោយមិនបង្កើតនូវអនិរន្តរភាពក្នុងការការបង្វែរនោះទេ)។

ផ្អែកតាមគំរូសហគ្រាសធនាគារ RR ឧបករណ៍ប្រតិបត្តិការសំខាន់ គឺអត្រាការប្រាក់កម្ចីរបស់ធនាគារកណ្តាល(KIR-L)ដែលផ្តល់ទៅដល់ធនាគារប្រកបដោយប្រសិទ្ធភាព ដោយធានាឱ្យមានកង្វះខាតសាច់ប្រាក់ងាយស្រួលតាមរយៈ OMO គ្រប់ពេលវេលា (ពោលគឺធនាគារកណ្តាលរក្សាបើកចំហឱ្យមានប្រាក់កម្ចីដល់ធនាគារគ្រប់ពេល)។ "ការធ្វើឱ្យមានប្រសិទ្ធភាព" នូវប្រព័ន្ធឆ្លងកាត់ KIR តាមអត្រាគោលរបស់ធនាគារ (និងរាល់អត្រាផ្សេងទៀត និងអត្រាប្តូរប្រាក់ ដែលជះឥទ្ធិពលលើតម្រូវការប្រាក់កម្ចី (ជាកត្តាចលករដ៏ចម្បងក្នុងការបង្កើតរូបិយវត្ថុ)។

គំរូ IBR គឺស្រដៀងនឹងគំរូសហគ្រាសធនាគារ BR ដែរ។ ប៉ុន្តែវាផ្តោតទៅលើអត្រាអន្តរធនាគាររបស់ធនាគារ និងជះឥទ្ធិពលលើវានៅត្រង់លក្ខខណ្ឌទាំងលើអតិរេកសាច់ប្រាក់ងាយស្រួលរបស់ធនាគារទុនបម្រុងលើស (ER) និងកង្វះសាច់ប្រាក់ងាយស្រួលរបស់ធនាគារបម្រុង។ ដូចករណីមុនដែរ គំរូនេះក៏មានគោលបំណងជាអវសាន្ត គឺដើម្បីធ្វើឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើអត្រាប្រាក់កម្ចីរបស់ធនាគារ (និងអត្រាប្តូរប្រាក់ និងអត្រាផ្សេងទៀត) និងជះឥទ្ធិពលលើតម្រូវការ។ មានភស្តុតាងបង្ហាញថា ផ្អែកតាមគំរូពីរចុងក្រោយលក្ខខណ្ឌទុនបម្រុង (ដូចដែលយើងបានឃើញស្រាប់ហើយវាមិនមាននៅគ្រប់ករណីទាំងអស់) គឺជាធាតុ*មិនសំខាន់* មួយនៅក្នុងការបង្កើតរូបិយវត្ថុ។ វាគ្រាន់តែជាកត្តាមួយក្នុងចំណោមកត្តាជាច្រើន ដែលជះឥទ្ធិពលលើសាច់ប្រាក់ងាយស្រួលរបស់ធនាគារដូចដែលបានរៀបរាប់លម្អិតពីខាងដើមប៉ុណ្ណោះ។

ជាចុងក្រោយ មុនពេលដែលយើងឈានដល់យន្តការនៃការបញ្ជូនគោលនយោបាយរូបិយវត្ថុ (MPTM) ដែលកាន់តែមានសារសំខាន់ (ជាងមុន)នោះ អាជ្ញាធររូបិយវត្ថុ (ធនាគារកណ្តាល និងរតនាគារ) មិនតែងតែដោះស្រាយបញ្ហាបានត្រឹមត្រូវជានិច្ចទេ។ គេសន្មតថាធនាគារនឹងផ្តល់ប្រាក់កម្ចីដល់អតិថិជនដែលអាចជឿទុកចិត្តបាន និងសម្រាប់គម្រោងដែលអាចដំណើរការបាន។ ធនាគារកណ្តាល មានឧបករណ៍គ្រប់យ៉ាងដើម្បីទប់ស្កាត់កំណើនរូបិយវត្ថុហួសកម្រិត។ ប្រព័ន្ធនេះ គឺជាប្រព័ន្ធមួយដ៏ល្អប្រសើរមួយ ពីព្រោះវាតែងមានរូបិយវត្ថុជានិច្ចដែលបានរំដោះសេដ្ឋកិច្ចចេញពីបញ្ហាកង្វះខាតរូបិយវត្ថុយ៉ាងតឹងតែង(កាក់មាស និងមាសគីឡូ)កាលពីមុន ប៉ុន្តែមាន ភស្តុតាងជាច្រើនដែលបង្ហាញថាអាជ្ញាធរមិនមានការទទួលខុសត្រូវគ្រប់គ្រាន់...ផលវិបាក គឺជារឿងមួយដ៏ឈឺចាប់។ ថាតើត្រូវមានគំរូអនុវត្តថ្មីមួយដែលត្រូវគិតគូរពីភាពបត់បែនសេដ្ឋកិច្ចដែរឬទេ? គំរូមួយទាក់ទងនឹងការខ្ចីប្រាក់របស់ធនាគារពី រដ្ឋាភិបាលនៃបណ្តាប្រទេសក្រីក្រ សម្រាប់គម្រោងអភិវឌ្ឍន៍អាចកើតឡើងក្នុងទំហំមួយដែលប្រាក់កម្ចីបង្កើតឱ្យមានប្រាក់ចំណូលសម្រាប់ចំណាយលើអត្រាការប្រាក់កម្ចី ដោយសន្មតថាសេដ្ឋកិច្ចក្នុងស្រុកអាចផលិតទំនិញបាន(សម្រាប់តម្រូវការអភិវឌ្ឍ?)

## ៦.៣- ឥទ្ធិពលនៃគោលនយោបាយរូបិយវត្ថុ៖ អត្រាការប្រាក់ និងអតិផរណា

(Monetary policy: from interest to inflation)

យើងអាចចូលមើលគេហទំព័ររបស់ធនាគារកណ្តាល វានឹងបង្ហាញអំពីគោលបំណងនៃគោលនយោបាយរូបិយវត្ថុ ត្រូវបានអនុវត្តឡើងជាមួយនឹងការកំណត់គោលដៅសំខាន់ គឺថាអតិផរណាគួរតែត្រូវបានកាត់បន្ថយ។ ហេតុផលនៃគោលបំណងនេះ គឺការកំណត់គោលដៅអតិផរណា (inflation tar-geting) ពោលគឺរក្សាកម្រិតអតិផរណាឱ្យទាបពី ២% ទៅ ៣% ក្នុង១ឆ្នាំ អាចជួយដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។ កម្រិតអតិផរណាខ្ពស់ អាចបំផ្លិចបំផ្លាញដល់កំណើនសេដ្ឋកិច្ច ពីព្រោះអាចធ្វើឱ្យមានការប្រែប្រួលក្នុងការសម្រេចចិត្តប្រើប្រាស់ និងវិនិយោគរបស់ភ្នាក់ងារគ្រួសារដែលប្រាស់ចាកពីប្រសិទ្ធភាពកត្តាផលិតកម្ម។ ជារឿយៗអតិផរណាតែងតែពង្រីកខ្លួនរបស់វា ហើយវាពិតជាលំបាកខ្លាំងណាស់ក្នុងការលុបវា។ ដើម្បីផ្តល់សារប្រយោជន៍ដល់គោលបំណងប្រទេសអភិវឌ្ឍន៍ភាគច្រើនលើពិភពលោកមានគោលដៅអតិផរណាដែលពួកគេត្រូវបានកំណត់ត្រឹម ២% ឬមានកម្រិត ២-៣% ប្រចាំឆ្នាំ (ឬមានគោលដៅបត់បែនដូចក្នុងករណីសហរដ្ឋអាម៉េរិក)។ ជាទូទៅ គោលដៅអតិផរណាត្រូវបានកំណត់ដោយរដ្ឋាភិបាល និងប្រតិបត្តិដោយធនាគារកណ្តាល ក្នុងករណីភាគច្រើនប្រតិបត្តិការឯករាជ្យពីរដ្ឋាភិបាល។ ការបែងចែកនេះជាមុខងាររវាងរដ្ឋាភិបាល និងធនាគារកណ្តាលត្រូវបានគេទទួលស្គាល់ជាទូទៅថាមានសារសំខាន់ពីរដ្ឋាភិបាល ពីព្រោះធនាគារកណ្តាល ត្រូវតែចាត់វិធានការគោល នយោបាយរូបិយវត្ថុប្រឆាំងនឹងសកម្មភាពហិរញ្ញវត្ថុរបស់រដ្ឋាភិបាល (និងផ្សេងទៀត)។ ចំពោះប្រទេសមួយមានធនាគារកណ្តាល ធ្វើប្រតិបត្តិការមិនឯករាជ្យជាមួយរដ្ឋាភិបាលមិនត្រូវបានគេទទួលស្គាល់នេះទេ។ កម្រិតអតិផរណាចន្លោះពី ២-៣% ប្រចាំឆ្នាំត្រូវបានគេចាត់ទុកថាអាចទទួលយកបាន ពីព្រោះក្នុងកម្រិតនេះកំណើនសេដ្ឋកិច្ច និងការរំពឹងទុកក្នុងការបង្កើតទ្រព្យសម្បត្តិមានភាពល្អប្រសើរបំផុត។ នៅក្នុងកម្រិតខ្ពស់ និងកម្រិតទាបនៃផលប៉ះពាល់នៃការការពារ ឬការការពារទ្រព្យសម្បត្តិប្រជាជាតិចូលបានបញ្ចូលក្នុងសមីការផលិតផលជាតិសរុប។ មូលហេតុចម្បងនៃអតិផរណាខ្ពស់ដែលមិនអាចទទួលយកបាន គឺតម្រូវការសរុប [C + I + x - M = GDP (ចំណាយ)] ហួសសមត្ថភាពសេដ្ឋកិច្ចដើម្បីផ្តល់ (ការផ្គត់ផ្គង់សរុប)។ ផ្អែកលើកំណើនតម្រូវការនិងការផ្គត់ផ្គង់ គឺជាសមត្ថភាពរបស់ប្រព័ន្ធធនាគារក្នុងការបង្កើតរូបិយវត្ថុ។ មូលហេតុចម្បងបរិត្តផរណាគឺនៅទ្រឹង ឬបង្កើតរូបិយវត្ថុអវិជ្ជមាន។ ការកើនឡើងការបង្កើតរូបិយវត្ថុ គឺជាតម្រូវការប្រាក់កម្ចីរបស់រដ្ឋាភិបាលវិស័យវិនិយោគ និងភ្នាក់ងារគ្រួសារ ហើយការកើនឡើងនៃតម្រូវការប្រាក់កម្ចី គឺជាអត្រាការប្រាក់គោលរបស់ធនាគារ។ សម្រាប់វិស័យសាជីវកម្ម និងភ្នាក់ងារគ្រួសារមានអត្រាការប្រាក់របស់ធនាគារពិសេស។

អត្រាការប្រាក់កម្ចីរបស់ធនាគារ (lending rate of bank) ត្រូវបានកំណត់ (ក្នុងករណីភាគច្រើន) ជាប្រតិបត្តិការទីផ្សារបើកចំហ(OMO) ដើម្បីមានឥទ្ធិពលទៅលើសាច់ប្រាក់ងាយស្រួលធនាគារ និងអត្រាការប្រាក់ដែលបានកំណត់ដោយធនាគារកណ្តាល សម្រាប់ប្រាក់កម្ចីរបស់ពួកគេទៅឱ្យធនាគារ (KIR-L) ឬសម្រាប់ប្រាក់បម្រុងលើស(KIR-D)។ អ្វីដែលសំខាន់ខាងលើ គឺជាមាគ៌ានៃគោលនយោបាយរូបិយវត្ថុបញ្ជាស។ ឥឡូវនេះ យើងពិពណ៌នាសង្ខេបនូវអ្វីដែលគេហៅថាយន្តការ

បញ្ជូនគោលនយោបាយរូបិយវត្ថុ(MPTM) ចាប់ផ្តើមពីអត្រារបស់ធនាគារកណ្តាល និងបញ្ចប់ដោយអត្រាអតិផរណា។

នៅលើគេហទំព័ររបស់ធនាគារកណ្តាល នឹងបង្ហាញពីយន្តការបញ្ជូនគោលនយោបាយរូបិយវត្ថុ (MPTM) ភាគច្រើន ហើយមានរូបភាពបង្ហាញពីទស្សនៈរបស់ពួកគេអំពី MPTM ពោលគឺជាមាគ៌ាពីអត្រារបស់ធនាគារកណ្តាលទៅការអភិវឌ្ឍកម្រិតថ្លៃ (=អតិផរណា ឬបរិត្តផរណា)។ សូមមើលរូបភាពទី៥ គឺជាការបញ្ចូលគ្នានៃចំណុចខ្លះក្នុងចំណោមពួកគេ។ មុននឹងយើងចាប់ផ្តើមជាមួយនឹងការពន្លឿនយន្តការបញ្ជូនគោលនយោបាយរូបិយវត្ថុ (MPTM) យើងត្រូវតែបញ្ជាក់ពីតថភាពជាក់ស្តែងដែលការបញ្ជូនមានការផ្លាស់ប្តូរគោលនយោបាយរូបិយវត្ថុអាចចំណាយពេលពី១ទៅ២ឆ្នាំ ដើម្បីឱ្យមានឥទ្ធិពលលើការអភិវឌ្ឍន៍តម្លៃ។

គំនូសតាងទី១២ បង្ហាញពីៈ យន្តការបញ្ជូនគោលនយោបាយរូបិយវត្ថុ (MPTM)




លោកុប្បត្តិនៃអត្រាការប្រាក់ គឺអត្រាកំណត់គ្រប់គ្រងដោយធនាគារកណ្តាល[៤៩]។ ដូចយើងបានឃើញហើយថា ធនាគារកណ្តាលមួយចំនួនមានអត្រាផ្លូវការមួយគឺ KIR-L ត្រូវបានអនុវត្តចំពោះកង្វះខាតសាច់ប្រាក់ងាយស្រួល ហើយធនាគារកណ្តាលខ្លះទៀតមានអត្រាផ្លូវការចំនួនពីរ គឺអត្រាដែលត្រូវបានបញ្ជាក់ និងអត្រាប្រាក់បញ្ញើសម្រាប់ផ្នែកបន្ថែម KIR-D។ គំរូម៉ូដែលទាំងពីរនេះ មានឥទ្ធិពលដោយផ្ទាល់លើអត្រា b2b-IBM ដែលជះឥទ្ធិពលយ៉ាងខ្លាំងដល់អត្រាការប្រាក់របស់ធនាគារ (ជាពិសេសអត្រាការប្រាក់បញ្ញើប្រចាំថ្ងៃ)។ អត្រាប្រាក់បញ្ញើផ្សេងទៀតរបស់ធនាគារ ក៏មានប៉ះពាល់ដោយសារតែអត្រានេះដែរ។ កិច្ចខិតខំប្រឹងប្រែងរបស់ធនាគារ ដើម្បីស្វែងរកប្រាក់ចំណេញឱ្យបានច្រើនបំផុតសម្រាប់ម្ចាស់ភាគហ៊ុន ដោយព្យាយាមរក្សាកម្រិតមធ្យមភាគរវាងថ្លៃដើមនៃប្រាក់បញ្ញើ ឬប្រាក់កម្ចី

[៤៩] *Here we ignore the firm_RR model, where is essentially a theoreticsl model rarely applied today*

និងប្រាក់ចំណូលលើទ្រព្យសកម្ម។ ដូច្នេះការផ្លាស់ប្តូរអត្រាការប្រាក់ផ្លូវការមានផលប៉ះពាល់យ៉ាងខ្លាំងដល់អត្រាការប្រាក់កម្ចីរបស់ធនាគារ។

អត្រាពង្រីកប្រាក់កម្ចីប្រាក់ចំណេញខ្ពស់របស់ធនាគារ គឺជាអត្រាការប្រាក់គោលរបស់ធនាគារ។ រាល់អត្រាប្រាក់កម្ចីរបស់ធនាគារសម្រាប់ NMD ត្រូវបានកំណត់ជាមូលដ្ឋាននៅលើអត្រាការប្រាក់គោលរបស់ធនាគារ(PR)។ អត្រាបំណុលដែលអាចលក់បាន (ដូចជាវិក្កយបត្ររតនាគារ និងប័ណ្ណពាណិជ្ជ) ក៏មានឥទ្ធិពលគួរឱ្យកត់សម្គាល់ផងដែរ។ ជាទូទៅការផ្លាស់ប្តូរ KIR របស់ធនាគារកណ្តាលត្រូវបាន ផ្គូផ្គងដោយការផ្លាស់ប្តូរអត្រាការប្រាក់កម្ចីរបស់ធនាគារ។ អត្រាប្រាក់កម្ចីធនាគារ គឺជាធាតុចូលដ៏សំខាន់ក្នុងការសម្រេចចិត្តក្នុងការខ្ចីប្រាក់។ បុគ្គលខ្ចីប្រាក់ពីធនាគារ និងអ្នកប្រើប្រាស់ក្នុងការរំពឹងទុកនៃប្រាក់ចំណូលរបស់ពួកគេនាពេលអនាគត។ ក្រុមហ៊ុនខ្ចីប្រាក់សម្រាប់គោលបំណងពង្រីកអាជីវកម្ម (ស្តុក ទំនិញ និងការពង្រីកហេដ្ឋារចនាសម្ព័ន្ធអាជីវកម្ម)។

វិស័យធនាគារឆ្លើយតបទៅនឹងតម្រូវការប្រាក់កម្ចី និងបង្កើតរូបិយវត្ថុ(ប្រាក់បញ្ញើ) ផ្តល់ជូនដល់បុគ្គលដែលគួរឱ្យកម្ចី (មានការងារធ្វើនឹងអាចសងបំណុលបាន) ហើយក្រុមហ៊ុនកំពុងខ្ចីប្រាក់សម្រាប់គម្រោងថ្មីៗដែលលំហូរសាច់ប្រាក់ ឬត្រឡប់មកវិញ(FVs) នាពេលអនាគតលើសពីតម្លៃនៃកម្ចីប្រាក់។

ការកើនឡើងអត្រាការប្រាក់នឹងធ្វើឱ្យបុគ្គលកាន់តែច្រើនមិនសម្រេចចិត្តខ្ចីប្រាក់ និងគម្រោងជាច្រើនទៀត ដែលមិនអាចទទួលយកបានត្រូវបានកាត់បន្ថយអត្រាកំណើនវិនិយោគ ខណៈពេលអត្រាការប្រាក់ធ្លាក់ចុះនឹងធ្វើឱ្យមានកើនឡើងគម្រោងវិនិយោគ។ ការខ្ចីប្រាក់ ឬការបង្កើតប្រាក់ គឺកត្តាចម្បងក្នុងការផ្លាស់ប្តូរតម្រូវការក្នុងស្រុក។

មិនមែនសុទ្ធតែបុគ្គល និងក្រុមហ៊ុនទាំងអស់ខ្ចីប្រាក់ពីវិស័យធនាគារនោះទេ។ សាធារណជនមួយចំនួនធំ គឺក៏ជាអ្នកផ្តល់កម្ចី ឬអ្នកសន្សំ និងអត្រាការប្រាក់សម្រាប់ពួកគេក៏មានសារសំខាន់សម្រាប់អ្នកខ្ចីផងដែរ។ អត្រាការប្រាក់ទាបធ្វើឱ្យការសន្សំមិនសូវមានការទាក់ទាញទេ រីឯការចំណាយកាន់តែមានភាពទាក់ទាញខ្លាំង។ ការនិយាយគ្នាក៏អនុវត្តនេះដែរ។ ការផ្លាស់ប្តូរអត្រាផ្លូវការមានផលប៉ះពាល់ភ្លាមៗទៅលើតម្លៃទ្រព្យផ្សេងទៀត។ ទាំងនេះជាអ្វី? ទាំងនេះ គឺជាតម្លៃនៃទ្រព្យសកម្មក្រៅពីតម្លៃទ្រព្យសម្បត្តិរបស់ធនាគារមានដូចជាសញ្ញាប័ណ្ណ ប័ណ្ណភាគហ៊ុន(ភាគហ៊ុន) ទ្រព្យសម្បត្តិ និងទំនិញ។ លើកលែងតែប្រភេទទំនិញបានលើកឡើងនេះ (សញ្ញាប័ណ្ណ ប័ណ្ណភាគហ៊ុន និងទ្រព្យសម្បត្តិ) ដែលប្រភេទទំនិញទាំងនេះមានលំហូរសាច់ប្រាក់នាពេលអនាគត។ អ្នកនឹងចាំបានថាតម្លៃបច្ចុប្បន្ន (= PV) លំហូរសាច់ប្រាក់នាពេលអនាគត (FV) ត្រូវបានបញ្ចុះអប្បហារដោយអត្រាការប្រាក់ជាក់លាក់ដែលទាក់ទងទៅនឹង (PV)។ ដូច្នេះនៅពេលដែលអត្រាការប្រាក់កើនឡើង នោះធ្វើឱ្យតម្លៃទ្រព្យសកម្មមានការធ្លាក់ចុះ ហើយករណីនេះបញ្ច្រាសគ្នាវិញ។

ប្រភេទទំនិញដូចជា (សញ្ញាប័ណ្ណ ប័ណ្ណភាគហ៊ុន និងទ្រព្យសម្បត្តិ) មិនមានលំហូរសាច់ប្រាក់នាពេលអនាគតទេ។ ប៉ុន្តែអត្រាការប្រាក់ខ្ពស់ធ្វើឱ្យវាមិនសូវទាក់ទាញការវិនិយោគ ហើយផ្ទុយទៅវិញអត្រាទាបធ្វើឱ្យមានការទាក់ទាញវិនិយោគ។ ដោយសារតែបុគ្គល និងក្រុមហ៊ុនគឺជាម្ចាស់ទ្រព្យសម្បត្តិនៃប្រព័ន្ធហិរញ្ញវត្ថុ (ដោយផ្ទាល់ ឬដោយប្រយោលតាមរយៈវិស័យធនាគារ និងវិស័យវិនិយោគ) តម្លៃនៃទ្រព្យសកម្មមានឥទ្ធិពលយ៉ាងខ្លាំងទៅលើតម្រូវការក្នុងស្រុក (C + I)។

ការផ្លាស់ប្តូរអត្រាផ្លូវការរបស់ធនាគារកណ្តាលក៏ជះឥទ្ធិពលដល់ការរំពឹងទុក និងកម្រិតទំនុកចិត្ត របស់ក្រុមហ៊ុន និងបុគ្គល ដែលមានឥទ្ធិពលលើតម្រូវការក្នុងស្រុក។ ផលប៉ះពាល់ទាំងនេះ ក៏មានជះឥទ្ធិពលដល់វិស័យបរទេសផងដែរ។ ដូច្នេះ អត្រាប្តូរប្រាក់ជះឥទ្ធិពលយ៉ាងខ្លាំងទៅលើតម្រូវការខាងក្រៅសុទ្ធ (X - M) និងតម្លៃការនាំចូល។ ការផ្លាស់ប្តូរតម្រូវការក្នុងស្រុកមានផលប៉ះពាល់ដល់វិស័យការងារ។ ប្រសិនបើ មានសម្ពាធទៅលើការផ្គត់ផ្គង់ផ្នែកជំនាញ វាមានសម្ពាធលើប្រាក់ឈ្នួលពលកម្ម ដែលជាផលប៉ះពាល់ដល់តម្លៃរបស់អ្នកប្រើប្រាស់។

ដូចដែលបានឃើញហើយចំណុចទាំងអស់ខាងលើ គឺជាកត្តាសំខាន់នៃតម្រូវការក្នុងស្រុក ហើយប្រព័ន្ធធនាគារ ជួយដល់តម្រូវការតាមរយៈការផ្តល់ប្រាក់កម្ចី [ការពេញចិត្តប្រាក់កម្ចីគឺសមភាគីនៃប្រាក់បញ្ញើធនាគារថ្មី (=ប្រាក់)]។ សមត្ថភាពសេដ្ឋកិច្ចក្នុងការផ្គត់ផ្គង់ទំនិញ និងសេវាកម្មថ្មីៗ ដើម្បីបំពេញតម្រូវការកើនឡើងគឺជាកត្តាដ៏សំខាន់។

គម្លាតកាន់តែធំរវាងតម្រូវការសរុប(=សរុប) និងការផ្គត់ផ្គង់សរុប គឺជាកត្តាចម្បងក្នុងការអភិវឌ្ឍតម្លៃ (price developments)។ ការប្រែប្រួលតម្លៃទំនិញនាំចូលទៅមុខងារមួយនៃអត្រាប្តូរប្រាក់ គឺជាកត្តាដ៏សំខាន់មួយ ប៉ុន្តែកត្តានេះ អាស្រ័យលើទំហំតម្រូវការខាងក្រៅសុទ្ធទាក់ទងតម្រូវការក្នុងស្រុក។ វង្វិលជុំសេដ្ឋកិច្ច ត្រូវបានបញ្ចប់នៅពេលដែលមនុស្សម្នាក់ពិចារណាថា ការអភិវឌ្ឍតម្លៃជាផលប៉ះពាល់ដល់ការសម្រេចចិត្តគោលនយោបាយរូបិយវត្ថុ។

ពាក្យចុងក្រោយ ក្នុងខែសីហា ឆ្នាំ២០០៧ យើងបានឃើញផ្នែកដ៏អាក្រក់នៃប្រព័ន្ធរូបិយវត្ថុ។ ការបង្កើតរូបិយវត្ថុ គឺមានច្រើនពេកហើយយើងបានឃើញអតិផរណាកើនឡើងនៅទូទាំងពិភពលោក ដែលឆ្លុះបញ្ចាំងពីការកើនឡើងនៃតម្លៃទំនិញអន្តរជាតិ ដូចជា ប្រេង ចំណីអាហារ ដែកថែប ជាដើម។

អ្នកបានដឹងហើយថា វាមានទំហំធំ (នៅសហរដ្ឋអាមេរិក) ដោយផ្អែកលើការផ្តល់ប្រាក់កម្ចីរបស់ធនាគារឱ្យដល់អ្នកខ្ចីដែលមិនគួរឱ្យគោរព។ នេះគឺការបរាជ័យមិនត្រឹមតែជំហរនៃការជឿទុកចិត្តដែលធនាគារកាន់កាប់ប្រាក់នោះទេ ដោយសារតែសមត្ថភាពរបស់ធនាគារក្នុងការបង្កើតរូបិយវត្ថុ ពីព្រោះសាធារណជនជាទូទៅទទួលយកប្រាក់បញ្ញើធនាគារជាមធ្យោបាយទូទាត់ប្រាក់ដ៏សំខាន់ ប៉ុន្តែក៏ជាការបរាជ័យរបស់អ្នកចូលរួមសម្ព័ន្ធភាពមួយចំនួននៅក្នុងប្រព័ន្ធរូបិយវត្ថុះ

ធនាគារកណ្តាល នៅក្នុងការអនុវត្តមិនមានប្រសិទ្ធិភាពនៃគោលនយោបាយរូបិយវត្ថុ និយតករធនាគារដែលមិនបានត្រួតពិនិត្យធនាគារឱ្យមានប្រសិទ្ធភាព និងទីភ្នាក់ងារវាយតម្លៃចំណាត់ថ្នាក់ប្រាក់កម្ចីមួយចំនួនធំ ដែលត្រូវបានបិទបាំងដោយប្រាក់ចំណូល ដែលបានមកពីការវាយតម្លៃបំណុលទ្រព្យសម្បត្តិ ឬអង្គភាព ដែលមានគោលបំណងពិសេស (SPVs/SPEs) ហើយភ្លេចទំនាស់ផលប្រយោជន៍ដែលពួកគេមាន។ ជាក់ស្តែងនេះ មិនបានអនុវត្តចំពោះប្រទេសទាំងអស់ទេ។ ប៉ុន្តែយើងមិនត្រូវភ្លេចពីពេលវេលាល្អៗ មុនសម័យកាលនេះទេ នៅពេលដែលការបង្កើតទ្រព្យសម្បត្តិមិនធ្លាប់មានពីមុនមក។ នេះ គឺជាផ្នែកដ៏ប្រណិតនៃប្រព័ន្ធរូបិយវត្ថុដែលអាចធ្វើទៅបានដោយអព្ភូតហេតុនៃការបង្កើតរូបិយវត្ថុ។

សរុបរួម គោលនយោបាយរូបិយវត្ថុចាំបាច់ត្រូវបានគិតទុកជាមុនះសម្រាប់ហេតុផលនេះធនាគារ កណ្តាលប្រើគំរូអេកូណូមេទ្រីក ដែលមានលក្ខណៈទំនើបសម្រាប់ការត្រួតពិនិត្យឡើងវិញ។ គោលនយោបាយរូបិយវត្ថុ គឺដំណើរការគ្រប់គ្រងបរិមាណការផ្គត់ផ្គង់រូបិយវត្ថុសរុបនៅក្នុងសេដ្ឋកិច្ច ដើម្បីស

ម្រេចបាននូវគោលដៅម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ ដូចជាការបន្ទាបអត្រាអតិផរណា ការបង្កើននិកម្មភាព និងកំណើនសេដ្ឋកិច្ច។ សម្រាប់គោលដៅមួយផ្សេងទៀតនៃគោលនយោបាយរូបិយវត្ថុ គឺជាការបង្កើនបរិមាណរូបិយវត្ថុ អត្រាប្តូរប្រាក់ បរិមាណរូបិយវត្ថុ និងគុណភាពនៃការឱ្យខ្ចី ស្ថានភាពនៅលើទីផ្សារមូលប័ត្រ តម្រូវការសរុបរបស់សេដ្ឋកិច្ច និងលំហូរមូលនិធិឆ្លងដែន។ល។

## ៦.៤- ឥទ្ធិពលរុញចេញនៃគោលនយោបាយរូបិយវត្ថុ

( Crowding-out effect on MP )

ខ្លឹមសារនៃឥទ្ធិពលរុញចេញ គឺជាគោលនយោបាយសារពើពន្ធពង្រីក (ឬហៅថាគោលនយោបាយឱនភាពថវិកា) ដើម្បីជំរុញកំណើនសេដ្ឋកិច្ចដោយប្រើឧបករណ៍គោលនយោបាយសារពើពន្ធតាមរយៈបង្កើនចំណាយរបស់រដ្ឋាភិបាល និងការកាត់បន្ថយកម្រិតពន្ធ ដើម្បីជំរុញខ្សែកោងតម្រូវការសរុបឱ្យរំកិលទៅខាងស្តាំ(ឥទ្ធិពលរុញចេញ)។ ខណៈពេលបង្កើនការចំណាយរបស់រដ្ឋាភិបាល ជំរុញឱ្យមានកំណើនតម្រូវការសរុបទៅលើទំនិញ និងសេវា ពេលនោះវានឹងបណ្តាលឱ្យអត្រាការប្រាក់កើនឡើងផងដែរ ហើយអត្រាការប្រាក់កើនឡើង បានជះឥទ្ធិពលលើការចំណាយវិនិយោគ និងសម្ពាធសម្រាប់តម្រូវការសរុបផងដែរ។ ថាតើឥទ្ធិពលរុញចេញនឹងកើតឡើងពិតប្រាកដអាស្រ័យលើគម្លាតវិបត្តិសេដ្ឋកិច្ច នៅពេលរដ្ឋាភិបាលអនុវត្តនូវគោលនយោបាយសារពើពន្ធពង្រីករបស់ខ្លួនឬ? ទោះបីជាយ៉ាងនេះក្តី ក៏នៅមានឥទ្ធិពលនៃគោលនយោបាយផ្សេងទៀត កំពុងដំណើរការក្នុងទិសដៅបញ្ច្រាសគ្នាផងដែរ។ ការថយចុះតម្រូវការសរុបកើតឡើង នៅពេលគោលនយោបាយសារពើពន្ធរបស់រដ្ឋាភិបាលត្រូវបានបង្កើនអត្រាការប្រាក់ និងកាត់បន្ថយការវិនិយោគត្រូវបានគេហៅថា "**ឥទ្ធិពលរុញចេញ**"។ ជាឧទាហរណ៍ ប្រសិនបើ រដ្ឋាភិបាល បង្កើនកាចំណាយចំនួនទឹកប្រាក់ ៥០០លានដុល្លារ សម្រាប់ការទិញលើទំនិញ និងសេវាតាមរយៈការចំណាយរបស់រដ្ឋាភិបាលទាំងនេះ បានជំរុញកំណើនតម្រូវការសរុប ដូចជាចំណូលពីប្រាក់បៀវត្សរបស់កម្មករ និងចំណូលក្រុមហ៊ុនអាជីវកម្ម (ឥទ្ធិពលគុណ) សម្រាប់ក្រុមហ៊ុនផ្សេងទៀតក៏នឹងទទួលបានផលចំណេញ។ ពេលចំណូលកើនឡើង ភ្នាក់ងារគ្រួសារមានគម្រោងចំណាយកាន់តែច្រើនឡើងលើទំនិញ និងសេវា ជាលទ្ធផលភ្នាក់ងារគ្រួសារមានជម្រើសបន្ថែមទៀតនៅក្នុងទម្រង់សន្ទនីយ។ ពោល គឺចំណូលកើនឡើងដោយសារតែគោលនយោបាយសារពើពន្ធពង្រីក តាមរយៈការបង្កើនតម្រូវការរូបិយវត្ថុដូចមានបង្ហាញលើក្រាហ្វិកទី៩ខាងក្រោម។

### *ទិដ្ឋភាពទ្រឹស្តីឥទ្ធិពលរុញចេញ៖*

អំឡុងពេលមានវិបត្តិសេដ្ឋកិច្ចធ្ងន់ធ្ងរ (During deep recessionary)៖

ឥទ្ធិពលរុញចេញ (Crowding-out effect) ហាក់បីដូចជាមិនងាយនឹងកើតមានឡើងឡើយ។ ក្នុងន័យថា ការវិនិយោគក្នុងវិស័យឯកជនមានការធ្លាក់ចុះយ៉ាងខ្លាំងក្លារួចជាស្រេចទៅហើយ នៅពេលមានគម្លាតវិបត្តិសេដ្ឋកិច្ចធ្ងន់ធ្ងរបែបនោះ។ ករណីការចំណាយដ៏តិចតួចនោះ ឥទ្ធិពលរុញចេញដែលអាចកើតទៅបាន លុះត្រាតែរដ្ឋាភិបាលគួរតែផ្តល់នូវការខ្ចីប្រាក់ក្នុងកម្រិតមួយ ដែលមានកម្រិតអត្រាការប្រាក់ទាប។

អំឡុងពេលមានវិបត្តិនៃសេដ្ឋកិច្ចមិនធ្ងន់ធ្ងរ (During mild recessions)៖

ឥទ្ធិពលរុញចេញ គឺទំនងជាអាចកើតមានឡើង។ ដោយសារការប្រើប្រាស់ធនធានសេដ្ឋកិច្ចត្រូវបានបិទបញ្ចប់វិបត្តិសេដ្ឋកិច្ចដោយធ្វើឱ្យមាននិកម្មភាពពេញលេញ និងជំរុញការចំណាយវិស័យវិនិយោគឯកជនកាន់តែខ្ពស់។ ករណីនេះ រដ្ឋាភិបាលអាចផ្តល់នូវកម្រិតអត្រាការប្រាក់ឱ្យបានខ្ពស់ជាងមុន ដើម្បីទាក់ទាញឱ្យអ្នកផ្តល់នូវប្រាក់កម្ចីឱ្យកាន់តែច្រើនឡើង។

ក្រាហ្វិកទី៩ បង្ហាញពី៖ ឥទ្ធិពលរុញចេញ (Cross-out effect)




## ៦.៤.១- តើអ្វីជាឥទ្ធិពលរុញចេញ? (What is Crowding Out?)

ឥទ្ធិពលរុញចេញ (Crowding-out) គឺជារុញចេញកំណើនសេដ្ឋកិច្ចឱ្យធ្លាប់រហ័សតាមរយៈការចំណាយ ឬការឱ្យខ្ចីប្រាក់របស់រដ្ឋាភិបាល ដើម្បីផ្លាស់ប្តូរនូវធនធានសេដ្ឋកិច្ចខ្សត់កម្រក្នុងវិស័យឯកជនទៅកាន់វិស័យសាធារណៈ ដែលមានកម្រិតផលិតភាពអាចនៅមានកម្រិតទាបជាង។ រាល់ការចំណាយរបស់រដ្ឋាភិបាល គឺជាការចំណាយសាធារណៈលើទំនិញ និងសេវាកម្មរបស់សង្គមជាតិ ដូចជាការចំណាយលើវិស័យអប់រំ ការចំណាយលើការថែទាំសុខភាព និងការចំណាយលើការការពារជាតិជាដើម។ រាល់ការចំណាយទាំងនេះ គឺជាឥទ្ធិពលរុញចេញ (Crowding-out effect) របស់គោលនយោបាយសារពើពន្ធរបស់រដ្ឋាភិបាលតាមរយៈការចំណាយផ្ទេរ(Transfer payments) របស់រដ្ឋាភិបាលសម្រាប់ការចំណាយសាធារណៈលើសុខុមាលភាពសង្គមចំពោះបុគ្គលចាស់ជរា អនិកម្មភាព សោធននិវត្តិន៍ជាដើម។ ការចំណាយឡើងវិញលើសេវា សាធារណៈទាំងនេះមានឥទ្ធិពលរុញចេញជាស្វ័យប្រវត្តិ ដែលជំរុញកំណើនសេដ្ឋកិច្ចមានស្ថិរភាពរយៈពេលវែង។ ជាពិសេស ការរុញចេញកំណើនវិនិយោគរបស់រដ្ឋាភិបាលលើគម្រោងធំៗ ដែលមានដូចជា ហេដ្ឋារចនាសម្ព័ន្ធ ស្ពាន ផ្លូវថ្នល់ ជាដើម។

ជាលទ្ធផល ឥទ្ធិពលនៃរុញចេញ មានដំណើរការលើការចំណាយរបស់រដ្ឋាភិបាលលើសុខភាពសង្គមជាតិ ដែលជាកត្តាជំរុញឱ្យមានការចំណាយសេវាសាធារណៈកើនឡើង តាមរយៈការបង្កើនគម្រោងវិនិយោគធំៗរបស់រដ្ឋ ដើម្បីបង្កើនកំណើនសេដ្ឋកិច្ច ខ្សែកោងតម្រូវការសរុបរំកិលទៅផ្នែកខាងស្តាំ។

គំនូសតាងទី១៣ បង្ហាញ៖ ឥទ្ធិពលរុញចេញ (Crowding-out effect)




## ការវិភាគលើទ្រឹស្តីនៃឥទ្ធិពលរុញចេញ៖

គំនូសតាងទី៧ ខាងក្រោមនេះបង្ហាញពីដំណើរការប្រព្រឹត្តិទៅនៃឥទ្ធិពលរុញចេញរបស់រដ្ឋាភិបាល ដែលបានបង្កើនការចំណាយសាធារណៈលើការទិញទំនិញ និងសេវារបស់រដ្ឋាភិបាល។ ខណៈពេលរដ្ឋាភិបាលបានបង្កើនការចំណាយលើការទិញទំនិញ និងសេវា ដើម្បីជំរុញកំណើនតម្រូវការសរុបកើនឡើង។ ប្រសិនបើករណីរដ្ឋាភិបាលបានបង្កើនការចំណាយរបស់ខ្លួននាំឱ្យមានកម្រិតឱនភាពថវិកាជាតិនៅពេលនោះតម្រូវឱ្យរដ្ឋាភិបាលលក់ប័ណ្ណបំណុលត្រូវបានកើតឡើង។ បណ្តាលឱ្យការខ្ចីប្រាក់កើន ហើយអត្រាការប្រាក់កើនឡើងកាន់តែខ្ពស់ផងដែរ នាំឱ្យកាត់បន្ថយការវិនិយោគវិស័យឯកជន និងការប្រើប្រាស់របស់គ្រួសារបានជះឥទ្ធិពលលើតម្រូវការសរុប។ ករណីរដ្ឋាភិបាលចង់បង្កើនការចំណាយសេវាសាធារណៈចាំបាច់ត្រូវតែបង្កើនការប្រមូលចំណូលពន្ធឱ្យបានច្រើនជាងការចំណាយរបស់ខ្លួន។ ករណីការបង្កើនចំណូលពន្ធរបស់រដ្ឋាភិបាលនឹងជះឥទ្ធិពលទៅលើការប្រើប្រាស់របស់គ្រួសារ ដូចជាផលប៉ះពាល់ដល់ការវិនិយោគវិស័យឯកជនផងដែរ។ ចំពោះការបង្កើនអត្រាការប្រាក់នាំឱ្យកាត់បន្ថយការវិនិយោគឯកជននេះ ដោយសាររដ្ឋាភិបាលបានអនុវត្តគោលនយោបាយសារពើពន្ធពង្រីក មានឥទ្ធិពលតិចតួចលើវិនិយោគឯកជន និងការប្រើប្រាស់របស់គ្រួសារត្រូវបានគេហៅថា "*ឥទ្ធិពលរុញចេញ*"។

ដូច្នេះ កំណើននៃអត្រាការប្រាក់នាំឱ្យកាត់បន្ថយបរិមាណតម្រូវការលើការទិញទំនិញ និងសេវាដោយសារថ្លៃដើមលើទំនិញ និងសេវាកើនឡើង រួមបញ្ចូលអត្រាការប្រាក់កម្ចីមានកម្រិតខ្ពស់ជាកត្តានាំឱ្យធ្លាក់ចុះតម្រូវការចំណាយលើការប្រើប្រាស់ និងកាត់បន្ថយការវិនិយោគ។

ឧទាហរណ៍៖ ចំណាយសេវាសាធារណៈរបស់រដ្ឋាភិបាលអង់គ្លេស ដែលសរុបមានបរិមាណ ៧៤៥ពាន់លានផោន នៅក្នុងឆ្នាំ២០០៥។ នេះគឺស្មើនឹង ៤៣% នៃផលិតផលក្នុងស្រុកសរុប។ ក្នុងនោះដែរ មានទឹកប្រាក់ចំនួន ៥០ ពាន់លានផោន ទៅលើការចំណាយមូលធន។ ការចំណាយលើសេវាសាធារណៈដូចជា ការអប់រំ និងសុខភាព ស្មើនឹង ៤៣% នៃផលិតផលក្នុងស្រុកសរុប (GDP)។

សរុបរួម ទិដ្ឋភាពទ្រឹស្តីនៃឥទ្ធិពលរុញចេញតាមរយៈគំនូសតាងខាងលើនេះ មានខ្លឹមសារថា ប្រសិនបើរដ្ឋាភិបាលបង្កើនការចំណាយលើការទិញទំនិញ និងសេវារបស់ខ្លួនតម្រូវការសរុបសម្រាប់ទំនិញ និងសេវា អាចកើតឡើងដោយតែចំនួនច្រើនជាង ឬតិចជាងនេះប៉ុណ្ណោះ អាស្រ័យលើឥទ្ធិពលគុណ ឬឥទ្ធិពលរុញចេញធំជាង។

### ៦.៤.២- ការវិភាគឥទ្ធិពលរុញចេញ ( Analysis Crowding out )

វិភាគឥទ្ធិពលរុញចេញ គឺជាគោលនយោបាយសារពើពន្ធពង្រីក (គោលនយោបាយឱនភាពថវិកា) គឺជួយឱ្យមានកំណើនអត្រាការប្រាក់ និងកាត់បន្ថយការចំណាយវិនិយោគ មានន័យថាការថយចុះវិស័យវិនិយោគឯកជន។ ហេតុនេះ វាបានធ្វើឱ្យថយចុះ ឬផ្តាច់ទាំងស្រុងឥទ្ធិពលនៃគោលនយោបាយពង្រីក។ ថាតើឥទ្ធិពលរុញចេញ វានឹងកើតឡើងពិតប្រាកដអាស្រ័យលើជម្រៅវិបត្តិនៃសេដ្ឋកិច្ច ខណៈពេលដែលរដ្ឋាភិបាលអនុវត្តនូវគោលនយោបាយសារពើពន្ធពង្រីករបស់ខ្លួន។ ក្នុងករណីរដ្ឋាភិបាល បង្កើនប្រាក់កម្ចីនាំឱ្យមានតម្រូវការកើនខ្ពស់សម្រាប់មូលនិធិដែលអាចខ្ចីបាន និងការកើនឡើងអត្រាការប្រាក់។

ឧទាហរណ៍៖ មូលប័ត្របំណុលដែលនេះអាចបង្កើនការខ្ចីប្រាក់ សម្រាប់អាជីវកម្មនៅក្នុង វិស័យឯកជន។

ឧបមាថា៖ សេដ្ឋកិច្ចស្ថិតក្នុងស្ថានភាពធ្លាក់ចុះ រដ្ឋាភិបាលចាត់វិធានការគោលនយោបាយពង្រីក ដោយបង្កើនចំណាយរដ្ឋាភិបាល។ ដោះស្រាយបញ្ហានេះ រដ្ឋាភិបាលត្រូវចេញមុខលើទីផ្សាររូបិយវត្ថុ ក្នុងគោលបំណងផ្តល់ហិរញ្ញប្បទានសម្រាប់ឱនភាពថវិកា។ បន្ទាប់ពីនេះ ការកើនឡើងតម្រូវការរូបិយវត្ថុ គឺបានធ្វើឱ្យអត្រាការប្រាក់ឡើងខ្ពស់។ ពេលគឺបរិមាណនៃប្រាក់កម្ចីកើនឡើងខ្ពស់។ ដោយសារតែការចំណាយបានប្រែប្រួលបញ្ច្រាសសមាមាត្រទៅនឹងអត្រាការប្រាក់ ដែលជាកត្តានាំឱ្យការវិនិយោគមួយចំនួនត្រូវបង្អាក់ ឬរុញចេញ។ ដូចមានបង្ហាញលើក្រាហ្វិកទី១០ ខាងក្រោមនេះ។

ក្រាហ្វិកទី ១០ បង្ហាញពី៖ វិភាគឥទ្ធិពលរុញចេញ ( Analysis of cross-out effect )




### ៦.៤.៣- ការវាយតម្លៃទ្រឹស្តីរុញចេញ ( Evaluating of Crowding Out Theory )

- ប្រូបាប៊ីលីតេនៃឥទ្ធិពលរុញចេញបានកំណត់ ១០០% គឺជាឧបករណ៍បញ្ហាពីចម្ងាយ ប្រសិនបើ សកម្មភាពសេដ្ឋកិច្ចកំពុងដំណើរការកម្រិតទាបជាងសមត្ថភាពរបស់ខ្លួន

នោះ ហើយការផ្គត់ផ្គង់មានការសន្សំចំនួនដ៏ច្រើនអាចរកបាន ដើម្បីទិញប័ណ្ណបំណុលរបស់រដ្ឋទើបចេញថ្មី(មូលប័ត្ររដ្ឋ)។

- តាមរយៈសេដ្ឋវិទូលោកកេនស៍ បានអះអាងថាឱនភាពសារពើពន្ធមានឥទ្ធិពលរុញចូលដែលធ្វើឱ្យមានកង្វះខាតការវិនិយោគវិស័យឯកជន។
- ការអនុវត្តគោលនយោបាយឱ្យចំគោលដៅបានល្អ ទាន់ពេលវេលា និងស្ថានភាពបណ្ដោះអាសន្ន ការចំណាយរបស់រដ្ឋាភិបាលអាចស្រូបទាញយកសមត្ថភាពការប្រើប្រាស់ដែលមិនសូវបានល្អ ដើម្បីផ្ដល់នូវឥទ្ធិពលមេគុណខ្លាំងក្លាដែលបង្កើតចំណូលពន្ធបន្ថែម។
- ការរិះគន់លើទ្រឹស្ដីជាមូលដ្ឋាន គឺថាការផ្គត់ផ្គង់មូលនិធិដែលអាចរកខ្ចីបានមិនត្រូវបានកំណត់តែប្រភពក្នុងស្រុកទេ ក៏ប៉ុន្តែហិរញ្ញវត្ថុខាងក្រៅស្រុកក៏អាចរកខ្ចីបានដែរ។

ដូចនេះ បង្វែរការចាប់អារម្មណ៍បញ្ហានៃការអនុវត្តន៍នូវគោលនយោបាយសារពើពន្ធទៅជាគុណវិបត្តិសំខាន់ៗនៃគោលនយោបាយសារពើពន្ធ។ ជាទ្រឹស្ដីឥទ្ធិពលរុញច្រានចេញ គឺជាគោលនយោបាយសារពើពន្ធពង្រីក ដែលជំរុញឱ្យមានកំណើនអត្រាការប្រាក់ និងបន្ថយចំណាយវិនិយោគឯកជន។ ហេតុនេះ វាធ្វើឱ្យថយចុះ ឬកាត់ផ្ដាច់នូវឥទ្ធិពលនៃគោលនយោបាយសារពើពន្ធពង្រីកទាំងស្រុង។

ករណី សេដ្ឋកិច្ចស្ថិតក្នុងស្ថានភាពធ្លាក់ចុះ រដ្ឋាភិបាលចាត់វិធានការគោលនយោបាយ ធន្ទានុសិទ្ធិ ដោយបង្កើនការចំណាយរបស់រដ្ឋាភិបាល។ ដើម្បីបំពេញតម្រូវការការងារនោះ រដ្ឋាភិបាលនឹងចេញមុខលើទីផ្សាររូបិយវត្ថុក្នុងគោលបំណង ដើម្បីផ្ដល់ហិរញ្ញប្បទានឱនភាព។ បន្ទាប់ពីនោះ ការកើនឡើងតម្រូវការលុយគឺវាធ្វើឱ្យអត្រាការប្រាក់ឡើងខ្ពស់ ពោលគឺថ្លៃនៃប្រាក់កម្ចីកើនខ្ពស់។ ដោយហេតុថាការចំណាយត្រូវបានប្រែប្រួលបញ្ច្រាសសមាមាត្រនឹងអត្រាការប្រាក់ និងវិស័យវិនិយោគឯកជនមួយចំនួននឹងត្រូវបង្អាក់ ឬរុញចេញ (Choked-off ឬCrowded-out)។

ឥទ្ធិពលតួគុណបញ្ជាក់ថា ពេលរដ្ឋាភិបាលទិញទំនិញ និងសេវាមានទឹកប្រាក់ចំនួន៥០ពាន់លានដុល្លារពីក្រុមហ៊ុន។ បានបង្ហាញឱ្យឃើញថា លទ្ធផលកំណើនតម្រូវការសរុប ជាធម្មតាមានទំហំធំជាង៥០ពាន់លានដុល្លារ។ ខណៈពេលដែលកំណើនការទិញរបស់រដ្ឋាភិបាលជំរុញឱ្យមានកំណើនតម្រូវការសរុបសម្រាប់ទំនិញ និងសេវាកម្មបណ្ដាលឱ្យអត្រាការប្រាក់កើន បើករណីអត្រាការប្រាក់កើនខ្ពស់នោះ ក៏នឹងកាត់បន្ថយដល់ការវិនិយោគផងដែរ ហើយជាសម្ពាធសម្រាប់តម្រូវការសរុប។ តំហយតម្រូវការសរុបដែលកើតឡើងពេលការពង្រីកគោលនយោបាយសារពើពន្ធ បង្កើនអត្រាការប្រាក់ត្រូវបានហៅថាឥទ្ធិពលនៃការរុញចេញ (Crowding-out effect)។

ឥទ្ធិពលនៃរុញចេញកើតឡើងនៅក្នុងទីផ្សាររូបិយវត្ថុ។ ខណៈពេលរដ្ឋាភិបាលទិញទំនិញពីក្រុមហ៊ុនកំណើនក្នុងតម្រូវការនឹងបង្កើនប្រាក់ចំណូលរបស់កម្មករ និងម្ចាស់ក្រុមហ៊ុន (ឥទ្ធិពលតួគុណ)។ ការកើនឡើងចំណូលរបស់ក្រុមគ្រួសារ មានផែនលើការចំណាយលើការប្រើប្រាស់ទំនិញ និងសេវាកម្មកាន់តែច្រើនថែមទៀត។ ជាលទ្ធផល ពួកគេក៏ជ្រើសរើសកាន់កាប់ទ្រព្យសម្បត្តិរបស់ខ្លួនគេបន្ថែមក្នុង

ទម្រង់សន្ទនីយភាព។ ពោលគឺជាកំណើនចំណូលដែលបណ្តាលមកពីការពង្រីកគោលនយោបាយសារពើពន្ធ និងបង្កើនតម្រូវការរូបិយវត្ថុ។

ឥទ្ធិពលនៃកំណើនតម្រូវការរូបិយវត្ថុ ត្រូវបានបង្ហាញនៅក្នុងក្រាហ្វិកទី១០ ខាងលើ។ ការប្រែប្រួលការផ្គត់ផ្គង់រូបិយវត្ថុ ដែលខ្សែកោងការផ្គត់ផ្គង់ជាបន្ទាត់ឈរត្រង់ គឺស្ថិតនៅដដែល។ នៅពេលកម្រិតចំណូលកាន់តែខ្ពស់ ដែលខ្សែកោងតម្រូវការរូបិយវត្ថុរំកិលទៅខាងស្តាំពី ($MD_1$) ទៅរក($MD_2$) ហើយអត្រាការប្រាក់បានកើនឡើងពី ($r_1$) ទៅរក ($r_2$) ដើម្បីរក្សាការផ្គត់ផ្គង់ និងតម្រូវការឱ្យមានតុល្យភាព។

បញ្ច្រាសមកវិញ កំណើនអត្រាការប្រាក់បានកាត់បន្ថយបរិមាណតម្រូវការលើទំនិញ និងសេវាកម្ម។ ជាពិសេសថ្លៃដើមនៃប្រាក់កម្ចីមានកម្រិតខ្ពស់ពីតម្រូវការសម្រាប់ការវិនិយោគ និងអាជីវកម្មបានធ្លាក់ចុះ។ ពោលគឺនៅពេលកំណើនក្នុងការទិញរបស់រដ្ឋាភិបាលបង្កើនតម្រូវការ សម្រាប់ទំនិញ និងសេវា វាក៏អាចរុញច្រានការវិនិយោគផងដែរ។ ឥទ្ធិពលនៃការរុញចេញនេះ មួយផ្នែកនឹងប៉ះប៉ូវដល់ការទិញរបស់រដ្ឋាភិបាលដែលមានលើតម្រូវការសរុប។

## ៦.៥- ឥទ្ធិពលនៃគោលនយោបាយសារពើពន្ធលើការនាំចេញសុទ្ធ

(Net export: effects of fiscal policy)

ឥទ្ធិពលនៃការនាំចេញសុទ្ធតាមរយៈពាណិជ្ជកម្មអន្តរជាតិអាចនឹងធ្វើឱ្យចុះខ្សោយប្រសិទ្ធភាពនៃគោលនយោបាយសារពើពន្ធផងដែរ។ ការវិភាគឥទ្ធិពលរុញចេញបានបញ្ជាក់អំពីលទ្ធភាពនៃការឡើងអត្រាការប្រាក់ស្ថិតក្រោមឥទ្ធិពលគោលនយោបាយសារពើពន្ធពង្រីក ដែលនាំឱ្យការកាត់បន្ថយការវិនិយោគឯកជន។ ដូចនេះ គោលនយោបាយសារពើពន្ធពង្រីកមានឥទ្ធិពលលើការនាំចេញសុទ្ធផងដែរ។

ការអនុវត្តន៍គោលនយោបាយសារពើពន្ធពង្រីកអាចធ្វើឱ្យអត្រាការប្រាក់ឡើងកាន់តែខ្ពស់ ដែលអាចជះឥទ្ធិពលដល់ការវិនិយោគឯកជន និងការផ្គត់ផ្គង់ត្រូវបានកាត់បន្ថយ។ ក៏ប៉ុន្តែ អត្រាការប្រាក់កើនឡើងកាន់តែខ្ពស់ គឺអាចទាក់ទាញមូលធនហិរញ្ញវត្ថុពីក្រៅប្រទេស ដោយសារកម្រិតអត្រាការប្រាក់មានការប្រែប្រួល។ ដូចនេះ តើការកើនឡើងថ្លៃប្រាក់ដុល្លារអាម៉េរិកមានឥទ្ធិពលបែបណាទៅដល់ការនាំចេញសុទ្ធរបស់សហរដ្ឋអាម៉េរិក?

ហេតុផលនៃការឡើងថ្លៃប្រាក់ដុល្លារនេះ សម្រាប់ការទិញទំនិញរបស់អាម៉េរិកគឺត្រូវការចំនួនឯកសាររូបិយវត្ថុបរទេសកាន់តែច្រើនជាងមុន។ ដូច្នេះ ទំនិញនាំចេញរបស់អាម៉េរិកគឺថ្លៃកាន់តែខ្ពស់ជាងថ្លៃទំនិញទិញពីបរទេស។ បញ្ហានេះធ្វើឱ្យការនាំចេញរបស់អាម៉េរិកត្រូវបានកាត់បន្ថយ។ ផ្ទុយមកវិញប្រជាពលរដ្ឋអាម៉េរិកអាចសម្រេចចិត្តប្តូររូបិយវត្ថុរបស់ខ្លួនជាមួយនឹងរូបិយប័ណ្ណបរទេស (Currency) ដោយទទួលបានចំនួនកាន់តែច្រើន ពោលគឺពួកគេនឹងទិញទំនិញនាំចូលកាន់តែច្រើន។ នេះជាហេតុផលធ្វើឱ្យមានការកាត់បន្ថយការនាំចេញរបស់អាម៉េរិក បែរជាបង្កើនការនាំចូលទំនិញពីបរទេសវិញ។ ហេតុការណ៍នេះនាំឱ្យការចំណាយនាំចេញសុទ្ធរបស់សហរដ្ឋអាម៉េរិកត្រូវបានកាត់បន្ថយ។ ហេតុការណ៍នេះបានធ្វើឱ្យគោលនយោបាយសារពើពន្ធពង្រីកត្រូវបានជាប់គាំង។ ដូចនេះ គោលនយោបាយសារពើពន្ធពង្រីកអាចនឹងចុះខ្សោយនូវប្រសិទ្ធភាពរបស់ខ្លួន ដើម្បីរក្សាស្ថិរភាពកំណើនសេដ្ឋកិច្ច។

*វិភាគទិដ្ឋភាពទ្រឹស្តី៖*

គោលនយោបាយសារពើពន្ធពង្រីកសំដៅលើការបង្កើនតម្រូវការសរុប ដែលនាំឱ្យខ្សែកោងតម្រូវការសរុបរំកិលពី ($AD_1$) ទៅរក ($AD_2$) គឺអាចដំឡើងអត្រាការប្រាក់ក្នុងស្រុក ជាលទ្ធផលចុងក្រោយនាំឱ្យកាត់បន្ថយការនាំចេញសុទ្ធ ដោយសារតែឥទ្ធិពលគោលនយោបាយសារពើពន្ធពង្រីកមានឥទ្ធិពលលើការនាំចេញសុទ្ធ។ ការកាត់បន្ថយនាំចេញសុទ្ធគឺជាសមាសធាតុនៃតម្រូវការសរុបមួយផ្នែកត្រូវបានទូទាត់ដោយឥទ្ធិពលនៃគោលនយោបាយសារពើពន្ធពង្រីក។ ឥទ្ធិពលនាំចេញសុទ្ធកើតឡើងដោយសារគោលនយោបាយសារពើពន្ធ ត្រូវបានផ្សារភ្ជាប់ជាមួយ៖

១-បញ្ហាពេលវេលា (Time)

២-បញ្ហានយោបាយ (Political)

៣-ឥទ្ធិពលរុញចេញ និង

៤-អតិផរណា (Inflation)

ដែលជាបុព្វហេតុធ្វើឱ្យមានភាពស្មុគស្មាញដល់ការគ្រប់គ្រងតម្រូវការសរុបផងដែរ។ យើងដឹងថាឥទ្ធិពលនាំចេញសុទ្ធនឹងកើតឡើងដោយសារតែគោលនយោបាយសារពើពន្ធគឺមានទិសដៅបញ្ចុះអត្រាការប្រាក់ក្នុងស្រុកដោយប្រើគោលនយោបាយសារពើពន្ធបង្រួម គឺដើម្បីបង្កើនការនាំចេញសុទ្ធវិញម្តង។ ដូចនេះ ឥទ្ធិពលរុញចេញបានបង្ហាញថា គោលនយោបាយសារពើពន្ធពង្រីកអាចដំឡើងអត្រាការប្រាក់ និងកាត់បន្ថយការចំណាយវិនិយោគ។ ទន្ទឹមនឹងនេះ គោលនយោបាយសារពើពន្ធ អាចត្រូវបានចុះ ខ្សោយដោយសារឥទ្ធិពលនាំចេញសុទ្ធកើតឡើងតាមរយៈ៖

១)- អត្រាការប្រាក់

២)- តម្លៃប្រាក់ដុល្លារនៅលើទីផ្សារពិភពលោក និង

៣)- ទំហំការនាំចេញ និងការនាំចូល។

សរុបរួម គោលនយោបាយសារពើពន្ធ អាចត្រូវបានចុះខ្សោយដោយសារតែឥទ្ធិពលនាំចេញសុទ្ធដូចបានពន្យល់ខាងលើនេះស្រាប់។ ទន្ទឹមនឹងនេះដែរ មានគោលនយោបាយពាណិជ្ជកម្មអន្តរជាតិមួយទៀតគឺជាគោលនយោបាយ ដែលមានទិសដៅធ្វើឱ្យមានឥទ្ធិពលដោយផ្ទាល់លើបរិមាណផលិតផលទំនិញ និងសេវា ដែលត្រូវនាំចេញ និងនាំចូល។ គោលនយោបាយពាណិជ្ជកម្មគឺមានទិសដៅបង្កើនការនាំចេញ ឬការពារឧស្សាហកម្មនៅក្នុងស្រុកពីការប្រណាំងប្រជែងពីបរទេស ដោយយោងទៅលើការនាំចូល ឬកំណត់បរិមាណទំនិញ ឬសេវា ដែលត្រូវនាំចូលដោយប្រើប្រាស់នូវប្រព័ន្ធ **កូតា**។ គោលនយោបាយនេះការពារឧស្សាហកម្មក្នុងស្រុក ហៅថា **គោលនយោបាយគាំពារនិយម**។

## សេចក្តីសន្និដ្ឋាន ( Summary )

ការតម្រែតម្រង់កំណើនផលិតផលជាក់ស្តែង ធៀបនឹងអត្រាកំណើននៃការផ្គត់ផ្គង់រូបិយវត្ថុក្នុងរយៈពេលយូរមិនបង្ហាញពីទំនាក់ទំនងគួរឱ្យកត់សម្គាល់រវាងអថេរទាំងនេះទេ ហើយទិន្នន័យដែលមានរយៈពេលវែងក៏មិនបង្ហាញពីទំនាក់ទំនងគួរឱ្យកត់សម្គាល់រវាងកំណើនទិន្នផល និងអត្រាអតិផរណាដែរ។ ទិន្នផលទាំងនេះ បង្ហាញពីឯករាជ្យភាពនៃអត្រាកំណើនរយៈពេលវែងនៃទិន្នផលពីការផ្គត់ផ្គង់រូបិយវត្ថុ និងអត្រាអតិផរណា។ ផ្ទុយនឹងលទ្ធផលខាងលើ ផ្អែកតាមលំនាំអង្គហេតុជាក់ស្តែងបង្ហាញថាសេដ្ឋកិច្ចរូបិយវត្ថុមានមូលធន និងផលិតផលក្នុងកម្មករនិយោជិតម្នាក់ច្រើនជាងសេដ្ឋកិច្ចដោះដូរវត្ថុ និងវត្ថុយ៉ាងច្រើន និងថាកាលណាអន្តរការីហិរញ្ញវត្ថុកាន់តែមានប្រសិទ្ធភាព នោះតម្លៃរបស់វាគឺកាន់តែកើនឡើង។ អង្គហេតុទាំងនេះឆ្លុះបញ្ចាំងពីវិធី ដែលយើងគួរគិតពិចារណាពីវិស័យធនាគារ និងអន្តរការីហិរញ្ញវត្ថុនៅក្នុងបរិបទនៃទ្រឹស្តីកំណើន។ នេះមិននិយាយអំពីបរិមាណរូបិយវត្ថុតែនាមនៅក្នុងវិស័យសេដ្ឋកិច្ចទេ ប៉ុន្តែនៅក្នុងក្របខ័ណ្ឌសេវាពិតដែលផ្តល់ដោយអន្តរការីហិរញ្ញវត្ថុ និងអន្តរកម្មរវាងវិស័យនេះ និងវិស័យផ្សេងទៀតរបស់ខឿនសេដ្ឋកិច្ចមួយ។

ទ្រឹស្តីកំណើនសេដ្ឋកិច្ចជាស្តង់ដារតាមបែបនេអូក្លាស៊ិក ដែលគ្របដណ្តប់លើក្រដាសប្រាក់ដាក់បញ្ចូលរូបិយវត្ថុតែនៅក្នុងក្របខ័ណ្ឌបរិមាណរូបិយវត្ថុតែនាមប៉ុណ្ណោះ ហើយមិនបង្ហាញពីផលប៉ះពាល់ជាវិជ្ជមានរបស់រូបិយវត្ថុមកលើទិន្នផលនោះទេ ដោយសារការដាក់បញ្ចូលសមតុល្យពិតនៅក្នុងនោះនឹងកាត់បន្ថយការសន្សំសម្រាប់បង្កើនមូលធនរូបវន្ត។ មានគោលការណ៍ហេតុផលពីរនៃការថយចុះនូវការសន្សំនេះ នោះគឺការកើនឡើងនូវសមតុល្យពិតនឹងបង្កើននូវប្រាក់ចំណូលសុទ្ធ និងជាយថាហេតុ ការប្រើប្រាស់ទំនិញ។ លើសពីនេះទៀត ចំណែកប្រាក់សន្សំដែលថយចុះត្រូវបានបែងចែកមួយផ្នែកសម្រាប់បង្កើនសមតុល្យពិតនេះ ដែលជាហេតុធ្វើឱ្យធ្លាក់ចុះនូវការវិនិយោគ និងកំណើនមូលធន។

ជាលក្ខខណ្ឌចាំបាច់ ដើម្បីជំរុញឱ្យមានផលប៉ះពាល់ជាក់ស្តែងរបស់រូបិយវត្ថុបន្ថែមទៀតមកលើសេដ្ឋកិច្ចគឺត្រូវទទួលស្គាល់ការពិត ដែលថាមុខងារផលិតកម្មនៅក្នុងសេដ្ឋកិច្ចរូបិយវត្ថុមានលក្ខណៈខុសគ្នាពីសេដ្ឋកិច្ចមិនមែនជារូបិយវត្ថុៈ សេដ្ឋកិច្ចរូបិយវត្ថុមានលម្បៀងផលិតផល មូលធន និងកម្លាំងពលកម្មខ្ពស់។ រូបិយវត្ថុអនុញ្ញាតឱ្យមានឯកទេសកម្ម ពាណិជ្ជកម្ម និងការពង្រីកទំហំរបស់សហគ្រាសក្នុងកម្រិតមួយ ដែលមិនអាចកើតមាននៅក្នុងប្រព័ន្ធសេដ្ឋកិច្ចដោះដូរវត្ថុ និងវត្ថុ និងនៅក្នុងសេដ្ឋកិច្ចដែលទើបតែមានប្រព័ន្ធរូបិយវត្ថុដំបូង។ លើសពីនេះទៀត ដោយមានការផ្លាស់ប្តូរបច្ចេកវិទ្យាប្រតិបត្តិការពីប្រព័ន្ធដោះដូរវត្ថុ និងវត្ថុមួយទៅមួយទៀតដោយមានការប្រើប្រាស់រូបិយវត្ថុ នោះការកាត់បន្ថយពេលវេលាប្រតិបត្តិការនាំឱ្យការផ្គត់ផ្គង់កម្លាំងពលកម្មកើនឡើង។ លើសពីនេះទៀត វិស័យហិរញ្ញវត្ថុដែលមានប្រសិទ្ធភាពអនុញ្ញាតឱ្យមានការកៀរគរ និងការបែងចែកប្រាក់សន្សំកាន់តែច្រើននៅក្នុងគម្រោងវិនិយោគនានា ដែលជាហេតុជំរុញឱ្យមានកំណើនមូលធន និងបង្កើននូវផលិតភាពរួមរបស់វា។

ទ្រឹស្តីកំណើនសេដ្ឋកិច្ច ដែលអនុវត្តចំពោះសេដ្ឋកិច្ចសម័យទំនើបត្រូវបង្វែរពីការផ្តោតលើក្រដាសប្រាក់ តែមានត្រឹមនឹងផ្តោតទៅលើវិស័យហិរញ្ញវត្ថុទាំងមូលវិញ។ វិស័យនេះមិន (រូបិយវត្ថុខាងក្រៅ) ភាគហ៊ុន ធនាគារពាណិជ្ជកម្មប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរួមបញ្ចូលទាំងជើងសារវិនិយោគ និងទីផ្សារក្រុមហ៊ុនធានារ៉ាប់រង និងទទួលវត្ថុបញ្ចាំមូលនិធិសោធន ។ល។ ផងដែរ។ ទោះបីជាអន្តរការីហិរញ្ញវត្ថុ

ប្រើធនធានសេដ្ឋកិច្ចមួយចំនួន ក្នុងការផលិតផលិតផលពាក់កណ្តាលសម្រេចក៏ដោយ ប៉ុន្តែគេអាចទទួលបានផលយ៉ាងច្រើនក្រោស់ក្រែលពីការប្រើប្រាស់ផលិតផលពាក់កណ្តាលសម្រេចនៅក្នុងដំណើរការផលិតផលសម្រេច។ ផលិតកម្ម និងការប្រើប្រាស់ប្រសើរបំផុតនូវសេវាហិរញ្ញវត្ថុនៅក្នុងវិស័យសេដ្ឋកិច្ចទាមទារឱ្យមានវិស័យហិរញ្ញវត្ថុដែលមានប្រសិទ្ធភាព។ លើសពីនេះទៀត បច្ចេកវិទ្យាបម្រើឱ្យវិស័យនេះវិវត្តទៅតាមស្ថានភាពសេដ្ឋកិច្ចជាទូទៅ ជាមួយនឹងសមាមាត្រទ្រព្យសកម្មហិរញ្ញវត្ថុពិសេសដែលសមស្របទៅនឹងការវិវត្តនៃបច្ចេកវិទ្យាបម្រើឱ្យការធ្វើពាណិជ្ជកម្ម និងផលិតកម្មទំនិញ ដែលមានការប្រែប្រួលទៅតាមបច្ចេកវិទ្យានេះ។ ដូច្នេះ បរិមាណទ្រព្យសកម្មរូបិយវត្ថុណាមួយ គឺមិនមែនជាសូចនាករល្អមួយ ដែលបង្ហាញពីទិន្នផលសម្រេចរបស់វិស័យហិរញ្ញវត្ថុទៀតទេ។

សេដ្ឋកិច្ចប្រទេសកំពុងអភិវឌ្ឍន៍ ដែលមានប្រព័ន្ធរូបិយវត្ថុកំពុងវិវត្តផ្តល់នូវការពិសោធន៍មួយសម្រាប់ពិនិត្យមើលផលប៉ះពាល់នៃហិរញ្ញប្បទានលើផលិតកម្ម ពាណិជ្ជកម្ម ការវិនិយោគ និងអាំងតង់ស៊ីតេមូលធន។ ការសិក្សាជាក់ស្តែងមួយចំនួនធំគាំទ្រដល់ការសន្និដ្ឋានដែរថា វិស័យហិរញ្ញវត្ថុកំពុងវិវត្តដែលមានប្រសិទ្ធភាពបានរួមចំណែកយ៉ាងច្រើនដល់កំណើន និងការអភិវឌ្ឍសេដ្ឋកិច្ច។

ប៉ុន្តែផ្ទុយមកវិញ វិស័យផ្សេងៗទៀតផ្តល់នូវធាតុចូលមួយចំនួនសម្រាប់វិស័យហិរញ្ញវត្ថុក្នុងទម្រង់ជាប្រភេទសម្ភារមូលធន ចំណេះដឹង និងបច្ចេកវិទ្យាព័ត៌មាន ការអប់រំ និងជំនាញរបស់និយោជិត ។ល។ ប្រសិទ្ធភាពនៃវិស័យហិរញ្ញវត្ថុក៏ដូចជាវិស័យដទៃទៀតក៏ចំណុះឱ្យបទប្បញ្ញត្តិការផ្លាស់ប្តូរបច្ចេកវិទ្យា និងទិដ្ឋភាពផ្សេងទៀតនៃបរិយាកាសសេដ្ឋកិច្ច។

ហិរញ្ញប្បទាន គឺជាវិស័យដ៏ធំមួយដែលមានសេវាចាំបាច់សម្រាប់ប្រើប្រាស់ដោយគ្រប់វិស័យសេដ្ឋកិច្ចទាំងអស់។ ម្យ៉ាងវិញទៀត វាប្រើនូវធាតុចូល និងចំណេះដឹងដែលមានប្រភពមកពីវិស័យផ្សេងទៀត។ ដូច្នេះ មានទំនាក់ទំនងជានិម្មិតរូបរវាងវិស័យហិរញ្ញវត្ថុ ដែលមានប្រសិទ្ធភាព និងមានលក្ខណៈប្រកួតប្រជែងក៏ដូចជាវិស័យសេដ្ឋកិច្ចដទៃទៀត។ ប្រការនេះធ្វើឱ្យមានការពិបាកក្នុងការផ្តល់ហេតុផលសម្រាប់ការចោទជាសំណួរថា តើប្រសិទ្ធភាពនៃវិស័យហិរញ្ញវត្ថុកើតឡើងពីវិស័យសេដ្ឋកិច្ចផ្សេងទៀតដែរឬយ៉ាងណា ឬថាតើវិស័យហិរញ្ញវត្ថុដែលមានប្រសិទ្ធភាពខ្លាំងអាចរួមចំណែកដល់ប្រសិទ្ធភាពនៃវិស័យបន្ទាប់បន្សំដែរឬយ៉ាងណា?

យោងតាមការសិក្សាជាក់ស្តែងក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ បានចាប់ផ្តើមញែកពីទំនាក់ទំនងរវាងអត្រាកំណើនផលិតផល និងការផ្គត់ផ្គង់រូបិយវត្ថុ (ឬអតិផរណា) និងរវាងកំណើនផលិតផលក៏ដូចជាប្រសិទ្ធភាព និងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ។ នៅក្នុងសំណុំអថេរដំបូង លទ្ធផលនៃការសិក្សាជាធម្មតាមិនមានភស្តុតាងបញ្ជាក់ពីទំនាក់ទំនង ឬថាទំនាក់ទំនងមិនរឹងមាំ ឬអវិជ្ជមានបន្តិច។ នៅក្នុងសំណុំអថេរចុងក្រោយ លទ្ធផលជាធម្មតាបង្ហាញពីទំនាក់ទំនងវិជ្ជមានគួរឱ្យកត់សម្គាល់ដោយមានគោលការណ៍ហេតុផលទ្វេទិសរវាងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងសេដ្ឋកិច្ច។ ដូច្នេះ សម្រាប់ការសន្និដ្ឋានលើលទ្ធផលរកឃើញជាក់ស្តែងទាំងនេះ ចំពោះគោលនយោបាយរូបិយវត្ថុគឺគួរគាំទ្រដល់ដល់ការបង្កើនប្រសិទ្ធភាព ភាពចម្រុះ និងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុឯកជនកាន់តែខ្លាំងឡើង។

ដូចនេះ គោលបំណងគោលនយោបាយរូបិយវត្ថុ ដើម្បីការអភិវឌ្ឍន៍សេដ្ឋកិច្ច រក្សាស្ថិរភាពថ្លៃយុត្តិធម៌សង្គម និងរក្សាស្ថិរភាពកំណើនសេដ្ឋកិច្ចជាដើម។ គោលនយោបាយនេះ អាចសម្រេចទៅ

បានលុះត្រាតែយន្តការនៃគោលនយោបាយរូបិយវត្ថុរក្សាបាននូវស្ថិរភាពថ្លៃ និងអត្រាអតិផរណាត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។

ភាពជោគជ័យនៃគោលនយោបាយរូបិយវត្ថុ អាស្រ័យលើការចាត់វិធានការទាន់ពេលវេលា និងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពរបស់រដ្ឋាភិបាល ជាពិសេសការអនុវត្តន៍នូវគោលនយោបាយនេះដោយធនាគារកណ្ដាល។ ដូច្នេះ គោលនយោបាយរូបិយវត្ថុ រួមបញ្ចូលនូវសេចក្ដីសម្រេចពីរផ្សេងគ្នាគឺពាក់ព័ន្ធការការផ្គត់ផ្គង់រូបិយវត្ថុ និងតម្រូវការរូបិយវត្ថុ របស់ភ្នាក់ងារសេដ្ឋកិច្ចទាំងមូល។ ជាកត្តាសំខាន់គឺដើម្បីរក្សាការងារធ្វើពេញលេញដល់សង្គម ដើម្បីរក្សាមិនឱ្យមានកម្លាំងចលករនៅក្នុងសេដ្ឋកិច្ច។ ទន្ទឹមនឹងនេះដែរ យន្តការនៃគោលនយោបាយរូបិយវត្ថុមិនគ្រប់គ្រាន់ ដើម្បីរក្សាកំណើនសេដ្ឋកិច្ចរយៈពេលវែងនោះទេ ប៉ុន្តែចាំបាច់ត្រូវមានគោលនយោបាយសារពើពន្ធជាយន្តការបញ្ច្រាសពីគោលនយោបាយរូបិយវត្ថុ ដើម្បីកែខៃកម្រិតអតិផរណាឡើងខ្ពស់ និងកម្រិតអត្រាការប្រាក់។ ជាមួយនឹងយន្តការផ្សេងៗទៀត គោលនយោបាយរូបិយវត្ថុក៏មានឥទ្ធិពលលើស្ថិរភាពសេដ្ឋកិច្ចរយៈពេលវែងផងដែរ។

រដ្ឋាភិបាលប្រើគោលនយោបាយរូបិយវត្ថុ ដើម្បីមានឥទ្ធិពលលើតម្រូវការសរុបក្នុងសេដ្ឋកិច្ចក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីសម្រេចឱ្យបាននូវស្ថិរភាពថ្លៃ ភាពមានការងារពេញលេញ និងកំណើនសេដ្ឋកិច្ច។ *តាមទស្សនៈសេដ្ឋវិទូលោក កេនស៍ បានណែនាំថាកំណើនការចំណាយរបស់រដ្ឋាភិបាល និងតំហយអត្រាពន្ធ គឺជាវិធីល្អបំផុតសម្រាប់ជំរុញតម្រូវការសរុប។* សេចក្ដីណែនាំនេះ អាចអនុវត្តបានក្នុងពេលមានវិបត្តិសេដ្ឋកិច្ច ឬសកម្មភាពសេដ្ឋកិច្ចរីកចម្រើនតិចតួច គោលនយោបាយសារពើពន្ធជាយន្តការដ៏សំខាន់មួយសម្រាប់បង្កើតរចនាសម្ព័ន្ធសម្រាប់កំណើនសេដ្ឋកិច្ចដ៏ខ្លាំងក្លា និងផ្ដល់ភាពមានការងារពេញលេញ។ រដ្ឋាភិបាលអាចនឹងប្រើភាពលើសកញ្ចប់ថវិកា ដើម្បីកាត់បន្ថយល្បឿននៃកំណើនសេដ្ឋកិច្ចខ្លាំងក្លា និងធ្វើឱ្យមានស្ថិរភាពថ្លៃ ពេលមានអតិផរណាឡើងខ្ពស់។ *តាមទ្រឹស្ដីរបស់លោក កេនស៍ បានបែងបន្ថែមថា ការកាត់បន្ថយចំណាយក្នុងសេដ្ឋកិច្ចមួយ នឹងនាំដល់ការថយចុះកម្រិតនៃតម្រូវការសរុប និងធ្វើឱ្យមានស្ថិរភាពថ្លៃ។*

ទន្ទឹមនឹងនោះ មានសេដ្ឋវិទូជាច្រើនបានធ្វើការជជែកវែកញែកអំពីប្រសិទ្ធភាពនៃកម្លាំងជំរុញសារពើពន្ធ។ នៅពេលដែលរដ្ឋាភិបាលជួបនឹងឱនភាពថវិកា ផលទុនជាតិប្រមូលបានតាមរយៈកម្ចីសាធារណៈ ឬកម្ចីពីបរទេស។ (ការបង្កើតមូលប័ត្ររបស់រដ្ឋាភិបាល) រដ្ឋាភិបាលទប់ទល់នឹងឱនភាពតាមរយៈការបង្កើតនូវមូលប័ត្ររដ្ឋាភិបាល អត្រាការប្រាក់ អាចត្រូវបង្កើនឡើងនៅតាមទីផ្សារ ពីព្រោះកម្ចីរបស់រដ្ឋាភិបាលបង្កើតតម្រូវការខ្ពស់ជាងសម្រាប់ឥណទានក្នុងទីផ្សារហិរញ្ញវត្ថុ។ បណ្ដាលឱ្យតម្រូវការទំនិញ និងសេវាសរុបថយចុះ ដែលផ្ទុយទៅនឹងកម្លាំងជំរុញសារពើពន្ធ។

# បណ្ណាល័យសាស្ត្រ


Ando, Albert, H. Eguchi, R. Farmer, and Y. Suzuki, eds. Monetary Policy in Our Times. Cambridge: MIT Press, 1985.

Bank of Canada. [Online.] available: www.bankofcanada.ca [Accessed: various dates].

Bank of England. [Online.] Available: www.bankofengland.co.uk [Accessed: various dates]

Bernstein, Michael. The Great Depression: Delayed Recovery and Economic Change in America, 1929-1939. New York: Cambridge University Press, 1987.

Best, Gary Dean. Pride, Prejudice, and Politics: Roosevelt Versus Recovery, 1933-1938. New York: Praeger, 1991.

Blake, D, 2000. Financial market analysis. Chichester: John Wiley & Sons Limited.

Bordo, Michael D. "Financial Crises, Banking Crises, Stock Market Crashes, and the Money Supply: Some International Evidence, 1870-1933." In Forrest Capie and Geoffrey E. Wood, eds., Financial Crises and the World Banking System. London: Macmillan, 1986.

Bordo, Michael D. "The Classical Gold Standard—Some Lessons for Today." Federal Reserve Bank of St. Louis Review 63, no. 5 (1981): 2-17.

Bordo, Michael D., and A. J. Schwartz, eds. "Transmission of Real and Monetary Disturbances Under Fixed and Floating Rates." Cato Journal 8, no. 2 (1988): 451-472.

Bordo, Michael D., and A. J. Schwartz, eds. A Retrospective on the Classical Gold Standard, 1821-1931. Chicago: University of Chicago Press, 1984. Especially "The Gold Standard and the Bank of England in the Crisis of 1847," by R. Dornbusch and J. Frenkel.

Bordo, Michael D., Claudia Goldin, and Eugene N. White, eds. The Defining Moment: The Great Depression and the American Economy in the Twentieth Century. Chicago: University of Chicago Press, 1998.

Brown, E. Cary. "Fiscal Policy in the Thirties: A Reappraisal." American Economic Review 46 (December 1956): 857-879.

Brunner, Karl, and Allan H. Meltzer. "An Aggregate Theory for a Closed Economy." In Jerome L. Stein, ed., Monetarism. New York: American Elsevier, 1976.

Brunner, Karl, ed. The Great Depression Revisited. Boston: Martinus Nijhoff, 1981.

Cole, Harold L., and Lee E. Ohanian. "New Deal Policies and the Persistence of the Great Depression: A General Equilibrium Analysis." Journal of Political Economy 112 (August 2004): 779-816.

Davies, G, 2002. History of money. Cardiff: University of Wales Press.

De Kock, MH, 1946. Central banking. London: Staples Press.

Eichengreen, Barry. Golden Fetters: The Gold Standard and the Great Depression, 1919-1939. New York: Oxford University Press, 1992.
European Central Bank. [Online.] Available: www.ecd.int. [Accessed: various dates].

Faura, AP, 1977. A money market analysis, South African Reserve Bank Quarterly Bulletin. September. Pretoria: South African Reserve Bank.

Faure, AP, 1995. Understanding the money market shortage. Paper written for clients of Alexander Securities (Pty) Limited. March. Stellenbosch: Alexander Securities (Pty) Limited.

Faure, AP, 2005. The financial system. Cape Town: Quoin Institute (Pty) Limited.

Faure, AP, 2008. Monetary policy: bank liquidity management. Cape Town: Quoin Institute.

Faure, AP, 2008. Monetary policy: money, its statistical causes and its real drivers. Cape Town: Quoin Institute.

Faure, AP, 2008. Monetary policy: transmission. Cape Town: Quoin Institute.
Federal Reserve Board. [Online.] Available: www.federalreserve.gov/fomc/ [Accessed: various dates].

Feldstein, Martin. “The Economics of the New Unemployment.” Public Interest 33 (Fall 1973): 3–42.

Feldstein, Martin. “Why Is Productivity Growing Faster?” NBER Working Paper no. 9530. National Bureau of Economic Research, Cambridge, Mass., 2003.

Field, Alexander J. “Uncontrolled Land Development and the Duration of the Depression in the United States.” Journal of Economic History 52 (June 1992): 785-805.

Fisher, Irving. The Theory of Interest. 1930. Reprint. Brookfield, Vt.: Pickering and Chatto, 1997. Available online at: http://www.econlib.org/library/YPDBooks/Fisher/fshToI.html

Ford, A. The Gold Standard, 1880-1914: Britain and Argentina. Oxford: Clarendon Press, 1962.

Friedman, M., and A. J. Schwartz. A Monetary History of the United States, 1867–1960. Princeton: Princeton University Press and National Bureau of Economic Research, 1963.

Friedman, Milton, and Anna Jacobson Schwartz. A Monetary History of the United States, 1867-1960. Princeton: Princeton University Press, 1963.

Friedman, Milton. “The Role of Monetary Policy.” Presidential address at the Eightieth Annual Meeting of the American Economic Association, December 1967. American Economic Review 58, no. 1 (March 1968): 1–17.

Friedman, Milton. A Program for Monetary Stability. New York: Fordham University Press, 1959.

Further Reading

Glasner, David. Free Banking and Monetary Reform. New York: Cambridge University Press, 1989.

Goodhart, C. A. E. The Evolution of Central Banks. Cambridge: MIT Press, 1988.

Gowland, D, 1991. Money, inflation and unemployment. Herefordshire: Harvester Whealsheaf.

Greider, William. Secrets of the Temple: How the Federal Reserve Runs the Country. New York: Simon and Schuster, 1987.

Hall, Robert. “Employment Fluctuations and Wage Rigidity.” Brookings Papers on Economic Activity 1 (1980): 91–141.

Hall, Thomas, and J. David Ferguson. The Great Depression: An International Disaster of Perverse Economic Policies. Ann Arbor: University of Michigan Press, 1998.

Hansen, Alvin. Full Recovery or Stagnation? New York: Norton, 1938.

Harrod, RD,1969. Money. London: Macmillan and Company Limited.

Higgs, Robert. “Regime Uncertainty: Why the Great Depression Lasted So Long and Why Prosperity Returned After the War.” Independent Review 1 (Spring 1997): 561-590.

Higgs, Robert. “Wartime Prosperity? A Reassessment of the U.S. Economy in the 1940s.” Journal of Economic History 52 (March 1992): 41-60.

Higgs, Robert. Crisis and Leviathan: Critical Episodes in the Growth of American Government. New York: Oxford University Press, 1987.

Howells, P. and Bain, K., 2002. The economics of money, banking and finance. Harlow, Essex: Reason Education Limited.

Humphrey, T. “The Choice of a Monetary Policy Framework: Lessons from the 1920s.” Cato Journal 21, no. 2 (2001): 285–313.

Jevons, WS, 1875. Money and the mechanism of exchange. London: Kegan Paul, Trench & Co.

McCallum, Bennett T. Monetary Economics: Theory and Policy. New York: Macmillan, 1989.

Meijer, JH, 1992. Instrument of monetary policy. In Falkena, HB et al. (eds). Fundamentals of the South African financial system. Halfway house: Southern Book Publishers (Pty) Limited.

Meulendyke, Ann-Marie. U.S. Monetary Policy and Financial Markets. 1989. New York: Federal Reserve Bank of New York, 1998.

Mishin, FS, 2004. The economics of money, banking, and financial markets. Boston: pearson Addison-Wesley.

Morgan, EV, 1965. A history of money. Middlesex, England: Penguin Books.

Newlyn, WT, 1971. Theory of money. London: Oxford University Press.

O'Brien, Anthony Patrick. "A Behavioral Explanation for Nominal Wage Rigidity During the Great Depression." Quarterly Journal of Economics 104 (November 1989): 719-735.

Officer, L. "The Efficiency of the Dollar-Sterling Gold Standard, 1890-1908." Journal of Political Economy 94 (1986): 1038-1073.

Patinkin, Don. "Interest." In International Encyclopedia of the Social Sciences. Vol. 7. New York: Macmillan, 1968.

Peppers, Larry. "Full-Employment Surplus Analysis and Structural Change: The 1930s."
, PJ, 1985. Monetary economics. London: Butterworth.

Pilbeam, K, 1998. Finance and financial market. London: Macmillan Press Limited.
Explorations in Economic History 10 (Winter 1973): 197-210.

Pierce, DG and Tysome Renaghan, Thomas. "A New Look at Fiscal Policy in the 1930s." Research in Economic History 11 (1988): 171-183.

Reprinted as The Rationale of Central Banking and the Free Banking Alternative. Indianapolis: Liberty Fund, 1990. Available online at: http://www.econlib.org/library/LFBooks/SmithV/smvRCB.html

Rose, PR, 2000. Money and capital markets. Boston: Irwin McGraw-Hill.

Saint-Etienne, Christian. The Great Depression, 1929-1938: Lessons for the 1980s. Stanford: Hoover Institution Press, 1984.

Samuelson, Paul A. "Money, Interest Rates and Economic Activity: Their Interrelationship in a Market Economy." In Robert C. Merton, ed., The Collected Scientific Papers of Paul A. Samuelson. Vol. 3. Cambridge: MIT Press, 1972. Originally published in American Bankers Association, Proceedings of a Symposium on Money, Interest Rates, and Economic Activity. New York, 1967.

Smal, MM and De Jager, S, 2001. The monetary transmission mechanism in South Africa. Occasional Paper No. 16, September. Pretoria: South African Reserve Bank.

Smiley, Gene. Rethinking the Great Depression: A New View of Its Causes and Consequences. Chicago: Ivan R. Dee, 2002.

Smith, V. C. The Rationale of Central Banking. Westminster: P. S. King and Son, 1936.

South Africa Reserve Bank, 2010. Quarterly Bulletin. Various.

South African Reserve Bank, 2004c. A consultative paper on: modifications to the money market operations of the South African Reserve Bank. Financial Markets Development. December. Pretoria: South African Reserve Bank.

South African Reserve Bank. [Online.] Available: www.reservebank.co.za. [Accessed: various dates].

Statues of the Republic of south Africa, 1989. South African Reserve Bank Act 90 of 1989. Pretoria: Government Printer.

Statues of The Republic South Africa, 1989. Constitution of the Republic of South Africa Third Amendment Act 26 of 1996. Pretoria: Government Printer.

Stein, ed., Monetarism. New York: American Elsevier, 1976.

Summers, Lawrence H. “Why Is the Unemployment Rate So Very High Near Full Employment?” Brookings Papers on Economic Activity 2 (1986): 339–383.

Summers, Lawrence H. Understanding Unemployment. Cambridge: MIT Press, 1990.

Summers, Lawrence H., and Kim B. Clark. “Labor Market Dynamics and Unemployment: A Reconsideration.” Brookings Papers on Economic Activity 1 (1979): 13–60.

Symposium: “Monetarism: Lessons from the Post-1979 Experiment.” American Economic Review Papers and Proceedings 74 (May 1984): 382–400.

Taylor, John B., ed. Monetary Policy Rules. Chicago: University of Chicago Press, 1999.

Temin, Peter, and Barrie Wigmore. “The End of One Big Deflation.” Explorations in Economic History 27 (October 1990): 483-502.

Temin, Peter. “Socialism and Wages in the Recovery from the Great Depression in the United States and Germany.” Journal of Economic History 50 (June 1990): 297-308.

Temin, Peter. Did Monetary Forces Cause the Great Depression? New York: Norton, 1976.

Temin, Peter. Lessons from the Great Depression. Cambridge: MIT Press, 1989.

Timberlake, R. H. Monetary Policy in the United States: An Intellectual and Institutional History. Chicago: University of Chicago Press, 1993.

Van der Merwe, EJ, 2004. Inflation targeting in South Africa. Occasional Paper No. 18, July. Pretoria: South African Reserve Bank.

Van Staden, B 1996. A new monetary analysis for South Africa. Pretoria: South African Reserve bank Quarterly Bulletin, Bulletin, March.

Van Staden, B, 1963. A monetary analysis for South A new analysis for South Africa.

Vedder, Richard K., and Lowell P. Gallaway. Out of Work: Unemployment and Government in Twentieth-Century America. New York: Holmes and Meier, 1993.

Walsh, Carl E. Monetary Theory and Policy. Cambridge: MIT Press, 1998.

Walton, Gary M., ed. Regulatory Change in an Atmosphere of Crisis: Current Implications of the Roosevelt Years. New York: Academic Press, 1979.

Warburton, Clark. Depression, Inflation, and Monetary Policy: Selected Papers, 1945–1953. Baltimore: Johns Hopkins University Press, 1966.

Weinstein, Michael. Recovery and Redistribution Under the NIRA. Amsterdam: North-Holland, 1980.

Wright, Gavin. “The Political Economy of New Deal Spending: An Econometric Analysis.” Review of Economics and Statistics 56 (February 1974): 30-38.